# នីតិអន្តរជាតិសាធារណៈ

ដោយ

**បណ្ឌិត មាស បូរ៉ា**

រក្សាសិទ្ធិ

ឆ្នាំ ២០១៣

សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា

បោះពុម្ពលើកទី ១ ចំនួន ១000ច្បាប់
នៅព្រះរាជាណាចក្រកម្ពុជា។ មិនមានផ្នែកណាមួយ
នៃសៀវភៅនេះ ត្រូវបានផលិត ឬ ថតចម្លងឡើងវិញ
តាមមធ្យោបាយណាក៏ដោយ ដោយ
គ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធឡើយ។

# អារម្ភកថា

គោលបំណងរបស់ខ្ញុំបាទក្នុងការសរសេរសៀវភៅ ដើម្បីបោះពុម្ពផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងនេះ មានជាយូរមកហើយ តាំងពីមុនពេលបន្តការសិក្សាក្រោយឧត្តមសិក្សានៅក្នុងប្រទេសជប៉ុន។ គោលបំណងនេះ កាន់តែមានសន្ទុះ នៅពេលដែលខ្ញុំបានចូលសិក្សាស្រាវជ្រាវច្បាប់ នៅសាកលវិទ្យាល័យច្បាប់ នៅទីក្រុងណាហ្គូយ៉ា (Nagoya) ដែលមានបណ្ណាល័យសម្បូរបែបនូវសៀវភៅ និង ទស្សនាវដ្ដីសិក្សាស្រាវជ្រាវ។ បន្ថែមពីលើនេះ មានឯកសារសៀវភៅសិក្សាជាច្រើន ជាភាសាជប៉ុន។ ក្នុងអំឡុងពេលសិក្សានៅទីនោះ ខ្ញុំបាទខិតខំសរសេរសៀវភៅ ស្ដីពី ច្បាប់អន្តរជាតិសាធារណៈទូទៅជាអក្សរដោយដៃ រួចផ្ញើឲ្យបងប្អូន ជួយវាយជាអត្ថបទកុំព្យូទ័រជាភាសាខ្មែរ។ ទោះបីជាយ៉ាងនេះក្ដី ខ្ញុំមានការបញ្ហាលំបាកក្នុងការកែតម្រូវឡើងវិញ និងបញ្ចូលព័ត៌មានមានបច្ចុប្បន្នភាពពាក់ព័ន្ធច្បាប់អន្តរជាតិ។

ឆន្ទៈនាំឲ្យមានការសរសេរបានកើតមានជាថ្មី នៅពេលខ្ញុំបាទ បានសិក្សាច្បាប់អន្តរជាតិសាធារណៈនៅឯ Hague Academy of International Law ក្នុងប្រទេសហូឡង់ដ៍ ក្រោមអាហារូបករណ៍របស់អង្គការសហប្រជាជាតិ ( the International Law Felloship Programme)។ ការចាប់ផ្ដើមការសរសេរជាដុំកំភួន មានចាប់ពីពេលនោះមក ហើយបន្តិចម្ដងៗទៅតាមពេលវេលាទំនេរដែលមានក្រៅពីការងារចម្បងសម្រាប់ក្រុពះ។

ការសរសេរសៀវភៅមួយមិនមែនជាការងាយស្រួលឡើយ ជាពិសេសជាភាសាជាតិ ដែលពាក្យពេជន៍ខ្លះ មិនទាន់ឆ្លើយតបទៅនឹងន័យនៃពាក្យច្បាប់

អន្តរជាតិជាភាសាអង់គ្លេសនៅឡើយ។ នេះទាមទារឲ្យមានការសិក្សាស្រាវជ្រាវទូលំទូលាយ តស៊ូ ព្យាយាម និង មុតមាំ។ វាទាមទារផងដែរឲ្យអ្នកសរសេរ ដឹងអំពីវិធីសាស្ត្រសរសេរ ដើម្បីផ្តល់ព័ត៌មានលេចធ្លោជារួម និង ស៊ីជម្រៅ។

ដោយសារ ខ្ញុំបាទមាននិស្ស័យជាអ្នកសរសេរ និង ស្រាវជ្រាវ ព្រមទាំងមានមូលដ្ឋានច្បាប់ តាំងពីកម្រិតបរិញ្ញាបត្រ រហូតបញ្ចប់ថ្នាក់បណ្ឌិតច្បាប់ ម្យ៉ាងទៀត ការសរសេរស្នាដៃមួយជាភាសាខ្មែរ ពាក់ព័ន្ធជាមួយជំនាញ ដែលសាធារណជនមិនសូវដឹងឮ ជាកិច្ចការងារមួយដ៏មានសារៈសំខាន់ ជូនជនរួមជាតិ និង ដោយសារសៀវភៅជាស្នាដៃមួយមិនរលត់ ផ្តល់ប្រយោជន៍ដល់អ្នកជំនាន់ក្រោយ ដែលទុកជាការសងគុណចំពោះភពផែនដី ផ្តល់កំណើតដល់ខ្ញុំបាទ ខ្ញុំបាទបានជម្នះឈ្នះចោរលួចពេលវេលា ដែលមានសំបូរបែបទាក់ទាញយ៉ាងខ្លាំង ឲ្យមនុស្សលោកចំណាយពេលវេលាសប្បាយរហូតជ្រុលឥតប្រយោជន៍ និងឈ្នះកត្តាបន្ទុចបង្អាក់ ដូចជាការលួចថតចម្លងជាដើម ដើម្បីសរសេរសៀវភៅនេះឡើង។

អត្ថបទនេះ ត្រូវបានរៀបចំឡើង ក្នុងលក្ខណៈមួយសាមញ្ញ បង្កឲ្យមានលំហូរដ៏រលូននៃព័ត៌មាន។ អត្ថបទចាប់ផ្តើម ជាមួយការរៀបរាប់ អំពីប្រវត្តិកំណើតនៃច្បាប់អន្តរជាតិ ប្រភេទ ប្រភព និងចរិតលក្ខណៈនៃច្បាប់អន្តរជាតិ។ អត្ថបទក៏បានដាក់បញ្ចូលផងដែរនូវ ប្រធានបទថ្មីៗនៃច្បាប់អន្តរជាតិ និងការអភិវឌ្ឍនៅក្នុងតំបន់ ដូចជា បញ្ហាច្បាប់លំហអាកាស ការបង្កើតយន្តការសិទ្ធិមនុស្សនៅក្នុងតំបន់។

ប្រិយមិត្ត អ្នកសិក្សាស្រាវជ្រាវ ជាទីរាប់អាន! វាជាកត្តាសត្យានុម័ត ដែលមនុស្សតែងតែមានកំហុសខុសឆ្គង។ អត្ថបទនេះ ពិតជាមានកំហុសអចេតនាជៀសមិនរួច។ ខ្ញុំបាទ សូមទទួលយកនូវការរិះគន់ទាំងអស់ ប្រសិនបើមានដើម្បីស្ថាបនា ធ្វើឲ្យស្នាដៃនាពេលខាងមុនកាន់តែមានខ្លឹមសារល្អប្រសើរ។

ទីក្រុងភ្នំពេញថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៣

**បណ្ឌិត មាស បូរ៉ា**

## សេចក្តីថ្លែងអំណរគុណ និងឧទ្ទិសស្នាដៃ

ដូចដែលខ្ញុំបាទបានជម្រាបក្នុងអារម្ភកថារួចមកហើយ ការសរសេរអត្ថបទ មិនមែនជាកិច្ចការងារងាយស្រួលទេ។ វាទាមទារពេលវេលា និងការគាំទ្រពី សំណាក់មនុស្សមួយចំនួន។ ស្នាដៃនេះនឹងមិនមានជារូបរាងឡើយ ប្រសិន បើមិនមានការផ្តល់កំណើត ឱកាស ការជំរុញ ការយោគយល់ និងឧបត្ថម្ភពី សំណាក់ អ្នកមានគុណ ឯកឧត្តម លោក លោកស្រី ដែលមានរាយ នាមខាងក្រោម និងដែលខ្ញុំមិនបានរាយនាមឈ្មោះក្នុងអត្ថបទនេះ។

១. លោកឪពុក **ឈ្មោះ ចាន់ សុខ** និងអ្នកម្តាយ **ឈ្មោះ ហ៊ី ឡេង** ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ អប់រំ បីបាច់ ថែរក្សា ប្រកបដោយ ព្រហ្មវិហារធម៌ រហូតខ្ញុំបាទ បានរៀនសូត្ររហូតបញ្ចប់ថ្នាក់បណ្ឌិតច្បាប់។

២. ភរិយារបស់ខ្ញុំឈ្មោះ **ស្តើង សុខេង** ដែលបានចំណាយពេលវេលា រ៉ាប់រងធ្វើកិច្ចការងារជាច្រើន ដោយគ្មាននឿយហត់ និងត្អូញត្អែរ ទុកពេល ឲ្យខ្ញុំធ្វើការងារ និងស្រាវជ្រាវ។ កូនប្រុសឈ្មោះ **សុខ សមដូចប្រាថ្នា** និង កូនស្រីឈ្មោះ **សុខ សមលក្ខិណា** ដ៏ល្អ របស់ខ្ញុំបាទ ដែលផ្តល់ក្តីសង្ឃឹម និងជំរុញ ឲ្យខ្ញុំបាទខិតខំដើម្បីអនាគតដ៏វែងឆ្ងាយរបស់ពួកគេ។

៣. សាស្ត្រាចារ្យច្បាប់ **OBATA Kaoru** សាស្ត្រាចារ្យដឹកនាំ ការស្រាវជ្រាវរបស់ខ្ញុំបាទក្នុងអំឡុងពេលសិក្សាស្រាវជ្រាវ ៦ឆ្នាំ នៅ Nagoya Univeristy Graduate School of Law, Japan។

៤. ឯកឧត្តម **លី ធុជ** ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិអេស្កាប់ ឯកឧត្តម **យូ ប៊ុនឡេង** ប្រធានសាលាឧទ្ធរណ៍ និង ជាសហចៅក្រមស៊ើបអង្កេតជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ

កម្ពុជា ឯកឧត្តម **ស្តើង សុខុម** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ និងជាសាកលវិទ្យាធិការសាកលវិទ្យាល័យឯកទេស នៃកម្ពុជា និង ឯកឧត្តម **គីម វឌ្ឍនា** អគ្គលេខាធិការគណៈកម្មាធិការជាតិអេស្កាប់ និងឯកឧត្តម **នួន ផារ័ត្ន** ក្រុមប្រឹក្សាអ្នកច្បាប់ ដែលបានផ្តល់តម្លៃដល់អ្នកស្រាវជ្រាវ អនុញ្ញាតដល់ខ្ញុំបាទ អវត្តមានពីការងារដើម្បី ទៅសិក្សាក្នុងរយៈពេលខ្លី នៅក្រៅ និងក្នុងប្រទេស។

៥. បណ្ឌិត **ប៊ុន រ៉ូ** បណ្ឌិត **លាប ប៉ូឡូ** បណ្ឌិត **ឱម សុទ្ធី** និងបណ្ឌិត **សឿ យាន** និងសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា ដែលបានចូលរួមឧបត្ថម្ភជាថវិកា សម្រាប់ការបោះពុម្ពអត្ថបទនេះ។

៦. បេក្ខបណ្ឌិត **សុទ្ធ សាងបុណ្យ** បណ្ឌិត **សំរិទ្ធ មាំមួន** បណ្ឌិត **លឹម ស៊ុយហុង** ឯកឧត្តម **ស៊ា ម៉ៅ** លោកបណ្ឌិត **ភិន សុវត្ថិ** លោកអនុបណ្ឌិត **នាក់ សេរីគីរីន** លោកអនុបណ្ឌិត **កុន វិទ្យា** ដែលបានជួយពិនិត្យ និងកែសម្រួលផ្នែកខ្លះនៃអត្ថបទ។

៧. ឯកឧត្តមបណ្ឌិត **ហោ ប៉េង** ដែលបានផ្តល់នូវចំណាប់អារម្មណ៍។

៨. អនុបណ្ឌិត **ថៅ សំ** និងលោក **ណុល ដារ៉ា** ដែលបានជួយកែអក្ខរាវិរុទ្ធ។ ក្មួយប្រុសឈ្មោះ **សុខ ស៊ីណា** ដែលបានជួយកែសម្រួលលេខទំព័រ។

៩. បងប្អូនប្រុសស្រី មិត្តភក្តិទាំងអស់ ដែលបានចូលរួមចំណែកតាមរយៈការលើកទឹកចិត្ត ដើម្បីឲ្យស្នាដៃនេះ លេចជារូបរាងឡើង។

១០.សាកលវិទ្យាល័យ ណាហ្គូយ៉ា និង the UN International Law Fellowship Programme ដែលជាទីកន្លែង និងផ្តល់ឱកាសឲ្យខ្ញុំបាទបានសិក្សាច្បាប់អន្តរជាតិ។

សូមឧទ្ទិសស្នាដៃនេះ ដល់បុព្វការីជន និងញាតិសន្តាន ដែលបានបាត់បង់ជីវិត ដើម្បីបុព្វហេតុជាតិ និងសូមឲ្យស្នាដៃនេះ មានប្រយោជន៍សម្រាប់ការអភិវឌ្ឍជូនជនរួមជាតិ និងប្រទេសជាតិ។

# មាតិកា


អារម្ភកថា ............ II

សេចក្តីថ្លែងអំណរគុណ និងឧទ្ទិសស្នាដៃ ............ V

អក្សរកាត់ ............ XXII

## ជំពូក ១

## សេចក្តីផ្តើម

១.១. មូលហេតុ និង កំណកំណើតច្បាប់អន្តរជាតិសាធារណៈ ............ ០១

ការវិវត្តនយោបាយតាមគោលគំនិតទស្សនវិជ្ជានាំឲ្យមានការបង្កើតរដ្ឋសម័យទំនើប(សតវត្សរ៍១៥និង១៦) ............ ០២

សង្គ្រាម ............ ០៥

១.២. ច្បាប់អន្តរជាតិសាធារណៈនាពេលបច្ចុប្បន្ន ............ ០៧

១.៣. និយមន័យនៃច្បាប់អន្តរជាតិសាធារណៈ ............ ០៨

១.៤. ច្បាប់អន្តរជាតិសាធារណៈ និងច្បាប់អន្តរជាតិឯកជន ............ ១០

១.៥. ការចងក្រង និងការអភិវឌ្ឍច្បាប់អន្តរជាតិ ............ ១១

## ជំពូក ២

## ប្រធាននៃច្បាប់អន្តរជាតិ

២.១. រដ្ឋ ............ ១៣

២.១.១. ធាតុផ្សំនៃរដ្ឋ ............ ១៣

២.១.១.១. ប្រជាជន ............ ១៣

២.១.១.២. ដែនដី ............................................................ ១៥
២.១.១.២.១. គោលការណ៍ *Uti Possidetis* ...................... ១៦
២.១.១.៣. រដ្ឋបាលគ្រប់គ្រង ............................................... ១៨
២.១.២. ការបង្កើតរដ្ឋ និងការទទួលស្គាល់រដ្ឋ ............................ ១៩
២.១.៤. សិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋ ........................................ ២១
២.២. អង្គការអន្តរជាតិ ........................................................ ២៤
២.៣. បុគ្គល ........................................................................ ២៥

## ជំពូក ៣

## ប្រភពនៃច្បាប់អន្តរជាតិសាធារណៈ

៣.១. ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ( *ចទអ)* ........................... ២៨
៣.១.១. និយមន័យ .............................................................. ២៨
៣.១.២. ជាតុផ្សំរបស់ *ចទអ* .................................................. ២៩
៣.១.២.១. ជាតុផ្សំក្នុងន័យចង្អៀត ........................................ ២៩
៣.១.២.២. ជាតុផ្សំក្នុងន័យទូលាយ ........................................ ៣២
៣.១.៣. ប្រភេទនៃ *ចទអ* ..................................................... ៣៤
៣.១.៣.១. *ចទអ* កម្រិតសាកល និងតំបន់ ............................. ៣៤
៣.១.៣.២. *ចទអ* ដែលត្រូវបានបង្កើតក្នុងពេលដ៏ខ្លី ................. ៣៧
៣.១.៤. ចរិតលក្ខណៈរបស់ *ចទអ* ........................................... ៣៨
៣.១.៤.១. ជំហររបស់រដ្ឋ និងអ្នកស្រាវជ្រាវខ្លះ ........................ ៤០
៣.១.៤.១.១. បន្ទាបឥទ្ធិពល *ចទអ* ................................ ៤៣
៣.១.៤.១.២. ការជំទាស់ក្នុងពេលដែល *ចទអ* កំពុងកកើត ៤៤

៣.១.៥. ទំនាក់ទំនងរវាងសន្ធិសញ្ញា និង *ចទអ* ......................... ៤៦
៣.១.៥.១. តើវត្តមានវិធានក្នុងសន្ធិសញ្ញា អាចលុបសុពលភាពវិធានដូចគ្នានៃ *ចទអ?*..................................... ៤៦
៣.១.៥.២. តើវិធានក្នុងសន្ធិសញ្ញាខ្ពស់ជាងវិធាននៃ *ចទអ* ឬ? .... ៥០
៣.២. សន្ធិសញ្ញា.............................................................................. ៥២
៣.២.១. និយមន័យ និងប្រភេទ ............................................. ៥២
៣.២.២. ការតាក់តែង និងការចូលជាធរមានរបស់សន្ធិសញ្ញា...... ៥៣
៣.២.៣. អសុពលភាព និងការបញ្ចប់សន្ធិសញ្ញា......................... ៥៦
៣.២.៤. ខរក្សាសិទ្ធិមិនអនុវត្ត ................................................... ៦១
៣.២.៥. ការបកប្រែសន្ធិសញ្ញា .................................................. ៦៦
៣.២.៥.១. វិធីផ្អែកតាមចេតនារបស់អ្នកធ្វើច្បាប់ ........................ ៦៦
៣.២.៥.២. វិធីបកស្រាយទូលាយ ............................................ ៦៧
៣.២.៥.២.១. អត្ថន័យនៃពាក្យក្នុងបរិបទគោលបំណង....... ៦៨
៣.២.៥.២.២. ស្ថានភាពសង្គម និងប្រសិទ្ធភាពនៃកតិកាសញ្ញា.......................................... ៧២
៣.២.៥.២.៣. ប្រៀបធៀបច្បាប់ និងការអនុវត្ត.................. ៧៦
៣.២.៥.២.៤. ឯកសារពាក់ព័ន្ធ ....................................... ៧៧
៣.៣. ប្រភពផ្សេងទៀត ប្រភេទ និងឋានានុក្រម.................................. ៧៨

## ជំពូក ៤

## ច្បាប់ជាតិ និងច្បាប់អន្តរជាតិ

៤.១. ទ្រឹស្តីពាក់ព័ន្ធ ............................................................................ ៨១

៤.២. ការប្រតិបត្តិច្បាប់អន្តរជាតិ............................................................ ៨៣
៤.៣. ទីតាំងរបស់ច្បាប់អន្តរជាតិក្នុងប្រព័ន្ធច្បាប់ជាតិ............................ ៨៦
៤.៤. ទំនាស់រវាងច្បាប់ជាតិ និងច្បាប់អន្តរជាតិសាធារណៈ.................. ៨៧

## ជំពូក ៥

## អង្គការអន្តរជាតិ

៥.១. ប្រភេទ និង សមត្ថកិច្ច.................................................................. ៨៩
៥.២. អភ័យឯកសិទ្ធិ និងការទទួលខុសត្រូវ.......................................... ៩២

## ជំពូក ៦

## យុត្តាធិការ

៦.១. យុត្តាធិការផ្អែកតាមទីកន្លែងប្រព្រឹត្តបទល្មើស
(Territorial Principle)................................................................ ៩៧
៦.២. យុត្តាធិការផ្អែកតាមសញ្ជាតិ (Nationality Principle).............. ៩៨
៦.៣. យុត្តាធិការសម្រាប់ការពារប្រយោជន៍សំខាន់របស់ជាតិ
(Protective Principle)................................................................ ៩៩
៦.៤. យុត្តាធិការសាកល (Universal Jurisdiction)........................ ១០០
៦.៥. ការអនុវត្តយុត្តាធិការ និងបញ្ហាដែលពាក់ព័ន្ធ............................ ១០៣
៦.៦. មូលដ្ឋានផ្សេងទៀតនៃយុត្តាធិការ.............................................. ១០៥

## ជំពូក ៧

## ការប្រើកម្លាំងយោធា


៧.១. ប្រវត្តិនៃការហាមឃាត់ ........ ១០៦
៧.២. ខ្លឹមសារនៃការហាមប្រើកម្លាំង ........ ១០៧
៧.៣. សិទ្ធិការពារខ្លួន (Self-Defence) ........ ១០៨
៧.៤. សិទ្ធិការពារខ្លួនរួម (Collective Self-Defence) ........ ១១៣
៧.៥. ការប្រើកម្លាំងទ័ពក្រោមជំពូក៧នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ........ ១១៤
៧.៦. អន្តរាគមន៍មនុស្សធម៌ ........ ១១៥


## ជំពូក ៨

## ដំណោះស្រាយជម្លោះដោយសន្តិវិធី


៨.១. ជម្រើសនៃដំណោះស្រាយ ........ ១១៧
៨.២. តុលាការអាជ្ញាកណ្តាលអចិន្ត្រៃយ៍ ........ ១១៨
៨.៣. តុលាការយុត្តិធម៌អន្តរជាតិ ........ ១២០
៨.៣.១. ប្រវត្តិនៃការបង្កើត ទីតាំង និងសមាសភាព ........ ១២០
៨.៣.២. សមត្ថកិច្ច ........ ១២១
៨.៣.២.១. បណ្តឹង ........ ១២១
៨.៣.២.២. វិធានការបណ្តោះអាសន្ន ........ ១២៣
៨.៣.២.៣. ដំណើរការ និងបណ្តឹងតប ........ ១២៨
៨.៣.២.៤. វិធីនៃការដាក់ភស្តុតាង ........ ១៣១

៨.៣.២.៥. ច្បាប់ដែលត្រូវអនុវត្ត ........................................ ១៣១
៨.៣.២.៦. ខ្លឹមសារ ទម្រង់ និងការអនុវត្តសាលក្រម .............. ១៣៣
៨.៣.២.៧. សំណើសុំបកស្រាយសាលក្រម និងបណ្ដឹងសើរើ.... ១៣៤
៨.៣.៣. ប្រឹក្សាយោបល់ ................................................. ១៣៥

## ជំពូក ៩

## ការការពារបុគ្គលក្រោមច្បាប់អន្តរជាតិ

៩.១. ការការពារជនភៀសខ្លួន ................................................ ១៣៧
៩.១.១. ប្រវត្តិ...................................................................... ១៣៧
៩.១.២. និយមន័យ................................................................ ១៣៩
៩.១.៣. សិទ្ធិ និងកាតព្វកិច្ចរបស់ជនភៀសខ្លួន ....................... ១៤១
៩.១.៤. ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកជនភៀសខ្លួនរបស់ អង្គការសហប្រជាជាតិ ............................................. ១៤២
៩.១.៥. បញ្ហាពាក់ព័ន្ធ.......................................................... ១៤៣
៩.១.៥.១. ការកំណត់ឋានៈ និងឧបដិសេធ............................ ១៤៤
៩.១.៥.២. ការមិនបញ្ជូនជនភៀសខ្លួនត្រឡប់ទៅជួបការធ្វើទុក្ខបុកម្នេញ .................................................... ១៤៦
៩.១.៥.៣. ការបណ្ដេញជនភៀសខ្លួននៅព្រំដែន និងនៅក្នុងដែនសមុទ្រអន្តរជាតិ.................................................. ១៤៧
៩.១.៥.៤. ការបណ្ដេញដោយប្រយោល ................................ ១៤៨
៩.១.៥.៥. ការស្នាក់នៅក្នុងទីសុវត្ថិភាពក្នុងស្រុក (Internal Flight) ............................................. ១៥០

៩.១.៥.៦. ការសន្យាមានលក្ខណៈនយោបាយ........................ ១៥១
៩.២. សិទ្ធិមនុស្ស.................................................................................. ១៥២
៩.២.១. ប្រវត្តិនៃច្បាប់សិទ្ធិមនុស្ស.............................................. ១៥២
៩.២.២. ការវិវត្តនៃវិធានច្បាប់សិទ្ធិមនុស្ស និងយន្តការឃ្លាំមើល
ការគោរពសិទ្ធិមនុស្ស.................................................... ១៥៤
៩.២.២.១. ការវិវត្តនៃវិធាន ...................................................... ១៥៤
៩.២.៣. ប្រភេទនៃសិទ្ធិ ............................................................ ១៥៨
៩.២.៤. បញ្ហាចម្បងមួយចំនួន.................................................. ១៦២
៩.២.៤.១. គោលការណ៍មិនរើសអើង.................................... ១៦២
៩.២.៤.១.១. និយមន័យ.............................................. ១៦២
៩.២.៤.១.២. មូលដ្ឋាននៃការរើសអើង .......................... ១៦៣
៩.២.៤.១.៣. ការរើសអើង និងរើសអើងពូជសាសន៍........ ១៦៣
៩.២.៤.១.៤. ទម្រង់ការរើសអើង អ្នកប្រព្រឹត្ត
និងជនរងគ្រោះ...................................... ១៦៤
៩.២.៤.១.៥. ការរើសអើង និងករណីលើកលែង............. ១៦៦
ក. ក្នុងច្បាប់ .............................................................. ១៦៧
ខ. សកម្មភាពវិជ្ជមាន .................................................... ១៦៨
៩.២.៥. ការកម្រិតសិទ្ធិ.............................................................. ១៧០
៩.២.៦. ការផ្អាកអនុវត្តសិទ្ធិ........................................................ ១៧៣
៩.២.៧. សិទ្ធិស្វ័យសម្រេច ( Right to Self-Determination )......... ១៧៨
៩.២.៧.១. សញ្ញាណនៃសិទ្ធិស្វ័យសម្រេច.............................. ១៨០
៩.២.៧.២. សិទ្ធិស្វ័យសម្រេចក្នុងបរិបទនៃរបបអាណានិគម
និងការកាន់កាប់ដោយបរទេស............................. ១៨១

៩.២.៧.៣. សិទ្ធិស្វ័យសម្រេចក្រោបរិបទនៃរបបអាណានិគម... ១៨២
៩.២.៨. កាតព្វកិច្ចរបស់រដ្ឋ........................................................ ១៨៥
៩.២.៩. សិទ្ធិទទួលបានដំណោះស្រាយមានប្រសិទ្ធភាព.......... ១៨៧
៩.២.១០. យន្តការពិនិត្យមើលការប្រតិបត្តិសន្ធិសញ្ញា
សិទ្ធិមនុស្ស............................................................ ១៨៨
៩.២.១០.១. យន្តការបង្កើតតាមធម្មនុញ្ញរបស់អង្គ
ការសហប្រជាជាតិ............................................ ១៨៨
៩.២.១០.២. យន្តការបង្កើតតាមសន្ធិសញ្ញា.......................... ១៩០
៩.២.១០.២.១. របាយការណ៍...................................... ១៩១
៩.២.១០.២.២. បណ្តឹងរបស់បុគ្គល.............................. ១៩៥
៩.២.១០.២.៣. បណ្តឹងរបស់រដ្ឋ.................................. ២០០
៩.២.១០.២.៤. ការស៊ើបសួរ........................................ ២០១
៩.២.១០.២.៥. ការចុះពិនិត្យមន្ទីរឃុំឃាំង ..................... ២០៣
៩.២.១១. សិទ្ធិមនុស្សក្នុងតំបន់................................................ ២០៥
៩.២.១១.១. តំបន់អឺរ៉ុប.......................................................... ២០៥
៩.២.១១.២. តំបន់អន្តរ-អាមេរិក ........................................... ២០៩
៩.២.១១.៣. តំបន់អាហ្វ្រិក....................................................... ២១១
៩.២.១១.៤. តំបន់ដទៃទៀត ................................................. ២១៣
៩.២.១២. បញ្ហាមួយចំនួនពាក់ព័ន្ធសិទ្ធិមនុស្ស ........................ ២១៤
៩.២.១២.១. ការការពារសិទ្ធិមនុស្ស និងការបង្ក្រាបភេរវកម្ម..... ២១៤
៩.២.១២.២. ទ្រឹស្តី និងប្រយោជន៍នៃការគោរពសិទ្ធិមនុស្ស...... ២១៦
៩.៣. ការការពារបុគ្គលក្នុងពេលមានសង្គ្រាម...................................... ២២០
៩.៣.១. ប្រវត្តិ នៃច្បាប់មនុស្សធម៌អន្តរជាតិ ............................. ២២០

៩.៣.២. សង្គ្រាមអន្តរជាតិ និងមិនមែនអន្តរជាតិ........................ ២២២
៩.៣.៣. គោលការណ៍ចម្បងនានា ............................................ ២២៥
៩.៣.៣.១. គោលការណ៍បែងចែក និងហាមឃាត់ការវាយ
ប្រហារមិនរើសមុខ............................................ ២២៥
៩.៣.៣.២. សម្ភារ និងបុគ្គលដែលត្រូវការពារ ......................... ២២៧
៩.៣.៣.៣. ការហាមឃាត់វិធី និងមធ្យោបាយធ្វើសង្គ្រាម ......... ២២៩
៩.៣.៤. ការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ............................ ២៣០
៩.៣.៤.១. អនុវត្តន៍ដោយអង្គការអន្តរជាតិ ............................. ២៣០
៩.៣.៤.២. អនុវត្តន៍ដោយរដ្ឋ ................................................ ២៣១
៩.៣.៥. ទំនាក់ទំនងរវាងច្បាប់មនុស្សធម៌អន្តរជាតិ
និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ................................... ២៣៣
៩.៣.៦. ការហាមឃាត់ការប្រើអាវុធគីមី .................................. ២៣៥
៩.៣.៦.១. យន្តការថ្នាក់ជាតិសម្រាប់លុបបំបាត់អាវុធគីមី......... ២៣៧
៩.៣.៦.២. យន្តការអន្តរជាតិសម្រាប់លុបបំបាត់អាវុធគីមី ........ ២៣៨
៩.៤. ការការពារតាមផ្លូវទូត (Diplomatic Protection).................... ២៣៩
៩.៤.១. ប្រវត្តិ និយមន័យ និងចរិតលក្ខណៈ............................ ២៣៩
៩.៤.២. វិសាលភាពនៃការការពារ ............................................ ២៤១
៩.៤.៣. លក្ខខណ្ឌសម្រាប់អនុញ្ញាតឲ្យមានអន្តរាគមន................ ២៤២

## ជំពូក ១០

## ការទទួលខុសត្រូវចំពោះការរំលោភកាតព្វកិច្ចអន្តរជាតិ

១០.១. ការទទួលខុសត្រូវរបស់បុគ្គល ................................................ ២៤៤

១០.១.១. យន្តការសម្រាប់ការអនុវត្តការទទួលខុសត្រូវ ........... ២៤៦
១០.១.១.១. តុលាកាព្រហ្មទណ្ឌសម្រាប់ Rwanda
និងសម្រាប់ អតីតយូហ្គោស្លាវី .......................... ២៤៧
១០.១.១.២. តុលាការព្រហ្មទណ្ឌអន្តរជាតិ............................ ២៤៩
១០.១.១.២.១. ប្រវត្តិ.................................................. ២៤៩
១០.១.១.២.២. សមត្ថកិច្ច និងការអនុវត្តសមត្ថកិច្ច ......... ២៥០
ក. បទប្រល័យពូជសាសន៍............................................ ២៥១
ខ. បទឧក្រិដ្ឋកម្មសង្គ្រាម.............................................. ២៥២
គ. បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ .................................... ២៥៣
ឃ. បទឈ្លានពាន ....................................................... ២៥៤
ង. សមត្ថកិច្ចលើបុគ្គល និងដែនដី.................................. ២៥៥
១០.១.១.២.៣. ការទទួលយកបណ្ដឹង និងដំណើរ
ការនីតិវិធី ............................................ ២៥៥
១០.១.១.២.៤. ទម្រង់នៃការទទួលខុសត្រូវ.................... ២៥៧
១០.១.១.២.៥. មូលដ្ឋានសម្រាប់ការរួចផុតពីការ
ទទួលខុសត្រូវ .................................... ២៦១
១០.១.១.២.៦. បញ្ហាប្រឈម.................................... ២៦២
ក. អភ័យឯកសិទ្ធិ......................................................... ២៦២
ខ. ការលើកលែងទោសជាទូទៅ .................................... ២៦៦
គ. កិច្ចសហការក្នុងការចាប់ខ្លួន...................................... ២៦៧
១០.១.១.៣. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា........... ២៦៨
១០.១.១.៣.១. គោលបំណងនៃការបង្កើត..................... ២៧០
១០.១.១.៣.២. រចនាសម្ព័ន្ធ និងដំណើរការការងារ.......... ២៧១

១០.១.១.៣.៣. សមត្ថកិច្ច ........................................... ២៧៤
១០.១.១.៣.៤. ការទទួលខុសត្រូវ និងទម្រង់នៃការ
ទទួលខុសត្រូវ ..................................... ២៧៨
១០.១.១.៣.៥. ច្បាប់ដែលត្រូវអនុវត្ត............................ ២៨០
១០.១.១.៣.៦. បញ្ហាគួរឲ្យចាប់អារម្មណ៍ ....................... ២៨១
ក. ការលើកលែងទោស ................................................ ២៨១
ខ. អាជ្ញាយុកាលនៃការចោទប្រកាន់............................... ២៨២
គ. ការឃុំខ្លួនមុនបង្កើតអង្គជំនុំជម្រះ ............................ ២៨៥
ឃ. ចម្លើយសារភាពដោយបង្ខិតបង្ខំ ............................... ២៨៨
ង. សហឧក្រិដ្ឋកម្មរួម ................................................. ២៩០
១០.១.១.៤. បត្យាប័ន និងការជួយគ្នាផ្នែកតុលាការ................ ២៩៥
១០.១.១.៤.១. បញ្ហាប្រឈម និងដំណោះស្រាយ.................. ២៩៨
១០.១.១.៥. ការជួយគ្នាក្នុងវិស័យតុលាការ............................ ៣០១
១០.២. ការទទួលខុសត្រូវរបស់រដ្ឋ...................................................... ៣០២
១០.២.១. កំហុសជាអន្តរជាតិ.................................................. ៣០៣
១០.២.២. ការទទួលខុសត្រូវរួម................................................ ៣០៥
១០.២.៣. មូលដ្ឋាននាំឲ្យរួចខ្លួនពីការទទួលខុសត្រូវ................ ៣០៥
១០.២.៤. វិធានការឆ្លើយតបចំពោះការរំលោភកាតព្វកិច្ចអន្តរជាតិ.... ៣០៧
១០.២.៥. ការលើកឡើងឲ្យមានការទទួលខុសត្រូវ.................. ៣០៨
១០.២.៦. ផលវិបាកនៃការរំលោភកាតព្វកិច្ច........................... ៣០៩
១០.២.៧. ការទទួលខុសត្រូវ ក្រោមសន្ធិសញ្ញាផ្សេងទៀត........ ៣១១
១០.២.៨. ការទទួលខុសត្រូវរបស់សហគមន៍អន្តរជាតិ............ ៣១១

# ជំពូក ១១

# វិស័យផ្សេងទៀតនៃច្បាប់អន្តរជាតិសាធារណៈ

១១.១. ច្បាប់សមុទ្រ ........ ៣១៣
១១.១.១. ប្រវត្តិ ........ ៣១៣
១១.១.១.១. បញ្ហាមួយចំនួនចែងក្នុងអនុសញ្ញា ........ ៣១៦
១១.១.១.១.១. ខ្សែមូលដ្ឋាន (Baseline) ........ ៣១៦
១១.១.១.១.២. ដែនសមុទ្ររបស់រដ្ឋ ........ ៣១៧
១១.១.១.១.៣. តំបន់តភ្ជាប់ ........ ៣១៨
១១.១.១.១.៤. តំបន់សេដ្ឋកិច្ចផ្តាច់មុខ ........ ៣១៩
១១.១.១.១.៥. តំបន់ខ្ពង់រាបបាតសមុទ្រ ........ ៣២០
១១.១.១.១.៦. សមុទ្រអន្តរជាតិ ........ ៣២០
១១.១.១.១.៧. តំបន់បាតសមុទ្រជ្រៅ ........ ៣២១
១១.១.១.១.៨. កំណត់សម្គាល់ ........ ៣២២
១១.១.១.២. យន្តការ ........ ៣២៣
១១.២. បរិស្ថាន ........ ៣២៧
១១.២.១. បញ្ហាបម្រែបម្រួលអាកាសធាតុ ........ ៣២៩
១១.២.២. បញ្ហាជីវចម្រុះ ........ ៣៣១
១១.២.៣. ផ្លូវទឹក ........ ៣៣៣
១១.២.៤. បញ្ហាដទៃទៀតនៃវិស័យបរិស្ថាន ........ ៣៣៤
១១.២.៥. គោលការណ៍សំខាន់នៃច្បាប់បរិស្ថានអន្តរជាតិ ........ ៣៣៤
១១.២.៥.១. គោលការណ៍បង្ការ និងប្រុងប្រយ័ត្នទុកជាមុន ...... ៣៣៥

១១.២.៥.២. ការទទួលខុសត្រូវដូចគ្នា តែតាមលទ្ធភាពផ្សេងគ្នា
(Common but Different Responsibility) ..........................៣៣៧
១១.២.២. យន្តការ ................................................................ ៣៣៨
១១.២.២.១. សន្និសីទរបស់រដ្ឋជាភាគី
(Conference of States Parties) .................. ៣៣៨
១១.២.២.២. យន្តការដទៃទៀត........................................... ៣៣៩
១១.២.២.៣. បញ្ហាប្រឈម ................................................ ៣៤០
១១.៣. សេដ្ឋកិច្ច ................................................................................ ៣៤២
១១.៣.១. ប្រវត្តិ......................................................................... ៣៤២
១១.៣.២. GATT និងគោលការណ៍ចម្បង.................................. ៣៤៤
១១.៣.២.១. ការប្រព្រឹត្តដូចគ្នាចំពោះរដ្ឋ
(Most Favor Nation : MFN) ...................... ៣៤៥
១១.៣.២.២. ឧបត្ថម្ភធន (Subsidies)................................ ៣៤៦
១១.៣.២.៣. ការការពារ (Safeguard) ............................... ៣៤៧
១១.៣.៣. GATT ទៅជា WTO ................................................ ៣៤៨
១១.៣.៤. យន្តការដោះស្រាយជម្លោះ ...................................... ៣៥០
១១.៣.៥. បញ្ហាពាណិជ្ជកម្ម សុខភាព និង បរិស្ថាន.................. ៣៥៣
១១.៣.៦. ទំនាក់ទំនងរវាង កិច្ចព្រមព្រៀង WTO និង កិច្ចព្រមព្រៀង
ពាណិជ្ជកម្មសេរី (Free Trade Agreement: FTA) ..... ៣៥៥
១១.៤. លំហអាកាស ......................................................................... ៣៥៥
១១.៤.១. ការប្រើប្រាស់ធនធានថាមពលនុយក្លេអ៊ែរនិងសម្ភារ
ដទៃទៀតក្នុងលំហអាកាស ...................................... ៣៥៧

១១.៤.២. ការធ្វើអាជីវកម្មក្នុងលំហអាកាស និងសេចក្តីត្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ..... ៣៥៨
១១.៤.៣. ស្ថានីយអវកាសអន្តរជាតិ និងច្បាប់របស់រដ្ឋ..... ៣៥៩
សន្និដ្ឋាន..... ៣៦០
Subject Index ..... ៣៦២
លិខិតជូនប្រិយមិត្ត..... ៣៦៥
ប្រវត្តិអ្នកនិពន្ធ..... ៣៦៧
ឯកសារយោង ..... ៣៧០
ចំណាប់អារម្មណ៍ (ទំព័រក្របខាងក្រោយ ខាងក្រៅ)

# អក្សរកាត់

| | | |
|---|---|---|
| ACHR | : | African Convention on Human Rights |
| AJIL | : | American Journal of International Law |
| ASEAN | : | Association of Southeast Asian Nations |
| ASIL | : | American Society of International Law |
| AU | : | African Union |
| BYIL | : | British Yearbook of International Law |
| CAT | : | Committee against Torture |
| CEDAW | : | Convention on the Elimination of Discrimination against Women |
| CERD | : | Convention on Elimination of Racial Discrimination |
| CIL | : | Customary International Law |
| CPC | : | Criminal Procedure of Cambodia |
| CRC | : | Convention of the Rights of Child |
| DSU | : | Dispute Settlement Understanding |
| ECCC | : | Extraordinary Chambers in the Courts of Cambodia |
| ECHR | : | European Convention on Fundamental Rights and Freedom |
| ECOSOC | : | Economic, Cultural, Social Council (UN) |
| EJIL | : | European Journal of International Law |
| ETS | : | European Treaty Series |
| EU | : | European Union |
| GATT | : | General Agreement on Tariff and Trade |
| Harv. L. Rev. | : | Harvard Law Review |
| HRC | : | Human Rights Committee |
| HRW | : | Human Rights Watch |
| ICC | : | International Criminal Court |
| ICCPR | : | International Covenant on Civil and Political Rights |
| ICESCR | : | International Covenant on Economic, Social and Cultural Rights |

| | | |
|---|---|---|
| ICJ | : | The International Court of Justice |
| ICRC | : | International Committee of Red Cross |
| ICTR | : | International Criminal Tribunal for Rwanda |
| ICTY | : | International Criminal Tribunal for Former Yugoslavia |
| IJRL | : | International Journal of Refugee Law |
| IL | : | International Law |
| ILC | : | International Law Commission |
| ILM | : | International Legal Materials |
| ILR | : | International Law Report |
| IO | : | International Organization |
| ITLOS | : | International Tribunal of the Law of the Sea |
| JCE | : | Joint Criminal Enterprise |
| NATO | : | North Atalantic Treaty Organization |
| OCIJ | : | Office of the Co-Investigating Judges |
| OP | : | Optional Protocol |
| OPCW | : | Organization of Prohibition of Chemical Weapons |
| PCA | : | Permanent Council of Arbitration |
| PCIJ | : | Permanent Court of International Justice |
| PIL | : | Public International Law |
| PTC | : | Pre-Trial Chamber |
| RES. | : | Resolution |
| UDHR | : | Universal Declaration of Human Rights |
| UN | : | The United Nations |
| UNCLOS | : | The United Nations Convention on the Law of the Sea |
| UNFCCC | : | The United Nations Framework Conference on Climate Change |
| UNGA | : | The United Nations General Assembly |
| UNHCHR | : | The United Nations High Commissioner for Human Rights |
| UNHCR | : | The United Nations High Commissioner for Refugees |

| | | |
|---|---|---|
| UNSC | : | The United Nations Security Council |
| UNTS | : | The United Nations Treaty Series |
| VCLT | : | Vienna Convention on the Law of the Treaties |
| WTO | : | World Trade Organization |

# ជំពូក ១
# សេចក្តីផ្តើម

## ១.១. មូលហេតុ និងកំណកំណើតច្បាប់អន្តរជាតសាធារណៈ

ការស្រាវជ្រាវបានបង្ហាញថា កំណកំណើតនៃច្បាប់អន្តរជាតិសាធារណៈ មានប្រភពនៅក្នុងទ្វីបអឺរ៉ុប និងទ្វីបអាស៊ី។ ក្នុងទ្វីបអាស៊ី ទំនាក់ទំនង ក្នុងវិស័យពាណិជ្ជកម្មរវាងឥណ្ឌា និងចិន ដែលជារដ្ឋដ៏ចាស់ក្នុងទ្វីបអាស៊ី បានបង្កើតនូវវិធានគ្រប់គ្រងនូវទំនាក់ទំនងរបស់រដ្ឋទាំងពីរនេះ។[1] ទោះបីជាយ៉ាងណាក្តី ច្បាប់អន្តរជាតិមានប្រភពនៅក្នុងទ្វីបអឺរ៉ុប មានការរីកចម្រើនរហូតមកដល់សព្វថ្ងៃ ដោយសារមានការស្រាវជ្រាវ រក្សាទុក និង ចងក្រង ការអនុវត្តនៃវិធានច្បាប់អន្តរជាតិរហូតមកដល់ពេលបច្ចុប្បន្ននេះ។

ការវិវត្តច្បាប់អន្តរជាតិ កើតចេញពីទំនាក់ទំនងរវាងរដ្ឋ ឬក្នុងបរិបទក្នុងស្រុករួចរីកសាយមកដល់កម្រិតអន្តរជាតិ។ មានព្រឹត្តិការណ៍ពីរ ពាក់ពន្ធ័ជាមួយនឹងការវិវត្តនេះ ដែលគួរបង្ហាញជូន។ ទី១ គឺការវិវត្តនយោបាយ តាមគោលគំនិតទស្សនវិជ្ជា នាំឲ្យមានការបង្កើតរដ្ឋសម័យទំនើប និងសង្គ្រាមសាសនា។

[1] Peter Malanczuk, Akhehurst’s Modern Introduction to International Law (Peter Malanczuk, IL), 7th ed., 1997, pp.8 and 13; Malcolm N. Shaw, International Law (Shaw, IL), 6th ed., 2008, p. 14; William R. Slomanson, Fundamental Perspectives on International Law (William, Perspectives on IL), 1990, p.1; Tunku Sofiah Jewa, the Third World and International Law (Tunku, the Third World), 2007, pp. 13 and 15.

## ការវិវត្តនយោបាយ តាមគោលគំនិតទស្សនវិជ្ជា នាំឲ្យមានការបង្កើតរដ្ឋសម័យទំនើប (សតវត្សរ៍ ១៥ និង ១៦)

នាកាលសម័យដើម ប្រទេសត្រូវបានដឹកនាំដោយស្តេច ដែលគ្រប់គ្រងដែនដីធំធេង និងមានស្តេចត្រាញ់តាមតំបន់តូចៗផង ក្រោមចំណុះរបស់ស្តេចចក្រវាឡ។ ស្តេច ឡើងគ្រងរាជតាមពូជពង្ស ហើយតាំងខ្លួនជាអាទិទេព។ ពាក្យសម្តីរបស់ស្តេច ជាសម្តីរបស់អាទិទេព ចាត់ទុកដូចជាច្បាប់ ដែលប្រជារាស្រ្តត្រូវគោរព។ គ្មានការបែងចែកដាច់រវាងសាសនា និងការដឹកនាំរដ្ឋទេ នាពេលនោះ ពីព្រោះថា ស្តេចជាប្រមុខដឹកនាំរដ្ឋ និងក៏ជាមេដឹកនាំសាសនា។ ការដឹកនាំតាមបែបនោះ ដោយស្តេចនាសម័យនោះ មានចរិតផ្តាច់ការ។ ប្រជារាស្រ្ត មិនមែនជាប្រធាននៃច្បាប់ទេ តែជាកម្មវត្ថុនៃច្បាប់។[2] ប្រជារាស្រ្ត មិនមានសិទ្ធិសេរីភាព មានតែកាតព្វកិច្ចចំពោះព្រះរាជា។ ស្តេច គឺជាចៅក្រមហើយគ្មានការបែងចែកអំណាចរវាងស្ថាប័នដឹកនាំសំខាន់ៗរបស់រដ្ឋទេ។

ក្នុងទំនាក់ទំនងខាងក្រៅ ស្តេចតែងតែធ្វើសង្រ្គាម ដណ្តើមកាន់កាប់ពង្រីកទឹកដី។ ដោយយល់ឃើញនូវការដឹកនាំរបៀបនេះ ដែលបង្កទុក្ខទោសដល់ប្រជាពលរដ្ឋ ហើយប្រទេសជាតិ បានជួបនូវគ្រោះវិកវរ ក្រុមអ្នកទស្សនវិជ្ជាបានពិចារណា និងបង្កើតជាទ្រឹស្តី ដែលមានឥទ្ធិពលយ៉ាងខ្លាំង នាំទៅដល់ការតស៊ូរើបម្រះពីការដឹកនាំផ្តាច់ការ។ ទស្សនវិទូ បានផ្តោតសំខាន់ លើខ្លឹមនៃភាពថ្លៃថ្នូររបស់បុគ្គល ដែលជាសមាសភាព នាំឲ្យសង្គមមានភាពរីកចម្រើន និងស្ថេរភាព។ ធម្មជាតិបង្កើតមនុស្សមក ផ្តល់នូវសិទ្ធិ និងសេរីភាពមកជា

[2] Peoples, as subject of law, have rights and obligations while they are considered objects of law, they do not have rights and subject to sale as goods, *see* Anthony Aust, handbook of International Law (Anthony Aust, handbook), 2005, p. 13.

មួយ។ នេះជាសិទ្ធិពីធម្មជាតិ (Natural Rights) ដែលមនុស្សមាន ក្នុងនាមជាមនុស្ស មិនមែនរដ្ឋ ឬអាទិទេពជាអ្នកផ្តល់សិទ្ធិឡើយ។

ទស្សនវិទូ បានពិចារណាឃើញថា បុគ្គលគ្រប់រូបមានសិទ្ធិ និងសេរីភាព ហើយដោយសារប្រយោជន៍បុគ្គលម្នាក់ៗ ការអនុវត្តសិទ្ធិ និងសេរីភាព អាចនឹងប៉ះពាល់សិទ្ធិអ្នកដទៃ ដែលនឹងបង្ក ឲ្យមានជម្លោះ ឬអវិភាពក្នុងសង្គម។ បុគ្គលម្នាក់ៗ ត្រូវគោរពសិទ្ធិសេរីភាពរបស់បុគ្គលដទៃទៀត។ ដូចនេះ រដ្ឋត្រូវបង្កើតច្បាប់ ដែលក្នុងនោះ សរសេរកំណត់អំពីសិទ្ធិសេរីភាព ដែលបុគ្គលមាន និងអ្វីដែលបុគ្គលមិនត្រូវធ្វើ។ ជាមួយគ្នានេះ ច្បាប់ចែងបង្កើតស្ថាប័ន យន្តការអនុវត្តច្បាប់។ ស្ថាប័ននេះ ត្រូវបានបង្កើតឡើងដើម្បីបម្រើប្រយោជន៍ប្រជាជន ហើយអ្នកបម្រើការងារក្នុងស្ថាប័ន ជាតំណាងរបស់ប្រជាជន។ អ្នកតំណាង ត្រូវបានជ្រើសតាំងឡើងតាមរយៈការបោះឆ្នោត។ ប្រសិនបើពួកអ្នកតំណាងខកខានមិនធ្វើតាមការសន្យា ដែលថានឹងធ្វើការសម្រាប់ប្រយោជន៍អ្នកដែលខ្លួនតំណាង ពួកគេនឹងទទួលខុសត្រូវ ដូចជាចាកចេញពីអំណាចជាដើម។ គំនិត និងទស្សនៈនេះ ត្រូវបានវិវត្តន៍ និង ទទួលយករហូតមកដល់សព្វថ្ងៃនេះ។

តុលាការត្រូវបានបង្កើតឡើង ដើម្បីដាក់ទោសទណ្ឌចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងទាមទារឲ្យតុលាការមានឯករាជ្យភាព ពីអំណាចរបស់ស្តេច។ ទស្សនវិទូ បានត្រួសត្រាយថា អ្នកដែលជាអ្នកគ្រប់គ្រង មិនត្រូវជាអ្នកធ្វើច្បាប់ទេ ពីព្រោះបើមិនដូចនេះ អ្នកគ្រប់គ្រងនឹងធ្វើច្បាប់ បម្រើផល

ប្រយោជន៍ក្រុមខ្លួន ចាកឆ្ងាយពីកិច្ចសន្យាសង្គម[3] នាំឲ្យមានការតវ៉ា បង្កឲ្យមានភាពរីករាលក្នុងសង្គម។ ដូចនេះ ប្រជាពលរដ្ឋ ត្រូវការស្ថាប័នធ្វើច្បាប់ ដែលឯករាជ្យពី រដ្ឋាភិបាល (អ្នកគ្រប់គ្រង) និងតុលាការ។ នេះ គឺផ្អែកតាមទ្រឹស្តីនៃការបែងចែកអំណាច។ ដោយសារទាំងអ្នកគ្រប់គ្រង ទាំងអ្នកដែលត្រូវគេគ្រប់គ្រងសុទ្ធសឹងជាមនុស្ស មានភាពស្មើភាពគ្នាចំពោះមុខច្បាប់ និងទទួលខុសត្រូវចំពោះមុខច្បាប់ ដោយគ្មានរើសអើង អ្នកគ្រប់គ្រងប្រទេស ក៏ត្រូវស្ថិតនៅក្រោមច្បាប់ដែរ។ ក្នុងន័យនេះ អ្នកគ្រប់គ្រង ត្រូវដឹកនាំតាមច្បាប់។ ជាសរុប ទ្រឹស្តីទាំងអស់នេះ ជារួម ឆ្លុះបញ្ចាំងនូវ ប្រជាធិបតេយ្យ នីតិរដ្ឋ (Rule of Law) សិទ្ធិមនុស្ស ដែលមានការវិវត្ត និងជះឥទ្ធិពលយ៉ាងខ្លាំងលើការផ្លាស់ប្តូរនៃរបត់ដឹកនាំ និងនយោបាយរហូតមកដល់ពេលបច្ចុប្បន្ននេះ។ នេះហើយគឺជាទ្រឹស្តីនៃការបង្កើត និងគ្រប់គ្រងរដ្ឋសម័យទំនើប។

ទ្រឹស្តីទាំងនេះ បង្ហាញពីភាពផ្ទុយគ្នា ស្ទើរគ្រប់ទិដ្ឋភាព នៃការដឹកនាំក្រោមរបបរាជានិយមសម័យនោះ។ ទ្រឹស្តីទាំងនេះ នាំឲ្យមានបដិវត្តន៍ វាយរំលំអំណាចស្តេចនៅក្នុងប្រទេសបារាំង។ ជាលទ្ធផល បដិវត្តន៍នាំឲ្យមានការចែកដាច់រដ្ឋ និងសាសនា។ ស្តេចនៅតែជាមេសាសនា រដ្ឋាភិបាលជាអង្គភាពគ្រប់គ្រង សភាជាអ្នកធ្វើច្បាប់ តុលាការជាអ្នកបកស្រាយច្បាប់ ហើយស្ថាប័នទាំងបីនេះត្រូវស្ថិតនៅឯករាជក្យពីគ្នា។ ប្រជាពលរដ្ឋ មានសិទ្ធិសេរីភាពស្មើភាព ចូលរួមសកម្មភាពនយោបាយ ទទួលបានយុត្តិធម៌នៅពេលមានការរំលោភបំពានលើសិទ្ធិរបស់ខ្លួន។ អ្នកដឹកនាំ ត្រូវដឹកនាំតាមច្បាប់។ ក្រោយពីបដិវត្តន៍ ទទួលបានជោគជ័យ គោលការណ៍ចម្បង ទាញចេញពីទ្រឹស្តីទាំង

[3] Jean-Jacques Rousseau, On the Social Contract, Translated by Donald A. Cress, 1987.

នេះ ត្រូវបានដាក់បញ្ចូលក្នុងច្បាប់រដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ប្រទេស។

## សង្គ្រាម

ព្រឹត្តិការណ៍ខាងលើ បង្ហាញពីការរង្គោះរង្គើអំណាចដឹកនាំក្នុងប្រទេសទាំងមូល ហើយបានជះឥទ្ធិពលដល់ព្រឹត្តិការណ៍ទីពីរ ដែលជាសង្គ្រាមសាសនា។

ចក្រភព Roman មានមនុស្សមួយចំនួនជាគ្រីស្តបរិស័ទ។ ពួកគេយកវិហារ Roman Catholic Church ជាកណ្តាលសម្រាប់ភ្ជាប់បុគ្គលទៅនឹងអាទិទេព។ នេះធ្វើឲ្យគ្រីស្តមួយចំនួនក្នុងដែនដីចំណុះ ដែលចង់ប្រាស្រ័យ ដោយផ្ទាល់ជាមួយអាទិទេព តាមរយៈព្រះគម្ពី Bible មិនសប្បាយចិត្ត។[4] រួមជាមួយមូលហេតុផ្សេងទៀត ពួកអ្នកតវ៉ា ដែលហៅថា Protestants បានចាប់ផ្តើមមានទំនាស់ជាមួយ Catholics។ ទំនាស់យូរទៅ ក្លាយជាសង្គ្រាម ដែលមានពីរដំណាក់កាល។ ដំណាក់កាលទី ១ (ឆ្នាំ១៦១៨ ដល់ ១៦៣៥) ស្តេចចក្រភពនៅរក្សាអំណាចបាន។ ដំណាក់កាលទី២ ពីឆ្នាំ ១៦៣៥ ដល់ ១៦៤៨ មានការចូលរួមពីស្តេចអាឡឺម៉ង់ ដែលនាំឲ្យស្តេចចក្រភព បានចុះចាញ់។ សង្គ្រាមបានធ្វើឲ្យរង្គោះរង្គើអំណាចស្តេចចក្រភព បើកដៃឲ្យស្តេចត្រាញ់ ឬអ្នកគ្រប់គ្រងប្រចាំតំបន់នីមួយៗ ទទួលបានអំណាច គ្រប់គ្រងតំបន់ឯករាជ្យពីស្តេចចក្រភព។ តំបន់ទាំងនោះ ក៏បានក្លាយជាតំបន់ឯករាជ្យ ដែលអាចចាត់ថាជារដ្ឋក្នុងន័យរដ្ឋ តាមច្បាប់អន្តរជាតិបច្ចុប្បន្ន។ ដើម្បីបង្ការកុំឲ្យមានសង្គ្រាម រដ្ឋ ឬតំបន់ទាំងនោះ បានស្រុះស្រួលធ្វើសន្ធិសញ្ញា

[4] Alfred-Maurice De Zayas, *Wesphalia*, in Encyclopedia of Public International Law, 1984, pp. 1465-69.

Wesphalia ចែងពីវិធានគ្រប់គ្រងរដ្ឋ និង ទទួលស្គាល់នូវសេរីភាព សាសនារបស់ជនភាគតិច។[5] តំបន់នីមួយៗ កំណត់សាសនារបស់ខ្លួន និងទទួលស្គាល់អធិបតេយ្យភាពរបស់តំបន់ក្នុង Holy Roman Empire។ គ្រប់ភាគី ត្រូវការពារមាត្រា ស្តីពី សន្តិភាព ដោយគ្មានការរើសអើងផ្អែកតាមសាសនា។ ជាមួយគ្នានេះ សន្ធិសញ្ញា ក៏មានចែងអំពីការដោះស្រាយជម្លោះ។ ទោះបីជាយ៉ាងនេះក្តី នាពេលក្រោយមក មានសង្គ្រាមបង្កឡើងដោយស្តេច Napoleon របស់ប្រទេសបារាំង ដែលបានបញ្ចប់ដោយសន្ធិសញ្ញា Verseille និងបង្កើតនូវសន្ធិសញ្ញាឆ្នាំ ១៨៩៩ សម្រាប់ដោះស្រាយជម្លោះ។ ព្រឹត្តិការណ៍ទាំងអស់នេះ នាំឲ្យមានការបង្កើតនូវវិធានជាហូរហែ សម្រាប់គ្រងគ្រង ទំនាក់ទំនងរវាងរដ្ឋ។

ព្រឹត្តិការណ៍ចុងក្រោយ គឺសង្គ្រាមលោកលើកទី២ ដែលបានបញ្ចប់ទៅក្នុងឆ្នាំ ១៩៤៥ នាំឲ្យមានការបង្កើតអង្គការសហប្រជាជាតិ បន្តវេនពីអង្គការសង្គមប្រជាជាតិ និងតុលាការយុត្តិធម៌អន្តរជាតិ បន្តវេនពី Permanent Court of International Justice បង្កើតក្រោយបញ្ចប់សង្គ្រាមលោកលើកទី១ ។ ធម្មនុញ្ញអង្គការសហប្រជាជាតិ ត្រូវបានអនុម័ត ដោយដាក់ចេញ នូវវិធានហាមឃាត់ការប្រើកម្លាំងទ័ព ដើម្បីដោះស្រាយបញ្ហា លើកកម្ពស់សិទ្ធិមនុស្ស ព្រមទាំងបានចែងពីគោលការណ៍ចម្បង ជាច្រើនសម្រាប់គ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋ និង បង្កើតស្ថាប័នអន្តរជាតិសំខាន់ផ្សេងៗទៀត។ វិធាន

[5] Buergenthal and Sean D. Murphy, Public International Law (Thomas, PIL), 2007, p. 12; Tunku, the Third World, *supra* note 1, p. 13; Harold Hongju Koh, *why do nations obey international law*? 106 Yale Law Journal (1997), p. 2607-2068.

ទាំងនោះ ត្រូវបានចាត់ថាជាវិធានច្បាប់អន្តរជាតិសហសម័យ ហើយត្រូវបានវិវត្តន៍ រីកចម្រើនរហូតមកដល់ពេលបច្ចុប្បន្ន។[6]

ជាសរុប ការបង្កើត និងវិវត្តន៍នៃច្បាប់អន្តរជាតិ មានជាយូរយារមកហើយ។ ព្រឹត្តិការណ៍ក្នុងប្រវត្តិសាស្ត្រ បានរុញច្រានឲ្យមានការប្រែប្រួលនៃរបត់នយោបាយ ផ្អែកតាមទ្រឹស្តីទស្សនវិជ្ជា។ ការវិវត្តចេញមកពី វិធានក្នុងប្រទេស ប្រើប្រាស់ក្នុងទំនាក់ទំនងជាមួយប្រទេសមួយក្នុងតំបន់មួយ ហើយរីកសាយមកកម្រិតអន្តរជាតិ។

## ១.២. ច្បាប់អន្តរជាតិសាធារណៈនាពេលបច្ចុប្បន្ន

មុនសង្គ្រាមលោកលើកទី១ មានតែសន្ធិសញ្ញាអន្តរជាតិចំនួនតិចតួច[7] និងស្ថាប័នអន្តរជាតិតិចតួចសម្រាប់អនុវត្តច្បាប់អន្តរជាតិ[8]។ ក្នុងពេលបច្ចុប្បន្ន ច្បាប់អន្តរជាតិមានការវិវត្ត រីកសាយភាយយ៉ាងខ្លាំង និងឥតឈប់ឈរ។ មានវិធានច្បាប់ជាច្រើន ចែងគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ រដ្ឋ និងបុគ្គល រដ្ឋ និងអង្គការអន្តរជាតិ ក្នុងវិស័យជាច្រើនដូចជា បរិស្ថាន សិទ្ធិមនុស្ស សេដ្ឋកិច្ចជាដើម។ វិស័យទាំងនោះ មានទំនាក់ទំនង និងពឹងផ្អែកគ្នាទៅវិញទៅមក។

[6] Peter Malanczuk, IL, *supra* note 1, pp. 11 and 12.

[7] 1899 Hague Conevntion for the Pacific Settelemnt of International Disputes; 1907 Hague Convention relative to the Opening of Hostilities; 1907 Hague Convention respecting the Laws and Customs of War on Land.

[8] For instance, the Permanent Court of Arbitration and the League of Nations; for the League of Nation, *see* Helmut Volger, A Concise Encyclopedia of the United Nations (Helmut, A Concise of the UN), 2nd ed., 2010, pp. 477-478.

បុគ្គលបានក្លាយ ជាប្រធាននៃច្បាប់អន្តរជាតិ។ រដ្ឋជាច្រើន ត្រូវបានបង្កើត ជាពិសេស ក្នុងទសវត្សរ៍ទី ៧០[9] ហើយបានក្លាយជាសមាជិករបស់អង្គការសហប្រជាជាតិ។ រដ្ឋបាន ដាក់បញ្ចូលច្បាប់អន្តរជាតិ ទៅក្នុងច្បាប់ជាតិ ចូលរួមយ៉ាងសកម្មជាងមុន ក្នុងការធ្វើសន្ធិសញ្ញា និងក្នុងកិច្ចការងាររបស់ស្ថាប័នអន្តរជាតិ។ រដ្ឋបានដាក់ពាក្យបណ្តឹងជាច្រើន ចូលមកតុលាការអន្តរជាតិ ហើយរដ្ឋមួយចំនួន បានពិភាក្សាយ៉ាងផុសផុល ក្នុងផ្ទៃក្នុងប្រទេស អំពីវិធានការ និង ការគោរពតាមច្បាប់អន្តរជាតិ។ ស្ថាប័នអន្តរជាតិជាច្រើន ត្រូវបានបង្កើត។ ក៏ប៉ុន្តែ អ្វីដែលជាក្តីបារម្ភ គឺការស្ថិតនៅដោយដុំៗ និងជួនកាលមិនស៊ីសង្វាក់គ្នា (Fragmentation of International Law)[10] នៃវិធានអន្តរជាតិ និងស្ថាប័នអន្តរជាតិ។ នេះដោយសារ បុគ្គលដែលអនុវត្តច្បាប់ ឬធ្វើច្បាប់អន្តរជាតិ មកពីប្រព័ន្ធច្បាប់ផ្សេងគ្នា មានស្ថាប័នជាច្រើនក្នុងវិស័យផ្សេងៗទៀត ដាក់ចេញនូវច្បាប់រៀងៗខ្លួន និង ការអនុវត្តច្បាប់អន្តរជាតិដោយរដ្ឋមានកម្រិតខុសៗគ្នាផងដែរ។ នេះបង្កជាបញ្ហាពិបាក និងមិនអាចធ្វើទៅរួចក្នុងការចងក្រង និងធានាយ៉ាងណាកុំឲ្យមានការបង្កើតវិធានមិនស៊ីសង្វាក់គ្នា ឬផ្ទុយគ្នា។

## ១.៣. និយមន័យនៃច្បាប់អន្តរជាតិសាធារណៈ

ច្បាប់អន្តរជាតិ ត្រូវបានគេផ្តល់ន័យថា ជាបណ្តុំនៃវិធាន គ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ។ នេះជាន័យ ដែលត្រូវបានផ្តល់ នៅមុនសង្គ្រាមលោក

[9] Helmut, A Concise of the UN, *supra* note 8, pp. 68-69.

[10] Conclusions of the work of the Study Group on the Fragmentation of International Law: Difficulties arising from the Diversiifcation and Expansion of International Law , Yearbook of the International Law Commission, 2006, vol. II, Part II.

លើកទី២។[11] និយមន័យនៃច្បាប់អន្តរជាតិ មានការប្រែប្រួល ក្រោយពីសង្គ្រាមលោកលើកទី ២ ដែលមានខ្លឹមសារថា ជាបណ្ដុំវិធាន គ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ រដ្ឋ និងឯកជន រដ្ឋ និងអង្គការអន្តរជាតិ។[12]

បម្រែបម្រួលនេះ កើតមាន ដោយសារការវិវត្ត ជាពិសេសទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ។ និយមន័យមុនការប្រែប្រួល ឆ្លុះបញ្ចាំង នូវអធិបតេយ្យភាពដាច់ខាតរបស់រដ្ឋ (Absolute State Sovereignty) ហើយមានតែរដ្ឋទេ ដែលជាប្រធាន ( Subject) នៃច្បាប់អន្តរជាតិ។[13]

ជំហរនេះ នាំឲ្យមានការយល់ថា ការប្រព្រឹត្តលើប្រជាជាតិ ដូចជាការបំពារបំពានសិទ្ធិ ដោយអាជ្ញាធរគ្រប់គ្រងរបស់ខ្លួន ជាកិច្ចការងារផ្ទៃក្នុងរបស់រដ្ឋ។[14] ប្រជាជាតិគ្មានសិទ្ធិ ដែលទាមទារឲ្យមានកាតព្វកិច្ចរបស់រដ្ឋ ក្នុងការការពារសិទ្ធិ។ បុគ្គលក៏គ្មានកាតព្វកិច្ច ក្រោមច្បាប់អន្តរជាតិ ឲ្យគោរពច្បាប់អន្តរជាតិដែរ។ ជាលទ្ធផល មានការរំលោភនូវសិទ្ធិមនុស្ស ដោយរដ្ឋ ឬបុគ្គល ហើយមិនត្រូវបានចោទប្រកាន់ ដាក់ទោស ចំពោះកំហុសប្រព្រឹត្តល្មើសនឹងច្បាប់អន្តរជាតិឡើយ។ នេះ នាំឲ្យមានការចែងច្បាប់ គ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋ និងបុគ្គល ផ្ដល់នូវកាតព្វកិច្ចដល់រដ្ឋ និងបុគ្គល។ ប្រសិនបើរដ្ឋ ឬបុគ្គល ប្រព្រឹត្តល្មើសច្បាប់អន្តរជាតិ នឹងនាំឲ្យមានការទទួលខុសត្រូវ។

---

[11] Rebecca M.M. Wallace, International Law (Rebecca, IL), 4th ed., 2002, pp. 1 and 2; William, Perspectives on IL, *supra* note 1, p.1.
[12] Thomas, PIL, *supra* note 5, p.2.
[13] Thomas, PIL, *supra* note 5, p. 1.
[14] Anthony Aust, handbook, *supra* note 2, p. 216.

## ១.៤. ច្បាប់អន្តរជាតិសាធារណៈ និងច្បាប់អន្តរជាតិឯកជន

ច្បាប់អន្តរជាតិ មានពីរប្រភេទ៖ ច្បាប់អន្តរជាតិសាធារណៈ និង ច្បាប់អន្តរជាតិឯកជន (Private International Law)។ ច្បាប់អន្តរជាតិឯកជន ត្រូវបានផ្តល់ន័យថា ជាបណ្តុំវិធាន គ្រប់គ្រងទំនាក់ទំនងរវាងប្រជាពលរដ្ឋប្រទេសមួយ និងប្រជាពលរដ្ឋរបស់ប្រទេសមួយទៀត។[15] ច្បាប់នេះ ត្រូវបានគេដាក់ឈ្មោះ ផ្សេងៗ ដូចជា Conflict of Law[16]។ អាពាហ៍ពិពាហ៍រវាងប្រជាពលរដ្ឋប្រទេសមួយ នឹងប្រជាពលរដ្ឋរបស់ប្រទេសមួយទៀត ជាប្រធានបទ ចែងក្រោមច្បាប់អន្តរជាតិឯកជន។ ច្បាប់នេះ នឹងចែងអំពីលក្ខខណ្ឌ ដែលអាពាហ៍ពិពាហ៍ ត្រូវបានទទួលស្គាល់ ដោយរដ្ឋមួយទៀត។ អាស្រ័យហេតុនេះ ការទទួលស្គាល់ ឬមិនទទួលស្គាល់ គឺផ្អែកតាមច្បាប់ជាតិ។

កិច្ចស្របជាមួយនឹងច្បាប់ជាតិរបស់ប្រទេសមួយ អាចមិនស្របជាមួយច្បាប់របស់ប្រទេសមួយទៀត។ ដើម្បីដោះស្រាយបញ្ហានេះ នៅក្នុងកម្រិតសកលមានការចងក្រងវិធានរួម ដែលរដ្ឋទាំងអស់ អាចអនុវត្តបាន ក្នុងបំណងគ្រប់គ្រងទំនាក់ទំនងបុគ្គលស្ថិតនៅក្នុងដែនយុត្តាធិការរបស់ខ្លួន។ដោយសារប្រទេសមួយចំនួន មានច្បាប់អន្តរជាតិឯកជន[17] របស់ខ្លួន ឬ ប្រទេសខ្លះមិនមានច្បាប់ តែមានការអនុវត្តផ្សេងៗ ដែលនាំឲ្យមានការលំបាកក្នុងការអនុវត្ត

[15] Jan-Jaap Kuipers, the European Union and Private International Law (Jan-Jaap, Private IL), 2012, p. 2.
[16] *Id.*, p. 21.
[17] *Id.,* p. 149; Jerzy Rajski, *the New Polish Private International Law*, 15 International and Comparative Law Quarterly, 1965.

វិធានសកល[18] សន្ធិសញ្ញា ស្តីពីច្បាប់អន្តរជាតិឯកជនក្នុងតំបន់អឺរ៉ុប ត្រូវបានរៀបចំឡើង ដើម្បីគ្រប់គ្រងទំនាក់ទំនងរវាងប្រជាពលរដ្ឋក្នុងតំបន់នេះ។[19] សន្ធិសញ្ញានេះ អាចកើតមានឡើងបាន ដោយសារប្រទេសក្នុងតំបន់អឺរ៉ុប មានវប្បធម៌ និងប្រពៃណីស្រដៀងគ្នា។[20] ទោះបីជាយ៉ាងនេះក្តី រដ្ឋ និងរដ្ឋ បានធ្វើនូវសន្ធិសញ្ញាទ្វេភាគីពាក់ព័ន្ធជាមួយច្បាប់អន្តរជាតិឯកជន ដើម្បីសម្រួលទំនាក់ទំនង រវាងពលរដ្ឋក្នុងប្រទេសទាំងពីរនេះ តាមរយៈការធ្វើឲ្យមានឲ្យភាពស៊ីសង្វាក់រវាងវិធានទាំងនោះ។[21]

ច្បាប់អន្តរជាតិសាធារណៈ និង ច្បាប់អន្តរជាតិឯកជន មានទំនាក់ទំនងជាមួយគ្នា។ អាពាហ៍ពិពាហ៍រវាង ប្រជាពលរដ្ឋរបស់រដ្ឋពីរ ស្ថិតនៅក្រោមច្បាប់អន្តរជាតិឯកជន ក៏ប៉ុន្តែការប្រព្រឹត្តមិនបានល្អ ចំពោះស្វាមី ឬ ភរិយារបស់ប្រជាពលរដ្ឋខ្លួន ដែលនាំរហូតឲ្យមានការរំលោភសិទ្ធិមនុស្ស នាំឲ្យក្លាយជាបញ្ហាបញ្ញត្តិដោយច្បាប់អន្តរជាតិសាធារណៈ។

## ១.៥. ការចងក្រង និង ការអភិវឌ្ឍច្បាប់អន្តរជាតិ

ការអនុវត្ត និងទ្រឹស្តីនៃច្បាប់អន្តរជាតិ មានភាពចម្រូងចម្រាសជាច្រើន។ ច្បាប់អន្តរជាតិបច្ចុប្បន្ន ត្រូវបានចាត់ថាជាផលិតផលរបស់ប្រទេសលោកខាងលិច ហើយត្រូវបានធ្វើឡើងតាំងពីមុនប្រទេសខ្លះ ក្នុងទ្វីបអាស៊ី ឬ អាហ្វ្រិក មិនទាន់បានឯករាជ្យ។ មានស្ថាប័នជាច្រើន ត្រូវបានបង្កើតឡើង

[18] James Fawcett, Private International Law (James, Private IL), 14th ed., 2008, p. 11; for the Hague Conference on Private International Law, see http://www.hcch.net

[19] Jan-Jaap, Private IL, *supra* note 15, p. 7.

[20] James, Private IL, *supra* note 18, p. 12.

[21] Jan-Jaap, Private IL, *supra* note 15, p. 139.

ដែលចូលរួមកសាងវិធានច្បាប់អន្តរជាតិ។ ការអនុវត្តច្បាប់ អន្តរជាតិដោយប្រទេសនីមួយៗ ក៏មានភាពផ្សេងៗគ្នា។ វិធានច្បាប់ខ្លះ ហួសសម័យ។ វិធានខ្លះទៀត ត្រូវបានក្លាយជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ (Customary International Law or Unwritten Law)។ វិធានប្រភេទនេះខ្លះ ត្រូវបានចងក្រងដាក់បញ្ចូលក្នុងសន្ធិសញ្ញា។ ជាចុងក្រោយ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនត្រូវបានសរសេរជាលាយលក្ខណ៍អក្សរទេ។ នេះនាំឲ្យមានការខ្វែងគ្នា និងការមិនទុកចិត្តចំពោះច្បាប់អន្តរជាតិប្រភេទនេះ។ ទាំងនេះ ជាអង្គហេតុបង្ហាញអំពីភាពអាណាធិបតេយ្យ នៃការអនុវត្តច្បាប់អន្តរជាតិ។ នេះក៏ជាមូលហេតុជំរុញឲ្យមានការចងក្រង និង អភិវឌ្ឍន៍ច្បាប់អន្តរជាតិផងដែរ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមួយ ត្រូវបានចងក្រងដាក់បញ្ចូលទៅ ក្នុងសន្ធិសញ្ញា។ បន្ថែមពីលើនេះ វិស័យថ្មីៗមួយចំនួន ដូចជាការទទួល ខុសត្រូវរបស់រដ្ឋ[22] ត្រូវបានរៀបចំឡើង។ គោលបំណងនេះ ដើម្បីធ្វើឲ្យវិធានច្បាប់អន្តរជាតិ កាន់តែមានសុក្រឹតភាព និងភាពស៊ីសង្វាក់ ដែលនាំឲ្យមានភាពងាយស្រួលក្នុងការអនុវត្ត និងអនុវត្តន៍កាន់តែមានប្រសិទ្ធភាព។

[22] James Crawford, the International Law Commission's Articles on State Responsibility of International Organization, 2002, p. 1; other issues have been under process of codification are recognition of States, jurisdictional immunities, see Mathhew Craven, the Decolonization of International Law, 2007, p. 94; Helmut, A Concise of the UN, *supra* note 8, p. 395.

# ជំពូក ២
# ប្រធាននៃច្បាប់អន្តរជាតិ

## ២.១. រដ្ឋ

រដ្ឋជាប្រធាននៃច្បាប់អន្តរជាតិ[23]ជាយូរលង់មកហើយ និងជាប្រធានពេញលេញ។ នេះមានន័យថារដ្ឋ មានសិទ្ធិ និងកាតព្វកិច្ច។ រដ្ឋ អាចធ្វើបណ្តឹងទៅតុលាការអន្តរជាតិ និង មានឋានៈជានីតិបុគ្គលអន្តរជាតិ (International Personality[24]) ដែលតាមរយៈនេះ រដ្ឋអាចចរចា និង ចុះសន្ធិសញ្ញាជាមួយប្រធានដទៃទៀតរបស់ច្បាប់អន្តរជាតិ ដូចជាអង្គការអន្តរជាតិ។

រដ្ឋមានធាតុផ្សំចំនួនបី៖ ប្រជាជន ដែនដី និងស្ថាប័នគ្រប់គ្រង។[25] រដ្ឋ មានទម្រង់យ៉ាងតិចពីរប្រភេទដូចជា៖ រដ្ឋទោល (កម្ពុជា) និង រដ្ឋសហព័ន្ធ ដូចជា ឥណ្ឌា សហរដ្ឋអាមេរិក អូស្ត្រាលីជាដើម។

### ២.១.១. ធាតុផ្សំនៃរដ្ឋ

#### ២.១.១.១. ប្រជាជន

ប្រជាជន ជាសមាសភាពមួយ ដើម្បីឲ្យអង្គភាពមួយមានលក្ខណៈគ្រប់គ្រាន់ដែលហៅថាជារដ្ឋ។ ប្រជាជន អាចមានចំនួនតិច ឬច្រើន ហើយច្បាប់អន្តរ

---

[23] William, Perspectives on IL, *supra* note 1, p.35; Budislav Vukas and Trpimir M. Sosic, International Law: New Actors, New Concepts Continuing Dilemmas (Budislav, IL), 2010, p. 381.

[24] Budislav, IL, *supra* note 23, p. 99.

[25] William, Perspectives on IL, *supra* note 1, p.36; Thomas, PIL, *supra* note 5, p. 22.

ជាតិ មិនបានកំណត់ តើប្រជាជនមានចំនួនប៉ុន្មាននាក់ ដែលអាចធ្វើឲ្យអង្គភាពមួយក្លាយទៅជារដ្ឋទេ។[26] ជាការជាក់ស្តែង ក្នុងពេលបច្ចុប្បន្ននេះ រដ្ឋខ្លះមានប្រជាជនប្រហែល ឬ តិចជាងមួយលាននាក់។ រដ្ឋខ្លះមានប្រជាជនច្រើនពាន់លាននាក់ (ចិន)។ ទោះបីជាយ៉ាងនេះក្តី ប្រជាជនគួរមានចំនួនច្រើនគួរសម ដើម្បីសមល្មមទៅនឹងការចំណាយ ទៅលើដំណើរការដឹកនាំដ៏ស្មុគស្មាញអស់ថវិកាជាច្រើនរបស់រដ្ឋមួយ។

អ្វីជាប្រជាជន មិនត្រូវបានកំណត់ដោយច្បាប់អន្តរជាតិទេ។ ការកំណត់បុគ្គលណាមួយជាប្រជាពលរដ្ឋរបស់ខ្លួន គឺ ផ្អែកទៅតាមច្បាប់របស់រដ្ឋនោះ។[27] ប្រជាជន ក្នុងប្រទេសមួយ មានសមាសភាពច្រើន ដូចជា ជនជាតិដើម និងជនភាគតិច ដែលចូលទៅរស់នៅ ហើយបង្កើតជាសហគមន៍ ដែលមានចំនួនតិច បើធៀបជាមួយប្រជាជនដើម។ បច្ចុប្បន្ននេះ មិនមានរដ្ឋណាមួយ ដែលមានតែពូជសាសន៍តែមួយឡើយ។ នេះមិនទាន់គិតដល់សាសនាផ្សេងៗ ដែលប្រជាជនក្នុងរដ្ឋនោះទទួលយកផង។ ក្នុងរដ្ឋមួយ អាចមានប្រជាពលរដ្ឋ មានសញ្ជាតិពីរ ហើយក៏អាចមានប្រជាជន ដែលគ្មានសញ្ជាតិផងដែរ។ យ៉ាងណាក៏ដោយ ក្រុមមនុស្ស ដែលរស់នៅលើដែនដី ដែលជាសមាសភាពនាំឲ្យអង្គភាពណាមួយក្លាយជារដ្ឋ ត្រូវតែជាប្រជាជនអចិន្ត្រៃយ៍។[28]

---

[26] William, Perspectives on IL, *supra* note 1, p.36; Petter Malanczuk, IL, *supra* note 1, p. 76.

[27] Petter Malanczuk, IL, *supra* note 1, p. 76; ICJ, *Nottebohm* Case (Second Phase), Judgement of 6 April 1955, UN, Summaries of judgements, Advisory Opinions and Orders of the ICJ (ICJ, *Nottebohm*), 1992, p. 33.

[28] Petter Malanczuk, IL, *supra* note 1, p. 76.

### ២.១.១.២. ដែនដី

ដែនដីអាចមានទំហំតូច ឬក៏ធំ។ ដែនដី ត្រូវបានកំណត់ទៅដោយព្រំប្រទល់។ ទោះបីជាយ៉ាងនេះក្តី ដើម្បីបង្កើតបានរដ្ឋមួយ ច្បាប់អន្តរជាតិមិនទាមទារឲ្យមានព្រំប្រទល់ជាក់លាក់គ្រប់ចំណុច ១០០ ភាគរយឡើយ។

ដែនដីជាសមាសភាពមួយ ដ៏សំខាន់នៃរដ្ឋ។ ដែនដី មានដីគោក ក្រោមដីសមុទ្រ ក្រោមសមុទ្រ និងអាកាស។[29] ដែនសមុទ្រមានទំហំ ទៅតាមច្បាប់សមុទ្រ គឺ ១២ ម៉ាល (Mile) ពីខ្សែបន្ទាត់មូលដ្ឋាន (Baseline) ។[30] គេនៅមិនទាន់និយាយបានថាចម្ងាយប៉ុន្មានពីដី ទៅលំហអាកាស ឬទៅក្រោមដីជាកម្មសិទ្ធិរបស់រដ្ឋ។ នាវា ឬ យន្តហោះ ដែលជាកម្មសិទ្ធិរបស់រដ្ឋមួយ ត្រូវបានគេចាត់ ថាជាដែនដីរដ្ឋមួយ សម្រាប់អនុវត្តន៍ច្បាប់ ក្នុងករណីមាន បទឧក្រិដ្ឋកើតមានឡើង។

ដែនដី រាប់បញ្ចូលនូវដីរបស់ស្ថានទូតបរទេស តាំងនៅក្នុងរដ្ឋនោះ។ ដីរបស់ស្ថានទូត ត្រូវបានប្រគល់ដោយរដ្ឋ ផ្អែកទៅតាមគោលការណ៍ទៅវិញទៅមក សម្រាប់ប្រតិបត្តិការងារទូត ក្នុងរយៈពេលយូរអង្វែងណាមួយ តែវានៅតែជាដីរបស់រដ្ឋដែលប្រគល់នោះ។ គេពុំគួរមានការយល់ច្រឡំថា ដីនោះជាដីរបស់រដ្ឋដាក់ទូតទេ។ រដ្ឋដែលទូតតាំងនៅ មិនហ៊ានចូលក្នុងទូត ដោយគ្មានការអនុញ្ញាត ដោយសារ ខ្លួនមានកាតព្វកិច្ចតាមច្បាប់អន្តរជាតិ ឲ្យគោរពនូវអភ័យឯកសិទ្ធិទូត។

---

[29] Petter Malanczuk, IL, *supra* note 1, p. 76.

[30] Gary Knight and Hungdah Chiu, the International Law of Sea, 1991,p. 247; the 1982 United Nations Convention on the Law of the Sea (the UNCLOS), Art.3, www.un.org/depts/los/index.htm.

### ២.១.១.២.១. គោលការណ៍ *Uti Possidetis*[31]

គោលការណ៍នេះ ចាប់កំណើតក្នុងសតវត្សរ៍ ទី ១៧ ក្នុងបណ្ដាប្រទេស Latin America និងត្រូវបានទទួលស្គាល់ និងអនុវត្តតាម ក្នុងទ្វីបអាហ្វ្រិក។ វាជាគោលការណ៍ ដែលតម្រូវឲ្យទទួលស្គាល់ព្រំប្រទល់ ដែនដីខណ្ឌចែកដែនដីធ្វើឡើងដោយប្រទេសដាក់អាណានិគម។ ហេតុផលនៅពីក្រោយគោលការណ៍នេះ ដើម្បីបង្ការកុំឲ្យមាន ការសើរើព្រំដែន ដែលនាំបង្កឲ្យមានសង្គ្រាម ឬមានអរិភាពរវាងរដ្ឋ និងរដ្ឋជិតខាង។[32] គោលការណ៍នេះ ក៏នឹងអាចជួយការពារ និងគោរពអធិបតេយ្យភាពដែនដីរបស់រដ្ឋផងដែរ។

គោលការណ៍នេះ មិនអាចចាត់ថាជាវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិជាសាកលបានឡើយក្នុងពេលបច្ចុប្បន្ននេះ ដោយសារ មានរដ្ឋមួយចំនួននៅក្នុងតំបន់ចំនួនពីរប៉ុណ្ណោះទទួលស្គាល់។ មិនមាន សន្ធិសញ្ញាណាមួយចែងពីគោលការណ៍នេះឡើយ។ ការអនុវត្តគោលការណ៍នេះ មិនដាច់ខាតទេ ពីព្រោះរដ្ឋ ដែលពាក់ព័ន្ធ អាចឯកភាពលើការសើរើព្រំដែន។[33] គោលការណ៍នេះមិនអាចលុបលើ នូវសិទ្ធិស្វ័យសម្រេច ដែលត្រូវបានចាត់ថា ជាវិធានច្បាប់អន្តរជាតិមានលំដាប់ខ្ពស់ជាងគេ (*Jus Cogens*) [34] ដែលការអនុវត្ត

---

[31] Case concerning the frontier dispute (*Burkina Faso/Republic of Mali*), judgment of 22 December 1986, ICJ Reports, p. 172.

[32] Shaw, IL, *supra* note 1, p. 526; *Burkina Faso/Republic of Mali*, *supra* note 31, pp. 554, 565.

[33] Shaw, IL, *supra* note 1, p. 526.

[34] Halim Morris, Self-Determination: An Affirmative Right or Mere Rhetoric? 4 ILSA j. Int'l & Comp. L. 204 (1997). ICJ, East Timor (*Portugal v. Australia*), 1995 ICJ Reports, p. 102 (30 June 1995) (ICJ, East Timor); the self-determination produces the *erga omnes* obligation, *see* Helmut, A Concise of the UN, *supra* note 8, p. 380; Legal

សិទ្ធិស្វ័យសម្រេច អាចនាំឲ្យមានការរុះរើព្រំដែនចាស់។ មានឧទាហរណ៍ជាក់ស្តែងជាច្រើន ពាក់ព័ន្ធអំពើការបង្កើតរដ្ឋ ស៊ូដង់ខាងត្បូង និងកូសូវ៉ូ។ សាធារណរដ្ឋស៊ែប ជារដ្ឋបន្តពី សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ក្រោយពីមានជម្លោះក្នុងតំបន់កូសូវ៉ូដែលនាំឲ្យមានការសើរើព្រំដែន។[35]

ជាចុងក្រោយ រដ្ឋអាចនឹងមិនទទួលស្គាល់ សន្ធិសញ្ញាកំណត់ព្រំដែនប្រទេសធ្វើឡើងដោយប្រទេសជាក់អាណានិគម ដោយមានការបង្ខិតបង្ខំ ដែលនាំឲ្យសន្ធិសញ្ញា មិនមានសុពលភាពតាមច្បាប់អន្តរជាតិ។ ដើម្បីធ្វើយ៉ាងនេះបាន រដ្ឋត្រូវបង្ហាញថា វិធានពាក់ព័ន្ធការដាក់ឲ្យសន្ធិសញ្ញាមោឃភាព ចែងក្នុងសន្ធិសញ្ញា ស្តីពី ច្បាប់សន្ធិសញ្ញា ឆ្នាំ ១៩៦៩ ជាវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬ បង្ហាញថាសន្ធិសញ្ញានេះ អាចត្រូវបានអនុវត្តជាក់ថយក្រោយ ដែលអនុវត្តចំពោះ សន្ធិសញ្ញាកំណត់ព្រំដែនធ្វើមុនឆ្នាំ ១៩៦៩។[36] ទោះបីជាយ៉ាងនេះក្តី វានឹងអាចគ្រាន់តែជាគំនិតស្រមើស្រមៃ ពីព្រោះការទាមទារ គឺប្រហែលជាមិនអាចទៅរួចឡើយ ប្រសិនបើមិនមានមូលដ្ឋានផ្លូវច្បាប់រឹងមាំ។

---

Consequences of the Construction of a Wall in the Occupied Palestinian Territory, 2004 ICJ Reports, p. 172 (9 July).

[35] The South Sudan was created, detaching from Sudan, and admitted as the 193 th member of the United Nations on 15 July 2011. Kosovo was recognized as a State by more than 70 States but not yet admitted to the United Nations.

[36] The Vienna Convention on the Law of the Treaties (VCLT), May 23, 1969, 1155 U.N.T.S.331.

## ២.១.១.៣. រដ្ឋបាលគ្រប់គ្រង

រដ្ឋបាលគ្រប់គ្រងគឺ ជាសមាសភាគមួយទៀត សម្រាប់ចាត់អង្គភាពណាមួយថាជារដ្ឋ។ រដ្ឋបាលគ្រប់គ្រង គ្រប់គ្រងលើដែនដី និង ប្រជាជន។ ការគ្រប់គ្រង ត្រូវមានទ្រង់ទ្រាយជាក់លាក់ និង មានការដឹកនាំមានប្រសិទ្ធភាពក្នុងការថែរក្សាសណ្តាប់ធ្នាប់ និង ការប្រមូលពន្ធដារជាដើម។ រដ្ឋ ប៉ាឡេស្ទីន ប្រកាសដោយ អង្គការប៉ាឡេស្ទីន មិនត្រូវបានចាត់ថាជារដ្ឋទេ ដោយសារកង្វះខាតការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើដែនដីពាក់ព័ន្ធ។ បន្ថែមពីលើនេះ អង្គភាពមានសមត្ថភាព ធ្វើសកម្មភាពដោយឯករាជ្យ លើឆាកអន្តរជាតិគ្មានពឹងពាក់លើរដ្ឋដទៃទៀត។ ទោះបីជាយ៉ាងនេះក្តី ការបាត់បង់ការគ្រប់គ្រងដោយប្រសិទ្ធភាព ដោយសារសង្គ្រាមផ្ទៃក្នុង មិននាំឲ្យ រដ្ឋបាត់បង់អត្ថិភាពឡើយ។[37]

ក្រៅពីធាតុផ្សំទាំងបីខាងលើ អ្នកសិក្សាខ្លះ បានស្នើឡើងនូវសមាសភាគមួយបន្ថែមទៀត គឺសិទ្ធិស្វ័យសម្រេច និងការទទួលស្គាល់ជារដ្ឋ។ ទោះបីជាយ៉ាងនេះក្តី ធាតុផ្សំបន្ថែមនេះ មិនត្រូវបានទទួលយកជាទូទៅឡើយ។[38]

រដ្ឋបាលគ្រប់គ្រងយកលំនាំតាមកុម្មុយនីស្ត ឬប្រជាធិបតេយ្យ មិនសំខាន់ទេ។ ទោះបីជាយ៉ាងនេះក្តី ការគ្រប់គ្រង ត្រូវតែសមស្របទទួលយកបានយ៉ាងហោចណាស់ ដោយប្រជាពលរដ្ឋភាគច្រើន ដែលរដ្ឋនោះគ្រប់គ្រង។

[37] Petter Malanczuk, IL, *supra* note 1, p. 77.
[38] Shaw, IL, *supra* note 1, p. 138; Petter Malanczuk, IL, *supra* note 1, p. 80.

## ២.១.២.ការបង្កើតរដ្ឋ និងការទទួលស្គាល់រដ្ឋ

រដ្ឋអាចត្រូវបានបង្កើតឡើងថ្មី ឬ ផ្តាច់ចេញពីរដ្ឋដទៃផ្សេងទៀត។ ការកកើតរដ្ឋថ្មី កម្រនឹងកើតមានឡើងណាស់។ ភាគច្រើននៃការកកើតរដ្ឋថ្មី បានកើតមានឡើងក្រោយសង្គ្រាមលោកលើកទី២[39] ដែលរដ្ឋថ្មីជាច្រើន ត្រូវបានបង្កើត និងផ្តាច់ខ្លួនចេញពី អតីតសហភាពសូវៀត ដូចជារដ្ឋ Montegro។ ករណី របស់ East Timor គឺជាការកកើតរដ្ឋថ្មី តាមរយៈការទាមទារឯករាជ្យភាព និង ផ្អែកលើសិទ្ធិស្វ័យសម្រេច។ ដូចគ្នានេះដែរ ក្នុងករណី ការបង្កើតរដ្ឋ South Sudan។ ករណី Kosovo និង Palestine គឺជារឿងមួយដ៏ចម្រូងចម្រាស ដោយសារបញ្ហាផលប្រយោជន៍នយោបាយ និងកង្វះខាតមូលដ្ឋានច្បាប់អន្តរជាតិគាំទ្រ។

ការបង្កើតរដ្ឋ និងការទទួលស្គាល់រដ្ឋ ជារឿងពីរ មានទំនាក់ទំនងជាមួយគ្នា និងអាស្រ័យលើគ្នាទៅវិញទៅមក។ ការបង្កើតរដ្ឋទៅបាន លុះត្រាមានកម្លាំងជំរុញ ដោយរដ្ឋមួយចំនួន ដែលនេះ អាចត្រូវបានចាត់ថាជាការទទួលស្គាល់ជាមុន ដោយប្រយោល (Pre-recogniztion)។ ក្រោយពេលនោះ រដ្ឋទាំងនោះ ត្រូវបានបង្កើត និងត្រូវបានផ្តល់ការទទួលស្គាល់។

ច្បាប់អន្តរជាតិ មិនទាន់មានគោលការណ៍ ឬវិធានជាក់លាក់ណាមួយនិយាយអំពីការបង្កើតរដ្ឋ ឬការទទួលស្គាល់រដ្ឋទេ។ ការទទួលស្គាល់រដ្ឋណាមួយ គឺជាឆន្ទានុសិទ្ធិរបស់រដ្ឋ។ អាស្រ័យហេតុនេះ សកម្មភាពទទួលស្គាល់រដ្ឋមានភាពខុសប្លែកគ្នាពីរដ្ឋមួយទៅរដ្ឋមួយ និង ជួនកាលមានលក្ខណៈប្រយោល។ ក្នុងករណីខ្លះ គេពិបាកកំណត់ជំហររបស់រដ្ឋណាមួយ ពាក់ព័ន្ធ

[39] Petter Malanczuk, IL, *supra* note 1, p. 28.

ការទទួលស្គាល់រដ្ឋ។ ការទទួលស្គាល់ អាចធ្វើឡើងតាមរយៈលិខិតផ្លូវទូត សាទរអេបអរ ចំពោះការកើតចេញនូវរដ្ឋណាមួយ។ ការដាក់ទូត នៅក្នុងរដ្ឋមួយ ទើបត្រូវបានបង្កើតឡើង ជាតឹកតាងមួយយ៉ាងជាក់លាក់ បង្ហាញថាជាការទទួលស្គាល់រដ្ឋ។ ការណ៍ដែលអង្គការសហប្រជាជាតិ ទទួលឲ្យរដ្ឋថ្មី ធ្វើជាសមាជិករបស់ខ្លួន និងជួយជំរុញឲ្យមានការទទួលស្គាល់រដ្ឋ និងផ្តល់ភាពស្របច្បាប់នៃការបង្កើតរដ្ឋ។ មានការអះអាងថា កាលណារដ្ឋមួយ មានគ្រប់លក្ខណៈសម្បត្តិរួចហើយ គឺក្លាយជារដ្ឋ ដូចនេះមិនទាមទារឲ្យមានការទទួលស្គាល់ឡើយ (Declarative Theory) ។ ការទទួលស្គាល់ មិនមានផលវិបាកអ្វីឡើយក្នុងករណីនេះ។[40] ការអះអាងនេះ ជួបប្រទះនូវការជំទាស់ ដោយសារ ច្បាប់អន្តរជាតិ មានតួនាទី គ្រប់គ្រងលើទំនាក់ទំនងរដ្ឋ និងរដ្ឋ។ រដ្ឋមានភាពស្មើគ្នា និងមានទំនាក់ទំនងខ្សែរាប (Horizental)។ ដូចនេះ ការទទួលស្គាល់ ឬមិនទទួលស្គាល់ដោយរដ្ឋ ពិតជាមានផលវិបាក។ ដូចនេះ រដ្ឋ ត្រូវតែទទួលស្គាល់រដ្ឋ (Constitutive Theory)។ រដ្ឋមួយមិនទទួលស្គាល់អង្គភាពណាមួយថាជារដ្ឋ មានឥទ្ធិពលលើទំនាក់ទំនងរវាងខ្លួន និងរដ្ឋនោះ។ ឧទាហរណ៍ រដ្ឋខ្លះ មិនទទួលស្គាល់កោះតៃវ៉ាន់ ថាជារដ្ឋ នាំឲ្យរដ្ឋនោះ មិនមានទំនាក់ទំនងការទូតជាមួយតៃវ៉ាន់ទេ។ ផ្ទុយទៅវិញ មានទំនាក់ទំនងជាមួយតៃវ៉ាន់ តាមរយៈប្រទេសចិន ដោយសារ រដ្ឋចាត់ទុកចិនតែមួយ ហើយតៃវ៉ាន់ ជាដែនដីរបស់ចិន។

[40] Petter Malanczuk, IL, *supra* note 1, p. 83.

ទោះបីជាយ៉ាងនេះក្តី រដ្ឋដែលមិនទទួលស្គាល់រដ្ឋថ្មីណាមួយ មិនមែនជារដ្ឋនឹងប្រឈមការលំបាក ជាពិសេសក្នុងករណី ដែលរដ្ឋនោះ ត្រូវបានទទួលស្គាល់ដោយរដ្ឋជាច្រើន និង ដោយអង្គការសហប្រជាជាតិ។ ក្នុងករណីខ្លះ សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ តម្រូវឲ្យរដ្ឋ ត្រូវតែបំពេញតាមកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ ចំពោះរដ្ឋដែលខ្លួនមិនទទួលស្គាល់ក្តី។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ តាមរយៈសេចក្តីសម្រេច របស់ខ្លួន អាចបង្ខំ ឲ្យរដ្ឋ ក គោរពអធិបតេយ្យភាពរដ្ឋ ខ ទោះបីជា រដ្ឋ ក មិនទទួលស្គាល់យ៉ាងណាក្តី។

ជាចុងក្រោយ អ្នកសិក្សាស្រាវជ្រាវ គួរកត់សម្គាល់ថា មានភាពខុសគ្នារវាងការទទួលស្គាល់រដ្ឋ និងរដ្ឋាភិបាល។ រដ្ឋមួយ អាចមានរដ្ឋាភិបាលថ្មី តាមមធ្យោបាយហិង្សា។ ការមិនទទួលស្គាល់រដ្ឋាភិបាលថ្មី មិនប៉ះដល់ការទទួលស្គាល់រដ្ឋរួចហើយនោះទេ ពីព្រោះ ការធ្វើបដិវត្តប្តូររដ្ឋាភិបាល មិនបានប៉ះពាល់ដល់ប្រមុខរដ្ឋ ដែលនឹងនាំមិនឲ្យមានការបដិសេធរដ្ឋ។[41]

## ២.១.៤. សិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋ

រដ្ឋជាប្រធាននៃច្បាប់អន្តរជាតិ ដូចនេះរដ្ឋមានសិទ្ធិ និងកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ។ រដ្ឋមានសិទ្ធិស្វ័យការពារខ្លួន ក្នុងនាមជារដ្ឋ (the Inherent Right to Self-Defence)[42] ដែលអង្គភាពដទៃមិនមាន សូម្បីអង្គការ សហ

[41] Petter Malanczuk, IL, *supra* note 1, p. 86.
[42] The United Nations Charter (the UN Charter), Article 51, June 26, 1945, 557 U.N.T.S. 143, *see* Ian Brownlie, Basic Documents in International Law, 5th ed., 2002, p. 2.

ប្រជាជាតិ។ រដ្ឋមានសិទ្ធិ ប្តឹងទារសំណង។ រដ្ឋ អាចនឹងមិនសុំឲ្យរដ្ឋណាមួយ សងសំណង សម្រាប់អំពើរំលោភកាតព្វកិច្ចចំពោះខ្លួន។[43]

ខុសពីបុគ្គល ដែលមានសិទ្ធិខ្លះៗ ជាប្រភេទសិទ្ធិដាច់ខាត (Absolute Right)[44] រដ្ឋពុំមានសិទ្ធិដាច់ខាតឡើយ។ ទាញចេញពីនេះ រដ្ឋមិនមាន កាតព្វកិច្ចដាច់ខាតក្នុងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ។ ឧទាហរណ៍ រដ្ឋ មិនមាន កាតព្វកិច្ចដាច់ខាត ក្នុងការធ្វើបត្យាប័នឡើយ (Obligation to Extradite)។ រដ្ឋ មានកាតព្វកិច្ចដាច់ខាតតម្រូវ ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ[45] ដែលកាតព្វកិច្ចនេះ មិនមានប្រភពពីសិទ្ធិ ដែលរដ្ឋមានឡើយ។ ជាទូទៅ មិនមានការតម្រូវឲ្យមានកាតព្វកិច្ចដាច់ខាតរបស់រដ្ឋ ពីព្រោះ រដ្ឋ មានអធិបតេយ្យភាព ដែលមិនគួរត្រូវបានបង្ខំដាច់ខាតឲ្យចាត់វិធានការណា មួយឡើយ។ ក្នុងទំនាក់ទំនងរវាងរដ្ឋ និង បុគ្គល ជាពិសេសក្នុងវិស័យសិទ្ធិ មនុស្ស រដ្ឋមានកាតព្វកិច្ចដាច់ខាត ដែលរដ្ឋត្រូវបំពេញ ដើម្បីធានានូវសិទ្ធិ ដាច់ខាតរបស់បុគ្គល ឧទាហរណ៍ សិទ្ធិរួចផុតពីអំពើទារុណកម្ម (Absolute Right to Freedom from Torture)។

កាតព្វកិច្ច ដែលរដ្ឋមាន មានច្រើនប្រភេទ។ កាតព្វកិច្ច ក្រោមសន្ធិសញ្ញា ឬក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ វាអាចជាកាតព្វកិច្ច ដែលរដ្ឋមាន តែម្នាក់ឯង ឬកាតព្វកិច្ចរួម ក្នុងការឆ្លើយតបចំពោះអំពើរំលោភកាតព្វកិច្ចណា

---

[43] James Crawford, the International Law Commission's Articles on State Responsibility (James, Drafted Articles), 2002, p. 266.

[44] Please *see* the Chapter on Human Rights below.

[45] Obligation Imposed by the United Nations Security Council pursuant to Chapter VII of the United Nations Charter.

មួយ (*Erga Omnes* Obligation)[46]។ កាតព្វកិច្ច អាចជាកាតព្វកិច្ចដំបូង (Primary Obligation[47]) ឬកាតព្វកិច្ចទាញចេញពីការខកខានមិនបានបំពេញកាតព្វកិច្ចចម្បង។ ឧទាហរណ៍ រដ្ឋមានកាតព្វកិច្ចសងសំណង ចំពោះការខកខាន ដែលខ្លួនមិនបានបំពេញតាមកាតព្វកិច្ចណាមួយ ដែលជាលទ្ធផល ធ្វើឲ្យរដ្ឋមួយផ្សេងទៀតទទួលរងនូវផលប៉ះពាល់។

កាតព្វកិច្ច ជាប្រភេទទង្វើ (Obligation of Conduct) ដូចជា ការតម្រូវឲ្យធ្វើច្បាប់ ឬជាកាតព្វកិច្ចលទ្ធផល (Obligation of Result) ដូចជាការផ្តល់នូវដំណោះស្រាយមានប្រសិទ្ធភាព ។ រដ្ឋមានកាតព្វកិច្ច ផ្តល់សំណងដល់ការខូតខាតដល់បុគ្គល ដែលសិទ្ធិរបស់ពួកគេត្រូវបានបំពារបំពាន ដោយអាជ្ញាធររបស់រដ្ឋ។

រដ្ឋ មានជម្រើស ក្នុងការប្រកាន់យកនូវវិធានការណាមួយសម្រាប់អនុវត្តកាតព្វកិច្ច។ ឧទាហរណ៍ រដ្ឋបើមិនចង់កាត់ទោសឧក្រិដ្ឋជនណាមួយនៅក្នុងដែនដីរបស់ខ្លួន រដ្ឋ អាចធ្វើបត្យាប័នបុគ្គលទៅប្រទេសផ្សេង ដែលមាន

[46] The Institute of International Law, Resolution on Obligations *Erga Omnes* in International (www.idi-iil.org/idiE/resolutionE/2005), 2005, Article 2; Alfred P. Rubin, *Actio Popularis, Jus Cogens and Offenses Erga Omnes* (Afred, *Actio Popularis*), 35 (2) New England Law Review, 2001, p. 227; Bruno Simma, *does the UN charter provide an adequate legal basis for individual or collective responses to violations of obilgations erga omnes*? in Jost Delbruck, the future of international law enforcement, New scenarios, new law? 1993; Giorgio Gaja, obligations *Erga Omnes*, international crimes and Jus cogens: a tentative analysis of three related concepts, 1989.

[47] The Genocide Convention requires State to prosecute or extradite genocider found in its territories; this is primary obligation; Dan Kuwali, the Responsibility to Protect: Implementation of Article 4(h) intervention, 2011, p. 332

បំណងកាត់ទោស។ ជាចុងក្រោយ កាតព្វកិច្ចនីមួយៗ មានទំនាក់ទំនងជាមួយគ្នា (Primary and Secondary Obligation)។

## ២.២. អង្គការអន្តរជាតិ

អង្គការអន្តរជាតិ បានដើរតួសំខាន់ផងដែរ នៅក្នុងទំនាក់ទំនងអន្តរជាតិ។ សកម្មភាពរបស់ពួកគេ បានជះឥទ្ធិពលដល់ការរៀបចំ និងអភិវឌ្ឍន៍ច្បាប់អន្តរជាតិ តាមរយៈការចូលរួម ឬជំរុញបង្កើតវិធានច្បាប់អន្តរជាតិជាដើម។[48] នេះ បានតម្រូវឲ្យអង្គការមានសិទ្ធិ និង កាតព្វកិច្ចអន្តរជាតិ ដែលជាលក្ខណវិនិច្ឆ័យនៃស្ថាប័ន ដែលមានឋានៈជាប្រធានច្បាប់អន្តរជាតិ។ អង្គការអន្តរជាតិ មានសិទ្ធិក្នុងការធ្វើ និង ដាក់ពាក្យបណ្តឹង ទារសំណងជំងឺចិត្តសម្រាប់មន្ត្រីរបស់ខ្លួន ដែលជាជនរងគ្រោះ នៃអំពើរំលោភច្បាប់អន្តរជាតិដោយរដ្ឋ ទោះបី ជនរងគ្រោះជាជនជាតិរបស់រដ្ឋ ដែលប្រព្រឹត្តល្មើសក្តី។[49] ទន្ទឹមនឹងនេះ អង្គការអន្តរជាតិ ដូចជា អង្គការសហប្រជាជាតិ ត្រូវគោរពច្បាប់អន្តរជាតិ ពីព្រោះច្បាប់ទាំងនេះ ធ្វើឡើងដោយរដ្ឋ ឬដោយសារអង្គការអន្តរជាតិ ដែលត្រូវគោរព អនុលោមតាមគោលការណ៍ នីតិរដ្ឋអន្តរជាតិ (International Rule of Law)[50] និងដើម្បីភាពស្របច្បាប់ របស់កិច្ចការងាររបស់ខ្លួន ប្រសិនមិនដូចនេះទេ ខ្លួនអាចបាត់បង់នូវឋានៈជានីតិបុគ្គលអន្តរជាតិសាធារណៈ (International Personality)។

[48] The World Health Organization through initation of request of the advisory opinion from the international court of justice helps develop norms regarding use of nuclear weapon.

[49] ICJ, Reparation case, ICJ Report 1949, p. 174, 179.

[50] Tom Bingham, the Rule of Law, 2010, p. 110.

ខុសពីរូបវន្តបុគ្គល អង្គការអន្តរជាតិ មានឋានៈជានីតិបុគ្គលអន្តរជាតិសាធារណៈ។ តាមរយៈនេះ អង្គការអន្តរជាតិ មានសិទ្ធិធ្វើការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយរដ្ឋ។ ឧទាហរណ៍ អង្គការសហប្រជាជាតិ បានធ្វើកិច្ចព្រមព្រៀង ស្តីពី ការបង្កើតសាលាក្តី កាត់ទោសមេដឹកនាំខ្មែរក្រហម ជាមួយកម្ពុជា និងមានសិទ្ធិប្តឹងទៅតុលាការអន្តរជាតិ ដោយឯកឯង ដោយគ្មានការទាមទារការព្រមព្រៀងជាមុនពីរដ្ឋជាសមាជិក ។[51]

ការពិភាក្សាលម្អិតអំពី អង្គការអន្តរជាតិ និងរូបវន្តបុគ្គល មាននៅក្នុងទំព័របន្ទាប់។

## ២.៣. បុគ្គល

ការទទួលស្គាល់ថា បុគ្គលជាប្រធាននៃច្បាប់អន្តរជាតិ[52] ទើបកើតមាននៅក្រោយសង្គ្រាមលោកលើកទី១ និងទទួលស្គាល់កាន់តែទូលំទូលាយក្រោយសង្គ្រាមលោកលើកទី ២។

អ្នកសិក្សាខ្លះ បានជ្រាបរួចមកហើយ ក្នុងកាលសម័យមុន រូបវន្តបុគ្គល ត្រូវបានចាត់ថាជា កម្មវត្ថុនៃច្បាប់ (Object of Law)[53]។ តាមន័យនេះ និងនិយាយជាសាមញ្ញ បុគ្គល ដូចជា វត្ថុដែលអាចលក់ ឬដោះដូរបាន។ នេះអាចជាមូលដ្ឋានស្ថិតនៅពីក្រោយ ការជួញដូរទាសករ (Slavery) ស្បែក

[51] ICJ, Reparation, *supra* note 49, pp. 14-15.
[52] Thomas, PIL, *supra* note 5, p. 2.
[53] Geneva Slavery Convention, 26 September 1926, at www2.ohchr.org/English/law/slavery.htm; Shaw, IL, *supra* note 1, p. 258; "object of law" is contrary to "subject of law", *see* Laurence Burgorgue, the Inter-American Court of Human Rights, Case Law and Commentary, 2011, p. 397.

ខ្មៅ។ ទោះបីជាយ៉ាងនេះក្តី មនុស្សលោក មិនបានអត់ឱនឲ្យមានអំពើអមនុស្សធម៌នេះទេ។ ចលនាលុបបំបាត់ទាសកម្ម ត្រូវបានបង្កើតឡើង ដែលចុងបញ្ចប់នាំឲ្យមាន ឯកសារជាអន្តរជាតិលុបបំបាត់អំពើនេះ។[54]

បន្ទាប់មកបុគ្គល ត្រូវបានចាត់ថា មានសិទ្ធិសេរីភាព។ ឯកសារជាច្រើនជាពិសេសពាក់ព័ន្ធជាមួយសិទ្ធិមនុស្ស ត្រូវបានបង្កើតឡើង ជាពិសេសក្រោយសង្គ្រាមលោកលើកទី២ ដែលក្នុងនោះ សិទ្ធិជាច្រើនប្រភេទរបស់បុគ្គល ត្រូវបានចែងលម្អិត។ ទន្ទឹមនឹងនេះ បុគ្គល ក៏មានកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិផងដែរ ទោះបីជាអ្វីទៅជាកាតព្វកិច្ច នៅមិនទាន់ត្រូវបានសរសេរលម្អិតជាក់លាក់នៅឡើយ។ កាតព្វកិច្ចគោរពច្បាប់អន្តរជាតិ គឺជាឧទាហរណ៍មួយ ក្នុងចំណោមកាតព្វកិច្ចទាំងឡាយ។ ប្រសិនបើ បុគ្គល មិនគោរពកាតព្វកិច្ចទេ បុគ្គលនឹងត្រូវទទួលខុសត្រូវ។ ឧទាហរណ៍ ច្បាប់អន្តរជាតិ បានហាមឃាត់អំពើប្រល័យពូជសាសន៍។ បើបុគ្គលប្រព្រឹត្ត ឬចូលរួមប្រព្រឹត្ត គាត់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ មកដល់ពេលនេះ មានតុលាការអន្តរជាតិជាច្រើនត្រូវបានបង្កើតឡើង ដើម្បីកាត់ទោសបុគ្គល ដែលល្មើសច្បាប់អន្តរជាតិ។ តុលាការទាំងនោះ រាប់បញ្ចូលតុលាការនៅទីក្រុង Nuremburg ក្នុងប្រទេសអាឡឺម៉ង់ បង្កើតឡើងក្រោយសង្គ្រាមលោកលើកទី២។[55]

បុគ្គល មិនអាចចរចា និងចុះហត្ថលេខាលើសន្ធិសញ្ញាទេ លើកលែងក្នុងឋានៈជាតំណាងរបស់រដ្ឋ។ ដូចគ្នានេះដែរ បុគ្គល មិនអាចប្តឹងទៅតុលាការ

[54] Petter Malanczuk, IL, *supra* note 1, p. 21.
[55] Antonio Cassese, the Oxford Companion to International Criminal Justice (Antonio, the Oxford), 2009, p. 441.

អន្តរជាតិ ដោយគ្មានរដ្ឋផ្តល់ការព្រមព្រៀងជាមុនឡើយ។ ជាក់ស្តែង បុគ្គលអាចប្តឹងទៅ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានបង្កើតឡើងតាមកតិកាសញ្ញា ស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ លុះត្រារដ្ឋជាភាគីរបស់កតិកាសញ្ញាចូលភាគីពិធីសារបន្ថែមលើកតិកាសញ្ញានេះ ទើបគណៈកម្មាធិការអាចទទួល និងពិនិត្យពាក្យបណ្តឹងរបស់បុគ្គលបាន។[56]

[56] The International Covenant on Civil and Political Rights (the ICCPR), 16 Dec. 1966, 999 U.N.T.S. 171; the Optional Protocol to the ICCPR, 16 December 1966, 999 UNTS 171, Art.1.

# ជំពូក ៣
# ប្រភពនៃច្បាប់អន្តរជាតិសាធារណៈ

ប្រភពនៃច្បាប់អន្តរជាតិ ជាវិធាន ដែលទាញចេញពីនេះ ច្បាប់អន្តរជាតិត្រូវបានបង្កើតឡើង។[57] កាលណា អ្នកស្រាវជ្រាវបរិយាយអំពីប្រភពនៃច្បាប់អន្តរជាតិ ពួកគេច្រើនយោងដល់មាត្រា ៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ។ មាត្រានេះ ចែងដោយប្រយោលថា ប្រភពនៃច្បាប់អន្តរជាតិមានសន្ធិសញ្ញា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ (ចទអ)។[58] មានសំណួរជាច្រើន ពាក់ព័ន្ធជាមួយនឹងប្រភពនៃច្បាប់អន្តរជាតិ ដូចជាប្រភេទនៃប្រភពឋានានុក្រមនៃប្រភពជាដើម។ ផ្នែកខាងក្រោមនឹងស្រាយបំភ្លឺបញ្ហាទាំងនេះ។

## ៣.១. ច្បាប់ទំនៀមទម្លាប់អន្តរជាតិ (ចទអ)
### ៣.១.១. និយមន័យ

*ចទអ* កើតចេញពីបណ្តុំនៃការអនុវត្តរបស់រដ្ឋភាគច្រើន បង្កប់ន័យជាកាតព្វកិច្ច ដែលនាំឲ្យមានការអនុវត្តបែបនោះ។[59] មាត្រាទី ៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ដោយប្រយោល បានផ្តល់សញ្ញាណអំពី ចទអ ថាៈ *ទំនៀមទម្លាប់អន្តរជាតិ ជាភស្តុតាងនៃការអនុវត្តជាទូទៅ ដែលត្រូវបានចាត់ទុកជាច្បាប់*។[60]

[57] Birgit Schlutter, Developments in Customary International Law (Birgit, CIL), 2010, p. 11.
[58] The Statute of the International Court of Justice (the Statute of ICJ), Art. 38, *see* Ian Brownlie, Basic Documents, *supra* note 42, p. 312.
[59] Thomas, PIL, *supra* note 5, p. 22.
[60] The Statute of ICJ, *supra* note 58, Art.38.

### ៣.១.២. ធាតុផ្សំរបស់ ចទអ

ធាតុផ្សំនៃ *ចទអ* ជាបញ្ហាមួយក្នុងចំណោមបញ្ហាស្មុគស្មាញ[61] ដោយសារ ធាតុផ្សំ មិនត្រូវបានចែងយ៉ាងជាក់លាក់ក្នុងសន្ធិសញ្ញា ហើយនាំឲ្យមានការយល់ឃើញផ្អែក ទៅតាមប្រយោជន៍ក្នុងក្តីក្តាំអន្តរជាតិរបស់រដ្ឋ ដែលកើតមានឡើង។ នៅក្នុងពេលដែល វិធានច្បាប់អន្តរជាតិសិទ្ធិមនុស្ស មិនទាន់មានការរីកចម្រើន ធាតុផ្សំនៃ *ចទអ* មានលក្ខណៈចង្អៀត ក៏ប៉ុន្តែ បច្ចុប្បន្ននេះ ពាក់ព័ន្ធជាពិសេសជាមួយនឹងសិទ្ធិមនុស្ស ធាតុផ្សំ *ចទអ* ក្នុងន័យចង្អៀត ត្រូវបានបដិសេធដោយតុលាការអន្តរជាតិខ្លះ។[62] ទោះបីជាយ៉ាងនេះក្តី ធាតុផ្សំជារួមគឺ ការអនុវត្តរបស់រដ្ឋ (Practice) និងជំនឿផ្លូវច្បាប់ដែលនាំឲ្យអនុវត្តតាមវិធានណាមួយ (*Opinio Juris*[63]/ Legal Implication[64]) ។ ធាតុផ្សំទាំងពីរនេះ ត្រូវបានបកស្រាយយ៉ាងចង្អៀត និងទូលាយ ដូចដែលមានបង្ហាញខាងក្រោម។

#### ៣.១.២.១. ធាតុផ្សំក្នុងន័យចង្អៀត[65]

ដូចគ្នាក្នុងន័យទូលាយ សម្រាប់ធាតុផ្សំចង្អៀត ការអនុវត្តរបស់រដ្ឋ ត្រូវតែជាទូទៅ(General Practice) តែមិនចាំបាច់ការអនុវត្តជាសាកល (Universal Practice) ដែលតម្រូវឲ្យរដ្ឋទាំងអស់នៅក្នុងពិភពលោក ប្រកាន់យកការ

---

[61] Anthea Roberts, *Traditional and Modern Approches to Customary International Law: a Reconciliation* (Anthea, Approaches to CIL), in Henry J. Steiner, International Human Rights in Context, 3rd ed., 2007, p. 162.
[62] Birgit, CIL, *supra* note 57, p. 157.
[63] Birgit , CIL, *supra* note 57, p. 11.
[64] Kristin Nadasdy Wuerffel, *Note: Discriminating Among Rights? A Nation's Legislating a Hierarchy of Human Rights in the Context of Interntional Human Rights Customary Law*, 33 Valparaiso University Law Review, 1998, pp. 385-386.
[65] Anthea Roberts, Approaches to CIL, *supra* note 61, p. 162.

អនុវត្តណាមួយនោះឡើយ។[66] ការមិនតម្រូវដូចនេះ ជាការសមហេតុផល ពីព្រោះថាទម្រាំមានការអនុវត្តរបស់រដ្ឋមួយ រហូតឈានទៅដល់ មានការទទួលយក ឬមានការអនុវត្តដោយរដ្ឋទាំងអស់ក្នុងសាកលលោក ត្រូវឆ្លងកាត់ពេលវេលាដ៏យូរអង្វែង។ ដំណើរការបង្កើត *ចទអ* របៀបនេះ នឹងមិនងាយបង្កើតបាននូវ *ចទអ* ឡើយ។ ជាលទ្ធផល ពិភពលោក អាចជួបប្រទះនូវកង្វះខាតច្បាប់សម្រាប់ប្រើប្រាស់។ ភាពសមហេតុផលមួយទៀត នៃការមិនទាមទារនូវការអនុវត្តជាសាកល ដោយសារ វាមិនអាចធ្វើទៅរួចបានឡើយ ដែលរដ្ឋទាំងអស់ នៅក្នុងពិភពលោក ឯកភាពគ្នាជាឯកច្ឆន្ទ ប្រកាន់យកការអនុវត្តណាមួយ។

ការអនុវត្តជាទូទៅ ត្រូវបានចាត់ថា មានកើតឡើង ប្រសិនបើ រដ្ឋភាគច្រើនក្នុងតំបន់នីមួយៗក្នុងពិភពលោក ប្រកាន់យកការអនុវត្តណាមួយនោះ។ ការអនុវត្តដោយរដ្ឋក្នុងន័យនេះ ជាពិសេសដោយរដ្ឋ ដែលពាក់ព័ន្ធក្នុងវិវាទអន្តរជាតិ ត្រូវមានភាពស៊ីសង្វាក់គ្នា កើតមានក្នុងអំឡុងពេល វេលាយូរណាមួយនោះ។ ឧទាហរណ៍ ប្រសិន អាជ្ញាធររបស់រដ្ឋមួយ ពេលចាប់បាន ឧក្រិដ្ឋជនជាជនបរទេស តែងតែជូនដំណឹងដល់រដ្ឋរបស់ជននោះ (នេះវាជាការអនុវត្តជាក់ស្តែង) ទង្វើជាដដែលនេះ ត្រូវប្រកាន់យកក្នុងរយៈពេលវេលាមួយដែលគ្មានទង្វើផ្ទុយត្រូវបានកត់សម្គាល់ ទើបអាចត្រូវបានចាត់ ទុកជាការអនុវត្ត ក្នុងន័យ *ចទអ*។ ដោយសារមានការតម្រូវឲ្យមានការអនុវត្តដោយរដ្ឋភាគច្រើន ចង់មិនចង់ វាទាមទារឲ្យការអនុវត្តឆ្លងកាត់នូវពេលវេលាមួយដ៏

[66] Thomas, PIL, *supra* note 5, p. 23.

យូរ។[67] និយាយម្យ៉ាងទៀត ទម្រាំការអនុវត្តណាមួយរបស់រដ្ឋ ត្រូវបានគេចាត់ថាជា *ចទអ* នោះវាទាមទារ នូវពេលវេលាដ៏យូរ។

ទោះបីជាមានការអនុវត្តរបស់រដ្ឋភាគច្រើនរួចហើយក្តី តាមទ្រឹស្តី គេនៅមិនទាន់អាចចាត់ថាជា *ចទអ* បានឡើយ ដោយសារមិនទាន់បានបំពេញនូវធាតុផ្សំទី២របស់ *ចទអ* នោះគឺ ជំនឿផ្លូវច្បាប់ ដែលនាំឲ្យមានការអនុវត្តតាម។ ប្រសិនបើគ្មានធាតុផ្សំទី២នេះទេ ការអនុវត្តរបស់រដ្ឋ គ្រាន់តែជាការអនុវត្តធម្មតា។ ពេលខ្លះ វាគ្រាន់តែជាទង្វើសម្តែងការគួរសម (Coursty)[68] ដែលទង្វើណាមួយ ត្រូវបានធ្វើតាមឆន្ទៈផ្ទាល់ខ្លួនរបស់រដ្ឋ ដោយគ្មានវិធានណាមួយចាប់បង្ខំឲ្យធ្វើយ៉ាងដូចនោះ។ ម្យ៉ាងទៀត ទោះបីជារដ្ឋមិនបាន ធ្វើទង្វើនោះ ក៏តុលាការ មិនអាចចោទថា រដ្ឋបានរំលោភច្បាប់អន្តរជាតិ។ ឧទាហរណ៍ ប៉ូលីសរបស់រដ្ឋ *ក* មិនផាកពិន័យឡានរបស់អ្នកការទូតអន្តរជាតិ ដែលចតនៅក្នុងកន្លែងហាមចត។ នេះគឺជាការអនុវត្តរបស់ភ្នាក់ងាររដ្ឋ ដែលគេអាចចាត់ថា ជាការអនុវត្តរបស់រដ្ឋ។ ពុំមានច្បាប់ណាមួយ ចែងមិនឲ្យផាកពិន័យ ឡានអ្នកការទូត ដែលចតក្នុងកន្លែងហាមចតទេ តែអាចមានច្បាប់ឲ្យផាកពិន័យប្រជាជនសាមញ្ញ ដែលចតក្នុងទីកន្លែង ហាមឃាត់នោះ។ ប៉ូលីសមិនបានផាកពិន័យអ្នកការទូត អាចកើតពីឆន្ទៈរបស់គាត់ ឬមកពីមានការណែនាំពីរដ្ឋអំណាចថ្នាក់លើ កុំឲ្យធ្វើដូច្នេះ ដើម្បីសម្តែងការគួរសម ឬដើម្បីកុំឲ្យមានការស្ទះដំណើររបស់អ្នកការទូត ឬដោយសារមានការប្រព្រឹត្តដូចនេះទៅវិញទៅមក (Reciprocity) ចំពោះអ្នកការទូតរបស់រដ្ឋ *ក* ដោយប៉ូលីសបរទេស។ ជាសរុប ការអនុវត្តដូចនេះ មិនអាចចាត់ថាជា *ចទអ* ឡើយ។

[67] Thomas, PIL, *supra* note 5, p. 22.
[68] Thomas, PIL, *supra* note 5, p. 21.

ឧទាហរណ៍ផ្សេងទៀត កប៉ាល់ ដោតទង់ជាតិរដ្ឋមួយ ពេលបើកដល់ដែនសមុទ្រអន្តរជាតិ (High Sea) ជួនកាលបង្ហូតទង់ជាតិខ្លួនទម្លាក់ចុះ។ ទង្វើនេះ គ្មានច្បាប់អន្តរជាតិណាមួយ ចាប់បង្ខំឲ្យរដ្ឋធ្វើដូច្នោះទេ ហើយបើរដ្ឋ មិនបង្ហូតទម្លាក់ទង់ជាតិខ្លួន ក៏គ្មានខុសនឹងច្បាប់អ្វីដែរ។ ទង្វើបង្ហូតទង់ជាតិអាចកើតពីឆន្ទៈរបស់រដ្ឋ ដែលគិតថា វាជាសមុទ្រអន្តរជាតិ ជាសមុទ្ររួម ដែលប្រើដោយរដ្ឋទាំងអស់។ នេះជាឧទាហរណ៍ ស្តីពី ការអនុវត្តរបស់រដ្ឋ ដែលមិនស្ថិតក្នុងន័យ *ចទអ។ ជាសង្ខេប តាមន័យជាតុផ្សំចង្អៀត វាទាមទារឲ្យមានការអនុវត្តជាក់ស្តែង និង ជំនឿផ្លូវច្បាប់ ដែលតម្រូវឲ្យមានការអនុវត្តនោះ ហើយជាតុផ្សំទាំងពីរ ត្រូវតែដាច់ដោយឡែកពីគ្នា។*[69]

### ៣.១.២.២. ធាតុផ្សំក្នុងន័យទូលាយ

ជាតុផ្សំក្នុងន័យទូលាយ ដូចបាននិយាយក្នុងទំព័រខាងលើ មានជាតុផ្សំពីរដូចគ្នា តែវាមានភាពខុសគ្នានឹងជាតុផ្សំក្នុងន័យចង្អៀត ពីព្រោះថា ការអនុវត្តមិនចាំបាច់ជាការអនុវត្តជាក់ស្តែង ដែលអាចមើលឃើញជាក់លាក់ ដូចជាការមិនផាកពិន័យឡើយ។ ការអនុវត្ត ត្រូវបានគេមើលឃើញក្នុងទម្រង់ផ្សេង។ ឧទាហរណ៍ ការចូលរួមបោះឆ្នោត គាំទ្រសេចក្តីថ្លែងការណ៍ ឬ សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិដោយរដ្ឋ ត្រូវបានចាត់ថាជាការអនុវត្តរបស់រដ្ឋ។[70] ការប្រកាន់ជំហរនេះ ធ្វើឲ្យការញែកគ្នាដាច់រវាងការអនុវត្ត និងជំនឿផ្លូវច្បាប់មិនដាច់ស្រឡះ។ សេចក្តីថ្លែងការណ៍មួយ ដែលរដ្ឋ បានចូលរួមគាំទ្រ ត្រូវបានគេចាត់ថា ជាការអនុវត្តរបស់រដ្ឋផង និងថាបង្ហាញ

69 Birgit, CIL, *supra* note 57, pp. 17-18.
70 Anthea, Approches to CIL, *supra* note 61, p. 162.

ជំនឿផ្លូវច្បាប់ដែលនាំឲ្យមានការអនុវត្តផង។[71] ជំហរនេះ ត្រូវបានជំទាស់ដោយរដ្ឋ និងអ្នកស្រាវជ្រាវច្បាប់អន្តរជាតិមួយចំនួន ដែលចង់បានជាតុផ្សំក្នុងន័យចង្អៀត។[72] វាអាចជាការត្រឹមត្រូវម្យ៉ាង ពីព្រោះ ប្រសិន បើគេចាត់ថាការគាំទ្រសេចក្តីថ្លែងការណ៍ណាមួយ ជាការអនុវត្ត ដែលអាចចាត់ថាជា *ចទអ ចទអ* អាចនឹងត្រូវបានបង្កើតដោយរដ្ឋ តាមរយៈអង្គការសហប្រជាជាតិ ជាច្រើនក្នុងរយៈពេលដ៏ខ្លី ហើយជាផលវិបាក គឺវិធាន *ចទអ* ពិតជាមិនសូវមានឥទ្ធិពលដល់រដ្ឋឡើយ។ ផ្ទុយទៅវិញ ការប្រកាន់យកជាតុផ្សំក្នុងន័យចង្អៀត (ការអនុវត្តរបស់រដ្ឋ) គេនឹងពិបាក នឹងចាត់វិធានច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិបានឡើយ ដោយសារការចូលជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សរបស់រដ្ឋខ្លះ គ្រាន់ជាការសម្ដែង[73] ឬការចូលរួមបោះឆ្នោតគាំទ្រសេចក្តីថ្លែងការណ៍ណាមួយ ជារឿងពាក់ព័ន្ធជាមួយ ផលប្រយោជន៍នយោបាយ។ រដ្ឋចូលរួមគាំទ្រសេចក្តីថ្លែងការណ៍ និងចូលជាភាគីសន្ធិសញ្ញា ត្រូវគោរពតាមកាតព្វកិច្ចរបស់សន្ធិសញ្ញា តែជាក់ស្តែងអាជ្ញាធររបស់ខ្លួនបំពាន កាតព្វកិច្ចទៅវិញ។ ការមិនអនុវត្តតាមខ្លឹមសារកាតព្វកិច្ច ឬពេលខ្លះគោរព វាមិនមែនជាការអនុវត្តស៊ីសង្វាក់គ្នា ដែលទាមទារដើម្បីឲ្យការអនុវត្តមួយក្លាយជា *ចទអ* ឡើយ។ ការជំរុញឲ្យប្រកាន់យកជាតុផ្សំក្នុងន័យទូលាយនៃ *ចទអ* ដែលអាចនាំឲ្យកើតជា *ចទអ* យ៉ាងឆាប់រហ័ស និងមានបរិមាណច្រើន អាចមកពីការខ្វះខាតវិធានច្បាប់អន្តរជាតិ ព្រោះសន្ធិសញ្ញានីមួយៗ កម្រនឹងត្រូវបានបង្កើតឡើងណាស់ ហើយទម្រាំអនុម័ត

[71] Continental Shelf Case (*Lybyan Arab Jamahiriya v. Malta*), ICJ, judgement, 3 June 1985, ICJ Reports (1985), at 29-30; ICRC, Customary International Humanitarian Law (ICRC, Customary), 2007, Vol. 1, Xl.
[72] Anthony A. D'Amato, the Concept of Custom in International Law, 1971, p. 88.
[73] Birgit, CIL, *supra* note 57, p. 4.

ចេញជាសន្ធិសញ្ញាណាមួយ ត្រូវការចំណាយពេលវេលាយូរ ។ ទោះបីជាយ៉ាងនេះក្តី ជម្រើសកណ្តាលមួយរវាង ធាតុផ្សំក្នុងន័យចង្អៀត និងទូលាយ គួរត្រូវបានគេពិចារណា ដើម្បីឲ្យរដ្ឋភាគច្រើនទទួលយកបាន ស្របពេលគ្នានេះ អាចបំពេញបាននូវភាពមិនគ្រប់គ្រាន់របស់ច្បាប់អន្តរជាតិ (ប្រសិនបើមាន) និងទប់មិនឲ្យ *ចទអ* កើតច្រើនពេក ដែលនាំឲ្យខូចឥទ្ធិពលរបស់វិធានប្រភេទនេះ។ ដូច្នេះការទាញចេញជាការសន្និដ្ឋាន ថាវិធានណាមួយជាវិធាន *ចទអ* ត្រូវតែផ្អែកទៅតាមករណីជាក់ស្តែងនីមួយៗ។ ប្រសិនបើជាវិធានមួយសំខាន់ចាំបាច់ ហើយដែលពុំមានវិធានណាមួយជំនួសបាន ជាតុផ្សំក្នុងន័យទូលាយ គួរតែត្រូវបានយកមកប្រើប្រាស់ ដើម្បីទាញការសន្និដ្ឋានថា វិធានណាមួយនោះជា *ចទអ* ឬមិនទាន់។

### ៣.១.៣. ប្រភេទនៃ ចទអ

*ចទអ* អាចត្រូវបានគេចាត់ជាពីរ ឬបីប្រភេទ។ ទោះបីជាយ៉ាងនេះក្តីវាគ្រាន់តែជាទ្រឹស្តីតែប៉ុណ្ណោះ។ ផ្នែកនេះ នឹងពិនិត្យមើលប្រភេទនីមួយៗ ជាលម្អិត និងព្យាយាមដោះស្រាយបញ្ហាការទំនាស់រវាង *ចទអ* ដែលស្ថិតនៅក្នុងប្រភេទទាំងនេះ។

#### ៣.១.៣.១. ចទអ កម្រិតសាកល និងតំបន់

ប្រភេទនៃ *ចទអ* ទាំងពីរត្រូវតែមានជាតុផ្សំទាំងពីរខាងលើ។ វាអាចមានភាពខុសគ្នានូវបរិមាណនៃចំនួនរដ្ឋ ដែលប្រកាន់យកការអនុវត្តណាមួយនោះ។ ក្នុងករណី *ចទអ* កម្រិតសាកល (Universal Customary International Law) ការអនុវត្តរបស់រដ្ឋទូទៅក្នុងពិភពលោក ត្រូវបានតម្រូវឲ្យមាន។ ការហាមឃាត់អំពើប្រល័យពូជសាសន៍ គឺជាឧទាហរណ៍មួយ នៃ

*ចទអ* កម្រិតសាកល ដោយសារ រដ្ឋស្ទើរទូទាំងពិភពលោក ទទួលយកការហាមឃាត់អំពើប្រល័យពូជសាសន៍។[74] ផ្ទុយទៅវិញ *ចទអ* កម្រិតតំបន់តម្រូវឲ្យមានការអនុវត្ត ក្នុងវិស័យណាមួយ របស់រដ្ឋភាគីច្រើនក្នុងតំបន់ដែលពាក់ព័ន្ធ។ ការផ្តល់សិទ្ធិជ្រកកោន ដល់ជនបរទេស ដែលចូលមកក្នុងបរិវេណស្ថានទូតនៅក្រៅប្រទេស អនុវត្តដោយរដ្ឋមួយចំនួន នៅក្នុងតំបន់ Latin America ជាឧទាហរណ៍នៃ *ចទអ* កម្រិតតំបន់ ទោះបីការអនុវត្តរបៀបនេះស្ទើរលែងមានអត្ថិភាព ដោយសារមាននិន្នាការផ្លាស់ប្តូរការផ្តល់សិទ្ធិជ្រកកោន។ ជាទូទៅ លើកលែងរដ្ឋអនុវត្តផ្សេងពីនេះ បុគ្គលត្រូវតែស្ថិតនៅក្នុងដែនដីរបស់ប្រទេស ដែលខ្លួនសុំសិទ្ធិជ្រកកោន (Territorial Asylum)[75] ក្នុងពេលស្នើសុំសិទ្ធិជ្រកកោន។

ការអនុវត្តដោយរដ្ឋផ្តល់នូវសិទ្ធិជ្រកកោន នៅក្នុងដីស្ថានទូត ជាបញ្ហាច្បាប់មួយចំពោះមុខ តុលាការយុត្តិធម៌អន្តរជាតិ (International Court of Justice-ICJ) ក្នុងរឿងក្តី *Asylum Case*។[76] តុលាការបានពិនិត្យអង្គហេតុនិងផ្លូវច្បាប់ ហើយបានអះអាងថា ការអនុវត្តដូចនេះពីមុនមក ត្រូវបានរដ្ឋមួយចំនួនប្រកាន់យក តែក្រោយមក មានការបោះបង់ចោលនូវការអនុវត្តរបៀបនេះ សូម្បីក្នុងចំណោមរដ្ឋនៅក្នុងតំបន់នេះ។[77] ជំហរនេះបង្ហាញថាតុលាការមិនសូវឲ្យតម្លៃលើ *ចទអ* កម្រិតតំបន់ឡើយ ជាពិសេស *ចទអ*

[74] The Convention on the Prevention and Punishment of the Crime of Genocide, December 1948, UNTS, vol. 78, p. 277. As of 2012, there are 142 State Parties, *see* en.wikipedia.org/wiki/List_of_parties_to_the_Genocide_Convention.

[75] ICJ, Asylum Case, Judgement of 20 November 1950, summaries of Judgements, Advisory Opinions and Others of ICJ (ICJ, Asylum case); Niraj Nathwani, Refugees and Human Rights, Rethinking Refugee Law, 2003, p. 15.

[76] ICJ, Asylum Case, *supra* note 75.

[77] *Id.*, pp. 16-17.

ដែលមានជាយូរមកហើយ ហើយមាននិន្នាការទូទៅផ្ទុយនឹង *ចទអ* កម្រិតសាកល។ នោះគឺនិន្នាការ ផ្តល់សិទ្ធិជ្រកកោនក្នុងដែនដី ដល់បុគ្គលណាមួយដែលបានមកដល់ដែនដីរបស់រដ្ឋ។ តាមរយៈដំហរនេះ គេអាចឆ្លើយតបចំពោះ សំណួរពាក់ព័ន្ធជាមួយនឹង ទំនាស់រវាង *ចទអ* ទាំងពីរប្រភេទ ថា *ចទអ* កម្រិតសាកល នឹងត្រូវខ្ពស់ជាង *ចទអ* កម្រិតតំបន់ នៅពេល *ចទអ* ទាំងពីរប្រភេទមានភាពផ្ទុយគ្នា។ មូលហេតុមួយក្នុងចំណោមហេតុផលទាំងឡាយ គឺថា *ចទអ* កម្រិតសាកល មានការអនុវត្តទូទៅរបស់រដ្ឋក្នុងពិភពលោក ដែលបង្ហាញ ពីផលប្រយោជន៍រួមរបស់ពិភពលោក នៃការអនុវត្តរបស់រដ្ឋទូទាំងពិភពលោក ដែលលុបលើប្រយោជន៍របស់រដ្ឋក្នុងតំបន់ដែលមានចំនួនតិចជាង។ ការបដិសេធនូវ *ចទអ* កម្រិតតំបន់ ជាការមួយសមហេតុផល ដោយសារការផ្តល់សិទ្ធិជ្រកកោនដល់ជនបរទេស ក្នុងស្ថានទូតរបស់រដ្ឋមួយនៅក្រៅប្រទេស អាចនាំឲ្យមានអវិភាពរវាង ស្ថានទូត និងរដ្ឋដែលស្ថាតទូតស្ថិតនៅ ជាពិសេសប្រសិនបើ ការផ្តល់សិទ្ធិជ្រកកោនពាក់ព័ន្ធរឿងនយោបាយ។ ម្យ៉ាងវិញទៀត ដែនដីស្ថានទូត មិនមែនជាដីរដ្ឋដាក់ស្ថានទូតឡើយ វានៅតែជាដីរបស់រដ្ឋដែលស្ថានទូតស្ថិតនៅ។ ដូចនេះប្រសិនបើរដ្ឋដាក់ស្ថានទូតប្រព្រឹត្តមិនត្រឹមត្រូវ រដ្ឋម្ចាស់ដី អាចចោទស្ថានទូតថាបានជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ខ្លួន ឬរំលោភអធិបតេយ្យភាពដែនដីរបស់ខ្លួន ដែលជាគោលការណ៍នៃវិធានច្បាប់អន្តរជាតិ។[78]

[78] Resolutions Adopted on the Reports of the Sixth Committee, Declaration on Principles of International Law concerning Friendly Relations and Co-operation among States in accordance with the Charter of the United Nation (A/8082), p. 123.

### ៣.១.៣.២. ចទអ ដែលត្រូវបានបង្កើតក្នុងពេលដ៏ខ្លី

ផ្អែកតាមការពិភាក្សាខាងលើ *ចទអ* មិនអាចត្រូវបានបង្កើតបានក្នុងរយៈពេលខ្លីបានឡើយ ក៏ប៉ុន្តែនិន្នាការបច្ចុប្បន្នវាផ្សេងពីការបង្កើត *ចទអ* សម័យមុន។ ក្នុងវិស័យខ្លះ ឧទាហរណ៍ វិស័យសមុទ្រ អ្នកសិក្សា បានអះអាងថា *ចទអ* ពាក់ព័ន្ធនឹងការគ្រប់គ្រងសមុទ្រ ត្រូវបានបង្កើតឡើងក្នុងរយៈពេលដ៏ខ្លី ដែលគេផ្តល់ឈ្មោះថា *ចទអ* ដែលត្រូវបានបង្កើតបានក្នុងរយៈពេលដ៏ខ្លី (Instant Customary International Law)។[79] ទោះបីជាយ៉ាងនេះក្តីរយៈពេលមិនអាចមួយឆ្នាំ ឬបីឆ្នាំឡើយ។

ក្នុងពិភពលោកសព្វថ្ងៃនេះ រដ្ឋខ្លះ បានប្រើប្រាស់ធនធានធម្មជាតិ លើដែនដីគោកស្ទើរអស់គ្មានសល់។ រដ្ឋខ្លះមិនសូវសម្បូរធនធានធម្មជាតិលើដីគោក តែសម្បូរធនធានក្នុងសមុទ្រ។ ដោយសារមានបច្ចេកវិទ្យាទំនើប ដែលអនុញ្ញាតឲ្យរដ្ឋអាច ធ្វើអាជីវកម្មទាញផលប្រយោជន៍ពីធនធានក្នុងសមុទ្រ បាតសមុទ្រ និងក្រោមបាតសមុទ្រផង រដ្ឋបានចាប់ផ្តើមការអនុវត្ត ការងារពាក់ព័ន្ធនឹងការកំណត់ព្រំដែនសមុទ្រ ហើយរដ្ឋខ្លះ បានចាប់ផ្តើមប្រកាន់ជំហរតាមរដ្ឋដទៃផ្សេងទៀត ឬអនុវត្តតាមលំនាំ រដ្ឋដទៃទៀត ដែលនាំការអនុវត្តស៊ីសង្វាក់របស់រដ្ឋជាច្រើន កើតជារូបរាងឡើងក្នុងរយៈពេលដ៏ខ្លី។ ការអនុវត្តនេះ វាផ្អែកតាមក្របខ័ណ្ឌច្បាប់ ដែលមានស្រាប់ ស្របពេលដែលវិធានច្បាប់ ដែលពាក់ព័ន្ធមួយចំនួនទៀត ត្រូវបានអនុម័តធ្វើឡើង។ ដំណើរការនៃការបង្កើត *ចទអ* របៀបនេះ អាចកើតមានក្នុងបេត់នៃជាតុផ្សំទូលាយ ឬចម្រុះរវាង ជាតុផ្សំចង្អៀត និងទូលាយ។

[79] Robert Y. Jennings, *what is international law and how do we tell it when we see it* ( Robert, What is IL) *?* Schw. Jb. Int. R. 1981, p. 71; Shaw, IL, *supra* note 1, p. 78.

### ៣.១.៤. ចរិតលក្ខណៈរបស់ ចទអ

*ចទអ* ចងជាកាតព្វកិច្ចដល់រដ្ឋ ទាំងរដ្ឋមិនបានដឹងខ្លួន និងមិនចាំបាច់ត្រូវឲ្យរដ្ឋទទួលយល់ព្រមជាមុន នៅពេល *ចទអ* កើតមានរូបរាងឡើងនៅទីណាមួយក្នុងពិភពលោក (Automatically Binds States)។[80] នេះមានន័យថា

ប្រសិនបើមានការអនុវត្តរបស់រដ្ឋភាគច្រើន បានបង្កើតចេញជា *ចទអ* រួចហើយ ហើយរដ្ឋណាមួយមិនបានចូលរួម ក្នុងដំណើរការនៃការបង្កើត (មិនបានទទួលយកការអនុវត្ត ឬមិនដឹងអំពីការអនុវត្ត ឬ ដឹងរួចហើយតែស្ងាត់ស្ងៀមមិនឆ្លើយតបអ្វី) *ចទអ* នឹងចងកាតព្វកិច្ចដល់រដ្ឋ លើកលែងរដ្ឋជំទាស់តាំងពីដើមទីនៃការកកើត *ចទអ* ។ ដូចនេះ បើរដ្ឋមិនគោរពតាម ឬធ្វើផ្ទុយពីកាតព្វកិច្ចក្រោម *ចទអ* ដែលកើតមានរួចមកហើយ រដ្ឋនឹងត្រូវបានគេចោទប្រកាន់ថាបានរំលោភកាតព្វកិច្ច ហើយរដ្ឋត្រូវទទួលខុសត្រូវចំពោះផលវិបាក ដែលកើតមានពីការរំលោភនោះ។[81]

ការដឹងថាវត្តមានរបស់ *ចទអ* ដែលអាចប៉ះពាល់ផលប្រយោជន៍ ហើយរដ្ឋស្ងៀមស្ងាត់ មិនឆ្លើយតប ត្រូវបានគេចាត់ទុកថា ជាការទទួលយក (Acquiescence[82] ) ឬស្មានន័យថាព្រមព្រៀង (Silence Means Approval)។

---

[80] Christian Tomuschat, Obligations arising for States without or against their will, p. 280 (Christian, Obligations); Stephane Beaulac, *Customary International Law in Domestic Courts: Imbroglio, Lord Denning, Stare Decisis*, p. 381, in Christopher P.M. Waters, British and Canadian Perspectives on International Law, 2006.

[81] Draft Articles on Responsibility of States for Internationally Wrongful Acts (Draft Articles, States), 2001, Art.1; D.J. Harris, Cases and Materials on International Law (D.J., Cases on IL), 5th ed., 1998, p. 484.

[82] Liber Amicorum and Rudiger Wolfrum, Coexistence, cooperation and solidarity (Liber Amicorum, Coexistence), vol. 2012, p. 854; I.C. MaccGibbon, *the Scope of Acquiescence in International Law*, 31 BYIL, 1954, p. 143.

ទង្វើដូចនេះ នឹងត្រូវបានគេយកមកបដិសេធ ការស្នើសុំបដិសេធរបស់រដ្ឋនាពេលក្រោយ (Estoppel[83])។ ទ្រឹស្តីខ្លះ ទាញចេញពីសាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិ អាចពាក់ព័ន្ធនឹងដំណើរការ ដែល *ចទអ* ចងជាកាតព្វ កិច្ចដល់រដ្ឋ។ ក្នុងរឿងក្តីប្រាសាទព្រះវិហារ ព្រះរាជាណាចក្រថៃ ទទួលបានផែនទីជាច្រើនច្បាប់ ដែលដាក់ប្រាសាទ ព្រះវិហារក្នុងទឹកដីព្រះរាជាណាចក្រកម្ពុជា ហើយបែងចែកដល់អាជ្ញាធរ ដែលពាក់ព័ន្ធរបស់ខ្លួន ដោយគ្មានការតវ៉ាជំទាស់ដោយ អំពីកម្មសិទ្ធិលើប្រាសាទព្រះវិហារ របស់កម្ពុជា។[84] ក្រោយមកទៀត ស្តេចថៃមកទតមើលប្រាសាទព្រះវិហារ ដែលនៅលើកំពូលមាន ដោតទង់ជាតិបារាំងជាតំណាងឲ្យព្រះរាជាណាចក្រកម្ពុជា ហើយព្រះរាជាណាចក្រថៃ មិនបានតវ៉ាទេ។[85] នៅក្នុងពេលពិចារណារឿងក្តីអង្គហេតុនេះ ត្រូវបានតុលាការចាត់ថាព្រះរាជាណាចក្រថៃ ទទួលស្គាល់ដោយស្ងាត់ស្ងៀម ថាប្រាសាទព្រះវិហារជា កម្មសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជា។[86] ដូច្នេះ តាមរយៈទង្វើនេះ ភាគីថៃមិនអាចនិយាយ ថាប្រាសាទព្រះវិហារជារបស់ខ្លួនឡើយ។ នេះគឺជាមូលដ្ឋានដ៏ មានសក្តានុពលមួយក្នុងចំណោមមូលដ្ឋានទាំងឡាយ ដែលតុលាការបានផ្អែកតាម ដើម្បីសម្រេចថាប្រាសាទព្រះវិហារជាកម្មសិទ្ធិស្របច្បាប់របស់ភាគីកម្ពុជា។

---

[83] Liber Amicorum, Coexistence, *supra* note 82, p. 1598; D.W. Bowett, *Estoppel before International Tribunals and Its Relation to Acquiescence*, 33 the BYIL, 1957, p. 176.

[84] Temple of Preah Vihear (*Cambodia v. Thailand*), Summary of 1962 Merit Judgement (Preah Vihear, 1962 Merit), p. 2, www.icj-cij.org/docket/index.php?p.1

[85] *Id.*, p. 28.

[86] *Id.*

### ៣.១.៤.១. ជំហររបស់រដ្ឋ និងអ្នកស្រាវជ្រាវខ្លះ

ផ្អែកតាមគោលការណ៍ទូទៅរបស់ច្បាប់អន្តរជាតិ (General Principle of International Law) រដ្ឋមានកាតព្វកិច្ចគោរពនូវកាតព្វកិច្ច ដែលមានចែងនៅក្នុងសន្ធិសញ្ញា ដែលរដ្ឋបានចូលជាភាគី។[87] គោលការណ៍នេះ អនុញ្ញាតឲ្យរដ្ឋ អាចគ្រប់គ្រងនូវអ្វី ដែលខ្លួនត្រូវបំពេញតាម ឬមិនបំពេញតាមច្បាប់អន្តរជាតិក្នុងទម្រង់ជាសន្ធិសញ្ញា។ បើរដ្ឋយល់ថា ខ្លួនមិនចង់ធ្វើតាមសន្ធិសញ្ញាណាមួយ រដ្ឋអាចសម្រេចមិនចូលជាភាគី ហើយគ្មានសហគមន៍អន្តរជាតិ ឬរដ្ឋណាមួយ អាចបង្ខំឲ្យរដ្ឋចូល ជាភាគីឡើយ ។ប្រសិនបើដូច្នោះ ការចូលជាភាគីនឹងគ្មានសុពលភាព ព្រោះវាបានផ្ទុយ នឹងគោលការណ៍ព្រមព្រៀង (Principle of Consent) ដែលទទួលស្គាល់ ជាអន្តរជាតិ។[88]

ដូចដែលត្រូវបានបង្ហាញខាងលើ ចំពោះ *ចទអ* ជាទ្រឹស្តី វាមិនមានតម្រូវឲ្យរដ្ឋ ទទួលយល់ព្រមជាមុនដូចសន្ធិសញ្ញាឡើយ។ ដូចនេះ ការអនុវត្ត *ចទអ* គឺមានលក្ខណៈផ្ទាល់ (Direct Application) ប្រសិនបើ *ចទអ* កើតចេញជារូបរាងហើយ វាចងជាកាតព្វកិច្ចដល់រដ្ឋ។ ជាទូទៅ រដ្ឋពិបាកយល់ដឹងថា តើ *ចទអ* អ្វីកំពុងស្ថិតនៅក្នុងដំណើរការនៃការបង្កើត ដូចនេះមានការលំបាកបដិសេធ ឬគេចវេះ នៅពេល *ចទអ* កើតចេញជារូបរាង។ នេះមូលដ្ឋានដែលអង្គការអន្តរជាតិ ឬភាគីខ្លះ បានប្រើប្រាស់ *ចទអ* ជាសំអាងថារដ្ឋ បានរំលោភកាតព្វកិច្ច ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទោះបីរដ្ឋមិនមែនជាភាគីសន្ធិសញ្ញាដែលពាក់ព័ន្ធ ។ ការយោងដល់ *ចទអ* ពីព្រោះគេមិនអាច

[87] The VCLT, *supra* note 36, Art. 26.

[88] Helmut Tuerk, Reflections on the Contemporary Law of Sea, 2012, p. 25; Helmut, A Concise of the UN, *supra* note 8, p. 378.

ចោទប្រកាន់រដ្ឋថា ខុសនឹងកាតព្វកិច្ចចែងក្នុងសន្ធិសញ្ញាបានឡើយ ដោយសារ រដ្ឋមិនមែនជាភាគីរបស់សន្ធិសញ្ញា។ ឧទាហរណ៍ ពាក់ព័ន្ធការបណ្តេញ អ្នកសុំសិទ្ធិជ្រកកោននយោបាយ ដោយសាររដ្ឋ មិនមែនជាភាគីនៃអនុសញ្ញា ស្តីពី ឋានៈជនភៀសខ្លួន ដែលហាមមិនឲ្យដេញអ្នកសុំសិទ្ធិជ្រកកោន នយោបាយ ទៅជួបអំពើធ្វើ ទុក្ខបុកម្នេញ នៅរដ្ឋដើមរបស់ខ្លួន[89] ការបណ្តេញ នេះ មិនខុសពីកាតព្វកិច្ច ហាមដេញនេះឡើយ។ ក៏ប៉ុន្តែ ការបណ្តេញរបស់រដ្ឋនេះ អាចខុសនឹងកាតព្វកិច្ចមិនបណ្តេញក្រោម *ចទអ*។

ជំហរពាក់ព័ន្ធជាមួយនឹង *ចទអ* ត្រូវបានស្តែងឲ្យឃើញក្នុងសេចក្តីសម្រេចរបស់សាលាក្តីខ្មែរក្រហមផងដែរ។ គោលការណ៍នីត្យានុកូលភាព (the Principle of Legality[90]) ទាមទារឲ្យមានច្បាប់ ជាធរមានជាមុន ដែលកំណត់អំពើឧក្រិដ្ឋ និងទោសទណ្ឌ មុននឹងតុលាការកាត់ ទោសឧក្រិដ្ឋជនណាមួយ។ ក្នុងក្របខ័ណ្ឌសាលាក្តីខ្មែរក្រហម ដើម្បីឲ្យតុលាការនេះ អាចកាត់ទោសមេដឹកនាំជាន់ខ្ពស់ និង អ្នកទទួលខុសត្រូវខ្ពស់បំផុតរបស់របបកម្ពុជាប្រជាធិបតេយ្យចំពោះបទឧក្រិដ្ឋ ( បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ក្រោមច្បាប់អន្តរជាតិ និង បទទារុណកម្ម ឃាតកម្មក្រោមច្បាប់ជាតិ) ដែលត្រូវបានចោទថាបានប្រព្រឹត្តក្នុងចន្លោះ ឆ្នាំ ១៩៧៥

---

[89] The Convention relating to the Status of Refugees, 28 July 1951, UNTS, Vol. 189, p. 137, Art. 33.

[90] *Nullum Crimen Sine Lege*, the Jurisdiction of the Extraordinary Chambers in the Courts of Cambodia and Joint Criminal Enterprise, p. 68; Luke Marsh and Michael Ramsden, *Joint Criminal Enterprise: Cambodia's Reply to Tadic* (Luke, JCE), 11 international criminal law review (2011), p. 143; Silvia D'ASCOLi, Sentencing in International Criminal Law, 2011, p.14.

-១៩៧៩[91] វាតម្រូវឲ្យមានច្បាប់អន្តរជាតិ និងច្បាប់ជាតិដែលពាក់ព័ន្ធមានជាធរមានមុនឆ្នាំ ១៩៧៥ ជាមុនសិន។ ពាក់ព័ន្ធអំពើប្រល័យពូជសាសន៍ មានសន្ធិសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ ដែលកម្ពុជាជាភាគី។[92] ចំពោះបទឧក្រិដ្ឋក្រោមច្បាប់ជាតិ អង្គជំនុំជម្រះនៃសាលាក្តីខ្មែរក្រហមមិនជួបបញ្ហាទេ ដោយសារមានក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលនៅមានជាធរមាន។[93] បញ្ហាកើតមានពាក់ព័ន្ធនឹងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងទម្រង់ទទួលខុសត្រូវ ដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (Joint Criminal Enterprise- JCE[94]) ដោយសារមិនមានច្បាប់ ឬសន្ធិសញ្ញាចែង។ កង្វះខាតច្បាប់ប្រើប្រាស់ នាំឲ្យអង្គជំនុំជម្រះ និងមេធាវី បានងាកទៅប្រើប្រាស់ *ចទអ* ផ្អែកទៅតាមមាត្រា ១៥ របស់កតិកាសញ្ញា ស្តីពីសិទ្ធិនយោបាយ និងប្រជាពលរដ្ឋ[95] ដែលត្រូវបានសរសេរបញ្ចូលនៅក្នុងមាត្រាមួយចំនួនរបស់ច្បាប់បង្កើតសាលាក្តី។[96]

មេធាវីរបស់ជនត្រូវចោទ បានផ្អែកតាម ជាតុផ្សំចង្អៀតរបស់ *ចទអ* ហើយអះអាងថា មិនមានការអនុវត្តទទួលយក ដោយរដ្ឋជាច្រើន នូវទម្រង់ទទួល

[91] The Law on the Establishment of Exraordinary Chambers in the Courts of Cambodia for the Prosecution of Crimes Committed During the Period of Democratic Kampuchea (the ECCC Law), Arts. 1 and 2.

[92] Cambodia acceded to the Genocide Convention on 14 October 1950, *see* en.wikipedia.org/wiki/List_of_parties_to_the_Genocide_Convention

[93] 1956 Criminal Code of Cambodia.

[94] Luke, JCE, *supra* note 90, p. 143.

[95] IENG Sary's Motion against the Application at the ECCC of the Form of Liablity Known as Joint Criminal Enterprise IS's JCE Motion) , 28 July 2008, D97 (redacted version), p. 11.

[96] The ECCC Law, *supra* note 91, Art. 33 (new).

ខុសត្រូវសហឧក្រិដ្ឋកម្មរួម ដែលអាចត្រូវបានចាត់ថាជា *ចទអ* ឡើយ។[97] ទោះបីជាទម្រង់ទទួលខុសត្រូវប្រភេទនេះ ត្រូវបានទទួលស្គាល់មានឋានៈជា *ចទអ* ក៏អង្គជំនុំជម្រះ មិនអាចប្រើបានឡើយ ពីព្រោះអង្គជំនុំជម្រះនេះ ជាសាលាក្តីកូនកាត់[98] ស្ថិតក្រោមប្រព័ន្ធតុលាការកម្ពុជា[99] ដែលប្រើច្បាប់កម្ពុជាជាចម្បង[100] ហើយ វិធាន *ចទអ* មិនត្រូវបានអនុវត្តផ្ទាល់ ដោយគ្មានច្បាប់ចែងអនុញ្ញាតឲ្យប្រើក្នុងប្រព័ន្ធច្បាប់ប្រទេសកម្ពុជាឡើយ។[101] ជំហរ ឬការបកស្រាយរបស់មេធាវីជនត្រូវចោទ ស្រដៀងគ្នានឹងជំហរប្រកាន់ដោយរដ្ឋមួយចំនួន ដែលនឹងបង្ហាញជូនក្នុងផ្នែកបន្ទាប់ខាង ក្រោមនេះ។[102]

### ៣.១.៤.១.១. បញ្ហាបឥទ្ធិពល ចទអ

ដោយសាររដ្ឋពិបាកក្នុងការគ្រប់គ្រងលើ *ចទអ* រដ្ឋមានភាពស្ទាក់ស្ទើរក្នុងការទទួលយក *ចទអ* ហើយបានរិះរកមធ្យោបាយដើម្បីបញ្ចៀសការចងជាកាតព្វកិច្ចតាម *ចទអ*។ ទី១ រដ្ឋបានដាក់ *ចទអ* នៅទាបជាងច្បាប់ធម្មតាក្នុងប្រព័ន្ធច្បាប់ជាតិ។[103] ការធ្វើយ៉ាងដូចនេះ ងាយស្រួលសម្រាប់រដ្ឋក្នុងការបដិសេធនូវ *ចទអ* ដែលអាចប៉ះពាល់ដល់ប្រយោជន៍ របស់ជាតិ ដោយគ្រាន់តែកែច្បាប់ ដែលមានស្រាប់ ឬធ្វើច្បាប់ថ្មីបដិសេធ *ចទអ*។ ទី២ ក្នុងករណីដែលរដ្ឋទទួលយក *ចទអ ចទអ* នឹងមិនត្រូវបានអនុវត្តដោយងាយស្រួល នៅ

---

[97] IS's JCE Motion, *supra* note 95, pp. 8-9.

[98] IS's JCE Motion, *supra* note 95, pp. 12-13.

[99] *Id.*

[100] The ECCC Law, *supra* note 91, Art. 33 New.

[101] IS's JCE Motion, *supra* note 95, pp. 12-13.

[102] Hannes Vallikivi, *Domestic Applicability of Customary International Law in Estonia* (Hannes, Application of CIL) , 7 Juridica International 2002, p. 35.

[103] *Id.*

ក្នុងប្រព័ន្ធច្បាប់តុលាការក្នុងស្រុកទេ ដោយសារតុលាការ ប្រកាន់ជំហរថា តុលាការនឹងប្រើប្រាស់ *ចទអ* លុះត្រាតែច្បាប់ក្នុងស្រុក អនុញ្ញាត ឲ្យប្រើប្រាស់ *ចទអ*។ ទោះបីជាយ៉ាងនេះក្តី ប្រសិនតុលាការប្រើប្រាស់ *ចទអ* តុលាការនៅតែអាចបដិសេធ *ចទអ* បានដោយគ្រាន់តែអះអាងថា ច្បាប់ធម្មតាក្នុងស្រុកមានឋានៈខ្ពស់ជាង *ចទអ* ហើយទង្វើ ដែលត្រូវបានធ្វើឡើងនោះស្របតាមច្បាប់ជាតិ។ ទោះបីជាផ្ទុយពី *ចទអ* ក៏មិនខុសនឹងច្បាប់អន្តរជាតិដែរ។ ទាំងការដាក់ *ចទអ* ទាបជាងច្បាប់ជាតិធម្មតា និងការមិនអនុវត្តដោយផ្ទាល់ នៃ *ចទអ* មិនអាចត្រឹមត្រូវតាមគ្រប់កាលៈទេសៈឡើយ ពីព្រោះជួនកាល វិធាន *ចទអ* ខ្លះ ជាវិធានមានតម្លៃខ្ពស់បំផុត ក្នុងប្រព័ន្ធច្បាប់អន្តរជាតិ ដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញជាតិ ហើយដែលឋានៈដ៏ខ្ពស់របស់វិធាន *ចទអ* ត្រូវបានទទួលស្គាល់ដោយរដ្ឋ។[104] វិធានដ៏មានតម្លៃខ្ពស់នេះ ជាវិធានច្បាប់ ដែលពិភពលោកត្រូវការ ហើយដែលជាប្រយោជន៍ស្លាប់រស់របស់ពិភពលោក ដែលរដ្ឋមិនអាចដាក់ទាបជាងច្បាប់ធម្មតា ឬសូម្បីច្បាប់កំពូលរបស់ជាតិ ដែលច្បាប់ជាតិមិនអាចបដិសេធ *ចទអ* ដោយងាយៗបានឡើយ។

### ៣.១.៤.១.២. ការជំទាស់ក្នុងពេលដែល ចទអ កំពុងកកើត

វិធីសាស្ត្រមួយទៀត ដែលរដ្ឋអាចទប់ការចងជាកាតព្វកិច្ចក្រោម *ចទអ* ដែលរដ្ឋមិនបានទទួលយក គឺការបដិសេធជាដដែលៗ មិនទទួលយក *ចទអ*

[104] ICRC, Customary, *supra* note 71, Chapter 32, Rule 90, Torture and Cruel, Inhuman or Degrading Treatment, footnote 8 cited various national military laws/manuals recognizing the prohibtion of torture.

(Persistent Objection)។[105] វាហាក់គ្រាន់តែជាទ្រឹស្តី ដែលត្រូវបានបង្កើតឡើង ដោយអ្នកសិក្សាស្រាវជ្រាវច្បាប់អន្តរជាតិ។ តុលាការអន្តរជាតិ ក៏មានភាពស្ទាក់ស្ទើរ ក្នុងការយោងដល់ទ្រឹស្តីនេះដែរ។ ក្នុងរឿងក្តី *North Sea Continental Shelf* តុលាការបាននិយាយថា៖ វិធាន ១០ miles មិនអនុវត្តចំពោះ Norway ដោយសាររដ្ឋនេះ ជានិច្ចកាលបានជំទាស់ ការប្រើប្រាស់វិធាននេះប៉ះពាល់ដល់ប្រយោជន៍របស់ខ្លួន។[106] តាមទ្រឹស្តី ការជំទាស់នេះនឹងនាំ មិនឲ្យមានការចងជាកាតព្វកិច្ច ក្រោម *ចទអ* នៅពេល *ចទអ* កើតមានរូបរាងឡើង។ ការជំទាស់នេះ ត្រូវតែធ្វើនៅពេល ដែល *ចទអ* ទើបតែស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការបង្កើត។[107] ទោះបីវាជាការពិត រដ្ឋភាគច្រើនមានការពិបាកក្នុងការស្វែងយល់ដឹងថា *ចទអ* មួយណាដែលស្ថិតនៅក្នុងដំណាក់នៃការកកើត។

គំនិតនៃការមិនអាចបដិសេធជាក្រោយនៃ *ចទអ* នៅពេលដែល *ចទអ* កើតមានហើយ ជាមូលដ្ឋានមួយសម្រាប់ ឆ្លើយតបដល់រដ្ឋមួយចំនួន ជាពិសេសនៅក្នុងទ្វីបអាហ្វ្រិក និងអាស៊ី ដែលទើបទទួលបានឯករាជ្យ ពីការគ្រប់គ្រងរបស់ប្រទេសអាណានិគម មួយចំនួននៅក្នុងលោកខាងលិច ដែលរដ្ឋថ្មីទាំងនោះព្យាយាម សើរើច្បាប់អន្តរជាតិ ដែលមានមុនខ្លួនបានឯករាជ្យ។ រដ្ឋទាំងនោះ គិតថាច្បាប់ទាំងនោះជាច្បាប់របស់ពួកលោកខាងលិច ដែលរដ្ឋខ្លួនមិនបានចូលរួមធ្វើ។[108] សំណើសុំសើរើនេះ មិនសូវទទួលបានការគាំទ្រប៉ុន្មានទេ ដោយសាររដ្ឋទាំងនោះ ជួនកាល ប្រើប្រាស់ច្បាប់ ដែលខ្លួនធ្លាប់បដិសេធ មក

[105] Thomas, PIL, *supra* note 5, p. 23; Anthony Aust, handbook, *supra* note 2, p. 7.
[106] ICJ, *United Kingdom v. Norway*, ICJ Reports 1951, pp. 115, 131.
[107] Christian, Obligations, *supra* note 80, p. 275.
[108] *Id.*, p. 305.

ធ្វើជាមូលដ្ឋានសម្រាប់ការពារប្រយោជន៍របស់ខ្លួន ដែលជាប់ពាក់ព័ន្ធក្នុង ក្តីក្តាំអន្តរជាតិ ដែលខ្លួនជាភាគី។[109] ជាចុងក្រោយ រដ្ឋទាំងនោះ ពិតជាមិនអាចបដិសេធ នូវវិធានច្បាប់ ដែលមានតម្លៃខ្ពស់សម្រាប់ទ្រទ្រង់អាយុជីវិតរបស់ពិភពលោក ហើយទោះបីជាមានការជំទាស់ជាដដែលៗ ក្នុងដំណាក់កាលដែលវិធានស្ថិតក្នុងការចាប់ផ្តើមចេញរូបរាងយ៉ាងណាក្តី ក៏ការជំទាស់នឹងគ្មានប្រសិទ្ធភាពឡើយ បើពាក់ព័ន្ធ ជាមួយវិធានដ៏មានតម្លៃខ្ពស់នេះ។[110]

## ៣.១.៥. ទំនាក់ទំនងរវាងសន្ធិសញ្ញា និង ចទអ

### ៣.១.៥.១. តើចត្តមានចធានក្នុងសន្ធិសញ្ញា អាចលុបសុពលភាពចធានដូចគ្នានៃ ចទអ?

*ចទអ* ជាច្បាប់អរូបិយ និងជាច្បាប់មិនមែនជាលាយលក្ខណ៍អក្សរ (Unwritten Law)។ គួបផ្សំជាមួយភាពស្ទាក់ស្ទើររបស់រដ្ឋក្នុងការទទួលយក *ចទអ* ការចងក្រង *ចទអ* តាមរយៈការដាក់បញ្ចូលទៅក្នុងសន្ធិសញ្ញា ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ត្រូវបានអង្គការសហប្រជាជាតិធ្វើឡើង (Codification of Customary International Law)។ ការធ្វើរបៀបនេះ គឺដើម្បីឲ្យ *ចទអ* មានលក្ខណៈជាក់លាក់ ងាយស្រួលនៅក្នុងការយកទៅអនុវត្ត។ សន្ធិសញ្ញា ដែលចងក្រង *ចទអ* ត្រូវបានគេហៅថា Declaratory

---

109 Tunku, the Third World, *supra* note 1, pp. 143 and 181; Antonio Augusto Cancado Trindad, International Law for Humankind, 2010, p. 117-118.

110 David A. Colson, *How persistent must the persistent objector be?* 61 Wash. L. Rev. 1980, p.957; Ted L. Stein, *the Approach of the Different Drummer: the Principle of Persistent Objector in International Law*, 26(2) Harv. Int'l. L. J. 1985; Jonathan I. Charney, *the Persistent Objector Rule and the Development of Customary International Law*, BYIL, 1986; Ian Brownlie, principles of public international law (Brownlie, 4th), 4th ed., 1990, p. 11.

Treaty។[111] គេអាចសម្គាល់បានជា សន្ធិសញ្ញាប្រភេទនេះ តាមរយៈការពិនិត្យមើល បុព្វកថា ( Preamble) របស់សន្ធិសញ្ញា។[112] សន្ធិសញ្ញា ស្តីពីច្បាប់សន្ធិសញ្ញា ត្រូវបានគេចាត់ថាជា Declaratory Treaty។[113] សំណួរមួយ អាចត្រូវបានសួរថា៖ តើវិធាន *ចទអ* ដែលត្រូវបានសរសេរបញ្ចូលក្នុងសន្ធិសញ្ញារួចហើយនៅមានសុពលភាពដែរឬទេ?

ចម្លើយនេះ អាចត្រូវបានរកឃើញក្នុងសាលក្រមរបស់តុលាការយុត្តិធម៌ ក្នុងរឿងក្តីអន្តរជាតិ រវាង Nicaragua និង the United States of America។ Nicaragua បានប្តឹងប្រឆាំង នឹងសហរដ្ឋអាមេរិក ចំពោះការប្រើកម្លាំងទ័ពឈ្លានពានដែនដី ហើយរំលោភបូរណភាពដែនដីរបស់ខ្លួន។[114] តុលាការយុត្តិធម៌អន្តរជាតិ ក្នុងរឿងនេះ ត្រូវដោះស្រាយបញ្ហានីតិវិធី និងច្បាប់ជាច្រើនជាមុន មុននឹងសម្រេចថា សហរដ្ឋអាមេរិក បានរំលោភកាតព្វកិច្ចណាខ្លះ។ បញ្ហាមួយ គឺពាក់ព័ន្ធនឹង ខរក្សាសិទ្ធិមិនអនុវត្ត (Reservation) ធ្វើដោយសហរដ្ឋអាមេរិក នៅពេលប្រកាសទទួល ស្គាល់សមត្ថកិច្ចរបស់តុលាការយុត្តិធម៌អន្តរជាតិ ដែលដាក់ក្រៅសមត្ថកិច្ចរបស់តុលាការនូវជម្លោះប្រដាប់អាវុធចូលរួមដោយសហរដ្ឋអាមេរិក ចែងក្រោមសន្ធិសញ្ញាពហុភាគី ធ្វើជាមួយរដ្ឋ Latin America មួយចំនួន។[115] សេចក្តីអះអាងនេះ ត្រូវបាន

---

[111] Robert Y. Jennings, what is IL, *supra* note 79, p. 83; Ibrahim F.I. Shihata, *the Treaty as a Law-Declarating and Custom-Making Instrument* (Ibrahim, the Treaty), 22 Revue Egyptian de droit international, 1966, p. 62; R.R. Baxter, *multilateral Treaties as Evidence of Customary International Law*, 41 BYIL, 1965-66, p. 278.

[112] Ibrahim, the Treaty, *supra* note 111, p. 62

[113] *Id.*

[114] 'Case Concerning Military and Paramilitary Activities (*Nicaragua v United* States)'( ICJ, Military Case), 1986 ICJ Reports (ICJ Rep) 14, at 138 ( 275-276).

[115] *Id.*, 14, at 162( 275-276).

ទទួលយកដោយតុលាការ ហើយជាលទ្ធផល[116] តុលាការ មិនអាចពិចារណាការចោទប្រកាន់ពីការប្រើកម្លាំងទ័ព ក្រោមសន្ធិសញ្ញាពហុភាគីឡើយ។ តុលាការ បានផ្តើមយោងដល់ *ចទអ* ដើម្បីដាក់សហរដ្ឋអាមេរិក ឲ្យទទួលខុសត្រូវការរំលោភការប្រើកម្លាំង ចែងក្រោម *ចទអ* ដោយអះអាងថា ការហាមឃាត់ការប្រើកម្លាំងមានជាយូរយារណាស់មកហើយ តាំងពីពេលមុនវាត្រូវបានចែងដោយធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ(សន្ធិសញ្ញាពហុភាគី)[117] និង ជាពិសេសសហរដ្ឋអាមេរិក ដែលជាភាគីក្នុងរឿងក្តីបានទទួលស្គាល់ឋានៈ *ចទអ* របស់ការហាមប្រើកម្លាំងទ័ព។[118] តំណាង សហរដ្ឋអាមេរិក មានភាពវៀងវៃគ្រប់គ្រាន់ដោយឆ្លើយតបត្រឡប់ទៅវិញថា នៅពេលដែលការហាមប្រើកម្លាំងត្រូវបានចែងដោយសន្ធិសញ្ញា ការហាមប្រើកម្លាំងក្រោម *ចទអ* លែងមានសុពលភាពអនុវត្តហើយ។[119] សេចក្តីអះអាងនេះ សម្រាប់ជាការឆ្លើយប្រាប់តុលាការ ថា តុលាការគ្មានសមត្ថកិច្ច ពិនិត្យមើលសំណុំរឿងរបស់ Nicaragua ប្រឆាំងនឹង សហរដ្ឋអាមេរិកឡើយ។ ជាការឆ្លើយតប តុលាការបាននិយាយថា ការហាមឃាត់ការប្រើកម្លាំងក្រោម *ចទអ* នៅតែមានសុពលភាពឯករាជ្យពីសន្ធិសញ្ញា។[120]

តាមរយៈក្តីក្តាំនេះ ទំនាក់ទំនងរវាង សន្ធិសញ្ញា និង *ចទអ* ដែលចែងអំពីបញ្ហាដូចគ្នា គឺជាបញ្ហា ដែលតម្រូវឲ្យមានការចងក្រង *ចទអ* ទៅក្នុងសន្ធិសញ្ញា ធ្វើឲ្យ *ចទអ* មានលក្ខណៈជាក់លាក់ងាយស្រួលប្រើប្រាស់។ ក៏ប៉ុន្តែ

[116] *Id*., summary of Judgement of 27 June 1986, p. 164-65.
[117] *Id*., summary of Judgement of 27 June 1986, p. 165.
[118] *Id*., summary of Judgement of 27 June 1986, p. 165.
[119] *Id*., summary of Judgement of 27 June 1986, p. 165.
[120] *Id*., summary of Judgement of 27 June 1986, p. 165.

ទោះបីមានការចងក្រងក្តី វាអាចមានបញ្ហានៅពេល ដែលខ្លឹមសារក្រោម សន្ធិសញ្ញា និង *ចទអ* ក្នុងបញ្ហាតែមួយ មានន័យមិនដូចគ្នា និងបញ្ហាថាតើ សន្ធិសញ្ញា ឬ *ចទអ* មួយណាមានឋានៈខ្ពស់ជាង នៅពេលមានទំនាស់ រវាងគ្នា។

បញ្ហា វាអាចនឹងកាន់តែស្មុគស្មាញ ប្រសិនបើគិតទៅដល់ភាពស្ទាក់ស្ទើរ របស់រដ្ឋក្នុងការទទួលយក *ចទអ*។ ជំហររក្សាសុពលភាពរបស់ *ចទអ* ទោះបីមានសន្ធិសញ្ញាចែងក្តីគឺជារឿងមួយដ៏សមស្រប និងសមហេតុផល ប្រសិនបើគេពិនិត្យទៅមើលចរិតលក្ខណៈរបស់ច្បាប់អន្តរជាតិជាទូទៅ។ គេ អាចនិយាយថា *ចទអ* មានប្រភពចេញពីប្រព័ន្ធ Common Law ហើយ វាត្រូវបានគេប្រើប្រាស់ជាយូរលង់មកហើយ សូម្បីមុនសន្ធិសញ្ញាទៅទៀត។ សន្ធិសញ្ញា និង *ចទអ* ជាប្រភពចម្បងរបស់ច្បាប់អន្តរជាតិ។ ដូច្នេះ ច្បាប់ អន្តរជាតិ មិនអាចខ្វះ *ចទអ* បានឡើយ ជាពិសេសក្នុងកាលៈទេសៈ ដែល សហគមន៍អន្តរជាតិ បានប្រឈមមុខនឹងការខ្វះខាតវិធានច្បាប់សម្រាប់ប្រើ ប្រាស់។ ការបំពេញបន្ថែមដោយវិធានក្នុងសន្ធិសញ្ញា មិនងាយនឹងត្រូវបាន អនុម័តធ្វើឡើងឡើយ។ ដូចដែលបានបង្ហាញជូននៅក្នុងទំព័រខាងមុខ វាមិន អាចជៀសរួចបានឡើយ នូវភាពមិនដូចគ្នារវាងប្រធានបទដូចគ្នា ដែល ត្រូវចែងក្នុងសន្ធិសញ្ញា និង*ចទអ។* ខ្លឹមសារ ដែលចែងនៅក្នុង សន្ធិសញ្ញា អាចចង្អៀត និងមិនច្បាស់ ដែលខ្លឹមសារចែងនៅក្នុង *ចទអ* អាចជា បំពេញ បន្ថែម ឬបញ្ជាក់បន្ថែម។ ផ្ទុយទៅវិញ ប្រសិនបើគេបដិសេធ នូវសុពលភាព *ចទអ* ដោយសារតែវិធានដូចគ្នា ត្រូវបានចែង ដោយសន្ធិសញ្ញា វានឹងនាំ ឲ្យមានភាពរង្គោះរង្គើប្រព័ន្ធច្បាប់អន្តរជាតិ ដោយសាររដ្ឋ អាចបដិសេធ ចោលនូវ *ចទអ* ដោយគ្រាន់តែមានសន្ធិសញ្ញា ដែលរដ្ឋមានសេរីភាពចូល ឬ

មិនចូលជាភាគី។ រដ្ឋដែលមានចេតនាអាក្រក់ អាចបដិសេធ *ចទអ* ហើយ មិនចូលជាភាគី ឬដកខ្លួនពីសន្ធិសញ្ញា ។ ជាលទ្ធផល រដ្ឋអាចធ្វើអ្វី ដែលខ្លួនចង់ ដោយមិនមានសហគមន៍ អន្តរជាតិអាចចោទថា រដ្ឋរំលោភកាតព្វកិច្ចបាន។ គេអាចនិយាយថា ករណីនេះ វាអាចជាករណីកម្រ តែនៅពេលដែលវាជាបញ្ហាពាក់ព័ន្ធផលប្រយោជន៍សំខាន់របស់រដ្ឋ ឬកិត្តិនាមរបស់រដ្ឋ រដ្ឋពិតជាខិតខំរិះរកមធ្យោបាយច្បាប់ដើម្បីដោះរួចខ្លួន។ នេះត្រូវបានស្តែងឡើងតាមរយៈជំហររបស់សហរដ្ឋអាមេរិក។ សម្រាប់បញ្ហានីតិវិធីក្នុងរឿងក្តីនេះ ប្រសិនបើ តុលាការទទួលយកសេចក្តីអះអាងរបស់សហរដ្ឋអាមេរិកពាក់ព័ន្ធអសុពលភាពនៃ *ចទអ* ប្រទេស Nicaragua នឹងមិនទទួលបានដំណោះស្រាយអ្វីឡើយ។ ជាបន្ថែម ការមិនរក្សាទុកសុពលភាពរបស់ *ចទអ* តើមានផលវិបាកអ្វីខ្លះក្នុងទំនាក់ទំនងជាមួយនឹងរដ្ឋដទៃ។ នេះគឺជារឿងនីតិវិធីមួយដ៏ស្មុគស្មាញ។ វត្តមានរបស់ *ចទអ* អាចជួយជាសំអាងសម្រាប់ការពារផលប្រយោជន៍ជាពិសេសនៅពេលរដ្ឋ ដែលពាក់ព័ន្ធមិនបានចូលជាភាគីសន្ធិសញ្ញា។ ដូចនេះ ការរក្សាសុពលភាពរបស់ *ចទអ* គឺជាការរក្សាជម្រើសជាច្រើន សម្រាប់រដ្ឋប្រកាន់យក។ រដ្ឋដែលជាភាគីសន្ធិសញ្ញា ប្រើប្រាស់សន្ធិសញ្ញា ចំពោះរដ្ឋដែលមិនមែនជាភាគី រដ្ឋនោះអាចប្រើប្រាស់ *ចទអ*។

### ៣.១.៥.២. តើ ខចែងក្នុងសន្ធិសញ្ញា ខ្ពស់ជាងខចែងនៃ ចទអ ឬ?

នៅក្នុងស្ថានភាពគ្មានជម្លោះរវាងរដ្ឋ និងរដ្ឋ ទំនាស់រវាង *ចទអ* និងសន្ធិសញ្ញាអាច នឹងមិនកើតមានឡើយ តែប្រសិនបើក្នុងពេលមានជម្លោះ ហើយរដ្ឋជាភាគីម្ខាងផ្អែក ទៅលើ *ចទអ* ហើយម្ខាងទៀតផ្អែកទៅលើ

សន្ធិសញ្ញា ដែលរដ្ឋរៀងខ្លួនគិតថា អាចជានាប្រយោជន៍ក្នុងរឿងក្ដី ហើយស្នើសុំឲ្យតុលាការផ្អែកលើប្រភេទនៃវិធានទាំងនេះ ដើម្បីសម្រេចសេចក្ដី បញ្ហាវិវាទរវាងវិធានណាមួយខ្ពស់ជាងពិតជាកើតមាន។ ជាការពិតលើកលែងមាត្រា ៥៩ របស់លក្ខន្តិកៈរបស់ខ្លួន[121] តុលាការយុត្តិធម៌អន្តរជាតិនឹងសម្រេចតើវិធាន ឬក៏ច្បាប់អ្វីដែលខ្លួននឹងយកមកប្រើដើម្បីសំអាងក្នុងការសម្រេចសេចក្ដី។

ចំពោះបញ្ហានេះ ដោយយោងទៅលើមាត្រា ៣៨ ដែលដាក់សន្ធិសញ្ញាលំដាប់ទី ១ នៅពីលើ *ចទអ* គេអាចឆ្លើយថា សន្ធិសញ្ញា មានតម្លៃខ្ពស់ជាង *ចទអ។* ក៏ប៉ុន្តែ តាមការស្រាវជ្រាវលើប្រវត្តិនៃការធ្វើមាត្រា ៣៨នេះ អ្នកស្រាវជ្រាវ បានបង្ហាញផ្ទុយពីនេះ។ ការដែលគេដាក់សន្ធិសញ្ញាក្នុងលំដាប់ ទី១ មិនមានន័យថា សន្ធិសញ្ញាមានតម្លៃខ្ពស់ជាងគេទេ។[122] វាអាចគ្រាន់តែជាបញ្ហាទម្រង់ និងជម្រើសរបស់រដ្ឋ ពីព្រោះថា សន្ធិសញ្ញា ជាឯកសារជាលាយលក្ខណ៍អក្សរ ដែលរដ្ឋងាយទទួលយកបាន។ ការអះអាងអំពីឋានៈរបស់សន្ធិសញ្ញាយ៉ាងនេះ វាជាការត្រឹមត្រូវ ដោយហេតុថា វិធាន *ចទអ* ខ្លះមានចរិតដាច់ខាត និងតម្លៃខ្ពស់ជាងវិធានចែងក្នុងសន្ធិសញ្ញា។ ឧទាហរណ៍ សិទ្ធិគ្រួសារ ចែងក្នុងសន្ធិសញ្ញា មិនមានចរិតដាច់ខាត និងតម្លៃខ្ពស់ដូចវិធានពាក់ព័ន្ធនឹងការបង្ការអំពើទារុណកម្ម ដែលជាវិធាន *ចទអ* ឡើយ។ ដូចគ្នានេះដែរ វិធានមានឋានៈជា *ចទអ* ខ្លះ មានតម្លៃទាបជាងវិធានចែងក្នុង

[121] The Statute of ICJ, *supra* note 58.

[122] Sources of International Law: An Introduction by Professor Christopher Greenwood, 2008, p. 5, see untreaty.un.org/cod/avl/ls/Greenwood_IL.html; Michael Akehurst, *the Hierarchy of the Sources of International Law*, BYIL, 1976, pp. 274-275.

សន្ធិសញ្ញា។ ជាសរុប វិធានទាំងពីរប្រភេទនេះ មានឋានៈទាប ឬខ្ពស់ជាងគ្នា ទៅតាមប្រភេទនៃវិធានដែលជាប់ពាក់ព័ន្ធ។ ដូចនេះ ដើម្បីសន្និដ្ឋានថា វិធានណាមួយខ្ពស់ជាងវិធានណា អ្នកស្រាវជ្រាវ ត្រូវពិនិត្យទៅតាមករណីជាក់ស្តែងនីមួយៗ។ ភ្ជាប់ជាមួយចំណុចនេះ ការមិនទទួល យកការអនុវត្ត *ចទអ* ដោយគិតថា *ចទអ* មានតម្លៃទាប ឬចរិតលក្ខណៈ គឺមិនត្រឹមត្រូវទាំងស្រុងឡើយ។ ក្នុងករណី ដែល *ចទអ* ដែលពាក់ព័ន្ធមានតម្លៃខ្ពស់ រដ្ឋគួរប្រកាន់យកការអនុវត្ត ដោយមិនចាំបាច់តម្រូវឲ្យមានច្បាប់ជាមុន (Direct Application) ហើយត្រូវឲ្យតម្លៃវិធាននេះខ្ពស់ជាងវិធានណាៗទាំងអស់។

## ៣.២. សន្ធិសញ្ញា

### ៣.២.១. និយមន័យ និងប្រភេទ

តាមមាត្រា ២(១.ក) របស់សន្ធិសញ្ញាទីក្រុង Vienna ស្តីពី ច្បាប់សន្ធិសញ្ញា សន្ធិសញ្ញាគឺជាកិច្ចព្រមព្រៀងអន្តរជាតិរវាងរដ្ឋ និងរដ្ឋ ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ គ្រប់គ្រងដោយច្បាប់អន្តរជាតិ ដែលអាចជាឯកសារតែមួយ ឬរួមបញ្ចូលគ្នា។[123] តាមន័យនេះ កិច្ចព្រមព្រៀងជាសម្តីផ្ទាល់មាត់មិនអាចជាសន្ធិសញ្ញាទេ។ ពាក្យថា "គ្រប់គ្រងដោយច្បាប់អន្តរជាតិ" សំដៅថា កម្មវត្ថុត្រូវតែស្របនឹងច្បាប់អន្តរជាតិ។ អនុលោមតាមន័យនេះ រដ្ឋមិនអាចធ្វើកិច្ចព្រមព្រៀង ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឡើយ។ លក្ខណវិនិច្ឆ័យនេះ ក៏ទាមទារផងដែរ ឲ្យការធ្វើកិច្ចសន្យាទៅតាមទម្រង់ដែលវិធានអន្តរជាតិតម្រូវ ប្រសិនមិនដូចនេះទេ កិច្ចព្រមព្រៀងអាចនឹងគ្មាន

[123] There is treaty governing treaty between the State and International Organiztions, *see* the Work of the International Law Commission, 7th ed., Vol. II, 2007, p. 228.

សុពលភាព។ តាមវិធានច្បាប់អន្តរជាតិ សន្ធិសញ្ញា ទាមទារឲ្យមានការផ្តល់សច្ចាប័ន ឬព្រមព្រៀងដោយរដ្ឋ ទើបមានសុពលភាព ឬចងជាកាតព្វកិច្ចដល់រដ្ឋ។

ពាក់ព័ន្ធជាមួយនឹងការប្រើពាក្យពេចន៍ គេអាចមានចម្ងល់ថា តើសន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា ខុសគ្នាឬយ៉ាងណា? នេះជាសំណួរមួយ ដែលមិនទាន់មានចម្លើយជាក់លាក់ឡើយ។ សន្ធិសញ្ញា គឺជាពាក្យទូទៅ។ អនុសញ្ញាក៏ជាសន្ធិសញ្ញា។ ការប្រើពាក្យពេចន៍ អាចមិនមានបង្កប់ន័យសំខាន់ជាចម្បងទេ ពីព្រោះវាអាចគ្រាន់តែជាជម្រើសនៃការប្រើប្រាស់។ អ្នកស្រាវជ្រាវបានផ្តល់ការកត់សម្គាល់ថា កិច្ចព្រមព្រៀង វាជាពាក្យប្រើជាទូទៅ សំដៅលើកិច្ចព្រមព្រៀងទ្វេភាគីរវាងរដ្ឋ និងរដ្ឋ។ រីឯពាក្យ Pact ដែលជាកិច្ចព្រមព្រៀងផងដែរនេះ សំដៅលើកិច្ចព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ សម្រាប់បញ្ចប់សង្គ្រាម។ ឧទាហរណ៍ Peace Pact។[124] ការកត់សម្គាល់ ចុងក្រោយ ក្នុងវិស័យសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ ប្រើតែពាក្យអនុសញ្ញា (Convention) ឬកតិកាសញ្ញា (Covenant) តែប៉ុណ្ណោះ។

### ៣.២.២. ការតាក់តែង និង ការចូលជាធរមានរបស់សន្ធិសញ្ញា

កាលណាគេនិយាយអំពីការតាក់តែងសន្ធិសញ្ញា គេត្រូវគិតអំពីប្រភេទនៃកិច្ចព្រមព្រៀង ឬសន្ធិសញ្ញាជាមុនសិន ដែលវាអាចជាទ្វេភាគី ឬពហុភាគីរបស់តំបន់ណាមួយ ឬ សម្រាប់ពិភពលោកទាំងមូល។

[124] Bryan A. Garner, the Back's Law Dictionary (Bryan, the Black), 8th ed., p. 1140; for example, the Paris Pact of 1928 on the Banning of War (Kellogg-Briand Pact), *see* Peter Malanckuz, IL, *supra* note 1, p. 24.

ផ្នែកនេះនឹងរៀបរាប់ជាសង្ខេប អំពីនីតិវិធីធ្វើសន្ធិសញ្ញាសាកល ដោយអង្គការសហប្រជាជាតិ។ ក្នុងរចនាសម្ព័ន្ធរបស់អង្គការសហប្រជាជាតិ មានស្ថាប័នច្បាប់មួយមានឈ្មោះថា គណៈកម្មការច្បាប់អន្តរជាតិ (International Law Commission)។ គណៈកម្មការនេះ មានសមាជិកមកពីរដ្ឋជាភាគីរបស់អង្គការសហប្រជាជាតិ ស្ថិតនៅក្រោម ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (Ecosoc) ហើយដែលគណៈកម្មការខាងក្រោយនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មហាសន្និបាតអង្គការសហប្រជាជាតិ។

គណៈកម្មការច្បាប់អន្តរជាតិ មានភារកិច្ចចម្បង ពិនិត្យសិក្សាបញ្ហាច្បាប់អន្តរជាតិ ហើយបើមានភាពចាំបាច់ ស្នើឲ្យមានការធ្វើសន្ធិសញ្ញាថ្មីណាមួយ។ នេះទាមទារឲ្យមានការយល់ព្រម ពីមហាសន្និបាតរបស់អង្គការសហប្រជាជាតិ។ គណៈកម្មការ បង្កើតក្រុមការងារ ធ្វើសេចក្តីព្រាងសន្ធិសញ្ញា និងពិចារណាលើសេចក្តីព្រាង។ ក្នុងករណីខ្លះ រដ្ឋបានស្នើឡើងនូវសេចក្តីព្រាងដាក់ជូនគណៈកម្មការពិនិត្យ។[125] ការពិនិត្យ ចំណាយពេលវេលាយ៉ាងច្រើនឆ្នាំ។ ជាក់ស្តែង អនុសញ្ញា ស្តីពី ការប្រឆាំងនឹងអំពើទារុណកម្ម ចំណាយពេលចំនួនជិត ១០ឆ្នាំ មុននឹងត្រូវបានអនុម័តក្នុងឆ្នាំ ១៩៨៤។ ក្រោយពីមានការចូលរួមពីរដ្ឋ ឬអ្នកជំនាញ ក្នុងកិច្ចពិភាក្សាលើសេចក្តីព្រាង និងទទួលបានការព្រមព្រៀងពីរដ្ឋ សេចក្តីព្រាងដែលត្រូវបានអនុម័ត ត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីពិនិត្យ និងអនុម័ត។ មហា

[125] J. Herman Burgers and Hans Danelius, the United Nations Convention aginst Torture, A Handbbok, 1988, p. XI.

សន្និបាត ត្រូវអនុម័តក្នុងសំឡេង ២ភាគ ៣ នៃរដ្ឋដែលបានចូលរួម ដើម្បីបើកការចុះហត្ថលេខា លើសន្ធិសញ្ញា។[126]

វាផ្អែកទៅតាមសន្ធិសញ្ញា សន្ធិសញ្ញាខ្លះទាមទារឲ្យរដ្ឋមួយចំនួនកំណត់ ចូលជាភាគីតាមរយៈ ការផ្ដល់សច្ចាប័ន (Ratification) ដើម្បីនាំឲ្យសន្ធិសញ្ញាចូលជាធរមាន។ ប្រទេសទាំងនោះបានក្លាយជាភាគី។ រដ្ឋ ដែលចូលជាភាគីក្រោយពីការចូលជាធរមាន នឹងក្លាយជាភាគី តាមរយៈការទទួលយក (Accession)។ ឯកសារសច្ចាប័ន ឬទទួលយក ត្រូវដាក់តម្កល់ជាមួយ អគ្គលេខាធិការអង្គការសហប្រជាជាតិ។[127] ដូចគ្នានេះដែរ វាអាស្រ័យទៅតាមសន្ធិសញ្ញា សន្ធិសញ្ញាខ្លះនឹងចូលជាធរមានក្រោយពីរដ្ឋចុះហត្ថលេខា។ ក៏ប៉ុន្តែ ករណីនេះ ប្រហែលជាអនុវត្តចំពោះសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងទ្វេភាគី។[128]

ទោះបីជា រដ្ឋបានផ្ដល់សច្ចាប័ន ឬទទួលយកនូវសន្ធិសញ្ញាក្ដី តាមន័យចង្អៀត សន្ធិសញ្ញាមិនទាន់ចូលជាធរមានសម្រាប់រដ្ឋនោះទេ ដោយរង់ចាំរយៈពេលកំណត់ ឧទាហរណ៍ រយៈពេល ៣ខែកន្លងផុតទៅ។[129] ការទាមទារ

---

[126] Two third of States Parties constitutes quorum, *see* the Convention on the Rights of the Child (the CRC), 1989, 1577 UNTS 3, Art. 43 (5).

[127] The ICCPR, *supra* note 56, Art. 48; the VCLT, *supra* note 36, Art. 80; the UN Charter, *supra* note 42, Arts. 102, 110.

[128] VCLT, *supra* note 36, Arts. 11, 12.

[129] The ICCPR, *supra* note 56, Art. 49(1).

យ៉ាងនេះ មិនតម្រូវទេ ពីព្រោះរដ្ឋភាគី អាចព្រមព្រៀងឲ្យសន្ធិសញ្ញា អនុវត្ត ជាបណ្ដោះអាសន្ន រង់ចាំការចូលជាធរមាន។[130]

សន្ធិសញ្ញា ស្ដីពីច្បាប់សន្ធិសញ្ញា និង ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ទាមទារឲ្យមានការចុះបញ្ជីសន្ធិសញ្ញា។[131] នេះគឺដើម្បីបង្ការកុំឲ្យមាន សន្ធិសញ្ញាសម្ងាត់ (Secret Treaty)។ ក្នុងករណី មិនបានចុះបញ្ជី សន្ធិសញ្ញាណាមួយនោះ នឹងមិនត្រូវបានអនុញ្ញាតឲ្យលើកយកមកសំអាង នៅពីមុខអង្គការសហប្រជាជាតិឡើយ។[132]

មានបញ្ហាជាច្រើនពាក់ព័ន្ធជាមួយនឹងការអនុវត្តសន្ធិសញ្ញា មុនពេលចូលជាធរមាន និង ក្រោយចូលជាធរមានរបស់សន្ធិសញ្ញាសម្រាប់រដ្ឋណាមួយ។ ចំពោះ បញ្ហាទី ២ នឹងបរិយាយក្នុងជំពូកខាងក្រោយ។ ករណីសន្ធិសញ្ញា មិនទាន់ចូលជាធរមាន ហើយរដ្ឋគ្រាន់តែចុះហត្ថលេខា សន្ធិសញ្ញា ស្ដីពីច្បាប់សន្ធិសញ្ញា ចែងតម្រូវឲ្យរដ្ឋកុំឲ្យបំផ្លាញកម្មវត្ថុរបស់សន្ធិសញ្ញា។[133] ឧទាហរណ៍ កម្មវត្ថុរបស់សន្ធិសញ្ញា គឺការរក្សាទន្លេជាអន្តរជាតិ ណាមួយ ដូចនេះរដ្ឋមិនត្រូវ ចាក់ដីលុបទន្លេនោះឡើយ។

### ៣.២.៣.អសុពលភាព និងការបញ្ចប់សន្ធិសញ្ញា

សន្ធិសញ្ញា ក្រោយពីចូលជាធរមាន អាចគ្មានសុពលភាព ឬត្រូវតែគ្មានសុពលភាព។ ភាពមាន ឬគ្មានសុពលភាព អាចបណ្ដាលមកពីការខុស

---

[130] The VCLT, *supra* note 36, Art. 25. For its commentary, *see* Krieger, *Provisional Application*, in Oliver Dorr, Vienna Convention on the Law of Treaties, A Commentary, 2012, p. 407.

[131] The UN Charter, *supra* note 42, Art. 102; the VCLT, *supra* note 36, Art. 80.

[132] The UN Charter, *supra* note 42, Art. 102(2).

[133] The VCLT, *supra* note 36, Art. 18.

នីតិវិធីនៃការទទួលយកសន្ធិសញ្ញាក្នុងស្រុក កម្មវត្ថុនៃសន្ធិសញ្ញា ឬពាក់ព័ន្ធជាមួយបុគ្គលដែលចូលរួមចុះហត្ថលេខាលើកិច្ចព្រមព្រៀង ឬសន្ធិសញ្ញា។[134]

សន្ធិសញ្ញាគ្មានប្រសិទ្ធភាព ពីព្រោះកម្មវត្ថុរបស់វាផ្ទុយនឹង វិធានច្បាប់អន្តរជាតិមានតម្លៃខ្ពស់បំផុត (*Jus Cogens*) ឬនាពេលកំពុងអនុវត្ត មានវិធានច្បាប់អន្តរជាតិ *Jus Cogens* បានកើតមានឡើង ដែលតម្រូវឲ្យសន្ធិសញ្ញាគ្មានសុពលភាព។[135] វាអាស្រ័យទៅ លើវិសាលភាព នៃភាពផ្ទុយគ្នារវាងសន្ធិសញ្ញា និង *Jus Cogens* ។ ដូចនេះ ជួនកាល មានតែបទប្បញ្ញត្តិតែមួយនៃសន្ធិសញ្ញា ដែលត្រូវតែមោឃភាព។[136] ភាពគ្មានសុពលភាពនេះ មិនចាំបាច់ឲ្យមានការអះអាង ពីរដ្ឋថាសន្ធិសញ្ញា គ្មានសុពលភាពទេ ។ នេះជាសុពលភាពដាច់ខាត។

ករណីខ្លះ បុគ្គលដែលចុះហត្ថលេខា មិនមានអំណាចផ្តល់ជូនដោយរដ្ឋ (Full Power) ក្នុងការចុះហត្ថលេខា។ សន្ធិសញ្ញាទីក្រុង Vienna បានកំណត់ពីបុគ្គល ដែលជាតំណាងរបស់រដ្ឋ ដែលអាចសម្តែងនូវការព្រមព្រៀង និងចងជាកាតព្វកិច្ចដល់រដ្ឋ ដូចជា ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល។[137] ជួនកាលករណីខ្លះ បុគ្គលនោះមានអំណាច តែបានរំលោភនីតិវិធីក្នុងស្រុក។ ឧទាហរណ៍ ប្រទេសខ្លះទាមទារឲ្យអ្នកត្រូវចុះហត្ថលេខា ត្រូវទទួលការអនុញ្ញាតពីសភាជាមុន។ ទោះបីជាយ៉ាងនេះក្តី សន្ធិសញ្ញានៅមានសុពល

[134] The VCLT, *supra* note 36, Art. 46.
[135] For *Jus cogens*, see the VCLT, *supra* note 36, Arts. 47-53; A. J.J. de Hoogh, *the relationship between Jus Cogens, Obligations erga omnes and International Crimes: Peremptaory norms in perspective*, 42 Austrian Journal of Public and International Law (1991), p. 185.
[136] The VCLT, *supra* note 36, Art. 44.
[137] *Id.,* Arts. 7, 17.

ភាព ប្រសិនបើភាគីម្ខាងដឹងថាភាគីម្ខាង ធ្វើផ្ទុយនីតិវិធីក្នុងស្រុក តែនៅតែមិនជំទាស់។[138] មាត្រា ៤២ នៃសន្ធិសញ្ញាទីក្រុង Vienna បានហាមមិនឲ្យលើកយកបញ្ហានេះ ដើម្បីធ្វើឲ្យសន្ធិសញ្ញាគ្មានសុពលភាពទេ លុះត្រាតែបានបំពេញលក្ខខណ្ឌពីរ។ ទី១ មានការរំលោភច្បាប់ និងទី ២ វិធានច្បាប់ក្នុងស្រុកដែលត្រូវបានរំលោភ មានសារៈសំខាន់ខ្លាំង។[139] អំពើធ្វើដោយបុគ្គលចែងក្នុងមាត្រា ៧ នៃសន្ធិសញ្ញា ទីក្រុងVienna មិនមានប្រសិទ្ធភាពទេ។ ក៏ប៉ុន្តែ វាអាចនឹងមានប្រសិទ្ធភាពប្រសិនបើរដ្ឋទទួលស្គាល់។[140] រដ្ឋចូលរួមចរចាដទៃទៀត ត្រូវធ្វើការជំទាស់ ជាមុន ចំពោះមន្ត្រីតំណាងរដ្ឋណាមួយដែលធ្វើហួសពីកម្រិតអំណាចទទួលបានក្នុងកិច្ចការងារចរចាចុះសន្ធិសញ្ញា ក្រោយពេលដែលរដ្ឋនោះ ត្រូវបានជូនដំណឹងអំពីការប្រព្រឹត្តដូចនេះ បើមិនដូចនេះទេ សេចក្តីយល់ព្រមរបស់មន្ត្រីរូបនោះ នឹងចងជាកាតព្វកិច្ចដល់រដ្ឋដែលមិនជំទាស់។[141]

មាត្រា៥១ និង ៥២ បានចែងពីការគំរាម ការបង្ខិតបង្ខំលើតំណាងរដ្ឋ ឬរដ្ឋតាមរយៈការគំរាមប្រើកម្លាំង ដែលនាំឲ្យការព្រមព្រៀងគ្មានសុពលភាព។ សន្ធិសញ្ញាដែលធ្វើឡើងដោយរដ្ឋឈ្លានពាន ជាមួយប្រទេសក្រោម ការឈ្លានពាន ក៏នឹងមិនមានសុពលភាពផងដែរ។[142]

ពាក់ព័ន្ធជាមួយនឹងពាក្យ "ប្រើកម្លាំង" រដ្ឋជាច្រើនមានទស្សនៈផ្ទុយគ្នា។ រដ្ឋមួយចំនួន ចង់ឲ្យពាក្យនេះ មានន័យទូលាយ រាប់បញ្ចូលការគាបសង្កត់

[138] Peter Malanczuk, IL, *supra* note 1, p.138.
[139] The VCLT, *supra* note 36, Art. 42.
[140] The VCLT, *supra* note 36, Art. 8.
[141] The VCLT, *supra* note 36, Art. 47.
[142] Anthony Aust, Handbook, *supra* note 2, p.108.

ផ្នែកសេដ្ឋកិច្ច ឬនយោបាយ។ ក្រុមរដ្ឋផ្សេងទៀត ស្នើថា ការប្រើកម្លាំង សំដៅទៅលើការប្រើកម្លាំងទំព។ តាមបទអត្ថាធិប្បាយ ស្តីពី មាត្រា ២(៤) នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ពាក្យ "កម្លាំង" សំដៅលើកម្លាំង យោធា។ ការបកស្រាយនេះ ត្រូវបានគាំទ្រ ដោយយោងទៅលើការបដិសេធ សេចក្តីស្នើ ដោយប្រទេស ប្រេសីល ដែលស្នើថា កម្លាំង រាប់បញ្ចូលការគាបសង្កត់ផ្នែកសេដ្ឋកិច្ច។[143]អ្នកនិពន្ធ គាំទ្រជំហរនេះ ពីព្រោះថាប្រសិនបើការគ្រាន់តែគាបសង្កត់ខាងផ្នែកសេដ្ឋកិច្ច នាំឲ្យការព្រមព្រៀងគ្មានផលវិបាកផ្លូវច្បាប់ ហើយសន្ធិសញ្ញា នឹងគ្មានសុពលភាព នោះសន្ធិសញ្ញាជាច្រើន អាចនឹងគ្មានសុពលភាព ពីព្រោះរដ្ឋក្នុងទ្វីបអឺរ៉ុបជារឿយៗ ដាក់សម្ពាធខាងសេដ្ឋកិច្ចជាច្រើនមកលើប្រទេសកំពុងអភិវឌ្ឍន៍។ ជាចុងក្រោយ នៅមានមូលដ្ឋានជាច្រើនទៀត ដែលនាំឲ្យសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងគ្មាន សុពលភាព ដូចជា ការក្លែងបន្លំ កំហុស ការសូកតំណាងរដ្ឋ ជាដើម។[144]

សន្ធិសញ្ញា ដែលគ្មានសុពលភាព អាចក្លាយជាសុពលភាព ប្រសិនភាគីទាំងពីរព្រមទទួលយក។[145] ដើម្បីឲ្យសន្ធិសញ្ញាគ្មានសុពលភាព ភាគីត្រូវធ្វើការទាមទារ បើគ្មានការទាមទារទេ សន្ធិសញ្ញានៅតែមានប្រសិទ្ធភាព។ រដ្ឋតាមរយៈ សកម្មភាព សម្តែងនូវជាការទទួលស្គាល់សន្ធិសញ្ញា ដែលគេគិតថាសន្ធិសញ្ញាមានសុពលភាព។ រដ្ឋ ដែលអះអាងថា សន្ធិសញ្ញាគ្មានសុពលភាព ត្រូវធ្វើការជូនដំណឹងដល់ភាគីដទៃ ហើយភាគីនោះ ត្រូវឆ្លើយ

[143] Bruno Simma, the Charter of the United Nations, A Commentary (Bruno, Commentary), 1995, p. 112.
[144] The VCLT, *supra* note 36, Arts. 48,49 and 50 .
[145] The VCLT, *supra* note 36, Arts. 51-52; Peter Malanczuk, IL, *supra* note 1, p. 140.

តប។[146] ក្នុងរយៈពេលមួយឆ្នាំ ប្រសិនមិនអាចឈានដល់ដំណោះស្រាយ ភាគីអាចប្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ។[147]

សន្ធិសញ្ញា អាចនឹងត្រូវបញ្ចប់ បើភាគីទាំងអស់ឯកភាពបញ្ចប់។[148] ការបញ្ចប់ អាចត្រូវបានធ្វើឡើងជាឯកតោភាគី តាមរយៈ ការដកខ្លួនចេញពីសន្ធិសញ្ញាដោយរដ្ឋ។[149] ការរំលោភកាតព្វកិច្ច ដោយរដ្ឋ ក៏អាចនាំឲ្យមានការបញ្ចប់ ឬផ្អាកអនុវត្តសន្ធិសញ្ញា។ ការរំលោភ ត្រូវតែមានលក្ខណៈធ្ងន់ធ្ងរ (Material Breach) ដែលភាគីអាចបញ្ចប់ សម្រាប់ជាទណ្ឌកម្មចំពោះការរំលោភកាតព្វកិច្ច។ ឧទាហរណ៍ សន្ធិសញ្ញា ចែងការផ្តោះផ្លូវស្រូវចំនួន ៥០០០តោន តែភាគីផ្តល់ ខ្វះមួយតោន នេះមិនមែនជាការបំពានធ្ងន់ធ្ងរទេ។ មាត្រា ៦០ នៃសន្ធិសញ្ញាទីក្រុង Vienna មិនត្រូវបកឲ្យទូលាយទេ។[150] ការមិនអាចបំពេញតាមឧក្នុងសន្ធិសញ្ញា ក៏អាចជាមូលហេតុនៃការបញ្ចប់ ឬដកខ្លួនចេញពីសន្ធិសញ្ញា ក៏ប៉ុន្តែមាត្រា ៦១(១) ទាមទារថាលុះត្រាមានការបាត់បង់ ឬការបំផ្លាញជាអចិន្ត្រៃយ៍នូវកម្មវត្ថុ ដែលចាំបាច់សម្រាប់ប្រតិបត្តិសន្ធិសញ្ញា។ ការបាត់បង់ជាបណ្តោះអាសន្ន ជាមូលដ្ឋានសម្រាប់ផ្អាកសន្ធិសញ្ញា។ រដ្ឋមិនអាចសំអាង ថាមិនអាចអនុវត្តសន្ធិសញ្ញា ដោយសារការរំលោភដោយខ្លួនឯងឡើយ។[151] ឧទហរណ៍ ភ្នំដែលជាកម្មវត្ថុនៃសន្ធិសញ្ញា ត្រូវបានផ្ទុះរលាយបាត់ ដោយសារទង្វើរបស់រដ្ឋនោះ។ ការផ្លាស់ប្តូរស្ថានភាពជាជុំកំភួន ឬការកើតមាននូវ *Jus Cogens* នាំឲ្យមានការបញ្ចប់

146 The VCLT, *supra* note 36, Arts. 65 to 86.
147 The VCLT, *supra* note 36, Art. 66.
148 *Id.,* Art. 45.
149 *Id.,* Art. 56.
150 Peter Malanczuk, IL, *supra* note 1, p. 143.
151 The VCLT, *supra* note 36, Art. 61.

សន្ធិសញ្ញា។ ការបញ្ចប់សន្ធិសញ្ញា អាចកើតមានឯកឯង ក្នុងករណី ផ្លាស់ប្តូរស្ថានភាព។ រដ្ឋអាចជ្រើសរើសថា ផ្អាកការអនុវត្តសន្ធិសញ្ញា ឬបញ្ចប់សន្ធិសញ្ញា។

### ៣.២.៤. ខរក្សាសិទ្ធិមិនអនុវត្ត

ច្បាប់ជាតិគ្រប់គ្រងកិច្ចការងារក្នុងប្រទេស ផ្ទុយពីច្បាប់អន្តរជាតិ ដែលគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋ និង រដ្ឋ។ ជាសត្យានុម័ត ច្បាប់ទាំងពីរ អាចមានចំណុចផ្ទុយគ្នា។ នៅពេលរដ្ឋចូលជាភាគីសន្ធិសញ្ញា ដោយសារភាពផ្ទុយគ្នារវាងច្បាប់ទាំងពីរ រដ្ឋអាចនឹងមានបញ្ហាក្នុងការអនុវត្តច្បាប់អន្តរជាតិនៅក្នុងប្រទេស។ នេះអាចជាហេតុផលមួយ ដែលច្បាប់អន្តរជាតិ អនុញ្ញាតឲ្យមានការចុះខរក្សាសិទ្ធិមិនអនុវត្ត (Reservation)។ រដ្ឋមានឆន្ទានុសិទ្ធិក្នុងការចុះខរក្សាសិទ្ធិនេះ។ ខរក្សាសិទ្ធិ ដែលផ្អាកការអនុវត្តបទប្បញ្ញត្តិណាមួយ ទុកពេលដល់រដ្ឋឲ្យកែសម្រួលច្បាប់ឲ្យរួចរាល់ ដែលអាចអនុវត្តតាមខសន្ធិសញ្ញាបាន រដ្ឋអាចដកខនេះ នៅពេលណាដែលខ្លួនចង់ ដូចជាក្រោយដែលច្បាប់ជាតិ និងអន្តរជាតិ មានភាពស៊ីសង្វាក់គ្នា។

ខរក្សាសិទ្ធិ មានន័យថាជាសេចក្តីថ្លែងការណ៍ជាឯកតោភាគី ក្នុងគោលបំណងផ្លាស់ប្តូរន័យដើមនៃខ្លឹមសារ បទប្បញ្ញត្តិ ដោយរដ្ឋ ដែលចុះខរក្សាសិទ្ធិ។ វាអាចក្នុងទម្រង់មានឈ្មោះផ្សេងៗ ដូចជាសេចក្តីថ្លែងការណ៍ ឬការយល់ឃើញ (Understanding)។[152]

[152] The VCLT, *supra* note 36, Art.1; reservation of Chile when ratification of the Torture Convention, *see* www.treaties.un.org/Pages/ViewDetails; www.bayefsky.com/docs.php/area/reservations/node/1/state/35

សន្ធិសញ្ញាទីក្រុង Vienna ចែងអំពីខរក្សាសិទ្ធិ ការជំទាស់ និងសុពលភាពនៃខរក្សាសិទ្ធិ។ ទោះបីជាយ៉ាងនេះក្តី មានបញ្ហាជាច្រើន មិនត្រូវបានចែងបញ្ជាក់ក្នុងសន្ធិសញ្ញានេះទេ។ រដ្ឋ អាចចុះខរក្សាសិទ្ធិ ជាពិសេសនៅពេលរដ្ឋផ្តល់ សច្ចាប័នដល់សន្ធិសញ្ញា។ រដ្ឋជាភាគីណាមួយ អាចជំទាស់ខរក្សាសិទ្ធិ។ ការជំទាស់នេះ នឹងនាំឲ្យបទប្បញ្ញត្តិ ដែលត្រូវបានចុះខរក្សាសិទ្ធិនឹងមិនចងជាកាតព្វកិច្ចដល់រដ្ឋជំទាស់ឡើយ។[153] សន្ធិសញ្ញាទីក្រុងវៀនបានកំណត់ថា ក្នុងអំឡុង ១២ ខែក្រោយពី ខរក្សាសិទ្ធិ ត្រូវបានចុះ បើរដ្ឋមិនជំទាស់ទេ នោះមានន័យថា រដ្ឋយល់ព្រមលើខនោះ។[154] ទោះបីជា រដ្ឋជំទាស់ខរក្សាសិទ្ធិក្តី រដ្ឋចុះខរក្សាសិទ្ធិនៅតែជាភាគីនៃសន្ធិសញ្ញាជាដដែល។ ខរក្សាសិទ្ធិណាមួយ មិនមានប្រសិទ្ធភាព លុះត្រារដ្ឋទាំងអស់ជំទាស់។ ដូចគ្នានេះ ដើម្បីឲ្យខរក្សាសិទ្ធិណាមួយមានប្រសិទ្ធភាព រដ្ឋទាំងអស់ត្រូវយល់ព្រម។[155]

សន្ធិសញ្ញា ខ្លះមិនបានចែងអំពីខរក្សាសិទ្ធិ។[156] សន្ធិសញ្ញាខ្លះ មានចែងឲ្យចុះខរក្សាសិទ្ធិជាក់លាក់[157] ហើយខ្លះមិនបានចែងយ៉ាងនេះទេ។[158] បញ្ហាដ៏ចម្រូងចម្រាសបានកើតមាន នាពេលដែលរដ្ឋស្ទើរទាំងអស់ បានចូល

---

153 The VCLT, *supra* note 36, Art. 21.
154 *Id.,* Art. 20(5).
155 *Id.,* Art. 20(2).
156 Human Rights Committee, General Comment No.24 on Issues relating to reservations made upon ratification to the Convention (General Comment No. 24), U.N. Doc. CCPR/C/21/Rev.1/Add.6 (1994), para. 5.
157 The European Convention for the Protection of Human Rights and Fundamental Freedoms (the ECHR), Nov. 4, 1950, 213 U.N.T.S. 221, Art. 57.
158 General Comment No. 24, *supra* note 156, para. 6; for relevance, *see* the VCLT, *supra* note 36, Art. 19.

ជាភាគី អនុសញ្ញា ស្តីពី ការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ហើយរដ្ឋជាច្រើន បានចុះខរក្សាសិទ្ធិមិនអនុវត្តមាត្រាមួយចំនួន។ បញ្ហានេះ នាំឲ្យគណៈកម្មាធិការសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ បង្កើតឡើងតាមកតិកាសញ្ញា ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ បានលើកយកបញ្ហា ការចុះខរក្សាសិទ្ធិ មកពិភាក្សា។

គណៈកម្មាធិការ បានចេញនូវបទអធិប្បាយ ស្តីពី ខរក្សាសិទ្ធិមិនអនុវត្ត។[159] គណៈកម្មាធិការ បានគូសបញ្ជាក់ថា ប្រការដែលសន្ធិសញ្ញាមួយចំនួន មិនបានចែងអំពីខរក្សាសិទ្ធិមិនអនុវត្ត មិនបានន័យថា រដ្ឋមិនអាចចុះខនោះបានទេ។[160] វាអាស្រ័យទៅតាម ការកំណត់របស់សន្ធិសញ្ញានីមួយៗ។ បញ្ហាសំខាន់ ថាតើខនោះ ស្របជាមួយនឹងគោលបំណងរបស់សន្ធិសញ្ញា ដែរឬទេ? គណៈកម្មាធិការ មិនបានកំណត់ឲ្យបានជាក់លាក់ អ្វីជាគោលបំណង គ្រាន់តែផ្តល់ជាសញ្ញាណ តាមរយៈការលើកជាឧទាហរណ៍។ ប្រសិនបើសន្ធិសញ្ញា ទាមទារឲ្យរដ្ឋដាក់របាយការណ៍ ដល់គណៈកម្មាធិការពិនិត្យ ដើម្បីតាមដានមើលថា តើរដ្ឋបានអនុវត្តតាមកាតព្វកិច្ចឬទេ ហើយរដ្ឋចុះខរក្សាសិទ្ធិ ដែលផ្អែកតាមនេះ មិនដាក់របាយការណ៍ ជូនគណៈកម្មាធិការ ខនេះផ្ទុយពីគោលបំណងរបស់ន្ធិសញ្ញា។[161] បន្ថែមពីលើនេះ ប្រសិនបើខរក្សាសិទ្ធិណាមួយ ចែងមិនអនុវត្ត សិទ្ធិដាច់ខាត (Non-Deragble Rights)

159 The General Comment No. 24, *supra* note 156, p. 210.
160 *Id.,* para. 6.
161 *Id.*, para. 11.

ដូចជាសេរីភាពរួចផុតពីអំពើទារុណកម្មជាដើម[162] ខនេះនឹងខុសពីគោលបំណងរបស់សន្ធិសញ្ញា។

សំណួរមួយត្រូវបានលើកឡើងថា៖ បើគណៈកម្មាធិការរកឃើញថា ខរក្សាសិទ្ធិចុះដោយរដ្ឋណាមួយ មិនស្របជាមួយនឹងគោលបំណង តើខនោះ នៅមានសុពលភាពឬទេ? គណៈកម្មាធិការផ្តល់ចម្លើយជាវិជ្ជមាន។ ខនោះនឹងមិនមានសុពលភាព ហើយគណៈកម្មាធិការអាចធ្វើមិនដឹងមិនឮចំពោះខនោះ។[163]

គណៈកម្មាធិការ ហាក់ប្រកាន់នូវជំហរកណ្តាល ដោយមិនតម្រូវឲ្យមានការទទួលស្គាល់ខរក្សាសិទ្ធិ ដោយរដ្ឋទាំងអស់ទេ។ នេះដើម្បី ឲ្យរដ្ឋជាច្រើនបានចូលជាភាគីសន្ធិសញ្ញាសិទ្ធិមនុស្ស ស្របពេលគ្នានេះ បដិសេធនូវ ខណាមួយដែលខុសពីគោលបំណង។[164]

ការហ៊ានអះអាងថា ខ ណាមួយមិនស្របជាមួយនឹងគោលបំណងនៃសន្ធិសញ្ញា ហើយមិនមានសុពលភាព គឺជាបដិវត្តន៍ទ្រឹស្តីដ៏សម្បើមមួយ។ ពីព្រោះថា ទី១. គណៈកម្មាធិការ គ្មានអំណាចដាក់លាក់ក្នុងការពិចារណាមើលលើ ខរក្សាសិទ្ធិមិនអនុវត្ត និងទី២ មានតែរដ្ឋទេ ដែលអាចជំទាស់ ដល់ខរក្សាសិទ្ធិចុះដោយរដ្ឋ ហើយការបដិសេធមិននាំឲ្យខរក្សាសិទ្ធិគ្មានសុពលភាពទូទៅ ក្រៅពីខ្លួនដែលជារដ្ឋជំទាស់ឡើយ។ គណៈកម្មាធិការ បានពន្យល់ថា ការពិចារណាលើខរក្សាសិទ្ធិ គឺផ្នែកមួយនៃកិច្ចការងាររបស់ខ្លួន។

---

[162] *Id.*, para. 10.

[163] General Comment No. 24, *supra* note 156, para. 18.

[164] *Id.*

បើទោះបីជា កតិកាសញ្ញា ស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ មិនបានចែងក្តី គណៈកម្មាធិការ មានអំណាចដោយប្រយោល (Implied Power)។ ការពិនិត្យនេះ វាជាការងារសំខាន់ ជាពិសេស ក្នុងដំណើរពិនិត្យបណ្តឹងរបស់បុគ្គល ប្តឹងប្រឆាំងរដ្ឋ ដែលបញ្ហា ខរក្សាសិទ្ធិមានជាប់ពាក់ព័ន្ធ។[165] គណៈកម្មាធិការ ក៏បានបញ្ជាក់ផងដែរអំពី ការអនុវត្តជាក់ស្តែងរបស់រដ្ឋ ទាក់ទិនជាមួយនឹង ខរក្សាសិទ្ធិមិនអនុវត្ត។ សន្ធិសញ្ញាសិទ្ធិមនុស្ស មានគោលបំណងការពារសិទ្ធិមនុស្ស ប្រឆាំងនឹងអាជ្ញាធររដ្ឋ ដូចនេះ កម្រនឹងមានរដ្ឋណាមួយ អើពើជំទាស់ជាមួយនឹងខរក្សាសិទ្ធិណាស់។[166] តាមការវិភាគ នេះមានន័យថា ការធ្វើអន្តរាគមរបស់ គណៈកម្មាធិការ គឺជាការងារមួយសមហេតុផល។

ជាការពិតណាស់ ការធ្វើបដិវត្តទ្រឹស្តីរបស់គណៈកម្មាធិការ ប៉ះនឹងផលប្រយោជន៍ នឹងនាំឲ្យរដ្ឋមួយចំនួន មានសហរដ្ឋអាមេរិក[167] បារាំង[168] និងចក្រភពអង់គ្លេស[169] ធ្វើការជំទាស់ ដោយសាររដ្ឋទាំងនេះ អាចបាត់បង់អំណាច ហើយខរក្សាសិទ្ធិមួយចំនួនរបស់ពួកគេ ដែលបម្រើផលប្រយោជន៍នឹងត្រូវបានបដិសេធ ដោយគណៈកម្មាធិការ។ និយាយជារួម រដ្ឋទាំងបីនេះ មិនចង់ឲ្យគណៈកម្មាធិការមានអំណាចទេ ពាក់ព័ន្ធខរក្សាសិទ្ធិមិនអនុវត្ត។

[165] General Comment No. 24, *supra* note 156, para. 18.

[166] *Id*.

[167] The reply of the USA, *see* www.bayefsky.com/docs.php/ area/govresp/ node/2/ treaty/ccpr/opt/0/node/3/state/184

[168] The reply of France, *see* www.bayefsky.com/docs.php/area/govresp/node/2/ treaty/ccpr/opt/0/node/3/state/62

[169] The reply of UK, *see* www.bayefsky.com/docs.php/area/govresp/node/2/ treaty/ccpr/opt/0/node/3/state/182.

ដោយសារភាពចម្រូងចម្រាសដូចនេះហើយ ទើបបានជា គណៈកម្មការច្បាប់អន្តរជាតិ បានរៀបចំធ្វើសេចក្តីព្រាងណែនាំស្តីពី ខរក្សាសិទ្ធិមិនអនុវត្ត។ មកដល់ពេលនេះ វានៅតែជាសេចក្តីព្រាងនៅឡើយ ហើយអាចនឹងត្រូវបានបញ្ចប់ក្នុងពេលឆាប់ៗ[170]។

## ៣.២.៥. ការបកស្រាយសន្ធិសញ្ញា

### ៣.២.៥.១. វិធីផ្អែកតាមចេតនារបស់អ្នកធ្វើច្បាប់[171]

វិធីសាស្ត្របកស្រាយរបៀបនេះ ត្រូវបានគេប្រើយ៉ាងហោចណាស់តាំងពីសតវត្សរ៍ទី១៩។ ការប្រកាន់យកវិធីនេះ គឺផ្អែកលើមូលដ្ឋាននៃ ឥស្សរភាពរបស់សភាដែលជាអ្នកធ្វើច្បាប់។ ច្បាប់ដែលធ្វើដោយសភា ត្រូវបានគេសន្មតថាមានភាពជាក់លាក់។ អាស្រ័យហេតុនេះ ចេតនារបស់សភា ដែលជាអ្នកធ្វើច្បាប់ ត្រូវបានគេផ្តល់តម្លៃក្នុងការស្រាយបំភ្លឺភាពស្រពិចស្រពិលក្នុងច្បាប់។ ក្រោយមក វិធីបកស្រាយនេះត្រូវបានប្រើ ដោយពង្រីក ដោយមិនគ្រាន់តែផ្អែកលើចេតនារបស់អ្នកធ្វើច្បាប់ទេ ថែមទាំងពិនិត្យមើលឯកសារពាក់ព័ន្ធដទៃទៀត ដូចជា យោបល់របស់អ្នកជំនាញ។[172] អ្នកសិក្សាស្រាវជ្រាវច្បាប់ បានស្នើថា វិធីនេះគួរតែបានប្រើសម្រាប់ការបកស្រាយបញ្ហាខ្លឹម

[170] Reservations to Treaties, Text and Title of the draft guidelines provisionally adopted by the Drafting Committee on 5,6,18,19, 27, 28 and 29 May 2009, A/CN.4/L.744; *see* also the Work of the International Law Commission, 7th ed., Vol. 1, 2007, p.90.

[171] It is the exegetic method which makes use of legislative history, *see* Claire M. Germain, *Approaches to Statutory Interpretation and Legislative History in France* (Claire, Approaches), 13 Duke Journal of Comparative and International Law, 197 (2003).

[172] *Id.,* p. 200.

សារច្បាប់ ដែលទើបតែត្រូវបានអនុម័តនាពេលថ្មីៗ។[173] ការអះអាងនេះវាអាច ជាការត្រឹមត្រូវ ដោយសារ អ្នកធ្វើច្បាប់ កាលពី២០ ឬ៣០ឆ្នាំមុន មិនបាន ធ្វើច្បាប់ឲ្យបានគ្រប់ជ្រុងជ្រោយសម្រាប់តម្រូវតាមស្ថានភាព ៣០ឆ្នាំក្រោយ ឡើយ។[174] ដូចនេះ ចេតនាដែលអ្នកធ្វើច្បាប់មានកាលពី ៣០ឆ្នាំមុន អាចមិនឆ្លុះនឹងស្ថានភាពបច្ចុប្បន្នបានទេ។ បន្ថែមពីលើនេះ អ្នកធ្វើច្បាប់អាច លម្អៀងទៅរកក្រុមណាមួយ ដែលជះឥទ្ធិពលលើខ្លឹមសារច្បាប់។[175] វាប្រហែលមកពីហេតុផលយ៉ាងនេះ ទើបក្រោយមក វិធីសាស្ត្រនេះ មិនសូវមានការចាប់អារម្មណ៍ ហើយថៅក្រមងាកមកប្រើវិធីបកស្រាយមួយរបៀបទៀត (ការបកស្រាយទូលាយ)។

### ៣.២.៥.២. វិធីបកស្រាយទូលាយ

វិធីនេះ ជាវិធីដោយពិនិត្យមើលលើខ្លឹមសារនៃមាត្រាច្បាប់ និងកត្តាមួយចំនួនច្រើនទៀតដូចជាស្ថានភាពសង្គម។ អ្នកសិក្សាស្រាវជ្រាវ បានស្នើឲ្យប្រើ វិធីនេះ សម្រាប់បកស្រាយច្បាប់ ដែលមានជាយូរមកហើយ។[176] អ្នកបកស្រាយនឹងពិនិត្យមើល ខ្លឹមសារនៃពាក្យពេចន៍ ព្រមទាំងវេយ្យាករណ៍ក្នុងឃ្លា ពិនិត្យមើលគោលបំណងនៃច្បាប់ កាលៈទេសៈនៃសង្គម ស្ថានភាពនាពេលដែលច្បាប់ត្រូវបានអនុម័ត ឯកសារពាក់ព័ន្ធសម្រាប់អនុវត្តន៍ច្បាប់ ចេតនារបស់អ្នកធ្វើច្បាប់ មាត្រាច្បាប់ដែលពាក់ព័ន្ធ និងការអនុវត្តច្បាប់ដោយតុលាការជាតិ និងអន្តរជាតិ។ វិធីសាស្ត្រនេះ មានភាពបត់បែន និងអាចឆ្លើយតប

[173] *Id.*, p. 201.

[174] H. Jefferson Powell, *the Original Understanding of Original Intent* (H. Jefferson, the Original), 98 (5) Harv. L. Rev. 1(1985)

[175] *Id.*

[176] Claire, Approaches, *supra* note 171, p. 201.

ទៅតាមស្ថានភាពសង្គមបច្ចុប្បន្ន[177] ហើយត្រូវបានប្រើប្រាស់ដោយតុលាការអន្តរជាតិជាច្រើន[178] ពិសេសជាងនេះទៅទៀត សន្ធិសញ្ញា ស្តីពីច្បាប់សន្ធិសញ្ញា បានចែងទទួលយកវិធីសាស្ត្រនៃការបកស្រាយនេះ។[179]

### ៣.២.៥.២.១. អត្ថន័យនៃពាក្យ ក្នុងបរិបទគោលបំណង

ពាក់ព័ន្ធជាមួយពាក្យពេជន៍ ពាក្យ "ត្រូវតែ" មានន័យជាកាតព្វកិច្ច ដែលត្រូវធ្វើតាមចំណែកឯពាក្យ "គួរតែ" គ្រាន់តែបង្ហាញអំពី អនុសាសន៍ ដែលមិនចងជាកាតព្វកិច្ច។[180] ពាក្យ "ដូចជា" មានន័យ ជាពាក្យ បង្ហាញជាឧទាហរណ៍នូវអ្វី ដែលនៅមានជាច្រើនទៀត ដែលអ្នកធ្វើច្បាប់គិតថា មិនចាំបាច់សរសេរបញ្ចូលទាំងអស់ក្នុងមាត្រាច្បាប់។ មាត្រា ២ នៃកតិកាសញ្ញាស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ ចែងអំពីការហាមឃាត់ការរើសអើងផ្អែកលើមូលដ្ឋានមួយចំនួន *ដូចជា* ពូជ សាសន៍ ពណ៌សម្បុរ។[181] ការប្រើពាក្យ "ដូចជា" ន័យរបស់ពាក្យពេជន៍ មិនត្រូវបានបកស្រាយ ដោយគ្មានយោងទៅលើគោលបំណងនៃច្បាប់ឡើយ។

---

[177] Philippe Boillat, the European Convention on the Human Rights at 60: Building on the Past, Looking to the Furture, 2008, p. 3; *Artico v. Italy*, A 37 (1980); 3 EHRR 1, para. 33; Judge v. Canada (*Judge v. Canada*), Communication No. 829/1998, U.N. Doc. CCPR/C/78/D/829/1998 (2003), para. 10.3.

[178] For example, *Soering v. the United Kingdom*, No. 14038/88 [1989] ECHR 14 (July 7, 1989).

[179] The VCLT, *supra* note 36, Art. 31.

[180] LAGRANT Case (Germany v. United States of America), Summary of 27 June 2001 Judgment, pp. 195-196, at www.icj-cij.org; the HRC, *Sultanova et al. v. Uzbekistan,* Communication 915/2000, 20 March 2006, para. 5.2.

[181] The English will be "such as" which expresses "non-exhaustive"; the ICCPR, *supra* note 56.

គោលបំណង អាចប្រែប្រួលទៅតាមប្រភេទនៃច្បាប់ ឬ សន្ធិសញ្ញា។ ឧទាហរណ៍ គោលបំណងនៃសន្ធិសញ្ញា ពាក់ព័ន្ធជាមួយសិទ្ធិមនុស្ស គឺដើម្បីការពារផលប្រយោជន៍របស់បុគ្គល ហេតុដូចនេះ ការបកស្រាយត្រូវតែបកស្រាយយ៉ាងណា ផ្តល់ន័យដល់ការការពារផលប្រយោជន៍ជាក់ស្តែង។[182] ទន្ទឹមនឹងនេះ ការបកស្រាយន័យនៃពាក្យ ត្រូវពិចារណាថ្លឹងថ្លែងផងដែរនូវខ្លឹមសារនៃមាត្រាក្នុងច្បាប់ដែលមានបញ្ហា ឬច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត។ មាត្រា ១ នៃកតិកាសញ្ញា ស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ ទាមទារឲ្យរដ្ឋជាភាគី គោរព និងធានាឲ្យបានប្រាកដប្រជា នូវសិទ្ធិរបស់បុគ្គល *ស្ថិតនៅក្នុងដែនដី និង ស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន។*[183] តាមន័យធម្មតាពាក្យ "និង" ក្នុងឃ្លានេះ មានន័យគួបផ្សំ។ ផ្ទុយទៅវិញ គណៈកម្មាធិការសិទ្ធិមនុស្សបានបកស្រាយដោយមើលរំលងនូវន័យធម្មតា ដោយផ្តោត ជាសំខាន់លើគោលបំណងនៃសន្ធិសញ្ញា និងចរិតលក្ខណៈប្រែប្រួលនៃសិទ្ធិមនុស្ស ដែលតាមរយៈនេះ បង្កើតនូវកាតព្វកិច្ចគោរពសិទ្ធិសេរីភាព ដល់រដ្ឋចំពោះទង្វើធ្វើដោយអាជ្ញាធររបស់រដ្ឋ សូម្បីអំពើដែលពាក់ព័ន្ធកើតមាន នៅក្រៅដែនដី។[184]

ក្នុងរឿងក្តីប្រឆាំង នឹងអូស្រ្តាលីប្តឹងដោយ ប្រជាពលរដ្ឋកម្ពុជា ពាក់ព័ន្ធជាមួយនឹងការត្រួតពិនិត្យដោយតុលាការ លើភាពស្របច្បាប់នៃការឃុំខ្លួនរបស់ខ្លួន អូស្រ្តាលី បានអះអាងថា ពាក្យ "ច្បាប់" ដែលមានចែងនៅក្នុងសន្ធិ

[182] The HCR, General Comment No. 31 on the Nature of the General Legal Obligation Imposed on States Parties to the Covenant (the General Comment No. 31), CCPR/C/21/Rev.1/Add.13 (2004), para.3.
[183] The ICCPR, *supra* note 56.
[184] The General Comment No. 31, *supra* note 182, para.10.

សញ្ញា គឺសំដៅលើ "ច្បាប់ជាតិ"។ ដូច្នេះ ប្រសិនបើការឃុំខ្លួនត្រូវបាន អនុញ្ញាតក្នុងច្បាប់ជាតិ ទង្វើឃុំខ្លួននោះមិនខុសច្បាប់ជាតិ ការឃុំនឹងមិន រំលោភមាត្រា ៩ នៃកតិកាសញ្ញាស្តីពី នយោបាយ និងប្រជាពលរដ្ឋឡើយ ។[185] គណៈកម្មាធិការសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ ដែលជា ស្ថាប័នទទួលពិនិត្យមើលរឿងក្តីនេះ បានអះអាងថា ការឃុំខ្លួនត្រូវផ្អែកលើ លក្ខខណ្ឌចាំបាច់ ដែលតម្រូវឲ្យមានការឃុំខ្លួន។ នេះទាមទារឲ្យមានការ ពិនិត្យឡើងវិញ ថាតើលក្ខខណ្ឌតម្រូវសម្រាប់ធ្វើឲ្យការឃុំខ្លួនស្របច្បាប់ នៅ មានឬទេ។ ប្រសិនបើលក្ខខណ្ឌនោះ លែងមាន អាជ្ញាធរត្រូវដោះលែងបុគ្គល ដែលពាក់ព័ន្ធឲ្យមានសេរីភាព។ ច្បាប់តម្រូវឲ្យមានការពិនិត្យជាទៀងទាត់នូវ មូលដ្ឋាន ដែលនាំឲ្យមានការឃុំខ្លួន។ ប្រសិនការឃុំខ្លួន គ្មានការត្រួតពិនិត្យ ដូចដែលទាមទារនោះទេ ការឃុំខ្លួនអាចត្រូវបានចាត់ជា អំពើអមនុស្សធម៌ ដែលរំលោភមាត្រាផ្សេងទៀតនៃកតិកាសញ្ញានេះ។[186] តាមរយៈនេះ ការបក ស្រាយន័យនៃពាក្យ "ច្បាប់" ដោយគណៈកម្មាធិការ គឺមិនបានបកស្រាយ តាមន័យចំឡើយ។ វាគឺជាការបកស្រាយន័យរបស់ ពាក្យ ក្នុងបរិបទ នៃ គោលបំណងសន្ធិសញ្ញា ព្រមទាំងយោងដល់បទប្បញ្ញត្តិដទៃទៀតក្នុងសន្ធិ សញ្ញាដដែលនេះ។[187] ពាក្យ "ច្បាប់ " មិនមែនសំដៅ តែលើច្បាប់ជាតិ នោះទេ តែត្រូវផ្អែកលើច្បាប់អន្តរជាតិផងដែរ។[188]

ស្រដៀងគ្នានេះដែរ ពាក់ព័ន្ធជាមួយនឹងការបកស្រាយពាក្យ "ទណ្ឌកម្មស្រប ច្បាប់" ដែលមានចែងក្នុងមាត្រា ១ នៃកតិកាសញ្ញា ស្តីពីការប្រឆាំង

---

[185] The ICCPR, *supra* note 56; A v. Australia, Communication No. 560/1993, CCPR/C/59/D/560/1993 (Apr. 3, 1997), para. 9.5.
[186] *A v. Australia*, *supra* note 185, para. 9.5.
[187] *Id.*, para. 9.5.
[188] *Id.*, para. 9.5.

ជាមួយនឹងអំពើទារុណកម្ម មានសំណួរបានលើកឡើងថា៖ តើពាក្យនេះ សំដៅលើទណ្ឌកម្មអនុញ្ញាត ដោយច្បាប់ជាតិ ឬទាំងច្បាប់អន្តរជាតិ? បញ្ហា បានកើតឡើងរួចមក ហើយពាក់ព័ន្ធ នឹងទណ្ឌកម្ម "ចោលដុំថ្មសម្លាប់" (Stoning to Death) ដែលមានចែងអនុញ្ញាតដោយច្បាប់របស់ អ៊ីរ៉ង់។ តើអំពើចោលដុំថ្ម សម្លាប់មនុស្ស មិនមានជាអំពើអមនុស្សធម៌ ឬទារុណកម្ម ដែរឬទេ?[189] ទណ្ឌកម្ម ចោលដុំថ្ម ធ្វើឲ្យមានសេចក្តីសង្វេគជាខ្លាំងក្នុង ចំណោមសាធារណជន ដែលបានឃើញព្រឹត្តិការណ៍នេះ។ ជនរងគ្រោះ ទទួលរងនូវការឈឺចាប់ជាខ្លាំងមុននឹងស្លាប់។ ទណ្ឌកម្មប្រភេទនេះ វា ពាក់ព័ន្ធជាមួយការហាមឃាត់អំពើ អមនុស្សធម៌ និងអំពើទារុណកម្ម ដែល ត្រូវបានចែងឲ្យគោរពដោយ គ្មានការលើកលែង។[190] នេះទាមទារឲ្យមាន ការ បកស្រាយទូលាយ ដោយមិនគ្រាន់តែពិចារណាលើន័យត្រង់នៃពាក្យណា មួយឡើយ។ ការបកស្រាយ ទាមទារផងដែរនូវការពិនិត្យមើល មាត្រាដែល ពាក់ព័ន្ធដទៃទៀត។

គណៈកម្មាធិការសិទ្ធិមនុស្សរបស់អន្តរទ្វីបអាមេរិក បានបកស្រាយបទប្បញ្ញត្តិ ហាមមិនឲ្យមានការដេញមនុស្សប្រសិនបើ អ្នកដែលនឹងត្រូវបាន បណ្តេញ នឹងជួបរងគ្រោះថ្នាក់នៃអំពើ ធ្វើទុក្ខបុកម្នេញ ដោយពង្រីកការ ហាមនេះ រាប់បញ្ចូលទាំងការហាមដេញ នៅក្រៅដែនដីរបស់ខ្លួន ក្នុងរឿងក្តី បណ្តេញចេញជនជាតិ *ហៃទី* ដោយអាជ្ញាធរសហរដ្ឋអាមេរិក នៅក្នុងបរិវេណ

[189] The Convention against Torture and Other Cruel, Inhuman or Degrading Treatment or Punishment ( the Torture Convention) , Dec. 10, 1984, 1465 U.N.T.S. 85.

[190] The ECHR, *supra* note 157, Art. 3; the ICCPR, *supra* note 56, Art. 4.

សមុទ្រអន្តរជាតិ។ នេះបង្ហាញពីការបកស្រាយ ផ្តល់ភាពសំខាន់ដល់គោលបំណងរបស់កតិកាសញ្ញា។[191]

### ៣.២.៥.២.២. ស្ថានភាពសង្គម និងប្រសិទ្ធភាពនៃកតិកាសញ្ញា

វាជាការពិតណាស់ ជួនកាលច្បាប់ណាមួយ ត្រូវបានធ្វើឡើងជាយូរយារមកហើយ ដែលមិនសមស្របទៅតាមតម្រូវការបច្ចុប្បន្ន។ ពាក់ព័ន្ធជាមួយនឹងវិវាទ ដែលបុគ្គលម្នាក់បំពារបំពាន លើបូរណភាពរាងកាយរបស់ម្នាក់ទៀត ដែលច្បាប់ជាតិមិនបានផ្តល់ឱកាសដល់ជនរងគ្រោះ ដើម្បីប្តឹងទារសំណងពីជនប្រព្រឹត្តខុសឆ្គងមកលើខ្លួន តុលាការសិទ្ធិមនុស្សអឺរ៉ុប បានយោងដល់កំណើននៃអំពើហិង្សា និងផលវិបាករបស់វា ហើយបានបកស្រាយមាត្រាសិទ្ធិមនុស្សដែលពាក់ព័ន្ធ បង្កើតឲ្យមានកាតព្វកិច្ចវិជ្ជមាន។ កាតព្វកិច្ចនេះទាមទារឲ្យរដ្ឋជាភាគី អន្តរាគមន៍ក្នុងទំនាក់ទំនងរវាងបុគ្គល ដើម្បីជានាឲ្យជនរងគ្រោះ ទទួលបានយុត្តិធម៌។ ក្នុងរឿងក្តីនេះ តុលាការបានតម្រូវឲ្យរដ្ឋជាភាគីក្នុងរឿងក្តី ធ្វើច្បាប់បើកច្រកឲ្យជនរងគ្រោះអាចដាក់ពាក្យបណ្តឹងបាន។[192]

ក្នុងរឿងក្តី លោកសូរីង (*Soering*) ដែលពាក់ព័ន្ធជាមួយបត្យាប័ន *សូរីង* ពីប្រទេសអង់គ្លេស ទៅប្រឈមទោសប្រហារជីវិតនៅសហរដ្ឋអាមេរិក អង់គ្លេស បានតបឆ្លើយចំពោះ ការចោទប្រកាន់ថា បត្យាប័ន លោកសូរីង អាចនឹងរំលោភសិទ្ធិរួចផុតពីអំពើអមនុស្សធម៌ និងទារុណកម្ម ដែលអាច

[191] *Petitioners v. Haitian Centers Council*, Inc, et al. (*Haitian Case*), No. 92-344 (June 21, 1993), 113 S. Ct. 2549, para. 49; Report No.51/96, Decision of the Inter-American Commision on Human Rights as to the Merit of Case 10.675, United State (1997).

[192] *X and Y v. the Netherlands (X and Y)*, 91 Eur. Ct. H.R. (ser. A) (1985), para. 23.

នឹងកើតមាននៅសហរដ្ឋអាមេរិក ដោយអាជ្ញាធរសហរដ្ឋអាមេរិកដោយសំអាងលើ មាត្រា ១ នៃសន្ធិសញ្ញា ស្តីពីសិទ្ធិមនុស្សរបស់ អឺរ៉ុប ដែលមិនបានចែងឲ្យរដ្ឋទទួលខុសត្រូវចំពោះអំពើក្រៅដែនដី ដោយអាជ្ញាធររដ្ឋផ្សេង។[193] តុលាការសិទ្ធិមនុស្សអឺរ៉ុប បានទទួលស្គាល់ ការលើកឡើងរបស់អង់គ្លេស ក៏ប៉ុន្តែតុលាការ បានថ្លែងថា បញ្ហាសិទ្ធិមនុស្សជាបញ្ហាមានភាពប្រែប្រួល។[194] ការហាមឃាត់អំពើទារុណកម្ម និងអំពើអមនុស្សធម៌ ជាតម្លៃមួយដ៏សំខាន់របស់តំបន់អឺរ៉ុប។ ម្យ៉ាងទៀត អំពើអមនុស្សធម៌ដែលកើតមានឡើងលើ *សូរីង* នៅក្នុងសហរដ្ឋអាមេរិក ជាលទ្ធផលនៃបត្យាប័នធ្វើឡើងដោយអង់គ្លេស។ ដូចនេះ សន្ធិសញ្ញា ដែលត្រូវបាន អនុម័តជាយូរមកហើយ ត្រូវតែបានបកស្រាយឲ្យឆ្លើយតបទៅនឹងស្ថានការណ៍សង្គមបច្ចុប្បន្ន។[195]

ពាក់ព័ន្ធជាមួយវិធីបកស្រាយនេះ រឿងក្តីរបស់លោក *ពីណូឆេ* (Pinochet) អតីតប្រធានាធិបតីប្រទេស ឈីលី គួរត្រូវបានយោងដល់។ តុលាការជាន់ខ្ពស់របស់អង់គ្លេស ត្រូវដោះស្រាយបញ្ហាថាតើ លោក*ពីណូឆេ* មានអភ័យឯកសិទ្ធិឬទេ មុននឹងសម្រេចអំពីការបញ្ជូនគាត់ ពីប្រទេសអង់គ្លេស ទៅអេស្ប៉ាញតាមសំណើសុំបត្យាប័នរបស់ប្រទេសនេះ។ ទោះបីជាមានការ

---

193 *Soering v. the United Kingdom*, *supra* note 178.

194 *Id*., para. 102.

195 *Soering v. the United Kingdom, supra* note 178; although new judgement of *Alsani case* was criticized, *see* Alexander Orakhelashvili, *Restrictive Interpretation of Human Rights Treaties in the Recent Jurisprudence of the European Court of Human Rights* (Alexander, Restrictive), 14 EJIL 2003, 529-568; Javier Garcia Roca and Pablo Santolaya, Europe of Rights: A Compendium on the European Convention of Human Rights (Javier, A Compendium), 2012, pp. 73, 88; *Tyrer v. the United Kingdom*, EHRR 2, (1978):1, para. 31; Malgosia Fitzmaurice and Phoebe Okowa, Treaty Interpretation and the Vienna Convention on the Law of Treaties: 30 years on, 2010, p. 263.

ចម្រូងចម្រាសរវាងចៅក្រមជាន់ខ្ពស់ (House of Lords) យ៉ាងណាក្តី ចៅក្រមភាគច្រើនបានឯកភាពថា លោក *ពីណូឆេ* គ្មានអភ័យឯកសិទ្ធិឡើយ។ ចៅក្រមបានលើកឡើងអំពី ភាពចាំបាច់នៃសន្ធិសញ្ញា ស្តីពីការប្រឆាំងនឹងអំពើទារុណកម្ម ដែលមានបំណងធ្វើឲ្យការបង្ការអំពើ ទារុណកម្ម ឲ្យកាន់តែមានប្រសិទ្ធភាព។ ជាងនេះទៅទៀត ប្រទេស*ឈីលី* ក្នុងពេលដែល លោក ពីណូឆេ ស្ថិតនៅជាប្រធានាធិបតី បានចូលជាភាគីកតិកាសញ្ញានេះ ដែលហាមអំពើទារុណកម្មប្រព្រឹត្តដោយអាជ្ញាធររដ្ឋ។ តាមរយៈនេះ លោក *ពីណូឆេ* មិនអាចអះអាងថា មានអភ័យឯកសិទ្ធិរួចផុតពីអំពើចោទប្រកាន់ពាក់ព័ន្ធជាមួយការចូលរួមធ្វើទារុណកម្ម ក្នុងពេលគាត់ស្ថិតនៅក្នុងអំណាចឡើយ។[196] ការចូលជាភាគី បង្ហាញពីការ បោះបង់អភ័យឯកសិទ្ធិដល់អាជ្ញាធរ (Waiver of Immunity) ដោយប្រយោល។

ពាក់ព័ន្ធជាមួយព្រឹត្តិការណ៍ដាក់តាំងអាវុធនុយក្លេអ៊ែរ របស់សហភាពសូវៀតនៅក្នុងប្រទេសគុយបា នៅក្នុងអំឡុងសង្គ្រាមត្រជាក់ សហរដ្ឋអាមេរិក បានបកស្រាយមាត្រា៥១ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលចែងពី សិទ្ធិការពារខ្លួន (Right to Self-defence) ដែលទាមទារឲ្យមានការវាយប្រហារជាមុន ដោយរដ្ឋលើរដ្ឋមួយ មុនពេលដែលរដ្ឋរងគ្រោះអាចប្រើសិទ្ធិនេះបាន[197] ថាមិនអាចសមស្របទៅ តាមកាលៈទេសៈបច្ចុប្បន្ន ហើយត្រូវបកស្រាយអនុញ្ញាតឲ្យមានការវាយប្រហារដោយរដ្ឋ ដែលអាចក្លាយជា រដ្ឋរង

[196] R. v. Bow Street Metropolitan Stipendiary Magistrate and Others, *ex parte* Pinochet Ugarte (No 3), 24 March, 1999, [2000] 1 AC 147, at 276.

[197] The UN Charter, *supra* note 42.

គ្រោះ ដោយមិនចាំបាច់រង់ចាំការវាយប្រហារពីរដ្ឋណាមួយជាមុនឡើយ (Preemptive Self-Defence)។[198]

ជាចុងក្រោយពាក់ព័ន្ធជាមួយវិធីសាស្ត្របកស្រាយនេះ តុលាការយុត្តិធម៌អន្តរជាតិ បានបកស្រាយថា វិធានបណ្តោះអាសន្នចេញដោយខ្លួន ចងជាកាតព្វកិច្ចដល់រដ្ឋនៃជម្លោះ។[199] ដូចគ្នានេះដែរ វិធានការបណ្តោះអាសន្ន ស្នើដោយគណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ ក៏មានលក្ខណៈចងជាកាតព្វកិច្ច ទោះបីជាមិនមានចែងអំពីចរិតនៃ វិធានការប្រភេទនេះនៅក្នុងសន្ធិសញ្ញាដែលពាក់ព័ន្ធក្តី។[200] គណៈកម្មាធិការដដែលនេះ បានបកស្រាយមាត្រាដែលពាក់ព័ន្ធជាមូលដ្ឋាន សម្រាប់បង្កើតអំណាច (Implied Power) ដល់ខ្លួនក្នុងការត្រួតពិនិត្យមើល ខរក្សាសិទ្ធិមិនអនុវត្ត (Reservation) ដើម្បី បដិសេធចោលនូវ ខរក្សាសិទ្ធិ ដែលគណៈកម្មាធិការ ពិចារណារកឃើញថាមិនអាចទទួលយកបាន។[201] ឧទាហរណ៍ទាំងបីចុងក្រោយនេះ បង្ហាញពីរបៀបនៃការបកស្រាយច្បាប់ ដើម្បីឆ្លើយតបទៅតាមតម្រូវការក្នុងពេលបច្ចុប្បន្ន និងផ្តល់ប្រសិទ្ធភាពនៃសន្ធិសញ្ញា។

[198] Shaw, IL, *supra* note 1, p. 1027.

**[199]** LAGRANT Case, *supra* note 180, pp. 195-196.

[200] The HRC, General Comment No. 33 on the Obligations of States Parties under the Optional Protocol to the ICCPR (the General Comment No. 33) , CCPR/C/GC/33 (2008), para. 19; HRC, *Piandong v. Philippines*, Communication No.869/1999, Oct 2000, para. 5.2.

**[201]** The General Comment No. 24, *supra* note 156, para. 16.

### ៣.២.៥.២.៣. ប្រៀបធៀបច្បាប់ និងការអនុវត្ត

ការពិចារណាលើកត្តានេះ គឺដើម្បីជួយគាំទ្រ នូវគំហើញទាញចេញពីវិធីសាស្ត្រនៃការបកប្រែ ដោយផ្តោតលើអត្ថបទច្បាប់ (ទូលាយ)។ កត្តានេះ ក៏បានជួយជា ខ្លាំងក្នុងការជួយស្រាយបំភ្លឺភាពស្រពេចស្រពិលក្នុងច្បាប់ ពីព្រោះថា រដ្ឋទំនងជាយកតម្រាប់តាមអ្វីដែលរដ្ឋក្នុងតំបន់ធ្វើ និង ជាប្រយោជន៍របស់ខ្លួន។ នៅក្នុងសេចក្តីសម្រេច លើរឿងក្តីបត្យាប័នស្នើដោយសហរដ្ឋអាមេរិកចំពោះប្រទេសកាណាដា តុលាការកំពូលរបស់កាណាដា បានពិចារណាយ៉ាងស៊ីជម្រៅពាក់ព័ន្ធជាមួយនឹង ច្បាប់ សន្ធិសញ្ញា សាលក្រមរបស់តុលាការអន្តរជាតិ និងរបស់ជាតិ និងឯកសារផ្សេងៗទៀត ដែលជាប់ទាក់ទិនជាមួយការហាមឃាត់ទោសប្រហារជីវិត។ តុលាការកំពូលរបស់កាណាដា បានរកឃើញនូវនិន្នាការទូទៅនៃការលុបចោល ឬការមិនប្រើទោសប្រហារជីវិត។ ផ្អែកតាមគំហើញនេះ តុលាការបានតម្រូវឲ្យរដ្ឋាភិបាលកាណាដា សុំការធានាពីសហរដ្ឋអាមេរិក មិនឲ្យប្រើទោសប្រហារជីវិតលើជនដែលកាណាដា បញ្ជូនទៅវិញ នៅក្នុងគ្រប់ករណីបត្យាប័ន ពាក់ព័ន្ធទោសប្រហារជីវិត លើកលែងករណីពិសេស។[202] តុលាការទាមទារយ៉ាងនេះ នាំឲ្យមានការផ្លាស់ប្តូរទម្លាប់ ដែលរដ្ឋាភិបាលកាណាដា តម្រូវនូវការធានាកុំឲ្យមានទោសប្រហារជីវិតពីសហរដ្ឋអាមេរិក ក្នុងតែករណីចាំបាច់និងពិសេសតែប៉ុណ្ណោះ ។ ការទាមទារដូចនេះ គឺដើម្បីឲ្យសមស្របតាមខ្លឹមសារ

[202] In the case of Burn, Supreme Court of Canada said that the Canadian governement shall seek for assurance that death penalty will not be executed in all case except exceptional cases, (Neutral citation 2001 SCC 7. [2001] S.C.J No.8) cited in *Judge v. Canada*, *supra* note 177, para. 8.12.

ដែលទាមទារ ក្នុងសន្ធិសញ្ញាបត្យាប័នរវាងកាណាដា និងសហរដ្ឋអាមេរិក[203] ជួយបញ្ចៀសកុំឲ្យមានការរំលោភសិទ្ធិមនុស្ស[204] និងជាពិសេស កុំឲ្យមានការរំលោភច្បាប់របស់ កាណាដា ដែលលុបចោលទោសប្រហារជីវិត។[205]

### ៣.២.៥.២.៤. ឯកសារពាក់ព័ន្ធ

ឯកសារក្នុងផ្នែកនេះ មានឯកសារសេចក្តីព្រាងសន្ធិសញ្ញា ឯកសារនាពេលចូលជាភាគី និងឯកសារដទៃទៀត ដែលត្រូវបានធ្វើឡើងសម្រាប់អនុវត្តច្បាប់ និង សន្ធិសញ្ញា។ សន្ធិសញ្ញា ស្តីពី ច្បាប់សន្ធិសញ្ញា មាត្រា ៣១ បានចែងអំពីវិធីសាស្ត្របកស្រាយសន្ធិសញ្ញា ក្នុងនោះឯកសារពាក់ព័ន្ធ ការរៀបចំសន្ធិសញ្ញា (Drafting History Documents) ត្រូវបានចែងឲ្យប្រើប្រាស់សម្រាប់ជួយរកន័យនៃមាត្រា ដែលមានន័យមិនច្បាស់លាស់។[206] ទោះបីជាយ៉ាងនេះក្តី ការប្រើប្រាស់ឯកសារទាំងនោះ ត្រូវបានធ្វើឡើងក្នុងដំណាក់កាលទីពីរ បន្ទាប់ពីការរកន័យ ឬខ្លឹមសារនៃពាក្យ តាមរយៈការពិនិត្យមើលអត្ថបទច្បាប់ ដែលមិនទទួលបានលទ្ធផល ឬទទួលបានន័យដែលពិបាកទទួលយក។[207] ម្យ៉ាងវិញទៀត ប្រសិនបើន័យ ឬខ្លឹមសារដែលទទួលបានពីការពិចារណា លើឯកសារពាក់ព័ន្ធជាមួយការព្រាងសន្ធិសញ្ញា មិនអាចទទួលយកបាន ចៅក្រមនឹងមិនទទួលយកន័យយ៉ាងដូចនេះឡើយ។[208] ក្នុង

[203] The Extradition Treaty between the USA and Canada (1976), 27 UST. 983; TIAS. N. 8237, Art.6; Michael Abbell, Extradition to and from the Uinted States (Michael, Extradition to USA), 2010, p. 128.
[204] Without seeking assurance, Canada might violate Art. 6 of the ICCPR to which it is party, *Judge v. Canada*, *supra* note 177, para. 10.1.
[205] *Id.,* para. 10.1.
[206] The VCLT, *supra* note 36, Art. 31.
[207] *Id.*
[208] The VCLT, *supra* note 36, Art. 31.

រឿងក្តីប្តឹងដោយ អាឡឺម៉ង់ ប្រឆាំងជាមួយនឹង សហរដ្ឋអាមេរិក ក្នុងការពិចារណាថាតើ វិធានការបណ្តោះអាសន្ន មានចរិតជាកាតព្វកិច្ច ឬមិនមែន តុលាការយុត្តិធម៌អន្តរជាតិ ជាដំបូង បានពិនិត្យមើលឯកសារសន្ធិសញ្ញា ជាមុនសិន។ ឯកសារនោះគឺ លក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ។ តុលាការ មិនបានរកឃើញមាត្រាណាមួយ ដែលជួយបញ្ជាក់ថាតើវិធានការបណ្តោះអាសន្ន ចងជាកាតព្វកិច្ចទេ។ តុលាការ ពិនិត្យមើលស្ថានភាពបច្ចុប្បន្ននៃច្បាប់អន្តរជាតិ រួមជាមួយគោលបំណងរបស់វា ហើយទាញសេចក្តីសន្និដ្ឋានថា វិធានការបណ្តោះអាសន្ន មានចរិតចងជាកាតព្វកិច្ច។ ដើម្បីបន្ថែមការគាំទ្រ តុលាការបាន ពិនិត្យមើលឯកសារពាក់ព័ន្ធការពង្រាងសន្ធិសញ្ញា។ ឯកសារព្រាង មិនបាននិយាយអំពី វិធានការប្រភេទនេះទេ។ តុលាការបាន ទាញយកការមិនបាននិយាយដល់វិធានការនេះក្នុងពេលធ្វើសេចក្តីព្រាងលក្ខន្តិកៈ ដើម្បីគាំទ្រគំហើញទាញចេញពីការពិនិត្យមើលអត្ថបទ និងកត្តាដែលពាក់ព័ន្ធ ថាវិធានការបណ្តោះអាសន្ន មានចរិតចង ជាកាតព្វកិច្ច។[209]

### ៣.៣. ប្រភពផ្សេងទៀត ប្រភេទ និងឋានានុក្រម

ក្រៅពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងសន្ធិសញ្ញា មានវិធានដទៃផ្សេងទៀត ដែលជាប្រភពរបស់ច្បាប់អន្តរជាតិ មានដូចជា គោលការណ៍ទូទៅរបស់ច្បាប់ សេចក្តីសម្រេចរបស់តុលាការ និង ស្នាដៃស្រាវជ្រាវ។[210]

[209] The Rules of the International Court of Justice (ICJ, Rules), at www.icj-cij.org/documents. LAGRANT Case, *supra* note 180, pp. 195-196.
[210] The Statute of ICJ, *supra* note 58, Art. 38.

គោលការណ៍ច្បាប់នេះ សំដៅលើគោលការណ៍ច្បាប់ជាតិ ដែលខុសពីគោលការណ៍ច្បាប់អន្តរជាតិ។ គោលការណ៍នេះ ដូចជា គោលការណ៍ សមធម៌ (Equity)។[211] គេប្រើគោលការណ៍នេះ សម្រាប់កាត់សេចក្តី ដើម្បីរកយុត្តិធម៌ជូនភាគីតាមចំណែកសមស្រប ជំនួសឲ្យចំណែកស្មើគ្នា (Equality)។[212]

សេចក្តីសម្រេចតុលាការ មានវិសាលភាពមិនទូលាយទេ ដោយសារសាលក្រម ឧទាហរណ៍ សាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិ ចងជាកាតព្វកិច្ចដល់រដ្ឋភាគីតែប៉ុណ្ណោះ។ ដូចគ្នានេះដែរ ស្នាដៃស្រាវជ្រាវរបស់អ្នកនិពន្ធល្បីៗ ក៏អាចជាមូលដ្ឋាន ដែលទាញចេញពីនេះ វិធានច្បាប់អន្តរជាតិត្រូវបានបង្កើតឡើង។[213]

អ្នកស្រាវជ្រាវច្បាប់អន្តរជាតិ បានចាត់ប្រភពច្បាប់អន្តរជាតិ ជាច្រើនប្រភេទទៅតាមនីតិវិធីនៃការបង្កើត ឬតាមតួនាទី។ សន្ធិសញ្ញា ត្រូវបានធ្វើឡើងតាមនីតិវិធីត្រឹមត្រូវ។ ដូចនេះ អ្នកស្រាវជ្រាវ បានចាត់ថា ជាប្រភពផ្លូវការ។ រីឯច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាប្រភេទមិនផ្លូវការ (Informal Sources)។[214] គោលការណ៍ទូទៅនៃច្បាប់ មានតួនាទីបង្គ្រប់បន្ថែម ឬត្រូវបានគេប្រើ នៅក្នុងករណី មិនមានសន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ

[211] Peter Malanczuk, IL, *supra* note 1, p. 55.
[212] The UNCLOS, *supra* note 30, Art. 15.
[213] Shaw, IL, *supra* note 1, p. 112.
[214] Contrarily, it is a formal source, *see* Rebecca, IL, *supra* note 11, p. 8.

អនុវត្តក្នុងការដោះស្រាយក្តីក្តាំ។ ដូចនេះ អ្នកសិក្សាស្រាវជ្រាវ បានចាត់ថាជាប្រភពបន្ទាប់បន្សំ។[215]

មានសំណួរអាចលើកឡើងថាៈ តើសន្ធិសញ្ញាអន្តរជាតិ មានឋានៈខ្ពស់ជាងច្បាប់ទំនៀមទម្លាប់អន្តរជាតិឬ ពីព្រោះសន្ធិសញ្ញា ត្រូវបានគេសរសេរក្នុងលេខរៀងទី ១ ក្នុងមាត្រា ដែលនិយាយពាក់ព័ន្ធអំពី ប្រភពនៃ ច្បាប់អន្តរជាតិ? អ្នកស្រាវជ្រាវ បានឆ្លើយរួចហើយ ថាមិនមែនដូចនេះទេ។[216] ចម្លើយនេះ គឺជាការត្រឹមត្រូវពីព្រោះថា វិធានដែលមានឋានៈ ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិខ្លះ ជាវិធានខ្ពស់ជាងគេ (*Jus Cogens*) ដែលខ្ពស់ជាងវិធានមានចែងនៅក្នុងសន្ធិសញ្ញា។ ការដាក់សន្ធិសញ្ញា ក្នុងលេខរៀង ទី១ ប្រហែលជាវាជាប្រភពផ្លូវការ។

[215] Shaw, IL, *supra* note 1, p. 98; Rebecca, IL, p. 8.
[216] Peter Malanczuk, IL, *supra* note 1, p. 56.

# ជំពូក ៤
# ច្បាប់ជាតិ និងច្បាប់អន្តរជាតិ

## ៤.១. ទ្រឹស្តីពាក់ព័ន្ធ

មានទ្រឹស្តីចំនួនពីរ ដែលពាក់ព័ន្ធះ ទ្រឹស្តីទី១ Monism និងទ្រឹស្តីទី២ Dualism។ ទ្រឹស្តីទាំងពីរមានប្រភពមកពី ទ្រឹស្តីច្បាប់ផ្សេងគ្នា។ ទ្រឹស្តីទី ១ មានប្រភពពីច្បាប់ធម្មជាតិ (Natural Law) ហើយទ្រឹស្តីទី ២ ទំនងមានឫសគល់មកពី ទ្រឹស្តីប្រាកដនិយម (Realism or Positivism)។ ទ្រឹស្តីទីមួយ បង្ហាញថា មានប្រភពច្បាប់តែមួយគត់ ហើយដែលច្បាប់ជាតិ និងអន្តរជាតិ ដែលមានមូលដ្ឋានចេញមក។ សម្រាប់ទ្រឹស្តីនេះ ច្បាប់អន្តរជាតិជានិច្ចកាលត្រូវខ្ពស់ជាងច្បាប់ជាតិ[217] ដោយសារច្បាប់អន្តរជាតិបម្រើផលប្រយោជន៍រួមរបស់បណ្តាប្រទេសទាំងអស់លើពិភពលោក។ ទាញចេញពីនេះ ច្បាប់អន្តរជាតិ ក្រោយពីពេលដែលត្រូវបានទទួលយក ដូចជាតាមរយៈការផ្តល់សច្ចាប័នលើសន្ធិសញ្ញា ច្បាប់អន្តរជាតិនោះ ត្រូវតែបានអនុវត្តផ្ទាល់នៅក្នុងប្រទេស (Direct Application) ដោយមិនចាំបាច់មាន ច្បាប់ធ្វើដោយសភា ធ្វើឲ្យសន្ធិសញ្ញាក្លាយជាច្បាប់ក្នុងស្រុកឡើយ (Transfor–mation Act)។ ប្រទេសហូឡង់ដ៍បាន ប្រកាន់យកទ្រឹស្តីនេះ (អនុវត្តន៍ផ្ទាល់)ក្នុងករណីជាប្រភេទ Self-Executing Treaty។ រដ្ឋនេះ បានដាក់ច្បាប់រដ្ឋធម្មនុញ្ញ ឲ្យទាបជាងសន្ធិសញ្ញាប្រភេទនេះ។[218] តែទោះ

[217] Peter Malanczuk, IL, *supra* note 1, p. 63; Rebecca, IL, *supra* note 11, p.35.

[218] Dinah Shelton, International law and Domestic Legal Systems; Incorporation, Transformation, and Persuasion (Dinah, Incorporation), 2011, pp. 416 and 421.

បើជាយ៉ាងនេះក្តី វាអាចគ្រាន់តែជាទ្រឹស្តី ហើយក្រោយមករដ្ឋនេះ បានកែប្រែជំហរ ពីព្រោះរដ្ឋត្រូវការកែប្រែរដ្ឋធម្មនុញ្ញ ជាច្រើនដងនៅពេល ដែលខណៈណាមួយរបស់ច្បាប់រដ្ឋធម្មនុញ្ញ ផ្ទុយនឹងបទប្បញ្ញត្តិរបស់សន្ធិសញ្ញា ដែលការងារនេះ ពិតជាមិនអាចធ្វើបានទេ។

ទ្រឹស្តីទី២ គូសបញ្ជាក់ថា ច្បាប់ជាតិ និងច្បាប់អន្តរជាតិ ជាប្រភេទច្បាប់ពីរដោយឡែកពីគ្នា និងមានប្រភេទផ្សេងគ្នាផងដែរ។[219] ច្បាប់ទាំងពីរអាចខ្ពស់ឬទាបជាងគ្នាទៅតាមកាលៈទេសៈ។ ច្បាប់អន្តរជាតិ មិនអាចត្រូវបានអនុវត្តទេ ប្រសិនបើមិនមាន ច្បាប់របស់សភាធ្វើសន្ធិសញ្ញា ឲ្យក្លាយជាច្បាប់ជាតិ (Transformation)។[220] មានប្រទេសជាច្រើន ជាពិសេសប្រទេសក្នុងប្រព័ន្ធ Common Law ដូចជាអង់គ្លេស បានទទួលយកទ្រឹស្តីនេះ។

អ្នកសិក្សាស្រាវជ្រាវគួរចងចាំថា ប្រទេសមួយប្រកាន់យកទ្រឹស្តីណាមួយ ទាក់ទងក្នុងការអនុវត្តច្បាប់អន្តរជាតិ វាជារឿងទ្រឹស្តីសុទ្ធសាធ និងកម្រលើកយកមកសំអាងណាស់។ ដូចនេះ គេគួរពិនិត្យមើលការអនុវត្តជាក់ស្តែងឲ្យបានច្រើន។[221]

[219] Peter Malanczuk, IL, *supra* note 1, p. 63; Rebecca, IL, *supra* note 11, p.35.
[220] Anthony Aust, Modern Treaty Law and Practice (Anthony, Modern Treaty) , 2nd ed., 2007, pp. 187 -188; John H. Jackson, *Status of treaties in domestic legal systems: a policy analysis*, 86 the AJIL (1992), pp. 315-316; Anette Faye Jacobsen, Human Rights Monitoring, 2008, p. 607.
[221] Andrzej Wasilkowski, monist and dualist at present, 1996, p. 332.

## ៤.២. ការប្រតិបត្តច្បាប់អន្តរជាតិ

ការប្រតិបត្តិច្បាប់អន្តរជាតិ នៅក្នុងស្រុក គឺជាបញ្ហាដ៏ស្មុគស្មាញមួយទៀត ដោយសារបរិបទសង្គម ឬប្រព័ន្ធច្បាប់ផ្សេងៗរបស់រដ្ឋ។ ការប្រត្តិបត្តិនេះ មានន័យថាជាការបំពេញយ៉ាងមានប្រសិទ្ធភាព នូវកាតព្វកិច្ចជាអន្តរជាតិ ចងដល់រដ្ឋ ដែលជាភាគីសន្ធិសញ្ញាណាមួយ។ ការសំខាន់ គឺជាការផ្តល់ប្រសិទ្ធភាព ដល់ច្បាប់អន្តរជាតិ (Give Effect)[222]។ ដោយសារ រដ្ឋមានប្រពន្ធ័ច្បាប់ដោយឡែក ស្ថាប័នច្បាប់អន្តរជាតិ ផ្តល់នូវភាពបត់បែនដល់រដ្ឋ ក្នុងការបំពេញតាមកាតព្វកិច្ចជាអន្តរជាតិ។[223]

រដ្ឋអាចចាត់វិធានការសមស្រប ដែលមានប្រសិទ្ធភាព ដូចជាវិធានការច្បាប់ (ការកែច្បាប់ ឬធ្វើច្បាប់ថ្មី) វិធានការរដ្ឋបាល (ដាក់វិន័យដល់មន្ត្រី ដែលល្មើសច្បាប់ ដើម្បីបង្ការការរំលោភច្បាប់ ឬសិទ្ធិមនុស្ស) វិធានការតុលាការ (ដូចជាប្តឹងទៅតុលាការ) វិធានការសង្គម (ផ្តល់ការស្តារនីតិសម្បទា) ឬ វិធានការផ្សព្វផ្សាយច្បាប់អន្តរជាតិជាដើម។[224] សន្ធិសញ្ញាទីក្រុងវៀន ស្តីពីច្បាប់សន្ធិសញ្ញា បានចែងច្បាស់ថាៈ រដ្ឋមិនអាចលើកយកនូវ ចន្លោះខ្វះខាតនៃច្បាប់ជាតិរបស់ខ្លួន មកធ្វើយុត្តិកម្ម សម្រាប់ការខកខានមិនបានបំពេញតាមកាតព្វកិច្ចតម្រូវដល់រដ្ឋឡើយ។[225]

---

[222] Rebecca J. Cook, *State responsibility for violations of Women's Rights*, 17 Harvard Human Rights Journal (1994), p. 147; the Committee on Economic, Social and Cultural Rights, General Comment No. 9: the Domestic Application of the Covenant (General Comment No. 9), HRI/GEN/1/Rev.9, p. 47, paras. 1-2.

[223] General Comment No. 9, *supra* note 222, paras. 1-2.

[224] The ICCPR, *supra* note 56, Art. 2(2).

[225] Josef L. Kunz, *the Meaning and the Range of the Norm Pacta Sunt Servanda*, the 39 (2) AJIL, p. 181 (1945) ; Hans Wehberg, *Pacta Sunt Servanda*, 53 AJIL, 775 (1959).

ការធ្វើឲ្យសម្រេចតាមកាតព្វកិច្ច និងចេញជាលទ្ធផល ដែលចង់បាន (Obligation of Result) វាមិនមែនជាការងារងាយស្រួលឡើយ។ ទាក់ទង ក្នុងបញ្ហានេះ យើងត្រូវពិនិត្យមើលការអនុវត្តជាក់ស្តែង នូវសន្ធិសញ្ញា ក្នុងស្រុក ហើយដែលទាមទារឲ្យមានការពិនិត្យមើល ការលើកយកមាត្រាសន្ធិសញ្ញា មកសំអាងនៅមុខតុលាការក្នុងករណីជាក់លាក់ណាមួយ។

សម្រាប់ប្រទេស អង់គ្លេស ប្រសិនបើគ្មានច្បាប់ដោយសភា ធ្វើសន្ធិសញ្ញាឲ្យក្លាយជាច្បាប់ក្នុងស្រុក បុគ្គលជាឯកជននឹងមិនអាចលើកយកមាត្រាណាមួយ ឲ្យតុលាការពិនិត្យថា (Invocation) តើអំពើណាមួយខុស ពីបទប្បញ្ញត្តិក្នុងសន្ធិសញ្ញាដែរឬទេ? តុលាការ នឹងជំទាស់ ឬមិនមើលបណ្តឹង ដោយអះអាងថា ការពិចារណាបណ្តឹង ដោយគ្មានច្បាប់សភាអនុញ្ញាតឲ្យធ្វើយ៉ាងនេះ គឺជាការបំពានការងាររបស់សភា (Parliamentary Supremacy)។

ប្រទេសប្រកាន់ប្រព័ន្ធ Civil Law ដូចជាបារាំង ដែលទទួលយកការអនុវត្តច្បាប់អន្តរជាតិផ្ទាល់ ទាមទារថា ច្បាប់អន្តរជាតិ ដូចជាសន្ធិសញ្ញា ត្រូវតែបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីជាផ្លូវការរបស់រដ្ឋ ( Official Gazette) សិន មុនពេលតុលាការអាចយកទៅប្រើបាន។ ទោះបីជាយ៉ាងនេះក្តី នេះអាចគ្រាន់តែជាទ្រឹស្តី ពីព្រោះការអនុវត្តមិនបានដូច ឬមានការដើរឆ្ងាយពីទ្រឹស្តីពិត។ ទោះបីជា សន្ធិសញ្ញាត្រូវបានផ្សព្វផ្សាយ តុលាការនៅតែមិនប្រើប្រាស់សន្ធិសញ្ញា ប្រសិនបើបទប្បញ្ញត្តិ ឬសន្ធិសញ្ញាទាំងមូលមិនត្រូវបានសរសេរបញ្ចូល ឬយោង (Incorporation) ក្នុងច្បាប់របស់សភា ដែល

គេគិតថា ច្បាប់នេះបើកផ្លូវឲ្យប្រើនូវសន្ធិសញ្ញា។[226] នេះបង្ហាញថា វាមិនមែនជាការអនុវត្តផ្ទាល់ទេ។ វាអាចជាការអនុវត្តផ្ទាល់មានលក្ខខណ្ឌ ឬផ្អែកតាមច្បាប់។

ទាំង Incorporation និង transformation គឺសុទ្ធតែជាឧបសគ្គក្នុងប្រទេសក្នុងការប្រតិបត្តិច្បាប់អន្តរជាតិ ពីព្រោះថា ប្រសិនបើមិនមានច្បាប់បើកផ្លូវច្បាប់អន្តរជាតិនឹងមិនអាចត្រូវបានគេពិចារណា។ ទោះបីជា មានច្បាប់ក្តីចៅក្រមសហរដ្ឋអាមេរិក អាចចាត់ថាបទប្បញ្ញត្តិសន្ធិសញ្ញា ដែលពាក់ព័ន្ធមិនមែនជាប្រភេទអនុវត្តឯកឯង (Non-Self Executing Provision/Treaty)[227] ដែលទាមទារឲ្យមានច្បាប់សម្រាប់អនុវត្តសន្ធិសញ្ញា (Implementing Act) ជាមុនសិន។ ជាថ្មីម្តងទៀត ចុះបើច្បាប់នោះ មិនទាន់ត្រូវបានធ្វើ ឬប្រសិនបើត្រូវបានធ្វើហើយ តែតុលាការនៅតែមិនអនុវត្តច្បាប់អន្តរជាតិ? នេះជាសំណួរមួយដ៏ស្មុគស្មាញ។ នេះជាមូលហេតុ នាំឲ្យច្បាប់អន្តរជាតិមិនត្រូវបានរដ្ឋគោរព បន្ថែមពីមូលហេតុ ដែលថាមិនមានយន្តការមានអំណាចយ៉ាងមានប្រសិទ្ធភាពបង្ខំ ឬដាក់ទណ្ឌកម្មដល់រដ្ឋណាដែលប្រព្រឹត្តផ្ទុយនឹងកាតព្វកិច្ចអន្តរជាតិ។ អនុសាសន៍ដ៏ល្អមួយ គឺការបង្រៀនឲ្យចៅក្រម

[226] Dinah, Incorporation, *supra* note 218, pp. 216, 228-229; Anthony, Modern Treaty, *supra* note 220, pp. 183-184.

[227] Lori Fisler Damrosch, *the Role of US Senate concerning self-executing and non-self-executing treaties*, 67 Chicago-Kent Law Review (1991), pp. 515-516; Jordan J. Paust, *self-executing treaties*, 82 the AJIL (1988), 766-768; *see* also John C. Yoo, *treaties and public lawmaking: a textual and structural defense of non-self-execution*, 99 the Columbia Law Review (1999), p. 2218; Carlos Manuel Vazquez, *the four doctrines of self-executing treaties*, 89 the AJIL (1995), 695; Kristen B. Rosati, *the United Nations Convention against Torture: A self-executing treaty that prevents the removal of persons ineligible for asylum and withholding of removal*, 26 Denva Journal of International Law and Policy (2003), p. 534.

មេធាវីដែលជាអ្នកដើរតួសំខាន់ក្នុងការអនុវត្តច្បាប់ និងលើកទឹកចិត្តជំរុញពួកគេឲ្យអនុវត្តច្បាប់អន្តរជាតិ។

## ៤.៣. ទីតាំងរបស់ច្បាប់អន្តរជាតក្នុងប្រព័ន្ធច្បាប់ជាត

យ៉ាងហោចណាស់មាន រូបមន្តពីរ ពាក់ព័ន្ធជាមួយនឹងទីតាំងរបស់ច្បាប់អន្តរជាតិ (សន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។ ទី១ សន្ធិសញ្ញាស្ថិតនៅទាបជាងច្បាប់រដ្ឋធម្មនុញ្ញ តែខ្ពស់ជាងច្បាប់ជាតិធម្មតា។[228] ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ស្ថិតនៅពីក្រោមច្បាប់ជាតិ។ នេះអាចជាករណីកម្ពុជា បើតាមការវិភាគរបស់អ្នកនិពន្ធនេះ។ ទី២ សន្ធិសញ្ញាស្ថិតនៅក្រោមច្បាប់ធម្មនុញ្ញ និងលំដាប់ស្មើ នឹងច្បាប់ធម្មតា ហើយច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្រោមបន្ត។ នេះ ជាករណីសហរដ្ឋអាមេរិក ឬអង់គ្លេស។[229]

តាមខ្លឹមសារខាងលើ ច្បាប់រដ្ឋធម្មនុញ្ញស្ថិតនៅពីលើសន្ធិសញ្ញា។ វាមិនអាចថាគ្រប់វិធានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ សុទ្ធតែខ្ពស់ជាងច្បាប់អន្តរជាតិឡើយ ។ ក៏ប៉ុន្តែ រដ្ឋទាំងអស់បានគិតថា ច្បាប់ធម្មនុញ្ញគឺជាច្បាប់កំពូលរបស់រដ្ឋ ដូចនេះមិនអាចទាបជាងច្បាប់អន្តរជាតិទេ។ សន្ធិសញ្ញា ខ្ពស់ជាងច្បាប់ជាតិគឺជាជំហរមួយ ដែលគេអាចទទួលយកបាន ពីព្រោះសន្ធិសញ្ញា ចែងគ្រប់គ្រងអំពីប្រយោជន៍រួមរបស់រដ្ឋជាច្រើន។ ដូចនេះ ការដាក់សន្ធិសញ្ញា ស្មើនិងច្បាប់ជាតិផ្អែកតាមទ្រឹស្តី Last-in-Time Rule បង្កើតដោយចៅក្រម ឬអ្នកសិក្សាអាមេរិក ជាកំហុសមួយពិបាកទទួលយក[230] ពីព្រោះប្រទេសមួយអាច

[228] Anthony, Modern Treaty, *supra* note 220, pp. 183-184.
[229] *Tag v. Rogers* 167 F,2d 664, 666 (1959); 28 ILR, p. 467 cited in Shaw, IL, *supra* note 1, p. 158.
[230] Shaw, IL, *supra* note 1, pp. 165-166.

ធ្វើច្បាប់ជាតិ បដិសេធសន្ធិសញ្ញា ដែលខ្លួនយល់ថា ប៉ះដល់ប្រយោជន៍ជាតិខ្លួន បានដោយងាយតាមទ្រឹស្តីនេះ។ គេគួរកត់សម្គាល់ថា ទ្រឹស្តីនេះលែងមានភាពពេញនិយមហើយ។ ជាចុងក្រោយ ការដាក់ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្រោមសន្ធិសញ្ញា និងច្បាប់ជាតិ មិនត្រឹមត្រូវសម្រាប់គ្រប់វិធានទេ។ ដូចដែលបានរៀបរាប់ខាងលើរួចហើយ វិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិខ្លះ មានចរិត និងឋានៈខ្ពស់ជាងវិធានមាននៅក្នុងសន្ធិសញ្ញាទៅទៀត។ តាមការយល់ឃើញ ការដាក់ឋានៈច្បាប់ទំនៀមទម្លាប់អន្តរជាតិ វាគ្រាន់ ជាបញ្ហាបច្ចេកទេសទេ។ នេះដោយសារ ច្បាប់ប្រភេទនេះ មិនទាមទារ ឲ្យរដ្ឋផ្តល់សច្ចាប័នទទួលយកទេ ហើយចងជាកាតព្វកិច្ចដល់រដ្ឋ ឯកឯង។ រដ្ឋអាច ធ្វើច្បាប់ជាតិ ដើម្បីបដិសេធវិធាន ប្រសិនបើមានទំនាស់ផលប្រយោជន៍ជាតិ។

មិនមានច្បាប់ជាតិណាមួយ និយាយជាក់លាក់អំពីទីតាំងរបស់ច្បាប់អន្តរជាតិក្នុងប្រព័ន្ធច្បាប់ជាតិទេ ជាពិសេសពាក់ព័ន្ធជាមួយនឹង ច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដូចនេះ ការចាត់ថ្នាក់ ទាញចេញពីការវិភាគរបស់អ្នកសិក្សាស្រាវជ្រាវច្បាប់អន្តរជាតិ។ ដូចនេះ អ្នកសិក្សាគួរតែពិចារណានូវករណីនីមួយៗដោយឡែកៗ ប្រសិនបើនិយាយអំពីទីតាំងរបស់ច្បាប់អន្តរជាតិ។

### ៤.៤. ទំនាស់រវាងច្បាប់ជាតិ និងច្បាប់អន្តរជាតិសាធារណៈ

រដ្ឋបានធ្វើច្បាប់ជាតិ មុនខ្លួនចូលជាភាគីសន្ធិសញ្ញាណាមួយ ដូចនេះ វាជាការជៀសមិនរួចនូវទំនាស់រវាងបទប្បញ្ញត្តិនៃច្បាប់ទាំងពីរ។ រដ្ឋបានធ្វើការសិក្សាច្បាប់របស់ខ្លួន មុនចូលជាភាគីសន្ធិសញ្ញា ដើម្បីកាត់បន្ថយនូវទំនាស់ច្បាប់។ ទោះបីជាយ៉ាងនេះក្តី សូម្បីរដ្ឋមានការជឿនលឿនក្នុងវិស័យច្បាប់

អន្តរជាតិ និងមានធនធានមនុស្សក្នុងវិស័យនេះ ក៏ជៀសមិនរួចពីទំនាស់រវាងច្បាប់ទាំងពីរដែរ។ ការដោះស្រាយទំនាស់នេះ អាចធ្វើឡើងតាមរយៈការបកស្រាយច្បាប់ ធ្វើយ៉ាងណាកុំឲ្យមានទំនាស់។ បន្ថែមពីលើនេះ ការយោងដល់ទីតាំងរបស់ច្បាប់អន្តរជាតិ ក៏ជាវិធីមួយសម្រាប់ដោះស្រាយបញ្ហាផងដែរ។ ឧទាហរណ៍ បើបទប្បញ្ញត្តិជាតិផ្ទុយនឹងបទប្បញ្ញត្តិសន្ធិសញ្ញា បទប្បញ្ញត្តិខាងក្រោយនេះ នឹងត្រូវបានអនុវត្តតាម។ ពាក់ព័ន្ធជាមួយចំណុចនេះ វាជាការល្អតាមរយៈវិធីណាមួយ ដូចជាការអនុម័តច្បាប់ ចែងឲ្យដឹងជាក់លាក់ថា ច្បាប់អន្តរជាតិមានទីតាំងនៅត្រង់ណា នៅក្នុងប្រព័ន្ធច្បាប់ជាតិ។

# ជំពូក ៥
# អង្គការអន្តរជាតិ

ក្នុងសម័យបច្ចុប្បន្ននេះ មានអង្គការអន្តរជាតិ (International Organization-IO) ជាច្រើន។ មានហេតុផលជាច្រើន ដែលនាំឲ្យមានការកកើតឡើងដ៏ច្រើននេះ។ ទី១ ដោយសារវិស័យជាច្រើន នៃច្បាប់អន្តរជាតិ ត្រូវបានពង្រីក និងបង្កើន។ ទី២ សមាហរណកម្មលើវិស័យជាច្រើន បាននាំឲ្យមានអង្គការអន្តរជាតិ។ វាអាចជាគោលបំណងបំពេញបន្ថែម លើការងារឲ្យកាន់តែមានប្រសិទ្ធភាព ក្នុងវិស័យដែលរដ្ឋមិនអាចធ្វើបាន។

អង្គការអន្តរជាតិ ត្រូវបានផ្តល់ន័យថា ជាអង្គភាព មានសមាសភាពជារដ្ឋ ឬអង្គការអន្តរជាតិផ្សេងៗទៀត បង្កើតឡើងក្រោមច្បាប់អន្តរជាតិ និង ស្វ័យភាពពីសមាជិករបស់ខ្លួន។[231] និយមន័យនេះ គ្រាន់តែជាន័យរួមទេ ពីព្រោះថា ច្បាប់ទូទៅសម្រាប់ អង្គការអន្តរជាតិស្ថិតនៅក្នុងដំណាក់មិនច្បាស់លាស់នៅឡើយ។[232]

## ៥.១. ប្រភេទ និង សមត្ថកិច្ច

យ៉ាងហោចណាស់ មានអង្គការអន្តរជាតិពីរប្រភេទ ទី១ អង្គការអន្តរជាតិកម្រិតពិភពលោក និងតំបន់ ដូចជា អង្គការសហប្រជាជាតិ និង អាស៊ានជាដើម។ គេក៏អាចចាត់ថា ជាអង្គការអន្តរជាតិផងដែរ ដូចជា គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម (International Committee of Red

[231] Dapo Akande, *international organization* (Dapo, IO), p. 278-279 in Malcolm D. Evans, International Law, 2nd ed., 2006.
[232] *Id.*, p. 280.

Cross) ទោះបីជាអង្គការនេះ បង្កើតឡើងដោយតែប្រទេសមួយ (ស្វីស) យ៉ាងណាក្តី ដោយសារ អង្គការនេះ មានសាខាជាច្រើននៅលើពិភពលោក និងធ្វើការងារយ៉ាងទូលំទូលាយ។

អង្គការអន្តរជាតិខ្លះ ផ្តោតទៅលើវិស័យមួយយ៉ាងជាក់លាក់ ឧទាហរណ៍ អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ICAO) ដែលជាអង្គភាពជំនាញរបស់អង្គការសហប្រជាជាតិ។[233] ក៏ប៉ុន្តែអង្គការខ្លះ មានតួនាទីជាច្រើន។

ផ្អែកតាមប្រភេទខាងលើ អង្គការអន្តរជាតិមានប្រភេទ និងសមត្ថកិច្ចដោយឡែកៗ ដោយអនុលោមទៅតាមខ្លឹមសារនៃ ឯកសារបង្កើតអង្គការអន្តរជាតិនីមួយៗ។ ឧទាហរណ៍ អង្គការសហប្រជាជាតិ ជាអង្គការពិភពលោកមួយដ៏ធំជាងគេ។ ឯកសារបង្កើត បានចែងអំពី គោលការណ៍ចម្បង តួនាទីយ៉ាងសំខាន់ និងសមត្ថកិច្ចដ៏ទូលំទូលាយរបស់ អង្គការសហប្រជាជាតិ។[234] អង្គការនេះ មានស្ថាប័នកំពូលជាច្រើន ដូចជា មហាសន្និបាតអង្គការសហប្រជាជាតិ និង ក្រុមប្រឹក្សាសន្តិសុខ។ ក្រៅពីមានស្វ័យភាពពីរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ មានអំណាចចាត់វិធានការ ដែលស្តែងជាកាតព្វកិច្ចដែលរដ្ឋត្រូវគោរពតាម។[235] ពិសេសជាងនេះទៅទៀត កាតព្វកិច្ចតម្រូវតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ខ្ពស់ជាងកាតព្វកិច្ចចែងបង្គាប់តាមសន្ធិសញ្ញាដទៃទៀត។[236]

[233] The International Civil Aviation Organization, *see* en.wikipedia.org/wiki/ International _Civil_Aviation_Organization

[234] The UN Charter, *supra* note 42, Arts. 1 and 2; Bardo Fassbender, the United Nations Charter as the Constitution of the International Community, 2009.

[235] The UN Charter, *supra* note 42, Art. 25.

[236] The UN Charter, *supra* note 42, Art. 103.

អង្គការអន្តរជាតិ ខ្លះមានឋានៈជានីតិបុគ្គលអន្តរជាតិ (International Personality) ដែលតាមរយៈនេះ អង្គការអាចធ្វើកិច្ចការងារ ដោយស្វ័យភាព ដូចជាចុះសន្ធិសញ្ញាជាមួយរដ្ឋជាដើម។[237] សកម្មភាពរបស់អង្គការសហប្រជាជាតិ ជាឧទហរណ៍មួយ បង្ហាញ ថាអង្គការនេះមានឋានៈដូចនេះ។ ជាក់ស្តែង អង្គការសហប្រជាជាតិ បានចុះកិច្ចព្រមព្រៀងជាមួយ រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតសាលាក្តីជំនុំជម្រះ មេដឹកនាំខ្មែរក្រហម។

នៅពេលដែលគេទទួលស្គាល់ថា អង្គការអន្តរជាតិ មានឋានៈជានីតិបុគ្គលអន្តរជាតិ អង្គការនោះ មានសិទ្ធិផងដែរ ក្នុងការប្តឹងទៅតុលាការអន្តរជាតិ ដើម្បីការពារផលប្រយោជន៍របស់ខ្លួន រាប់បញ្ចូល ផលប្រយោជន៍របស់បុគ្គលិករបស់ខ្លួន ដែលជាជនរងគ្រោះនៃអំពើរំលោភច្បាប់អន្តរជាតិ។ តុលាការយុត្តិធម៌អន្តរជាតិ បានអះអាងយ៉ាងដូចនេះ ក្នុងយោបល់ប្រឹក្សារបស់ខ្លួន (Advisory Opinion) ពាក់ព័ន្ធជាមួយ ការស្លាប់របស់លោក Count Bernadotte ជនជាតិរបស់ស៊ុយអែត ដែលជាបុគ្គលិករបស់អង្គការសហប្រជាជាតិ ត្រូវបានសម្លាប់ដោយ ក្រុមភេរវករ ក្នុងទីក្រុង Jerusalem។[238] តុលាការបាននិយាយថា អង្គការសហប្រជាជាតិ ទោះបី មិនមានច្បាប់ចែងអនុញ្ញាតឲ្យមានអំណាច ដើម្បីប្តឹងទៅតុលាការការពារប្រយោជន៍របស់ខ្លួនក្តី អង្គការនេះ មានអំណាច (Implied Power) ដែលនេះនាំឲ្យស្ថាប័ន នេះ អាចប្តឹងទៅតុលាការ ដើម្បីជានានូវប្រតិបត្តិការងារដោយរលូន។[239]

---

[237] Ian Brownlie, PIL, *supra* note 110, p. 677.

[238] D.J., Cases on IL, *supra* note 81, p. 132.

[239] *Id.,* p. 134; Brownlie, 7th ed., *suora* note 110, p. 677; the UN also intervenes on behalf of his staff against State of which the staff possesses the nationality, *see* ICJ,

### ៥.២. អភ័យឯកសិទ្ធិ និង ការទទួលខុសត្រូវ

អង្គការអន្តរជាតិ ក៏ដូចជារដ្ឋដែរ មានអភ័យឯកសិទ្ធិ ដើម្បីឲ្យអង្គការអាចដំណើរការការងារទៅបានរលូន។ អភ័យឯកសិទ្ធិ ត្រូវបានចែងផ្តល់ ដោយសន្ធិសញ្ញា ច្បាប់ទំនៀមទម្លាប់អន្តរជាតិផងដែរ។ វាជាសន្ធិសញ្ញាពហុភាគី[240] ឬ ទ្វេភាគីរវាងអង្គការ និងរដ្ឋ[241] ដែលអង្គការស្ថិតនៅ។ បន្ថែមពីលើនេះ ច្បាប់ជាតិខ្លះ បានចែងផ្តល់អភ័យឯកសិទ្ធិ ដល់អង្គការអន្តរជាតិ។ ឧទាហរណ៍ ច្បាប់ ស្តីពី អង្គការអន្តរជាតិ របស់ប្រទេសអង់គ្លេស ឆ្នាំ ១៩៦៨។ អភ័យឯកសិទ្ធិទាំងនោះ មានអភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការរបស់រដ្ឋ អភ័យឯកសិទ្ធិរួចផុតពី ការអនុវត្តនូវសេចក្តីសម្រេចមកលើអង្គការជាដើម។[242]

អង្គការអន្តរជាតិ មានឋានៈជានីតិបុគ្គលអន្តរជាតិ ជាប្រធាននៃច្បាប់អន្តរជាតិ ដែលមានសិទ្ធិនិងកាតព្វកិច្ច។ កាតព្វកិច្ច គឺជាកាតព្វកិច្ចគោរពតាមច្បាប់អន្តរជាតិផងដែរ។ ជាក់ស្តែង អង្គការសហប្រជាជាតិ ទោះបីជាខ្លួនជាអង្គការកំពូលរបស់ពិភពលោកក្តី ខ្លួនមិនត្រូវស្ថិតនៅលើច្បាប់អន្តរជាតិឡើយ។ ស្ថាប័ននេះ ត្រូវតែគោរព នីតិរដ្ឋអន្តរជាតិ (International Rule of Law)។ អ្នកស្រាវជ្រាវ បានរិះគន់ ដល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ដែលដោយប្រយោលបំពានដល់វិធាននៃច្បាប់អន្តរជាតិ ដូចជាច្បាប់

---

Difference relating to Immunity from Legal Process of A Special Rapproteur of the Commission on Human Rights, Advisory Opinion of 29 April 1999.

[240] The UN Charter, *supra* note 42, Art. 5; the 1946 General Convention on the Privillages and Immunities of the United Nations and the 1947 Convention on the Privillages and Immunities of the Specialised Agencies.

[241] Dapo, IO, *supra* note 231, p. 294.

[242] *Id.,* pp. 295-296.

មនុស្សធម៌អន្តរជាតិ។[243] អ្នកខ្លះ បានអះអាងស្នើឲ្យមានតុល្យភាពនៃអំណាច ដែលអនុញ្ញាតឲ្យ តុលាការយុត្តិធម៌អន្តរជាតិ មានអំណាចរដ្ឋបាល ត្រួតពិនិត្យសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ។[244]

ដោយសារមានការទាមទារកុំឲ្យអង្គការអន្តរជាតិ បំពារបំពានច្បាប់អន្តរជាតិ ហើយគ្មានវិធានណាមួយ ចែងគ្រប់គ្រង គណៈកម្មការច្បាប់អន្តរជាតិ បានរៀបចំ និង ចងក្រងនូវវិធាន ស្តីពី ការទទួលខុសត្រូវរបស់អង្គការអន្តរជាតិ។[245] មកដល់ពេលនេះ ឯកសារនេះ នៅតែជាសេចក្តីព្រាងនៅឡើយ។ ដូចគ្នានឹងរដ្ឋ អង្គការអន្តរជាតិ ត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ឬទង្វើពាក់ព័ន្ធខ្លួន ដែលរំលោភវិធានច្បាប់អន្តរជាតិ។[246] ទោះបីជាយ៉ាងនេះក្តី មិនមែនគ្រប់អំពើទាំងអស់ សុទ្ធតែជាអំពើខុសច្បាប់អន្តរជាតិ ដែលនាំឲ្យមានការទទួលខុសត្រូវទេ។ មានកាលៈទេសៈ មួយចំនួន ដែលនាំឲ្យលើកលែងនូវការទទួលខុសត្រូវ ឧទាហរណ៍ ការព្រមព្រៀងរបស់ភាគី ចំពោះទង្វើរបស់ អង្គការអន្តរជាតិ។ មាត្រា ២០ បានចែងថា ៖ *កិច្ចព្រមព្រៀង មានសុពលភាពដោយរដ្ឋ ឬអង្គការអន្តរជាតិ ដល់ការប្រព្រឹត្ត នូវអំពើណាមួយ ដោយអង្គការអន្តរជាតិណាមួយទៀត បដិសេធអំពើខុស ទាក់ទងជាមួយនឹងរដ្ឋ*

[243] Shaw, IL, *supra* note 1, p. 127.

[244] Marko Divac Oberg, *the Legal Effects of Resolutions of the UN Security and General Assembley in Jurisprudence of the ICJ*, 16(5) *EJIL* (2005).

[245] Draft Articles on the Responsibility of International Organizations, with commentaries (Draft Articles, IO), 2011, adopted by the ICL at 63th Session, *see* Yearbook of the the International Law Commission, 2011, vol. II, Part Two.

[246] *Id.*, Art. 1.

*ឬអង្គការអន្តរជាតិ ក្នុងកម្រិត ដែលអំពើនោះ ស្ថិតនៅក្នុងខ្លឹមសារនៃការយល់ព្រមៗ*[247]

[247] Draft Articles, IO, Art. 20, Chapter 5.

# ជំពូក ៦
# យុត្តាធិការ

ក្នុងសម័យបុរាណ ដែលមធ្យោបាយធ្វើដំណើរមិនមានទូលំទូលាយ និង បច្ចេកវិទ្យាប្រើប្រាស់ ក្នុងការប្រព្រឹត្តបទល្មើសមិនទាន់ទំនើប បទឧក្រិដ្ឋ ត្រូវបានប្រព្រឹត្តឡើងក្នុងតែផ្ទៃប្រទេសមួយ និងពុំប៉ះពាល់ដល់ប្រទេសច្រើន ទៀតឡើយ។ ក្នុងសម័យបច្ចុប្បន្ន ស្ថានភាពនេះបានប្រែប្រួល។ ជនល្មើស បានគេចមកក្រៅប្រទេស ហើយអំពើខ្លះប៉ះពាល់ដល់រដ្ឋជាច្រើន ដែលទាម ទារឲ្យរដ្ឋធ្វើកិច្ចសហការបង្ក្រាបបទឧក្រិដ្ឋ ដូចជា បត្យាប័ន និងជួយគ្នា ទៅវិញទៅមកក្នុងវិស័យតុលាការ ដែលមានការជួយប្រមូលភស្តុតាងជាដើម ។ ព្រឹត្តិការណ៍ ដែលបានកើតឡើងក៏បានជំរុញ ឲ្យមានការកែសម្រួលច្បាប់ និងធ្វើច្បាប់ ពង្រីកយុត្តាធិការរបស់តុលាការ។ នេះក៏បានជំរុញឲ្យមាន ទំនាស់រវាងរដ្ឋ និងរដ្ឋពាក់ព័ន្ធ ជាមួយការកាត់ទោសលើឧក្រិដ្ឋជនណាមួយ។ មិនមានច្បាប់អន្តរជាតិណាមួយ គ្រប់គ្រង អំពីទំនាស់យុត្តាធិការឡើយ។ ជាទូទៅ អាទិភាពត្រូវបានផ្តល់ជូនដល់រដ្ឋ ជាទីកន្លែង ដែលបទឧក្រិដ្ឋកើត មាន ដោយពិចារណាលើ ភស្តុតាង និងសាក្សី ព្រមទាំងជនរងគ្រោះ។

យុត្តាធិការ គឺជាអំណាចក្រោមច្បាប់អន្តរជាតិ ឬជាតិ ក្នុងការចែងនូវអំពើ របស់ រូបវន្តបុគ្គល និងនីតិបុគ្គល តាមរយៈច្បាប់របស់ជាតិ។[248] មានយុត្តា ធិការ ចំនួនពីរប្រភេទ៖ ទី១ យុត្តាធិការអនុវត្ត (Jurisdiction to Enforce) ដូចជាការស៊ើបអង្កេត ចាប់ខ្លួន ឬចោទប្រកាន់និង ទី២ គឺយុត្តាធិការ

[248] Shaw, IL, *supra* note 1, p. 645.

ចែងបទប្បញ្ញត្តិ (Jurisdiction to Prescribe)។[249] យុត្តាធិការក្នុងការអនុវត្ត ទាមទារឲ្យមានការយល់ព្រមពីរដ្ឋ។ ឧទាហរណ៍ ក្នុងករណីប៉ូលីសរបស់រដ្ឋមួយ អាចចូលទៅប្រមូលភស្តុតាងក្នុងរដ្ឋមួយទៀត លុះត្រាមានកិច្ចព្រមព្រៀងជាពិសេស រវាងរដ្ឋដែលពាក់ព័ន្ធទាំងនោះ។ ប៉ូលីសរបស់រដ្ឋ តំបន់ Schengen អាចចូលទៅក្នុងរដ្ឋមួយទៀតបានដោយមិនចាំបាច់សុំការយល់ព្រមពីរដ្ឋ ជាសមាជិកនៃតំបន់នេះ។[250] មាត្រា៧ របស់កតិកាសញ្ញា ស្តីពី ការប្រឆាំងនឹងអំពើទារុណកម្ម ទាមទារឲ្យរដ្ឋ ចាប់ ឬបញ្ជូនខ្លួនជនប្រព្រឹត្តអំពើទារុណកម្ម ដែលត្រូវបានរកឃើញ លើដែនដីខ្លួន[251] គឺជាឧទាហរណ៍បង្ហាញអំពីយុត្តាធិការអនុវត្ត។

យុត្តាធិការក្នុងការចែងបទប្បញ្ញត្តិ គឺផ្អែកទៅតាមប្រភេទនៃបទល្មើស។ ចំពោះបទល្មើស ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនទាមទារឲ្យរដ្ឋចែងជាបញ្ញត្តិទេ។ ដូចគ្នានេះដែរ មិនមានការទាមទារចាំបាច់ ចែងបទល្មើសក្រោមសន្ធិសញ្ញាទេ សម្រាប់ប្រទេសប្រកាន់យក Commom Law នាសម័យមុន។ បញ្ហាសំខាន់ គឺជាការអនុវត្តជាក់ស្តែង ទៅតាមអ្វីដែលច្បាប់អន្តរជាតិបានទាមទារ។ កតិកាសញ្ញា ប្រឆាំងនឹងអំពើទារុណកម្ម មាត្រា៤ ទាមទារឲ្យរដ្ឋជាភាគី ចាត់អំពើទារុណកម្ម ជាបទឧក្រិដ្ឋ ដែលមាន

[249] Benedetto Conforti, An introduction to International law, 2012, pp. 75, 77; Marko Milanovic, Extraterritorial Application of Human Rights Treaties (Marko, Extraterritorial), 2011, p. 23.

[250] Citizens of all European Economic Area member states (EU, Iceland, Liechtenstein, Norway) and Switzerland are visa-exempt, *see* en.wikipedia.org/Visa_policy_in_the_European_Union

[251] The Torture Convention, *supra* note 189, Art. 7.

ទោសទណ្ឌធ្ងន់។[252] ប្រសិនបើរដ្ឋមានច្បាប់ចាត់ទុកអំពើទារុណកម្មជាបទឧក្រិដ្ឋ រួចហើយក្តី ត្រូវធ្វើយ៉ាងណា ឲ្យដូចន័យនៃពាក្យទារុណកម្ម តាមមាត្រា ១ នៃកតិកាសញ្ញានេះ។[253] ទោះបីជាយ៉ាងនេះក្តី ប្រសិនបើរដ្ឋមិនមានច្បាប់ចាត់ទុកអំពើទារុណកម្មជាបទឧក្រិដ្ឋក្តី ឲ្យតែរដ្ឋអាចអនុវត្តតាមពេញលេញតាមមាត្រានេះ នឹងមិនខុសកាតព្វកិច្ចចែងក្នុងសន្ធិសញ្ញានេះទេ។ ការទាមទារដោយមាត្រា ៤ គឺជាឧទាហរណ៍បង្ហាញ ពីលក្ខណៈជាកាតព្វកិច្ចនៃយុត្តាធិការ ក្នុងការធ្វើបញ្ញត្តិ (Mandatory Jurisdiction to Prescribe)។ នៅមានវិស័យខ្លះ ដែលមិនទាមទារដោយច្បាប់អន្តរជាតិ ហើយដែលផ្អែកទៅលើឆន្ទានុសិទ្ធិរបស់ រដ្ឋក្នុងការចែងជាបញ្ញត្តិ (Permissive Jurisdi ction to Prescribe)។[254]រដ្ឋ មានយុត្តាធិការផ្អែកទៅតាម ទីកន្លែងបទល្មើស ជនជាតិ និងមូលដ្ឋានផ្សេងទៀត។

### ៦.១. យុត្តាធិការផ្អែកតាមទីកន្លែងប្រព្រឹត្តបទល្មើស (Territorial Principle)

វាជាយុត្តាធិការ មួយប្រភេទ ផ្តល់ដល់រដ្ឋ ដែលជាទីកន្លែងដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត។ វាជាប្រភេទមួយ មានប្រវត្តិ និងទទួលបានការទទួលស្គាល់ជាយូរមកហើយ និងមិនមានការជំទាស់ឡើយ។ យុត្តាធិការនេះ ត្រូវបានប្រកាន់យកជាចាំបាច់ដោយរដ្ឋ ប្រកាន់យកប្រព័ន្ធ Common Law ។ មូលហេតុមិនមានការជំទាស់ ពីព្រោះយុត្តាធិការនេះ ងាយស្រួលអនុវត្តដោយសារមានសាក្សី ភស្តុតាងនៅនឹងកន្លែងកើតហេតុ។ ដែនដី សំដៅលើ

[252] *Id.,* Art. 4.
[253] Provisional Conclusions and Recommendations, CAT/A/58/44 (2003), para. 99(a).
[254] PCIJ, *France v. Turkey* (1972), PCIJ Reports, Series A, No. 10, pp. 18-19.

ផ្ទៃដីរបស់រដ្ឋ រាប់បញ្ចូលដែនសមុទ្ររបស់រដ្ឋ។ វាក៏រាប់បញ្ចូលនូវនាវា កប៉ាល់ ដែលត្រូវបានចុះបញ្ជីក្នុងប្រទេស។[255]

### ៦.២. យុត្តាធិការផ្អែកតាមសញ្ជាតិ (Nationality Principle)

យុត្តាធិការនេះ ត្រូវបានផ្ដល់ដល់រដ្ឋ ដែលមានប្រជាពលរដ្ឋ ជាអ្នកប្រព្រឹត្តបទល្មើស (Active Nationality Principle)។ វានឹងមិនមានបញ្ហាចម្រូងចម្រាសទេ នៅពេលដែល ជនល្មើសជាប្រជាពលរដ្ឋ ប្រព្រឹត្តល្មើសនៅលើដែនដីរបស់ខ្លួន។ វាអាចមានបញ្ហាច្បាប់ ដែលតម្រូវឲ្យប្រទេសក្នុងប្រព័ន្ធ Common Law ប្រើយុត្តាធិការដើម្បីកាត់ទោស អំពើធ្វើដោយប្រជាពលរដ្ឋខ្លួននៅក្រៅប្រទេស ឬអំពើនៅក្រៅប្រទេស ដែលមានជនរងគ្រោះ ជាប្រជាពលរដ្ឋខ្លួន (Passive Nationality Principle)[256] ដោយសារដូចបានបញ្ជាក់រួចមកហើយ ច្បាប់របស់ប្រទេសប្រកាន់ប្រព័ន្ធ Common Law អនុញ្ញាតឲ្យកាត់សេចក្ដីចំពោះបទឧក្រិដ្ឋ ដែលកើតក្នុងប្រទេសតែប៉ុណ្ណោះ។ តុលាការអង់គ្លេស អាចកាត់ទោសបានលុះត្រា មានច្បាប់អនុវត្តសម្រាប់អំពើក្រៅដែនដី (Extraterritorial Jurisdiction Law)។[257] ចំពោះប្រទេសប្រកាន់ប្រព័ន្ធ Civil Law នឹងមិនមានបញ្ហាច្បាប់ឡើយពីព្រោះ ច្បាប់របស់ខ្លួនអនុញ្ញាត នូវយុត្តាធិការប្រភេទនេះ។[258] យុត្តាធិការនេះ ផ្អែកទៅតាម

[255] Javier, A Compenduim, *supra* note 195, p. 35; see also Antonio, the Oxford, *supra* note 55, pp. 531-532.

[256] Antonio, the Oxford, *supra* note 55, p. 451.

[257] Application of domestic laws outside their territory, for example, the United States, *see* Shaw, IL, *supra* note 1, p. 688.

[258] This is because most of civil law countries do not extradite their nationals, *see* Antonio, the Oxford, *supra* note 55, p. 229.

សញ្ជាតិរបស់ជនល្មើស ឬជនរងគ្រោះ ដែលច្បាប់រដ្ឋចែងកំណត់។ វាសំដៅលើសញ្ជាតិ ក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត។[259]

## ៦.៣. យុត្តាធិការសម្រាប់ការពារប្រយោជន៍សំខាន់របស់ជាតិ (Protective Principle)

សកម្មភាពខ្លះ ធ្វើឡើងដោយជនបរទេស នៅក្រៅដែនដីរបស់រដ្ឋ មួយអាចធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រយោជន៍រដ្ឋណាមួយ។ ដើម្បីឆ្លើយតបបញ្ហានេះ រដ្ឋមួយចំនួនបាន ធ្វើច្បាប់ អនុញ្ញាតឲ្យតុលាការខ្លួន មានយុត្តាធិការលើបទឧក្រិដ្ឋទាំងនោះ។ ក្នុងសម័យបុរាណ បទឧក្រិដ្ឋក្លែងរូបិយវត្ថុ ស្ថិតចូលក្នុងយុត្តាធិការប្រភេទនេះ។[260] ក្នុងពេលបច្ចុប្បន្ន ប្រភេទបទល្មើស ត្រូវបានបន្ថែម រាប់បញ្ចូលបទប៉ះពាល់សេដ្ឋកិច្ច និងសន្តិសុខជាតិ ហើយប្រទេសជាច្រើនបានប្រកាន់យក។[261] ពាក់ព័ន្ធនឹងប្រយោជន៍របស់រដ្ឋ ផ្អែកតាមទ្រឹស្តីនៃផលវិបាក (Effect Doctrine) រដ្ឋបានធ្វើច្បាប់ចែងអំពី យុត្តាធិការលើបទល្មើស ដែលកើតមានក្នុងដែនដីរបស់ខ្លួន និងបានបញ្ចប់នៅក្រៅប្រទេស (Subjective Territorial Principle) ដែលប៉ះពាល់ដល់ប្រយោជន៍របស់រដ្ឋ។ ដូចគ្នានេះដែរ រដ្ឋមានយុត្តាធិការលើបទឧក្រិដ្ឋ កើតនៅក្រៅប្រទេស តែបញ្ចប់ក្នុងប្រទេស ហើយដែលប៉ះប្រយោជន៍របស់ខ្លួន(Objective Territorial Principle)។ យុត្តាធិការប្រភេទ នេះខុសពីយុត្តាធិការ

[259] Some commentators suggested excercise jurisdiction over persons with nationality of the State concerned during the time of prosecution, *see* Antonio, the Oxford, *supra* note 55, p. 229.
[260] Antonio, the Oxford, *supra* note 55, p. 474.
[261] *Id.*, p. 474.

ការពារ ដោយសារវាបង្កើតឡើងសម្រាប់ ការពារប្រយោជន៍ មិនប្រយោល របស់រដ្ឋដូចជា ករណីមនុស្សឃាតជាដើម។

### ៦.៤. **យុត្តាធិការសាកល** (Universal Jurisdiction)

វាជាយុត្តាធិការមួយផ្តល់តាមសន្ធិសញ្ញា ដល់រដ្ឋសម្រាប់ កាត់ទោសជន ប្រព្រឹត្តបទឧក្រិដ្ឋ ក្រោមច្បាប់អន្តរជាតិ ដូចជា ការធ្វើជាទាសភាព បទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស ជាតិជាដើម។ យុត្តាធិការនេះ ខុសពីប្រភេទយុត្តាធិការ ដែលត្រូវបានបរិយា យនៅក្នុងទំព័រមុន ដោយសារ មិនមានទំនាក់ទំនងដែនដី ផលប្រយោជន៍ សញ្ជាតិ ជាមួយរដ្ឋដែលប្រើប្រាស់យុត្តាធិការនេះឡើយ។ បច្ចុប្បន្ននេះ បទ ល្មើសជាច្រើន ត្រូវបានបន្ថែមចូលក្នុងយុត្តាធិការនេះ ឧទាហរណ៍ បទ ទារុណកម្ម។[262] យុត្តាធិការនេះ ត្រូវបានផ្តល់ចំពោះបទល្មើសធ្ងន់ធ្ងរ ប៉ះ ដល់មនុស្សលោក ដែលរដ្ឋទាំងអស់ ត្រូវចូលរួមប្រឆាំង និងលុបបំបាត់។ គេ អាចនិយាយបានថា យុត្តាធិការនេះ ទាញចេញពីកាតព្វកិច្ច *Erga Omnes* Obligation។[263]

ការអនុវត្តយុត្តាធិការនេះ ត្រូវផ្អែកលើលក្ខខណ្ឌមួយចំនួន ដូចជាទាមទារឲ្យ ជនប្រព្រឹត្តស្ថិតនៅក្នុងដែនដីរបស់រដ្ឋ ដែលចង់ប្រើយុត្តាធិការសាកល។[264] រដ្ឋអាចធ្វើការចោទប្រកាន់លើជនល្មើសខ្លួនឯង ឬធ្វើបត្យាប័ន[265] ប្រគល់ជន ត្រូវចោទទៅឲ្យរដ្ឋដទៃ ដែលមានបំណង ចង់កាត់ទោសជននោះ។ នេះ

---

[262] Antonio, the Oxford, *supra* note 55, p. 555.

[263] The obligation of extradition is not erga omnes obligation.

[264] The Torture Convention, *supra* note 189, Art. 7.

[265] It is noted that some crimes not attracting universal jurisdiction, but still demand obligation to extradite or prosecute.

អាចទាញការសន្និដ្ឋានបានថា ការទាមទារឲ្យជនត្រូវចោទណាមួយស្ថិត នៅក្នុងដែនដីជាមុន មុននឹងរដ្ឋអនុវត្តយុត្តាធិការ គឺជារឿងអនុវត្ត ពីព្រោះច្បាប់របស់រដ្ឋជាច្រើន មិនអនុញ្ញាតឲ្យមានការកាត់ទោសកំបាំងមុខ (Trial *In Absentia*)ទេ។

ករណីរបស់មេដឹកនាំ ប្រទេស ឈីលី លោក *Pinochet* ជារឿងមួយបង្ហាញអំពីការអនុវត្តយុត្តាធិការសាកល។ លោក *Pinochet* បានមកព្យាបាល ជំងឺនៅក្នុងប្រទេសអង់គ្លេស។[266] រដ្ឋអាជ្ញារបស់ អេស្ប៉ាញ (Spain) តាមបណ្តឹងរបស់ប្រជាពលរដ្ឋខ្លួន បានស្នើសុំឲ្យប្រទេសអង់គ្លេសបញ្ជូនលោក *Pinochet* ទៅមុខតុលាការអេស្ប៉ាញ ប្រឈមមុខនឹងការចោទប្រកាន់បទទារុណកម្ម ប្រព្រឹត្តទៅក្នុងអំឡុងនៃការកាន់អំណាចរបស់គាត់[267] មុនចុះពី អំណាចទទួលបានងារជាព្រឹទ្ធសភាមួយជីវិត (Senator for Life)[268] ដែលតាមរយៈនេះ គាត់មានអភ័យឯកសិទ្ធិ។ ក្នុងរឿងនេះ ទាំងប្រទេសអង់គ្លេស និង អេស្ប៉ាញ ដែលជារដ្ឋអាចប្រើប្រាស់ យុត្តាធិការ មិនមានជនជាតិខ្លួន ជាជនរងគ្រោះ និងបទល្មើសមិនបានប្រព្រឹត្តនៅក្នុងដែនដីរបស់ខ្លួនឡើយ ។ ប្រទេសអង់គ្លេស ជាប្រទេសមួយ ត្រូវអនុវត្តយុត្តាធិការនេះ ដោយសារ លោក *Pinochet* ស្ថិតនៅក្នុងដែនដីរបស់ខ្លួន។ ក៏ប៉ុន្តែរដ្ឋនេះ ស្ទាក់ស្ទើរ ដូចដែលបានជម្រាបមកហើយ ច្បាប់អង់គ្លេស មិនអនុញ្ញាតឲ្យកាត់ទោស ជនដែលប្រព្រឹត្តបទល្មើសនៅក្រៅដែនដីខ្លួនឡើយ

[266] Naomi Roht-Arriaza, *the Multiple Prosecution of Augusto Pinochet*, in Ellen L. Lutz & Caitlin Reiger, Prosecuting Heads of State, 2009, p. 4.
[267] *Id.*, pp. 79-82.
[268] Jo Stigen, the Relationship between the international criminal court and national jurisdiction (Stigen, the Relationship), 2008, p. 417.

ហើយម្យ៉ាងទៀតលោក *Pinochet* ត្រូវបានគេជឿថា មានអភ័យឯកសិទ្ធិ។[269]

ទង្វើរបស់តុលាការប្រទេសអេស្ប៉ាញ ត្រូវបាន មេដឹកនាំរដ្ឋមួយចំនួន ថាធ្វើហួសជ្រុលពីព្រោះ លោក *Pinochet* មិនស្ថិតនៅក្នុងដីរបស់ខ្លួនឡើយ។ ទោះបីជាយ៉ាងនេះក្តី អ្នកការពារនិងគាំទ្រសិទ្ធិមនុស្សជាច្រើន បានសាទរនូវទង្វើរបស់តុលាការអេស្ប៉ាញ។ ការប្រកាន់ជំហរផ្ទុយពីក្រុមអ្នកគាំទ្រសិទ្ធិមនុស្ស បង្ហាញយុត្តាធិការនេះ គួរហៅថា (Conditionally Universal Jurisdiction)។[270]

សន្មតិថាតុលាការ អេស្ប៉ាញបានទទួលជោគជ័យ ក្នុងការសុំបត្យាប័នពីប្រទេសអង់គ្លេស ហើយឆ្លងតាមការកាត់ទោស រកឃើញថា លោក *Pinochet* មានទោស មានសំណួរថា៖ តើជនរងគ្រោះអាចទទួលបានសំណងដែរឬទេ? តើអ្នកណាជាអ្នកចេញសំណង? មានអ្នកស្រាវជ្រាវខ្លះអះអាងថាពួកគេទទួលបានសំណង ពីជនល្មើស ឬសូម្បីពីប្រទេស ដែលកាត់សេចក្តីក្នុងរឿងនោះ។ នេះដោយផ្អែកលើហេតុផលថា ការហាមឃាត់អំពើទារុណកម្ម ជាវិធានស្ថិតនៅក្នុងលំដាប់ខ្ពស់ របស់ច្បាប់អន្តរជាតិ។ តុលាការអន្តរជាតិ មិនបានយល់ឃើញដូចនេះទេ ហើយបានអះអាងថា បញ្ញាចរិតលក្ខណៈនៃវិធាន គឺជារឿងមួយ ហើយការអនុវត្តសំណងគឺជារឿងមួយទៀត។[271] មាត្រានៃសន្ធិសញ្ញា ស្តីពី ការប្រឆាំងនឹងអំពើទារុណកម្ម មិនបាន

[269] House of Lords found that Pinochet does not have immunity as regards crime of torture, *see* Robert Cryer, *Pinochet, see* Antonio, the Oxford, *supra* note 55, p. 875.
[270] Antonio, the Oxford, *supra* note 55, p. 557.
[271] Alexander, Restrictive, *supra* note 195, p. 350.

ចែងតម្រូវនូវកាតព្វកិច្ចសំណងដូចនេះឡើយ។[272] បុគ្គលអាចប្រើប្រាស់វិធីផ្សេង មានក្រោមច្បាប់ជាតិ។ ឧទាហរណ៍ ច្បាប់របស់អាមេរិក អនុញ្ញាតឲ្យបុគ្គលប្តឹងទារសំណង ពីអ្នកប្រព្រឹត្តអំពើទារុណកម្មនៅក្រៅប្រទេសដែលចូលមកក្នុងដែនដីរបស់សហរដ្ឋអាមេរិក។[273] កន្លងមក មានការអនុវត្តរួចហើយ ដូចជាករណី *ម៉ាកូស* អតីតប្រធានាធិបតីរបស់ ប្រទេស ហ្វីលីពីន។[274] អ្វីដែលគួរឲ្យចងចាំនោះគឺថា លុះត្រាជនល្មើសមានវត្តមាននៅក្នុងដែនដីរបស់រដ្ឋ។

## ៦.៥.ការអនុវត្តយុត្តាធិការ និងបញ្ហាដែលពាក់ព័ន្ធ

នៅក្នុងករណីខ្លះ ការអនុវត្តយុត្តាធិការ មិនមានភាពចម្រូងចម្រាសឡើយ។ នេះក្នុងករណី ដែលបទល្មើសប្រព្រឹត្តនៅក្នុងដែនដីរបស់រដ្ឋ ដោយប្រជាពលរដ្ឋរបស់រដ្ឋនោះ។ ករណី ដែលជនល្មើសបានប្រព្រឹត្តបទល្មើស បានរត់គេចខ្លួន ទៅប្រទេសផ្សេង ហើយប្រទេសនោះមានសមត្ថកិច្ចផងដែរ ក្នុងការកាត់សេចក្តី ដោយសារបុគ្គលនោះមានជនសញ្ជាតិរបស់រដ្ឋនោះដែរ បញ្ហានឹងមានភាពស្មុគស្មាញ។ នេះរាប់បញ្ចូលបញ្ហាបត្យាប័ន។

បត្យាប័នត្រូវបានផ្តល់ន័យថា ជាដំណើរការប្រគល់ ឬទទួលជនណាមួយឲ្យទៅទទួលទោស ឬប្រឈមនឹងការកាត់ទោស ចំពោះបទល្មើសដែលខ្លួនបាន

---

[272] Narrowly interpreted, Art. 14 of the Torture Convention does not oblige State party to provide compensation to victim of torture, staying in her territory, committed abroad by other State’s authorities.

[273] Michael Koebele, Corporate responsibility under the Alien Tort Statute, 2009, p. 49.

[274] *Hilao and Ors v Estate of Marcos*, Appeal Decision, 103 F3d 767 (9th Cir 1996); ILDC 841 (US 1996).

ប្រព្រឹត្ត។[275] រដ្ឋមាន កាតព្វកិច្ចធ្វើបត្យាប័ន តាមសន្ធិសញ្ញា ឬតាមទម្លាប់ ក៏ប៉ុន្តែកាតព្វកិច្ចនេះ ប្រឈមនឹងលក្ខខណ្ឌ និងការហាមមិនឲ្យធ្វើបត្យាប័ន តាមច្បាប់អន្តរជាតិ ឬច្បាប់ក្នុងស្រុក។ ឧទាហរណ៍ ច្បាប់ជាតិខ្លះ មិនអនុញ្ញាតឲ្យធ្វើបត្យាប័នប្រជាពលរដ្ឋខ្លួនឡើយ។[276] ច្បាប់អន្តរជាតិ ហាមមិនឲ្យរដ្ឋធ្វើបត្យាប័នបុគ្គល ដែលជាលទ្ធផលនៃការធ្វើបត្យាប័ន បុគ្គល នោះនឹងជួបប្រទះនូវអំពើទារុណកម្ម។[277]

ការអនុវត្តតាមយុត្តាធិការសាកល ពាក់ព័ន្ធជាមួយការធ្វើបត្យាប័នភេរវជន គឺជាបញ្ហា មួយចម្រូងចម្រាសនិងស្មុគស្មាញ។ វាពាក់ព័ន្ធជាមួយនឹងបញ្ហា Dual Criminality[278] ដោយសារច្បាប់រដ្ឋមិនទាន់ផ្តល់និយមន័យច្បាស់លាស់ពាក់ព័ន្ធអ្វីទៅជាភេរវកម្ម។[279] អំពើភេរវកម្ម ត្រូវបានចាត់ថាជាបទល្មើសនយោបាយ ដែលស្ថិតនៅក្នុងករណី លើកលែង ក្នុងការធ្វើបត្យាប័ន។[280] រដ្ឋបានស្នើកុំឲ្យចាត់ថា អំពើភេរវកម្មជា បទល្មើសនយោបាយ ដែលរាំងស្ទះដល់បត្យាប័ន។ តាមការអនុវត្ត រដ្ឋច្រើនកាត់ទោសបុគ្គល ដែលមាន

---

[275] Antonio, the Oxford, *supra* note 55, p. 321.

[276] *See* MEAS Bora, *Extradition under International Law and Cambodian Law Extradition: International and Cambodian Law*, in Hor Peng, Kong Phallack and Jorg Menzel, Eds., Introduction to Cambodian Law, 2012, p. 433; Antonio, the Oxford, *supra* note 55, p. 229.

[277] The Torture Convention, *supra* note 189, Art. 3.

[278] Inter-American Convention on Mutual Assistance in Criminal Matters, Art. 5, *see* www.0as.org/urisdico/english/treaties/a-55.html.

[279] The reason that States could not agree so far on the defintion of terrorist act causes prolonged dicussion of draft convention on the combatting of terrorsit acts; Geoff Gilbert, transnational fugitive offenders in international law, extradition and other mechanisms, 1998, pp. 251-253.

[280] International Commission of Jurists, Legal Commentary to the ICJ Berlin Declaration, counter-terrorsim, human rights and the rule of law (Commentary on Berlin Declaration), Human Rights and Rule of Law Series: No. 1, 2008, p. 23.

និន្នាការនយោបាយផ្សេងពីរដ្ឋ ថាបានប្រព្រឹត្តបទល្មើសបទភេរវកម្ម។ នេះនាំឲ្យមានការ ហាមឃាត់ការកាត់ទោស ដោយផ្អែកលើគំនិតនយោបាយ។[281]

## ៦.៦.មូលដ្ឋានផ្សេងទៀតនៃយុត្តាធិការ

ក្រៅពីមូលដ្ឋានខាងលើ ច្បាប់របស់រដ្ឋខ្លះ បានចែងឲ្យមានយុត្តាធិការលើបទល្មើស ដែលបានប្រព្រឹត្តដោយបុគ្គល ដែលស្នាក់នៅស្របច្បាប់ក្នុងរដ្ឋ នាពេលដែលជននោះ បានប្រព្រឹត្តបទល្មើស។[282] ជាចុងក្រោយ រដ្ឋខ្លះ មានយុត្តាធិការ លើបុគ្គលដែលអាជ្ញាធររបស់ខ្លួនបានគ្រប់គ្រង។[283] ឧទាហរណ៍ ទាហានបរទេស ដែលចូលរួមធ្វើសង្គ្រាមឲ្យប្រទេសអង់គ្លេស ស្ថិតនៅ ក្រោមអំណាចយុត្តាធិការរបស់អង់គ្លេស។ ជាចុងក្រោយផ្អែកតាមសន្ធិសញ្ញា ឬកិច្ចព្រមព្រៀង រវាងរដ្ឋ និងរដ្ឋ រដ្ឋមួយព្រមព្រៀងឲ្យរដ្ឋមួយទៀត អនុវត្តយុត្តាធិការជំនួសខ្លួន។ ពួកតាលីប៉ង់មួយចំនួន ដែលត្រូវចាប់បានដោយទាហានអាមេរិក ត្រូវបានបញ្ជូនទៅ សហរដ្ឋអាមេរិក ដើម្បីទទួលការកាត់ទោសនៅទីនោះ។

[281] *Id*., pp. 15, 22.

[282] Antonio, the Oxford, *supra* note 55, p. 229.

[283] *Id*., p.229.

# ជំពូក ៧

# ការប្រើកម្លាំងយោធា

## ៧.១. ប្រវត្តនៃការហាមឃាត់

ការធ្វើសង្គ្រាម ឬហាមធ្វើសង្គ្រាម ជារឿងមួយដ៏ចម្រូងចម្រាសជាយូរយារមកហើយ ហើយបានឆ្លុះពីចរិតលក្ខណៈនៃច្បាប់អន្តរជាតិសម័យបុរាណ។ មុនសង្គ្រាមលោកលើកទី១ ឬសូម្បីក្រោយសង្គ្រាមលោកលើកទី១ រដ្ឋប្រើកម្លាំងទ័ព និងធ្វើសង្គ្រាមយ៉ាងញឹកញាប់ដើម្បី ពង្រីកទឹកដី ដោះស្រាយជម្លោះ ការពារប្រជាពលរដ្ឋខ្លួន ដែលត្រូវរដ្ឋដទៃធ្វើទុក្ខទោសនៅក្រៅប្រទេស។[284]ច្បាប់ដែលពាក់ព័ន្ធជាមួយ សង្គ្រាមសម័យនោះ និយាយចែងអំពីវិធីធ្វើសង្គ្រាម តែមិនបានហាមឃាត់សង្គ្រាមទូលំទូលាយទេ។ សង្គ្រាមប្រល័យលោកទាំងពីរ អាចជាឧទាហរណ៍មួយ នៃកម្សោយនៃវិធានពាក់ព័ន្ធជាមួយនឹងការហាមឃាត់សង្គ្រាម។ ធម្មនុញ្ញរបស់អង្គការសង្គមប្រជាជាតិ មិនបានហាម ការប្រើកម្លាំងទ័ពឡើយ។ ក្រោយបញ្ចប់សង្គ្រាមលោកលើកទី ២ ឆ្នាំ ១៩៤៥ ធម្មនុញ្ញអង្គការសហប្រជាជាតិ ត្រូវបានអនុម័តនិង បានហាមឃាត់ការគំរាមកំហែង និងការប្រើកម្លាំង[285] លើកលែងការការពារខ្លួនរដ្ឋ (Self-Defence) និងការប្រើកម្លាំងតាមជំពូកទី ៧របស់ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

[284] Shaw, IL, *supra* note 1, p. 1156; Peter Malanczuk, IL, *supra* note 1, p. 19.
[285] The UN Charter, *supra* note 42, Art.2.

## ៧.២. ខ្លឹមសារនៃការហាមប្រើកម្លាំង

មាត្រា ២ (៤)៖ សមាជិកទាំងអស់ ត្រូវបានហាមមិនឲ្យគំរាម ឬប្រើប្រាស់កម្លាំងក្នុងទំនាក់ទំនងអន្តរជាតិ ប្រឆាំងនឹងអធិបតេយ្យភាពដែនដី ឬឯករាជ្យភាពនយោបាយរបស់រដ្ឋណាមួយ ឬ ក្នុងលក្ខណៈដែលផ្ទុយជាមួយនឹងគោលបំណងរបស់អង្គការសហប្រជាជាតិ។

តើអ្វីទៅជាការគំរាមកំហែង? តើការដាក់សម្ពាធផ្នែកសេដ្ឋកិច្ច ជាការគំរាមកំហែង? តើការបង្ហាំងកប៉ាល់នៅក្នុងសមុទ្រអន្តរជាតិ ជាការគំរាមកំហែងដល់ឯករាជ្យភាពនយោបាយឬទេ? ការគំរាមកំហែងនេះ មិនអាចចាត់ជាការគំរាមកំហែងទេ។ ការបកស្រាយទូលាយពេក អាចនាំឲ្យមានការរាំងស្ទះដល់ដំណើរការនៃទំនាក់ទំនងរវាងរដ្ឋជាមួយនឹងរដ្ឋ ដោយសារអំពើទាំងនោះអាចនាំឲ្យមានការតបត។ ការបកស្រាយពាក្យ "គំរាមកំហែង" ក្នុងមាត្រា២ (៤) គួរត្រូវពិចារណាជាមួយនឹង មាត្រាដទៃទៀត ដូចជា មាត្រា ៥១ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។ ទោះបី ជាអ្នកស្រាវជ្រាវ ពិបាកទទួលយកការប្រដូចន័យរបស់ពាក្យ "គំរាមកំហែង" ទៅនឹងពាក្យ "ការប្រើប្រាស់កម្លាំង" ឬ "ការវាយប្រហារ" តែពាក្យ "គំរាមកំហែង" គួរតែមានស្ថានភាពស្រដៀងនេះ។[286] ពាក្យ "ក្នុងលក្ខណៈដែលផ្ទុយជាមួយនឹងគោលបំណងរបស់អង្គការសហប្រជាជាតិ" មិនមែនសម្រាប់បង្ការកុំឲ្យការគំរាមកំហែងផ្ទុយពី *Jus Cogens* ទេ ក៏ប៉ុន្តែ វាជាចន្លោះប្រហោងសម្រាប់សកម្មភាពក្រោយពេលដែលធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ត្រូវបានអនុម័ត ដែល

[286] Bruno, Commentary, *supra* note 143, p. 112.

មិនអាចព្យាករនូវសកម្មភាព ដែលផ្ទុយនឹងគោលបំណងរបស់អង្គការសហប្រជាជាតិ។

### ៧.៣. សិទ្ធិការពារខ្លួន (Self-Defence)

មាត្រា ៥១ នៃធម្មនុញ្ញអង្គការសហប្រជាជាតិចែងថា ៖ មិនមានអ្វីក្នុងធម្មនុញ្ញនេះ ប៉ះពាល់ដល់សិទ្ធិការពារមានស្រាប់ (Inherent Rights) របស់រដ្ឋ ឬរដ្ឋជារួម ប្រសិនបើមានការវាយប្រហារដោយប្រើកម្លាំងទ័ព កើតមានឡើង ប្រឆាំងនឹងសមាជិក របស់អង្គការសហប្រជាជាតិ រហូតដល់ក្រុមប្រឹក្សាសន្តិសុខប្រកាន់យកវិធានការចាំបាច់ ក្នុងការការពារសន្តិភាព និងសន្តិសុខ។ វិធានការប្រកាន់យកដោយរដ្ឋ ក្នុងការអនុវត្តសិទ្ធិការពារខ្លួន ត្រូវរាយការណ៍ជាបន្ទាន់ទៅ ក្រុមប្រឹក្សាសន្តិសុខ និងមិនត្រូវប៉ះអំណាច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាសន្តិសុខ ក្រោមធម្មនុញ្ញនេះ ក្នុងការប្រកាន់យក សកម្មភាព ដែលចាំបាច់ក្នុងការថែរក្សា និងធ្វើឲ្យប្រសើរនូវសន្តិសុខ និង សន្តិភាពអន្តរជាតិ។[287]

តាមខ្លឹមសារក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ការហាមឃាត់ការប្រើកម្លាំងជា វិធានទូទៅ ហើយការអនុញ្ញាតឲ្យមាន (Self-Defence) គឺជាករណីលើកលែង។ ជាទូទៅរដ្ឋមិនប្រកាសជាចំហថា ខ្លួននឹងធ្វើសង្គ្រាមឡើយ។ នៅពេលធ្វើសង្គ្រាម រដ្ឋអះអាងថានេះ ជាសិទ្ធិការពារខ្លួន។ ជាប្រយោល វាជាអំពើផ្ទុយទៅនឹងការហាមប្រើកម្លាំង។ ផ្ទុយទៅវិញ និងជាក់

[287] The UN Charter, *supra* note 42, Art. 51.

ស្តែងវានឹងមានការប្រើកម្លាំងជាញឹកញាប់ដោយរដ្ឋផ្សេងៗ ដែល នេះតម្រូវឲ្យមានការស្នើនូវការបកស្រាយមាត្រា ៥១ ឲ្យចង្អៀត។

សិទ្ធិដែលមានស្រាប់ (Inherent Right) មានន័យថា រដ្ឋមានអធិបតេយ្យភាព ហើយដែលអាចឈរជើងបាន ត្រូវតែមានសិទ្ធិវាយបក ដើម្បីការពារខ្លួនពីការវាយប្រហារពីខាងក្រៅ។ ន័យម្យ៉ាងទៀត គឺសិទ្ធិនេះ មានជាយូរយារមកហើយមុនការដាក់បញ្ចូលក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិទៅទៀត។ វាជាសិទ្ធិមានឋានៈជាទំនៀមទម្លាប់អន្តរជាតិ។ គេអាចប្រដូចសិទ្ធិនេះទៅនឹងសិទ្ធិរក្សាខ្លួន (Right of Self-Preservation) ជាសិទ្ធិដ៏ទូលាយ អាចអនុញ្ញាតឲ្យ ប្រកាន់យកសកម្មភាពណាមួយជាការឆ្លើយតបនឹងការវាយប្រហារ[288] ទោះបីផ្ទុយពីវិធានច្បាប់អន្តរជាតិ រាប់បញ្ចូលការបង្ការកុំឲ្យមានការវាយប្រហារ។[289] ការប្រដូចដូចនេះ អាចនាំឲ្យមានការបកស្រាយសិទ្ធិក្នុង មាត្រា ៥១ ទូលាយ អនុញ្ញាតឲ្យរដ្ឋធ្វើការវាយប្រហារជាមុន មុនការវាយប្រហារពីខាងក្រៅជាមុន។ វាជាការវាយប្រហារបង្ការ ដែលត្រូវបានហៅថា Preemptive Self-Defence។ សហរដ្ឋអាមេរិក ប្រើទ្រឹស្តីនេះ សម្រាប់ជាយុត្តិកម្មលើការវាយប្រហាររបស់ខ្លួន ដែលអាចមានក្នុងវិបត្តិនុយក្លេអ៊ែរ បណ្តាលមកពីការដាក់តាំងអាវុធរបស់សហភាពសូវៀតនៅក្នុងទឹកដីគុយបា ក្នុងឆ្នាំ ១៩៦២ ក្នុងសម័យសង្គ្រាមត្រជាក់។ តុលាការយុត្តិធម៌អន្តរជាតិនៅ ក្នុងសំណុំរឿងរបស់ *Nicaragua* ប្រឆាំងជាមួយ សហ

[288] Kelsen, the Principles of International Law (Kelsen, PIL), (1966, 2nd ed.), reviewed and edited by Robert W. Tucker, pp.58-59.

[289] William Edward Hall, Treatise on International Law, (1924, 8th ed.), p. 65, para. 11; Kelsen, PIL, id., pp.58-59.

រដ្ឋអាមេរិក អះអាងថា ខណៈទទួលស្គាល់ថា សិទ្ធិក្នុងមាត្រា ៥១ ជាទំនៀមទម្លាប់អន្តរជាតិ សិទ្ធិក្នុងមាត្រា៥១ នេះត្រូវបកស្រាយឲ្យចង្អៀតជាងសិទ្ធិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយ ទាមទារនូវលក្ខខណ្ឌសមមាត្រ (Proportionality) និងភាពចាំបាច់ (Necessity of Self-Defence)។[290]

ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ត្រូវបានអនុម័តតាំងពីឆ្នាំ ១៩៤៥។ ក្នុងអំឡុងពេលរៀបចំធម្មនុញ្ញ អ្នកធ្វើសេចក្តីព្រាង ពិតជាមិនអាចព្រាងបទប្បញ្ញត្តិឲ្យត្រូវគ្រប់ជ្រុងជ្រោយ សម្រាប់រយៈ១០ ឬ២០ ឆ្នាំក្រោយឡើយ ដូចនេះ ការបកស្រាយ គួរពិចារណាទៅលើស្ថានភាពបច្ចុប្បន្នផងដែរ។ ក្នុងករណី ដែលការវាយប្រហារពីខាងក្រៅ ពិតជាអាចកើតមាន រដ្ឋគួរអាចប្រើប្រាស់សិទ្ធិការពារជាមុន (Anticipatory Self-Defence)។[291] ក៏ប៉ុន្តែគ្រាន់ តែស្មានថា មានការវាយប្រហារពីខាងក្រៅអាចកើតមានឡើង ហើយរដ្ឋធ្វើការវាយប្រហារជាការបង្ការជាមុន (Preemptive Self-Defence) ពិតជាពិបាកទទួលយកតាមផ្លូវច្បាប់។

អនុលោមតាមខ្លឹមសារខាងលើ ពេលវេលានៃការវាយប្រហារ មិនមែនជាការសំខាន់ប៉ុន្មានទេ បើប្រៀបធៀបជាមួយនឹងចរិតលក្ខណៈនៃការវាយប្រហារ។ វាត្រូវតែជាការវាយប្រហារដោយអាវុធ (Armed Attack) ពីរដ្ឋខាងក្រៅដោយរដ្ឋឬ ដោយក្រុមប្រដាប់អាវុធ ដែលអាចគាំទ្រដោយរដ្ឋនោះ។ តើការ

[290] Bowett asserted that self-defence is different from right of self preservation, *see* Bowett, Self-defence in International Law (1958), p. 270; ICJ, Legality of the Threat or Use of Nuclear Weapons, ICJ Reports, 1996, pp. 226, 245; 110 ILR, p. 163.
[291] Shaw, IL, *supra* note 1, pp. 1137-1138.

វាយប្រហារវាចាំបាច់លុះត្រា មានទ្រង់ទ្រាយធំឬ? នេះជាសំណួរមួយដ៏ពិបាកឆ្លើយ។ ការពិចារណាត្រូវធ្វើឡើងតាម ករណីនីមួយៗជាក់ស្តែង។ អ្វីគួរឲ្យកត់សម្គាល់ គឺថា មិនដូចមាត្រា ២(៤) មាត្រា ៥១ មិនបាននិយាយអំពីបំណងនៃការវាយប្រហារ និង អំពីផលវិបាកនៃការវាយប្រហារឡើយ។ ទោះបីជាយ៉ាងនេះក្តី ការវាយប្រហារ គួរតែមានផលវិបាកធ្ងន់ធ្ងរ ដែលជំរុញឲ្យមាន Self-Defence។ តុលាការយុត្តិធម៌អន្តរជាតិ បានបញ្ជាក់ថា គ្រាន់តែការចល័តទ័ពក្នុងទ្រង់ទ្រាយតូច មិនមែនជាការវាយប្រហារដោយអាវុធទេ។[292] ក្នុងន័យនេះ តុលាការយុត្តិធម៌អន្តរជាតិប្រើ Large Scale and Effect Test ក្នុងការពិចារណា ថាតើមានការវាយប្រហារប្រដាប់អាវុធឬគ្មាន? ទោះបីជាយ៉ាងនេះក្តី ក្នុងរឿងក្តី Oil Plateform ការពិចារណា ថាមានការវាយប្រហារ ឬគ្មាន តុលាការបានអះអាងថា ការដាក់មីនបំផ្លាញកប៉ាល់អាមេរិក ដោយអ៊ីរ៉ង់ អាចស្ថិតក្នុងការវាយប្រហារក្នុងន័យមាត្រា ៥១។[293] ជាសង្ខេប ការពិចារណា គឺផ្អែកទៅលើស្ថានភាពជាក់ស្តែង។

មាត្រា ៥១មិនមានបញ្ជាក់ អំពីប្រភពនៃការវាយប្រហារទេ។ វាអាចធ្វើឡើងដោយក្រុមប្រដាប់អាវុធ ឬដោយរដ្ឋណាមួយ។ កត្តាសំខាន់ គឺការវាយប្រហារដោយអាវុធ(Armed Attack) កើតមានឡើង។ ទោះបីជាយ៉ាងនេះក្តី ស្ថានភាពដូចនេះ អាចនាំឲ្យរដ្ឋប្រើសិទ្ធិការពារខ្លួន អាចវាយប្រហារបង្កផលវិបាកធ្ងន់ជាងអ្វី ដែលខ្លួនទទួល ដែលនាំឲ្យខុសគោលការណ៍សមមាត្រ។

[292] ICJ, *Military Case*, *supra* note 114, pp. 437-8; Shaw, IL, *supra* note 1, p. 1134.
[293] Oil Plateform (*Iran v. USA*) ICJ Reports, 2003, pp. 161, 187; 130 ILR, pp. 323, 346; Shaw, IL, *supra* note 1, p. 1133.

ការវាយប្រហារដោយឥណ្ឌា លើទ័ពប៉ាគីស្ថាន ឲ្យដកចេញពីប្រទេសបង់ក្លាដេស រួចទ័ពឥណ្ឌាដកភ្លាម ជាការបំពេញតាមគោលការណ៍សមមាត្រ។ ការរកឃើញថាមានការខុសឆ្គងនឹងគោលការណ៍សមមាត្រ នឹងកើតមាននៅក្នុងអំឡុងពេលដេញដោលនៅក្នុងតុលាការ។ តាមទ្រឹស្តីនេះ រដ្ឋអាចប្រើអាវុធនុយក្លេអ៊ែរ ដើម្បីទប់ទល់នឹងការវាយប្រហារដោយប្រើអាវុធប្រភេទនេះ។ ទោះបីជាយ៉ាងនេះក្តី ការប្រើប្រាស់ អាចនាំឲ្យរំលោភច្បាប់មនុស្សធម៌អន្តរជាតិ ឬបរិស្ថាន ដែលត្រូវបានហាមឃាត់ដោយច្បាប់អន្តរជាតិ។[294]

វាស្រដៀងគ្នានឹងការពិចារណាលើគោលការណ៍ចាំបាច់ ដើម្បីវាយប្រហារដែរឬទេ? ជាចុងក្រោយ វាមិនមានភាពច្បាស់លាស់ ថាតើការប្រើកម្លាំងទប់ទល់ ត្រូវធ្វើភ្លាមយ៉ាងណា ដើម្បីចាត់ថាជាការការពារខ្លួន។ ច្បាប់ព្រហ្មទណ្ឌជាតិ តម្រូវឲ្យមានការវាយប្រហារតបភ្លាម ប្រសិនបើជា ការការពារខ្លួន ស្របច្បាប់។ តម្រូវការដូចនេះ ក្នុងន័យសន្តិសុខជាតិ ទាមទារការតបទប់ជាបន្ទាន់ វាជាការសមហេតុផល[295] តែអាចខុសពីវិធានពាក់ព័ន្ធការដោះស្រាយជម្លោះដោយសន្តិវិធី ដែលទាមទារឲ្យមានការចរចាមុននឹងការប្រើកម្លាំង។[296] ម៉្យាងទៀតការវាយប្រហារភ្លាមៗ ជាការអនុវត្តដោយគ្មានពិចារណា

[294] ICJ, Legality of the Threat, *supra* note 290, p. 98.

[295] If the self-defence was used to stop State from violating obligation, it might be countermeasure and can be done immediately, *see* Draft Articles, States, *supra* note 81, Art. 49. However, it is argued to rule out the self defence as a countermeasure.

[296] The UN Charter, *supra* note 42, Art. 33.

អាចក្លាយជាការវាយប្រហារខុសនឹងធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលនាំឲ្យរដ្ឋទទួលខុសត្រូវ។

### ៧.៤. សិទ្ធិការពារខ្លួនរួម (Collective Self-Defence)

ការប្រើប្រាស់សិទ្ធិការពារ អាចធ្វើឡើងដោយរដ្ឋរងគ្រោះផ្ទាល់ ឬដោយរដ្ឋ ឬក្រុមរដ្ឋផ្សេងទៀត ដែលស្នើសុំដោយរដ្ឋរងគ្រោះ ផ្អែកតាមសន្ធិសញ្ញា។ នេះគឺជា Collective Self-Defence។ តុលាការយុត្តិធម៌អន្តរជាតិ ក្នុងករណីការការពារប្រភេទនេះ ទាមទារឲ្យមានការសុំជួយពីរដ្ឋរងគ្រោះ។ ក្នុងរឿងក្តី *Nicaragua* ប្រឆាំងសហរដ្ឋអាមេរិក សហរដ្ឋអាមេរិក ធ្វើការវាយប្រហារលើ *Nicaragua* ដោយមិនមានការសុំឲ្យជួយពី Elsavador ដែលជារដ្ឋរងគ្រោះដោយការវាយប្រហារដោយកងកម្លាំង ពីដែនដី Nicaragua។[297]

មាត្រា ៥១ ទាមទារឲ្យមានការរាយការណ៍ដល់ក្រុមប្រឹក្សាសន្តិសុខ អំពីការប្រើប្រាស់ សិទ្ធិ ការពារខ្លួន។ ការពារទាមទារនេះ គ្រាន់តែជាតឹកតាងបង្ហាញថាមានការវាយប្រហារ ហើយដែលរដ្ឋត្រូវការពារខ្លួន។ នេះក៏ជាការជួយដល់ក្រុមប្រឹក្សាសន្តិសុខ ដែលមាន តួនាទីថែរក្សា និងការពារសន្តិសុខ ឲ្យបានដឹងងាយស្រួលការទប់ទល់នឹង ស្ថានការណ៍រីករ៉ វ តាមរយៈការចាត់វិធានការចាំបាច់។ ការខកខានមិនបានរាយការណ៍ មិនបណ្តាលឲ្យការប្រើប្រាស់

[297] ICJ, Armed Activities on the Territory of the Congo (*Democratic Republic of the Congo v. Uganda*), Dissenting Opinion of Judge *Ad Hoc* Kateka, ICJ Reports 2005, para. 16; ICJ, Military Case, *supra* note 114, para. 199; Martin Dixon & Robert McCorquodale, Cases and Materials on International Law, 1991, p. 574.

សិទ្ធិស្របច្បាប់ទៅជាការប្រើប្រាស់កម្លាំងខុសនឹងធម្មនុញ្ញអង្គការសហប្រជាជាតិឡើយ។

### ៧.៥. ការប្រើកម្លាំងទ័ព ក្រោមជំពូក ៧ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ

ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ជាស្ថាប័នចម្បង ដែលមានភារកិច្ចផ្តាច់មុខក្នុងការការពារ និងថែរក្សាសន្តិភាព និង សន្តិសុខពិភពលោក។[298] ខុសពីសម័យសង្គ្រាមត្រជាក់ បច្ចុប្បន្ននេះក្រុមប្រឹក្សា បានធ្វើការអន្តរាគមន៍[299]ក្នុងជម្លោះជាច្រើន សូម្បីជម្លោះប្រដាប់អាវុធរវាងរដ្ឋពីរ ប្រសិនបើសង្គ្រាមទាំងនោះ អាចនឹងប៉ះពាល់ដល់សន្តិសុខ និងសន្តិភាពតំបន់ ឬពិភពលោក។[300] ក្រុមប្រឹក្សាសន្តិសុខ ប្រកាន់យកការប្រើកម្លាំងជាជម្រើសចុងក្រោយ។ ក្រុមប្រឹក្សាអាច ប្រើកម្លាំងដោយខ្លួនឯង ឬអនុញ្ញាតឲ្យស្ថាប័នតំបន់ ធ្វើកិច្ចការងារជំនួសខ្លួន ដោយរក្សាអំណាចតាមដាន និងត្រួតពិនិត្យ និងក្នុងករណីខ្លះចូលអន្តរាគមន៍ ឡើងវិញដោយខ្លួនឯង។[301] ក្នុងករណីខ្លះ ក្រុមប្រឹក្សាសន្តិសុខ ចូលអន្តរាគមន៍តាមសំណើរបស់ស្ថាប័ន តំបន់ និងធ្វើការងារជាមួយស្ថាប័ននោះ។[302]

[298] UN Charter, *supra* note 42, Art. 24.

[299] UNSC Resolution on Combating Terrorist Act is law-making; thus, UNSC is legislator.

[300] UNSC, basing on Chapter VII, adopted resolution allowing an armed attack against Iraqui government which invaded Kuwait in 1990, *see* Shaw, IL, *supra* note 1, p. 1147.

[301] NATO is a military alliance, and does not fall within a regional arrangement mentioned in the UN Charter; the Charter of AU requires to inform the UNSC.

[302] There is also the case where regional body invited State to intervene.

## ៧.៦. អន្តរាគមន៍មនុស្សធម៌

ការអន្តរាគមនេះគឺក្នុងន័យមនុស្សធម៌ គឺប្រើប្រាស់ដើម្បីជួយការពារសិទ្ធិមនុស្ស ការពារប្រជាពលរដ្ឋប្រទេសមួយ ដែលទទួលរងគ្រោះដោយសារអំពើបំពានលើ សិទ្ធិសេរីភាពធ្ងន់ធ្ងរ និងបង្ក្រាបប្រជាជនឯងធ្ងន់ធ្ងរ។ ក្នុងសម័យបុរាណ ការអន្តរាគមប្រភេទនេះ ធ្វើឡើងដោយបំពារបំពាន ដោយប្រទេសមានអំណាច ដើម្បីការពារផលប្រយោជន៍ខ្លួន។ អាស្រ័យហេតុនេះ ការអន្តរាគមប្រភេទនេះ ត្រូវបានចាត់ទុក ជាការឈ្លានពានខុសច្បាប់អន្តរជាតិ។ បច្ចុប្បន្នការអន្តរាគមរបៀបនេះ អាចមិនមានបញ្ហាទេ បើធ្វើឡើងដោយអង្គការសហប្រជាជាតិ[303] ឬស្ថាប័នតំបន់ក្រោមកិច្ចឃ្លាំមើលដោយអង្គការសហប្រជាជាតិ។ ក្នុងករណីខាងក្រោយនេះ វាតម្រូវឲ្យមានសំណើស្នើសុំពីរដ្ឋ។ ទោះបីជាយ៉ាងនេះក្តី វាជាការពិបាកបំពេញតាមពីព្រោះរដ្ឋដែលស្នើសុំត្រូវជារដ្ឋស្របច្បាប់[304] ហើយក្នុងករណីខ្លះ រដ្ឋដែលទាមទារឲ្យមានការស្នើសុំ ជារដ្ឋបំពានច្បាប់អន្តរជាតិ។

ក្នុងករណី វៀតណាម ឈ្លានពាន ក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៧៩ អ្នកជំនាញមួយរូប បានអះអាងថា វាមិនខុសច្បាប់អន្តរជាតិទេ ពីព្រោះវាជា Self

[303] We might say that acting under chapter VII is humanitarian intervention.

[304] For relevance, the Kuwaiti government in exile appealed for assistance from other States, *see* Shaw, IL, *supra* note 1, p. 1147. Hungary and Czechoslovakia in 1956 and 1968 respectively invited Soviet Union to make intervention in their countries, *see* Antonio Tanca, Foreign Armed Intervention in Internal Conflicts, 1993, pp. 27, 42.

Defence និងជាការអន្តរាគមមនុស្សធម៌ ទោះបីជាយ៉ាងនេះក្តី សហគមន៍អន្តរជាតិយល់ផ្សេងពីនេះ។[305]

[305] Gary Klintworth, Vietnam’s Intervention in Cambodia in International Law, 1989, pp. 109-110.

# ជំពូក ៨
# ដំណោះស្រាយជម្លោះដោយសន្តិវិធី

## ៨.១. ជម្រើសនៃដំណោះស្រាយ

ប្រវត្តិសាស្ត្រនៃទំនាក់ទំនងអន្តរជាតិ បានបង្ហាញនូវសង្គ្រាមដ៏វិនាសកម្ម យ៉ាងតិចចំនួនពីរ នោះគឺសង្គ្រាមលោកលើកទី១ និងទី២ ដែលសាធារណជនទូទៅបានដឹងរួចមកហើយ។ ឆ្លងកាត់ព្រឹត្តិការណ៍នេះ ក្រោយបញ្ចប់សង្គ្រាមលោកលើកទី២ ឆ្នាំ ១៩៤៥ អង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើង។ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ បានដាក់ការថែរក្សាសន្តិភាពពិភពលោក ជាគោលបំណងដ៏ចម្បងមួយ។ ធម្មនុញ្ញដដែលបានហាមឃាត់ការប្រើកម្លាំងទ័ព សម្រាប់ដោះស្រាយជម្លោះអន្តរជាតិ លើកលែងការប្រើកម្លាំងនោះ ជាការអនុវត្តសិទ្ធិការពារខ្លួនរបស់រដ្ឋ។[306] មាត្រា ៣៣ នៃធម្មនុញ្ញបានចែង ពាក់ព័ន្ធជាមួយការដោះស្រាយជម្លោះ អន្តរជាតិ ។

តាមមាត្រានេះ វិធីសាស្ត្រនៃការដោះស្រាយជម្លោះ មានច្រើនបែបយ៉ាង ដែលមានការចូលរួមដោយភាគីក្នុងជម្លោះ ឬការចូលរួមដោយភាគីទី៣។ គេក៏អាចចាត់ថា ជាវិធីសាស្ត្រដោះស្រាយ ក្រៅតុលាការ និងតាមប្រព័ន្ធតុលាការ។ ទោះបីជាយ៉ាងនេះក្តី ជាទូទៅការដោះស្រាយជាដំបូង ត្រូវធ្វើឡើងតាមរយៈការចរចា ហើយក្នុងករណី ដែលភាគីនៃជម្លោះ មិនទទួលបានដំណោះស្រាយជាទីពេញចិត្តទេ វិធីសាស្ត្រដោះស្រាយផ្សេងទៀត នឹងត្រូវបានប្រកាន់យក។ ភាគី អាចជ្រើសរើសយកការផ្សះផ្សា ឬប្តឹងទៅតុលាការអន្តរជាតិតែម្តង។ វិធីសាស្ត្រ ដែលចែងនៅក្នុងមាត្រានៃធម្មនុញ្ញអង្គការ

[306] The UN Charter, *supra* note 42, Art. 51.

សហប្រជាជាតិ មិនមែនមានតែប៉ុណ្ណោះទេ។ នៅមានវិធីសាស្ត្រផ្សេងទៀតនៅក្នុងកម្រិតតំបន់ជាដើម។ ជម្រើសមួយណា គឺអាស្រ័យទៅតាមសេចក្តីសម្រេចរបស់រដ្ឋ ដែលខ្លួនមានអធិបតេយ្យភាព ឬទៅតាមសន្ធិសញ្ញាដែលពាក់ព័ន្ធបានតម្រូវ។ ឧទាហរណ៍ សន្ធិសញ្ញាខ្លះ ដែលរដ្ឋក្នុងជម្លោះ ជាភាគីទាមទារឲ្យដោះស្រាយជម្លោះត្រឹមតែការចរចា។ [307]

ផ្នែកដែលនិយាយអំពី ការដោះស្រាយជម្លោះអន្តរជាតិក្នុងសៀវភៅនេះ មិនមានចេតនា បង្ហាញជូនជាលម្អិតអំពី យន្តការនៃការដោះស្រាយជម្លោះនីមួយៗឡើយ។ ផ្នែកនេះ នឹងបង្ហាញជូននូវ តុលាការពីរប្រភេទ ដូចខាងក្រោម និងផ្តោតជាសំខាន់លើ តុលាការយុត្តិធម៌អន្តរជាតិ ដោយសារកម្ពុជាធ្លាប់បានធ្វើការប្តឹងផ្តល់ ហើយដោយយល់ឃើញថា តុលាការនេះ កាន់តែទទួលបានការចាប់អារម្មណ៍ពីសំណាក់រដ្ឋជាច្រើន។[308]

## ៨.២. តុលាការអាជ្ញាកណ្តាលអចិន្ត្រៃយ៍

សន្និសីទសន្តិភាពលើកទី១ ធ្វើនៅទីក្រុង Hague បានបង្កើតតុលាការនេះឡើងក្នុងឆ្នាំ ១៨៩៩ ផ្អែកតាមមាត្រា ២០ ដល់២៩នៃសន្ធិសញ្ញាឆ្នាំ ១៨៩៩ សម្រាប់ការដោះស្រាយដោយសន្តិវិធី នៃជម្លោះអន្តរជាតិ។ សន្និសីទលើកទី ២ បានកែសម្រួលសន្ធិសញ្ញាឆ្នាំ ១៨៩៩ ដោយសន្ធិសញ្ញាឆ្នាំ ១៩០៧។ តុលាការ គឺជាយន្តការដ៏ចាស់ជាងគេសម្រាប់ដោះស្រាយជម្លោះប្រភេទនេះ។

[307] 2005 Supplementary Treaty to 1985 Border Delimination Treaty between Cambodia and Viet Nam, Art. 5.
[308] Shaw, IL, *supra* note 1, p. 1114.

មកដល់ ខែ កុម្ភៈឆ្នាំ ២០១២ មានរដ្ឋចូលជាភាគី នៃសន្ធិសញ្ញាបង្កើតតុលាការនេះចំនួន ១១៥។ តុលាការនេះ មានទីតាំងនៅក្នុងទីក្រុង Hague នៃប្រទេសហូឡង់ដ៍។ តុលាការនេះ ខុសពី តុលាការយុត្តិធម៌អន្តរជាតិ ដោយបើចំហរដល់ភាគីដទៃ ហើយពិនិត្យមើលជម្លោះរវាងរដ្ឋ និងក្រុមហ៊ុនឯកជនទៀតផង។

តុលាការ មានស្ថាប័នរដ្ឋបាល មានមធ្យោបាយជួយចុះបញ្ជីសម្រាប់ការផ្សះផ្សាជាដើម។ ក្នុងដើមទសវត្សរ៍ទី ១៩៨០ តុលាការបានជួយបង្កើតសេវាកម្មរដ្ឋបាលនៃតុលាការដោះស្រាយជម្លោះរវាង Iran និង សហរដ្ឋអាមេរិក ( Iran-United States Claims Tribunal )។

ចន្លោះឆ្នាំ ១៩៤៦ និង ១៩៩០ គេមិនសូវស្គាល់តុលាការនេះទេ ដោយសារតុលាការនេះ ធ្វើកិច្ចការងារ ដោះស្រាយជម្លោះជាសម្ងាត់។ សូម្បីសេចក្តីសម្រេច ក៏មានលក្ខណៈសម្ងាត់ទៅតាមការស្នើសុំរបស់ភាគី។

ចាប់ពីពេលនោះ មកក្តីក្តាំនៅពីមុខតុលាការនេះ កាន់តែមានកំណើនជាលំដាប់។ តុលាការនេះដោះស្រាយវិវាទអន្តរជាតិ ពាក់ព័ន្ធព្រំដែនសមុទ្រ វិនិយោគអន្តរជាតិជាដើម និងប្រើប្រាស់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលអនុវត្តចំពោះ ភាគីនៃជម្លោះ ក្នុងការសម្រេចសេចក្តី។[309]

[309] Cambodia ratified the 1899 and 1907 Convention on January 4, 1956, see en.wikipedia.org/wiki/Permanent_Court_of_Arbitration (Accessed on 27 July 2012).

## ៨.៣. តុលាការយុត្តិធម៌អន្តរជាតិ

### ៨.៣.១. ប្រវត្តិនៃការបង្កើត ទីតាំង និងសមាសភាព

តុលាការយុត្តិធម៌អន្តរជាតិ ត្រូវបានបង្កើតឡើងក្រោយសង្គ្រាមលោកលើកទី ២ ក្រោយពី លក្ខន្តិកៈរបស់ខ្លួនត្រូវបានអនុម័ត។[310] តុលាការនេះបន្តវេនពី តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ (Permanent Court of International Justice) ដែលត្រូវបាន បង្កើតឡើង នៅក្រោយសង្គ្រាមលោកលើកទី ១។[311] តុលាការ ជាស្ថាប័នចម្បងមួយរបស់អង្គការសហប្រជាជាតិ។[312]

តុលាការមានទីតាំង នៅក្នុងវិមានសន្តិភាព ក្នុងទីក្រុងឡាអេ នៃប្រទេសហូឡង់ដ៍។ តុលាការ មានសមាសភាព ១៥ ចៅក្រម ដែលត្រូវបានជ្រើសរើសចេញក្នុងចំណោមអ្នកការទូត ឬសាស្ត្រាចារ្យ ដែលមានបទពិសោធច្បាប់អន្តរជាតិ និងមានកិត្តិនាមល្បីល្បាញ លើឆាកអន្តរជាតិ។[313] ចៅក្រមទាំងនោះ ត្រូវបានជ្រើសរើសចេញពីរដ្ឋ ជាភាគីរបស់អង្គការសហប្រជាជាតិ និងបោះឆ្នោតតែងតាំង ដោយសំឡេងភាគច្រើនដាច់ខាតរបស់មហាសន្និបាតរបស់អង្គការសហប្រជាជាតិ និង ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ។[314] ទោះបីជាយ៉ាងនេះក្តី ចៅក្រម ត្រូវតែសម្រេចក្តីដោយឯករាជ្យ។[315]

---

[310] 26 June 1945, *see* Helmut, A Concise of the UN, *supra* note 8, p. 375.

[311] Helmut, the Concise of the UN, *supra* note 8, p. 375.

[312] The UN Charter, *supra* note 42, Art. 92; the Statute of the ICJ, *supra* note 58, Art.1.

[313] Helmut, the Concise of the UN, *supra* note 8, p. 376; the Statute of ICJ, *supra* note 58, Arts. 2, 3 and 15.

[314] Helmut, the Concise of the UN, *supra* note 8, p. 376.

[315] Helmut, the Concise of the UN, *supra* note 8, p. 378.

តាំងពីបង្កើតមក ចៅក្រមដែលមានសញ្ជាតិ របស់ប្រទេសជាសមាជិកអចិន្ត្រៃយ៍ទាំងប្រាំ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ តែងតែត្រូវបានជ្រើសរើស។ បច្ចុប្បន្ននេះ មានចៅក្រមជាច្រើនរូប មកពីបណ្តាទ្វីបផ្សេងៗ នៃពិភពលោក ដូចជា អាហ្វ្រិក អាស៊ី ត្រូវបានជ្រើសតាំង។ នេះបង្ហាញឲ្យឃើញនូវ ការកែសម្រួលរចនាសម្ព័ន្ធ ឲ្យបានកាន់តែប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹង ការរិះគន់ ដែលអះអាងថា តុលាការនេះ នឹងមិនផ្តល់យុត្តិធម៌ដល់ប្រទេស នៅអាស៊ីទេ ដោយសារ សមាសភាពចៅក្រមភាគច្រើនជ្រើសរើសចេញពីទ្វីបអឺរ៉ុប។[316] នេះក៏បង្ហាញពី លក្ខណៈប្រជាធិបតេយ្យ ដែលអង្គការសហប្រជាជាតិខិតខំជំរុញ។ តុលាការយុត្តិធម៌អន្តរជាតិជាស្ថាប័នមួយចម្បង របស់អង្គការកំពូលនេះ ត្រូវតែប្រកាន់យករបៀបចាត់ចែងការងារមានលក្ខណៈប្រជាធិបតេយ្យ។ និន្នាការនេះ ផ្តល់ឱកាសដល់អ្នកស្រាវជ្រាវ ក្នុងទ្វីបអាស៊ី មានឱកាសក្នុងការក្លាយទៅជាចៅក្រមនៃតុលាការនេះ។ ទោះបីជាយ៉ាងនេះក្តី អ្នកដែលមានបំណង ជាសំខាន់ត្រូវមានមូលដ្ឋាន ឬចំណេះដឹងច្បាប់អន្តរជាតិ ជ្រៅជ្រះ ទទួលស្គាល់លើឆាកអន្តរជាតិ។

### ៨.៣.២. សមត្ថកិច្ច

### ៨.៣.២.១. បណ្តឹង

តុលាការមានសមត្ថកិច្ចពីរ៖ ការពិនិត្យមើលបណ្តឹង និង ផ្តល់ប្រឹក្សាយោបល់។ បណ្តឹងធ្វើឡើងដោយរដ្ឋ ប្រឆាំងនឹងរដ្ឋ ដែលរដ្ឋទាំងពីរត្រូវទទួលស្គាល់សមត្ថកិច្ចរបស់តុលាការក្នុងការទទួល និងពិនិត្យពាក្យបណ្តឹង។[317] រដ្ឋជា

---

[316] Helmut, the Concise of the UN, *supra* note 8, p. 385.

[317] The Statute of the ICJ, *supra* note 58, Art. 36.

អតីត សមាជិករបស់តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ បង្កើតឡើង ក្រោយសង្គ្រាមលោកលើកទី១ ត្រូវបានចាត់ថាទទួលស្គាល់សមត្ថកិច្ចរបស់ តុលាការយុត្តិធម៌អន្តរជាតិ ប្រសិនបើមិនប្រកាសមិនទទួលស្គាល់។[318] ក្នុង រឿងក្តីប្រាសាទព្រះវិហារ តុលាការយុត្តិធម៌អន្តរជាតិបាន អះអាងថា ប្រទេស ថៃទទួលស្គាល់សមត្ថកិច្ចរបស់តុលាការយុត្តិធម៌អន្តរជាតិ ពីព្រោះរដ្ឋនេះ មិន បានប្រកាសមិនទទួលស្គាល់ខណៈពេលដែលតុលាការអចិន្ត្រៃយ៍ ប្តូរមកជា តុលាការយុត្តិធម៌អន្តរជាតិទេ។[319]

រដ្ឋ នាពេលប្រកាសទទួលស្គាល់ អាចប្រកាសដាក់លក្ខខណ្ឌកម្រិត សមត្ថ កិច្ចរបស់តុលាការនេះ។ ឧទាហរណ៍ រដ្ឋប្រកាសឲ្យតែតុលាការពិនិត្យ មើល តែជម្លោះពាក់ព័ន្ធ កិច្ចព្រមព្រៀងទ្វេភាគី[320] ឬមិនដោះស្រាយជម្លោះ ស្ថិត ក្នុងយុត្តាធិការក្នុងស្រុក។[321] រដ្ឋខ្លះ ប្រកាសអនុញ្ញាតឲ្យតុលាការនេះ ពិចារ ណា ជម្លោះពាក់ព័ន្ធបញ្ហាណាមួយ ដែលរដ្ឋដទៃប្រកាសធ្វើដូចគ្នាដែរ។[322] ក្នុងករណីខ្លះ រដ្ឋទាំងពីរនៃ ជម្លោះមិនបានប្រកាសទទួលស្គាល់សមត្ថកិច្ច របស់តុលាការជាមុន តែក្រោយមកបានឯកភាព ធ្វើកិច្ចព្រមព្រៀង ជាលាយ លក្ខណ៍អក្សរ ឲ្យតុលាការពិចារណាជម្លោះរបស់ពួកខ្លួន។[323]

---

[318] *Id.*, Art. 35(5).

[319] Helmut, the Concise of the UN, *supra* note 8, p. 378.

[320] The Declaration of the USA signed by Harry S. Truman in 1946, printed in Martin Dixon, Materials on IL, *supra* note 297, p. 614.

[321] The US Declaration of 14 August 1946, 61 Stat. 1218 (1947), reprinted in US Department of State Bulletin, Vol. 15, 1 September 1946, 542-453.

[322] Helmut, the Concise of the UN, *supra* note 8, p. 379.

[323] The Statute of the ICJ, *supra* note 58, Arts. 36(2) and 40.

បណ្តឹងអាចពាក់ព័ន្ធជាមួយនឹង ការបំពារបំពានកាតព្វកិច្ចដោយរដ្ឋណាមួយ មានចំពោះរដ្ឋមួយទៀត។ តុលាការនឹងសម្រេចសេចក្តី រួចចេញជាសាលក្រម ចងជាភាគីដល់រដ្ឋក្នុងជម្លោះ ហើយដែលរដ្ឋត្រូវតែគោរព។[324]

## ៨.៣.២.២. វិធានការបណ្តោះអាសន្ន

នៅក្នុងដំណើរការក្តីនៅមុខតុលាការយុត្តិធម៌អន្តរជាតិ វិធានការបណ្តោះអាសន្ន ត្រូវបានស្នើដោយរដ្ឋណាមួយនៃបណ្តឹង ក្នុងអំឡុងពេលដំណើរការក្តីក្តាំ និងពិនិត្យ សម្រេចដោយតុលាការ។[325] វាជាវិធានការ ជារួម រារាំង និងទប់ស្កាត់នូវព្រឹត្តិការណ៍ ដែលនាំឲ្យប៉ះពាល់ដល់ កម្មវត្ថុនៃបណ្តឹងរង់ចាំសេចក្តីសម្រេចរបស់តុលាការ។ វិធានការនេះ ស្រដៀងគ្នានឹង បញ្ជាឬដីការបស់តុលាការជាតិ ដែលផ្អាកសកម្មភាព ឬរារាំងសកម្មភាពណាមួយ ដែលប៉ះពាល់ដល់ផ្ទះ(កម្មវត្ថុនៃបណ្តឹង) តាមសំណើរបស់ ភាគីណាមួយ ប្តឹងទាមទារផ្ទះ។[326]

មានបញ្ហាច្បាប់ស្មុគស្មាញជាច្រើន ពាក់ព័ន្ធជាមួយសំណើសុំវិធានការបណ្តោះអាសន្ន។ ទី១. តើតុលាការមានសមត្ថកិច្ចក្នុងការពិនិត្យមើលបណ្តឹងឬទេ? ទី២. តើពាក្យសុំ មានលក្ខណវិនិច្ឆ័យ ដែលទាមទារ ដើម្បីឲ្យពាក្យសុំអាចទទួលយកបានដោយតុលាការឬទេ? តាមវិធាន ៧៣ នៃវិធាននីតិវិធីរបស់តុលាការ ពាក្យសុំត្រូវមានហេតុផលនៃពាក្យសុំ វិធានការដែលចង់ឲ្យតុលាការសម្រេចឬប្រកាស និងផលវិបាក ប្រសិនបើវិធានការទាំ

[324] Helmut,the Concise of the UN, *supra* note 8, p. 383.

[325] The ICJ, Rules, *supra* note 209, Rule 73.

[326] Injunction order is a court one commanding or preventing an action, *see* Bryan, the Black, *supra* note 124 , p. 788.

ងនោះមិនត្រូវបានផ្តល់ដោយតុលាការ។ ក្នុងពាក្យសុំរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទិនជាមួយបណ្តឹងសុំបកស្រាយសាលក្រម ឆ្នាំ ១៩៦២ ចេញដោយតុលាការ កម្ពុជាបានស្នើ ឲ្យប្រទេសថៃដកទ័ពជាបន្ទាន់ និងឥតលក្ខខណ្ឌពីដីកម្ពុជា ក្នុងតំបន់ប្រាសាទព្រះវិហារ រារាំងសកម្មភាពរបស់ទ័ពថៃ និង ហាមឃាត់សកម្មភាព ដែលអាចនឹងប៉ះពាល់សិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជា។ ហេតុផលនៃការសុំវិធានការ គឺដើម្បីរារាំងកុំឲ្យជម្លោះកាន់តែតានតឹង។[327]

ពាក្យស្នើសុំវិធានការបណ្តោះអាសន្ន ជាផ្នែកមួយក្នុងដំណើរការនីតិវិធីសម្រាប់រឿងក្តី ។ អាស្រ័យហេតុនេះ ដោយផ្អែកតាមគោលការណ៍ច្បាប់អន្តរជាតិ (គោលការណ៍ព្រមព្រៀងដោយរដ្ឋ) តុលាការត្រូវពិនិត្យមើលជាមុនថា ខ្លួនមានយុត្តាធិការក្នុងការពិនិត្យ មើលបណ្តឹងដែរឬទេ។ ខុសពីបណ្តឹងថ្មី ដែលទាមទារឲ្យរដ្ឋទាំងពីរជាភាគី ត្រូវទទួលស្គាល់យុត្តាធិការរបស់តុលាការក្នុងការពិនិត្យមើលបណ្តឹង បណ្តឹងសុំឲ្យមានការបកស្រាយមិនទាមទារឲ្យរដ្ឋទទួលស្គាល់យុត្តាធិការឡើយ។[328] អ្វីជាសំខាន់ ក្នុងរឿងក្តីនេះ ថាតើវាជាជម្លោះពាក់ព័ន្ធជាមួយនឹងខ្លឹមសារ ឬវិសាលភាពនៃសាលក្រមដែរឬទេ[329] ជាបន្ថែម ទោះបីមិនមានការទាមទារក្តី តុលាការនឹងពិនិត្យមើលថាតើជម្លោះពាក់ព័ន្ធជាមួយផ្នែកនៃសេចក្តីសម្រេច (Operative Clause) ឬ

[327] Cambodia files an Application requesting interpretation of the Judgement rendered by the Court on 15 June 1962 in the case concerning the Temple of Preah Vihear (Cambodia v. Thailand) and also asks for the urgent indication of provisional measures, No. 2011/14, dated on 2 May 2011, p.3.

[328] The Request for interpretation of the judgment of the 15 June 1962 in the case concerning the Temple of Preah Vihear (Cambodia v. Thailand), ICJ Order dated on 18 July 2011, para. 21.

[329] The Statute of the ICJ, *supra* note 58, Art. 60.

ក្នុងផ្នែកទាញហេតុផល ក្នុងសាលក្រម ឲ្យតែពាក់ព័ន្ធជាមួយផ្នែកនៃសេចក្តីសម្រេច។[330] តុលាការនឹងពិនិត្យមើលភាពសមស្រប នៃសិទ្ធិដែលត្រូវសុំការពារ។ មានន័យថា សិទ្ធិជារបស់ភាគីស្នើសុំឬទេ។ តុលាការ ក៏នឹងពិនិត្យមើលទំនាក់ទំនងរវាងវិធានការទាមទារ និងការការពារសិទ្ធិ និង លក្ខណៈបន្ទាន់បង្ខំនៃវិធានការបណ្តោះអាសន្ន ព្រមទាំងស្ថានភាព ដែលអាចនាំទៅរកផលវិបាកដែលមិនអាចស្តារឡើងវិញបាន។

តុលាការ បានពិចារណាឃើញថា មានភាពជាក់លាក់ (*Prima Facie*) នៃការកើតមាននៃជម្លោះ ក្នុងន័យមាត្រា ៦០ របស់លក្ខន្តិកៈរបស់តុលាការ។[331] នោះគឺ ភាពមិនច្បាស់លាស់ នៃពាក្យជុំវិញប្រាសាទ "Vicinity"។ កម្ពុជាយល់ថា តុលាការ ក្នុងឆ្នាំ ១៩៦២ ទទួលស្គាល់ ផែនទី ឆ្នាំ ១៩០៤ និង១៩០៧ ដែលតាមរយៈផែនទី ទទួលស្គាល់ខ្សែព្រំដែន ដាក់ប្រាសាទព្រះវិហារ និងតំបន់ជុំវិញក្នុងអធិបតេយ្យ ដែនដីរបស់កម្ពុជា។[332] ផ្ទុយទៅវិញ ថៃអះអាងថា ព្រំដែននៃតំបន់ប្រាសាទព្រះវិហារនៅមិនទាន់កំណត់។[333] បន្ថែមពីលើនេះ កម្ពុជាបានអះអាងថា កាតព្វកិច្ចតម្រូវចំពោះថៃ ដោយសាលក្រមឆ្នាំ ១៩៦២ ឲ្យដកទ័ពចេញ បន្តមានរហូតមកដល់ពេលនេះ។ ថៃបានឆ្លើយតបថា វាជាកាតព្វកិច្ចបញ្ចប់ភ្លាមៗ ហើយថៃបានបំពេញរួចរាល់ហើយ។[334] ពាក់ពន្ធ័ជាមួយនឹងវិធានការបណ្តោះអាសន្ន តុលាការបានពិចារណាឃើញថា មានហានិភ័យពិតប្រាកដមែន និងតម្រូវជាបន្ទាន់ឲ្យតុលាការ

[330] The Request for interpretation, ICJ Order, *supra* note 328,para. 23.
[331] *Id.*, para. 21.
[332] *Id.*, para. 26.
[333] *Id.*, paras. 27 and 30.
[334] *Id.*, paras. 29 and 31.

ចេញនូវវិធានការបណ្តោះអាសន្ន[335] រួមជាមួយនឹងភាពសមស្របនៃសិទ្ធិទាមទារការការពារស្នើដោយកម្ពុជា និងភាពឆ្លើយតបរបស់វិធានការការពារចំពោះការការពារសិទ្ធិ។[336] ដោយផ្អែកលើយុត្តិសាស្ត្ររបស់ខ្លួន ពាក់ព័ន្ធនឹងវិសាលភាពនៃវិធានការ ដែលមិនចាំបាច់ដូចគ្នាទាំងស្រុង ទៅនឹងអ្វីដែលភាគីបានស្នើឡើង[337] តុលាការបានដាក់ចេញ នូវវិធានការបណ្តោះអាសន្នចំនួនបួនចំណុច ក្នុងនោះទាមទារឲ្យភាគី ទាំងពីរដកទ័ពចេញពីតំបន់ជម្លោះ រួមទាំងតំបន់ប្រាសាទព្រះវិហារ ដើម្បីទុកតំបន់ក្លាយជាតំបន់គ្មានកងទ័ព ។[338]តំបន់គ្មានកងទ័ពនេះមានវិសាលភាពធំធេង។[339]

វិធានការបណ្តោះអាសន្ននេះ មានលក្ខណៈប្លឹងប្លែង ស្រដៀងគ្នានឹងខ្លឹមសារនៃវិធានការបណ្តោះអាសន្នមុនៗដែរ។[340] កងទ័ពកម្ពុជា ត្រូវបានទាមទារឲ្យដកចេញពីដែនដី ស្របច្បាប់របស់ខ្លួន ដោយឆន្ទានុសិទ្ធិតុលាការ ទោះបីថៃពុំបានស្នើសុំយ៉ាងដូចនេះក្តី។ អ្នករិះគន់ បានសម្តែងការមិនពេញចិត្តចំពោះការបញ្ជានេះ។ ទោះបីជាយ៉ាងនេះក្តី ការតម្រូវឲ្យកម្ពុជាដកទ័ពចេញនេះមិនមានន័យថា តុលាការចាត់ថា ក្នុងដំណាក់កាលនេះ ទីតាំងណាមួយនោះ

---

[335] *Id.*, para. 47.

[336] *Id.,* para. 45; *see* also Declaration of Judge ad hoc Guillaume.

[337] *Id.*, para. 60; *see* also *Certain activities carried out by Nicaragua in the Border Area ( Costa Rica v. Nicaragua), Provisional Measures, Order of 8 March 2011*, para. 76.

[338] The Request for interpretation, ICJ Order, *supra* note 328, para. 69.

[339] *Id.,* see map, p. 17.

[340] The ICJ, Case Concerning Application of the International Convention on the Elimination of All Forms of Racial Discrimination (Georgia v. Russian Federation), Request for the Indication of Provisional Measures, Order of 15 October 2008, para. 149.

មិនមែនជា ដែនដីរបស់កម្ពុជាឡើយ។[341] តុលាការ ទាមទារឲ្យភាគីទាំងពីរ ដកចេញពីទីតាំង ដើម្បីបង្កើតជាតំបន់គ្មានទ័ព ចូលជ្រៅទៅក្នុងដែនដីនៃភាគីទាំងពីរ។ មានយោបល់ជំទាស់របស់ចៅក្រមមួយចំនួន ចំពោះវិធានការការពារសម្រាប់ដែនដី ដែលមិនបាននិយាយក្នុងសាលក្រមឆ្នាំ១៩៦២ ។[342] ការជំទាស់ នេះវាសមស្រប ពីព្រោះតំបន់ជម្លោះផ្សេងឆ្ងាយពីប្រាសាទព្រះវិហារ គួរជាប្រធានបទនៃបណ្តឹងថ្មី។[343] តុលាការប្រើវិធានការទូលាយនេះ គឺសម្រាប់ករណីព្រំដែនមានជម្លោះប្រដាប់អាវុធ ដែលទាមទារឲ្យមានសន្តិភាព។ ការអះអាងនេះ ទាញចេញអំពីការយោងដោយតុលាការក្នុងដីកាដល់វិធានហាមឃាត់ ការប្រើប្រាស់កម្លាំងប្រដាប់អាវុធ ចែងក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។[344]

វិធានការបណ្តោះអាសន្ន មិនត្រូវបានចែងថាចងជាកាតព្វកិច្ចឡើយ។ ក៏ប៉ុន្តែឆ្លើយតបទៅកាន់ការអះអាងរបស់សហរដ្ឋអាមេរិក ក្នុងរឿងក្តីប្តឹងប្រឆាំងដោយ ប្រទេសអាឡឺម៉ង់ តុលាការបានអះអាងថា មាត្រាដែលពាក់ព័ន្ធមិនបាននិយាយអំពីចរិតនៃវិធានការឡើយ។ តុលាការ បានផ្អែកតាមគោលបំណងរបស់លក្ខន្តិកៈរបស់ខ្លួន ហើយអះអាងថា វិធានការបង្កើតជាកាតព្វកិច្ច ព្រមទាំងអះអាងថា ឯកសារនៃសេចក្តីព្រាងលក្ខន្តិកៈ មិនបាននិយាយផ្ទុយពីគំហើញនេះឡើយ។[345] គណៈកម្មាធិការសិទ្ធិមនុស្ស ក៏បានពិចារណា

[341] The Request for interpretation, ICJ Order, *supra* note 328, para. 21, *see* also Declaration of Judge ad hoc Guillaume.
[342] *Id.,* para. 21, *see* Dissenting opinion of Judge Donoghue.
[343] *Id.,* Dissenting opinion of Judge *ad hoc* Cot.
[344] *Id.*, para. 66.
[345] LAGRANT Case, *supra* note 180, pp. 195-196, at www.icj-cij.org; Helmut, the Concise of the UN, *supra* note 8, p. 382.

ថា វិធានការបណ្តោះអាសន្ន ចងជាកាតព្វកិច្ចផងដែរ។[346] បញ្ហាសំខាន់ថាតើភាគីនឹងអនុវត្ត តាមវិធានការឬយ៉ាងណា? ក្នុងករណី ភាគីមិនអនុវត្ត តើមានវិធានការបង្ខំអ្វី ដើម្បីឲ្យរដ្ឋអនុវត្តតាម?

### ៨.៣.២.៣. ដំណើរការ និង បណ្តឹងតប

នៅពេលតុលាការទទួលបានបណ្តឹងពីរដ្ឋណាមួយ ជាបឋមតុលាការ ត្រូវពិនិត្យមើលថា តើខ្លួនអាចទទួលយកបណ្តឹងនេះបានឬទេ? តុលាការត្រូវពិនិត្យមើលថារដ្ឋចុងចម្លើយ ទទួលស្គាល់សមត្ថកិច្ចរបស់តុលាការឬទេ? ក្នុងករណី បណ្តឹងអាចទទួលយកបាន តុលាការ នឹងពិនិត្យដល់អង្គសេចក្តីដែលនេះជាដំណាក់កាលពិនិត្យថា មានការរំលោភកាតព្វកិច្ចច្បាប់អន្តរជាតិដូចដែលបានចោទប្រកាន់ឡើងឬទេ (Merit Stage)។

តុលាការនឹងជូនដំណឹងអំពី បណ្តឹងដល់រដ្ឋចុងចម្លើយ ដើម្បីរដ្ឋនេះ អាចធ្វើការជំទាស់ជាបឋមទៅលើការទទួលយកពាក្យបណ្តឹង (Preliminary Objection)។[347] រដ្ឋអាចធ្វើការឆ្លើយតបចំពោះបញ្ហានេះ ស្របជាមួយគ្នានឹងការដាក់បណ្តឹង ឬអំណះអំណាងតប។ ការឆ្លើយតប ត្រូវធ្វើឡើងក្នុងអំឡុងពេលវេលាកំណត់ដោយតុលាការ។ រដ្ឋដើមបណ្តឹង មានសិទ្ធិផងដែរ ក្នុងការឆ្លើយតប ទៅនឹងគ្រប់ចំណុចលើកឡើងដោយរដ្ឋចុងចម្លើយ ក្នុងអំឡុងពេលវេលាកំណត់ដោយតុលាការ។

កិច្ចការងារជំទាស់ រួមផ្សំជាមួយការឆ្លើយតប ទាមទារនូវការសិក្សាស្រាវជ្រាវទ្រឹស្តីច្បាប់ សាលក្រមមុនៗរបស់តុលាការ ដែលតម្រូវឲ្យមានការជួយពីអ្នក

[346] The General Comment No. 33, *supra* note 200, para. 19.
[347] Helmut, the Concise of the UN, *supra* note 8, p. 381.

ស្រាវជ្រាវ មេធាវី តំណាងរបស់រដ្ឋ។ភាគីទាំងសងខាង មានសិទ្ធិដូចគ្នា ក្នុងការជួលរកមេធាវី ឬស្នើឲ្យមានអ្នកជំនាញការ។ រដ្ឋ អាចចូលរួមក្នុងដំណើរការ ឬមិនចូលរួមឆ្លើយ។ ការមិនចូលរួម ឬសហការ អាចនាំផលអវិជ្ជមានដល់រដ្ឋ ពីព្រោះរដ្ឋមិនមានឱកាសក្នុងការការពារប្រយោជន៍ ដែលអាចបំពារបំពានដោយរដ្ឋជាភាគីម្ខាងទៀត។ ក្នុងរឿងក្តី *Nicaragua* ប្រឆាំងនឹងសហរដ្ឋអាមេរិក តុលាការបានឆ្លើយតប ចំពោះការមិនសហការរបស់សហរដ្ឋអាមេរិកថា មានការសោកស្តាយ ដោយសារការសម្រេចរបស់ខ្លួនមានផលអវិជ្ជមានដល់ដំណើរការនៃរដ្ឋបាលតុលាការ។[348]

ការកំណត់ពេលវេលា ឆ្លើយតប ឬជំទាស់ គឺដើម្បីកាត់បន្ថយនូវពេលវេលាប្រើក្នុងនីតិវិធី ដែលមានការចោទប្រកាន់ថា បានចំណាយពេលវេលាដ៏យូរ[349] ហើយក៏នឹងទុកពេលវេលាស្មើគ្នា ដល់ភាគីក្នុងការឆ្លើយតបដោយសមភាព។ ដោយសារមិនបានសិក្សា និងយល់ដឹងស៊ីជម្រៅអំពីនីតិវិធី ខ្វះធនធានមនុស្សមានសមត្ថភាពខាងច្បាប់អន្តរជាតិ ដែលអាចជួយធ្វើសារណាឆ្លើយតបឲ្យបានល្អ ឬដោយសារកត្តាផ្សេងៗទៀត ដែលនាំឲ្យមានការយឺតយ៉ាវក្នុងការដាក់អំណះអំណាងឆ្លើយតប រដ្ឋមួយអាចនឹងបាត់បង់ឱកាសក្នុងការការពារផលប្រយោជន៍របស់ខ្លួនក្នុងរឿងក្តី។ តុលាការ ទោះបីមិនបានស្តែងជាក់លាក់ក្តី អាចនឹងផ្តល់ការលម្អៀងដល់ភាគីម្ខាង ក្នុងករណីនេះ។ នេះ តម្រូវឲ្យរដ្ឋពិចារណាឲ្យជាក់លាក់ ជាពិសេសមុនសម្រេចប្តឹងទៅតុលាការនេះ។

---

[348] The Statute of the ICJ, *supra* note 58, Art. 53; ICJ, Military Case, *supra* note 114, para. 27.

[349] The Statute of the ICJ, *supra* note 58, Arts. 43 and 52.

ដូចដែលបានរៀបរាប់ក្នុងជំពូកមុនរួចមកហើយ ដោយផ្អែកតាមគោលការណ៍ស្ម័គ្រចិត្ត រដ្ឋប្តឹងអាចដកបណ្តឹងជាឯកតោភាគី ឬ ដោយមានការព្រមព្រៀងពីភាគីទាំងពីរ។ តុលាការនឹង សម្រេចដករឿងក្តីចេញពីបញ្ជីរឿងរបស់ខ្លួន។[350] មិនមានយន្តការណាមួយ ដែលអាចបង្ខំឲ្យរដ្ឋ ដែលដកពាក្យបណ្តឹងចេញពីតុលាការ ចេញលុយសងតុលាការ ចំពោះការចំណាយលើការងារ និងដំណើរការនៃបណ្តឹង ដែលត្រូវបានដក។

រដ្ឋជាភាគីទី៣ ដែលគិតថាផលប្រយោជន៍របស់ខ្លួន នឹងត្រូវបានប៉ះពាល់ មានសិទ្ធិចូលរួមជា ភាគីអន្តរាគមន៍ក្នុងបណ្តឹងរវាងរដ្ឋ និងរដ្ឋផងដែរ។ រដ្ឋនោះ ត្រូវដាក់លិខិតជាផ្លូវការ សុំចូលអន្តរាគមន៍ ក្នុងរយៈពេលកំណត់មួយដោយតុលាការ។ ទោះបីជាយ៉ាងនេះក្តី វាអាស្រ័យទៅតាមរដ្ឋ ថាតើខ្លួនចង់ចូលអន្តរាគមន៍ ឬមិនចូលរួម។ ការខកខានមិនបានចូលរួម អាចនឹងនាំឲ្យតុលាការ មិនសម្រេចបណ្តឹងទាំងស្រុង។ ក្នុងរឿងក្តី East Timore Portugal បានប្តឹងប្រឆាំងនឹង Australia ពាក់ព័ន្ធជាមួយការមិនបានចូលរួមរបស់ ឥណ្ឌូណេស៊ី តុលាការថ្លែងថា៖ *ក្នុងករណីនេះ ផលវិបាកនៃសាលក្រមស្នើចេញដោយ Portugal នឹងនាំឲ្យមានការកំណត់វត្តមានឥណ្ឌូនេស៊ី ក្នុងទីម័រខាងកើត ..ហើយ ICJ មិនមានសមត្ថកិច្ចពិនិត្យមើលបញ្ហាជនជានខ្ពង់រាបបាតសមុទ្ររបស់ទីម័រខាងកើត។ សិទ្ធិ និងកាតព្វកិច្ច*

[350] ICJ: Questions and Answers about the Principal Judicial Organ of the UN, 2000, pp. 56-57.

*របស់ឥណ្ឌូនេស៊ី ជាបញ្ហាសំខាន់នៃសាលក្រម ដែលធ្វើដោយគ្មានការយល់ព្រមរបស់រដ្ឋនេះ។*[351]

**៨.៣.២.៤. ទធីនៃការដាក់ភស្តុតាង**

វាជាការធម្មតាទេ រដ្ឋជាភាគីដែលប្តឹងរដ្ឋណាមួយ មានបន្ទុកក្នុងការដាក់ភស្តុតាង ហើយភាគីដែលតបឆ្លើយត្រូវ ដាក់ភស្តុតាងផងដែរ គាំទ្រការដោះបន្ទុក និងដាក់របស់ខ្លួន។ ក្នុងសំណុំរឿងក្តីប្រាសាទព្រះវិហារ តុលាការបានអះអាងថា ៖*បន្ទុកនៃភស្តុតាងទាក់ទង ត្រូវស្ថិតលើភាគី ដែលដាក់អំណះអំណាងនៅចំពោះមុខខ្លួន។*[352]

ភស្តុតាង ជាសំខាន់ជាឯកសារ ដូចជា ផែនទីជាដើម។ តុលាការមិនមានឆន្ទានុសិទ្ធិច្រើន ក្នុងការចុះឬ ប្រមូលភស្តុតាងឡើយ។ តុលាការពិនិត្យជាសំខាន់ ទៅលើអ្វី ដែលភាគីទាំងពីរដាក់ជូន។ ដូចនេះ ប្រសិនបើភាគីណាមួយ មិនប៉ិនប្រសប់ក្នុងការបង្កើតឯកសារភស្តុតាង ភាគីនោះ អាចប្រឈមនឹងការចាញ់ក្តី។

**៨.៣.២.៥. ច្បាប់ដែលត្រូវអនុវត្ត**

ច្បាប់សម្រាប់យកមកអនុវត្ត ត្រូវបានកំណត់ក្នុងលក្ខន្តិកៈ របស់តុលាការនេះ។ ច្បាប់ទាំងនោះ មានដូចជា សន្ធិសញ្ញា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ

[351] Helmut, the Concise of the UN, *supra* note 8, p. 380; the Statute of ICJ, *supra* note 58, Art. 62; ; ICJ, East Timor, *supra* note 34, (2.3).
[352] Preah Vihear case, judgement of 1962, *supra* note 84, p. 16; Oil Platforms, *supra* note 293, p. 119

គោលការណ៍ទូទៅនៃច្បាប់ជាតិ ជាដើម។[353] គេគួរកត់សម្គាល់ថា ច្បាប់ដែលតុលាការយកមកប្រើ ធ្វើជាសំអាងក្នុងការវិនិច្ឆ័យសេចក្តី ត្រូវតែចងជាកាតព្វកិច្ចដល់រដ្ឋជាភាគី។ នេះមានន័យថា តុលាការនឹងប្រើសន្ធិសញ្ញាណាមួយបានលុះត្រា រដ្ឋភាគីចូលជាភាគី។ ផ្អែកតាមជំហរនេះ ភាគីទាំងពីរអាចស្នើឲ្យតុលាការ ផ្អែកលើតែសន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិណាមួយ។[354] តុលាការនឹងប្រើគោលការណ៍ទូទៅនៃច្បាប់ ក្នុងករណី ដែលគ្មានសន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬប្រើដើម្បីគាំទ្រនូវគំហើញទាញចេញពីការបកស្រាយសន្ធិសញ្ញា។

តុលាការប្រើប្រាស់ និងយោងដល់ស្នាដៃស្រាវជ្រាវច្បាប់អន្តរជាតិ របស់អ្នកស្រាវជ្រាវល្បីៗដោយប្រយ័ត្នប្រយែង។[355] សម្រាប់សាលក្រម របស់តុលាការអន្តរជាតិដទៃទៀត តុលាការក៏បានប្រើប្រាស់ផងដែរ តែមិនបង្ខំឲ្យតុលាការប្រើប្រាស់ឡើយ។[356] តុលាការជារឿយៗ យោងទៅដល់ខ្លឹមសារនៃសាលក្រម និងសេចក្តីសម្រេចមុនៗរបស់ខ្លួនផងដែរ។ នេះនាំឲ្យមានការបង្កើតជាយុត្តិសាស្ត្រ (Precedents) ដែលហាក់ចងជាកាតព្វកិច្ចដល់តុលាការខ្លួនឯង ឬអាចចងដល់ភាគីនៃរឿងក្តី ក្នុងរឿងក្តីសម្រេចរួច ឬរឿងក្តីនាពេលខាងមុខ។[357]

ពាក់ព័ន្ធជាមួយច្បាប់អនុវត្ត រដ្ឋជាភាគីនីមួយៗ ត្រូវតែមានភាពវៃឆ្លាតប្រសិនបើពួកគេចង់ឈ្នះក្តី។ ដូចនេះ ក្នុងពេលជំទាស់ រដ្ឋត្រូវព្យាយាមឲ្យ

---

[353] The Statute of ICJ, *supra* note 58, Art. 38.
[354] *Id.*
[355] *Id.*
[356] The ICJ always refers to jurisprudences of other international tribunals or courts.
[357] The Statute of the ICJ, *supra* note 58, Art. 59.

អស់លទ្ធភាពក្នុងការធ្វើឲ្យតុលាការ គាំទ្រនូវច្បាប់ ដែលខ្លួនស្នើឡើងសម្រាប់ប្រើប្រាស់ ដែលការពារប្រយោជន៍របស់ខ្លួនមាននៅក្នុងរឿងក្តី និងបដិសេធឲ្យខាងតែបាននូវវិធាន ដែលការប្រើប្រាស់ ដោយតុលាការ ដែលធ្វើឲ្យផលប្រយោជន៍របស់ភាគីបដិបក្ខក្នុងរឿងក្តី ត្រូវបានគាំទ្រ។

### ៨.៣.២.៦. ខ្លឹមសារ ទម្រង់ និងការអនុវត្តសាលក្រម

សាលក្រម នឹងចងជាកាតព្វកិច្ចដល់ភាគី ដែលភាគីត្រូវគោរព។ សាលក្រមជាប្រភេទបិទផ្លូវតវ៉ា (Final Judgement)។ ករណីមិនគោរពតាមសាលក្រម ភាគីអាចស្នើសុំតាមរយៈតុលាការ ដើម្បីស្នើឲ្យក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិជួយបង្ខំឲ្យមានការអនុវត្ត។[358]

សាលក្រមមានបីផ្នែក៖ ប្រវត្តិនីតិវិធី ខ្លឹមសារ និងឯកសារភ្ជាប់។ ខ្លឹមសាររៀបរាប់ ផងដែរនូវ ការរកឃើញរបស់តុលាការ ពាក់ព័ន្ធជាមួយការចោទប្រកាន់។ រាល់ការសម្រេច ស្តីពី ការចោទប្រកាន់ និងការជួសជុល ការខូចខាត (Reparation) ដែលអាចមាន ក្នុងករណីតុលាការរកឃើញថាមានការរំលោភកាតព្វកិច្ចដោយភាគីណាមួយនៅក្នុងជម្លោះ ត្រូវបានបង្ហាញតាមរយៈសំឡេងគាំទ្រ ឬមិនគាំទ្ររបស់ចៅក្រម ដែលក្នុងនោះ មានចៅក្រមដែលត្រូវបានជ្រើសតាំងដោយភាគី (*Ad Hoc* Judge)។[359] ការជួសជុលការខូតខាត អាចមានជាសំណង (Compensation) ការធ្វើឲ្យមានសភាពដូចដើម (Restitution) ដូចជាការប្រគល់នូវវត្ថុ ដែលត្រូវបាន

---

[358] The Press Release No. 2012/36 on Request for Interpretation of the Judgement of 15 June 1962 in the Case concerning the Temple of Preah Vihear (*Cambodia v. Thailand*), 29 November 2012, the International Court of Justice, p. 3.

[359] The Statute of ICJ, *supra* note 58, Art. 31.

បែអូសជូនភាគីជាម្ចាស់វិញ។ វាអាច ជាការធ្វើឲ្យភាគីម្ខាងសប្បាយចិត្ត (Satisfaction) ដូចជាការសុំទោស ការសន្យាថា អំពើដែលត្រូវបានចោទប្រកាន់ថារំលោភកាតព្វកិច្ចអន្តរជាតិ នឹងមិនកើតមាននាពេលអនាគត។ នៅក្នុងរឿងក្តី Germany ប្រឆាំងនឹង the United States of America តុលាការបានបង្គាប់ឲ្យសហរដ្ឋអាមេរិក សន្យាថា ការចាប់ជនជាតិអាឡឺម៉ង់ ដោយអាជ្ញាធរសហរដ្ឋអាមេរិកនាពេលអនាគត ត្រូវមានការជូនដំណឹង ដល់អាជ្ញាធរទូតរបស់ អាឡឺម៉ង់នៅក្នុងទឹកដីសហរដ្ឋអាមេរិក។[360]

ចៅក្រមអាចបញ្ចេញយោបល់ផ្ទាល់ខ្លួន ហើយភ្ជាប់យោបល់នេះជាមួយសាលក្រម។ វាអាចជាយោបល់ស្រប តែមានមូលដ្ឋានផ្សេង ចំពោះសេចក្តីសម្រេចស្របនេះ។ វាក៏អាចជាយោបល់ផ្ទុយ (Dissenting Opinion)។[361] យោបល់ទាំងនោះ ទោះបីជាមិនមានឥទ្ធិពលផ្លូវច្បាប់ ដូចជាសាលក្រម តែវាជួយអភិវឌ្ឍវិធានច្បាប់អន្តរជាតិផងដែរ។

### ៨.៣.២.៧. សំណើសុំបកស្រាយសាលក្រម និងបណ្តឹងសើរើ

រដ្ឋជាភាគីណាមួយក្នុងរឿងក្តី ក្នុងករណីមិនអាចអនុវត្តសាលក្រមបាន ដោយសារ សាលក្រមមានភាពមិនច្បាស់លាស់ អាចស្នើឲ្យតុលាការបកស្រាយសាលក្រម។[362] ការស្នើសុំនេះ អាចសុំនាពេលណាក៏បាន ទោះបីជា

---

[360] La Grand Case, ICJ, summaries of June 2001 judgement, operation part, p. 189, www.icj-cij.org.

[361] The Statute of ICJ, *supra* note 58, Art. 57; *see* Edward McWhinney and Mariko Kawano, Judge Shigeru Oda and the Path to Judicial Wisdom, Opinions (Declarations, Separate Opinions, Dissenting Opinions) on the International Court of Justice, 1993-2003), Vol. IV, 2006.

[362] The Statute of ICJ, *supra* note 58, Art. 60.

រយៈពេលយូរក្រោយពីថ្ងៃប្រកាសចេញសាលក្រមក្តី។ ជាក់ស្តែង ពាក់ព័ន្ធក្នុងក្តីក្តាំ ប្រាសាទព្រះវិហារ តុលាការចេញសាលក្រមក្នុងឆ្នាំ ១៩៦២ ហើយសំណើសុំឲ្យមានការបកស្រាយ ទើបត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០១១។[363] វាមិនមានបញ្ហាផ្លូវច្បាប់អ្វីរាំងឡើយ ទោះបី ភាគីមួយ បានដកខ្លួនឈប់ទទួលស្គាល់សមត្ថកិច្ចរបស់តុលាការ ក្នុងការដោះស្រាយជម្លោះ ក្រោយពីពេលមានសាលក្រម ពីព្រោះសាលក្រមនៅតែមានឥទ្ធិពល។

រដ្ឋភាគីនៃជម្លោះ ដែលត្រូវបានតុលាការចេញសាលក្រមរួចហើយ ក៏អាចធ្វើបណ្តឹងសើរើបានដែរ ក្នុងករណីមានភស្តុតាងថ្មី ដែលតុលាការមិនបានពិចារណា ហើយការពិចារណា ឬមិនបានដឹងភស្តុតាងនេះ គឺជាកំហុសរបស់តុលាការ។[364]

### ៨.៣.៣. ប្រឹក្សាយោបល់

មានតែអង្គការសហប្រជាជាតិ និងស្ថាប័នចំណុះមួយចំនួន ដូចជា អង្គការសុខភាពពិភពលោក (World Health Organization: WHO) ដែលអាចស្នើឲ្យតុលាការយុត្តិធម៌អន្តរជាតិ ផ្តល់យោបល់ លើបញ្ហាច្បាប់មួយចំនួន។ ទោះបីជាយ៉ាងនេះក្តី ស្ថាប័នទាំងនោះ ត្រូវមានការសុំការអនុញ្ញាតពីមហាសន្និបាតអង្គការសហប្រជាជាតិជាមុន។[365] ជាទូទៅ យោបល់ប្រឹក្សា

[363] Request for Interpretation, ICJ Press Release, *supra* note 358.
[364] The Statute of ICJ, *supra* note 58, Art. 61.
[365] The UN Charter, *supra* note 42, Art. 96.

មិនចងជាកាតព្វកិច្ចទេ វាគ្រាន់តែជួយបំភ្លឺបញ្ហាច្បាប់អន្តរជាតិ។ មានករណីលើកលែងខ្លះ ដែលយោបល់ប្រឹក្សា មានចរិតជាកាតព្វកិច្ច។[366]

នៅពេលមានសំណើ តុលាការត្រូវពិនិត្យ មើលថាតើបញ្ហា ដែលត្រូវបានស្នើឡើងជាបញ្ហាច្បាប់ដែរឬទេ? នេះគឺជាលក្ខខណ្ឌក្នុងការទទួលយកសំណើមកពិនិត្យ។ នៅក្នុងយោបល់ប្រឹក្សា ពាក់ព័ន្ធជាមួយបញ្ហាអភ័យឯកសិទ្ធិ តុលាការបានកំណត់ន័យ បញ្ហាច្បាប់ថា៖ *វាជាសំណួរ ធ្វើឡើងពាក់ព័ន្ធជាមួយនឹងច្បាប់ ព្រមទាំងលើកឡើងនូវបញ្ហាច្បាប់អន្តរជាតិ ដែលទាមទារចម្លើយផ្អែកតាមច្បាប់ និងហាក់ទំនងជាសំណួរ ដែលមានចរិតច្បាប់*។[367] នៅក្នុងដំណើរការ នៃការពិនិត្យ រដ្ឋពាក់ព័ន្ធអាចចូលរួមយោបល់ តាមរយៈការដាក់អំណះអំណាងជាលាយលក្ខណ៍អក្សរទៅតុលាការ។[368]

ទោះបីជា យោបល់ប្រឹក្សា មិនមានចរិតជាកាតព្វកិច្ច តែវាជួយបំភ្លឺបញ្ហាច្បាប់ជាច្រើន។ ក្នុងយោបល់ប្រឹក្សា ស្តីពី ភាពស្រប ឬមិនស្របច្បាប់នៃការប្រើប្រាស់អាវុធនុយក្លេអ៊ែរ តុលាការបានអះអាងថា មិនមានច្បាប់ណាមួយហាមឃាត់ការប្រើប្រាស់អាវុធនុយក្លេអ៊ែរ ក្នុងសង្គ្រាមការពារខ្លួនទេ ក៏ប៉ុន្តែរដ្ឋត្រូវតែពិចារណាដល់ច្បាប់មនុស្សធម៌អន្តរជាតិផងដែរ ពីព្រោះអាវុធប្រភេទនេះ បង្កឲ្យមានការខូចខាតមិនរើសមុខ (Discriminatory Attack) ដែលខុសពីគោលការណ៍ នៃច្បាប់មនុស្សធម៌អន្តរជាតិ។[369]

---

[366] ICJ Diffeerence relating to Immunity from Legal Process of a Special Rapporteur of the Commission on Human Rights, Advisory of 29 April 1999, p. 66.
[367] ICJ, the Legality of the Use by a State of Nuclear Weapons in Armed Conflict, Advisory of 8 July 1996, Summaries of Judgements, 1992-1996, p. 90.
[368] ICJ, Jurisdictional Immunities of the State (Germany v. Italy: Greece intervening), Summary of the Judgement of 3 Februaray 2012.
[369] Helmut, the Concise of the UN, *supra* note 8, p. 384.

# ជំពូក ៩
# ការការពារបុគ្គលក្រោមច្បាប់អន្តរជាតិ

## ៩.១. ការការពារជនភៀសខ្លួន

### ៩.១.១. ប្រវត្តិ

ប្រវត្តិនៃ ការសុំជ្រកកោន បានកើតមានជាយូរយារមកហើយ។ មានការវិវត្ត ពីការជ្រកកោនដោយសារមូលហេតុសាសនា ទៅកាន់ការស្នើសុំមួយ ដោយសារមូលហេតុនយោបាយ។[370] ការវិវត្តនេះ នាំឲ្យមានការបង្កើតបាននូវសិទ្ធិជ្រកកោន ក្នុងក្របខ័ណ្ឌនៃការការពារសិទ្ធិមនុស្សទូទៅ។ សេចក្តីថ្លែងការណ៍ស្តីពី សិទ្ធិមនុស្សឆ្នាំ ១៩៤៨ បានចែងយ៉ាងប្រយ័ត្នប្រយែងថា បុគ្គលមានសិទ្ធិក្នុងការសុំជ្រកកោន។[371] ក៏ប៉ុន្តែ ការផ្តល់ ឬមិនផ្តល់គឺជាឆន្ទានុសិទ្ធិរបស់រដ្ឋនៃដែនដី ដែលបុគ្គលស្នើសុំ។ អ្នកសិក្សាស្រាវជ្រាវ ពិតមិនពិបាកយល់ទេ អំពីការយល់ឃើញដូចនេះ។ ការផ្តល់សិទ្ធិជ្រកកោន ដល់អ្នកធ្វើនយោបាយប្រឆាំងនឹងរដ្ឋមួយ អាចនាំឲ្យមានភាពល្អក់កករ ក្នុងទំនាក់ទំនងរវាងរដ្ឋនោះ និងរដ្ឋ ដែលផ្តល់សិទ្ធិជ្រកកោន។ ភាពដែលអាចកើតមាននេះ កើតជាច្រើនក្នុងសម័យសង្គ្រាមត្រជាក់ ចន្លោះឆ្នាំ ១៩៤៥ ដល់ ១៩៩០។ បន្ថែមពីលើនេះ លំហូរដ៏សន្ធឹកសន្ធាប់ របស់អ្នកសុំសិទ្ធិជ្រកកោន (Mass Influx) មកកាន់ប្រទេសមួយ ក្រៅពីប៉ះពាល់ដល់សន្តិសុខរបស់រដ្ឋនោះ អាចដាក់បន្ទុកផ្នែកហិរញ្ញវត្ថុដល់រដ្ឋទទួល ហើយដែលចង់ ឬមិនចង់

[370] Political Asylum, www.newworldencyclopedia.org/entry/Political_asylum, p. 1.
[371] The Universal Declaration of Human Rights (the UDHR), 10 December 1948, General Assembly Resolution 217 A (III), Art. 14.

ឆន្ទានុសិទ្ធិក្នុងការផ្តល់នូវការជ្រកកោន នឹងត្រូវបានជ្រើសរើសយកដោយរដ្ឋ លើកលែងតែផ្ទុយនឹងបទប្បញ្ញត្តិច្បាប់អន្តរជាតិ។[372]

ឆ្នាំ ១៩៥១ សន្ធិសញ្ញា ស្តីពី ឋានៈនៃជនភៀសខ្លួន ត្រូវបានអនុម័តដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិ។[373] វាជាសន្ធិសញ្ញាមួយ ចែងលម្អិតអំពីសិទ្ធិរបស់ជនភៀសខ្លួន កាតព្វកិច្ចរបស់រដ្ឋ និង ជនភៀសខ្លួន និយមន័យនៃជនភៀសខ្លួន ព្រមទាំងមានបទប្បញ្ញត្តិមួយចំនួនទៀត ដូចជាកិច្ចសហការរវាងរដ្ឋ និងឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកជនភៀសខ្លួន។ ក្រោយមកក្នុងឆ្នាំ ១៩៦៧ អង្គការសហប្រជាជាតិ បានអនុម័តនូវពិធីសារបន្ថែម ដល់សន្ធិសញ្ញា ឆ្នាំ ១៩៥១ សំដៅពង្រីកប្រភេទមនុស្ស ដែលអាចចាត់ទុកថាជាជនភៀសខ្លួន។[374] ស្រដៀងគ្នាជាមួយនឹងសន្ធិសញ្ញាវិស័យសិទ្ធិមនុស្សដែរ សន្ធិសញ្ញាឆ្នាំ ១៩៥១ មិនបានឆ្លុះបញ្ចាំងឲ្យគ្រប់គ្រាន់នូវបរិបទក្នុងស្រុក នៃប្រទេសជាភាគី ជាពិសេស ប្រទេសក្រៅតំបន់អឺរ៉ុប។ នេះនាំឲ្យមានការបង្កើតឡើងនូវសន្ធិសញ្ញា ឬសេចក្តីថ្លែងការណ៍ជាច្រើនទៀតពាក់ព័ន្ធនឹងជនភៀសខ្លួន និងសិទ្ធិជ្រកកោនសម្រាប់តំបន់ដោយឡែកៗនីមួយៗ។[375]

---

372 Declaration on Territorial Asylum, 14 December 1967, A/RES/2312, Art. 3(2).

373 The Refugee Convention, *supra* note 89.

374 Optional Protocol Relating to the Refugee Convention, 31 January 1967, UNTS, Vol. 606, p. 267.

375 For example, Organization of Africa Union Convention Governing the Specific Aspects of Refugee Problems in Africa, Human Rights, A Compilation of International Instruments, vol. II, Regional Instruments, ST/HR/1/Rev.5 (Vol.II), p. 323.

### ៩.១.២. និយមន័យ

ជនភៀសខ្លួន ត្រូវបានផ្តល់ន័យថា ជាបុគ្គលស្ថិតនៅក្រៅប្រទេស ដែលខ្លួនមានសញ្ជាតិ ដោយសារមូលហេតុភិតភ័យ (well-found fear) ថានឹងមានការធ្វើទុក្ខបុកម្នេញ (persecution) ដោយសារមូលហេតុ សាសនា ពូជសាសន៍ សញ្ជាតិ សមាជិកនៃក្រុមសង្គម ឬនយោបាយ ដោយឡែកណាមួយ មិនអាចឲ្យខ្លួនវិលត្រឡប់ទៅប្រទេសដើមកំណើត ឬ នាំឲ្យមិនមានចេតនាសុំការការពារពីប្រទេសនោះ ពីព្រោះតែភ័យខ្លាចនូវការធ្វើទុក្ខបុកម្នេញ។[376]

អ្នកសិក្សាស្រាវជ្រាវ ត្រូវកត់សម្គាល់ថា ការរត់ភៀសខ្លួនទៅនៅក្រៅប្រទេសកំណើត ឬប្រទេសជាលំនៅឋានរបស់ខ្លួន គឺដោយសារព្រឹត្តិការណ៍ កើតមានមុនថ្ងៃទី ១ មករា ឆ្នាំ ១៩៥១។[377] ហេតុផលនៃការកំណត់កាលវេលានេះ មិនមានភាពច្បាស់លាស់ទេ។ ការកំណត់នេះ នឹងនាំឲ្យមានការបដិសេធបុគ្គលមួយចំនួន ទោះបីពួកគាត់ អាចត្រូវបានចាត់ថាជាជនភៀសខ្លួន ដោយសារព្រឹត្តិការណ៍ក្រោយឆ្នាំ ខែមករា ១៩៥១។ អាស្រ័យហេតុនេះ ពិធីសារឆ្នាំ ១៩៦៧ ត្រូវបានធ្វើឡើងដើម្បីលុបចោលនូវកាលបរិច្ឆេទនេះ។[378]

ករណីបុគ្គលមានសញ្ជាតិពីរ ដែលក្នុងចំណោមប្រទេសណាមួយ មិនមានការធ្វើទុក្ខបុកម្នេញ ដែលគាត់អាចរស់នៅបាន បុគ្គលនោះ នឹងមិនត្រូវចាត់ថាជាជនភៀសខ្លួនទេ។[379] ស្រដៀងគ្នានេះដែរ បុគ្គលមួយទទួល បានឋានៈជាជនភៀសខ្លួន ហើយក្រោយមក ស្ថានភាពរបស់ប្រទេសដើម ប្រែ

[376] The Refugee Convention, *supra* note 89, Art. 1(A.2).
[377] The Refugee Convention, *supra* note 89, Art. 1 (B.1).
[378] The OP to the Status of Refugees, *supra* note 374, Art. 1(2).
[379] The Refugee Convention, *supra* note 89, Art. 1(A.2).

ប្រែួល លែងមានការធ្វើទុក្ខបុកម្នេញ បុគ្គលនោះ អាចនឹងត្រូវបានដកឋានៈជាជនភៀសខ្លួន។[380] ក្រោយពីទទួលបានឋានៈរួចហើយក្តី ប្រសិនបើរដ្ឋផ្តល់ឋានៈ រកឃើញជនភៀសខ្លួន ធ្លាប់មានទោស ឬជាឧក្រិដ្ឋជន មុនពេលបានឋានៈ បុគ្គលនោះក៏ អាចនឹងត្រូវបានបាត់ឋានៈផងដែរ។[381]

ក្នុងការកំណត់ថាជនណាមួយ ជាជនភៀសខ្លួន ឬមិនមែន បញ្ហាសំខាន់គឺការកំណត់ថា តើមានការធ្វើទុក្ខបុកម្នេញដែរឬទេ? ការស្វែងរកចម្លើយគឺជាការលំបាក ពីព្រោះសន្ធិសញ្ញាឆ្នាំ ១៩៥១ មិនបានផ្តល់ន័យ ដល់ពាក្យ "ការធ្វើទុក្ខបុកម្នេញ"។ ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកជនភៀសខ្លួនបានដាក់ចេញនូវសេចក្តីថ្លែងការណ៍មួយចំនួន តែមិនបានផ្តល់ន័យជាក់លាក់ដល់ពាក្យនេះឡើយ។[382] អ្នកសិក្សាស្រាវជ្រាវ ក៏មិនបានផ្តល់ន័យផងដែរ ដោយគ្រាន់តែផ្តល់ជាសញ្ញាណ។ ការរំលោភសិទ្ធិជាមូលដ្ឋានធ្ងន់ធ្ងរ មានចរិតរើសអើង អាចជាការធ្វើទុក្ខបុកម្នេញ។[383] ទោះបីជាយ៉ាងនេះក្តី គេត្រូវកំណត់ថា អ្វីទៅគឺជាសិទ្ធិមូលដ្ឋានជាមុនសិន។ វាជាសំណួរមួយទៀត ដែលពិបាករកចម្លើយរួម។

---

[380] It is called: “cessation clause”, the Refugee Convention, *supra* note 89, Art. 1 (C.5).

[381] It is called: “exclusion clause”, the Refugee Convention, *supra* note 89, Art. 1 (F).

[382] For example, Handbook on Procedures and Criteria for Determining Refugee Status under the 1951 Convention and the 1967 Protocol relating to the Status of Refugees, HCR/IP/4/Eng/REV.1, 1992.

[383] Guy S. Goodwin Gill, the Refugee in International Law (Guy, Refugee), 2nd ed., 1996, p. 67.

### ៩.១.៣. សិទ្ធិ និងភាតព្វកិច្ចរបស់ជនភៀសខ្លួន

យ៉ាងហោចណាស់ មានជនបរទេសពីរប្រភេទ ដែលចាកចេញពីប្រទេសដើមទៅនៅបរទេស។ ប្រភេទទី១ ក្នុងគោលបំណងឲ្យមានជីវភាពធូរជារ និងប្រភេទទី២ ក្នុងគោលបំណងសុំការការពារ និងរួចផុតពីការធ្វើទុក្ខបុកម្នេញនៅក្នុងប្រទេសដើមរបស់ខ្លួន។ មនុស្សក្នុងប្រភេទទី២ ត្រូវបានចាត់ទុកជាជនភៀសខ្លួន ដែលត្រូវទទួលបានការការពារជាពិសេស ទោះបីក្នុងករណីខ្លះការការពារ មានលក្ខណៈបណ្ដោះអាសន្នយ៉ាងណាក្ដី។

ជនភៀសខ្លួន ទទួលបានសិទ្ធិ និងការគាំពារជាច្រើន បើប្រៀបធៀបជាមួយជនអន្តោប្រវេសន៍ធម្មតា។ ជនភៀសខ្លួន ក្នុងវិស័យខ្លះ ទទួលបានការការពារដូចប្រជាពលរដ្ឋរបស់ប្រទេស ដែលខ្លួនកំពុងស្នាក់នៅ ដូចជាក្នុងការអប់រំកម្រិតបឋមសិក្សា វិស័យសាសនាជាដើម។[384] ចំពោះវិស័យដទៃទៀត សន្និសញ្ញា ទាមទារឲ្យរដ្ឋមានការអនុគ្រោះឲ្យបានច្រើនតាមតែអាចធ្វើទៅបាន និងមិនត្រូវផ្ដល់សិទ្ធិទាបជាងអ្វី ដែលផ្ដល់ជូនជនបរទេសទូទៅឡើយ។[385] ជនភៀសខ្លួន ទទួលបានលិខិតធ្វើដំណើរ[386] និងការសម្រួលការបញ្ជូនទ្រព្យសម្បត្តិទៅប្រទេស ដែលខ្លួនទទួលបានការតាំងទីលំនៅជាអចិន្ត្រៃយ៍[387] (Permanent Settlement) ព្រមទាំងការចូលសញ្ជាតិ[388] (Naturalization)។

---

[384] The Refugee Convention, *supra* note 89, Art. 22.

[385] *Id.*, Art.7 (1).

[386] Guy, Refugee, *supra* note 383, p. 302; the Refugee Convention, *supra* note 89, Art. 28.

[387] The Refugee Convention, *supra* note 89, Art. 30.

[388] *Id.*, Art. 34.

ការផ្តល់ឲ្យសិទ្ធិ ឬការការពារនេះ មិនត្រូវផ្អែកទៅតាមគោលការណ៍ទៅវិញទៅមកឡើយ (Principle of Reciprocity)។[389] បន្ថែមពីលើនេះ ជនភៀសខ្លួន ទទួលបានសិទ្ធិ និងការការពារជាច្រើនទៀត អនុលោមតាមសន្ធិសញ្ញាដទៃទៀត និង ច្បាប់ទំនៀមទម្លាប់អន្តរជាតិជាដើម ដោយមិនប្រកាន់នូវប្រភេទរបស់បុគ្គល។ នេះ ដើម្បីឲ្យស្របទៅតាមគោលការណ៍ មិនរើសអើង។[390] ជនភៀសខ្លួន មានកាតព្វកិច្ចផងដែរ តាមសន្ធិសញ្ញាឆ្នាំ ១៩៥១។ មាត្រា ២ របស់សន្ធិសញ្ញាឆ្នាំ ១៩៥១ បានចែងថា ជនភៀសខ្លួនត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិ ព្រមទាំងវិធានការសម្រាប់រក្សាសណ្តាប់ធ្នាប់សាធារណៈរបស់រដ្ឋ ដែលខ្លួនស្នាក់នៅ។[391]

### ៩.១.៤. ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ

ឧត្តមស្នងការ ត្រូវបានបង្កើតនៅក្នុងឆ្នាំ ១៩៤៩ តាមសេចក្តីសម្រេចលេខ ៣១៩(៤) ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ១៩៤៩។[392] ឧត្តមស្នងការទទួលបញ្ជា និងអនុវត្តគោលនយោបាយរបស់អង្គការសហប្រជាជាតិ តាមនីតិវិធីកំណត់ដោយមហាសន្និបាតអង្គការសហប្រជាជាតិ។

[389] The Refugee Convention, *supra* note 89, Art. 7(4).
[390] *Id.*, Art. 3.
[391] *Id.*, Art. 2.
[392] UN High Commissioner for Refugees, www.refworld.org/publisher/UNHCR.html Handbook on Procedures, *supra* note 382, paras. 13-19.

ឧត្តមស្នងការ មានការិយាល័យនៅក្នុងទីក្រុង ហ្សឺណែវ ប្រទេសស្វីស ដឹកនាំដោយឧត្តមស្នងការម្នាក់ មានអាណត្តិ៣ឆ្នាំ ជ្រើសតាំងដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិ តាមសំណើរបស់អគ្គលេខាអង្គការសហប្រជាជាតិ ។ ឧត្តមស្នងការ ប្រើប្រាស់ថវិការបស់អង្គការសហប្រជាជាតិ មានតួនាទីផ្តល់ការការពារជាអន្តរជាតិ ដល់ជនភៀសខ្លួន ដែលស្ថិតចូលក្នុងសមត្ថកិច្ចរបស់ខ្លួន ស្វែងរកទីជម្រកអចិន្រ្តៃយ៍ដល់ពួកគេ ឬជួយធ្វើមាតុភូមិនិវត្តន៍ចូលមកប្រទេសកំណើតវិញ។ ដើម្បីអនុវត្តការងារ ឧត្តមស្នងការ បានរៀបចំបទប្បញ្ញត្តិអន្តរជាតិជាច្រើនពាក់ព័ន្ធជាមួយនឹងការការពារជនភៀសខ្លួន។ ឧត្តមស្នងការ ត្រូវធ្វើកិច្ចការងារ និង សហការជាមួយរដ្ឋដែលពាក់ព័ន្ធក្នុងការកំណត់ឋានៈជនភៀសខ្លួន និងផ្តល់ជំនួយបច្ចេកទេស ផ្អែកតាមកិច្ចព្រមព្រៀងជាមួយរដ្ឋពាក់ព័ន្ធ។

### ៩.១.៥. បញ្ហាពាក់ព័ន្ធ

បញ្ហាជនភៀសខ្លួន ជាបញ្ហាមួយដ៏សើបមួយ ពីព្រោះវាពាក់ព័ន្ធជាមួយបញ្ហារំលោភសិទ្ធិមនុស្ស ដែលនាំឲ្យបុគ្គលណាមួយ រត់ចាកចេញចោលប្រទេសរបស់ខ្លួន ទៅកាន់ប្រទេសផ្សេងមួយទៀត ដើម្បីរស់នៅផុតពីការធ្វើទុក្ខបុកម្នេញ។ ផ្នែកខាងក្រោម នឹងរៀបរាប់អំពីបញ្ហាចម្រូងចម្រាសមួយចំនួនទាក់ទងជាមួយនឹងការកំណត់ឋានៈជាជនភៀសខ្លួន និង អំណះអំណាងមួយចំនួន ដែលរដ្ឋបានលើកឡើងក្នុងដំណើរការអនុវត្តកាតព្វកិច្ច ចែងក្នុងសន្ធិសញ្ញា ឆ្នាំ ១៩៥១។

### ៩.១.៥.១. ការកំណត់ឋានៈ និង ឧបដិសេធ

មានជំហរពីរប្រភេទ ពាក់ព័ន្ធជាមួយនឹង ការកំណត់ឋានៈជនភៀសខ្លួន។ ជំហរទី១ បានអះអាងថា អ្នកដែលសុំសិទ្ធិជ្រកកោន គឺជាជនភៀសខ្លួនរួចទៅហើយ (Declaratory Status)។[393] នេះផ្ទុយពីជំហរទី២ ដែលថ្លែងថា អ្នកដាក់ពាក្យសុំ គ្រាន់តែជាអ្នកសុំសិទ្ធិជ្រកកោន (Asylum Seeker)។[394] ការប្រកាន់ជំហរផ្សេងៗនេះ មានអត្ថន័យបង្កប់ផ្សេងៗផងដែរ ហើយផលវិបាកក៏មានលក្ខណៈខុសគ្នា។ ប្រសិនបើ រដ្ឋចាត់បុគ្គលណាមួយថា ជាជនភៀសខ្លួន ការប្រព្រឹត្តលើបុគ្គលនោះ ពិតខុសគ្នាពីការប្រព្រឹត្តលើបុគ្គល ដែលគ្រាន់តែជាអ្នកសុំសិទ្ធិជ្រកកោន។ រដ្ឋ មានកាតព្វកិច្ច មិនបញ្ជូនជនភៀសខ្លួនទៅប្រទេស ដែលពួកគេនឹងជួបការធ្វើទុក្ខបុកម្នេញ។ ផ្ទុយទៅវិញ រដ្ឋអាចបញ្ជូនអ្នក ដែលគ្រាន់តែជាជនសុំសិទ្ធិជ្រកកោនទៅកាន់ប្រទេសដើមវិញ ទោះបីជាមានការធ្វើទុក្ខបុកម្នេញ។

ជាទូទៅរដ្ឋបានប្រកាន់ជំហរទី២។ បុគ្គលសុំសិទ្ធិជ្រកកោន ត្រូវដាក់ពាក្យសុំ និងឆ្លងកាត់ដំណើរការនីតិវិធី មុនពេលកំណត់ថា ពួកគេគឺជាជនភៀសខ្លួន។ ទោះបីជាយ៉ាងនេះក្តី អ្នកដាក់ពាក្យសុំ ត្រូវទទួលបានការការពារបណ្តោះអាសន្ន និងមិនត្រូវបញ្ជូនចេញពីប្រទេសឡើយ ដើម្បីរង់ចាំលទ្ធផលនៃការពិនិត្យពាក្យសុំ។ ជំហរទី២ អាចត្រឹមត្រូវក្នុងករណីខ្លះ ពីព្រោះ ជាលទ្ធផលជនណាមួយ អាចត្រូវបានរកឃើញថា មិនមែនជនភៀសខ្លួនទេ ពីព្រោះការរត់ចេញពីប្រទេសដើម ក្នុងគោលបំណងទទួលបានជីវភាពធូរជារ នៅក្រៅ

[393] Handbook on Procedures, *supra* note 382, para. 28.
[394] Guy, the Refugee, *supra* note 383, p. 32.

ប្រទេស។[395] ការសម្រេចណាមួយ ត្រូវផ្អែកទៅលើករណីជាក់ស្តែង និងតាមស្ថានភាពដោយឡែករបស់អ្នកសុំសិទ្ធិជ្រកកោន។[396]

ក្នុងការពិនិត្យមើលពាក្យសុំ រដ្ឋមាននិន្នាការ ពិនិត្យមើលសាវតារ បទល្មើសប្រព្រឹត្តឡើងដោយអ្នកស្នើសុំមុនចូលមកទឹកដីរបស់ខ្លួន។ ប្រសិនបើ រដ្ឋរកឃើញថាមានមែន រដ្ឋនឹងប្រើខបដិសេធ (Exclusion Clause)[397] ហើយសម្រេចថាអ្នកសុំមិនមានឋានៈជាភៀសខ្លួនទេ។ ផ្អែកតាមសេចក្តីសម្រេចនេះ រដ្ឋអាចបដិសេធផ្តល់ការការពារ និងអាចដេញជននោះចេញពីប្រទេសរបស់ខ្លួន។ ការប្រើខនេះ ឲ្យបានត្រឹមត្រូវ វានឹងមិនមានបញ្ហាទេ អ្វីដែលជាបញ្ហា គឺការប្រើប្រាស់នូវខនេះដោយបំពាន ដែលធ្វើឲ្យជនដែលសមនឹងទទួលឋានៈជាជនភៀសខ្លួន បែរទៅជាមិនបានទៅវិញ។ គោលបំណងរបស់សន្ធិសញ្ញា ឆ្នាំ ១៩៥១ គឺការពារជនភៀសខ្លួនពីការធ្វើទុក្ខបុកម្នេញ។ នេះជាគោលបំណងចម្បង ដែលរដ្ឋជាភាគី ត្រូវគិតពិចារណាជាមុន។ ការប្រើខបដិសេធ ត្រូវតែជារឿងបន្ទាប់បន្សំ និងបកស្រាយឲ្យចង្អៀត។[398] ប្រសិនបើបុគ្គលជាជនភៀសខ្លួន គាត់នឹងមិនត្រូវបានបញ្ជូនទៅប្រទេសដើមដែលនឹងជួបការធ្វើទុក្ខបុកម្នេញទេ។ រដ្ឋ អាចចាត់វិធានការចំពោះបទល្មើសតាមរយៈកិច្ចសហការជាមួយរដ្ឋពាក់ព័ន្ធ ដើម្បីធានាថា ជននោះនឹងមិនប្រឈមនឹងការធ្វើទុក្ខបុកម្នេញ ក្នុងពេលជាមួយគ្នានេះ នឹងមិនរួចផុតពីការ

[395] They are called "economic migrants", *see* David Robertson, A Dictionary of Human Rights, 2nd ed., 2004, p. 24.
[396] Handbook on Procedures, *supra* note 382, para. 29.
[397] UNHCR, Exclusion from Refugee Status, EC/GC/01/2Track/1, 20 May 2001.
[398] Handbook on Procedures, *supra* note 382, para. 149.

ទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌ ដែលគាត់បានប្រព្រឹត្តមុនសុំសិទ្ធិជ្រកកោន។

### ៩.១.៥.២. ការមិនបញ្ជូនជនភៀសខ្លួនត្រឡប់ទៅជួបការធ្វើទុក្ខបុកម្នេញ

កាតព្វកិច្ចមិនបញ្ជូន ជនភៀសខ្លួនទៅកាន់ប្រទេសណាមួយ ដែលគាត់នឹងជួបការធ្វើទុក្ខបុកម្នេញ ត្រូវបានចែងនៅក្នុងសន្ធិសញ្ញា ឆ្នាំ ១៩៥១ ថា៖ *"រដ្ឋភាគីមិនត្រូវបណ្តេញ ឬបញ្ជូន ជនភៀសខ្លួន តាមមធ្យោបាយណាមួយក៏ដោយ ទៅកាន់ព្រំដែន ដែលជីវិត ឬ សេរីភាពរបស់ពួកគេ នឹងត្រូវបានគំរាមកំហែង ដោយសារមូលហេតុ ពូជសាសន៍ សាសនា សញ្ជាតិ សមាជិកនៃសង្គម ឬ ទស្សនៈនយោបាយ"*។[399] វាជាកាតព្វកិច្ចមួយថ្មីសំខាន់ និងមានភាពចម្រូងចម្រាស។ នេះដោយសារកាតព្វកិច្ចនេះ តម្រូវឲ្យរដ្ឋបញ្ជូន ទទួលខុសត្រូវចំពោះអំពើអាជ្ញាធររដ្ឋផ្សេង ដែលបានធ្វើទុក្ខបុកម្នេញ លើជនភៀសខ្លួន ក្រោយពេលជនភៀសខ្លួន ត្រូវបានបញ្ជូនចេញទៅ។ ការតម្រូវនេះ ងាកចេញឆ្ងាយពីទ្រឹស្តីដើម ស្តីពី ការទទួលខុសត្រូវរបស់រដ្ឋ តម្រូវចំពោះតែអំពើដែលត្រូវបានធ្វើដោយអាជ្ញាធររបស់ខ្លួន ក្នុងដែនដីរបស់ខ្លួន។ ការពិនិត្យថាជនណាមួយ នឹងជួបការធ្វើទុក្ខបុកម្នេញ ទាមទារឲ្យរដ្ឋ មុនបញ្ជូន ពិចារណាអំពីស្ថានភាពសិទ្ធិមនុស្សរបស់រដ្ឋដែលពាក់ព័ន្ធ។ នេះអាចផ្ទុយជាមួយគោលការណ៍មិនជ្រៀតជ្រែក (Rule of Non-Inquiry)[400] ហើយរដ្ឋ អាចទទួលរង

[399] The Refugee Convention, *supra* note 89, Art. 33; the similar provision was included in the Conevntion against Torture, Art. 3; Jean Allain, *the Jus Cogens Nature of non-refoulement*, 13 (4) IJRL (2002).

[400] Meas Bora, Extradition, *supra* note 276, p. 433; John Quigley, *the Rule of Non-Inquiry and Human Rights Treaties*, 45 Cath. U.L. Rev. (1996), p. 1213.

នូវការចោទប្រកាន់ពីរដ្ឋដទៃ ថាបានជ្រៀតជ្រែកកិច្ចការងារផ្ទៃក្នុង ដែលអាចនឹងនាំឲ្យទំនាក់ទំនងរវាងរដ្ឋទាំងពីរមានភាពល្អក់កករ។

មានបញ្ហាជាច្រើនពាក់ព័ន្ធជាមួយការបញ្ជូនជនភៀសខ្លួនទៅវិញ ជាពិសេសពាក់ព័ន្ធជាមួយនឹងវិសាលភាពរបស់វា។ តើការហាមឃាត់ការបញ្ជូនទៅវិញអនុវត្ត ចំពោះករណីដេញនៅលើសមុទ្រអន្តរជាតិ ឬនៅព្រំដែនដែរឬទេ? តើការសន្យាជាលក្ខណៈ នយោបាយ (Political Assurance) ថាមិនធ្វើទុក្ខបុកម្នេញ ក្រោយពីរដ្ឋបានទទួលជនភៀសខ្លួន ក្រោយពេលបញ្ជូនអាចទទួលយកបានដែរឬទេ? តើការហាមឃាត់មិនបញ្ជូនទៅវិញ អនុវត្តចំពោះការដេញចេញដោយប្រយោល (Indirect Refoulement)? និងជាចុងក្រោយ បន្លាស់ទីក្នុងស្រុក (Internal Flight) ទៅកាន់កន្លែងមានសុវត្ថិភាព អាចរួចផុតពីការធ្វើទុក្ខបុកម្នេញ នឹងនាំឲ្យរួចផុតពីការចោទប្រកាន់ថា រដ្ឋបានរំលោភកាតព្វកិច្ចមិនបញ្ជូនទៅវិញដែរឬទេ?

### ៩.១.៥.៣. ការបណ្តេញជនភៀសខ្លួននៅព្រំដែន និងនៅក្នុងដែនសមុទ្រអន្តរជាតិ

ការបណ្តេញទាំងពីរប្រភេទនេះ អាចត្រូវបានធ្វើឡើងនៅក្រៅដែនដី ដែលរដ្ឋអាចអះអាងថា មិនស្ថិតចូលក្នុងការហាមបញ្ជូន។ ការហាមបញ្ជូននេះអនុវត្តនាពេល ដែលបុគ្គលស្ថិតនៅក្នុងដែនដីរបស់រដ្ឋជាមុនសិន។[401] ការអះអាងនេះ វាស្របគ្នាទៅនឹង ការទាមទារ ជាទូទៅ ថាអ្នកសុំសិទ្ធិជ្រកកោនត្រូវចូលមកក្នុងដែនដីរបស់រដ្ឋជាមុនសិន មុននឹងដាក់ពាក្យស្នើសុំ (Territor-

[401] Haitian Case, *supra* note 191, para. 71; *see* Seline Trevisanut, *the Principle of Non-Refoulement at Sea and the Effectiveness of Asylum Protection*, in Max Planck Yearbook of United Nations Law, Volume 12, 2008, pp. 205-246.

ial Asylum)[402]។ រដ្ឋ មិនអាចផ្តល់ការជ្រកកោននៅក្នុងស្ថានទូតរបស់រដ្ឋនៅក្រៅប្រទេសទេ ពីព្រោះ វាមិនមែនជាដែនដីរបស់ខ្លួន។

ដោយសារការវិវត្តនៃច្បាប់អន្តរជាតិ ជាពិសេស ក្នុងវិស័យសិទ្ធិមនុស្ស ទីកន្លែងនៃសកម្មភាពរបស់អាជ្ញាធររបស់រដ្ឋ ដែលរំលោភច្បាប់អន្តរជាតិ មិនមែនជាកត្តាចម្បងក្នុងការបង្កើតឲ្យមានការទទួលខុសត្រូវរបស់រដ្ឋឡើយ។ អ្វីជាសំខាន់ គឺការចូលរួមរបស់អាជ្ញាធររបស់រដ្ឋ ដែលអាចចាត់ថាអំពើនោះស្ថិតចូលក្នុងដែនសមត្ថកិច្ចរបស់រដ្ឋ។[403] ក្នុងរឿងក្តី នៃការបណ្តេញជនភៀសខ្លួន *ហៃទី* ដោយកងម៉ារីនរបស់សហរដ្ឋអាមេរិក គណៈកម្មការអន្តរទ្វីបអាមេរិក បានអះអាងថា ទោះបីការដេញកើតមាននៅលើដែនសមុទ្រអន្តរជាតិក្តី សហរដ្ឋអាមេរិកត្រូវទទួលខុសត្រូវ។[404] ស្របគ្នានឹងជំហរនេះ មានឯកសារអន្តរជាតិជាច្រើន ដែលហាមឃាត់ការដេញនៅតាមព្រំដែន និងក្នុងដែនសមុទ្រអន្តរជាតិ។[405]

### ៩.១.៥.៤. ការបណ្តេញដោយប្រយោល

ជនភៀសខ្លួន អាចត្រូវបានបណ្តេញដោយរដ្ឋមួយ ទៅកាន់រដ្ឋមួយ ជាទីកន្លែងដែលមិនមានការធ្វើទុក្ខបុកម្នេញ។ ការដេញនេះ នឹងមិនខុសពីកាតព្វកិច្ចហាមបញ្ជូនទេ។ មានការវិវត្តថ្មី ជាពិសេសពាក់ព័ន្ធ ប្រទេសទីពាមានសុវត្ថិភាព (Safe Third Country) បង្កើតឡើងតាមសន្ធិសញ្ញាទ្វេភាគីរបស់

[402] UNHCR Note on the Principle of *Non-Refoulement*, territorial application, *see* www.refworld.org/docid/438c6d972.html.

[403] Guy, the Refugee, *supra* note 383, p. 123.

[404] *Haitian* Case, *supra* note 191, paras. 183-189.

[405] Note on the Principle of Non-Refoulement, *supra* note 402.

រដ្ឋជាពិសេសក្នុងទ្វីបអឺរ៉ុប។[406] តាមរយៈ ខ ស្តីពី ប្រទេសទី៣មានសុវត្ថិភាព រដ្ឋមួយអាចបញ្ជូនអ្នកសុំសិទ្ធិជ្រកកោន ឲ្យទៅកាន់ប្រទេសណាមួយ ដែលខ្លួនឆ្លងកាត់ ដែលត្រូវបានចាត់ ថាជាប្រទេសទី៣មានសុវត្ថិភាព (គ្មានការធ្វើទុក្ខបុកម្នេញ)។ ទោះបីយ៉ាងនេះក្តី ជននោះអាចនឹងត្រូវបានបញ្ជូនបន្តទៅប្រទេសដើមកំណើត ឬប្រទេសណាមួយ ដែលនឹងជួបប្រទះការធ្វើទុក្ខបុកម្នេញ។ មានយុត្តិសាស្ត្ររួចទៅហើយ ដែលដាក់ការទទួលខុសត្រូវដល់រដ្ឋបណ្តេញទី១ ប្រសិនបើរដ្ឋបញ្ជូនបានដឹងថា រដ្ឋទទួល នឹងបណ្តេញជននោះទៅប្រទេសដែលបុគ្គល នឹងជួបការធ្វើទុក្ខបុកម្នេញ តែរដ្ឋបណ្តេញទី១ នៅតែបញ្ជូនទៅរដ្ឋនោះ។[407]

មិនមានលក្ខណៈវិនិច្ឆ័យ ជាក់លាក់ដើម្បីកំណត់ ថារដ្ឋណាដែលមានសុវត្ថិភាពទេ។ រដ្ឋដែលមានច្បាប់រដ្ឋធម្មនុញ្ញ ចែងធានាសិទ្ធិមនុស្ស មិនប្រាកដថា រដ្ឋនោះគោរពសិទ្ធិមនុស្សបានល្អ ហើយអាចត្រូវបានចាត់ថាជារដ្ឋទី៣មានសុវត្ថិភាពឡើយ ។[408] ដូចនេះ រដ្ឋទី៣ អាចជាទីកន្លែងនៃការធ្វើទុក្ខបុកម្នេញបន្ថែមពីលើនេះ មិនអាចការពារពីការបណ្តេញចេញទៅរដ្ឋដើមកំណើត ។ អាស្រ័យហេតុនេះ ខស្តីពីរដ្ឋទី៣មានសុវត្ថិភាព ត្រូវបានអ្នកសិក្សាស្រាវជ្រាវ និងរដ្ឋខ្លះបានរិះគន់។[409]

[406] David Robertson, A Dictionary, *supra* note 395, p. 24.
[407] Mutombo v. Switzerland, Communication No. 13/1993, U.N. Doc.A/49/44 at 45 (1994), para. 10.
[408] Note on the Principle of *Non-Refoulement*, *supra* note 402 (Third Country Concept).
[409] Guy, the Refugee, *supra* note 383, pp. 340-341.

តាមរយៈយុត្តិសាស្ត្រ គេអាចសន្និដ្ឋានបានថា រដ្ឋនឹងទទួលខុសត្រូវក្នុងករណី នៃអំពើរំលោភសិទ្ធិខ្លះ ដែលរដ្ឋដទៃបានប្រព្រឹត្ត។

### ៩.១.៥.៥. ការស្នាក់នៅក្នុងទីសុវត្ថិភាពក្នុងស្រុក (Internal Flight)

ស្រដៀងនឹងខស្តីពីរដ្ឋទី៣មានសុវត្ថិភាព ការស្នាក់នៅក្នុងទីសុវត្ថិភាពក្នុងស្រុក (IF) គឺជាការវិវត្តថ្មីមួយទៀត ទាញចេញពីការអនុវត្តរបស់រដ្ឋ ក្នុងការបំពេញកាតព្វកិច្ចចែងក្នុងសន្ធិសញ្ញាឆ្នាំ ១៩៥១។ រដ្ឋទាញ IF ចេញពីមូលដ្ឋានថា ការផ្តល់ឋានៈជាជនភៀសខ្លួន ឬការមិនបញ្ជូនជនណាមួយត្រឡប់ទៅប្រទេសដើមវិញ ដោយសារជននោះគ្មានការការពារ។ ដូចនេះ ក្រោយពីការបណ្តេញទៅដល់ប្រទេសដើម បុគ្គលអាចទៅរស់នៅក្នុងទីសុវត្ថិភាពក្នុងស្រុក ឬរដ្ឋដេញទៅកាន់ទីកន្លែងនោះ រដ្ឋមិនខុសនឹងកាតព្វកិច្ចអន្តរជាតិ ជាពិសេស កាតព្វកិច្ចមិនបញ្ជូនទៅវិញទៅជួបការធ្វើទុក្ខបុកម្នេញទេ។ មូលដ្ឋាននេះ ក៏អាចនាំឲ្យបដិសេធពាក្យសុំឋានៈជាជនភៀសខ្លួន។[410] វាអាចទទួលយកបាន ក៏ប៉ុន្តែដោយពិចារណាលើ រចនាសម្ព័ន្ធគ្រប់គ្រងមានប្រសិទ្ធភាពទូទាំងប្រទេស បុគ្គលពិតជាពិបាករត់គេចណាស់ ពីការចាប់យកមកធ្វើទុក្ខបុកម្នេញដោយអាជ្ញាធរ ទោះបីរត់ទៅជ្រកនៅទីណាក្នុងដែនដីរដ្ឋ។ ម្យ៉ាងទៀត ការអនុវត្តនេះ ហាក់បង្ហាញពីភាពមិនសូវខ្វាយខ្វល់របស់រដ្ឋក្នុងការការពារសិទ្ធិរបស់ជនភៀសខ្លួន ដែលជាគោលបំណងចម្បងរបស់សន្ធិសញ្ញា ឆ្នាំ ១៩៥១។ វាប្រហែលជាបញ្ហាស្មុគស្មាញនៃ IF នេះហើយ ទើប

[410] Steve Peers and Nicola Rogers, EU Immigration and Asylum Law: Text and Commentary, 2006, p. 324.

ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកជនភៀសខ្លួន បានចេញសេចក្ដីណែនាំស្ដីពី IF។[411]

### ៩.១.៥.៦. ការសន្យាមានលក្ខណៈនយោបាយ

រដ្ឋអាចដេញជនភៀសខ្លួនទៅកាន់ ប្រទេសផ្សេងក្រោយពីមានការសន្យាថា រដ្ឋនោះមិនធ្វើទុក្ខបុកម្នេញជននោះ។ រដ្ឋដែលដេញ គិតថាការសន្យាអាចនឹងលុបបំបាត់ការធ្វើទុក្ខបុកម្នេញ។ នេះកើតមាន ក្នុងករណី ដែលអ្នកសុំសិទ្ធិជ្រកកោន អាចជាអតីតឧក្រិដ្ឋជន ដែលរដ្ឋជាប្រទេសកំណើត ចង់បាន។

ការសន្យាប្រភេទនេះ មិនមានចែងអនុញ្ញាតនៅក្នុងសន្ធិសញ្ញា ឆ្នាំ ១៩៥១ ទេ។ វាជាការអនុវត្តរបស់រដ្ឋ ដែលទាញមូលដ្ឋានចេញពី សន្ធិសញ្ញា ស្ដីពីបត្យាប័ន។ ការសន្យាមានលក្ខណៈនយោបាយ ហើយរដ្ឋសន្យា អាចក្រឡាស់សម្ដី ដោយគ្មានទទួលទោសកំហុសឡើយ។ មានយុត្តិសាស្ត្ររួចហើយ មិនទទួលស្គាល់នូវការសន្យាដោយរដ្ឋ ដោយសារភាពស្មុគស្មាញក្នុងការតាមដានការអនុវត្តតាមការសន្យា។[412]

---

[411] Guy, the Refugee, *supra* note 383, p. 75; Guidelines on International Protection: “Internal Flight or Relocation Alternative”within the Context if Article 1A(2) of the 1951 Convention and/or 1967 Protocol relating to the Status of Refugees, HRC/GIP/03/04, 23 July 2003.

[412] Human Rights Watch, “Empty Promises:” Diplomatic Assurances and the United Nations System, www.hrw.org/reports/2004/un0404/3.htm; Committee against Torture, *Hanan Ahmed Fouad Abd El Khalek Attia v. Sweden*, CAT/C/31/D/199/2002, 24 November 2003, para.13.

## ៩.២. សិទ្ធិមនុស្ស

### ៩.២.១. ប្រវត្តនៃច្បាប់សិទ្ធិមនុស្ស

មុនសង្គ្រាមលោកលើកទី ២ ការការពារ និងលើកតម្កើងសិទ្ធិមនុស្សមិនទាន់សាយភាយទំលូទូលាយ លើឆាកអន្តរជាតិនៅឡើយ។ គេឃើញមានបទប្បញ្ញត្តិស្តីពី សិទ្ធិមនុស្ស ត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ របស់ប្រទេសមួយចំនួន នៅក្នុងទ្វីបអឺរ៉ុប ដូចជាបារាំង ដែលជាលទ្ធផលនៃបដិវត្តន៍បារាំងបង្កើតនូវ សេចក្តីប្រកាស ក្នុងឆ្នាំ ១៧៨៩។[413] នាពេលនោះ បញ្ហាសិទ្ធិមនុស្ស ក្លាយជាប្រធានបទលើឆាកអន្តរជាតិនៅមានកម្រិត និងកើតមានក្នុងករណីដែលមានការប្រព្រឹត្តរបស់រដ្ឋមួយ លើប្រជាពលរដ្ឋនៃប្រទេសមួយទៀត។ ឧទាហរណ៍ ករណីប្រព្រឹត្តិផ្ទុយ ពីគោលការណ៍យុត្តិធម៌ (Denial of Justice) ដែលរដ្ឋត្រូវអន្តរាគមន៍តាមផ្លូវទូត (Diplomatic Protection) ក្នុងការការពារប្រយោជន៍របស់ពលរដ្ឋខ្លួន។[414] សន្ធិសញ្ញា បង្កើតមានឡើងសម្រាប់ គ្រប់គ្រងការប្រព្រឹត្តរបស់រដ្ឋមួយ លើប្រជាពលរដ្ឋប្រទេសមួយដែលធ្លាក់ខ្លួនជាឈ្លើយសឹក ក្នុងពេលមានសង្គ្រាម។ ទង្វើស្រដៀងគ្នានេះកើតមានពាក់ព័ន្ធ ការការពារជនភាគតិច ដែលត្រូវបានផ្លាស់ប្តូរលំនៅ ដោយសារសង្គ្រាមលោកលើកទី ១ ចូលទៅរស់នៅ ក្នុងប្រទេសមួយទៀត។ រដ្ឋពាក់ព័ន្ធបានបង្កើតសន្ធិសញ្ញាទ្វេភាគី បង្កើតកាតព្វកិច្ចទៅវិញទៅមក ក្នុង

[413] The 1958 Consitution of France; the 1789 Declaration of the Rights of Man was added as a preamble to the Constitution, *see* en.wikipedia.org/wiki/ Declaration _of_the_Rights_of_Man..

[414] The domestic remedy of State that violate rights of victim shall be resorted by that victim before State to which victim belongs or has nationality intervents (exhaustion of local remedy).

ការជានាសិទ្ធិនៃជនភាគតិច។ មានតែសន្ធិសញ្ញាលុបបំបាត់ ទាសភាពទេ ដែលមិនឆ្លុះបញ្ចាំងនូវប្រយោជន៍ សួនតួរបស់រដ្ឋ។[415]

យន្តការធានាការពារសិទ្ធិ ក៏មិនទាន់មានសម្បូរបែបដែរ នាពេលនោះ។ អង្គការសង្គមប្រជាជាតិ បានបង្កើតនូវគណៈកម្មាធិការសម្រាប់ការពារសិទ្ធិជនភាគតិច សម្រាប់ទទួល ពាក្យបណ្តឹង ពាក់ព័ន្ធការរំលោភសិទ្ធិជនភាគតិច តែទោះបីជាយ៉ាងនេះក្តី យន្តការនេះ មិនសូវមានសកម្មភាពផុសផុលទេ។ នេះដោយសារ ដំណាក់កាលលើកតម្កើងសិទ្ធិសេរីភាព ស្ថិតនៅក្នុង ដំណាក់កាលចាប់ផ្តើម ពិបាកទប់ទល់ នឹងជំហរ នៃអធិបតេយ្យភាពដាច់ខាតរបស់រដ្ឋ ការមិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ និងការយល់ឃើញរបស់រដ្ឋថា ការប្រព្រឹត្តលើប្រជាពលរដ្ឋរបស់ខ្លួន គឺជាកិច្ចការផ្ទៃក្នុង។[416]

ក្រោយសង្គ្រាមលោកលើកទី២ ដោយពិនិត្យឃើញនូវមហាវិនាសកម្ម នៃការរំលោភសិទ្ធិមនុស្ស ហើយការរំលោភសិទ្ធិមនុស្ស ក៏ជាដើមចមមួយនៃសង្គ្រាមលោកលើកទី ២ បញ្ហាការលើកកម្ពស់សិទ្ធិមនុស្ស បានក្លាយជាបញ្ហាដ៏មានសារៈសំខាន់មួយ។[417] ឯកសារសិទ្ធិមនុស្ស ជាច្រើនប្រភេទ ត្រូវបាន អនុម័ត ហើយយន្តការឃ្លាំមើលការគោរពសិទ្ធិមនុស្សកម្រិតពិភពលោក តំបន់ និងជាតិ ត្រូវបានបង្កើតឡើងផងដែរ។ បញ្ហាសិទ្ធិមនុស្ស បានក្លាយ

[415] The Slavery Convention 1926 requires State parties to take actions to protect rights of victims although they are not citizens of those States, 182 UNTS 51.
[416] Mark Gibney, *Transnational State Responsibility for violations of human rights*, 12 Harvard Human Rights Journal (1999) ,p. 269.
[417] Johannes Morsink, *world war two and the Universal Declaration*, 15 Human Rights Quarterly (1993), p. 1.

ជាបញ្ហា នៃការពិភាក្សា រិះគន់ និងដេញដោលនៅលើឆាកអន្តរជាតិជាញឹកញាប់។ ប្រទេសមួយចំនួន បានដាក់បញ្ហាសិទ្ធិមនុស្ស ចូលទៅក្នុងរបៀបវារៈកិច្ចការងារទំនាក់ទំនងអន្តរជាតិ។[418] ក្នុងករណីមានការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ អង្គការសហប្រជាជាតិ អាចប្រើប្រាស់កម្លាំងទ័ព ដើម្បីបញ្ឈប់ការបំពារបំពាន និង បង្កើតតុលាការចម្រុះជាតិ និងអន្តរជាតិ ដើម្បីកាត់ទោសបុគ្គលដែលរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ ជាការកត់សម្គាល់ដ៏មានសារៈសំខាន់ គឺថាការប្រព្រឹត្តដោយអាជ្ញាធររដ្ឋ ទៅលើប្រជាពលរដ្ឋខ្លួនឯងលែងជាបញ្ហាក្នុងស្រុកហើយ។

## ៩.២.២. ការវិវត្តនៃវិធានច្បាប់សិទ្ធិមនុស្ស និងយន្តការឃ្លាំមើលការគោរពសិទ្ធិមនុស្ស

### ៩.២.២.១. ការវិវត្តនៃវិធាន

វាជាទម្លាប់ ឬចរិតយូរមកហើយ របស់អង្គការសហប្រជាជាតិ ដែលបង្កើតនូវវិធានស្តង់ដារសម្រាប់អនុវត្តជាមុន។ នេះ ដោយអនុលោមទៅតាម អាណត្តិការងារសំខាន់មួយរបស់អង្គការសហប្រជាជាតិ គឺការរៀបចំ និងបង្កើតវិធានច្បាប់អន្តរជាតិ។ ការបង្កើតនេះចាប់ផ្តើមពី ការបង្កើតជាសេចក្តីថ្លែងការណ៍ សេចក្តីសម្រេច ដែលមិនចងជាកាតព្វកិច្ច (Soft Law) តែវាជាមូលដ្ឋានបង្កើតនូវសន្ធិសញ្ញាជាបន្តបន្ទាប់។ ឯកសារជាសេចក្តីថ្លែងការណ៍ មានសំបូរបែបច្រើនជាងប្រភេទជាសន្ធិសញ្ញា ពីព្រោះប្រភេទខាងក្រោយនេះ តម្រូវឲ្យមានចំណុចលម្អិត និងចងជាកាតព្វកិច្ច។

[418] Peter R. Baehr, *Concern for Development Aid and Fundamental Human Rights: the Dilemma as Faced by the Netherlands*, 4(1) Human Rights Quarterly, 42 (1982).

ឯកសារពាក់ព័ន្ធសិទ្ធិមនុស្ស មានច្រើនសន្ធឹកសន្ធាប់ ដែលគេអាចនិយាយថា គ្មានវិស័យដទៃណាមួយនៃច្បាប់អន្តរជាតិ មានឯកសារច្រើនដូចនេះ។ វាផ្តើមចេញពីធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ដែលមានចែងដាក់ការលើកកម្ពស់សិទ្ធិមនុស្ស ក្នុងគោលបំណងរបស់អង្គការកំពូលនេះ និងមានមាត្រាមួយចំនួនទៀត។[419] អ្នកសិក្សាស្រាវជ្រាវ អះអាងថា មាត្រាមួយចំនួនតូចនេះ មិនគ្រប់គ្រាន់ទេ ហើយខ្លឹមសារនៃមាត្រាទាំងនោះ គ្រាន់តែបានចែងពីការសន្យារបស់រដ្ឋ ក្នុងកិច្ចការងារសិទ្ធិមនុស្ស។[420] ទោះបីជាយ៉ាងនេះក្តី អ្នកស្រាវជ្រាវ គួរកត់សម្គាល់ថា បញ្ហាសិទ្ធិមនុស្ស គឺពិតជាកិច្ចការសំខាន់ហើយ ទើបត្រូវបានចាត់ចូលក្នុងបំណងរបស់អង្គការសហប្រជាជាតិ។ ដោយសារ ធម្មនុញ្ញគឺជាច្បាប់កំពូល ដូចនេះ វាមិនអាចចែងលម្អិតអំពីបញ្ហាសិទ្ធិមនុស្សបានឡើយ។ មាត្រាទាំងនេះ នឹងក្លាយជាមូលដ្ឋាន សម្រាប់ការរៀបចំ និងបង្កើតឯកសារបន្តបន្ទាប់ក្រោយមកទៀត។

បីឆ្នាំក្រោយការបង្កើតនូវធម្មនុញ្ញអង្គការសហប្រជាជាតិ ក្នុងឆ្នាំ ១៩៤៥ សេចក្តីថ្លែងការណ៍ជាសាកល ស្តីពី សិទ្ធិមនុស្ស ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ។[421] សេចក្តីថ្លែងការណ៍ គឺជាឯកសារសិទ្ធិមនុស្សអន្តរជាតិ ដ៏លម្អិតមួយលើកដំបូង។ ឯកសារនេះ បានសរសេរបញ្ចូលនូវសិទ្ធិចម្រុះ សិទ្ធិនយោបាយ[422] សេដ្ឋកិច្ច[423] សង្គមកិច្ចជាដើម[424]។ ក្នុង

---

[419] The UN Charter, *supra* note 42, Arts. 55 and 56.

[420] Menno T. Kamminga, Inter-State Accountability for violations of human rights, 1992, p. 74; L.C. Green, *General Principles of Law and Human Rights*, 8 Current Legal Problems, 1955, p. 174.

[421] The UDHR, *supra* note 371.

[422] *Id.,* Art. 21.

[423] *Id.,* Art. 23.

[424] *Id.*, Arts. 12, 22.

នោះផងដែរ ឯកសារ ក៏បាននិយាយអំពី សិទ្ធិរបស់កុមារ[425] និង ស្ត្រីក្នុងបទប្បញ្ញត្តិមួយចំនួនផងដែរ។[426] អ្វីជាការកត់សម្គាល់ សេចក្តីថ្លែងការណ៍មិនបាន ចែងឲ្យបង្កើត យន្តការអន្តរជាតិសម្រាប់ឃ្លាំមើលការលើកកម្ពស់សិទ្ធិមនុស្ស ដោយរដ្ឋទេ។ កង្វះខាតនេះ រួមជាមួយចំណងជើងនៃ ឯកសារ "សេចក្តីថ្លែងការណ៍" បានធ្វើឲ្យអ្នកសិក្សាខ្លះ គិតថា សេចក្តីថ្លែងការណ៍មិនចងជាកាតព្វកិច្ចដល់រដ្ឋ ពីព្រោះរដ្ឋមិនតម្រូវឲ្យចូលជាភាគីឡើយ ។ ទោះបីជាយ៉ាងនេះក្តី វាគឺជាជោគជ័យដ៏ធំមួយរបស់អង្គការសហប្រជាជាតិ ដែលបានអនុម័តនូវសេចក្តីថ្លែងការណ៍នេះឡើង ក្នុងបរិបទនៃសង្គ្រាមត្រជាក់ និងធ្វើឡើងក្នុងរយៈពេលដ៏ខ្លី នៃការអភិវឌ្ឍវិស័យសិទ្ធិមនុស្ស ហើយការបង្កើតនូវឯកសារជាប្រភេទសន្ធិសញ្ញាចងជាកាតព្វកិច្ចដល់រដ្ឋ ជួបប្រទះការលំបាក។ គេត្រូវចងចាំថា វិធានខ្លះ ដូចជាការហាមឃាត់អំពើទារុណកម្មចែងក្នុងសេចក្តីថ្លែងការណ៍ មានឋានៈជាវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ[427] ដែលរដ្ឋត្រូវតែគោរព ដោយមិនខ្វល់ថា វិធាននេះមាននៅក្នុងលិខិតុបករណ៍ឯកសារប្រភេទអ្វីក៏ដោយ។

កង្វះខាតយន្តការ អាចជាហេតុផលមួយ ដែលនាំឲ្យមានការបង្កើតនូវ កតិកាសញ្ញា ស្តីពី សិទ្ធិបុគ្គល និងសិទ្ធិនយោបាយក្នុងឆ្នាំ ១៩៦៧។[428] ឯកសារនេះ មាននិយាយតែអំពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងមានយន្តការ សម្រាប់តាមដានការអនុវត្តកាតព្វកិច្ចរបស់រដ្ឋជាភាគី របស់កតិកា

[425] *Id.,* Art. 25.

[426] *Id.*, Art. 16.

[427] Rhona K.M. Smith, Textbook on International Human Rights, 5th ed., 2012, p. 38.

[428] William A. Schabas, the Death Penalty as Cruel Treatment and Torture, 1996, p.30; the ICCPR, *supra* note 56.

សញ្ញា ដោយតម្រូវឲ្យរដ្ឋ រៀបចំរបាយការណ៍ និងដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្សបង្កើតតាមកតិកាសញ្ញានេះ។[429] ទោះបីជាយ៉ាងនេះក្តី យន្តការបណ្តឹងដោយបុគ្គល ប្រឆាំងនឹងរដ្ឋ មិនត្រូវបានចែងទេ ហើយត្រូវបានចែងនៅក្នុងពិធីសារបន្ថែម អនុម័តក្រោយមកទៀត។[430]

ជាបន្តបន្ទាប់ក្រោយមក ជាក់ស្តែង មានសន្ធិសញ្ញាជាច្រើន ដែលចែងផ្តោតលើសិទ្ធិរបស់ក្រុមមនុស្ស ដូចជា សិទ្ធិរបស់កុមារ[431] សិទ្ធិរបស់ស្ត្រី[432] និងសន្ធិសញ្ញាខ្លះទៀត ផ្តោតលើប្រធានបទជាក់លាក់ ដូចជា ពាក់ព័ន្ធការហាមឃាត់ទារុណកម្ម។[433] មានការអភិវឌ្ឍ ទាក់ទិននឹងយន្តការ ដូចមានចែងឯកសារមួយចំនួន ដែលត្រូវបានអនុម័តជាបន្តបន្ទាប់ ដូចជា យន្តការបណ្តឹងរដ្ឋ[434] យន្តការស៊ើបអង្កេត (Inquiry) ជាដើម។[435] យន្តការស៊ើបអង្កេត អនុញ្ញាតឲ្យស្ថាប័នសិទ្ធិមនុស្ស ទៅមើលទីកន្លែងក្នុងដែនដីរបស់រដ្ឋដែលជា កន្លែងដែលសិទ្ធិមនុស្ស ត្រូវបានចោទប្រកាន់ថាបានរំលោភបំពាន។[436] ការចុះទៅមើលនេះ ត្រូវការអនុញ្ញាតពីរដ្ឋ ដែលពាក់ព័ន្ធជាមុន។[437] រដ្ឋកម្រអនុញ្ញាតឲ្យមានការទៅពិនិត្យណាស់។ អាស្រ័យហេតុនេះ យន្តការដដែល ត្រូវបានកែសម្រួលក្នុងឯកសារក្រោយមកទៀត ដែលមិនតម្រូវឲ្យ

[429] The ICCPR, *supra* note 56, Art. 40.
[430] The Optional Protocol to ICCPR, *supra* note 56, Art.1.
[431] The CRC, *supra* note 126.
[432] Convention on the Elimination of Discrimination against Women (CEDAW), 1979, 1249 UNTS 13.
[433] The Torture Convention, *supra* note 189.
[434] *Id.*, Art. 21.
[435] *Id.,* Art. 20.
[436] *Id.*
[437] *Id.*

មានសុំការអនុញ្ញាតពីរដ្ឋជាមុនទេ មុនទៅកាន់ដែនដីរបស់រដ្ឋ។ បើរដ្ឋ ចូលជាភាគី សន្ធិសញ្ញា រដ្ឋនឹងទទួលយកយន្តការនេះ។ រដ្ឋត្រូវអនុញ្ញាតឲ្យមានការចូលទៅពិនិត្យដែនដី (កន្លែងឃុំឃាំង)។ អនុគណៈកម្មាធិការ គ្រាន់តែជូនដំណឹងដល់រដ្ឋជាមុន មុនចុះទៅពិនិត្យមន្ទីរឃុំឃាំង។[438]

ជាសរុប ទាំងឯកសារ និងយន្តការពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ត្រូវបានបង្កើត និងអនុម័ត ជាច្រើន ជាពិសេសក្រោយសង្គ្រាមលោកលើកទីពីរ។

### ៩.២.៣. ប្រភេទ នៃសិទ្ធិ

សិទ្ធិត្រូវបានបែងចែកជាច្រើនប្រភេទ។ មានសិទ្ធិនយោបាយ ដូចជា សិទ្ធិបោះឆ្នោត[439] សិទ្ធិផ្នែកវប្បធម៌ (សិទ្ធិសេរីភាពខាងសាសនា)[440] សិទ្ធិស៊ីវិល (សិទ្ធិមានគ្រួសារ)[441] សិទ្ធិសេដ្ឋកិច្ច (សិទ្ធិទទួលបានការងារ)[442]។ សិទ្ធិទាំងនេះ ត្រូវបានចាត់ថាជាសិទ្ធិបុគ្គល ដែលខុសពីសិទ្ធិរួម ដូចជាសិទ្ធិស្វ័យសម្រេចជាដើម។[443]

អ្នកសិក្សាខ្លះ បានចាត់ថ្នាក់សិទ្ធិជាបីប្រភេទ ៖សិទ្ធិជំនាន់ទី១ ទី២ និងទី៣។[444] ទី១ គឺសំដៅលើសិទ្ធិនយោបាយ។ ទី២ សិទ្ធិខាងសេដ្ឋកិច្ច និងទី៣

---

438 The Optional Protocol to the Torture Convention, December 2002, A/RES/57/199, Art. 4.

439 ICCPR, *supra* note 56, Art. 25.

440 *Id.*, Art. 18.

441 *Id.*, Art. 23.

442 International Covenant on Economic, Social and Cultutal Rights ( ICESCR), 1966, 993 UNTS 3, Art. 7.

443 ICCPR, *supra* note 56, Art. 1.

444 Manfred Nowak, Introduction to the International Human Rights Regime (Manfred, HRs Regime), 2003, p. 23; Declaration of the Rights of Man, *supra* note 413.

គឺសិទ្ធិអភិវឌ្ឍ និងទទួលបានបរិស្ថានល្អ។ ចំណាត់ថ្នាក់នេះ ប្រហែលជាផ្អែកទៅតាមពេលវេលានៃការកកើតនៃសិទ្ធិនៃប្រភេទនីមួយៗ។ ជាក់ស្តែង សិទ្ធិនយោបាយ មានប្រវត្តិកើតមានជាយូរយារមកហើយ យ៉ាងហោចណាស់តាំងពីក្រោយបដិវត្តន៍បារាំង ឆ្នាំ ១៧៨៩។[445]

អ្នកសិក្សាខ្លះ បានចាត់ជាសិទ្ធិជាមូលដ្ឋាន និងចម្បង (Basic/Fundamental Rights) ឬសិទ្ធិមានពីកំណើត (Inherent Rights)។ សិទ្ធិប្រភេទក្រោយនេះ មានដូចជា សិទ្ធិរស់រានមានជីវិត។ ពេលកើតមកមនុស្សមានជីវិតដែលត្រូវរស់រាន។[446]សិទ្ធិជាមូលដ្ឋាន ត្រូវបានកំណត់ជាសិទ្ធិសំខាន់សម្រាប់ការរស់រានមានជីវិត ដែលរដ្ឋជាទូទៅទទួលស្គាល់។ ឧទាហរណ៍ សិទ្ធិសេរីភាពរួចផុតពីអំពើទារុណកម្ម។[447] តាមន័យនេះ សិទ្ធិខ្លះ អាចស្ថិតចូលក្នុងប្រភេទទាំងពីរ។ ឧទាហរណ៍ សិទ្ធិរស់រានមានជីវិត អាចជាសិទ្ធិជាមូលដ្ឋានផង និងជាសិទ្ធិ ដែលមានស្រាប់ពីកំណើតផងដែរ។

ការកំណត់សិទ្ធិ ជួនកាលវាផ្អែកទៅតាមអាទិភាព និងស្ថានភាពរបស់ប្រទេសមួយ ឬពាក់ព័ន្ធជាមួយបញ្ហានយោបាយ។ គេអាចគិតថា សិទ្ធិដែលមានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ របស់ប្រទេសមួយ ជាសិទ្ធិមូលដ្ឋានរបស់ខ្លួន។[448] ប្រសិនបើការគិតដូចនេះ ជាការត្រឹមត្រូវ សិទ្ធិជាមូលដ្ឋាន អាចនឹងមានចំនួនច្រើន។

[445] Declaration of the Rights of Man, *id.*
[446] ICCPR, *supra* note 56, Art. 6.
[447] *Id.*, Art. 4.
[448] Jorg Menzel, *Cambodia from Civil War to a Constituiton to Constitutionalism*? in Constitutionalism in Southeast Asia, Clauspeter Hill and Jorg Menzel (Eds.), 2008, pp. 39-68, p. 55.

ការចាត់ថ្នាក់សិទ្ធិ អាចបង្ហាញពីអាទិភាព ហើយរដ្ឋអាចជំរុញ ការអនុវត្តសិទ្ធិណាមួយ ដែលខ្លួនយល់ឃើញថាសំខាន់។ ជាក់ស្តែង ជាពិសេសនៅក្នុងអំឡុងសង្គ្រាមត្រជាក់ មានការលម្អៀងដ៏ជាក់លាក់ លើប្រភេទសិទ្ធិមួយប្រភេទ។ ប្រទេសអភិវឌ្ឍ ជម្រុញឲ្យមានការគោរពសិទ្ធិនយោបាយ និងចង់ឲ្យប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសប្រកាន់យករបបកុម្មុយនីស្ត អនុវត្តន៍សិទ្ធិប្រភេទនេះឲ្យមានប្រសិទ្ធភាព។ ផ្ទុយទៅវិញ ប្រទេសកំពុងអភិវឌ្ឍ ចង់ជំរុញសិទ្ធិសេដ្ឋកិច្ចជាមុន សំដៅលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ដែលជាការងារចាំបាច់។ ការអះអាងដោយឡែកៗនេះ សុទ្ធតែមានមូលដ្ឋានដោយឡែកៗផងដែរ។ ប្រទេសអភិវឌ្ឍចង់ជំរុញសិទ្ធិនយោបាយ ពីព្រោះវានឹងជួយទ្រទ្រង់ប្រជាធិបតេយ្យ ដែលប្រទេសរបស់ខ្លួនប្រកាន់យក ក្នុងហេតុផលថា ប្រសិនប្រទេសមានប្រជាធិបតេយ្យ មានយុត្តិធម៌ ការអភិវឌ្ឍសេដ្ឋកិច្ចនឹងនាំប្រយោជន៍ដល់អ្នកគ្រប់គ្នា ហើយធ្វើឲ្យប្រទេស មានសុខសន្តិភាពពេញលេញ ជាវិជ្ជមាន (Positive Peace) និងយូរអង្វែង។ ប្រទេសកំពុងអភិវឌ្ឍ ស្ទាក់ស្ទើរក្នុងការជំរុញសិទ្ធិនយោបាយ ពីព្រោះវាអាចនាំឲ្យមានការរង្គោះរង្គើអំណាចគ្រប់គ្រងរដ្ឋរបស់ខ្លួន ដែលធ្លាប់មានបក្សតែមួយ។ ប្រទេសនេះ បានអះអាងថា ប្រទេសអភិវឌ្ឍ មិនជំរុញសិទ្ធិសេដ្ឋកិច្ច ពីព្រោះប្រទេសនេះ មិនអាចធានា សុខមាលភាពដូចគ្នារវាងប្រជាពលរដ្ឋខ្លួន និងជនចំណូលថ្មីមកពីប្រទេសកំពុងអភិវឌ្ឍ ដែលរស់នៅក្នុងប្រទេសរបស់ខ្លួន។ បញ្ហាចម្បងរបស់ ប្រទេសកំពុងអភិវឌ្ឍ គឺការអភិវឌ្ឍសេដ្ឋកិច្ច ការកសាងប្រទេស និងធានាជីវិតរបស់ប្រជាពលរដ្ឋ ជាពិសេសក្នុងករណីប្រទេសទាំងនោះ ទើបងើបចេញពីសង្គ្រាមហែកហួរ។

ទំនាស់ទ្រឹស្តី បាននាំឲ្យមានការបង្កើត គោលគំនិតជាច្រើន ដែលអាចនិយាយថា មានចរិតនយោបាយ ដូចជាភាពមិនអាចកាត់សេចក្តី ថាខុសឬត្រូវនូវសិទ្ធិសេដ្ឋកិច្ច (Non-Justiciability)តាមផ្លូវតុលាការបាន [449] ឬការអនុវត្តសិទ្ធិជំនាន់ទីមួយត្រូវធ្វើជាបន្ទាន់ និងពេញលេញ (Full and Immedia -te Implementation of Civil and Political Rights)។[450]

ទំនាស់ទ្រឹស្តីនេះ បានថមថយឥទ្ធិពល នៅក្រោយការបញ្ចប់សង្គ្រាមត្រជាក់ក្នុងឆ្នាំ ១៩៩០។ ឯកសារផែនការលើកស្ទួយ សិទ្ធិមនុស្ស ដែលជាលទ្ធផលនៃសន្និសីទពិភពលោក ស្តីពី សិទ្ធិមនុស្ស ឆ្នាំ ១៩៩៣ នៅទីក្រុង Vienna បានចែងថា *សិទ្ធិទាំងអស់មានភាពពំនាក់អាស្រ័យនឹងគ្នា និងត្រូវតែអនុវត្តព្រមគ្នា*។[451] សិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ដែលជាប្រភេទសិទ្ធិស៊ីវិល មិនអាចត្រូវបានធានាពេញលេញ ភ្លាមៗបានទេ ពីព្រោះរដ្ឋត្រូវចំណាយពេលវេលាយូរក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ក្នុងវិស័យតុលាការ ត្រូវការថវិកាដើម្បីទិញសម្ភារ បរិក្ខារសម្រាប់តុលាការធ្វើកិច្ចការនេះ។ ថវិកានេះ បានមកពីការអភិវឌ្ឍសេដ្ឋកិច្ច។ និយាយឲ្យសាមញ្ញ គឺការធានាសិទ្ធិសេដ្ឋកិច្ច។ ពាក់ព័ន្ធជាមួយភាពអាចកាត់សេចក្តី រកខុសត្រូវ

[449] International Commission of Jurists, Courts and the Legal Enforcement of Economic, Social and Cultural Rights, Comparative Experiences of Justiciability, Human Rights and Rule of Law Series: No.2, 2008, p. 1-3.

[450] The ICCPR, *supra* note 56, Art. 2; contrarily, *see* ICESCR, *supra* note 442, Art. 2.

[451] World Conference on Human Rights: Vienna Declaration and Programme of Action, *see* Ian Brownlie, Brownlie's Documents on Human Rights, 6th ed., 2010, p. 151, I (5).

ទាំងសិទ្ធិនយោបាយ និងសេដ្ឋកិច្ច សុទ្ធតែអាចដាក់ក្រោមការវិនិច្ឆ័យសេចក្តីដោយតុលាការបាន។[452]

### ៩.២.៤. បញ្ហាចម្បងមួយចំនួន

### ៩.២.៤.១. គោលការណ៍មិនរើសអើង

### ៩.២.៤.១.១. និយមន័យ

កតិកាសញ្ញា ស្តីពី សិទ្ធិនយោបាយ និងសិទ្ធិប្រជាពលរដ្ឋ ជាពិសេសមាត្រា ២ មិនបានផ្តល់ន័យថា អ្វីទៅជាការរើសអើងឡើយ។[453] ន័យនៃពាក្យនេះ អាច ត្រូវបានទាញចេញពីមាត្រា ១ របស់អនុសញ្ញា ស្តីពី ការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងផ្អែក លើពូជសាសន៍ ដែលចែងថា ៖

> *"ការរើសអើងផ្អែកលើពូជសាសន៍ មានន័យថា ជាការបែងចែក ការបដិសេធចេញ ការដាក់កម្រិត ឬការប្រព្រឹត្តល្អៀង ដោយផ្អែកទៅលើ ពូជសាសន៍ ពណ៌សម្បុរ ដើមកំណើតសង្គម... ដែលមានគោលបំណង ឬផលវិបាកនាំឲ្យមានការបដិសេធ ឬប៉ះពាល់ដល់ការទទួលស្គាល់ ការប្រោស្រ័យ ឬការប្រត្តិបត្តិក្នុងភាពស្មើគ្នានៃសិទ្ធិ និង សេរីភាព ជាមូលដ្ឋាន ក្នុងវិស័យវប្បធម៌ សង្គម សេដ្ឋកិច្ច នយោបាយ ឬវិស័យផ្សេងទៀត ក្នុងផ្អែកសាធារណៈ"*[454]

[452] The General Comment No. 9, *supra* note 222, para.10.
[453] The ICCPR, *supra* note 56.
[454] The International Convention on the Elimination of All Forms of Racial Discrimination (CERD), 1966, 660 UNTS 195, *see* also CEDAW, *supra* note 432, Art. 1.

### ៩.២.៤.១.២. មូលដ្ឋាន នៃការរើសអើង

ការបែងចែក ជាការបង្ហាញពីការចាត់នូវភាពខុសគ្នា។ ឧទាហរណ៍ បែងចែកក្រុមមនុស្សប្រភេទ ក និង ប្រភេទខ។ ការបដិសេធចេញ ជាការមិនរាប់បញ្ចូលនូវបុគ្គលណាមួយក្នុងក្រុមណាមួយ។ ការកម្រិត គឺជាការកម្រិតសិទ្ធិសេរីភាពលើក្រុមមនុស្សមួយក្រុម ហើយចំណែកឯការប្រព្រឹត្តល្អៀងគឺជាការឲ្យតម្លៃ ឬប្រយោជន៍ទៅលើបុគ្គលណាមួយ ឬក្រុមណាមួយខ្ពស់ជាងជាដើម។

មាត្រា២ បានចែងនូវមូលដ្ឋាន ដែលផ្អែកតាមមូលដ្ឋាននេះ អំពើប្រព្រឹត្តខុសគ្នាត្រូវបានកំណត់។ មូលដ្ឋានទាំងនោះរួមមាន៖ ភេទ ពណ៌ សញ្ជាតិ ដើមកំណើតសង្គម ទ្រព្យសម្បត្តិ និង ឋានៈដទៃទៀត។ ការរើសអើងផ្អែកលើភេទ ឧទាហរណ៍ អំពើ ឬ ច្បាប់ ដែលមិនអនុញ្ញាតឲ្យស្ត្រី ធ្វើការងារដោយសារជាស្ត្រីភេទ។ ដោយសារមាត្រា ២ ប្រើពាក្យ "ឋានៈដទៃទៀត" ដែលបង្ហាញពីមូលដ្ឋានច្រើនប្រភេទ ដូចនេះ គេអាចនិយាយបានថា មាត្រា ២ ហាមឃាត់ផងដែរនូវការរើសអើងលើបុគ្គលណាមួយ ដោយសារគាត់ជាជនពិការ។

### ៩.២.៤.១.៣. ការរើសអើង និង រើសអើងពូជសាសន៍

គេអាចនិយាយបានថា ការរើសអើង ជាពាក្យទូទៅ ហើយដែលឆ្លុះបញ្ចាំងអំពីករណីណាមួយ។ ឧទាហរណ៍ អាជ្ញាធរ មិនបានអនុញ្ញាតឲ្យកុមារជនជាតិអ៊ីស្លាម បានចូលរៀនទេ តែអនុញ្ញាតឲ្យកុមារកាន់សាសនាកាតូលិក បានចូលរៀន។ ការប្រព្រឹត្តខុសគ្នាទៅ លើជំពូក មនុស្សនេះ មិនផ្អែកលើហេតុផលសមស្របទេ ដោយគ្រាន់តែផ្អែកលើមូលដ្ឋានថា ក្មេងនោះជាជនជាតិអ៊ីស្លាម។ ការរើសអើងពូជសាសន៍ (Apartheid) មានចរិតលក្ខណៈធ្ងន់ធ្ងរ ជាងការរើសអើងធម្មតា (មួយករណី)។ វាមានលក្ខណៈជាប្រព័ន្ធ ទូលំទូលាយ

ឬអាចកើតចេញពីគោលនយោបាយ សម្រេចឡើងដោយ អ្នកដឹកនាំប្រទេស។ ការនិយាយយ៉ាងនេះ វាស៊ីគ្នានឹង ព្រឹត្តិការណ៍ ដែលកើតមានឡើង នៅប្រទេសអាហ្រ្វិកខាងត្បូង (South Africa) ។ ពួកស្បែកស មកពីចក្រភពអង់គ្លេស ដែលមានចំនួនតិច បានគ្រប់គ្រងដឹកនាំ ប្រជាជនដើមស្បែកខ្មៅ ដែលជាចំនួនភាគច្រើន។ ប្រជាជនស្បែកខ្មៅទាំងនេះ ត្រូវបានគេរើសអើង ជាខ្សែរសង្វាក់ និង ដោយបំពារបំពានយ៉ាងធ្ងន់ធ្ងរ ដោយមិនអនុញ្ញាតឲ្យជិះយាន សាធារណៈ ដូចជារទេះភ្លើងជាមួយនឹងក្រុមមនុស្សស្បែកស។ ក្រុមមនុស្សស្បែកខ្មៅ ត្រូវបាន មន្ត្រីសន្តិសុខ ឬប៉ូលីសធ្វើទុក្ខបុកម្នេញ ដោយសារការបំពានវិធាន។[455] ពួកស្បែកខ្មៅទាំងនោះ មិនត្រូវបានអនុញ្ញាតឲ្យធ្វើការងារសាធារណៈមានតួនាទីធំដុំទេ។ ស្ថានភាពកើតមាន ដ៏សង្វេគនេះ ក្រោយមក ត្រូវបានសហគមន៍អន្តរជាតិថ្កោលទោស ហើយទីបំផុត របបដែលប្រកាន់ការរើសអើង ត្រូវបានបញ្ចប់ នាំឲ្យប្រទេសអាហ្វ្រិកខាងត្បូង ទទួលបានឯករាជ្យភាព។ ព្រឹត្តិការណ៍នេះ នាំឲ្យមានការអភិវឌ្ឍវិធានហាមឃាត់អំពើរើសអើងផ្អែកលើពូជសាសន៍។[456]

### ៩.២.៤.១.៤. ទម្រង់ការរើសអើង អ្នកប្រព្រឹត្ត និងជនរងគ្រោះ

ជនរងគ្រោះនៃអំពើរើសអើង អាចជាពលរដ្ឋ ឬ ជនបរទេស ដែលជាជនរងគ្រោះនៃអំពើប្រព្រឹត្តខុសគ្នា ដោយសាររូបគាត់ ជាប្រជាពលរដ្ឋភេទស្រី ឬ ជាជនបរទេស។ ការប្រព្រឹត្តិខុសគ្នា អាចកើតមានឡើង រវាងជនបរទេស និង ជនបរទេស នៅក្នុងដែនដីរបស់រដ្ឋមួយ។ ឧទាហរណ៍ អាជ្ញាធររបស់រដ្ឋ បាន

[455] Apartheid in South Africa, *see* en.wikipedia.org/wiki/Apartheid_in_South-Africa, accessed on 10 Jan 2013.
[456] The CERD, *supra* note 454.

ដាក់កម្រិតការធ្វើដំណើរលើជនបរទេសមួយនៃប្រទេសមួយ តែមិនបានធ្វើដូចនេះ ទៅលើជនបរទេសមកពីប្រទេសមួយផ្សេងទៀត ទោះបីជាអ្នកទាំងពីរ ស្ថិតនៅក្នុងដែនដីរបស់ខ្លួនដូចគ្នាក្តី។ បន្ថែមពីលើនេះ អំពើប្រព្រឹត្តខុសគ្នា ក៏អាចកើតមានរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋផងដែរ។ ឧទាហរណ៍ អាជ្ញាធររដ្ឋ ចេញអត្តសញ្ញាណប័ណ្ណដល់ប្រជាពលរដ្ឋម្នាក់ ក៏ប៉ុន្តែមិនបានចេញជូនប្រជាពលរដ្ឋម្នាក់ទៀត ដោយសារ ប្រជាពលរដ្ឋរូបនោះ ប្រកាន់យកនិន្នាការនយោបាយផ្សេង។

ភាពជាម្ចាស់របស់សិទ្ធិ ដូចគ្នានឹងសិទ្ធិសេរីភាពដទៃទៀតដែរ ទាមទារនូវកាតព្វកិច្ចរបស់រដ្ឋ ជានាកុំឲ្យមានការរើសអើង ដែលអាចត្រូវបានធ្វើឡើងដោយអាជ្ញាធររដ្ឋ ឬ ជនមិនមែនជាមន្ត្រីរដ្ឋ ដូចជាប្រជាពលរដ្ឋ ឬក្រុមហ៊ុនឯកជន។ ក្រុមហ៊ុនក្នុងស្រុក អាចប្រព្រឹត្តអំពើរើសអើង លើបុគ្គលម្នាក់ ដោយសារគាត់ជាជនបរទេស។[457] ទាញចេញពីឧទាហរណ៍នេះ ការរើសអើង អាចស្តែងចេញយ៉ាងតិចក្នុងពីរទម្រង់។ វាអាចត្រូវបានមើលឃើញតាមរយៈការអនុវត្ត ឧទាហរណ៍ ទង្វើដែលមន្ត្រីពេទ្យផ្តល់សេវាថែទាំសុខភាពល្អដល់អ្នកមានជីវភាពធូរធារ ហើយមិនបានធ្វើដូចនេះចំពោះ អ្នកមានជីវភាពក្រីក្រ។ អំពើនេះ ជួនកាលមិនត្រូវបានអនុញ្ញាត ដោយច្បាប់ឡើយ។ ទីពីរ វាអាចស្តែងឲ្យគេមើលឃើញពីការប្រព្រឹត្តខុសគ្នា ចែងនៅក្នុងច្បាប់ ឧទាហរណ៍ ច្បាប់បោះឆ្នោត ជ្រើសរើសតំណាងរាស្ត្រ មិនអនុញ្ញាតឲ្យជន

[457] Louis Henkin, the international bill of rights, the covenant on civil and political rights, 1981, pp. 262-263.

បរទេស បោះឆ្នោតឡើយ។[458] ឧទាហរណ៍ ចុងក្រោយនេះ វាបង្ហាញពីការប្រព្រឹត្តខុសគ្នា រវាងជនបរទេស និង ប្រជាពលរដ្ឋ ទោះបីជា ទាំងជនបរទេស និង ប្រជាពលរដ្ឋសុទ្ធតែជាមនុស្ស។ បើយើងពិចារណាមួយភ្លែត ហើយសន្និដ្ឋានថា វាជាការរើសអើងនោះ ការរើសអើង នឹងកើតមានគ្រប់ទិសទីពេលវេលា និងករណី។ និយាយជាសាមញ្ញ បើគិតដូច្នេះ អំពើណាមួយក៏ជាការរើសអើងដែរ។ ផ្នែកខាងក្រោម នឹងបង្ហាញជូន លក្ខណវិនិច្ឆ័យដែលតាមរយៈនេះ តើការប្រព្រឹត្តខុសគ្នាប្រភេទណា ត្រូវបានចាត់ថាជាការរើសអើង ឬមិនមែនជាការរើសអើង។

### ៩.២.៤.១.៥. ការរើសអើង និងករណីលើកលែង

មុននឹងសម្រេចថាអំពើអ្វីមួយជាការរើសអើង គេត្រូវពិចារណាសំណួរចំនួនពីរៈ តើមានការប្រព្រឹត្តិខុសគ្នា រវាងបុគ្គល និង រវាងក្រុមមនុស្សផ្សេងគ្នា ផ្អែកលើមូលដ្ឋានណាមួយ ដូចជា ភេទ ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ពួកគេដែរឬទេ? បើមាន តើការប្រព្រឹត្តនោះ មានហេតុផលសមស្រប ឬសមហេតុផលដែរឬទេ?[459] បើការប្រព្រឹត្តខុសគ្នា ដោយគ្មានហេតុផលសមស្រប អំពើនោះទើបជាអំពើរើសអើង។ ផ្ទុយទៅវិញ បើការប្រព្រឹត្ត

---

[458] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ របស់កម្ពុជា មាត្រា៣៤ថ្មី ក្នុងកម្រងឯកសារច្បាប់មួយចំនួនដែលកំពុងអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៥ ទំព័រ ១៤ (កម្រងឯកសារ) ។ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០១ មាត្រា ១៩ ក្នុងកម្រងឯកសារ ទំព័រ ៩៤៣។

[459] HCR, the General Comment No. 18 : Non-Discrimination, www2.ohchr.org/English/bodies/hrc/comments.htm, para. 13; Jacobs & White, the European Convention on Human Rights (Jacobs, ECHR), 4th ed., 2006, p. 413; *Frette v. France* (App. 36515/97), Judgement of 26 February 2002, 38 EHRR 438 (2004), para. 34.

ផ្អែកលើហេតុផលសមស្រប វានឹងមិនមែន ជាការរើសអើងឡើយ។ ច្បាប់ប្រទេសជប៉ុន មុនការធ្វើវិសោធនកម្ម មិនផ្តល់សញ្ជាតិជប៉ុនដល់កូន កើតពីស្ត្រីមានសញ្ជាតិជប៉ុន ដែលរៀបការជាមួយបុរសជាជនបរទេសឡើយ។ ផ្ទុយទៅវិញ ច្បាប់ដដែលនេះ នឹងផ្តល់សញ្ជាតិជប៉ុនដល់កូនរបស់បុរសជប៉ុន ដែលកើតពីប្រពន្ធជាជនបរទេស។ បុរសជប៉ុន និង ស្ត្រីជប៉ុន សុទ្ធតែជាមនុស្ស ក៏ប៉ុន្តែ ច្បាប់បានចែងឲ្យមានការប្រព្រឹត្តខុសគ្នារវាងស្ត្រីជប៉ុន និងបុរសជប៉ុន ដោយគ្មានហេតុផលសមស្រប ក្រៅពី ភេទរបស់ប្រជាពលរដ្ឋ។ ច្បាប់ចែងរបៀបនេះ ដោយគ្មានហេតុផលសមស្រប បង្កើតបានជាការរើសអើង។ ដោយសារភាពរើសអើង សភាជប៉ុនបានសម្រេចកែសម្រួលច្បាប់នេះ។[460]

ជាសង្ខេប វាមិនមែនគ្រប់ការប្រព្រឹត្តខុសគ្នា សុទ្ធតែអាចត្រូវបានចាត់ថាជាការរើសអើងឡើយ។ គេអាចនិយាយបានម្យ៉ាងទៀតថា ការប្រព្រឹត្តខុសគ្នាខ្លះ មិនមែនជាការរើសអើងឡើយ។ មានការលើកលែងពីរប្រភេទ ចំពោះការរើសអើង ដូចមានខាងក្រោម។

### ក. ក្នុងច្បាប់

ពាក់ព័ន្ធចំណុចនេះ ច្បាប់បានកំណត់យ៉ាងជាក់លាក់ នូវការប្រព្រឹត្តខុសគ្នាទៅលើក្រុម មនុស្សទោះបីច្បាប់ មិនបានចែងនូវមូលហេតុអ្វី បានជាតម្រូវ

[460] For other discrimination issues, *see* CEDAW, Concluding Observations, CEDAW/C/JPN/CO/6, 2009, paras. 17 and 29; the Government of Japan, Human Rights Council: 16th Session, Unversal Periodic Review, Mid-term progress report by Japan on its implementation of recommendations made in May 2008, March 2011, point.5.

ឲ្យមានការប្រព្រឹត្តខុសគ្នាយ៉ាងដូចនោះ។ គេអាចយល់បាននូវមូលហេតុទាំងនោះ ប្រសិនបើពិនិត្យ និង ពិចារណាឲ្យបានហ្មត់ចត់។ កតិកាសញ្ញា ស្តីពីសិទ្ធិនយោបាយ និង ប្រជាពលរដ្ឋតម្រូវកុំឲ្យរដ្ឋជាភាគីប្រហារជីវិត ឧក្រិដ្ឋជនដែលមានអាយុក្រោម ១៨ឆ្នាំ និង នារីមានផ្ទៃពោះ។[461] កតិកាសញ្ញាក៏បានចែងតម្រូវឲ្យឃុំខ្លួនឧក្រិដ្ឋវ័យក្មេង ដាច់ដោយឡែកពីឧក្រិដ្ឋជនពេញវ័យ។[462]

## ខ. សកម្មភាពវិជ្ជមាន

មានស្ថានភាពខុសគ្នារវាងបុគ្គល និងរវាងក្រុមមនុស្សផ្សេងៗជាច្រើនទៀត។ ជាក់ស្តែង ចំនួនស្ត្រីធ្វើការងារ នៅក្នុងវិស័យសាធារណៈ អាចមានចំនួនតិចជាងបុរស។ នេះជា រឿងរ៉ាវរបស់សង្គមយូរមកហើយ។ បន្ថែមពីលើនេះ ធម្មជាតិដូចជារញ្ជួយដី ទឹកជំនន់ ដែលអាចកើតមានឡើង អាចធ្វើឲ្យប៉ះដល់ជីវភាពរបស់ប្រជាពលរដ្ឋនៅតំបន់មួយ និងធ្វើឲ្យជីវភាព របស់ពួកគាត់ដុនដាប បើធៀបនឹងជីវភាពរបស់ប្រជាពលរដ្ឋនៅតំបន់ក្បែរ ដែលមិនត្រូវបានប៉ះពាល់ដោយគ្រោះអាសន្នធម្មជាតិ។

ច្បាប់សិទ្ធិមនុស្ស និងអ្នកធ្វើច្បាប់ បានព្យាករ និងមើលឃើញអំពីសភាពដែលអាចកើតមានជាយថាហេតុនេះ និងបានដឹងអំពីការលំបាក ដែលរដ្ឋប្រឈម ក្នុងឧប្បត្តិហេតុនេះ ដែលតម្រូវឲ្យទុកច្រក និងលទ្ធភាពឲ្យរដ្ឋដោះ

461 ច្បាប់ប្រទេសខ្លះអនុញ្ញាតឲ្យប្រហារជីវិតស្ត្រីក្រោយពេលសម្រាលកូនរួច។ ទោះបីជាយ៉ាងនេះក្តី ការសម្លាប់ម្តាយអាចបំពារបំពាន សិទ្ធិគ្រួសារ (Right to Family); the ICCPR, *supra* note 56, Art. 6.

462 The ICCPR, *supra* note 56, Art. 10.

ស្រាយ។ វិធានការរបស់រដ្ឋសម្រាប់ដោះស្រាយនេះ នឹងមិនជាទង្វើរើសអើងទេ។ វាជាទម្រង់ លើកលែង ដែលមានសញ្ញាណ ជាអំពើវិជ្ជមាន ឬអំពើជួយជ្រោមជ្រែង (Affirmative/Positive Action)។[463] អំពើនេះមានគោលបំណងជួយលើកកម្ពស់ ដល់ក្រុមមនុស្សមានស្ថានភាពលំបាកដោយសារស្ថានភាព នាំឲ្យពួកគេពិបាកប្រាស្រ័យសិទ្ធិរបស់ពួកគេ។ ទង្វើជួយឲ្យពួកគេមានលទ្ធភាព ទទួលផល ពីសិទ្ធិ ហើយជួយឲ្យរដ្ឋបំពេញបានតាមកាតព្វកិច្ចពាក់ព័ន្ធ ចែងនៅក្នុងសន្ធិសញ្ញា ដែលខ្លួនបានចូលជាភាគី។ វាជួយឲ្យរដ្ឋបំពេញបានតាមគោលការណ៍ស្មើភាពគ្នារវាងបុរស និងស្ត្រី។[464] ទង្វើរបស់រដ្ឋ ជួយឲ្យស្ត្រីចូលរួម ក្នុងកិច្ចការងារសាធារណៈ ដែលពីមុនមកមានចំនួនស្ត្រីតិចតួចបានចូលរួម ជាឧទាហរណ៍មួយ ស្តីពី សកម្មភាពវិជ្ជមាន។[465] អំពើនេះ ជាការឆ្លើយតប ឬជាការកែទម្លាប់ ដែលមានពីមុនមកជាទូទៅ ដែលស្ត្រីត្រូវបានបដិសេធពីកិច្ចការងាររាជការ ដោយទុកឲ្យចូលរួមតែក្នុងកិច្ចការគាំពារគ្រួសារ។ នេះជាមូលដ្ឋានសមស្រប នៅពីក្រោយសកម្មភាពរបស់រដ្ឋ។ ទោះបីជាយ៉ាងនេះក្តី សកម្មភាពវិជ្ជមានក៏តម្រូវឲ្យមានដែនកម្រិតដែរ។ នេះមានន័យថា បើអំពើនេះ ត្រូវបានធ្វើហួសពីមូលហេតុ ឬបំណងដែលតម្រូវ វានឹងផ្ទុយគោលការណ៍សមមាត្រ។[466] ឧទាហរណ៍

[463] យោបល់ទី ១៨ របស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ស្តីពីអំពើរើសអើង។ យោបល់ ទី២៥ របស់គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិរបស់អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងមាត្រា ២៥ កថាខណ្ឌ ២៣; Louis Henkin, the bill of rights, *supra* note 457, pp. 259-260; Manfred, HRs Regime, *supra* note 444, p. 86.

[464] The ICCPR, *supra* note 56, Art. 3.

[465] The HCR, General Comment No. 25 on Article 25 (Right to Participate in Public Affairs), 1996, para. 23, www2.ohchr.org/English/bodies/hrc/comments.htm

[466] Jacobs, ECHR, *supra* note 459, p. 447.

អាជ្ញាធរបានដាក់ចេញវិធានការជំរុញឲ្យស្ត្រីចូលរួមក្នុងវិស័យការងារ ដោយបង្កើនចំនួន ស្ត្រីក្នុង ការងាររហូតដល់ ១០ពាន់នាក់ ដើម្បីឲ្យចំនួននេះ មានសមមាត្រ ឬស្រដៀងគ្នា នឹងចំនួនបុរស ដែលធ្វើការងារ។ ជាលទ្ធផលជាក់ស្តែង ចំនួនស្ត្រីចូលរួមការងារ បានកើនលើសចំនួនបុរស។ ករណី អំពើវិជ្ជមាននេះ អាចក្លាយជា អំពើរើសអើងវិញ។[467] ជាសរុប អំពើដែលអាចត្រូវបានចាត់ជា អំពើវិជ្ជមាន ក៏ត្រូវមានក្រឹត្យក្រមិ និងដែនកំណត់របស់វាដែរ។

### ៩.២.៥. ការកម្រិតសិទ្ធិ

បុគ្គលគ្រប់រូប មានសិទ្ធិ និងសេរីភាព។ ការប្រាស្រ័យនូវសិទ្ធិ ត្រូវមានការទទួលខុសត្រូវ។ នេះមានន័យថា បុគ្គលត្រូវទទួលខុសត្រូវចំពោះអំពើ ដែលនាំឲ្យមានហានិភ័យណាមួយដល់បុគ្គល សង្គម ឬប្រទេសជាតិ តាមរយៈការអនុវត្តសិទ្ធិ និងសេរីភាពរបស់ខ្លួន។ ឧទាហរណ៍ បុគ្គលមានសិទ្ធិ បញ្ចេញមតិ ក៏ប៉ុន្តែការបញ្ចេញយោបល់ តាមរយៈសារព័ត៌មានក្តី មិនត្រូវនាំឲ្យមានហិង្សា ប្រកាន់ពូជសាសន៍ទេ។ បុគ្គល ត្រូវតែទទួលខុសត្រូវ តាមច្បាប់ជាតិ។ ដូចគ្នានេះដែរ បុគ្គលមិនអាច ចូលទៅកាន់ទីកន្លែងសម្ងាត់សម្រាប់សន្តិសុខជាតិដោយគ្មានការអនុញ្ញាត ហើយនិយាយថា ខ្លួនអនុវត្តសិទ្ធិសេរីភាពដើរហើរឡើយ។ ឆ្លើយតបចំពោះបញ្ហានេះ ច្បាប់ជាតិមួយចំនួនបានចែងថា បុគ្គលត្រូវអនុវត្តសិទ្ធិរបស់ខ្លួន ដោយអនុលោមទៅតាមច្បាប់។[468] សន្ធិសញ្ញាពាក់ព័ន្ធសិទ្ធិមនុស្ស បានចែងនូវដែនកម្រិតអនុវត្តសិទ្ធិ ថាៈ *ការអនុវត្តសិទ្ធិចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ* (មាត្រា ១៩) *ត្រូវភ្ជាប់ជាមួយ*

[467] It was called: “reverse discrimination”.

[468] Article 31 of the 1993 Cambodian Constituion.

*ករណីយកិច្ច និងការទទួលខុសត្រូវជាពិសេស។ ...ការកម្រិតសិទ្ធិ ត្រូវតែចែងដោយច្បាប់និងចាំបាច់...(ខ) សម្រាប់ការការពារសន្តិសុខជាតិ...*។[469] អ្នកសិក្សាបានដាក់ការកម្រិតសិទ្ធិនេះ ជាការកម្រិតសិទ្ធិ ដែលមានជាប់ជាមួយនឹងសិទ្ធិ (Inherent Limitation/ Permissible Limitations[470])។ ទោះបីជាយ៉ាងនេះក្តី ការកម្រិតនេះ មានភ្ជាប់តែជាមួយ សិទ្ធិមួយចំនួនតូចប៉ុណ្ណោះ ដូចជា សិទ្ធិសេរីភាពជួបប្រជុំ ជាដើម។[471]

ការកម្រិតនេះ មិនមានន័យថា បុគ្គលមិនមែនជាម្ចាស់នៃសិទ្ធិទេ។ ដូច ដែលបាននិយាយនៅក្នុងកថាខណ្ឌខាងលើ ការកម្រិតគ្រាន់ តែជួយឲ្យបុគ្គលអាចប្រាស្រ័យនូវសិទ្ធិដោយសុខសន្តិភាព ហើយសម្រួលដល់រដ្ឋ តាមរយៈការចាត់វិធានការផ្លូវច្បាប់ ដើម្បីឲ្យបុគ្គល អាចទទួលផលពីសិទ្ធិរបស់ខ្លួនដោយសុខសន្តិភាព។ តាមខ្លឹមសារនៃមាត្រាដែលពាក់ព័ន្ធ ការកម្រិតសិទ្ធិត្រូវតែជាករណីលើកលែង។[472] គណៈកម្មាធិការសិទ្ធិមនុស្ស អង្គការសហប្រជាជាតិបាននិយាយថា ការអនុវត្តសិទ្ធិបុគ្គល ដោយបុគ្គល ជាវិធាន តែការកម្រិតសិទ្ធិត្រូវតែជាករណីលើកលែង។[473] នេះមានន័យថា ការកម្រិតសិទ្ធិត្រូវធ្វើជាកម្រ និងក្នុងករណីចាំបាច់។ ការកម្រិតសិទ្ធិ ត្រូវមានមូលដ្ឋានក្នុងច្បាប់ ចាំបាច់សម្រាប់គោលបំណងជាក់លាក់ ដូចជាដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ។[474] ក្នុងន័យនេះ វាតម្រូវឲ្យមានច្បាប់ចែងអនុ

[469] The ICCPR, *supra* note 56, Art. 19.

[470] Louis Henkin, the Bill of Rights, *supra* note 457, p. 290.

[471] The ICCPR, *supra* note 56, Art. 22; Jacobs, ECHR, *supra* note 459, p. 437.

[472] Loukis G. Loucaides, the European Convention on Human Rights, Collected Essays, 2007, p. 219.

[473] Manfred, HRs Regime, *supra* note 444, p. 57.

[474] The ICCPR, *supra* note 56, Art. 12.

ញ្ញាត ជាមុន ឲ្យមានការកម្រិតសិទ្ធិ។ វិធានការកម្រិត ត្រូវឆ្លើយតបទៅនឹងគោលបំណង និងភាពចាំបាច់។ នេះមានន័យថា ប្រសិនបើមានវិធានការណ៍ណាមួយ អាចត្រូវបានប្រកាន់យក ជំនួសឲ្យការកម្រិតសិទ្ធិ អាជ្ញាធរត្រូវតែប្រកាន់យកនូវវិធានការជំនួសនោះ។ វិធានការណ៍ ឬច្បាប់ ដែលត្រូវប្រកាន់យក ឬចែង មិនត្រូវមានលក្ខណៈរើសអើងឡើយ។[475] ការបកស្រាយខកម្រិតសិទ្ធិ ត្រូវបកស្រាយឲ្យបានចង្អៀត។[476]

មានភាពចម្រូងសម្រាសជាច្រើន ពាក់ព័ន្ធការបកស្រាយខកម្រិតសិទ្ធិ ជាពិសេសពាក់ព័ន្ធអ្វីទៅជាច្បាប់[477] និងអ្វីទៅជា សន្តិសុខជាតិ។[478] ដោយសារពាក្យពេចន៍ ទាំងពីរនេះ មានន័យមិនច្បាស់ អាជ្ញាធរអាចបកស្រាយពាក្យនេះ យ៉ាងទូលាយ ដើម្បីជាលេសក្នុងការកម្រិតការអនុវត្តសិទ្ធិ និងចាត់វិធានការចំពោះបុគ្គលណាមួយ ដែលធ្វើសកម្មភាពប៉ះពាល់ផលប្រយោជន៍នយោ

---

[475] The revevant provisions of ICCPR allowing inherent limitation of rights shall be interpreted in conjunction of the prohibition of non-discrimantion of the Art. 2 of the ICCPR, *see Lovelace v. Canada*, HRC, Communication No. 24/1977, HRC 1981 Report, Annex XVIII.

[476] Handbook on Procedures, *supra* note 382, para. 149; African Commission on Human Rights, Legal resources *Foundation v. Zambia*, 2001a, s. 70; UN ECOSOC, Siracusa Principles on the Limitation and Degoration Provisions in ICCPR, U.N. Doc. E/CN.4/1985/4, Annex (1985), I (A3).

[477] Inter-American Court of Human Rights, the World “Laws”in Article 30 of the American Convention on Human Rights, Advisory Opinion OC-6/86, May 9, 1986; *A v. Australia*, *supra* note 185, para. 9.5; Alexander Kiss, *Commentary by the Rapporteur on Limintation Provisions*, 17 (1) Human Rights Quarterly 1985, p. 18.

[478] Louis Henkin, the bill of rights, *supra* note 457, pp. 296-297; Alexander Kiss, *Commentary*, *supra* note 477, p. 20; Bert B. Lockwood, *Working Paper for the Committee of Experts on Limitation Provisions*, 25(4) Human Rights Quarterly 2003, p. 72.

បាយរបស់រដ្ឋ។[479] ឧទាហរណ៍ រដ្ឋអាចហាមឃាត់ ការធ្វើបាតុកម្មដោយយកលេសថា ការធ្វើដូចនេះ នឹងប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

### ៩.២.៦. ការផ្អាកអនុវត្តសិទ្ធិ

ការកម្រិតសិទ្ធិ ខាងលើ អាចកើតមាននៅក្នុងពេលធម្មតា (ពេលមានសន្តិភាព)។ ក្នុងករណីពេលសង្គ្រាម ច្បាប់សិទ្ធិមនុស្ស ក៏បានចែងអនុញ្ញាតឲ្យមានការផ្អាកការអនុវត្តសិទ្ធិមួយចំនួន ដើម្បីទុកអំណាចដល់រដ្ឋ ក្នុងការស្តារស្ថានភាពវឹកវរ។ មាត្រា៤ នៃកតិកាសញ្ញា ស្តីពី សិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ បានចែងលម្អិតអំពីបញ្ហានេះ។[480]

ដូចគ្នានឹងការកម្រិតសិទ្ធិ ការផ្អាកអនុវត្តសិទ្ធិ ត្រូវបំពេញតាមលក្ខខណ្ឌមួយចំនួន។ ស្ថានភាព ដែលវឹកវរ ត្រូវតែជាគ្រោះអាសន្នសាធារណៈ ដែលប៉ះពាល់ដល់អាយុជីវិតជាតិ។[481] អនុលោមតាមន័យនេះ មិនមែនគ្រប់ស្ថានភាពវឹកវរទាំងអស់ ដូចជា ទឹកជំនន់ អាចជាមូលដ្ឋានក្នុងការផ្អាកការអនុវត្តសិទ្ធិឡើយ។ សង្គ្រាម អាចជាស្ថានភាពវឹកវរ និង ជាគ្រោះអាសន្នសាធារណៈ។[482] អាជ្ញាធរ ត្រូវធ្វើសេចក្តីប្រកាស ដាក់ស្ថានភាព ក្នុងគ្រោះអាសន្នសាធារណៈ។ រដ្ឋដែលចាត់វិធានការផ្អាកការអនុវត្តសិទ្ធិ ត្រូវជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវជូនដំណឹង

---

[479] Alexander Kiss, *Commentary*, *supra* note 477, p. 20.

[480] The ICCPR, *supra* note 56, Art.4.

[481] *Id.*, Art. 4 (1).

[482] M. Nowak, UN Covenant on Civil and Political Rights, CCPR Commentary (2nd rev. ed.), 2005, pps. 89 and 90; Derogation from human rights treaties in situtations of emergency, *see* www.geneva-academy.ch/RULAC.

ជាបន្តទៅកាន់រដ្ឋជាភាគីទាំងអស់។ ខ្លឹមសារនៃការជូនដំណឹង ត្រូវមាននិយាយអំពីវិធានការ សិទ្ធិដែលត្រូវបានផ្អាក និង មូលហេតុនៃការផ្អាក។[483] រដ្ឋក៏ត្រូវជូនដំណឹងផងដែរ នៅពេលដែលស្ថានភាពលែងមានសភាពរឹករវ ហើយបញ្ឈប់ការប្រកាន់យកនូវវិធានការណាមួយ។[484] ការតម្រូវ ឲ្យជូនដំណឹងនេះ គឺដើម្បីអង្គការសហប្រជាជាតិ អាចជួយតាមដានឃ្លាំមើល ការវិវត្តរបស់ព្រឹត្តិការណ៍ និង ដើម្បីឲ្យរដ្ឋដទៃ អាចចាត់វិធានការជួយសង្គ្រោះប្រជាពលរដ្ឋរបស់ខ្លួន រស់នៅ ឬធ្វើការក្នុងដែនដីរបស់រដ្ឋ ដែលចាត់វិធានការផ្អាកការអនុវត្តសិទ្ធិ។

ក្នុងពេលមានគ្រោះអាសន្នសាធារណៈ រដ្ឋត្រូវបានអនុញ្ញាតឲ្យចាត់វិធានការមួយចំនួន ដែលតាមរយៈនេះ សិទ្ធិមួយចំនួន ត្រូវបានផ្អាកការអនុវត្ត។ ឧទាហរណ៍ ក្នុងពេលសន្តិភាព បុគ្គល អាចធ្វើដំណើរគ្រប់ពេលវេលា ដោយគ្មានកម្រិត ក៏ប៉ុន្តែ ក្នុងពេលមានគ្រោះអាសន្នសាធារណៈ បុគ្គលអាចត្រូវបានអនុញ្ញាតឲ្យដើរហើរត្រឹមម៉ោង ១០យប់ជាដើម។ នេះគឺជាការផ្អាកអនុវត្តសិទ្ធិ និងសេរីភាពដើរហើរជាបណ្តោះអាសន្នដោយអន្លើ។ ទោះបីជាយ៉ាងនេះក្តី មានសិទ្ធិមួយចំនួន ដែលមិនត្រូវអនុញ្ញាតឲ្យរដ្ឋផ្អាកការអនុវត្ត ទោះបីជា ប្រទេសស្ថិតនៅក្នុងស្ថានភាពគ្រោះអាសន្នសាធារណៈយ៉ាងណាក្តី។ សិទ្ធិនេះ ត្រូវបានផ្តល់ឈ្មោះថាជាសិទ្ធិដាច់ខាត (Non-Derogable Rights)។ រដ្ឋត្រូវគោរព ឲ្យបានខ្ជាប់ខ្ជួននូវសិទ្ធិទាំងនេះ។ ការធ្វើយុត្តិកម្ម

[483] The ICCPR, *supra* note 56, Art.4; HRC, the General Comment No. 29 on States of Emergency (Article 4) (the General Comment No. 29), CCPR/C/21/Rev.1/Add.11, 2001, para.17.

[484] The General Comment No. 29, *supra* note 483, para.17.

ណាមួយ ចំពោះការរំលោភសិទ្ធិដាច់ខាតនេះ នឹងមិនត្រូវទទួលយកឡើយ។ សិទ្ធិទាំងនោះមានដូចជា សិទ្ធិរួចផុតពីអំពើទារុណកម្ម សិទ្ធិរស់រានមានជីវិត ការមិន ត្រូវបានដាក់ទោសព្រហ្មទណ្ឌ ដោយសារខកខានមិនបានគោរពតាមកាតព្វកិច្ចក្នុងកិច្ចសន្យា។[485]

បើយើងពិនិត្យបញ្ជីសិទ្ធិដាច់ខាតទាំងនេះ យើងឃើញថា មានហេតុផលផ្សេងៗ នៃការចាត់ទុកសិទ្ធិណាមួយជាសិទ្ធិដាច់ខាត។ ការហាមឃាត់អំពើទារុណកម្ម ក្នុងពេលមានសង្គ្រាម នឹងជួយទប់ស្កាត់ស្ថានភាពគ្រោះអាសន្នសាធារណៈ មិនឲ្យកាន់តែរីករាល។ រីឯការមិនត្រូវបានដាក់ទោសព្រហ្មទណ្ឌដោយសារខកខានមិនបានគោរពតាមកាតព្វកិច្ចក្នុងកិច្ចសន្យា មិនពាក់ព័ន្ធជាមួយនឹងស្ថានភាពគ្រោះអាសន្នទេ ដូចនោះ មិនមានហេតុផលអ្វីត្រូវផ្អាកការអនុវត្តសិទ្ធិនេះ ក្នុងពេលមានគ្រោះអាសន្នឡើយ។ អាស្រ័យហេតុនេះ សិទ្ធិនេះ ត្រូវបានចាត់ថាជាសិទ្ធិដាច់ខាត។ តាមន័យនេះ សិទ្ធិដាច់ខាត អាចមិនមែនជាសិទ្ធិជាមូលដ្ឋាន។ ដូចនេះ ការមិនទទួលយកនូវយុត្តិកម្មណាមួយដោយសហគមន៍អន្តរជាតិ ចំពោះការរំលោភសិទ្ធិមិនសំខាន់នេះ លើកឡើងដោយអាជ្ញាធររដ្ឋ ពិតជាមិនសូវមានមូលដ្ឋានទេ។

សិទ្ធិរស់រានមានជីវិត និងសិទ្ធិរួចផុតពីអំពើទារុណកម្ម ពិតជាសំខាន់ នឹងទាក់ទងជាមួយគ្រោះអាសន្នសាធារណៈ។ ជាបឋម អ្នកសិក្សាត្រូវយល់ថា ក្នុងអំឡុងពេលគ្រោះអាសន្នសាធារណៈធ្ងន់ធ្ងរ តុលាការស៊ីវិល របស់រដ្ឋ

[485] A.A. Cancado Trindade, human rights, *Recueil des Cours*, p. 86-87, 1987; Joan Fitzpatrick, human rights in crisis (1994), p. 35; Teraya koji, *Emerging hierarchy in international human rights and beyond: from the perspective of non-derogable rights*, 12 (5) EJIL 2001, p. 927; the ICCPR, *supra* note 56, Art.4.

ដែលដាក់ប្រទេសក្នុងស្ថានភាពគ្រោះអាសន្ន មិនមានដំណើរពេញលេញទេ។ ដោយសារអេសន្តិសុខ តុលាការយោធា និងកងកម្លាំងប្រដាប់អាវុធ ត្រូវបានដាក់ឲ្យមានដំណើរការយ៉ាងសកម្មដើម្បីទប់ស្ថានការណ៍កុំឲ្យកាន់តែរីកវរ។ ប្រទេសខ្លះ ប្រើប្រាស់តុលាការបិទមុខ លាក់អត្តសញ្ញាណ ក្នុងពេលធ្វើការវិនិច្ឆ័យសេចក្តី។[486] ដើម្បីស្តារស្ថានភាពរីកវរ អាជ្ញាធរ អាចនឹងប្រើប្រាស់អំពើទារុណកម្ម ដើម្បីយកចម្លើយសារភាព សម្រាប់បង្ក្រាបបទល្មើសរបស់ក្រុមកម្លាំងប្រដាប់អាវុធបដិបក្ខ។ ជម្រើសនេះ អាចនឹងនាំឲ្យស្ថានភាពគ្រោះអាសន្នសាធារណៈធូរស្រាល តែក៏អាចកាន់តែរីកវរ ដោយសារទារុណកម្ម ត្រូវបានធ្វើចំពោះមនុស្សគ្មានទោស នាំឲ្យក្រុមបដិបក្ខកាន់តែប្រកាន់យកការសេងសឹក។ នេះហើយ គឺជាមូលហេតុ ដែលនាំឲ្យមានការហាមឃាត់ជាដាច់ខាតនូវអំពើទារុណកម្ម សូម្បីក្នុងពេលមានសង្គ្រាម។

សិទ្ធិរស់រានមានជីវិត ក៏មានសារៈសំខាន់ផងដែរ ហើយវាទាក់ទងទៅនឹងគ្រោះអាសន្នសាធារណៈ។ អ្នកសិក្សា ត្រូវចងចាំថា ទោសប្រហារជីវិតនៅតែត្រូវបានអនុញ្ញាតក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ តែការប្រហារជីវិត ត្រូវធ្វើចំពោះឧក្រិដ្ឋជន មិនរាងចាល ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ក្រោយពីវិនិច្ឆ័យសេចក្តីដោយយុត្តិធម៌ និងមានសាលក្រមជាស្ថាពរ។[487] ទោះបីជាយ៉ាងនេះក្តី ការសម្លាប់មនុស្ស ត្រូវបានហាមឃាត់ជាដាច់ខាត ក្នុងពេលមានគ្រោះ

---

[486] Commentary on Berlin Declaration, *supra* note 280, p. 27; Johann Bair, the International Covenant on Civil and Political Rights and Its (First) Optional Protocol, 2005, p. 60; HRC, General Comment No. 32, para. 23 www2.ohchr.org/English/bodies/hrc/comments.htm, Art. 14: Right to equality before courts and tribunals and to a fair trial, U.N. Doc. CCPR/C/GC/32 (2007), para. 37.

[487] The ICCPR, *supra* note 56, Art. 6.

អាសន្នសាធារណៈ។ ហេតុផលនៃការហាមឃាត់ការសម្លាប់ ដើម្បីស្តារស្ថានភាពគ្រោះអាសន្នសាធារណៈ ហើយក៏អាចជួយរដ្ឋ មិនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ ក្នុងបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ ដូចជា បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលជាលទ្ធផលនៃអំពើប្រព្រឹត្តក្នុងអំឡុងពេលគ្រោះអាសន្នសាធារណៈ។

វិធានការដែលត្រូវបានចាត់ ក្នុងពេលមានគ្រោះអាសន្ន មិនត្រូវមានចរិតរើសអើងទេ។[488] ឧទាហរណ៍ រដ្ឋមិនអាចផ្អាកអនុវត្តសិទ្ធិចំពោះក្រុមមនុស្សណាមួយ ហើយមិនកម្រិតសិទ្ធិក្រុមណាមួយ ដោយមិនមានហេតុផលសមស្រប សម្រាប់ការប្រព្រឹត្តខុសគ្នាទេ។ វិធានការ ក៏មិនត្រូវរំលោភកាតព្វកិច្ចដទៃទៀត ក្រោមសន្ធិសញ្ញាដទៃទៀត។ នេះវាពាក់ព័ន្ធដល់ការគោរពសិទ្ធិដាច់ខាត ដែលមានចែងនៅក្នុងសន្ធិសញ្ញាផ្សេង ដែលរដ្ឋជាភាគី។ ការផ្អាកអនុវត្តសិទ្ធិ ចែងក្នុងកតិកាសញ្ញា ស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ អាចខុសពីកាតព្វកិច្ច ចែងក្នុងសន្ធិសញ្ញាផ្សេង ក្នុងការគោរពសិទ្ធិដដែល។ នេះដោយសារតែ បញ្ជីនៃសិទ្ធិដាច់ខាត ក្នុងសន្ធិសញ្ញានីមួយៗខុសគ្នា។[489] ជាក់ស្តែង សិទ្ធិទទួលបានការធានាតាមផ្លូវតុលាការ ក្នុងស្ថានភាពគ្រោះអាសន្ន មិនមែនជាសិទ្ធិដាច់ខាតទេ ក្នុងកតិកាសញ្ញា ស្តីពី សិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ តែជាសិទ្ធិដាច់ខាតក្រោមកតិតាសញ្ញា សិទ្ធិរបស់

[488] The General Comment No. 29, *supra* note 483, para.8.

[489] A.A. Cancado Trindade, human rights, *Recueil des Cours*, p. 76-77, 1987; Joan F. Hartman, *Working Paper for the Committee of Experts on the Article 4 Derogation Provision*, 7 Human Rights Quarterly, 1985, p. 112.

អន្តរទ្វីបអាមេរិក។[490] ទោះបីជាយ៉ាងនេះក្តី សិទ្ធិទទួលបានការជានាតាមផ្លូវតុលាការ ត្រូវបានចាត់ថាជាសិទ្ធិដាច់ខាត។[491]

ជាចុងក្រោយ វិធានការ ត្រូវតែសមស្របតាមគោលបំណង និងចាំបាច់គ្រោះអាសន្នសាធារណៈ។[492]

### ៩.២.៧. សិទ្ធិស្វ័យសម្រេច (Right to Self-Determination)

គោលបំណងមួយ របស់អង្គការសហប្រជាជាតិ គឺ អភិវឌ្ឍន៍ទំនាក់ទំនងល្អរវាងរដ្ឋ ដោយឈរលើការគោរពគោលការណ៍ នៃសិទ្ធិស្មើគ្នា និងសិទ្ធិស្វ័យសម្រេចរបស់ប្រជាជន។[493] សិទ្ធិស្មើគ្នា និងសិទ្ធិស្វ័យសម្រេច មានទំនាក់ទំនងគ្នា។ មានសិទ្ធិស្មើគ្នា បង្ហាញពីភាពគ្មានការជិះជាន់គ្នា គឺមានសិទ្ធិស្វ័យសម្រេច។ មាត្រានេះហាក់បង្ហាញថា វាគ្រាន់តែជាគោលការណ៍ តែមិនមែនជាសិទ្ធិ ហើយប្រើក្នុងទំនាក់ទំនងរវាងរដ្ឋនឹងរដ្ឋឡើយ។ ការអះអាងថាវាគ្រាន់តែជាគោលការណ៍ ជាការសមហេតុផល ដោយសារតែ រដ្ឋដែលចូលរួមក្នុងការធ្វើសេចក្តីព្រាងធម្មនុញ្ញអង្គការសហប្រជាជាតិខ្លះ ជារដ្ឋដាក់អាណានិគម ដែលពិបាកឲ្យពួកគេយល់ព្រម ទទួលស្គាល់ថា មានសិទ្ធិស្វ័យសម្រេច ដែលបង្កើតកាតព្វកិច្ចសម្រាប់ពួកគេ។ គោលការណ៍ស្វ័យសម្រេច

---

[490] *Habeas Corpus* in Emergency Sistuation (Arts. 27(2) and 7(6) of the American Convention on Human Rights), Advisory Opinion OC-8/87, January 30, 1978, Inter-Am. Ct. H.R. (ser.A) No.8 (1978), para. 44; the General Comment No. 29, *supra* note 483, para. 15; International Commission of Jurists, Legal Commentary to the ICJ Geneva Declaration, upholding the rule of law and the role of judges and lawyers in times of crisis, Human Rights and Rule of Law Series: No. 3, 2009, pp. 84-85.

[491] Daniel O'Donnell, *Commentary by the Rapporteur on Derogation*, 7(1)Human Rights Quarterly, 1985, 29.

[492] The General Comment No. 29, *supra* note 483, para.3.

[493] The UN Charter, *supra* note 42, Art. 1(2).

អាចត្រូវបានចាត់ថា កំពុងស្ថិតនៅក្នុងដំណើរអភិវឌ្ឍន៍ទៅជាសិទ្ធិ ទាញចេញពីកាតព្វកិច្ចក្នុងសន្ធិសញ្ញា ឆ្នាំ ១៩៤៨ ដែលតម្រូវឲ្យរដ្ឋការពារក្រុមមនុស្ស។ នេះមានន័យ ថាក្រុមមនុស្សមានសិទ្ធិ។[494] ក្រោយមកទៀតឆ្នាំ ១៩៦០ មហាសន្និបាតអង្គការសហប្រជាជាតិ បានចេញសេចក្តីថ្លែងការណ៍ឆ្នាំ ១៩៦០ ដែលនិយាយអំពីសិទ្ធិស្វ័យសម្រេច ចេញពីរបបអាណានិគម និងការកាន់កាប់ដោយបរទេស។[495] គេអាចបកស្រាយថា សេចក្តីសម្រេចផ្តល់សិទ្ធិស្វ័យសម្រេចដល់ប្រជាជន។ ទោះបីជាសេចក្តីសម្រេច មានតម្លៃ[496] តែមិនចងជាកាតព្វកិច្ចឡើយ លើកលែងតែ សេចក្តីសម្រេចចងក្រងនូវអ្វី ដែលចងជាកាតព្វកិច្ចពីមុនមក ក្នុងទម្រង់ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ឋានៈជាច្បាប់ទំនៀមទម្លាប់នៃសិទ្ធិស្វ័យសម្រេច ទើបត្រូវបានអះអាងដោយតុលាការយុត្តិធម៌អន្តរជាតិ ក្នុងឆ្នាំ ១៩៧២[497] ហើយសន្ធិសញ្ញាសិទ្ធិមនុស្ស បានចែងយ៉ាងច្បាស់អំពីសិទ្ធិនេះ។[498]

សិទ្ធិនេះ គឺជាសមិទ្ធផល នៃការទាមទារដោយក្រុមរដ្ឋក្នុងប្រទេសកំពុងអភិវឌ្ឍ ដែលទើបទទួលបានឯករាជ្យ ចេញពីរបបអាណានិគម ផ្អែកតាមសេចក្តីសម្រេចរបស់ មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ ១៩៦០។

---

[494] The Genocide Convention, *supra* note 74.

[495] The Declaration on the Granting of Independence to Colonial Countries and Peoples, Resolution 1514 (XV) of 14 December 1960.

[496] ICJ, *Military Case*, *supra* note 114, pp. 106-109.

[497] ICJ, Legal Consequences for States of the Continued Presence of South Africa in Namibia Notwithstanding Security Council Resolution 276 (1970), Advisory Opinion of 21 June 1971,p. 63.

[498] The ICCPR, *supra* note 56, Art. 1.

### ៩.២.៧.១. សញ្ញាណនៃសិទ្ធិស្វ័យសម្រេច

សិទ្ធិស្វ័យសម្រេច ជាសិទ្ធិរបស់ប្រជាជន ក្នុងការប្រកាន់យកដោយសេរីនូវរបបនយោបាយ សេដ្ឋកិច្ចតាមបំណងប្រាថ្នារបស់ខ្លួន។ តាមសញ្ញាណនេះ វាជាសិទ្ធិរួមរបស់ប្រជាជន។ សិទ្ធិស្វ័យសម្រេច ឆ្លុះពីឯករាជ្យ សិទ្ធិក្នុងការទទួលបាននូវធនធានធម្មជាតិ សម្រាប់ការអភិវឌ្ឍ រួចផុតពីនឹមត្រួតត្រារបស់បរទេស។

អ្វីជាប្រជាជន គឺជាការពិបាកផ្តល់ន័យ។ ពាក្យប្រជាជន សំដៅលើមនុស្សទាំងអស់ក្នុងប្រទេសមួយ រាប់បញ្ចូលជនជាតិភាគតិច ព្រមទាំងជនជាតិដើម។ ជនជាតិភាគតិចសំដៅលើ ក្រុមមនុស្សនៃពូជសាសន៍ណាមួយ ដែលមានចំនួនតិចជាងបើធៀបជាមួយនឹងប្រជាជាតិនៃប្រទេសមួយ។ អ្នកទាំងនោះ ក៏មានសញ្ជាតិនៃរដ្ឋ ដែលខ្លួនរស់នៅ ក៏ប៉ុន្តែពួកគេអាចជាអ្នកចំណូលថ្មីមកពីប្រទេសណាមួយ។ ជនជាតិដើម ជាជនជាតិ ដែលរស់នៅលើទឹកដីកំណើតតពូជពង្សត្រកូលតាំងពីដូនតានៅក្នុងទឹកដីនោះ។ ជនជាតិដើម ក៏អាចមានចំនួនតិចដូច ជនជាតិភាគតិចដែរ។ ក្នុងករណីប្រទេស មួយត្រូវបានកាន់កាប់ដោយប្រទេសមួយទៀត ប្រជាជនដែលត្រូវ បានគេកាន់កាប់ គឺជាជនជាតិដើម ដែលមានចំនួនច្រើន។[499]

[499] The 1960 Declaration, *supra* note 495; the ICCPR, *supra* note 56, Art.1; the United Nations Declaration on the Rights of Indigenous Peoples, 13 September 2007, UNGA resolution 61/295.

## ៩.២.៧.២. សិទ្ធិស្វ័យសម្រេចក្នុងបរិបទ នៃរបបអាណានិគម និងការកាន់កាប់ដោយបរទេស

ន័យដើមនៃ សិទ្ធិស្វ័យសម្រេច ជាសិទ្ធិរបស់ប្រជាជននៃប្រទេសមួយ ស្ថិតនៅ ក្រោមការកាន់កាប់របស់ប្រទេសមួយទៀត ទាមទារឯករាជភាពពីប្រទេសដែលកាន់កាប់។ ការប្រើប្រាស់សិទ្ធិស្វ័យសម្រេច គឺជាការទាមទារឯករាជ្យពីរបបអាណានិគម ដើម្បីរៀបចំប្រទេសតាមបំណងរបស់ប្រជាជន មិនតាមការដាក់បញ្ជាពីប្រទេសណាមួយ ។ ករណី East Timor ជាឧទាហរណ៍មួយ នៃការអនុវត្តសិទ្ធិស្វ័យសម្រេច របស់ប្រជាជនដើម នៃ East Timor ពីការគ្រប់គ្រងរបស់ប្រទេស ឥណ្ឌូនេស៊ី ដែលរដ្ឋនេះ បានទន្ទ្រានកាន់កាប់ East Timor ក្នុងពេលអតីតកាល។

ការអនុវត្តសិទ្ធិនេះ មិនមានការជំទាស់ពីសហគមន៍អន្តរជាតិទេ ពីព្រោះប្រជាជន East Timor ពិតជាមានសិទ្ធិស្វ័យសម្រេច (Right to External Self-Determination) តាមច្បាប់អន្តរជាតិ ទោះបីការទាមទារត្រូវចំណាយពេលលំបាក និងជួបប្រទះ នូវឧបសគ្គជាច្រើន ដោយសារតែប្រទេស ឥណ្ឌូនេស៊ី មិនចង់ឲ្យប្រទេសនេះ ផ្តាច់ចេញពីខ្លួន។ ប្រទេសឥណ្ឌូនេស៊ី មិនអាចអះអាងថា ចលនានៃការទាមទារ ឯករាជ្យភាពរបស់ East Timor ជាការរំលោភលើអធិបតេយ្យភាពដែនដី របស់ខ្លួនឡើយ ដោយសារតែប្រជាពលរដ្ឋ East Timor មានសិទ្ធិស្របច្បាប់ ហើយសិទ្ធិជាសិទ្ធិមានតម្លៃខ្ពស់ (Peremptory Norm)។[500]

[500] ICJ, East Timor, *supra* note 34, p. 102.

### ៩.២.៧.៣. សិទ្ធិស្វ័យសម្រេច ក្រោមបរិបទនៃ របបអាណានិគម

ក្នុងខណៈបច្ចុប្បន្ននេះ មានការវិវត្តគួរឲ្យចាប់អារម្មណ៍ ពាក់ព័ន្ធជាមួយសិទ្ធិស្វ័យសម្រេច។ កូសូវ៉ូ ដែលជាផ្នែកមួយនៃអតីតសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ក្រោយការរលំទៅនៃ យូហ្គោស្លាវី បានបំបែកខ្លួនពីរដ្ឋនេះ ទោះបីមានការជំទាស់ និងបង្ក្រាបពី សាធារណរដ្ឋ Serb ដែលជារដ្ឋបន្តវេនពីយូហ្គោស្លាវីយ៉ាងណាក្តី។ Kosovo បានប្រកាសឯករាជ្យ បង្កើតរដ្ឋថ្មី។[501] ក្នុងយោបល់របស់តុលាការយុត្តិធម៌អន្តរជាតិ តុលាការនេះ បានរកឃើញថា មិនមានច្បាប់អន្តរជាតិណា ហាមឃាត់មិនឲ្យមានការប្រកាសឯករាជ្យជាឯកតោភាគីទេ។[502] តុលាការ ចង់បង្ហាញថា ការប្រកាសឯករាជ្យរបស់ Kosovo មិនខុសច្បាប់អន្តរជាតិឡើយ។ ករណីមួយទៀត គឺការបង្កើត រដ្ឋថ្មីក្នុងប្រទេស ស៊ូដង់ខាងត្បូង (South Sudan)។ អង្គហេតុទាំងពីរស្រដៀងគ្នា ក៏ប៉ុន្តែករណី South Sudan មិនមានការជំទាស់ច្រើនទេ ដោយសារ Sudan ឯកភាពឲ្យមាន South Sudan។ នេះមានន័យថា ការបង្កើតរដ្ឋថ្មីមិនប៉ះពាល់អធិបតេយ្យភាពរបស់រដ្ឋ Sudanទេ។[503] មូលហេតុនាំឲ្យមានការទាមទារបំបែកខ្លួន បង្កើតជារដ្ឋថ្មី គឺដោយសារការមិនពេញចិត្តការដឹកនាំដែលមានការបង្ក្រាបសិទ្ធិមនុស្សធ្ងន់ធ្ងរ។[504] អ្នកការពារសិទ្ធិមនុស្ស ពិតជា

[501] There are 91 States prematurely recognized Kosovo as a State; however, Kosovo was not yet admitted to the United Nations, *see* en.wikipedia.org/wiki/Kosovo_status_process#2008_Declaration_of_independence (accessed on 5 October 2012).
[502] ICJ, 2010 July 22, Accordance with international law of the unilateral declaration of independence in respect of Kosovo, p.4, *see* www.icj-cji.org.
[503] UN welcome South Sudan as 193rd Member State, the UN News Centre, *see* www.un.org/apps/news (visited on 5 October 2012).
[504] For details of study on Kosovo, *see* James Summers, Kosovo: A Precedent? 2011.

មានក្តីសប្បាយរីករាយ ក៏ប៉ុន្តែ មានបញ្ហាច្បាប់ជាច្រើនពាក់ព័ន្ធ។ ទាំងករណី Kosovo និង South Sudan តាមន័យដើមនៃសិទ្ធិស្វ័យសម្រេច ប្រជាជននៃប្រទេសទាំងពីរនេះ ពិតមែនជាជនជាតិដើម តែមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយរបបអាណានិគមទេ។ ពួកគេ គួរអាចទទួលបានតែ Autonomy ឬសិទ្ធិស្វ័យសម្រេចផ្ទៃក្នុង (Right to Internal Self-Determination) ដោយមិនចាំបាច់បំបែកខ្លួន បង្កើតរដ្ឋថ្មីឡើយ។ ប៉ុន្តែ ប្រជាជនទាំងពីរប្រទេស មិនមានតំណាងរបស់ខ្លួនក្នុងរដ្ឋាភិបាល ទទួលរងនូវការរើសអើង និងបំពារបំពានសិទ្ធិធ្ងន់ធ្ងរ ពីរដ្ឋរបស់ខ្លួន ដែលជាមូលដ្ឋាន នាំឲ្យមានការទាមទារ External Self-Determination។ មូលហេតុ និងថាតើប្រជាជនគួរទទួលបានត្រឹមសិទ្ធិ Right to Internal or External-Self Determ ination ត្រូវបានបញ្ជាក់ ដោយតុលាការកំពូលរបស់ប្រទេស កាណាដា និងគណៈកម្មការសិទ្ធិមនុស្ស សម្រាប់តំបន់អាហ្វ្រិក។[505] ក្នុងសំណុំរឿងសុំបង្កើតរដ្ឋក្នុងតំបន់ Quebec ផ្តាច់ចេញពីកាណាដា តុលារការកំពូលរបស់កាណាដា បានរកឃើញថា ប្រជាពលរដ្ឋក្នុងតំបន់នេះ មានអ្នកតំណាងក្នុងរដ្ឋាភិបាល ហើយសិទ្ធិសេរីត្រូវបានធានា។ ដូចនេះប្រជាជន កាណាដាក្នុងតំបន់ Quebec មានសិទ្ធិ Right to Internal Self-Determination តែមិនមាន Right to External Self-Determination ឡើយ។ បញ្ហាដែលមានគឺការប្រឆាំងទៅនឹងគោលការណ៍អធិបតេយ្យភាពរបស់រដ្ឋ និង ប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ ទល់នឹងប្រយោជន៍របស់ប្រជាជន ដែលចង់

[505] Katangese Peoples' *Congress v. Zaire*, African Commission on Human and Peoples' Rights, Comm. No. 75/92 (1995), para. 6; reference to Secession of Quebec, *see* en.wikipedia.org/wiki/Reference_re_Secession_of_Quebec (accessed on 5 October 2012).

មានរដ្ឋថ្មី ដោយឡែក។ ចំនួនរដ្ឋតិចតួច ដែលទទួលស្គាល់ Kosovo ថាជារដ្ឋឯករាជ្យ ឆ្លុះឲ្យឃើញនូវភាព ចម្រូងចម្រាសនេះ។

ការទាមទារបំបែករដ្ឋក្នុងករណីខាងលើ ជាបរិបទនយោបាយ។ ផ្អែកតាមទិដ្ឋភាព ខាងសិទ្ធិសេដ្ឋកិច្ច និងសង្គមវិញ ប្រជាពលរដ្ឋមានសិទ្ធិលើធនធានធម្មជាតិ ដើម្បីការអភិវឌ្ឍក្នុងដែនដី ដែលខ្លួនរស់នៅ។ ទោះបីជាផ្លូវច្បាប់ មិនមានបញ្ហា តែការអនុវត្តពិតជាមានការលំបាក ពីព្រោះប្រជាជនអាចត្រូវបានអ្នកដឹកនាំ ដកហូតនូវសិទ្ធិទទួលបានផលពីធនធានធម្មជាតិ។

ជាសរុបមកដល់ពេលនេះ សិទ្ធិស្វ័យសម្រេច មានការអភិវឌ្ឍជាច្រើន។ ប្រជាជន ដែលជាអ្នកមានសិទ្ធិ គឺប្រជាជនដើម និង ជនភាគតិចផងដែរ។ សម្រាប់ប្រជាជនប្រភេទក្រោយនេះ គឺក្នុងករណី មានការបង្ក្រាបរើសអើងធ្ងន់ធ្ងរលើពួកគេ។ ពួកគេអាចទាមទារឲ្យមានការបង្កើតរដ្ឋមួយផ្សេងដោយឡែក។ បញ្ហាតម្លៃ និងសេចក្តី ថ្លៃថ្នូររបស់មនុស្ស គឺជាកត្តាសំខាន់។ ការបញ្ចៀសកុំឲ្យមានការបំបែករដ្ឋ គឺការធានា និងគោរពសិទ្ធិមនុស្ស។ ការបំបិទសិទ្ធិសេរីភាព និង បង្ក្រាបលើមនុស្ស អាចនាំឲ្យមានអន្តរាគមន៍ដោយរដ្ឋដទៃទៀត អង្គការតំបន់[506] ឬដោយអង្គការសហប្រជាជាតិ។ ថ្វីត្បិតតែ ប្រជាជនមានសិទ្ធិស្វ័យសម្រេចមែន ការអនុវត្តសិទ្ធិនេះ ត្រូវជៀសឲ្យបាននូវការប្រើកម្លាំង និងការប្រព្រឹត្តបទឧក្រិដ្ឋ បើមិនដូចនេះទេ ក្រុមទាមទារឯករាជ្យ អាចត្រូវបាន ចោទថាបានប្រព្រឹត្តអំពើភេរវកម្ម។ ការធ្វើរដ្ឋ

[506] Report of the Secretary-General, Implementing the responsibility to potect, A/63/677, 2009, paras. 28-29; Draft resolution referred to the High-level Pelnary Meeting of the General Assembly by the General Assembly ay its fifty-ninth session, 2005 World Summit Outcome, A/60/L.1.

ប្រហារ ត្រូវបានចាត់ថា ជាការផ្ទុយនឹងរដ្ឋធម្មនុញ្ញ ហើយរដ្ឋជាសមាជិករបស់សហភាព អាហ្វ្រិក នឹងមិនទទួលស្គាល់របប ដែលកើតឡើងតាមរយៈមធ្យោបាយនេះឡើយ។[507]

### ៩.២.៨. ភាតព្វកិច្ចរបស់រដ្ឋ

រដ្ឋមានកាតព្វកិច្ចជាច្រើនប្រភេទ មានចែងក្នុងសន្ធិសញ្ញា ដែលរដ្ឋជាភាគី ឬអនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ វាអាចជាកាតព្វកិច្ចធ្វើ ឬវិសោធនកម្មច្បាប់ជាដើម។

ផ្អែកតាមគោលការណ៍ទទួលយកកាតព្វកិច្ចដោយស្ម័គ្រចិត្ត រដ្ឋត្រូវតែអនុវត្តតាមកាតព្វកិច្ចដោយសុទ្ធចិត្ត[508] ហើយមិនអាចលើកយកច្បាប់ក្នុងស្រុកមកសំអាង ដើម្បីធ្វើយុត្តិកម្មចំពោះការរំលោភកាតព្វកិច្ចរបស់ខ្លួនឡើយ។[509] កាតព្វកិច្ចមានច្រើនប្រភេទ។ វាជាកាតព្វកិច្ច ទម្រង់ជាមធ្យោបាយ (Obligation of Means) ឬជាកាតព្វកិច្ចទាមទារឲ្យសម្រេច នូវលទ្ធផលអ្វីមួយ (Obligation of Result)។[510] កាតព្វកិច្ចខ្លះ ជាកាតព្វកិច្ចធម្មតា (មិនដាច់ខាត)។ ប៉ុន្តែ កាតព្វកិច្ចប្រភេទខ្លះទៀតជាកាតព្វកិច្ចដាច់ខាត ដែលទាញចេញពីសិទ្ធិដាច់ខាត។ កាតព្វកិច្ចប្រភេទនេះ ទាមទារឲ្យរដ្ឋត្រូវ

---

[507] Issaka K. Souare, *the AU and the challenge of unconstitutional changes of government in Africa*, 197 Institute for Security Studies (2009); African Commission on Human and Peoples'Rights, Resolution on the Unconstitutional Change of Governments, 51st Ordinary Session, May 2012, *see* www.achpr.org/sessions/51st/resolutions/213/.

[508] The VCLT, *supra* note 36, Art. 26.

[509] *Id.,* Art. 27.

[510] Pierre-Marie Dupuy, *reviewing the difficulties of codification: On ago's classification of obligations of means and Obligations of Result in relation to State Responsibility*, 10 EJIL (1999), p. 378.

គោរព ហើយមិនអាចលើកយកហេតុផលណាមួយ មកដោះសារក្នុងករណីមិនបានបំពេញតាមកាតព្វកិច្ចនេះឡើយ។ ទោះបីជាយ៉ាងនេះក្តី កាតព្វកិច្ចប្រភេទនេះ មិនសូវសម្បូរបែបទេ។

ជាចុងក្រោយ អ្នកស្រាវជ្រាវ បានចាត់ប្រភេទកាតព្វកិច្ចជាកាតព្វកិច្ចអវិជ្ជមាន (Negative Obligation) ឬ កាតព្វកិច្ចវិជ្ជមាន[511] (Positive Obligation)។ កាតព្វកិច្ចទាំងពីរនេះ ទាញចេញពីវិស័យសិទ្ធិមនុស្ស។ កាតព្វកិច្ចអវិជ្ជមាន មិនតម្រូវឲ្យមានសកម្មភាពយ៉ាងសកម្មពីរដ្ឋទេ។ រដ្ឋអាចគ្រាន់តែធ្វើច្បាប់ ឬណែនាំមន្ត្រីរបស់ខ្លួនមិនឲ្យបំពានសិទ្ធិ។ ជាមួយគ្នានេះដែរ រដ្ឋនឹងមិនលូកដៃក្នុងការបំពានសិទ្ធិរបស់បុគ្គល ដោយបុគ្គល ដែលគេចាត់ថាជាកិច្ចការឯកជន (Private Sphere)។ ការមិនជ្រៀតជ្រែកក្នុងជីវិតឯកជនមានប្រវត្តិជាយូរមកហើយ ហើយទាញចេញជាចម្បងពីខ្លឹមសារនៃការលើកកម្ពស់សិទ្ធិមនុស្ស (Promotion of Human Rights) ដែលជាសំខាន់ទាមទារឲ្យមាននូវការផ្សព្វផ្សាយ ឬបណ្តុះបណ្តាលសិទ្ធិមនុស្ស។ កាតព្វកិច្ចវិជ្ជមាន ជាកាតព្វកិច្ចមួយ ត្រូវបានបង្កើតនាពេលបច្ចុប្បន្ន ដែលទាមទារឲ្យរដ្ឋសកម្មក្នុងការការពារសិទ្ធិមនុស្ស (Proactive)។ ក្នុងបរិបទនេះ រដ្ឋត្រូវធ្វើអន្តរាគមន៍ សូម្បីក្នុងទំនាស់រវាងបុគ្គល ដើម្បីធានាថាជនរងគ្រោះត្រូវទទួលបាននូវសំណងសមស្រប។ នេះតម្រូវឲ្យរដ្ឋ ធ្វើហួសពីការគ្រាន់តែបង្កើត ច្បាប់ក្នុងក្រដាស ទៅជាការអនុវត្តមានប្រសិទ្ធភាព ដូចជាការស៊ើបអង្កេត និងដាក់ទោសទណ្ឌលើអ្នកប្រព្រឹត្តល្មើសនឹងច្បាប់។ កាតព្វកិច្ចនេះ

[511] *X and Y*, *supra* note 192, para. 23.

ទាញចេញពីខ្លឹមសារនៃការធានា និងការពារសិទ្ធិមនុស្ស (Ensure and Protect Human Rights)។

ដូចបានបរិយាយរួចមកហើយ រដ្ឋត្រូវគោរពកាតព្វកិច្ចអន្តរជាតិ។ ការរំលោភកាតព្វកិច្ច នឹងនាំឲ្យរដ្ឋទទួលខុសត្រូវ។ ទោះបីជាយ៉ាងនេះក្តី វាអាស្រ័យទៅតាមប្រភេទនៃកាតព្វកិច្ច ដែលពាក់ព័ន្ធ។ ក្នុងករណីខ្លះ ការរំលោភ អាចត្រូវបានរកឃើញថាមិនខុសឆ្គងទេ ដោយផ្អែកលើយុត្តិកម្ម។

### ៩.២.៩. សិទ្ធិទទួលបានដំណោះស្រាយមានប្រសិទ្ធភាព

សិទ្ធិនេះ ទាញចេញពីកាតព្វកិច្ចផ្តល់ប្រសិទ្ធភាពដល់កាតព្វកិច្ច (Obligation to Give Effect)។ កាតព្វកិច្ចនេះ ទូលំទូលាយ គ្របក្រសោបទាំងកាតព្វកិច្ចជាមធ្យោបាយ និង កាតព្វកិច្ចជាលទ្ធផល។ អាស្រ័យហេតុនេះ សិទ្ធិទាញចេញពីកាតព្វកិច្ចនេះ មានការពិបាកក្នុងការធានាការអនុវត្តឲ្យបានពេញលេញ ១០០ ភាគរយ សូម្បីក្នុងប្រទេសអភិវឌ្ឍ។

សិទ្ធិទទួលបានដំណោះស្រាយមានប្រសិទ្ធភាព ជាសិទ្ធិរបស់ជនរងគ្រោះ នៃអំពើរំលោភបំពានសិទ្ធិមនុស្ស ទទួលបានសំណងសមស្រប និងយុត្តិធម៌ចំពោះអំពើបំពារបំពានលើខ្លួន។ សំណងត្រូវប្រកាស ដោយតុលាការឯករាជ្យមានសមត្ថភា សមត្ថកិច្ច និងមិនលម្អៀង។ សេចក្តីសម្រេច អំពី សំណង ត្រូវតែអនុវត្តបាន និងជាក់ស្តែង។ ក្រៅពីសំណង ជនល្មើស ត្រូវតែបានផ្តន្ទាទោស ចំពោះអំពើល្មើសរបស់ខ្លួន ដើម្បីធានានូវនីតិរដ្ឋ និងភាពស្មើភាពគ្នាចំពោះមុខច្បាប់។ ពិចារណាលើវិសាលភាពនេះ សិទ្ធិនេះតម្រូវឲ្យមានយន្តការមានប្រសិទ្ធភាព ច្បាប់គ្រប់គ្រាន់ និងអនុវត្តយ៉ាងមានប្រសិទ្ធភាព។

ការអនុវត្តសិទ្ធិនេះ ជារួម មិនមែនជាការងារងាយស្រួលទេ។ ដូច្នេះ ប្រទេសទាំងអស់ មិនថាប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសអភិវឌ្ឍ មិនអាចគោរពតាមសិទ្ធិនេះបានមួយរយភាគរយ គ្រប់ពេលវេលា និងទីកន្លែងឡើយ។

### ៩.២.១០. យន្តការពិនិត្យមើលការប្រតិបត្តសន្ធិសញ្ញាសិទ្ធិមនុស្ស

សន្ធិសញ្ញាច្បាប់សិទ្ធិមនុស្ស ត្រូវបានអនុម័ត ដោយអង្គការសហប្រជាជាតិ ហើយតម្រូវឲ្យរដ្ឋជាភាគីគោរព និងអនុវត្តតាមកាតព្វកិច្ចយ៉ាងពេលលេញនៅថ្នាក់ជាតិ។ រដ្ឋអាចអនុវត្ត ឬមិនអនុវត្តតាម។ អាស្រ័យហេតុនេះ វាតម្រូវឲ្យ មានយន្តការរបស់អង្គការសហប្រជាជាតិ សម្រាប់តាមដានការអនុវត្តការគោរព សិទ្ធិ ដោយអាជ្ញាធររដ្ឋ។ យន្តការត្រូវបានបង្កើតជាយូរ មកហើយតាំងពីក្រោយសង្គ្រាមលោកលើកទី១ ក៏ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព និងសម្បូរបែបទេ។ យន្តការ អាចត្រូវបានគេចាត់ ជាពីរប្រភេទគឺ យន្តការបង្កើតតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ (UN-Charter Based Mechanism) និង យន្តការបង្កើតតាមសន្ធិសញ្ញា (Treaty Based Mechanism)។

#### ៩.២.១០.១. យន្តការបង្កើតតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ

ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ បានចែងនូវគោលបំណង ស្តីពី ការលើកកម្ពស់សិទ្ធិមនុស្ស ព្រមទាំងបទប្បញ្ញត្តិមួយចំនួន ដែលនិយាយអំពីកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ ក្នុងការលើកកម្ពស់សិទ្ធិមនុស្ស។[512] ដើម្បី

[512] The UN Charter, *supra* note 42, Arts. 1, 55 and 56.

សម្រួលការងាររួមរបស់អង្គការសហប្រជាជាតិ មហាសន្និបាតអង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើង ហើយនៅក្រោមស្ថាប័ននេះ មានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច (Economic and Social Council: ECOSOC)។[513] នៅក្រោមក្រុមប្រឹក្សានេះ មានបង្កើតគណៈកម្មការសិទ្ធិមនុស្ស (Human Rights Commission)។[514] គណៈកម្មការ មានស្ថាប័ន និងការិយាល័យជាច្រើន រួមទាំងក្រុមការងារ ដែលពិនិត្យស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសណាមួយ (Country Rapporteur)[515] ពិនិត្យលើប្រធានបទនៃសិទ្ធិណាមួយ (Thematic Rapporteur)។[516] គណៈកម្មការ មានការងារផងដែររៀបចំធ្វើសន្ធិសញ្ញាសិទ្ធិមនុស្ស។

គណៈកម្មការសិទ្ធិមនុស្ស ត្រូវបានប្តូរទៅជាក្រុមប្រឹក្សាសិទ្ធិមនុស្ស (Human Rights Council) នាពេលថ្មីៗនេះ។[517] ស្ថាប័ននេះ គឺជាស្ថាប័ននយោបាយ ពីព្រោះ សមាសភាពជាតំណាងរបស់រដ្ឋ ធ្វើការងារជាប្រយោជន៍របស់រដ្ឋ។ មានការចោទប្រកាន់ថាស្ថាប័ននេះធ្វើការងារក្នុងលក្ខណៈស្តង់ដារពីរ (Double Standards)។[518] សេចក្តីសម្រេចរបស់គណៈកម្មការ មិនចងជាកាតព្វកិច្ចទេ។ ទោះបីជាយ៉ាងនេះក្តី យន្តការនេះ នៅតែមានសារៈសំខាន់ ពីព្រោះ ស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសទាំងអស់ ត្រូវបានគេលើកយកមកពិនិត្យ ដែលធ្វើឲ្យរដ្ឋស្ថិតនៅក្រោមការពិភាក្សា នឹងមានការប្រយ័ត្ន

---

[513] Manfred, HRs Regime, *supra* note 444, p. 105.
[514] *Id.*
[515] Manfred, HRs Regime, *supra* note 444, p. 105; for details, *see* Dr. Bertrand G. Ramcharan, the Protection Roles of the UN Human Rights Special Procedures, 2009.
[516] Manfred, HRs Regime, *supra* note 444, p. 105.
[517] General Assembly, Resolution 6-/251, A/RES/60/251 (2006), para. 1.
[518] Manfred, HRs Regime, *supra* note 444, p. 114.

ប្រយែង ហើយរដ្ឋនឹងពិចារណារិះរកយន្តការការពារសិទ្ធិមនុស្សឲ្យបានល្អប្រសើរ។ ជាបណ្ដើរៗ ស្ថានភាពសិទ្ធិមនុស្ស នឹងកាន់តែប្រសើរ។ ជាចុងក្រោយ យន្តការនេះ អនុវត្តចំពោះគ្រប់រដ្ឋជាភាគីរបស់អង្គការសហប្រជាជាតិ។[519]

### ៩.២.១០.២. យន្តការបង្កើតតាមសន្ធិសញ្ញា

យន្តការប្រភេទនេះ ត្រូវបានបង្កើតជាច្រើន ក្រោយសង្គ្រាមលោកលើកទីពីរ នៅខណៈដែលសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើន ត្រូវបានអនុម័តឡើង។ យន្តការនេះ ត្រូវបានបង្កើតឡើងដោយផ្អែក តាមសន្ធិសញ្ញានីមួយៗ។ មានយន្តការចំនួន ៥ប្រភេទ។ ប្រសិនបើអ្នកសិក្សាពិនិត្យ និងពិចារណាឲ្យស៊ីជម្រៅ យន្តការទាំងនេះ មានការវិវត្តឥតឈប់ឈរ សំដៅធ្វើឲ្យយន្តការកាន់តែមានប្រសិទ្ធភាពក្នុងការធានាការការពារ និងគោរពសិទ្ធិមនុស្ស។ អនុសញ្ញាស្ដីពី ការប្រឆាំងអំពើទារុណកម្ម បង្កើតនូវយន្តការស៊ើបអង្កេត។[520] ក្នុងនោះ គណៈកម្មាធិការ ប្រឆាំងនឹងអំពើទារុណកម្ម អាចចុះទៅពិនិត្យទីកន្លែង ដែលត្រូវបានចោទថាមានការប្រព្រឹត្តអំពើទារុណកម្ម ប្រសិនបើរដ្ឋអនុញ្ញាត។ បទពិសោធបង្ហាញថា រដ្ឋកម្រនឹងអនុញ្ញាតឲ្យគណៈកម្មាធិការ ចុះទៅពិនិត្យទីកន្លែងក្នុងដែនដីរបស់ខ្លួនណាស់។ រដ្ឋមុននឹងអនុញ្ញាត ឲ្យមានការចុះទៅពិនិត្យ អាចបំបាត់ភស្តុតាងនៃអំពើទារុណកម្ម។ ក្រោយមក យន្តការចុះទៅពិនិត្យ ត្រូវបានបង្កើតឡើង ដែលអនុញ្ញាតឲ្យអនុគណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម ចុះទៅមើលកន្លែងឃុំខ្លួនមនុស្ស ដោយមិន

[519] *Id.,* p. 115.

[520] The Torture Convention, *supra* note 189, Art. 20.

ចាំបាច់មានការអនុញ្ញាតជាមុនពីរដ្ឋ។[521] យន្តការនេះ មានភាពបត់បែនសម្រាប់រដ្ឋ។ ជាក់ស្តែង ក្រោយពីចូលជាធរមាន សន្ធិសញ្ញាពាក់ព័ន្ធ ទុកពេលដល់រដ្ឋសម្រាប់ធ្វើកិច្ចការងារ ដូចជារៀបចំបង្កើតយន្តការក្នុងស្រុក មុននឹងអនុវត្តពេញលេញនូវយន្តការរបស់សន្ធិសញ្ញា។[522]

### ៩.២.១០.២.១. របាយការណ៍

រដ្ឋជាភាគី ក្រោយពីចូលជាភាគី ត្រូវដាក់របាយការណ៍ ស្តីពី ការអនុវត្តតាមកាតព្វកិច្ច ដែលចែងមាននៅក្នុងកតិកាសញ្ញា។ រដ្ឋ ត្រូវដាក់លើកទី១ មួយឆ្នាំក្រោយពីការចូលជាភាគី និង ៤ឆ្នាំ ជាបន្តបន្ទាប់។[523] ទោះបីជាយ៉ាងនេះក្តី រយៈពេលនេះ អាចប្រែប្រួលទៅតាមការកំណត់របស់សន្ធិសញ្ញានីមួយៗ។ គណៈកម្មាធិការ ក៏អាចទាមទារឲ្យរដ្ឋជាភាគី ដាក់នូវរបាយការណ៍ពិសេស ដែលខ្លួនគិតថាចាំបាច់។[524]

គណៈកម្មាធិការទទួលខុសត្រូវ បានដាក់ចេញនូវ សេចក្តីណែនាំ ដែលក្នុងនោះមាននិយាយអំពី ខ្លឹមសារនៃរបាយការណ៍ ដែលរដ្ឋត្រូវធ្វើតាមនាពេលរៀបចំរបាយការណ៍។[525] សម្រាប់របាយការណ៍ដំបូង នៅក្នុងសេចក្តីផ្តើម រដ្ឋត្រូវបរិយាយនូវ សាវតាប្រទេស អំពីរបបនយោបាយ ប្រព័ន្ធច្បាប់ជាដើម។ នៅក្នុងផ្នែកទី ២នៃរបាយការណ៍ដំបូង រដ្ឋត្រូវបរិយាយ អំពីការអនុវត្ត

[521] The OP to the Convention against, *supra* note 438, Art. 4.
[522] *Id.,* Art. 24.
[523] The ICESCR, *supra* note 442, Art. 16; ICCPR, *supra* note 56, Art. 40.
[524] ICCPR, *supra* note 56, Art. 40.
[525] Treaty-Specific Guidelines regarding the Form and Content of Periodic Reports to Be Submitted by States Parties under Article 44, paragraph 1(b), of the Convention on the Rights of the Child, 23 November 2010, CRC/C/58/Rev.2.

មាត្រានីមួយៗ ដោយបញ្ចូលវិធានការច្បាប់ ព្រមទាំងទិន្នន័យពាក់ព័ន្ធនឹងការអនុវត្តនៃមាត្រានីមួយៗ។ រដ្ឋក៏ត្រូវ បង្ហាញពីការលំបាក បញ្ហាប្រឈមក្នុងដំណើរការអនុវត្តតាមសន្ធិសញ្ញា។ ជាចុងក្រោយ រដ្ឋត្រូវដាក់នូវឯកសារដែលពាក់ព័ន្ធជាឧបសម្ព័ន្ធភ្ជាប់ជាមួយរបាយការណ៍ នាពេលដាក់របាយការណ៍ជូនគណៈកម្មាធិការ។

ក្រោយពីរដ្ឋដាក់របាយការណ៍រួច គណៈកម្មាធិការនឹងតែងតាំង សមាជិកម្នាក់របស់ខ្លួនឲ្យសិក្សារបាយការណ៍របស់រដ្ឋ រួចចេញនូវបញ្ជីសំណួរ (List of Issues)[526] សម្រាប់បញ្ជាក់នូវបញ្ហាមិនច្បាស់ក្នុងរបាយការណ៍ ដែលរដ្ឋត្រូវឆ្លើយតបជាមុន មុននឹងចូលរួមក្នុងការពិនិត្យរបាយការណ៍ផ្ទាល់ ឬឆ្លើយក្នុងអំឡុងពេលពិនិត្យ។ តាមកាលបរិច្ឆេទកំណត់ គណៈកម្មាធិការនឹងពិនិត្យរបាយការណ៍ ដោយគ្មានឬមានតំណាងរបស់រដ្ឋចូលរួម។ បេសកកម្មប្រចាំនៅទីក្រុងហ្សឺណែវអាចចូលរួមជំនួស។ ក្នុងពេលពិនិត្យជាក់ស្តែង គណៈកម្មាធិការនឹងអញ្ជើញតំណាងរបស់រដ្ឋឲ្យបង្ហាញជាសង្ខេប នូវរបាយការណ៍ ប្រសិនបើមានវត្តមាន បន្ទាប់មកសមាជិកគណៈកម្មាធិការ នឹងឆ្លាស់គ្នាលើកជាសំណួរ ដល់តំណាងរដ្ឋ ដែលតំណាងរដ្ឋអាចឆ្លើយ ឬមិនឆ្លើយ។ ក្នុងករណីខាងក្រោយនេះ រដ្ឋអាចសន្យាថា នឹងឆ្លើយជាលាយលក្ខណ៍អក្សរ ហើយបញ្ជូនមកគណៈកម្មាធិការនាពេលក្រោយ។ គណៈកម្មាធិការ នឹងចេញនូវសេចក្តីសង្កេត និងសន្និដ្ឋានចុងក្រោយ ពាក់ព័ន្ធនឹងការពិនិត្យរបាយការណ៍របស់រដ្ឋ។[527] សេចក្តីសង្កេត មានបង្ហាញពីសេចក្តីផ្តើម ដោយ

[526] Overview of the working methods of the Committee on the Rights of the Child, part B. constructive dialogue, at www2.ohchr.org/English/bodies/ crc/ workingmethods.htm.

[527] Concluding Observations of the Committee against Troture, CAT/C/KHM/CO/2.

បង្ហាញពីការខកចិត្ត នូវការដាក់របាយការណ៍យឺត ការធ្វើរបាយការណ៍រួមបញ្ចូលគ្នា ការណ៍ដែលរបាយការណ៍ មិនមានត្រឹមត្រូវតាមសេចក្តីណែនាំ ឬអាចជាការសរសើរក្នុងករណីរដ្ឋបានបំពេញតាមសេចក្តីណែនាំ ហើយមានកិច្ចសហការល្អពីតំណាងរបស់រដ្ឋបានល្អ ក្នុងពេលពិនិត្យ និងពិភាក្សារបាយការណ៍។[528] ផ្នែកទី២ រៀបរាប់អំពី បញ្ហាប្រឈមរបស់រដ្ឋ ក្នុងការអនុវត្តតាមសន្ធិសញ្ញា ដូចជា ស្ថានភាពប្រទេសទើបងើបពីសង្គ្រាមជាដើម។ ទោះបីជាយ៉ាងនេះក្តី ស្ថានភាពនេះ មិនត្រូវបានគណៈកម្មាធិការទទួលយកជា យុត្តិកម្មក្នុងការខកខានមិនបានអនុវត្តតាមខសន្ធិសញ្ញារបស់រដ្ឋឡើយ។[529] សេចក្តីសន្និដ្ឋាន បានសរសេរបញ្ចូលនូវចំណុចវិជ្ជមាន និងអវិជ្ជមានពាក់ព័ន្ធការអនុវត្តតាមសន្ធិសញ្ញា ព្រមទាំងអនុសាសន៍ ដែលពាក់ព័ន្ធ។[530] ដើម្បីបង្កើតនូវសេចក្តីសន្និដ្ឋាន គណៈកម្មាធិការ ក៏បានពិនិត្យមើលឯកសារពាក់ព័ន្ធផងដែរ ដូចជារបាយការណ៍របស់សង្គមស៊ីវិល (Shadow Report)។[531]

តាមខ្លឹមសារនៃសន្ធិសញ្ញាដែលពាក់ព័ន្ធសេចក្តីសន្និដ្ឋានមិនចងជាកាតព្វកិច្ចទេ តែទោះបីជាយ៉ាងនេះក្តី សេចក្តីសន្និដ្ឋានទាមទារឲ្យរដ្ឋ អនុវត្តតាម ហើយទាមទារឲ្យរដ្ឋប ធ្វើរបាយការណ៍ អំពីការអនុវត្តតាមអនុសាសន៍ ចែងក្នុងសេចក្តីសន្និដ្ឋាន រួចដាក់ជូនគណៈកម្មាធិការ។[532] រដ្ឋខ្លះ អនុវត្តតាម

---

[528] *Id.*, paras 2-4.

[529] *Id.*

[530] Manfred, HRs Regime, *supra* note 444, p. 99.

[531] *Id.*,

[532] Overview of the working methods of CRC, *see supra* note 526.

សេចក្តីសន្និដ្ឋាន ដោយសារ រដ្ឋយល់ឃើញថា មានហេតុផលសមស្រប។[533] យន្តការនៃការតាមដានអនុវត្តរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ តាមសេចក្តីសន្និដ្ឋាន មានភាពប្រសើរឡើងជាបណ្តើរៗ។ សមាជិកម្នាក់នៃគណៈកម្មាធិការ ត្រូវបានតែងតាំង ឲ្យទាក់ទងជាញឹកញយជាមួយរដ្ឋ ឬ តំណាងរដ្ឋនៅក្នុងបេសកកម្មប្រចាំអង្គការសហប្រជាជាតិ ដើម្បីតាមដានការអនុវត្តតាមអនុសាសន៍។[534]

ជាទូទៅរដ្ឋ មិនថាប្រទេសអភិវឌ្ឍ ឬកំពុងអភិវឌ្ឍ ដាក់របាយការណ៍យឺតយ៉ាវ ៤ ឬ៥ឆ្នាំ រហូតពេលខ្លះដាក់របាយការណ៍រួម ឧទាហរណ៍ លើកទី ២ ឬទី ៣រួមគ្នា ទោះបីជាគណៈកម្មាធិការ ធ្វើការក្រើនរំឭកឲ្យដាក់របាយការណ៍ ឲ្យទាន់ពេលកំណត់ជាញឹកញយក្តី។[535] នេះដោយសារ រដ្ឋខ្លះមិនបានចាត់ទុកការងារសរសេរបាយការណ៍ជាការងារអាទិភាព។ ការសរសេររបាយការណ៍ត្រូវការការចូលរួមពីស្ថាប័នពាក់ព័ន្ធ ហើយមិនមានស្ថាប័នសម្របសម្រួលណាមួយជាក់លាក់។[536] ហេតុផលចុងក្រោយ រដ្ឋធ្វើរបាយការណ៍ ស្តីពី សិទ្ធិមនុស្សជាច្រើន ក្នុងពេលតែមួយ ដែលនាំឲ្យមានការពិបាកក្នុងការបញ្ចប់ និងដាក់របាយការណ៍តាមកាលកំណត់។[537]

---

[533] Australia rejected recommendations by Human Rights Committee (HRC) in the case of *A v. Australia* (No. 560/1993), see the Annual Report of the Human Rights Committee in 1994 (A/49/40), para. 491; however, it was reported that the alleged inconsisting law with the ICCPR was repealed, *see* Report of the HRC, A/52/40.

[534] Manfred, HRs Regime, *supra* note 444, p. 101.

[535] *Id*., p. 97.

[536] *Id*.,

[537] *Id.,* p. 96.

ករណីរដ្ឋយឺតយ៉ាវ ឬមិនព្រមដាក់របាយការណ៍ ទោះបីជាមានការក្រើនរំឭកជាច្រើនក្តី គណៈកម្មាធិការ អាចធ្វើការពិនិត្យនូវព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការអនុវត្តតាមសន្ធិសញ្ញារបស់រដ្ឋ ដែលពាក់ព័ន្ធ។ គណៈកម្មាធិការ នឹងចេញសេចក្តីសន្និដ្ឋានបណ្តោះអាសន្ន (Provisional Concluding Observations) រួចបញ្ជូនទៅកាន់រដ្ឋ។ ក្នុងរយៈពេលកំណត់ណាមួយ រដ្ឋត្រូវឆ្លើយតប មុននឹងសេចក្តីសន្និដ្ឋានប្រភេទនេះ ក្លាយជាឯកសារផ្លូវការ ចុងក្រោយ។ ករណីរដ្ឋមិនបានឆ្លើយតប ហើយពេលវេលាកំណត់បានកន្លងផុតទៅ សេចក្តីសន្និដ្ឋានបណ្តោះអាសន្ន នឹងក្លាយជាសេចក្តីសន្និដ្ឋានផ្លូវការ។[538]

អង្គការសហប្រជាជាតិ និង រដ្ឋ បានស្នើឲ្យមានការកែទម្រង់យន្តការពិនិត្យរបាយការណ៍របស់រដ្ឋ ដើម្បីសម្រួលការងារសរសេរបាយការណ៍របស់រដ្ឋ ដោយគ្រោងនឹងបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សធំមួយ ធ្វើការងារជាអចិន្ត្រៃយ៍មួយ មានផ្នែកជាច្រើន ទទួលបន្ទុក សិទ្ធិកុមារ សិទ្ធិស្ត្រី ហើយរដ្ឋដាក់ពិនិត្យតែរបាយការណ៍ សរុបតែមួយ (Consolidated Report) ជូនគណៈកម្មាធិការ។[539] ទោះបីជាយ៉ាងនេះក្តី វាគ្រាន់តែជាការស្រមៃ ពីព្រោះវាទាមទារឲ្យមានការធ្វើវិសោធនកម្ម មាត្រាខ្លះនៃសន្ធិសញ្ញាដែលពាក់ព័ន្ធដែលចំណាយពេលវេលាច្រើន និងមិនអាចធ្វើទៅបានងាយឡើយ។

### ៩.២.១០.២.២. បណ្តឹងរបស់បុគ្គល

តាមយន្តការនេះ មិនថាបុគ្គលជាជនជាតិអ្វីទេ ឲ្យតែស្ថិតនៅក្រោមយុត្តាធិការរបស់រដ្ឋ អាចធ្វើពាក្យបណ្តឹង (Communication) ដោយខ្លួនឯង

538 Provisional Concluding and Recommendations, *supra* note 253.

539 Manfred, HRs Regime, *supra* note 444, pp. 96-97.

ឬដោយអ្នកតំណាង ប្រឆាំងនឹងរដ្ឋ ក្នុងករណីដែលខ្លួនគិតថា សិទ្ធិសេរីភាពរបស់ខ្លួន ត្រូវបានរំលោភ។[540] ពាក្យថា នៅក្រោមយុត្តាធិការ (Subject to Jurisdiction of State) មិនកម្រិតចំពោះ តែអំពើណាមួយប្រព្រឹត្តនៅក្នុងដែនដីរបស់រដ្ឋទេ។ អំពើនៅក្រៅដែនដីក៏ដោយ ឲ្យតែអំពើចូលរួមដោយអាជ្ញាធររដ្ឋ។ នេះអាចជាករណី ដែលអំពើរំលោភសិទ្ធិ ប្រព្រឹត្តដោយទាហានរបស់រដ្ឋបញ្ជូនទៅ ធ្វើការងារនៅក្រៅដែនដីរបស់រដ្ឋនោះ។[541]

ទោះបីជាមានការរំលោភសិទ្ធិក៏ដោយ ក៏គណៈកម្មាធិការទទួលពិនិត្យពាក្យបណ្ដឹង អាចទទួល ឬមិនទទួលពាក្យបណ្ដឹង។ ករណីទទួលយកបណ្ដឹងរួចហើយក្ដី គណៈកម្មាធិការ អាចមិនពិនិត្យខ្លឹមសារនៃបណ្ដឹង ប្រសិនបើបណ្ដឹង និងអ្នកប្ដឹងមិនបានបំពេញតាមលក្ខខណ្ឌ ដែលតម្រូវដោយសន្ធិសញ្ញា។[542]

បណ្ដឹង ត្រូវតែបណ្ដឹងប្រឆាំងនឹងរដ្ឋ ដែលជាភាគីសន្ធិសញ្ញា និងប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការក្នុងការទទួលពាក្យបណ្ដឹង។[543]

បណ្ដឹងត្រូវឆ្លងកាត់ ពីរដំណាក់កាល។ ទីមួយ គឺដំណាក់កាលទទួល ឬមិនទទួលយកពាក្យបណ្ដឹង (Admissibility Stage) និង ដំណាក់កាលពិនិត្យអង្គសេចក្ដី ( Merit Stage)។ នេះមានន័យថា តើមានការរំលោភសិទ្ធិមនុស្សដូចការចោទប្រកាន់ដែរឬទេ? ដំណាក់កាលទី១ បុគ្គលត្រូវបំពេញ

---

540 The Optional Protocol to the CRC on a Communications Procedure, A/Res/66/138, 27 January 2012, Art. 5.

541 The General Comment No. 31, *supra* note 182, para. 10.

542 The Torture Convention, *supra* note 189, Art. 22.

543 *Id*.

លក្ខខណ្ឌមួយចំនួនៈ បណ្តឹងត្រូវមានឈ្មោះអ្នកប្តឹងច្បាស់លាស់ ជាដើម។ បុគ្គលអ្នកប្តឹង មិនត្រូវបំពាននីតិវិធីប្តឹង ដូចជាត្រូវប្តឹងក្នុងរយៈពេលជាក់លាក់សមស្របណាមួយ ក្រោយពីមានការរំលោភសិទ្ធិ ឬ ត្រូវមានលិខិតអនុញ្ញាតឲ្យប្តឹងជំនួសជាដើម។[544] ជាចុងក្រោយ ប្រធានបទនៃការប្តឹង មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា ដែលជាប់ពាក់ព័ន្ធ។[545] នេះមានន័យថា បុគ្គលអាចប្តឹងពាក់ព័ន្ធនឹងការរំលោភសិទ្ធិ ដែលមានចែងក្នុងសន្ធិសញ្ញា តែមិនអាចប្តឹងអំពីការរំលោភសិទ្ធិ ដែលមិនមានចែងក្នុងសន្ធិសញ្ញាបានទេ។[546] ក្នុងករណីបណ្តឹងបំពេញបានតាមលក្ខខណ្ឌនេះ គណៈកម្មាធិការ នឹងទទួលយកពាក្យបណ្តឹង ហើយពិនិត្យមើលអង្គសេចក្តី។ ទោះបីជាយ៉ាងនេះក្តី លុះត្រាតែប្រធានបទនៃការប្តឹង មិនត្រូវបានពិនិត្យ ឬកំពុងត្រូវបានពិនិត្យ ដោយយន្តការណាផ្សេងទៀត ហើយបុគ្គលបានប្តឹងទៅតុលាការក្នុងស្រុក ដែលបានដោះស្រាយរួចហើយ (Exhaustion of Local Remedy)។[547] ដោយសារ មានយន្តការឃ្លាំមើលសិទ្ធិមនុស្សជាច្រើន ដែលអាចពិនិត្យមើលស្ថានភាពសិទ្ធិមនុស្ស គណៈកម្មាធិការ បានបកស្រាយឃ្លា "មិនត្រូវបានពិនិត្យ ឬកំពុងត្រូវបានពិនិត្យ ដោយយន្តការណាមួយផ្សេងទៀត" យ៉ាងចង្អៀត ដោយសំដៅទៅលើយន្តការបង្កើតឡើងដោយសន្ធិសញ្ញា។ ជាឧទាហរណ៍ ការពិនិត្យដោយក្រុម

[544] Rules of Procedure, CAT/C/3/Rev.5, 21 February 2011, Rule 113.

[545] Sarah Joseph, Ratie Mitchell *et al*, Seeking Remedies for Torture Victims, 2006, p.74.

[546] For example, there is not mentioned the right to property in the ICCPR; therefore, any individual might not file a comminucation alleging this right is violated; otherwise, his was considered inadmissible.

[547] Rules of Procedure, CAT/C/3/Rev.5, 21 February 2011, Rule 113.

ប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ មិនអាចរារាំងដល់ការពិនិត្យបណ្តឹងដោយគណៈកម្មាធិការទេ។[548]

បុគ្គល ត្រូវប្តឹងទៅតុលាការក្នុងស្រុកឲ្យដោះស្រាយជាមុនសិន មុននឹងដាក់ពាក្យប្តឹងទៅគណៈកម្មាធិការ។ នេះទុកឱកាសឲ្យតុលាការ ចេញសាលក្រម ឬជាសាលក្រមស្ថាពរសិន ដែលអាចត្រឹមតុលាការជាន់ទាប ឬជាន់ខ្ពស់។ ទោះបីជាយ៉ាងនេះក្តី ប្រសិនបើដំណើរការលើបណ្តឹង ដោយតុលាការក្នុងស្រុក មានការយឺតយ៉ាវមិនសមហេតុផល ឬ បណ្តឹងនឹងមិនទទួលបានលទ្ធផល ដូចជាក្នុងករណី ដែលជនត្រូវចោទត្រូវបានច្បាប់លើកលែងទោស បុគ្គលអ្នកប្តឹង អាចរំលងនីតិវិធីក្នុងស្រុក រួចប្តឹងទៅគណៈកម្មាធិការផ្ទាល់តែម្តង។[549]

គណៈកម្មាធិការ អាចពិនិត្យមើល ការទទួលយកបណ្តឹង និងអង្គហេតុដោយឡែក ឬរួមបញ្ចូលគ្នាក្នុងពេលតែមួយ។[550] ក្រោយពេលទទួលបណ្តឹងពីបុគ្គល គណៈកម្មាធិការ នឹងបញ្ជូនពាក្យបណ្តឹងទៅកាន់រដ្ឋ ដែលត្រូវបានគេប្តឹងប្រឆាំង ហើយបង្គាប់ឲ្យរដ្ឋនោះ ពន្យល់ និងបង្ហាញអំពីកិច្ចការងារមួយចំនួន ដែលខ្លួនបានធ្វើទាក់ទិននឹងបណ្តឹងនៅថ្នាក់ស្រុក។ រដ្ឋ ត្រូវឆ្លើយតបក្នុងរយៈពេល ៦ខែក្រោយពីទទួលពាក្យបណ្តឹង ពីគណៈកម្មាធិការ។[551] បុគ្គល នឹងត្រូវអនុញ្ញាតឲ្យឆ្លើយតបចម្លើយរបស់រដ្ឋ។ ដំណើរការនេះ ត្រូវការ

[548] Sarah Joseph, Seeking Remedies, *supra* note 545, p.72.
[549] CAT, Rules of Procedure, *supra* note 544, Rule 113.
[550] Sarah Joseph, Seeking Remedies, *supra* note 545, pp. 92- 93.
[551] CAT, Rules of Procedure, *supra* note 544, Rule 115.

ពេលវេលាជាច្រើនឆ្នាំ មុននឹងគណៈកម្មាធិការ ចេញសេចក្តីសម្រេច ចុងក្រោយ(View)។[552]

គណៈកម្មាធិការ នឹងពិនិត្យមើលនូវព័ត៌មាន ដែលផ្តល់ដល់ភាគីពាក់ព័ន្ធ ពីព្រោះគណៈកម្មាធិការមិនអាចចុះទៅប្រមូលភស្តុតាងដោយខ្លួនឯងឡើយ។ ភាគីត្រូវដាក់ឯកសារក្នុងរយៈពេលកំណត់ ដូចនេះ ភាគីត្រូវខិតខំដាក់ឯកសារសំខាន់ៗ ដែលមានប្រយោជន៍សម្រាប់ខ្លួន ក្នុងពេលកំណត់ បើមិនដូចនេះ រឿងក្តីដែលអាចឈ្នះ អាចក្លាយទៅជាចាញ់វិញក៏ថាបាន។[553]

សេចក្តីសម្រេចរបស់គណៈកម្មាធិការ នឹងរៀបរាប់អំពី សំណងដល់ជនរងគ្រោះក្នុងករណីរកឃើញថា មានការរំលោភសិទ្ធិ។[554] សេចក្តី សម្រេចមិនចងជាកាតព្វកិច្ច[555] តែត្រូវបានបកស្រាយថា ចងជាកាតព្វកិច្ច។ ទោះបីជាយ៉ាងនេះក្តី ករណីរដ្ឋមិនអនុវត្តតាម ក៏មិនមានបញ្ហាធំដុំទេ ពីព្រោះគណៈកម្មាធិការគ្មាន អំណាចទូលំទូលាយ ក្នុងការអនុវត្ត សេចក្តីសម្រេចឡើយ

[552] Measures to Improve Further the Effectiveness, harmonization and reform of the treaty body system, A/66/344,7 September 2011, para. 11.

[553] Manfred, HRs Regime, *supra* note 444, p. 101; burden of proof was shared and sifted between the complainants and State party, *see* Sarah Joseph, Seeking for Remedies, *supra* note 545, p. 71.

[554] Manfred, HRs Regime, *supra* note 444, p. 101; *see* "How to Complian about Human Rights Treaty Violations: the ICCPR-Descrption", http://www.bayefsky.com/complain/10_ccpr.php, para.2.

[555] Manfred, HRs Regime, *supra* note 444, p. 101; Sarah Joseph, Seeking Remedies, *supra* note 545, p. 93.

។[556] រដ្ឋមួយចំនួនទទួលយក និងធ្វើតាម សេចក្តីសម្រេច ទោះបីមានការជំទាស់ទៅនឹង ខ្លឹមសារនៃសេចក្តីសម្រេចនោះក្តី។[557]

### ៩.២.១០.២.៣. បណ្តឹងរបស់រដ្ឋ

រដ្ឋភាគីមួយ អាចប្តឹងប្រឆាំងនឹងរដ្ឋភាគីមួយទៀត ក្នុងករណី ដែលរដ្ឋមួយមិនបានបំពេញតាមកាតព្វកិច្ចរបស់សន្ធិសញ្ញា ដែលខ្លួនជាភាគី។ ដើម្បីអាចប្តឹងបាន រដ្ឋទាំងពីរ បន្ថែមពីលើការចូលជាភាគី ត្រូវប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការពិនិត្យមើលបណ្តឹងប្រឆាំង នឹងរដ្ឋ។[558]

នីតិវិធីបណ្តឹងប្រភេទនេះ មានភាពស្មុគស្មាញជាងនីតិវិធីបណ្តឹងដោយបុគ្គល ពីព្រោះ រដ្ឋទាំងពីរ ត្រូវឆ្លងកាត់ការចរចាគ្នាសិន ក្នុងរយៈពេលកំណត់ណាមួយ ដោយមានការចូលរួមពីគណៈកម្មាធិការ។ នៅពេលដែលរដ្ឋចរចាមិនបានសម្រេច រដ្ឋនឹងដាក់បណ្តឹងទៅគណៈកម្មាធិការ។[559] យន្តការនេះមិនសូវមានភាពពេញនិយមខ្លាំងទេ ហើយដំណើរមិនបើកចំហរឡើយ។

រដ្ឋជាច្រើនបានប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការពិនិត្យពាក្យបណ្តឹង ក៏ប៉ុន្តែមិនមានរដ្ឋណាមួយ ហ៊ានប្តឹងប្រឆាំងនឹងរដ្ឋមួយ

[556] Special Rapporteur was assigned to follow-up recommendations, *see* the Human Rights Committee, Rules of Procedure, U.N.Doc. CCPR/C/3/Rev.3 (1994), Rule 101(2).
[557] Australia rejected recommendations by Human Rights Committee (HRC) in the case of *A v. Australia* (No. 560/1993), see the Annual Report of the Human Rights Committee in 1994 (A/49/40), para. 491; however, it was reported that the alleged inconsisting law with the ICCPR was repealed, *see* Report of the HRC, A/52/40.
[558] The Torture Convention, *supra* note 189, Art. 21.
[559] *Id.*, Art. 21 (1.2).

ទៀតឡើយ។ មានមូលហេតុយ៉ាងតិចចំនួនពីរៈ ទី១ រដ្ឋខ្លាចរដ្ឋ ដែលខ្លួនប្ដឹងប្រឆាំងប្ដឹងបកប្រឆាំងនឹងខ្លួនវិញ។ លទ្ធភាពនៃការប្ដឹងបកអាចមានច្រើនដោយសារ រដ្ឋនីមួយៗមិនមានស្ថានភាពសិទ្ធិមនុស្សល្អឥតខ្ចោះនោះឡើយ។ ទី២ ការប្ដឹងគឺដើម្បីការពារសិទ្ធិរបស់បុគ្គល តែវាអាចប៉ះទង្គិចទំនាក់ទំនងការទូតរបស់រដ្ឋ និងរដ្ឋ ដែលជាផលប្រយោជន៍ជាតិ ដែលជាទូទៅរដ្ឋឲ្យតម្លៃខ្ពស់ជាងផលប្រយោជន៍របស់បុគ្គល។[560] ការបកស្រាយនេះ គាំទ្រដោយប្រយោល ដោយរឿងក្ដីប្ដឹងដោយ សាធារណរដ្ឋ Ireland ប្រឆាំងនឹង the United Kingdom។[561] ក្នុងករណីនេះ Ireland បានប្ដឹង ដោយសារ ជនជាតិរបស់ខ្លួន ត្រូវបានចោទប្រកាន់ថាជាភេរវករ និងទទួលរងអំពើទារុណកម្ម និងអំពើអមនុស្សធម៌ ដោយអាជ្ញាធរប្រទេសអង់គ្លេស ដើម្បីយកចម្លើយសារភាព អំពីអំពើភេរវកម្ម។ ប្រសិនបើជនរងគ្រោះ មិនមែនជាជនជាតិរបស់ខ្លួន Ireland អាចនឹងមិនប្ដឹង ដែលអាចនឹងនាំឲ្យទំនាក់ទំនងការទូតរបស់ខ្លួន និងអង់គ្លេសប្រេះឆា។

### ៩.២.១០.២.៤. ការស៊ើបសួរ

យន្តការនេះ មានចែងបង្កើតនៅក្នុងកតិកាសញ្ញា ស្ដីពី ការប្រឆាំងនឹងអំពើទារុណកម្ម។ យន្តការនេះ អនុញ្ញាតឲ្យគណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម ពិនិត្យមើលថាតើអំពើទារុណកម្ម ត្រូវបានប្រព្រឹត្តជាប្រព័ន្ធនៅក្នុងប្រទេសមួយ ដូចដែលមានការចោទប្រកាន់ដែរឬទេ?។[562] រដ្ឋត្រូវតែ

[560] Manfred, HRs Regime, *supra* note 444, p. 100.
[561] J.S. Watson, the limited utility of International Law in the Protection of Human Rights, 74 Proceedings of the American Society of International Law (1980), pp.3-4.
[562] The Torture Convention, *supra* note 189, Art.20.

ទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការជាមុនសិន មុនពេលដែលគណៈកម្មាធិការប្រើប្រាស់យន្តការចំពោះខ្លួន។

ជាការចាប់ផ្តើម វាទាមទារឲ្យមាន ព័ត៌មានទុកចិត្តបាន ចង្អុលបង្ហាញថា អំពើទារុណកម្ម កំពុងត្រូវបានប្រព្រឹត្តជាលក្ខណៈប្រព័ន្ធនៅក្នុងដែនដីរបស់រដ្ឋ។ ក្រោយពីទទួលព័ត៌មានដូចនេះ គណៈកម្មាធិការ អាចនឹងបង្កើតអនុ-គណៈកម្មាធិការ ដើម្បីពិនិត្យមើល ហើយស្នើឲ្យរដ្ឋសហការក្នុងការ ឆ្លើយតបចំពោះការចោទប្រកាន់។ ក្នុងគ្រប់ដំណើរការទាំងអស់ ត្រូវមានកិច្ចសហប្រតិបត្តិការពីរដ្ឋ។ នេះរួមបញ្ចូលផងដែរ នូវការផ្តល់ការយល់ព្រមពីសំណាក់រដ្ឋ ដល់ការចូលទៅក្នុងដែនដី ដោយគណៈកម្មការធិការ ដើម្បីពិនិត្យជាក់ស្តែង កន្លែងដែលត្រូវបានចោទប្រកាន់ថាមានការប្រព្រឹត្តអំពើទារុណកម្ម។[563]

ការពិនិត្យដោយគណៈកម្មាធិការ ត្រូវតែធ្វើឡើងជាសម្ងាត់។ គណៈកម្មាធិការ អាចដាក់បញ្ចូលនូវសេចក្តីសង្ខេបលទ្ធផលនៃការពិនិត្យ ក្នុងរបាយការណ៍របស់ខ្លួន ឬអាចដាក់បញ្ចូលខ្លឹមសារទាំងស្រុង ក្នុងករណីរដ្ឋយល់ព្រម។[564]

មានចំណុចពីរ ដែលគួរឲ្យកត់សម្គាល់។ ទី១ កន្លងមក មានព័ត៌មានពាក់ព័ន្ធដល់រដ្ឋជាច្រើន ដែលនាំឲ្យគណៈកម្មាធិការ បានផ្តើមធ្វើការងារក្រោមយន្តការនេះ។ ក៏ប៉ុន្តែ គណៈកម្មាធិការ មិនបានរកឃើញ ដូចអ្វីដែលត្រូវបានចោទប្រកាន់ថា មានការប្រព្រឹត្តអំពើទារុណកម្ម ជាលក្ខណៈប្រព័ន្ធ

[563] *Id.*
[564] *Id.*

ឡើយ។[565] នេះបង្ហាញថា គេមិនចេះតែរាយការណ៍ ឬចោទប្រកាន់ឡើយ។ ម្យ៉ាងទៀត ពាក្យថា "ការប្រព្រឹត្តជាប្រព័ន្ធ" ទាមទារឲ្យមានការបកស្រាយចង្អៀត ឬសំដៅលើការប្រព្រឹត្ត ដែលមានលក្ខណៈធ្ងន់ធ្ងរ។ ទី២ ការតម្រូវឲ្យមានការអនុញ្ញាតពីរដ្ឋជាមុន មុននឹងគណៈកម្មាធិការចូលទៅក្នុងដែនដី ជាចំណុចខ្សោយរបស់យន្តការនេះ។ ទោះបីជាការពិនិត្យដែនដី ជាការងារសំខាន់មួយក្តីក្នុងការស្វែងរកការពិត រដ្ឋអាចពន្យារពេលមុនអនុញ្ញាតឲ្យគណៈកម្មាធិការចូលទៅដែនដី ដើម្បីលាក់បំបាំងភស្តុតាង ឬសម្ភារប្រើប្រាស់សម្រាប់ធ្វើអំពើទារុណកម្ម។

### ៩.២.១០.២.៥. ការចុះពិនិត្យមន្ទីរឃុំឃាំង

យន្តការប្រភេទនេះ ត្រូវបានគ្រោងបង្កើតជាយូរមកហើយ ដោយអង្គការសហប្រជាជាតិ[566] ក៏ប៉ុន្តែត្រូវបានផ្អាកដោយសារហេតុផលមួយចំនួន ដូចជាការបារម្ភអំពីការជ្រៀតជ្រែកអធិបតេយ្យភាពរបស់រដ្ឋ។[567] ហេតុផលនៃការបង្កើតនេះ គឺដើម្បីជួយបង្ការអំពើអមនុស្សធម៌ និងទារុណកម្ម ពីព្រោះអំពើនេះ ជាអំពើដែលច្បាប់របស់រដ្ឋ បានចាត់ថាជាអំពើខុសច្បាប់ ហើយប្រសិនបើកើតមានហើយ មិនអាចជួសជុលបានឡើយ (Irreparable)។ ដោយពិចារណាឃើញថា យន្តការស្រដៀងគ្នានេះ មានសម្រាប់ទ្វីបអឺរ៉ុបទទួលបានជោគជ័យក្នុងការបង្ការអំពើទារុណកម្ម [568]អង្គការសហប្រជាជាតិបានចាប់ផ្តើមគិតគូរជាថ្មី នូវការបង្កើតយន្តការនេះ។ ក្រោយពីឆ្លងកាត់

---

[565] Manfred, HRs Regime, *supra* note 444, p. 104.

[566] Nigel S. Rodley, the Treatment of Prisoners under International Law, 2nd ed., 1999, p. 160.

[567] Manfred, HRs Regime, *supra* note 444, p. 104.

[568] Manfred, HRs Regime, *supra* note 444, pp. 87, 91.

ការពិភាក្សា ដ៏លំបាក និងយូរកន្លងមក ឯកសារបង្កើតយន្តការនេះ ត្រូវបាន អនុម័តឡើង។[569]

យន្តការនេះ នឹងអនុញ្ញាតឲ្យអនុគណៈកម្មាធិការ ប្រឆាំងនឹងអំពើទារុណកម្ម ចុះទៅពិនិត្យទីកន្លែង ដែលបុគ្គលត្រូវបានដកហូតសេរីភាព ដូចជាកន្លែង ឃុំខ្លួន។ ជាមួយនេះដែរ រដ្ឋជាភាគី មានកាតព្វកិច្ចបង្កើតគណៈកម្មាធិការ ឬ យន្តការជាតិឯករាជ្យ ដើម្បីចុះពិនិត្យកន្លែងឃុំខ្លួនក្នុងដែនដីរបស់ខ្លួន[570] និង ធ្វើការងារជាមួយអនុគណៈកម្មាធិការ នៅពេលចុះទៅពិនិត្យទីកន្លែងឃុំខ្លួន។

យន្តការនេះមានប្រយោជន៍ជាច្រើន។ រដ្ឋអាចទទួលជំនួយបច្ចេកទេស និង និងអាចដកបទពិសោធ ពីការធ្វើការងារជាមួយអនុគណៈកម្មាធិការ។

យន្តការនេះមានចំណុចខ្លាំងជាច្រើន។ ទី១ រដ្ឋនឹងអនុញ្ញាតឲ្យអនុគណៈ កម្មាធិការចូលទៅពិនិត្យ នៅពេលដែលរដ្ឋចូលជាភាគី។[571] អនុគណៈកម្មា ធិការ គ្រាន់តែជូនដំណឹងដល់រដ្ឋ មុនចុះទៅពិនិត្យ ដើម្បីឲ្យរដ្ឋជួយសម្រប សម្រួលការងារចុះពិនិត្យកន្លែងឃុំខ្លួន។[572] ចាប់ពីពេលជូនដំណឹងនេះ ដល់ ថ្ងៃចុះទៅពិនិត្យ មិនមានរយៈពេលយូរទេ។ នេះដើម្បីកុំឲ្យ រដ្ឋមានពេល ក្នុងការបង្វែរដានអនុគណៈកម្មាធិការ។ អនុគណៈកម្មាធិការ អាចជ្រើសរើស កន្លែងណាមួយ ដើម្បីខ្លួនចុះទៅពិនិត្យក៏បាន ព្រមទាំងធ្វើការសាកសួរបុគ្គល

---

[569] The OP to the Torture Convention, *supra* note 438.
[570] The Subcommittee on Prevention visited Cambodia already, *see* report on the Visit of the Subcommittee on Prevention, CAT/C/42/2 (2009).
[571] Ian Brownlie, Documents on HRs, *supra* note 451, p. 446; OP to the Torture Convention, *supra* note 438, Art. 4.
[572] OP to the Torture Convention, *supra* note 438, Art. 13 (2).

ពាក់ព័ន្ធជាសម្ងាត់ ដោយគ្មានការចូលរួមពីអាជ្ញាធរ។[573] អនុគណៈកម្មាធិការ អាចពិនិត្យកន្លែងឃុំខ្លួន ក្រៅពីពន្ធនាគារ ដូចជា កន្លែងស្តារនីតិសម្បទា កន្លែងឃុំខ្លួនមនុស្សវិកលចរិតជាដើម។[574] ក្នុងករណីខ្លះ រដ្ឋអាចសុំពន្យារការចុះពិនិត្យរបស់អនុគណៈកម្មាធិការ តែលុះត្រាមានមូលហេតុបន្ទាន់ នៃសន្តិសុខជាតិ។[575] ជាចុងក្រោយ យន្តការនេះ ផ្តល់នូវភាពបត់បែនសម្រាប់រដ្ឋ។ រដ្ឋអាចប្រកាសរក្សាសិទ្ធិមិនទាន់អនុញ្ញាតឲ្យអនុគណៈកម្មាធិការចុះទៅពិនិត្យប្រទេសខ្លួន ក្នុងរយៈពេលមួយកំណត់។ នេះទុករយៈពេលសម្រាប់រដ្ឋរៀបចំបទដ្ឋាន និងយន្តការអនុវត្ត ដើម្បីអាចអនុវត្តបានពេញលេញ មុនទទួលដំណើរចូលមកពិនិត្យរបស់អនុគណៈកម្មាធិការ។[576]

## ៩.២.១១. សិទ្ធិមនុស្សក្នុងតំបន់

### ៩.២.១១.១. តំបន់អឺរ៉ុប

ទំព័រខាងមុខ បានរៀបរាប់រួចហើយនូវ វិធានសិទ្ធិមនុស្សសាកល និងយន្តការសម្រាប់ឃ្លាំមើលការអនុវត្តសិទ្ធិមនុស្សរបស់រដ្ឋជាភាគី។ វិធានសិទ្ធិ ត្រូវបានចាត់ថា ជាស្តង់ដារអប្បបរមារួម (Minimum and Common Standards) ដែលមានន័យថា សូម្បីប្រទេសដ៏តូចមួយ ក៏អាចគោរព តាមស្តង់ដារទាំងនេះបានដែរ ហើយវិធានទាំងនេះ ត្រូវប្រើសម្រាប់គ្រប់រដ្ឋនិងប្រជាជាតិទូទាំងពិភពលោក។ ជាក់ស្តែង បទដ្ឋានអប្បបរមា អាចសំដៅលើចំនួនវិធាន តែការអនុវត្ត រដ្ឋមិនអាចគោរពវិធានបានល្អ ១០០ភាគរយឡើយ សូម្បីក្នុងប្រទេសរីកចម្រើនក្តី។ នេះអាចបណ្តាលមកពី វិធានមានចរិតលក្ខណៈ

[573] *Id.*, Art. 14(1.d).
[574] *Id.*, Art. 4(2).
[575] *Id.*, Art. 14(2).
[576] *Id.*, Art. 24.

ជាទ្រឹស្តី មិនឆ្លើយតបទៅតាមបរិបទនៃសង្គម ឬប្រទេស ឬតំបន់ណាមួយ។ ដោយហេតុនេះ ស្រដៀងគ្នានឹងវិស័យដទៃទៀត សកម្មជនសិទ្ធិមនុស្ស និង អាជ្ញាធរបានផ្តួចផ្តើម រៀបចំវិធាន និងយន្តការសិទ្ធិមនុស្សសម្រាប់តំបន់នីមួយៗ ដើម្បីបន្សុំទៅនឹងស្ថានភាពជាក់ស្តែងរបស់តំបន់នីមួយៗ។

ទ្វីបអឺរ៉ុប បានអនុម័តនូវ អនុសញ្ញាស្តីពី សិទ្ធិ និងសេរីភាពចម្បង។[577] ឯកសារនេះ ចែងពីសិទ្ធិមួយចំនួនតូច មិនលម្អិត និងជាពិសេស ផ្តោតលើសិទ្ធិប្រជាពលរដ្ឋនិងនយោបាយ។[578] ក្រោយមក អឺរ៉ុប បានអនុម័តពិធីសារបន្ថែម ចំនួន ១២ ភ្ជាប់ជាមួយនឹងកតិកាសញ្ញា។[579] ក្រៅពីនេះ សហគមន៍អឺរ៉ុប បានអនុម័ត ឯកសារសិទ្ធិមនុស្ស ដូចជា កតិកាសញ្ញា សម្រាប់បង្ការអំពើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មអមនុស្សធម៌ ឬបន្ទាបបន្ថោក។[580] ទោះបីជាយ៉ាងនេះក្តី ឯកសារសិទ្ធិមនុស្សរបស់ អឺរ៉ុបមិនសម្បូរបែបដូចឯកសារសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិឡើយ។
ពាក់ព័ន្ធជាមួយយន្តការ ទ្វីបអឺរ៉ុប មានបង្កើតយន្តការចុះទៅពិនិត្យមើលកន្លែងឃុំខ្លួន។[581] បន្ថែមពីលើនេះ ផ្អែកតាមកតិកាសញ្ញា គណៈកម្មការ និង

[577] The ECHR, *supra* note 157, p. 681.
[578] Manfred, HRs Regime, *supra* note 444, p. 160.
[579] For example, Protocol No. 13 to the Convention for the Protection of Human Rights and Functional Freedoms, Concerning the Abolition of the Death Penalty in All Circumstances (2002), *see* Brownlie's Documents, *supra* note 451.
[580] Brownlie's Documents on Human Rights, *supra* note 451, p. 785.
[581] The European Convention for the Prevention of Torture and Inhuman or Degrading Treatment or Punishment (1987), *see* Brownlie's Documents, *supra* note 451, Art. 1, p. 786; Manfred, HRs Regime, *supra* note 463, pp. 176-177.

តុលាការសិទ្ធិមនុស្សអឺរ៉ុប ត្រូវបានបង្កើតឡើង ដើម្បីពិចារណាបណ្តឹងរបស់រដ្ឋ ឬបុគ្គលក្នុងករណីចោទប្រកាន់ថាមានការរំលោភសិទ្ធិមនុស្ស។[582]

គណៈកម្មការ ពិនិត្យផងដែរ ថាតើបណ្តឹងអាចទទួលយកបានដែរឬទេ? ប្រសិនបើមិនអាចទទួលយកបាន គណៈកម្មការនឹងបញ្ចប់ដំណើរការពិនិត្យ។ ក្នុងករណីទទួលយកបាន គណៈកម្មការនឹងធ្វើការស៊ើបអង្កេត និងចេញយោបល់ ថាតើមានការរំលោភ សិទ្ធិដូចដែលបានចោទប្រកាន់ដែរឬទេ? យោបល់ ត្រូវបានបញ្ជូនជាសម្ងាត់ទៅ ភាគីទាំងសងខាង និងគណៈកម្មាធិការរដ្ឋមន្ត្រីរបស់អឺរ៉ុប។[583] ក្នុងអំឡុងពេលនៃដំណើរការ គណៈកម្មការ ដើរតួជាស្ថាប័នផ្សះផ្សាទំនាស់ ស្តីពី ការរំលោភសិទ្ធិមនុស្ស រវាងរដ្ឋ និងបុគ្គលដែលអះអាងថារដ្ឋបានរំលោភបំពានសិទ្ធិរបស់ខ្លួន។[584] ក្នុងអំឡុងពេលបីខែក្រោយពី ការបញ្ជូនយោបល់ និង មិនមានដំណោះស្រាយ រដ្ឋចុងចម្លើយ ឬរដ្ឋដែលជនជាតិខ្លួនជាជនរងគ្រោះ អាចបញ្ជូនបណ្តឹងទៅតុលាការ។[585]

ក្រោយឆ្នាំ ១៩៩៨ តុលាការសិទ្ធិមនុស្សជាអចិន្ត្រៃយ៍ ត្រូវបានបង្កើតជំនួសគណៈកម្មការ និង តុលាការ។ តុលាការនេះ មានអំណាចដោះស្រាយដោយមេត្រីភាព (Friendly) នូវជម្លោះរវាងរដ្ឋ និងរដ្ឋ ឬរដ្ឋ និងបុគ្គល ដែលត្រូវបានបញ្ជូនមកខ្លួន។[586]

---

582 Manfred, HRs Regime, *supra* note 444, p. 165; the ECHR, *supra* note 157, Arts. 32 and 33.

583 Jacobs, ECHR, *supra* note 459, p. 9.

584 Manfred, HRs Regime, *supra* note 444, p. 172.

585 Jacobs, ECHR, *supra* note 459, p.9.

586 *Id.*, p. 10; the ECHR, *supra* note 157, Art. 39.

តុលាការមានអំណាចជាច្រើន អាចប្រមូលភស្តុតាងបន្ថែមដោយខ្លួនឯង[587] ហើយដំណើរនៃនីតិវិធី គឺមិនខុសពីតុលាការជាតិឡើយ។ ដំណើរការនេះ រួមមាននីតិវិធីផ្ទាល់មាត់ផងដែរ។[588]

តុលាការចេញសាលក្រមលម្អិត របៀបជាសាលក្រមរបស់ប្រទេសប្រកាន់យកប្រព័ន្ធ Common Law។ ក្នុងនោះ តុលាការ បានវិភាគអំពីច្បាប់ជាតិ អន្តរជាតិ និងយោងដល់យុត្តិសាស្ត្ររបស់តុលាការផ្សេងៗទៀត មុននឹងរកឃើញថាតើ មានការរំលោភសិទ្ធិបុគ្គលដោយរដ្ឋដែរឬទេ?។ សាលក្រមរបស់តុលាការ បានរួមចំណែកយ៉ាងច្រើនដល់ការអភិវឌ្ឍវិធានច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយតុលាការជាតិ និងអន្តរជាតិជាច្រើន បានយោងដល់សាលក្រមរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប។

តុលាការនឹងប្រកាស នូវសំណងចំពោះការខូចខាត ប្រសិនបើរកឃើញថាមានការរំលោភសិទ្ធិសេរីភាពរបស់បុគ្គល ដោយរដ្ឋពិតប្រាកដមែន។ រដ្ឋត្រូវតែគោរពតាមខ្លឹមសារនៃសាលក្រម។ ករណីមិនបានគោរព គណៈកម្មាធិការរដ្ឋមន្ត្រីរបស់អឺរ៉ុប នឹង បង្ខំឲ្យរដ្ឋអនុវត្តតាម។[589]

យន្តការប្ដឹងដោយបុគ្គល ប្រឆាំងនឹងរដ្ឋ មានលក្ខណៈជាជម្រើស (Optional)។[590] មានន័យថានៅពេលរដ្ឋចូលជាភាគី រដ្ឋអាចសម្រេចជ្រើស

[587] D. J. Harris, Law of the European Convention on Human Rights, 2nd ed., 2008, pp. 846-847.
[588] D.J. Harris, Law of ECHR, *supra* note 587, pp. 841-842.
[589] Manfred, HRs Regime, *supra* note 444, p. 171; D.J. Harris, *supra* note 587, p. 5; the ECHR, *supra* note 157, Art. 46.
[590] The ECHR, *supra* note 157, Art. 34.

រើស និងទទួលស្គាល់យន្តការបណ្តឹងនេះ ឬមិនជ្រើសរើស។[591] ផ្ទុយទៅវិញ យន្តការបណ្តឹងរបស់រដ្ឋប្រឆាំងនឹងរដ្ឋ មិនមែនជាជម្រើសទេ (Manda tory)។[592] នេះមានន័យថា នៅពេលរដ្ឋចូលជាភាគី រដ្ឋត្រូវទទួលយក យន្តការនេះ។ នេះខុសពី យន្តការបណ្តឹងរបស់អង្គការសហប្រជាជាតិ បង្កើតឡើងតាមសន្ធិសញ្ញា ដែលមានលក្ខណៈជម្រើស ទាំងយន្តការបណ្តឹង ដោយបុគ្គលប្រឆាំងនឹងរដ្ឋ និងដោយរដ្ឋប្រឆាំងនឹងរដ្ឋ។

### ៩.២.១១.២. តំបន់អន្តរ-អាមេរិក

តំបន់អន្តរ-អាមេរិក បានអនុម័តសេចក្តីថ្លែងការណ៍ ស្តីពី សិទ្ធិស្រដៀងគ្នា នឹងសេចក្តីថ្លែងការណ៍ជាសាកល ស្តីពី សិទ្ធិមនុស្ស ឆ្នាំ ១៩៤៨។[593] បន្ថែម ពីលើនេះ តំបន់អាមេរិក ក៏មានសន្ធិសញ្ញា ស្តីពីសិទ្ធិបុគ្គល និងនយោបាយ ព្រមទាំងសន្ធិសញ្ញាដទៃទៀតដូចជា សន្ធិសញ្ញា ស្តីពីការប្រឆាំងអំពើរើស អើងជនពិការជាដើម។[594]

ចំពោះយន្តការ តំបន់នេះមានគណៈកម្មការ និងតុលាការសិទ្ធិមនុស្សប្រចាំ អន្តរទ្វីបអាមេរិក។[595] ដំណើរការនីតិវិធី មានលក្ខណៈស្រដៀងនឹងដំណើរ ការរបស់គណៈកម្មការ និងតុលាការសិទ្ធិមនុស្សប្រចាំទ្វីបអឺរ៉ុប ពាក់ព័ន្ធការ

---

[591] *Id.,* Art. 33.
[592] Manfred, HRs Regime, *supra* note 444, pp. 163-164.
[593] The Brownlie's Documents on Human Rights, *supra* note 451, p. 949.
[594] *Id.*, p.
[595] Manfred, HRs Regime, *supra* note 444, p. 199.

ទទួលពាក្យបណ្ដឹង ការសម្រេចលើអង្គហេតុ។ មានដំណើរការផ្សះផ្សា ដើម្បីឈានរកដំណោះស្រាយ មុនចូលដល់តុលាការផងដែរ។[596]

គណៈកម្មការ ដើរតួនាទីជាអ្នកការពារជនរងគ្រោះ ចោទឆ្លើយនៅពីមុខតុលាការ។[597] តុលាការពិនិត្យមើលឯកសារ ស្ដាប់ការដេញដោលផ្ទាល់មាត់រវាងភាគី។[598] តុលាការ និងគណៈកម្មការ មានអំណាចចុះទៅពិនិត្យដល់កន្លែង ដែលចោទថាមានការរំលោភសិទ្ធិមនុស្ស។[599] តុលាការ ទទួលពាក្យបណ្ដឹងពីគណៈកម្មការ និងរដ្ឋជាភាគី និងពិចារណា ចេញសាលក្រម លម្អិត និងជាក់លាក់ ដែលចងជាកាតព្វកិច្ចដល់រដ្ឋ ក្នុងនោះក៏បានចែងផងដែរ នូវសំណង ដែលជនរងគ្រោះទទួលពីរដ្ឋ ដែលរំលោភសិទ្ធិរបស់ខ្លួន។ អង្គការរបស់រដ្ឋអាមេរិក (the Organization of States of America: OSA) មានបន្ទុកចាប់បង្ខំឲ្យរដ្ឋអនុវត្តតាមខ្លឹមសារសាលក្រម។[600]

ខុសពីយន្តការអឺរ៉ុប យន្តការបណ្ដឹងដោយបុគ្គលប្រឆាំងនឹងរដ្ឋ មិនមានចរិតជម្រើស រីឯបណ្ដឹងដោយរដ្ឋប្រឆាំងនឹងរដ្ឋ មានចរិតជាជម្រើស ។[601] នេះ ដោយសាររដ្ឋ គិតថារដ្ឋប្ដឹងប្រឆាំងនឹងរដ្ឋមួយទៀត គឺជាការជ្រៀតជ្រែកកិច្ចការងារផ្ទៃក្នុងរបស់រដ្ឋ។ បន្ថែមពីការកាត់សេចក្ដី តុលាការ មានសមត្ថកិច្ច

---

[596] *Id.*, p. 197; the American Convention on Human Rights, Art. 49, *see* Brownlie's Documents on Human Rights, *supra* note 451, p. 955.

[597] ACHR, *supra* note 596, Art. 57.

[598] *Id.*, Art. 48(e).

[599] *Id.*, Art. 48(d).

[600] *Id.*, Arts. 61, 63, 65 and 68.

[601] *Id.*, Arts. 44 and 45.

ក្នុងការស្រាយបំភ្លឺន័យខ្លឹមសារនៃវិធាន ឬបទប្បញ្ញត្តិ តាមរយៈការចេញយោបល់ប្រឹក្សា។[602]

### ៩.២.១១.៣. តំបន់អាហ្វ្រិក

អង្គការសហគមន៍អាហ្វ្រិក (the Organization of Unity of Africa: OUA) បានអនុម័តនូវឯកសារសិទ្ធិមនុស្ស។[603] ឯកសារសិទ្ធិមនុស្សនេះ បង្ហាញអំពីការភ្ជាប់សិទ្ធិទៅនឹងបរិបទសង្គមរបស់អាហ្វ្រិក។[604] សង្គមនៃតំបន់នេះ ដូចគ្នានឹងតំបន់អាស៊ី ជាទូទៅ ភ្ជាប់ការអនុវត្តច្បាប់ និងសិទ្ធិសេរីភាពទៅនឹងកាតព្វកិច្ច (Duties) ។[605] នេះអាចផ្ទុយទៅនឹង ខ្លឹមសារនៃសិទ្ធិចែងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ពីព្រោះការអនុវត្តតាមករណីយកិច្ច (Duty) នាំឲ្យមានការកម្រិតសិទ្ធិជាប្រយោល។ ឧទាហរណ៍ ការអនុវត្តតាមករណីយកិច្ច ដែលតម្រូវថា កុមារត្រូវជួយការងារសហគមន៍ អាចតម្រូវឲ្យ កុមារផ្អាក ឬបោះបង់ចោលការសិក្សា។ នេះបានបង្អាក់នូវការប្រាស្រ័យសិទ្ធិអប់រំរបស់កុមារ។ ទោះបីជាយ៉ាងនេះក្តី ឯកសារ បានចែងផ្តល់នូវសិទ្ធិទទួលបានបរិស្ថានល្អ ដែលសម្រួលដល់ការអភិវឌ្ឍ។[606] សិទ្ធិនេះ មិនមានឃើញចែងនៅក្នុងឯកសារសិទ្ធិមនុស្សរបស់តំបន់ផ្សេងទៀតទេ។

---

[602] *Id.,* Art. 64.

[603] African Charter on Human and Peoples' Rights, *see* www.achpr.org/instruments/achpr/; later one the OUA was changed to the African Union, model following the European Union, *see* Manfred, HRs Regime, *supra* note 444, p. 206.

[604] ACHPR, *supra* note 603.

[605] Manfred, HRs Regime, *supra* note 444, p.207.

[606] The right to a general satistactory environment favourable to their development, *see* ACHPR, Art. 24.

ឯកសារសិទ្ធិមនុស្សរបស់ OUA មានចែងបង្កើតគណៈកម្មការសិទ្ធិមនុស្ស ដែលទទួលពិនិត្យមើលបណ្តឹងរបស់រដ្ឋប្រឆាំងនឹងរដ្ឋ[607] របស់បុគ្គលប្រឆាំងនឹងរដ្ឋ[608] ព្រមទាំងរបាយការណ៍របស់រដ្ឋ។[609] ឯកសារ មិនបានចែងអំពីបទប្បញ្ញត្តិ ឲ្យរដ្ឋទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មការ ក្នុងការទទួលពាក្យបណ្តឹងដោយបុគ្គលទេ។ ម្ចាស់បណ្តឹងត្រូវស្វះស្វែងរកដំណោះស្រាយក្នុងស្រុកជាមុនសិនមុននឹងប្តឹងទៅគណៈកម្មការ។[610] ឯកសារ ក៏មិនបាននិយាយអំពី អ្វីទៅជាដំណោះស្រាយ ក្នុងករណីដែលរកឃើញថា រដ្ឋបានរំលោភសិទ្ធិបុគ្គល ដូចដែលមានចោទនៅក្នុងពាក្យបណ្តឹង។ បទប្បញ្ញត្តិដែលពាក់ព័ន្ធ គ្រាន់តែបានចែងឲ្យគណៈកម្មការ ធ្វើរបាយការណ៍ជូនសន្និបាតរបស់ប្រមុខដឹកនាំរដ្ឋ។[611] តាមការអនុវត្ត គណៈកម្មការ អាចត្រឹមតែចេញនូវអនុសាសន៍ ដែលមិនចងជាកាតព្វកិច្ច ដែលក្នុងនោះទាមទារឲ្យរដ្ឋចេញនូវសំណងសមស្របដល់ជនរងគ្រោះ។[612] វាអាចជាមូលហេតុនេះហើយ ដែល OUA បានអនុម័តពិធីសារ ដើម្បីបង្កើតនូវតុលាការសិទ្ធិមនុស្ស ដើម្បីជួយធ្វើឲ្យកាន់តែប្រសើរនូវការគោរព និងការការពារសិទ្ធិមនុស្សក្នុងតំបន់អាហ្វ្រិក។[613] មកដល់ពេលនេះ ពិធីសារទទួលបានការយល់ព្រមពីរដ្ឋ

[607] The African Commission on Human and Peoples'Rights, *see* ACHPR, Chapters I and III, Arts. 30 and 47.

[608] ACHPR, Arts. 55 and 56.

[609] *Id.,* Art. 62.

[610] *Id.,* Arts. 48, 50 and 52.

[611] *Id.*, Art. 59.

[612] 373/09 INTERIGHTS, Institute for Human Rights and Development in Africa/Mauritania, Decision on 3 March 2010 of the Commission on Human and Peoples'Rights, para. 64, *see* www.achpr.org/communications/decisions/373.09/.

[613] Protocol to the African Charter on Human and Peoples's Rights on the Establishment of the African Court on Human and Peoples'Rights, *see* www.achpr.or/documents/court-establishment.

ចំនួន ២៤ នៃរដ្ឋសរុបទាំង ៥៤ ដែលលើសចំនួន សម្រាប់ធ្វើឲ្យពិធីសារចូលជាធរមាន។[614] ដូចនេះ ដំណើរការរៀបចំតុលាការ និងកំពុងត្រូវបានឈានទៅមុខ។

### ៩.២.១១.៤. តំបន់ដទៃទៀត

នៅក្នុងតំបន់ ឬក្រុមប្រទេសដទៃទៀត ដូចជាអារ៉ាប់ មិនមានសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សទេ មានតែសេចក្តីថ្លែងការណ៍ តែប៉ុណ្ណោះ។[615]

ថ្មីៗនេះ បន្ទាប់ពីមានការខិតខំជាយូរមកហើយ តំបន់អាស៊ីអាគ្នេយ៍ (Association of Southeast Asian Nations: ASEAN) បានផ្តួចផ្តើមបង្កើតយន្តការសិទ្ធិមនុស្សប្រចាំតំបន់នេះ។ ក្រោយពីមាន ធម្មនុញ្ញរបស់អាស៊ានសមាគម បានបង្កើតចេញនូវគណៈកម្មការសិទ្ធិមនុស្សអន្តររដ្ឋាភិបាល។[616] សមាគម កំពុងតែពិនិត្យមើល សេចក្តីព្រាងសេចក្តីថ្លែងការណ៍ អាស៊ាន

[614] The Protocol demands fifteen instruments of ratification or accession, *see* Article 34 of the Protocol, *see* www.achpr.or/documents/court-establishment (accessed on 27 July 2012).

[615] The ASEAN Intergovernmental Commission on Human Rights (AICHR) was established pursuant to Article 14 of the ASEAN Charter, for Term of References of the AICHR, *see* www.aseansec.org/22769.htm (accessed on 27 July 2012); Cairo Declaration on Human Rights in Islam (1990); Arab Charter on Human Rights (2004), *see* Brownlie's Documents on Human Rights, *supra* note 451, pp. 1111 and 1120.

[616] Points 4.2 and 4.7 of the Term of References of AICHR; the Charter of the Association of Southeast Asian Nations was adopted in Singapore on 20 November 2007, see www.aseansec.org/145.htm (accessed on 27 July 2012).

ស្តីពី សិទ្ធិមនុស្ស។[617] ឯកសារអាណត្តិការងារ (Term of Referrences) របស់គណៈកម្មការ បានចូលជាធរមានហើយ។[618] មកដល់ពេលនេះ គណៈកម្មការ បានកោះប្រជុំចំនួន ៤លើក។[619]

ការបង្កើតយន្តការសិទ្ធិមនុស្សសម្រាប់ ASEAN គឺជាការវិវត្តជាវិជ្ជមានមួយ។ ទោះបីជា គណៈកម្មការ មិនមែនជាតុលាការ មានសមាសភាព ដែលជាតំណាងរដ្ឋាភិបាល[620] និងមានអំណាចត្រឹមតែពិគ្រោះ ឬតាក់តែងឯកសារសិទ្ធិមនុស្សសម្រាប់សមាគមក្តី[621] វាជាការចាប់ផ្តើមមួយ ដែលគួរតែស្វាគមន៍។ វាជានិន្នាការទូទៅហើយ ដែលយន្តការដំបូងមួយ មានការងារត្រឹមតែធ្វើនូវលិខិតបទដ្ឋាន មុនមានអំណាចពេញលេញក្នុងការអនុវត្តឲ្យមានប្រសិទ្ធភាពនាពេលខាងមុខ។ ក្នុងរយៈពេលយូរ ឬឆាប់ គណៈកម្មការ អាចក្លាយទៅជាតុលាការ តាមរយៈការធ្វើវិសោធនកម្មឯកសារពាក់ព័ន្ធ ឬឯកសារបង្កើតថ្មី ដែលធ្វើឲ្យ គណៈកម្មការទទួលបានអំណាចច្រើនជាងមុន។

### ៩.២.១២. បញ្ហាមួយចំនួនពាក់ព័ន្ធសិទ្ធិមនុស្ស

#### ៩.២.១២.១. ការការពារសិទ្ធិមនុស្ស និង ការបង្ក្រាបភេរវកម្ម

បញ្ហាសិទ្ធិមនុស្ស និង ការបង្ក្រាបអំពើភេរវកម្ម ជាបញ្ហាចម្រូងចម្រាសមួយនាពេលបច្ចុប្បន្ននេះ។ នេះដោយសារ មានចលនាទាមទារការផ្តាច់ខ្លួនពីរដ្ឋ

[617] Press Release of the Fourth Meeting of the AICHR on the ASEAN Human Rights Declaration, Jakarta, 9-11 April 2012, *see* www.aseansec.org/22769.htm.
[618] CHA-AM HUA HIN Declaration on the Intergovernmental Commission on Human Rights, *see* www.aseansec.org/22769.htm.
[619] Press Release of the Fourth Meeting of the AICHR on the ASEAN Human Rights Declaration, *supra* note 617.
[620] Points 5.1 and 5.2 of the Term of References (in files of the author).
[621] *Id.*, point 4. 7.

ដោយសន្តិវិធី តែក្រោយមកបានក្លាយជាអំពើហិង្សា ដែលនាំឲ្យអាជ្ញាធររដ្ឋបង្ក្រាប និងដាក់ក្រុមមនុស្សណាមួយជាក្រុមភេរវករ។

ក្រោយពីមានអំពើវាយប្រហារនៅថ្ងៃទី ១១ខែ កញ្ញា ឆ្នាំ ២០០១ ដោយក្រុមភេរវករនៅមជ្ឈមណ្ឌលពាណិជ្ជកម្មក្នុងសហរដ្ឋអាមេរិក ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានចេញនូវសេចក្តីសម្រេចមួយ ផ្អែកតាមជំពូកទី ៧របស់ធម្មនុញ្ញអង្គការសហប្រជាជាតិ។[622] សេចក្តីសម្រេចនេះ ចងជាកាតព្វកិច្ចដល់រដ្ឋ ហើយតម្រូវឲ្យរដ្ឋ ធ្វើច្បាប់ចាត់អំពើភេរវកម្មជាបទឧក្រិដ្ឋ[623] និងគាំទ្រគ្នាទៅវិញទៅមក តាមរយៈការធ្វើបត្យាប័នបញ្ជូនជនសង្ស័យទៅទទួលការកាត់ទោស[624] ជានាមិនឲ្យជនសង្ស័យ ទទួលបាននូវឋានៈជាជនភៀសខ្លួន។[625] នេះសំដៅធ្វើយ៉ាងណាកុំឲ្យ ជនសង្ស័យជាភេរវករ រួចផុតពីសំណាញ់ច្បាប់។

ជាការឆ្លើយតប រដ្ឋជាច្រើន ជាពិសេសនៅក្នុងទ្វីបអឺរ៉ុប បានធ្វើច្បាប់ចែងកំណត់ន័យនៃអំពើភេរវកម្មយ៉ាងទូលាយ ដែលនាំឲ្យមានការបំពារបំពានសិទ្ធិមនុស្ស។[626] បន្ថែមពីលើនេះ មានការអនុវត្តច្បាប់ជាតិ ដោយបំពារបំពានសំដៅដល់ក្រុមមនុស្សមួយប្រភេទ ដែលនាំឲ្យមានការរំលោភគោលការណ៍មិនរើសអើង។[627]

[622] Resolution 1373, 28 September 2001, S/RES/1373 (2001), preamble.
[623] *Id.*, para. 1(b).
[624] *Id.*, paras. 2(f) and 3(e).
[625] *Id.,* para. 3(g).
[626] Report of the Special Rapporteur on the Promotion and Protection of Human Rights and Fundamental Freedoms While Countering Terrorism, 22 December 2012, A/HRC/16/51, paras 26 and 28.
[627] Commentary on Berlin Declaration, *supra* note 280, p. 7.

ក្រៅពីភាពងាយរងទទួលទារុណកម្ម ដើម្បីទទួលបាននូវចម្លើយសារភាព ជនសង្ស័យទទួលរងការរឹតត្បិតនូវ សិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ដូចជាកាត់សេចក្តីដោយសង្ខេបដោយតុលាការយោធា ឬដោយចៅក្រមលាក់អត្តសញ្ញាណដោយបិទបាំងមុខ[628] រងនូវការឃុំខ្លួនហួសពេលកម្រិត និង ឃុំខ្លួនដោយគ្មានការទាក់ទងទៅពិភពខាងក្រៅ (*Incommunicado* Detention) និង ទារុណកម្មជាដើម។[629]

ជនសង្ស័យជាភេរវករ ត្រូវបានរដ្ឋធ្វើបត្យាប័នបញ្ជូនទៅ រដ្ឋដទៃទៀត ដែលនឹងអាចរងនូវអំពើទារុណកម្ម និង ការកាត់សេចក្តីដោយអយុត្តិធម៌។[630]

### ៩.២.១២.២. ទ្រឹស្តី និងប្រយោជន៍នៃការគោរពសិទ្ធិមនុស្ស

ការវិវត្តនៃការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស មិនមែនជារឿងចៃដន្យទេ។ វាកកើតឡើងដោយសារព្រឹត្តិការណ៍ដ៏ជូរចត់ក្នុងប្រវត្តិសាស្ត្រ។ គោលបំណងរួម នៃការការពារ គឺដើម្បីសុខសន្តិភាពក្នុងប្រទេសនីមួយៗ។ សិទ្ធិមនុស្សមានប្រភពចេញពីលទ្ធិសាសនា ដែលមានគោលដៅដូចគ្នា គឺការរស់នៅដោយសុខសន្តិភាព។

[628] View of the Human Rights Committee, 6 November 1997, Communication No. 577/1994, CCPR/C/61/D/577/1994, para. 2.2; Roza Pati, Due Process and International Terrorism, An International Legal Analysis, 2009, p. 454; Commentary on Berlin Declaration, *supra* note 280, p. 64.

[629] Report of the Special Rapporteur, Countering Terrorism, *supra* note 626, paras 37; Human Rights Watch, Fighting Terrorism Fairly and Effectively, Recommendations for President-Elect Barack Obama, November 2008, pp. 16-17, see www.hrw.org/reports.

[630] Commentary on Berlin Declaration, *supra* note 280, p. 93.

សិទ្ធិមនុស្សសព្វថ្ងៃ មានឫសគល់ពីទ្វីបអឺរ៉ុប[631] ហើយគេ អាចនិយាយបានថា មានចរិតឧត្តមគតិនិយមពេក (Idealism) ដែលសូម្បីប្រទេសអឺរ៉ុប ដែលជាអ្នកត្រួសត្រាយគំនិតគោរពសិទ្ធិមនុស្ស និង ជាប្រទេសប្រជាធិបតេយ្យ មានសន្តិភាពយូរមកហើយ ក៏មិនអាចប្រកាន់ខ្ជាប់ខ្ជួនតាមការតម្រូវ របស់វិធានសិទ្ធិមនុស្ស ១០០ភាគរយឡើយ។ នេះដោយសារ បញ្ហាសិទ្ធិមនុស្ស មានការវិវត្តឥតឈប់ឈរ។

ទ្រឹស្តី មិនសមស្របតាមបរិបទនៃប្រទេស ឬសង្គម បាននាំឲ្យការអនុវត្តមិនបានល្អដូចការចង់បាន។ គួបផ្សំជាមួយការបូកបញ្ចូលផលប្រយោជន៍នយោបាយជាមួយការគោរពសិទ្ធិមនុស្ស ការគោរពស្ថិតនៅឆ្ងាយពីទ្រឹស្តី។ រដ្ឋ ឬក្រុមរបស់រដ្ឋនីមួយៗបានផ្តល់អាទិភាពដល់សិទ្ធិផ្សេងគ្នា និង លើកហេតុផ្សេងៗសម្រាប់យកមកដោះសារ ក្នុងការខកខានមិនគោរពសិទ្ធិមនុស្ស។

រដ្ឋមួយក្រុមយល់ថា សិទ្ធិនយោបាយមានសារៈសំខាន់ ហើយទាមទារឲ្យក្រុមរដ្ឋដទៃជំរុញការគោរពសិទ្ធិមនុស្ស។ ក្រុមរដ្ឋផ្សេងគិតថា ប្រទេសខ្លួននៅក្រីក្រ ដូចនេះ ត្រូវការជានាជីវភាពរស់នៅសមស្របរបស់ប្រជាពលរដ្ឋ ដែលនេះបង្ហាញថា ពួកគេចង់ជំរុញនូវសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច មុនការជំរុញការគោរពសិទ្ធិនយោបាយ។ ទាញចេញពីចំណុចនេះ ទ្រឹស្តីជាច្រើនត្រូវបានបង្កើតឡើង ដូចជាការអះអាងថា សិទ្ធិសេដ្ឋកិច្ច មិនអាចត្រូវបានកាត់សេចក្តីថាខុស ឬមិនខុស ដោយតុលាការឡើយ។ សិទ្ធិនយោបាយ ត្រូវតែបានអនុវត្តយ៉ាងពេញលេញ និងជាបន្ទាន់ក្រោយពេលរដ្ឋក្លាយជាភាគី។

---

[631] Philip Alston, *the Universal Declaration at 35: Western and Passe or Alive and Universal*, 31 the Review of International Commission of Jurists (1983), p. 61.

ទោះបីជាយ៉ាងនេះក្តី សេចក្តីថ្លែងការណ៍ ជាលទ្ធផលនៃ សន្និសីទរបស់ពិភព លោកលើកទី១ ស្តីពីសិទ្ធិមនុស្ស បានកំណត់យ៉ាងច្បាស់ថា សិទ្ធិនយោបាយ និងសេដ្ឋកិច្ច មិនអាចត្រូវបានផ្តាច់ពីគ្នា ហើយសិទ្ធិទាំងពីរប្រភេទនេះ អាស្រ័យនឹងគ្នាទៅវិញទៅមក។[632] ក៏ប៉ុន្តែ ជាការអនុវត្តគំនិតផ្ទុយពីនេះនៅ តែមាននៅឡើយ។

ដោយសារសិទ្ធិមិនទាន់ឆ្លើយតបទៅនឹងបរិបទនៃសង្គម ប្រទេស និងតំបន់ ឯកសារសិទ្ធិ និងយន្តការសម្រាប់តំបន់នីមួយៗ ត្រូវបានបង្កើតឡើង ដូច ដែលមាននិយាយក្នុងទំព័រមុន។ ដោយសារតែ ការមិនទុកចិត្តលើវិធានសិទ្ធិ មនុស្សនេះហើយ ទើបយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ មិន ត្រូវគេផ្តល់អំណាចច្រើន ក្នុងតាមដាន និងឃ្លាំមើលការការពារសិទ្ធិមនុស្ស ទេ។ ទោះបីជាយ៉ាងនេះក្តី អ្នកនិពន្ធបានកត់សម្គាល់ថា មានការវិវត្តជាច្រើន ទាំងវិធាន និងយន្តការ ហើយវិធាននិងយន្តការ ត្រូវបានបញ្ជ្រាបដល់ប្រព័ន្ធ ច្បាប់ជាតិ។ ច្បាប់របស់រដ្ឋ បានសរសេរបញ្ចូលវិធាន សិទ្ធិមនុស្ស។ យន្តការ ឃ្លាំមើលសិទ្ធិមនុស្សថ្នាក់ជាតិ ជាច្រើនត្រូវបានបង្កើត។

វាជាការលំបាកណាស់ ដែលទ្រឹស្តីសិទ្ធិមនុស្សមានប្រភពពីទ្វីបអឺរ៉ុប បង្កើត ជាង ១០០ឆ្នាំមុន ត្រូវបានបញ្ជ្រាបចូលក្នុងក្របខ័ណ្ឌច្បាប់របស់រដ្ឋ នាពេល ដែលរចនាសម្ព័ន្ធរបស់រដ្ឋ ធនធានមនុស្ស និងក្របខ័ណ្ឌច្បាប់ ធ្លាក់ចូល ក្នុងរបត់មួយ ដែលមិនទាន់សមស្របសម្រាប់ការធានាការគោរពសិទ្ធិមនុស្ស ។ នេះតម្រូវឲ្យអ្នករិះគន់ គិតគូរពិចារណា មុននឹងរិះគន់ស្ថានភាពសិទ្ធិ មនុស្សរបស់ប្រទេសមួយ។ ដោយយល់ឃើញនូវការលំបាកនេះ ប្រសិន

[632] Vienna Declaration and Programme of Action, para. 5, *see* Brownlie's Documents on Human Rights, *supra* note 451, p. 151.

បើរដ្ឋពិតជាបានខិតខំ តែនៅតែមានចន្លោះខកខានមិនបានធានាសិទ្ធិមនុស្ស ឲ្យបានមួយរយភាគរយ សាធារណជនពិតជាមានការយោគយល់។ ដោយសាររដ្ឋចូលជាភាគីសិទ្ធិសញ្ញាសិទ្ធិមនុស្សដោយស្ម័គ្រចិត្ត រដ្ឋត្រូវតែគោរពតាមកាតព្វកិច្ច ធ្វើឲ្យបានតាមការទាមទាររបស់សន្ធិសញ្ញា។ រដ្ឋនឹងទទួលបានការកោតសរសើរ ហើយសង្គមនឹងមានសុខសន្តិភាព។

ប្រមុខអ្នកដឹកនាំប្រទេស ជារឿយៗ ថ្លែងចំណាប់អារម្មណ៍អំពីប្រយោជន៍នៃការគោរពសិទ្ធិមនុស្ស នីតិរដ្ឋ (Rule of Law) និងប្រជាធិបតេយ្យ។ សិទ្ធិមនុស្ស ជួយលើកតម្កើងប្រជាធិបតេយ្យ និងនីតិរដ្ឋ។[633] សេដ្ឋកិច្ចប្រទេសមួយរីកចម្រើន ប្រជាជនមានជីវភាពធូរជារ តែបើសង្គមគ្មានយុត្តិធម៌ ដោយសារប្រព័ន្ធច្បាប់មិនរឹងមាំ តុលាការគ្មានឯករាជ្យ មិនអាចធានាយុត្តិធម៌ជូនសង្គម ការបែងចែកផលនៃកំណើនសេដ្ឋកិច្ចមិនស្មើគ្នា ឱកាសនៃការបង្កើតចំណូលមានសម្រាប់តែក្រុមអ្នកមានលុយ និងអំណាច អាចនឹងធ្វើឲ្យគម្លាតអ្នកមាន និងអ្នកក្រកាន់តែធំ ហើយក្នុងរយៈពេលវែង បើបញ្ហានេះមិនបានដោះស្រាយ សង្គមអាចនឹងមានបញ្ហាអស្ថេរភាពនាពេលខាងមុខ។ វិបត្តិនៅក្នុងប្រទេសអ៊ីរ៉ាក់ ដែលនាំឲ្យមានដួលរលំរបបសាដាម ហ៊ូសេន ជាឧទាហរណ៍មួយយ៉ាងជាក់លាក់។ គ្មាននរណាមួយរំពឹងថាមានព្រឹត្តិការណ៍ដូចនេះកើតឡើងឡើយ ដោយសារប្រជាពលរដ្ឋប្រទេសនេះ

633 Leonardo Morlino and Gianluigi Palombella, Rule of Law and Democracy, 2010, pp. 47-48; Commission Communication to the Council and Parliament, Democratization, the rule of law, respect for human rights and good governance: the challenges of the partnership between the Euroepan Union and the ACP States, COM (98) 146, 1998, p. 4; Asian Human Rights Commission, Rule of Law and Human Rights in Asia, 2006, pp. 1-2.

ទទួលបានចំណូលពីប្រេងកាតដ៏ច្រើនសន្ធឹកសន្ធាប់។ បញ្ហាអយុត្តិធម៌ក្នុងសង្គម និងការដឹកនាំផ្តាច់ការ ជាមូលហេតុនៃការដួលរលំនេះ។

## ៩.៣. ការការពារបុគ្គលក្នុងពេលមានសង្គ្រាម

### ៩.៣.១. ប្រវត្តនៃច្បាប់មនុស្សធម៌អន្តរជាតិ

សង្គ្រាមបានបំផ្លាញទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ ធ្វើឲ្យបាត់បង់ជីវិតមនុស្ស នាំឲ្យមានជនភៀសខ្លួន រំលោភសិទ្ធិមនុស្ស ប៉ះពាល់សេដ្ឋកិច្ច បរិស្ថាន។ ចុងបញ្ចប់នៃសង្គ្រាម សហគមន៍អន្តរជាតិ បានទាមទារឲ្យមានការបង្កើតតុលាការ នាំខ្លួនឧក្រិដ្ឋជនទៅទទួលខុសត្រូវ ដែលត្រូវចំណាយធនធាន។ វិនាសកម្មនៃសង្គ្រាម និង ភាពគ្មានការការពារបុគ្គល បាននាំឲ្យមានគំនិតនៃការបង្កើតបទវិធានច្បាប់មួយចំនួន បង្កើតយន្តការ ដូចជាគណៈកម្មាធិការជាតិដើម្បីជួយអ្នករងរបួសដោយសារសង្គ្រាម។

ក្រោមច្បាប់អន្តរជាតិ វិធានសម្រាប់អនុវត្តក្នុងពេលគ្មានសង្គ្រាម និងមានសង្គ្រាម មិនដូចគ្នាទេ បើទោះបីជាវិធានទាំងពីរមានទំនាក់ទំនង និងជួនកាលត្រូវបានប្រើប្រាស់ស្របជាមួយគ្នា។ វិធានសម្រាប់ពេលមានសង្គ្រាម គឺជាវិធានច្បាប់មនុស្សធម៌អន្តរជាតិ។ មូលហេតុនៃការនាំឲ្យកកើតឡើងនូវវិធានទាំងនេះ គឺដើម្បីឆ្លើយតប និង បញ្ចៀសនូវការឈឺចាប់ ដែលកើតមានឡើងក្នុងពេលមានសង្គ្រាម តាមរយៈ ការហាមឃាត់នូវវិធី និងមធ្យោបាយនៃការធ្វើសង្គ្រាម និងការដាក់កាតព្វកិច្ចមួយចំនួន ដល់រដ្ឋ និងភាគី ដែលចូលរួមធ្វើសង្គ្រាម។

វិធានច្បាប់មនុស្សធម៌អន្តរជាតិ បានកើតមានជាយូរយារមកហើយ តាំងពីឆ្នាំ ១៨៧៨ (Brussel Declaration) និងចាប់ផ្តើមចេញជារូបរាងក្នុងទម្រង់ជាសន្ធិសញ្ញា ក្នុងឆ្នាំ ១៩០៧ រួចត្រូវបានអភិវឌ្ឍជាហូរហែមកដល់ពេលបច្ចុប្បន្ន។ វិធានជាច្រើននៃវិធាននេះ ត្រូវបានចាត់ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ[634] និងក្លាយជាវិធានជាសាកលមួយ។ រដ្ឋទាំងអស់ បានចូលជាភាគីនៃសន្ធិសញ្ញា ទីក្រុង ហ្សឺណែវ។ ច្បាប់មនុស្សធម៌អន្តរជាតិ មិនតម្រូវគោរពគោលការណ៍ Principle of Reciprocity ដែលមានន័យថា លុះត្រាតែរដ្ឋអនុវត្ត ទើបរដ្ឋដទៃអនុវត្តចំពោះខ្លួនដែរ។ ដូចគ្នានេះដែរ វិធាននៅតែចងជាកាតព្វកិច្ចដល់រដ្ឋ ដែលបំបែកខ្លួន ហើយក្រោយមក ក្លាយជារដ្ឋថ្មីមួយ ទោះបីរដ្ឋនេះមិនមែនជាភាគីសន្ធិសញ្ញាក្តី។[635] នេះដោយសារ អ្នកទទួលប្រយោជន៍ពីសន្ធិសញ្ញា គឺបុគ្គល មិនមែនជារដ្ឋទេ។ ដូចនេះ ការផ្លាស់ប្តូររបបណាមួយ មិនប៉ះពាល់ដល់ការប្រាស្រ័យសិទ្ធិរបស់បុគ្គលឡើយ។

មានសន្ធិសញ្ញាជាច្រើន ចែងអំពីវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិ ដូចជាសន្ធិសញ្ញា ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ទាំងបួន ពិធីសារបន្ថែមទាំងបី និងសន្ធិសញ្ញាផ្សេងទៀត ដែលពាក់ព័ន្ធនឹងសង្គ្រាម ដូចជាសន្ធិសញ្ញាហាមឃាត់អាវុធគីមី។ សន្ធិសញ្ញាហ្សឺណែវ ទី១ ពាក់ព័ន្ធនឹងការការពារទាហានរងរបួស និងមានជំងឺនៅក្នុងសមរភូមិលើដីគោក។ សន្ធិសញ្ញាទី២

634 The Prohibition of transfer of people mentioned in article 8 of the Rome Statute (the Rome Statute of the International Criminal Court) is not customary international law. For the Rome Statute, see www.icc-cpi.int.

635 ICJ, Case Concerning Application of the Convention on the Prevention and Punishment of the Crime of Genocide, *Croatia v. Yugoslavia*, preliminary objections of the federal republic of Yugoslavia, 2002, para. 3.53; Menno T.Kamminga, inter-state accountability, *supra* note 420, pp. 134-135; Menno T.Kamminga, *State Succession in Respect of Human Rights Treaties*, 7 EJIL (1996), pp. 472 and 474.

គឺការពារទាហាននៅលើដែនទឹក ដែលជាជនរងគ្រោះ ដោយសារការខូតខាតកប៉ាល់។ សន្ធិសញ្ញាទី ៣ សម្រាប់ការពារឈ្លើយសឹក និងទី ៤ សម្រាប់ការពារជនស៊ីវិល។ ដោយសារសេចក្តីត្រូវការនៃភាពលម្អិតរបស់វិធាន និងឆ្លើយតបទៅនឹង ការវិវត្ត ពិធីសារសំខាន់ចំនួន៣ទៀត ត្រូវបានអនុម័ត ។ ទី ១ ទាក់ទងជាមួយការការពារ ជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ (១៩៧៧) និង ទី២ ស្តីពី ការការពារជនរងគ្រោះ នៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ។ ពិធីសារទី៣ គឺចែង ពាក់ព័ន្ធ ស្លាកសញ្ញា (Emblem) និងការប្រើប្រាស់។[636]

ជាសរុប មានសន្ធិសញ្ញាចំនួនពីរប្រភេទ។ ទី១ ពាក់ព័ន្ធជាមួយការការពារមនុស្ស (Geneva Law) និង Hague Law ពាក់ព័ន្ធជាមួយវិធីសាស្រ្ត និងមធ្យោបាយធ្វើសង្គ្រាម។

### ៩.៣.២. សង្គ្រាមអន្តរជាតិ និងមិនមែនអន្តរជាតិ

សង្គ្រាមត្រូវបានចែកចេញជាពីរប្រភេទ។ ការចាត់ប្រភេទនៃសង្គ្រាម វាជាការចាំបាច់ ពីព្រោះថា វិធានអនុវត្តសម្រាប់ប្រភេទនៃសង្គ្រាមនីមួយៗ មានភាពខុសគ្នា ទោះបីនាពេលបច្ចុប្បន្ន មានវិធានជាច្រើនត្រូវបានទាមទារឲ្យអនុវត្ត ដោយមិនគិតដល់ប្រភេទនៃសង្គ្រាម ឧទាហរណ៍ គោលការណ៍នៃការបែងចែកក្រុមមនុស្សជាទិសដៅនៃការវាយប្រហារ (the Principle of Distinction)។ នាពេលបច្ចុប្បន្ននេះ មានការពិបាក ក្នុងការបែងចែកប្រភេទសង្គ្រាម។

---

[636] *See* www.icrc.org/eng

សង្គ្រាមអន្តរជាតិជាសង្គ្រាមរវាងរដ្ឋ និងរដ្ឋ ដោយប្រើសព្វាវុធ ឬជាសង្គ្រាមរបស់រដ្ឋមួយចូលកាន់កាប់រដ្ឋមួយទៀត។ ការណ៍ដែលរដ្ឋមួយ អញ្ជើញរដ្ឋមួយ ទៀតឲ្យចូល មកកាន់កាប់ខ្លួនមិនមែនជាសង្គ្រាមឡើយ។ វាមិនទាមទារឲ្យមានការប្រកាសសង្គ្រាមជាផ្លូវការទេ។[637]សន្ធិសញ្ញាជាច្រើន អនុវត្តចំពោះសង្គ្រាមប្រភេទនេះ ដូចជាសន្ធិសញ្ញាទីក្រុងហ្សឺណែវទាំងបួន លើកលែងបទប្បញ្ញត្តិរួម (Common Article 3) របស់សន្ធិសញ្ញាទាំងនេះ។ ស្រដៀងគ្នានេះដែរ វាអាចជាសង្គ្រាមមិនអន្តរជាតិ រវាងរដ្ឋ និងកងកម្លាំងប្រដាប់អាវុធក្នុងស្រុក តែមានការចូលរួម ដោយរដ្ឋមួយទៀត គាំទ្រដល់ក្រុមប្រដាប់អាវុធ (Internationalization of Non International Armed Conflict)។ នេះគឺករណីរវាង Nicaragua និង Elsavador។[638]

សន្ធិសញ្ញាដែលពាក់ព័ន្ធមិនបាន ផ្តល់ន័យអ្វីទាំងជាសង្គ្រាមមិនមែនអន្តរជាតិឡើយ។ យុត្តិសាស្ត្រ និងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានផ្តល់ន័យថា វាជាជម្លោះប្រដាប់អាវុធ បន្លាយពេលវេលា បង្កឡើងរវាងកងទ័ពរដ្ឋាភិបាល និងក្រុមប្រដាប់អាវុធ។[639] មួយរយៈចុងក្រោយនេះ ជាពិសេសក្រោយពីការបញ្ចប់សង្គ្រាមត្រជាក់ សង្គ្រាមប្រភេទនេះ មានទម្រង់ផ្សេងទៅតាមក្រុមប្រដាប់អាវុធដែលចូលរួមធ្វើសង្គ្រាម។ សង្គ្រាមស្ថិតនៅក្នុង

[637] ICRC Opinion paper, March 2008, p. 1 (www.icrc.org/eng/assets/files/other/opinion-paper-armed-conflict.pdf); ICTY, the *Prosecutor v. Dusko Tadic*, Decision on the Defence Motion for Interlocutory Appeal on Jurisdiction, IT-94-1-A, 2 October 1995, para. 70.

[638] There is fighting during the Cold War period withing the territory of Elsavador between this governmental troops and armed group alledgedly supported by the Governement of Nicaragua.

[639] ICTY, *the Prosecutor v. Dusko Tadic*, Judgement, IT-94-1-T, 7 May 1997, para. 561-568.

ប្រភេទនេះ ដែលមានតាំងពីទសវត្សរ៍ឆ្នាំ ៦០ គឺសង្គ្រាមទាមទារឯករាជ្យ ធ្វើឡើងរវាង រដ្ឋអាណានិគម និងចលនាក្នុងស្រុក អនុវត្តសិទ្ធិស្វ័យសម្រេច និងទាមទារឯករាជ្យ។ វាជាសង្គ្រាមរវាងរដ្ឋាភិបាល និងក្រុមប្រដាប់អាវុធ ឬជាសង្គ្រាមរវាងក្រុមប្រដាប់អាវុធ នៅក្នុងដែនដីរបស់រដ្ឋមួយ (ករណីប្រទេសស៊ីរី)។

គួរមានការកត់សម្គាល់ថា មិនមែនព្រឹត្តិការណ៍រវាងកងកម្លាំងរដ្ឋាភិបាល និងក្រុមប្រដាប់អាវុធ សុទ្ធតែត្រូវបានចាត់ថា ជាសង្គ្រាមមិនមែនអន្តរជាតិឡើយ។ ការពិចារណាត្រូវបានធ្វើឡើង តាមករណីនីមួយៗ ដោយពិនិត្យទៅលើវិសាលភាពនៃការវាយប្រហារ ចំនួនមនុស្សស្លាប់ រចនាសម្ព័ន្ធនៃក្រុមប្រដាប់អាវុធ និង អំណាចរបស់ពួកគេ។ តើក្រុមនេះអាចជ្រើសរើស ឬកេណ្ឌមនុស្សធ្វើជាទាហានបានឬទេ?។ វាជាការច្បាស់លាស់ថា ការបង្ក្រាបបាតុកម្ម មិនមែនជាសង្គ្រាមក្នុងស្រុកទេ។[640]

វិធានដែលប្រើសម្រាប់ សង្គ្រាមប្រភេទនេះ គឺ Common Article 3 និងពិធីសារបន្ថែម ទី ២ របស់សន្ធិសញ្ញា ទីក្រុងហ្សឺណែវ ព្រមទាំងច្បាប់ទំនៀមទម្លាប់ដទៃទៀត។[641] មកដល់ពេលនេះ មិនមានរដ្ឋណា ជំទាស់អំពី

[640] ICRC Opinion paper, March 2008, p. 3, *supra* note 637, *Prosecutor v. Akayesu*, ICTR, Case No. ICTR-96-4, Judgement of September 2, 1998, para. 620; the *Prosecutor v. Rutaganda*, Case No. ICTR 96-3-T of December 6, 1999, para. 92; the *Prosecutor v. Kayishema and Ruzindana*, Case No. ICTR 95-1-T of May 21, 1999, para. 171.

[641] Geneva Convention (I) on Wounded and Sick in Armed Forces in the Field; Geneva Convention (II) on the Wounded, Sick and Shipwrecked of Armed Forces at Sea; Geneva Convention (III) on Prisoners of War; and Geneva Convention (IV) on Civilians, Common Art. 3, *see* www.icrc.org/applic/ihl/ihl.nsf/ vwTreaties1949 .xsp; the Rome Statute, *supra* note 634, Art. 21.

វិធានទាំងនេះឡើយ។ អ្វីដែលត្រូវបានជំទាស់ គឺការដាក់ឲ្យបុគ្គលទទួលខុសត្រូវ ចំពោះអំពើឧក្រិដ្ឋប្រព្រឹត្ត នៅក្នុងពេលសង្គ្រាមមិនមែនអន្តរជាតិ។ ការអះអាងរបៀបនេះត្រូវបានបដិសេធចោលរួចហើយ ដោយឈរលើមូលដ្ឋានថា វាមិនសមហេតុផលទេ ដែលជនប្រព្រឹត្តបទឧក្រិដ្ឋប្រព្រឹត្ត ក្នុងសង្គ្រាមមួយ ត្រូវបានកាត់ទោស តែឧក្រិដ្ឋជននៃសង្គ្រាមមួយទៀត មិនអាចត្រូវបានកាត់ទោស។ មាត្រា ៨នៃ លក្ខន្តិកៈទីក្រុងរ៉ូម ដាក់បទឧក្រិដ្ឋប្រព្រឹត្តក្នុងសង្គ្រាមមិនមែនអន្តរជាតិ ក្នុងយុត្តាធិការរបស់ខ្លួន សម្រាប់ធ្វើការចោទប្រកាន់។[642]

### ៩.៣.៣. គោលការណ៍ចម្បងនានា

### ៩.៣.៣.១. គោលការណ៍បែងចែក និងហាមឃាត់ការវាយប្រហារមិនរើសមុខ

គោលការណ៍នេះទាមទារឲ្យការវាយប្រហារ ត្រូវធ្វើទៅលើវត្ថុរបស់ទាហាន (Mlitary Object) ដូចជាយន្តហោះទាហាន និងបម្រើគោលដៅយោធា (Military Purpose)។ នេះទាមទារឲ្យមានការបែងចែករវាងទាហាន និងជនស៊ីវិល ដើម្បីធ្វើយ៉ាង ណាកុំឲ្យប៉ះពាល់ជនស៊ីវិលច្រើនពេក។ ការវាយប្រហារជាការសងសឹក អាចនាំឲ្យមានការសម្លាប់មិនរើសមុខ រាប់បញ្ចូលទាំងជនស៊ីវិល ដូចនេះ សន្ធិសញ្ញា បានហាមឃាត់ការវាយប្រហារ ដែលគ្រាន់តែជាការសងសឹក។[643] គោលការណ៍បែងចែកពាក់ព័ន្ធដល់ការប្រើប្រាស់ប្រភេទសព្វាវុធ ពីព្រោះសព្វាវុធខ្លះ បង្កផលប៉ះពាល់មិនរើសមុខ និងបង្កការឈឺចាប់ដែលមិនចាំបាច់។ ក្នុងន័យនេះ ការវាយប្រហារមិនរើស

[642] The Rome Statute, *supra* note 634, Art. 8.

[643] Louise Doswald-Beck, *International Humanitarian Law and Human Rights Law*, 293 International Review of the Red Cross, 1993.

មុខត្រូវបានហាមឃាត់ (Priniple of Prohibition of Nondiscrimation Attack)។ ដើម្បីបំពេញតាមគោលការណ៍នេះ គោលការណ៍សមមាត្រ (Principle of Proportionality) ត្រូវបានតម្រូវឲ្យគោរព។ គោលការណ៍នេះ ទាមទារឲ្យ វិធីសាស្រ្ត ឬមធ្យោបាយនៃការវាយប្រហារ ត្រូវសមស្របទៅតាមគោលដៅយោធាដែលចង់បាន។ ឧទាហរណ៍ ដើម្បីបំផ្លាញបន្ទាយទាហានមួយ ទាហានបានបំផ្លាញទីក្រុងទាំងមូល សម្លាប់ប្រជាពលរដ្ឋ រាប់ពាន់នាក់ នេះមិនត្រឹមត្រូវតាមគោលការណ៍សមមាត្រឡើយ។

ទាញចេញពីមូលដ្ឋាននៃគោលការណ៍សមមាត្រ និងបែងចែករវាង ជនស៊ីវិល និងទិសដៅយោធា (Military Target) ព្រមទាំងដើម្បីគោរពតាមគោលការណ៍ទាំងនេះ គោលការណ៍ប្រុងប្រយ័ត្នជាមុន (Precautionary Principle ) បានដើរតួនាទីយ៉ាងសំខាន់។ គោលការណ៍នេះ ដាក់ចេញនូវវិធាន ដែលតម្រូវឲ្យរដ្ឋ តាំងបន្ទាយទាហានចេញឆ្ងាយពី កន្លែងជនស៊ីវិលរស់នៅ ឬបញ្ជូនជនស៊ីវិល ចេញពីលេណដ្ឋានយោធា។ មុនពេលចាប់ផ្តើមវាយប្រហារ គោលការណ៍នេះ តម្រូវឲ្យរដ្ឋជាភាគីក្នុងសង្គ្រាម ពិនិត្យអំពីវិធីសាស្រ្ត និងមធ្យោបាយធ្វើសង្គ្រាម ព្រមទាំងធ្វើការជូនដំណឹងជាមុនអំពីការវាយប្រហារ ដើម្បីឲ្យជនស៊ីវិលអាចគេចផុតពីគ្រោះថ្នាក់។ ការពិត វាជាការមួយលំបាក សម្រាប់រដ្ឋ ក្នុងការអនុវត្តវិធាន ទាញចេញពីគោលការណ៍នេះ ម្ល៉ោះហើយរដ្ឋភាគច្រើន មានការស្ទាក់ស្ទើរក្នុងការទទួលយកវិធានទាំងនេះ។ ការតម្រូវឲ្យបញ្ជូនជនស៊ីវិលចេញ និងការដាក់លេណដ្ឋានឆ្ងាយពី

កន្លែងរស់នៅរបស់ជនស៊ីវិល មិនអនុវត្តក្នុងសង្គ្រាមមិនមែនអន្តរជាតិ ហើយគឺពុំមែនជាវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ។[644]

### ៩.៣.៣.២. សម្ភារ និងបុគ្គលដែលត្រូវការពារ

វត្ថុដែលត្រូវបានការពារដូចជា សម្ភារសម្រាប់បម្រើឲ្យការងារមនុស្សធម៌[645] អាគារវប្បធម៌[646] វត្ថុដែលចាំបាច់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ[647] និងមធ្យោបាយដឹកជញ្ជូន។[648] សម្ភារទាហានមិនត្រូវបានការការពារទេ។ ការពិចារណាថាអ្វីមួយជាកម្មវត្ថុរបស់ទាហាន គឺត្រូវពិនិត្យមើល ចរិត ឬប្រភេទ ទីតាំង គោលបំណងនៃវត្ថុនោះ។

មនុស្សដែលត្រូវបានការពារ ដូចជា ទាហានក្នុងវិបត្តិ[649] ឈ្លើយសឹក[650] បុគ្គលិកអង្គការមនុស្សធម៌[651] និងជនស៊ីវិលដែលស្ថិតនៅ ក្នុងកណ្តាប់ដៃ

---

[644] Knut Doermann, *Obligation of International Humanitarian Law*, 4 (2) Military and Strategic Affairs, September 2012, p.17; Nada Al-Duaij, *the Volunteer Human Shields in International Humanitarian Law*, 12 Oregon Review of International Law, 138 (2010).

[645] 1977 Additional Protocol (I) to the Geneva Conventions, Arts. 51(2), 52; 1977 Additional Protocol (II) to the Geneva Conventions, Art.13, *see* www.icrc.org/applic/ihl/ihl.nsf/vwTreaties1949.xsp; ICRC, International Humanitarian Law: Answers to Your Questions, 2002, p. 16 (www.icrc.org/eng/assets/files/other/icrc_002_0703.pdf.

[646] Protocol 1, *supra* note 645, Arts. 51(2), 52; protocol II, *supra* note 645, Art.13. There is a convention on the protection of culture during the time of war.

[647] Protocol 1, Arts. 51(2), 52; protocol II, Art.13.

[648] Protocol 1, Arts. 51(2), 52; protocol II, Art.13.

[649] Geneva Convention II of 1949, *supra* note 641, Art. 13.

[650] Geneva Convention III of 1949, *supra* note 641, Art.14. Prisoner of War does not exist for non-international armed conflict.

[651] ICRC, Other Protected persons: humanitarian workers, journalists, medical and religious personnel, *see* www.icrc.org/eng/war-and-law/protected persons.

របស់បច្ចាមិត្ត[652] ជនភៀសខ្លួន និងជនគ្មានសញ្ជាតិ។[653] ជនស៊ីវិលអាចជាប្រជាពលរដ្ឋ របស់រដ្ឋដែលចូលរួមធ្វើសង្គ្រាម ឬ ប្រជាពលរដ្ឋរបស់រដ្ឋទី៣ ដែលមិនមានស្ថានទូតក្នុងប្រទេសធ្វើសង្គ្រាម ដែលខ្លួនស្នាក់នៅ។ ពួកគេទទួលបានការការពារ ពីការវាយប្រហារ និងការពារក្នុងដៃរបស់បច្ចាមិត្ត។

អ្នកប្រយុទ្ធត្រូវបានគេផ្តល់ន័យថា ជាបុគ្គលកាន់កាប់អាវុធ ស្ថិតនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រង និងចូលរួមធ្វើសង្គ្រាមដើម្បីរដ្ឋ និងចូលរួមដោយផ្ទាល់ក្នុងសង្គ្រាម។[654] អ្នកប្រយុទ្ធអាចជាជនស៊ីវិល ឧទាហរណ៍ ក្នុងករណី ការងើបបះបោរប្រឆាំងនឹងការកាន់កាប់។ ខុសពីទាហាន អ្នកប្រយុទ្ធ ទាមទារនូវការចូលរួមផ្ទាល់[655] មានសញ្ញា ទង្វើធ្វើឲ្យប៉ះពាល់ដល់បច្ចាមិត្ត មានទំនាក់ទំនងរវាងអំពើនិងការប៉ះពាល់ និងជាអំពើធ្វើឡើងដើម្បីប្រយោជន៍ ភាគីម្ខាងនៃសង្គ្រាម។ ទាំងនិយមន័យ និងអ្វីទៅជាការចូលរួមផ្ទាល់ មិនមានភាពច្បាស់លាស់ឡើយ។ បុគ្គលមួយរូប ទូរស័ព្ទប្រាប់ អ្នកបើកយន្តហោះទម្លាក់គ្រាប់បែកចំទិសដៅ តើជាការចូលរួមដោយផ្ទាល់ដែរឬទេ?

ដូចដែលបានបរិយាយខាងលើ ជនស៊ីវិលមួយប្រភេទ ដែលទទួលបានការការពារ លុះត្រាជាប្រជាពលរដ្ឋរបស់រដ្ឋចូលរួមធ្វើសង្គ្រាម ដូចនេះសញ្ជាតិគឺជាកត្តាចម្បងសម្រាប់ផ្តល់នូវការការពារ ឬចាត់ចូលជាក្រុមមនុស្សដែលនឹងត្រូវបានការពារ។ ការកំណត់ជនណាមួយមានសញ្ជាតិរដ្ឋណាមួយ គឺផ្អែកទៅលើច្បាប់របស់ជាតិនោះ។[656] ការផ្អែកតាមសញ្ជាតិ ដើម្បីទទួលបានការ

[652] The 1949 Geneva Convention III and Additional Protocol I of 1977, *supra* note 641 and 645.
[653] The 1949 Geneva Convention IV, Art. 44.
[654] Antonio, the Oxford, *supra* note 55, p. 268.
[655] *Id.,* p. 268.
[656] ICJ, *Nottebohm*, *supra* note 27, p. 33.

ការពារ អាចមិនសមស្របទៅតាមគោលបំណង នៃច្បាប់មនុស្សធម៌អន្តរជាតិឡើយ ហើយជាការជាក់ស្តែង ប្រជាពលរដ្ឋប្រទេសមួយ អាចចូលរួមធ្វើសង្គ្រាមឲ្យភាគីម្ខាង ប្រឆាំងនឹងរដ្ឋរបស់ខ្លួន ដែលអាចត្រូវទទួលរងនូវការធ្វើទុក្ខបុកម្នេញ នៅក្នុងដៃរបស់រដ្ឋរបស់ខ្លួន ដូចនេះពួកគេគួរទទួលបាននូវ ការការពារ។ ករណីសង្គ្រាមនៅ *កូសូវូ* ដែលជាសង្គ្រាមរវាងពូជសាសន៍ ដែលមិនពាក់ព័ន្ធជាមួយសញ្ជាតិ ជាឧទាហរណ៍មួយ ស្តីពីភាពមិនច្បាស់លាស់ នៃការផ្អែកលើកត្តាសញ្ជាតិ ។ អាស្រ័យហេតុនេះ យុត្តិសាស្ត្ររបស់តុលាការ ហាក់នឹងមិនផ្តល់ទម្ងន់លើ កត្តាសញ្ជាតិសម្រាប់ការផ្តល់ការការពារទេ។

ការការពារទទួលបាន ចាប់ពីមានពេលចាប់ផ្តើមសង្គ្រាម រហូតដល់ពេលបញ្ចប់ទៅនៃសង្គ្រាម។[657] ទាហានដែលបាក់ទ័ព ត្រូវមានកាតព្វកិច្ចផ្តល់អត្តសញ្ញាណខ្លួនឯង ដើម្បីទទួលបានការការពារ តែពួកគេមិនត្រូវបាត់បង់ការទទួលបានការការពារ ដោយសារពួកគេបាន បំពារបំពានច្បាប់មនុស្សធម៌អន្តរជាតិឡើយ។ លក្ខខណ្ឌនេះ មិនតម្រូវទេសម្រាប់ជនស៊ីវិល។ សេចក្តីមន្ទិលថាជនស៊ីវិល ជាប្រជាពលរដ្ឋរបស់រដ្ឋណា នឹងបានជាប្រយោជន៍ដល់បុគ្គល ដែលនឹងត្រូវបានការការពារ។

### ៩.៣.៣.៣. ការហាមឃាត់វិធី និងមធ្យោបាយធ្វើសង្គ្រាម

ក្រៅពីគោលការណ៍ ដូចដែលបានបង្ហាញជូនខាងលើ ច្បាប់មនុស្សធម៌អន្តរជាតិ បានហាមការប្រើមធ្យោបាយធ្វើសង្គ្រាម ដូចជាការប្រើអាវុធគីមី ឬអាវុធដែលបង្កការខូចខាតមិនចាំបាច់ ព្រមទាំងហាមឃាត់នូវវិធីសាស្ត្រធ្វើសង្គ្រាម

[657] Geneva Convention IV of 1949, *supra* note 641, Art. 6, for example.

ដូចជាបង្អត់អាហារ និងយកជនស៊ីវិល ឬឈ្លើយសឹកទៅធ្វើជារបាំងសង្គ្រាម (Human Shield)។[658]

## ៩.៣.៤. ការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ

### ៩.៣.៤.១. អនុវត្តន៍ដោយអង្គការអន្តរជាតិ

ការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិឲ្យមានប្រសិទ្ធភាព ទាមទារឲ្យមានការចូលរួមពី អង្គការសហប្រជាជាតិ ប្រទេសជិតខាងនៃប្រទេសមានសង្គ្រាម អង្គការតំបន់ អង្គការមនុស្សធម៌ តុលាការអន្តរជាតិ ប្រទេសការពារ (Protecting Power) អង្គការអឡ្ហចន្ទក្រហមអន្តរជាតិ (International Committee of Red Cross: ICRC) និងគណៈកម្មការអង្កេត (Fact-Finding Commission) ជាដើម។

ប្រទេសការពារ ជាប្រទេសមួយដែលត្រូវបានទទួលយល់ព្រមដោយប្រទេសដែលជាភាគីនៃសង្គ្រាម។ ប្រទេសនេះ ត្រូវតែអព្យាក្រឹត មានតួនាទីចុះពិនិត្យមើលពន្ធនាគារជាដើម។[659]រដ្ឋភាគីនៃសង្គ្រាម ត្រូវផ្តល់ព័ត៌មានអំពីកងទ័ពដល់ប្រទេសការពារ ហើយប្រទេសនេះនឹងជូនដំណឹងដល់ប្រទេសជម្លោះ ដើម្បីងាយស្រួលស្វះស្វែងរក ក្នុងករណីបាត់ខ្លួន។ ប្រទេសការពារ ធ្វើការជាមួយ ការិយាល័យព័ត៌មានរបស់ប្រទេសជាភាគីនៃសង្គ្រាម។ គណៈកម្មការស៊ើបអង្កេត ត្រូវបានទាមទារដោយសន្ធិសញ្ញា ឲ្យរដ្ឋបង្កើតឡើង ដែលមាន

[658] Protocol II, *supra* note 645, Art. 14; Convention on the prohibition of the development, production, stockpiling and use of chemical weapons and on their destruction, 1993, Art.4, www.opcw.org/chemical-weapons-convention/.
[659] Geneva Convention IV of 1949, *supra* note 641, Art. 12 (1).

ការឯកភាពពីភាគីនៃសង្គ្រាម ដែលអាចអនុញ្ញាតឲ្យគណៈកម្មការនេះ ចុះធ្វើការងារស៊ើបអង្កេតពាក់ព័ន្ធជាមួយកិច្ចធ្វើសង្គ្រាម។[660]

ជាចុងក្រោយ គឺ ICRC ដែលជាស្ថាប័នមានតួនាទីសំខាន់បំផុត ក្នុងវិស័យច្បាប់មនុស្សធម៌អន្តរជាតិ ជាពិសេសពាក់ព័ន្ធជាមួយការរៀបចំ អភិវឌ្ឍ និងចងក្រង វិធានច្បាប់មនុស្សធម៌អន្តរជាតិ។[661] ក្រៅពីនេះ ICRC បានចុះពិនិត្យក្នុងមន្ទីរឃុំឃាំងក្នុងពេលមានសង្គ្រាម និងធ្វើកិច្ចការងារដទៃទៀត ជាគំនិតផ្តួចផ្តើមរបស់ខ្លួន ដែលមិនមានចែងនៅក្នុងលក្ខន្តិកៈរបស់ខ្លួន។ ICRC បានចុះទៅមើលស្ថានភាពពន្ធនាគារ សូម្បីក្នុងពេលមិនមានសង្គ្រាម ហើយរដ្ឋហាក់បីដូចជា មិនជំទាស់អំពីដំណើរការងារនេះឡើយ។

### ៩.៣.៤.២ អនុវត្តន៍ដោយរដ្ឋ

រដ្ឋមានកាតព្វកិច្ចជាច្រើន ដែលមានចែងក្រោមសន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ កាតព្វកិច្ចខ្លះ តម្រូវឲ្យបំពេញក្នុងពេលមិនទាន់មានសង្គ្រាម(សន្តិភាព)។ ឧទាហរណ៍ រដ្ឋត្រូវបកប្រែសន្ធិសញ្ញាដែលពាក់ព័ន្ធនានា ជាភាសាជាតិ និងផ្សព្វផ្សាយឯកសារ ទាំងនោះ ជាពិសេសដល់កងទ័ព។[662] រដ្ឋមានកាតព្វកិច្ចបណ្តុះបណ្តាល កងកម្លាំងប្រដាប់អាវុធ និងទីប្រឹក្សាច្បាប់នៅក្នុងក្រសួងការពារជាតិ ស្តីពី ច្បាប់មនុស្សធម៌អន្តរជាតិ[663] និងធ្វើ

[660] Protocol I, *supra* note 645, Art. 90.

[661] The ICRC coduncted many researches, such as one identifation of existing customary international law of the international humanitarian law; the ICRC also produced many commentary on the treaties or conventions on international humanitarian law; they are available at the website of the ICRC (www.icrc.org).

[662] Geneva Convention IV of 1949, *supra* note 641, Art. 144.

[663] *Id.*, Art. 144.

ប័ណ្ណសម្គាល់កងទ័ពជាដើម។[664] រដ្ឋត្រូវបង្កើត ការិយាល័យព័ត៌មានជាតិ សម្រាប់ចងក្រង និងរក្សាទិន្នន័យជនដែលត្រូវបានការពារ ជាប្រយោជន៍ សម្រាប់ប្រើប្រាស់ការពារជនស៊ីវិល។[665]រដ្ឋមានកាតព្វកិច្ចប្រកាស ឧទាហរណ៍កប៉ាល់ពេទ្យជាដើម។[666]

រដ្ឋត្រូវធ្វើច្បាប់ពាក់ព័ន្ធមួយចំនួន ដូចជាច្បាប់ចាត់អំពើប្រព្រឹត្តក្នុងពេលមានសង្គ្រាម ជាបទឧក្រិដ្ឋ បង្កើតយុត្តាធិការសម្រាប់កាត់ទោសអ្នកប្រព្រឹត្តទាំងនោះ។ សន្ធិសញ្ញា ក៏បានទាមទារផងដែរឲ្យមានការស៊ើបរកចាប់ខ្លួនឧក្រិដ្ឋជន នៅក្នុងដែនដីរបស់ខ្លួន ដើម្បីយកទៅកាត់ទោស និងបង្ក្រាបបទល្មើសដែលកើតមានឡើង។[667] នេះតម្រូវឲ្យ មានជាពិសេស ច្បាប់ចាត់អំពើបំពារបំពានធ្ងន់ធ្ងរ (Grave Breaches) ជាបទឧក្រិដ្ឋ ដែលតម្រូវឲ្យមានយុត្តាធិការសាកល (Universal Jurisdiction)។[668] សម្រាប់អំពើដទៃទៀត ដែលមិនចូលក្នុង Grave Breaches មិនតម្រូវឲ្យធ្វើដូចនេះទេ ក្រោមសន្ធិសញ្ញាទីក្រុងហ្សឺណែវ។ ក៏ប៉ុន្តែ មានការតម្រូវឲ្យធ្វើរបៀបនេះ ឬតម្រូវឲ្យធ្វើតាមផ្អែកតាមសន្ធិសញ្ញា ដែលពាក់ព័ន្ធផ្សេងទៀត។

664 The Geneva Convention I of 1949, *supra* note 641, Art. 40.

665 Geneva Convention IV of 1949, *supra* note 641, Art. 136.

666 Geneva Convention II of 1949, *supra* note 641, Art. 22.

667 Geneva Convention IV of 1949, *supra* note 641, Art. 146.

668 Antonio, the Oxford, *supra* note 55, pp. 531-532; Geneva Conevntion I of 1949, *supra* note 641, Art. 49.

## ៩.៣.៥. ទំនាក់ទំនងរវាងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

ច្បាប់សិទ្ធិមនុស្សជាច្បាប់សម្រាប់ប្រើក្នុងពេលសន្តិភាព និងសម្រាប់ទំនាក់ទំនង ជាពិសេស រវាងរដ្ឋ និងប្រជាពលរដ្ឋរបស់ខ្លួន។ ចំណែកឯច្បាប់មនុស្សធម៌អន្តរជាតិ អនុវត្តក្នុងអំឡុងពេលមានសង្គ្រាម សម្រាប់ការពារ ជាពិសេសបុគ្គលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋផ្សេង ព្រមទាំងចងជាកាតព្វកិច្ចដល់គ្រប់ភាគី តែមិនអនុវត្តក្រៅដែនដី ទូលំទូលាយ ដូចច្បាប់សិទ្ធិមនុស្សឡើយ។ ច្បាប់មនុស្សធម៌អនុវត្តក្រៅដែនដី ក្នុងករណីរដ្ឋធ្វើសង្គ្រាម ហើយកាន់កាប់ដែនដីរបស់រដ្ឋផ្សេង។ វាច្បាស់លាស់ថា ច្បាប់មនុស្សធម៌អន្តរជាតិមិនអនុវត្ត ក្នុងអំឡុងពេលសន្តិភាពឡើយ តែច្បាប់សិទ្ធិមនុស្ស អនុវត្តទាំងនៅក្នុងពេលសន្តិភាព និងពេលមានសង្គ្រាម។ នេះនាំឲ្យមានការ អនុវត្តត្រួតគ្នា។ ភាពត្រួតគ្នា បានបង្ហាញកាន់តែច្បាស់ ក្នុងករណីសង្គ្រាម មិនមែនអន្តរជាតិ រវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ ដែលជាក្រុមប្រដាប់អាវុធ ហើយដែលច្បាប់សិទ្ធិមនុស្ស អនុវត្តចំពោះ។[669] ច្បាប់មនុស្សធម៌អន្តរជាតិ នឹងក្លាយជាច្បាប់ពិសេស (*Lex Specialis*) ក្នុងពេលមានសង្គ្រាម។[670] ច្បាប់ទាំងពីរនេះ មានគោលបំណងមនុស្សធម៌ដូចគ្នា ដូចនេះបើមានចំណុចផ្ទុយគ្នា គេតម្រូវឲ្យបកស្រាយឲ្យស្របគ្នា និងបំពេញបន្ថែមគ្នាទៅវិញទៅមក។[671]

តាមច្បាប់សិទ្ធិមនុស្ស សិទ្ធិមួយចំនួន មានចរិតដាច់ខាត (Absolute Rights) ដែលមិនត្រូវអនុញ្ញាតឲ្យផ្អាកការអនុវត្តទេ ទោះបីជាក្នុងពេលមាន

[669] Warning before killing applied in peacetime is not applied during war.

[670] ICJ, Legality of the Threat, *supra* note 290, para. 25; Roberta Arnold and Noelle Quenivet, International Humanitorian Law and Human Rights Law, 2008, p.7.

[671] ICRC, International Humanitarian Law, *supra* note 645, p. 36.

គ្រោះអាសន្នជាសាធារណៈ ដូចជាសង្គ្រាម។[672] សិទ្ធិរួចផុតពីអំពើទារុណកម្ម ជាសិទ្ធិមួយក្នុងចំណោមសិទ្ធិទាំងនោះ។ សន្ធិសញ្ញាទីក្រុងហ្សឺណែវ ក៏បាន ហាមឃាត់អំពើទារុណកម្មផងដែរ។ សិទ្ធិទទួលបាននូវការកាត់សេចក្តីដោយ យុត្តិធម៌ មិនត្រូវបានរាប់បញ្ចូលក្នុង សិទ្ធិដាច់ខាតឡើយក្នុងសន្ធិសញ្ញា សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ ក៏ប៉ុន្តែ ការផ្អាកនូវការអនុវត្តសិទ្ធិ ក្នុងពេលសង្គ្រាម គឺមិនត្រូវប៉ះពាល់ដល់កាតព្វកិច្ចរបស់រដ្ឋ ក្រោមសន្ធិសញ្ញា ដទៃទៀត ដែលរដ្ឋជាភាគីឡើយ។ តុលាការ និងគណៈកម្មាធិការសិទ្ធិមនុស្ស បានបកស្រាយថា សិទ្ធិទទួលបានការ កាត់សេចក្តីដោយយុត្តិធម៌គឺ ជាសិទ្ធិ ដាច់ខាត។[673] សិទ្ធិនេះ ក៏ត្រូវបានទាមទារឲ្យរដ្ឋជាភាគីនៃសង្គ្រាម គោរពផង ដែរ ឧទាហរណ៍ រដ្ឋមិនត្រូវកាត់ទោស ឈ្លើយសឹកដោយគ្មានយុត្តិធម៌ទេ។[674]

សិទ្ធិខ្លះទៀតត្រូវបានកម្រិត (Inherent and Permissible Rights) ទោះបីពុំមានគ្រោះអាសន្នជាសាធារណៈក្តី។ សន្ធិសញ្ញាទីក្រុង*ហ្សឺណែវ* មិន បានចែងមិនឲ្យរដ្ឋ កម្រិតសិទ្ធិក្នុងពេលមានសង្គ្រាម និងមិនហាមប្រើសិទ្ធិ ទាំងនោះឡើយ លើកលែងភាពផ្ទុយគ្នារបស់សិទ្ធិក្រោមប្រភេទច្បាប់ទាំង ពីរ។ ក្នុងករណីនេះ ច្បាប់មនុស្សធម៌អន្តរជាតិ នឹងមានឋានៈខ្ពស់ជាង នៅ ក្នុងអំឡុងពេលមានសង្គ្រាម។

តាមការជាក់ស្តែង នៅក្នុងពេលមានសង្គ្រាម បទឧក្រិដ្ឋកម្មសង្គ្រាម អាចត្រូវ បានប្រព្រឹត្ត ហើយបទប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មប្រឆាំង នឹង

---

[672] The ICCPR, *supra* note 56, Art. 4.

[673] Inter-American Courts of Human Rights, *Habeas Corpus, supra* note 490, para. 44.

[674] Geneva Convention I of 1949, Art. 49; Geneva Convention II of 1949, Art. 50, *supra* note 641.

មនុស្សជាតិក៏អាច ត្រូវបានប្រព្រឹត្ត ដោយភាគីទាំងសងខាង។ ឧទាហរណ៍ រដ្ឋមួយនៃសង្គ្រាមបានសម្លាប់រង្គាលជនជាតិរបស់ខ្លួន ឬសម្លាប់ក្រុមជនជាតិដោយចេតនាបំបាត់ពូជ ដោយសារពួកគេជាក្រុមមនុស្សគ្រោះថ្នាក់ ព្រោះបានជួយដល់រដ្ឋជម្លោះម្ខាងទៀត។[675] នេះជាអង្គហេតុនៃការរំលោភវិធានច្បាប់សិទ្ធិមនុស្ស។ អង្គហេតុទាំងនេះ អាចត្រូវបានចាត់ចូលជាបទល្មើសប្រភេទផ្សេងៗគ្នា។

### ៩.៣.៦. ការហាមឃាត់ការប្រើអាវុធគីមី

ការប្រើប្រាស់អាវុធគីមីក្នុងសង្គ្រាម បានបំផ្លាញទ្រព្យសម្បត្តិ ដកហូតជីវិតមនុស្ស ព្រមទាំងបង្កផលវិបាកដល់សុខភាពមនុស្ស ដោយសារជាតុវិទ្យុសកម្ម។ អាវុធបរមាណូ ពីរគ្រាប់ទម្លាក់ ដោយសហរដ្ឋអាមេរិក ផ្ទុះកម្ពស់រាប់រយម៉ែត្រពីដែនដីលើទីក្រុងហ៊ីរ៉ូស៊ីម៉ា និង ណាហ្គាសាគីរបស់ជប៉ុន បានធ្វើឲ្យទីក្រុងទាំងនេះខ្ទេចរាបស្មើ និងសម្លាប់មនុស្ស ប្រហែលពីរយពាន់នាក់។[676] ទោះបីជា ការទម្លាក់នេះ នាំទៅដល់ ការចុះចាញ់របស់ជប៉ុន និងបញ្ចប់សង្គ្រាមលោកលើកទី២ក្តី វិនាសកម្មមានវិសាលភាពធំធេងមិនអាចថ្លែងបានដោយបានបន្សល់មនុស្សទទួលវិទ្យុសកម្មរាប់ពាន់នាក់។[677] ពួកគេរស់នៅយ៉ាងវេទនា និងទទួលរងគ្រោះនៃអំពើរើសអើងពីមនុស្សដោយសារខ្លាចជាតុ

[675] See following part on crimes under international law, such as genocide.
[676] Atomic bombings of Hiroshima and Nagasaki, *see* http://en.wikipedia.org/wiki/Atomic_bombings_of_Hiroshima_and_Nagasaki.
[677] Atomic bombings of Hiroshima and Nagasaki, *see* http://en.wikipedia.org/ wiki/Atomic_bombings_of_Hiroshima_and_Nagasaki.

វិទ្យុសកម្ម។[678] ៤០ឆ្នាំក្រោយមក អាវុធគីមី (Mustard Agent) ត្រូវបាន ប្រើប្រាស់ ដោយកងទ័ពអ៊ីរ៉ាក់ ក្រោមរបបសាដាមហ៊ូសេន ក្នុងសង្គ្រាម ជាមួយ អ៊ីរ៉ង់ ក្នុងចន្លោះឆ្នាំ ១៩៨០ ដល់ ១៩៨៨ ដោយបានសម្លាប់មនុស្ស និងរងផលប៉ះពាល់ដោយជាតុវិទ្យុសកម្ម ជាងមួយរយពាន់នាក់។[679]

ដោយពិចារណាឃើញនូវផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃអាវុធគីមី កិច្ចខិតខំប្រឹង ប្រែងរៀបចំសន្ធិសញ្ញា ហាមឃាត់ការប្រើប្រាស់អាវុធគីមី ត្រូវបានធ្វើឡើង ហើយនៅក្នុងឆ្នាំ ១៩៩២ សន្ធិសញ្ញា ស្តីពី អាវុធគីមី ត្រូវបានអនុម័ត។ សន្ធិសញ្ញា មានឧបសម្ព័ន្ធចំនួនបួន។[680] ទី១. យន្តការផ្ទៀងផ្ទាត់ (Verifi cation) ទី២. តារាងអាវុធគីមី ទី៣. យន្តការគ្រប់គ្រងព័ត៌មានសម្ងាត់ និង ទី៤.យន្តការចុះត្រួតពិនិត្យ។ សន្ធិសញ្ញា មិនអនុញ្ញាតឲ្យមានខរក្សាសិទ្ធិមិន អនុវត្តឡើយ (Reservation) ហើយត្រូវតែអនុវត្តក្នុងគ្រប់កាលៈទេសៈ។[681] តាមសន្ធិសញ្ញា អាវុធគីមី គឺជាជាតុពុល គ្រឿងផ្ទុះជាដើម។[682] សន្ធិសញ្ញា មានគោលបំណងក្នុងការហាមឃាត់ការប្រើប្រាស់អាវុធគីមី ព្រមទាំងប្រើ ប្រាស់សារជាតុគីមី និងការអភិវឌ្ឍបច្ចេកវិជ្ជាក្នុងប្រយោជន៍ មិនបង្កទុក្ខភ័យ ដល់មនុស្សលោក។ ដើម្បីសម្រេចបានតាមបំណងនេះ សន្ធិសញ្ញាទាមទារឲ្យ មានការរំសាយអាវុធ (Disarmment) មិនរីកសាយភាយ ការការពារ និង

[678] Atom-bomb survivors fear new generation face familiar discrimination, www. independent.co.uk/news/world/asia/atombomb-survivors-fear-new-generation-face-familiar-discrimination.

[679] Shahriar Khateri and Ruth Wangerin, the Open Wound, (2009), p. 7. During first world war, there was usage of chemical weapon during between France and Belguim hostilities; Peter Pringle, *Chemical Weapons*, in Roy Gutman, Crimes of War, 2nd ed., 2007, p. 93.

[680] Convention on chemical weapons, *supra* note 658.

[681] *Id*., Art. XXII.

[682] *Id*., Art. II.

កិច្ចសហការជាអន្តរជាតិ។[683] សន្ធិសញ្ញា តម្រូវឲ្យរដ្ឋជាភាគី ហាមឃាត់ការផលិត អភិវឌ្ឍន៍ ទទួលយក ការរក្សាទុក ឬ ស្តុកក្នុងឃ្លាំងអាវុធគីមី។ ពាក់ព័ន្ធចំណុចនេះ ការប្រើសារធាតុគីមី ដូចជាផ្សែងបង្ហូរទឹកភ្នែក សម្រាប់បង្ក្រាបបាតុកម្ម មិនស្ថិតនៅក្នុងការហាមប្រាម ដោយសន្ធិសញ្ញានេះឡើយ។[684]

សន្ធិសញ្ញា បានចូលជាធរមាននៅក្នុងឆ្នាំ ១៩៩៣ និងមានរដ្ឋជាភាគីចំនួន ៩៨ ភាគរយនៃប្រជាជនទូទាំងពិភពលោក។[685] North Korea មិនទាន់បានចុះហត្ថលេខាលើសន្ធិសញ្ញានេះឡើយ។[686] ប្រសិនបើរដ្ឋចូលជាភាគី រដ្ឋនឹងក្លាយជាសមាជិករបស់អង្គការហាមឃាត់អាវុធជាតិគីមី (The Organization of the Prohibtion of the Chemical Weapon :OPCW) ហើយអនុញ្ញាតឲ្យស្ថាប័នរបស់អង្គការនេះ ចុះទៅក្នុងប្រទេសរបស់ខ្លួនដើម្បី ពិនិត្យមើលអាវុធគីមី។[687]

### ៩.៣.៦.១. យន្តការថ្នាក់ជាតិសម្រាប់លុបបំបាត់អាវុធគីមី

រដ្ឋត្រូវចាត់វិធានការ ដូចជា តាមរយៈការធ្វើច្បាប់ ស្តីពី ការប្រើប្រាស់ ឬហាមឃាត់អាវុធគីមី ហើយអាចសុំឲ្យអង្គការហាមឃាត់អាវុធគីមី OPCW ជួយនៅក្នុងកិច្ចការងារនេះបាន។[688] សម្រាប់ជាការសម្រួល ច្បាប់ត្រូវមាន

[683] *Id.,* Art. 1.
[684] *Id.,* Arts. II (9) and VI.
[685] Organization for the Prohibtion of Chemical Weapons (OPCW), *see* http://www.opcw.org/about-opcw/member-states/status-of-participation-in-the-cwc
[686] *See id.*,
[687] *See id.*,
[688] CWC, *supra* note 658, Arts. I and VII.

ចែងបទប្បញ្ញត្តិ បង្គាប់ដល់ក្រុមហ៊ុនអនុញ្ញាតឲ្យស្ថាប័នរបស់ OPCW ចុះមើលក្នុងទីកន្លែង ព្រមទាំងដាក់ទោសទណ្ឌដល់បុគ្គល ដែលបានបំពានច្បាប់។ ច្បាប់ក៏តម្រូវឲ្យមានកិច្ចសហការ រវាងរដ្ឋក្នុងការអនុវត្តច្បាប់។[689] រដ្ឋត្រូវ មានការិយាល័យ ឬបុគ្គលសម្រាប់ធ្វើទំនាក់ទំនង (Focal Point)។ រដ្ឋត្រូវធ្វើ បញ្ជីអាវុធគីមីរបស់ខ្លួន និងប្រកាស ព្រមទាំងកម្ទេចចោលក្នុងរយៈពេល ១០ឆ្នាំ ចាប់ពីពេលដែលខ្លួនបានក្លាយជាភាគីសន្ធិសញ្ញា។[690] រដ្ឋមានកាតព្វកិច្ច កែសម្រួលអាវុធ ឲ្យសមស្របក្នុងរយៈពេល១៥ ឆ្នាំ ចាប់ពីពេលក្លាយជាភាគី។ ការចំណាយក្នុងការបំផ្លាញ និងសកម្មភាពនានា ទាមទារដោយ សន្ធិសញ្ញា ជាបន្ទុករបស់រដ្ឋជាភាគី។[691]

### ៩.៣.៦.២. យន្តការអន្តរជាតសម្រាប់លុបបំបាត់អាវុធគីមី

OPCW ជាអង្គការសម្រាប់ពិនិត្យមើលការអនុវត្តសន្ធិសញ្ញា ដោយរដ្ឋជាភាគី។[692] សន្និសីទរបស់រដ្ឋភាគី គឺជាស្ថាប័នកំពូល របស់សន្ធិសញ្ញា។ OPCW មានក្រុមប្រឹក្សាប្រតិបត្តិ ដែលមានសមាជិក ជារដ្ឋចំនួន ៤១។ លេខាធិការដ្ឋានបច្ចេកទេស ជួយរៀបចំសន្និសីទរបស់រដ្ឋជាភាគី និងមានស្ថាប័នក្រោមបង្គាប់ចំនួនពីរទៀត គឺ គណៈកម្មការគ្រប់គ្រងព័ត៌មានសម្ងាត់របស់រដ្ឋ និង ក្រុមប្រឹក្សាវិទ្យាសាស្ត្រ (Scientific Advisory Board)។ OPCW អាចចុះទៅពិនិត្យមើលក្នុងដែនដីរបស់រដ្ឋជាភាគី ដែលអាចជាការ

[689] *Id.,* Art. VII (1).
[690] *Id.,* Part IV(A)-Destruction of Chemical Weapons, para.17 (a).
[691] *Id.,* para. 26.
[692] OPCW, *supra* note 685.

ពិនិត្យជាធម្មតា ឬការពិនិត្យក្នុងករណីមានការចោទប្រកាន់ថា មានអ្វីមិនប្រក្រតី ពាក់ព័ន្ធនឹងអាវុធគីមី។[693]

សន្និសីទរបស់រដ្ឋជាភាគី មានសិទ្ធិដាក់ទណ្ឌកម្មចំពោះរដ្ឋជាភាគី ដែលមិនបានបំពេញកាតព្វកិច្ច ទៅតាមកម្រិតនៃការរំលោភ។ ករណីធម្មតា អង្គការអាចផ្អាកសមាជិកភាព ដកសិទ្ធិបោះឆ្នោត និងការទទួលបានជំនួយ ដែលរដ្ឋភាគីមានសិទ្ធិទទួល។ ករណីធ្ងន់ធ្ងរជាងនេះ សន្និសីទរបស់រដ្ឋភាគី នឹងចាត់វិធានការ ជារួមដោយរដ្ឋជាភាគី។ ចំពោះកម្រិតចុងក្រោយ សន្និសីទនឹងធ្វើសេចក្តីរាយការណ៍ទៅ មហាសន្និបាតអង្គការសហប្រជាជាតិ និង ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

## ៩.៤. ការការពារតាមផ្លូវទូត (Diplomatic Protection)

### ៩.៤.១. ប្រវត្តិ និយមន័យ និងចរិតលក្ខណៈ

ក្នុងអត្ថន័យដើមច្បាប់ការការពារសិទ្ធិមនុស្ស និង ច្បាប់មនុស្សធម៌ចែងផ្តល់នូវ កាតព្វកិច្ចការពារក្នុងរង្វង់ដែនដីរដ្ឋ ឬដែនដី ដែលសង្គ្រាមកើតមានឡើង។នេះមានន័យថា ច្បាប់សិទ្ធិមនុស្សមិនទាមទារឲ្យរដ្ឋ ការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ឬជនរងគ្រោះ ក្រុមហ៊ុន ដោយសារអំពើកើតមានក្នុងសង្គ្រាមដែលត្រូវបានបំពារបំពាន ឬកើតមាន ដោយអាជ្ញាធរបរទេសនៅក្រៅដែនដីរដ្ឋ ដែលប្រជាពលរដ្ឋមានសញ្ជាតិឡើយ។ ការការពារពីអំពើខាងក្រោយនេះ ផ្អែកតាមវិធានច្បាប់ដោយឡែក ដែលមានឈ្មោះថា ការការពារតាមផ្លូវទូត។ វាជាការការពារ តាមរយៈការអន្តរាគមន៍ តាមផ្លូវទូតដោយរដ្ឋដែលប្រជាពលរដ្ឋ ឬក្រុមហ៊ុនរបស់ខ្លួន ត្រូវបានបំពារបំពាន ឬទទួលរងការ

693 *Id.*

ខូចខាតដោយអំពើរបស់រដ្ឋបរទេស។[694] ការការពារ ស្តែងចេញតាមរយៈសកម្មភាព របស់ស្ថានកុងស៊ុល ឬស្ថានទូត ដូចជា ការចរចា ការឆ្លើយតប ការប្តឹងតាមផ្លូវតុលាការ ឬមជ្ឈត្តកម្ម ការដាក់សម្ពាធផ្នែកសេដ្ឋកិច្ច ឬការដកទំនាក់ទំនងទូតជាដើម។[695]

វិធាននៃការការពារតាមផ្លូវទូត មានកំណើតជាយូរមកហើយ[696] និង ផ្អែកតាមគោលការណ៍អធិបតេយ្យភាពដាច់ខាតរបស់រដ្ឋ។[697] ការការពារតាមផ្លូវទូតក្នុងន័យនេះ មានឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។[698] អំពើណាមួយ ធ្វើឡើងដោយរដ្ឋណាមួយ ប៉ះពាល់ដល់ប្រយោជន៍របស់បុគ្គល ឬក្រុមហ៊ុនរបស់ រដ្ឋមួយទៀត ដែលបុគ្គល ឬក្រុមហ៊ុនមានសញ្ជាតិ ត្រូវបានចាត់ថាជាការប៉ះពាល់ដល់រដ្ឋផ្ទាល់ ដូចនេះរដ្ឋនោះគឺជាស្ថាប័នរងគ្រោះ[699] មិនមែនជនជាតិ ឬក្រុមហ៊ុនរបស់ខ្លួនទេ ដែលជាជនរងគ្រោះ។ ទោះបីជា រដ្ឋមានករណីយកិច្ចការពារប្រជាពលរដ្ឋ ឬក្រុមហ៊ុនរបស់ខ្លួន ហើយអាចដាក់បណ្តឹងទាមទារសំណង ចំពោះការខូតខាត ដោយសារអំពើរបស់រដ្ឋផ្សេងក្តី[700] ករណីយកិច្ចនេះ មានចែងក្រោមច្បាប់ជាតិ។[701] ច្បាប់អន្តរជាតិ

---

[694] See the *Diallo* (*Guinea* v. *Democratic Republic of the Congo*) case, ICJ Reports, 2007, para. 39; Draft Articles on Diplomatic Protection, *see* the Report of the ICL on its 58th Session, A/61/10, 2006, p. 13.

[695] *Kaunda* v. *President of South Africa* CCT 23/04, 2004, ZACC 5, paras. 26-7; Shaw, IL, *supra* note 1, p. 809; *Van Zyl* v. *Government of RSA*, 2007, SCA, para.1.

[696] At least this issue was discussed in the judgement of the PCIJ in 1924, *see* Mavromattis Palestine Concessions Case, Greece v. U.K. (1924), PCIJ Reports, Series A, No. 2, p. 12.

[697] D.J., Cases on IL, *supra* note 81, p. 521.

[698] *Guinea v. Democratic Republic of the Congo, supra* note 694, para. 39.

[699] Peter Malanczuk, IL, *supra* note 1, p.257.

[700] Shaw, IL, *supra* note 1, p. 809.

[701] The 1993 Constitution of the Kingdom of Cambodia, Art. 33.

សាធារណៈ មិនទាន់ចែងច្បាប់ជាក់លាក់អំពីកាតព្វកិច្ច តម្រូវឲ្យរដ្ឋធ្វើដូចនេះឡើយ។ កិច្ចមិនអន្តរាគមន៍ ឬអន្តរាគមន៍ ដើម្បីការពារបុគ្គល ឬក្រុមហ៊ុន ដោយរដ្ឋ គឺផ្អែកតាមឆន្ទានុសិទ្ធិរបស់រដ្ឋ[702] និងជាសិទ្ធិរបស់រដ្ឋ។[703] រដ្ឋមានភាព ស្ទាក់ស្ទើរក្នុងការប្រើប្រាស់សិទ្ធិនេះ ដោយសារការមិនចង់ជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋផ្សេងទៀត។[704]

## ៩.៤.២. វិសាលភាពនៃការការពារ

ការការពារតាមផ្លូវទូត កម្រិតចំពោះការខូចខាត ដោយសារការរំលោភ នូវបទដ្ឋានអប្បបរមា សម្រាប់ការការពារជនបរទេស (the Minimum Standard of Treatment of Aliens)។[705] វិសាលភាពនៃការការពារ ត្រូវបានស្នើឲ្យធ្វើឡើង សម្រាប់ការពារជនគ្មានសញ្ជាតិ (Stateless Person) និង ជនភៀសខ្លួនផងដែរ ក្នុងអំឡុងពេល ដែលការខូចខាត និងការដាក់សេចក្តីអន្តរាគម (the Presentation of Claim) ជននោះស្នាក់នៅស្របច្បាប់ ឬក្នុងប្រទេសធ្វើអន្តរាគមន៍។[706] ការពង្រីកវិសាលភាពនេះ ងាកចេញពីលក្ខខណ្ឌសញ្ជាតិសម្រាប់ឲ្យរដ្ឋអាចធ្វើអន្តរាគមន៍ ដែលចាក់ឫសគល់ក្នុងវិធានការការពារតាមផ្លូវទូតជាយូរមកហើយ។[707] ដូច្នោះហើយ ការពង្រីកនេះស្ថិត

[702] *Kaunda* v. *President of South Africa, supra* note 695, paras. 29 and 34; UKMIL, 70 BYIL, 1999, pp. 528-9.

[703] *Mavrommatis Palestine Concessions* case, PCIJ, *supra* note 696, p.12.

[704] Shaw, IL, *supra* note 1, p. 810.

[705] *Guinea v. Democratic Republic of the Congo*, *supra* note 694, para. 39; miscarriage of justice means"a grossly unfair outcome in a judicial proceedings, as when a defendant is convicted despite a lack of evidence on an essential element of crimes", Bryan, the Black, *supra* note 124, p. 1019.

[706] The Draft Articles on Diplomatic Protection, *supra* note 694, Art. 8.

[707] ICJ, *Nottebohm*, *supra* note 27, p. 33.

នៅ ក្នុងដំណាក់កាល នៃការអភិវឌ្ឍច្បាប់អន្តរជាតិសាធារណៈ (Progressive Development of International Law)។[708]

### ៩.៤.៣.លក្ខខណ្ឌសម្រាប់អនុញ្ញាតឲ្យមានការអន្តរាគមន៍

ដើម្បីឲ្យរដ្ឋអាចអន្តរាគមបាន បុគ្គល ឬក្រុមហ៊ុន ត្រូវមានសញ្ជាតិរដ្ឋនោះ។ សញ្ជាតិត្រូវបានកំណត់ ដោយច្បាប់ជាតិរបស់រដ្ឋអន្តរាគមន៍ ហើយដែលទទួលស្គាល់ ដោយរដ្ឋដែលពាក់ព័ន្ធ។[709] ជាទូទៅ ក្រុមហ៊ុនចុះឈ្មោះ ក្នុងប្រទេសណាមួយ នឹងមានសញ្ជាតិរដ្ឋនោះ។[710] តុលាការយុត្តិធម៌អន្តរជាតិ ក្នុងករណី ដែលមានរដ្ឋពាក់ព័ន្ធជាច្រើន ចង់អន្តរាគមការពារ បន្ថែមពីលើលក្ខខណ្ឌសញ្ជាតិ ត្រូវមានចំណងទាក់ទងជាក់ស្តែង (Genuine Link) រវាងរដ្ឋ និងប្រជាពលរដ្ឋ ដែលរដ្ឋអន្តរាគមន៍តាមផ្លូវទូត។[711]ផ្អែកតាមលក្ខណវិនិច្ឆ័យនេះ តុលាការរកឃើញថា *Liechtenstein* ដែលជាប្រទេសផ្តល់សញ្ជាតិ (សញ្ជាតុបនីយកម្ម) ដល់លោក *Nottebohm* ជាម្ចាស់ភាគហ៊ុនមួយរបស់ក្រុមហ៊ុន មិនមានសិទ្ធិក្នុងការអន្តរាគម ទារសំណងខូចខាតជំនួសលោក *Nottebohm* ពីព្រោះ ទោះបីមាន សញ្ជាតិនេះក្តី គាត់រស់នៅជាអចិន្ត្រៃយ៍ ក្នុងប្រទេស *Guatemala*។[712] ក្នុងករណី វាគួរជាប្រទេសចុះឈ្មោះរបស់ ក្រុមហ៊ុន របស់លោក *Nottebohm* ឬប្រទេស

---

[708] For more information on progressive development of international law, *see* progressive development of the principles and norms of international law relating to the new international economic order, UN. A/Res/41/73 (3 December 1986).

[709] *Guinea v. Democratic Republic of the Congo*, *supra* note 694.

[710] Regulations of thr People's Republic of China Governing the Registration of Ships (1995 Jan, 01) , Art. 3 (www.asianlii.org/cn/legis/cen/laws/rgtros490); the UN Convention on Conditions for Registration of Ships, 7 February 1986, Art. 11.

[711] ICJ, Nottebohm, *supra* note 27, p. 33.

[712] *Id.*, p. 34.

ដែលលោក *Nottebohm* ជាប្រជាពលរដ្ឋ ជារដ្ឋដែលមានសិទ្ធិអន្តរាគមតាមផ្លូវច្បាប់ ចំពោះអំពើធ្វើខុសច្បាប់ ដោយប្រទេស*Guatemala*។ លក្ខណវិនិច្ឆ័យនេះ ចង្អៀត ហើយមិនត្រូវបានប្រកាន់យកក្នុង សេចក្តីព្រាងមាត្រាស្តីពីការការពារតាមផ្លូវទូតឡើយ។

បុគ្គល ឬក្រុមហ៊ុន ដែលទទួលរងការខូចខាត ត្រូវធ្វើការទាមទារសំណងលើការខូតខាត ដោយខ្លួនឯង ឲ្យចប់សព្វគ្រប់ជាមុនសិននៅក្នុងប្រទេស (Exhaustion of Local Remedy) ដែលបង្កឲ្យមានការខូចខាត មុននឹងរដ្ឋរបស់ខ្លួនចូលរួមអន្តរាគមន៍ការពារ។[713] នេះជាលក្ខខណ្ឌ តម្រូវដោយវិធាននីតិវិធី មុនពេលតុលាការអន្តរជាតិ ពិនិត្យមើលបណ្តឹងដោយ *Liechtenstein* ក្នុងករណីរឿងក្តី *Nottebohm*។ លក្ខណវិនិច្ឆ័យនេះ ផ្អែកលើវិធាន អធិបតេយ្យភាពរបស់រដ្ឋ ដែលតុលាការអន្តរជាតិ ទុកឱកាសឲ្យរដ្ឋពិនិត្យ និងដោះស្រាយបទចោទប្រកាន់ប្រឆាំងរដ្ឋ មុនតុលាការអន្តរជាតិពិនិត្យ និងសម្រេចលើរឿងក្តីណាមួយនោះ។

[713] The "exhautsion of local remedy" is a general principle of international law, *see* Art. 14, Draft Articles on Diplomatic Protection with Commentaries, *see* the Report of the ICL on its 58th Session, A/61/10, 2006.

# ជំពូក ១០

# ការទទួលខុសត្រូវចំពោះការរំលោភកាតព្វកិច្ចអន្តរជាតិ

## ១០.១. ការទទួលខុសត្រូវរបស់បុគ្គល

ក្នុងប្រវត្តិសាស្ត្រមនុស្សលោក មានសង្គ្រាមបង្កគ្រោះមហន្តរាយ ជាច្រើន ជាក់ស្តែងសង្គ្រាមលោក លើកទី១និងទី ២។ មានការកត់សម្គាល់ថា រដ្ឋគឺជាស្ថាប័នអរូបីយ មិនអាចប្រព្រឹត្តបទឧក្រិដ្ឋបាន ឡើយដោយគ្មានបុគ្គល ជាអ្នកដឹកនាំរដ្ឋចូលរួមប្រព្រឹត្ត។ និយាយម្យ៉ាងទៀត បុគ្គល តាមរយៈរដ្ឋ ប្រព្រឹត្តបទឧក្រិដ្ឋ។ ការដាក់ឲ្យ បុគ្គលទទួលខុសត្រូវ ទើបអាចបញ្ចៀសបាននូវវិនាសកម្ម។[714] គោលគំនិតនេះ កើតមានស្របពេលនៃការវិវត្តច្បាប់សិទ្ធិមនុស្ស ដែលចាត់ថាមនុស្សជា ប្រធាននៃ ច្បាប់អន្តរជាតិ (subject of International Law)។ ក្នុងន័យនេះ បុគ្គលមានសិទ្ធិ ដែលរដ្ឋមានកាតព្វកិច្ចធានា គោរពនូវសិទ្ធិ ហើយបុគ្គលមានកាតព្វកិច្ច ក្រោមច្បាប់អន្តរជាតិ ជាឧទាហរណ៍ កាតព្វកិច្ចគោរព សិទ្ធិមនុស្សរបស់ជនដទៃ ឬ ការមិនប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជាដើម។ ប្រសិនបើបុគ្គលប្រព្រឹត្ត គាត់នឹងទទួលខុសត្រូវព្រហ្មទណ្ឌ។ មានន័យថា អ្នកប្រព្រឹត្តនឹងត្រូវបានចោទប្រកាន់ និងចាប់ខ្លួនជាដើម។

មានជាតុផ្សំចំនួនពីរ សម្រាប់ដាក់ការខុសត្រូវលើបុគ្គល ទី១. មានបទឧក្រិដ្ឋកើតមានឡើង និងទី២ បុគ្គលនោះបានការចូលរួមតាមមធ្យោបាយ ឬទម្រង់

---

[714] Judgment of the International Military Tribunal for the Trial of the German Major War Criminals, Nuremberg, 30th September and 1st October, 1946, Cmd 6964, 41-2.

ណាក៏ដោយ ឧទាហរណ៍តាមរយៈការបញ្ជា។ ការទទួលខុសត្រូវរបស់បុគ្គល តម្រូវឲ្យបុគ្គលចេញនូវសំណងខូចខាត ចំពោះជនរងគ្រោះ នៃអំពើរបស់គាត់ ប្រសិនបើគាត់ត្រូវបានរកឃើញដោយតុលាការថាមានកំហុស។ នេះខុសពី ការទទួលខុសត្រូវរបស់រដ្ឋ (State Responsibility) ដោយសារអំពើរបស់ រដ្ឋ ហើយថវិកាចំណាយ សម្រាប់សំណងនៃការខូចខាត គឺជាបន្ទុករបស់រដ្ឋ។ សភាប្រទេស *X* បានអនុម័ត អនុញ្ញាតឲ្យរដ្ឋាភិបាល ខ្ចីលុយ ប្រទេស Y ដោយមានចែងកាតព្វកិច្ចសងលុយក្នុង សន្ធិសញ្ញា។ នេះគឺជា កិច្ចរបស់រដ្ឋ ទាញចេញពីអំពើរបស់រដ្ឋ (Act of State)។ បើរដ្ឋខកខានមិនបានសង រដ្ឋរំលោភកាតព្វកិច្ចទ្វេភាគី និងត្រូវទទួលខុសត្រូវសងសំណង ដោយយក ថវិកាជាតិ មកប្រើប្រាស់ដើម្បីសង។ ទោះបីជា មានការខុសគ្នាក្តី ប្រភេទទាំង ពីរនៃការទទួលខុសត្រូវ មានទំនាក់ទំនងគ្នា តែមិនចាំបាច់ ជាលក្ខខណ្ឌ នៃការនាំឲ្យមានការទទួលខុសត្រូវ នៃប្រភេទណាមួយឡើយ។ នៅក្នុងរឿងក្តី *Kosovo* ប្រឆាំងនឹង Serbia ភាគី Serbia បានស្នើឲ្យតុលាការយុត្តិធម៌ អន្តរជាតិ បដិសេធបណ្តឹងចោទ និងស្នើសុំមិនឲ្យ Serbia ជារដ្ឋទទួល ដោយ សារបុគ្គលដែលពាក់ព័ន្ធ នឹងអំពើប្រល័យពូជសាសន៍ ដែលជាអង្គហេតុ ក្នុងបណ្តឹង នៅមិនទាន់ត្រូវបានសម្រេចកាត់ទោស ICTY ឡើយ។ តុលាការ យុត្តិធម៌អន្តរជាតិ បានឆ្លើយតបថា ការទទួលខុសត្រូវរបស់បុគ្គល មិនប៉ះ ពាល់ដល់ការទទួលខុសត្រូវរបស់រដ្ឋទេ ចំពោះការខកខានមិនបានបំពេញ តាមកាតព្វកិច្ចក្រោមសន្ធិសញ្ញា ដែលហាមឃាត់ អំពើប្រល័យពូជសាសន៍ ។[715] បើតុលាការខ្លួនឯងរកឃើញថាមានអំពើ ប្រល័យពូជសាសន៍ កើតមាន

[715] Keren Michaeli, *Tadic*, *see* Antonio, the Oxford, *supra* note 55, p. 947.

ឡើង ហើយរដ្ឋខកខានមិនបានបង្ការ ឬនាំខ្លួនអ្នកទទួលខុសត្រូវចំពោះការប្រព្រឹត្ត រដ្ឋនឹងទទួលខុសត្រូវ។[716]

### ១០.១.១. យន្តការសម្រាប់ការអនុវត្តការទទួលខុសត្រូវ

យន្តការ គឺសំដៅទៅលើតុលាការ។ យ៉ាងហោចណាស់ មានតុលាការចំនួនពីរប្រភេទគឺ តុលាការជាតិ និងតុលាការអន្តរជាតិ។[717] តុលាការជាតិប្រទេសខ្លះ បានធ្វើការស៊ើបអង្កេត និងកាត់ទោសបុគ្គល ដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ។[718] ការកំណត់ថាតុលាការណាមួយ ជាតុលាការជាតិ គឺវាផ្អែកទៅលើ រចនាសម្ព័ន្ធ ដែលតុលាការស្ថិតនៅ ឬផ្អែកតាមច្បាប់ដែលតុលាការប្រើប្រាស់ និងបង្កើតឡើង។ តាមលក្ខណវិនិច្ឆ័យទី១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) ជាតុលាការជាតិ ដោយសារតុលាការនេះ ស្ថិតនៅក្នុងប្រព័ន្ធរបស់តុលាការជាតិកម្ពុជា។ សេចក្តីសន្និដ្ឋានយ៉ាងដូចនេះ សមហេតុសមផល ដោយសារអង្គជំនុំជម្រះ ប្រើច្បាប់កម្ពុជាជាចម្បង។[719] តាមលក្ខណវិនិច្ឆ័យនេះដែរ តុលាការសេរ៉ាឡេអូន គឺជាតុលាការ

[716] The Genocide Convention, *supra* note 74, Art. 6.

[717] The term “mixed tribunal” deos not have legal implication.

[718] Ward Ferdinandusse, *the Interaction of National and International Approches in the Reprssion of International Crimes*, 15(5) EJIL 2004. Belgium’s court wants to try in her court the minister of Congo for commission of crime under international law, *see* Case Concerning the Arrest Warrant of 11 April 2000 (Congo v. Belgium), 2002 ICJ 121 (Feb 14, 2002), 41 ILM 536 (2002).

[719] The ECCC Law, *supra* note 91, Art. 33 New.

អន្តរជាតិ ពីព្រោះមិនស្ថិតនៅ ក្នុងប្រព័ន្ធតុលាការជាតិ ហើយជាពិសេស តុលាការនេះ ប្រើច្បាប់អន្តរជាតិទាំងស្រុង។[720]

### ១០.១.១.១. តុលាការព្រហ្មទណ្ឌសម្រាប់ Rwanda និងសម្រាប់ អតីតយូហ្គោស្លាវ

តុលាការសម្រាប់ Rwnada (ICTR) ត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ តាមសំណើរបស់ Rwanda ដែលតុលាការនេះ មានសមត្ថកិច្ចលើបទឧក្រិដ្ឋកម្មសង្គ្រាម ប្រល័យពូជសាសន៍[721] ព្រមទាំងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ។ សមត្ថកិច្ចលើបទឧក្រិដ្ឋទាំងនេះ ត្រូវបានផ្តល់ផងដែរដល់តុលាការព្រហ្មទណ្ឌសម្រាប់ អតីតយូហ្គោស្លាវី (ICTY) បង្កើតឡើងមុន ICTR ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ តាមជំពូកទី ៧របស់ធម្មនុញ្ញអង្គការសហប្រជាជាតិ ។[722] ដោយសារមូលដ្ឋាននៃការបង្កើតតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខដែលសេចក្តីសម្រេចចងជាកាតព្វកិច្ចដល់រដ្ឋ តាមមាត្រា ២៥របស់ធម្មនុញ្ញអង្គការសហប្រជាជាតិ បញ្ហាអភ័យឯកសិទ្ធិ ការលើកលែងទោស ជាពិសេសការសហការក្នុងការចាប់ខ្លួន មិនជាការប្រឈមឡើយ។ តុលាការ ICTY មានអាទិភាពជាងតុលាការជាតិរបស់ ICTR និងរបស់ប្រទេសដទៃទៀត

[720] The Tribunal was established between the United Nations and Sierra Leone through agreement, *see* M. Cherif Bassiouni, Jose Doria and Hans-Petter Gasser, the Legal Regime of the International Criminal Court, 2009, p. 229.

[721] Nuremburg tribunal does not try accused for genicide since it covers extermination and crime against humanity; UN Security Council Res 955 of 8 November 1994 on Establishing the ICTR, U.N. Doc.S/RES/955 1994).

[722] Security Council Res 808, UN SCOR, 48th sess, 3175th mtg, [2], UN Doc S/RES/808 (1993).

ដោយអាចបញ្ឈប់នីតិវិធី នឹងតម្រូវឲ្យរដ្ឋ បញ្ជូនជនត្រូវចោទមកឲ្យខ្លួន។ ឧទាហរណ៍ ករណីរបស់ *Tadic* ។ *Tadic* ត្រូវបានចាប់ខ្លួនដោយ តុលាការប្រទេសអាឡឺម៉ង់ ក្រោយមកត្រូវបានបញ្ជូនមកតុលាការ។[723] ទោះបីជាយ៉ាងនេះក្តី តុលាការក្នុងស្រុកនៅតែអាចកាត់សេចក្តី ចំពោះបទល្មើស មិនធ្ងន់ធ្ងរ ដែលមិនចូលក្នុងយុត្តាធិការរបស់ ICTY ដោយសារផ្តួចផ្តើម របស់ តុលាការក្នុងស្រុកខ្លួនឯង ឬ តាមសំណើនៅមុខ ICTY ដោយជនត្រូវចោទ ដែលសុំឲ្យបញ្ជូនខ្លួនគាត់ទៅឲ្យតុលាការជាតិ ណាមួយដើម្បីកាត់ទោស ។[724] ICTY នឹងពិនិត្យមើលសំណើ ហើយក្នុងករណីខ្លះបដិសេធ ដោយសារ ខ្លួនមានសមត្ថកិច្ច ហើយការកាត់សេចក្តីនៅតុលាការក្នុងស្រុកនោះ មិនគោរពតាមនីតិវិធី ឬ ជាការកាត់ទោសឲ្យគ្រាន់តែល្អមើល។[725]

មានបញ្ហាពាក់ព័ន្ធនឹងភាពស្របច្បាប់របស់ ICTY លើកឡើងដោយ *Tadic* ។[726] *Tadic* បានអះអាងថា ស្ថានភាពនៅក្នុងប្រទេស យូហ្គោស្លាវី មិនប៉ះពាល់ដល់សន្តិសុខ និងសន្តិភាពពិភពលោកឡើយ។ ដូចនេះ ក្រុមប្រឹក្សាសន្តិសុខ មិនមានសមត្ថកិច្ចផ្អែកតាមជំពូកទី ៧ នៃធម្មនុញ្ញអង្គការសហប្រជាជាតិឡើយ។ តុលាការ គួរតែត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញា។[727] តុលាការ បានឆ្លើយតបថា ក្នុងពេលធម្មតា តុលាការ អាចត្រូវបានបង្កើតឡើងតាមសន្ធិសញ្ញា តែក្នុងករណីបណ្តោះអាសន្ន តុលាការក៏អាចត្រូវបានបង្កើតឡើងតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិបានដែរ។ ក្រុមប្រឹក្សា

[723] Keren Michaeli, *Tadic*, Antonio, the Oxford, *supra* note 55, p. 944.
[724] Ruth Mackenzie, the Manual on International Courts and Tribunals, 2nd ed., 2010, pp. 196-197.
[725] *Id.*, p. 196.
[726] Keren Michaeli, *Tadic*, see Antonio, the Oxford, *supra* note 55, p. 945.
[727] *Id.*, p. 945.

សន្តិសុខ ដែលមានតួនាទីជាស្ថាប័នថែរក្សាសន្តិភាព និងសន្តិសុខពិភពលោក អាចចាត់គ្រប់វិធាន ដូចជាការបង្កើតតុលាការ ដើម្បីថែរក្សា និងការពារសន្តិសុខ និងសន្តិភាពពិភពលោក។ មាត្រា ៤១ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ មិនមានហាមឃាត់ក្រុមប្រឹក្សាសន្តិសុខ មិនឲ្យបង្កើតតុលាការឡើយ។[728]

### ១០.១.១.២. តុលាការព្រហ្មទណ្ឌអន្តរជាតិ

#### ១០.១.១.២.១. ប្រវត្តិ

ចេតនាក្នុងការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ មានតាំងពីក្រោយសង្គ្រាមលោកលើកទី១មកម្ល៉េះ ក៏ប៉ុន្តែមិនមានចេញជាផ្លែផ្កាទេ។ នៅក្នុងពេលចរចាធ្វើសេចក្តីព្រាងសន្ធិសញ្ញា ស្តីពី ការហាមឃាត់ អំពើប្រល័យពូជសាសន៍ មានការស្នើ ឲ្យមានការបង្កើតតុលាការព្រហ្មទណ្ឌ អចិន្ត្រៃយ៍តាមខ្លឹមសាររបស់មាត្រានៃសន្ធិសញ្ញានេះ។[729] ទោះបីជាយ៉ាងនេះក្តី មិនទទួលបានការគាំទ្រច្រើនទេ ដោយសារការពិបាកក្នុងការផ្តល់ន័យដល់បទឧក្រិដ្ឋឈ្លានពាន(Aggression)។[730] ក្រោយមកដោយពិចារណាឃើញថា តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី បង្កើតតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការប្រជាជាតិ មិនត្រូវបានបង្កើតតាមសន្ធិសញ្ញា សម្រាប់តែព្រឹត្តិការណ៍មួយ មិនអចិន្ត្រៃយ៍ និង ដើម្បី

---

[728] *Id.,* pp. 945-946.

[729] For relevance, *see* Georghios M. Pikis, the Rome Statute for the International Criminal Court, 2010, p. 6.

[730] Draft IL Commission on Crime against Peac; for the development of norms, *see* the United Nations, Hostorical Review of Developments relating to Aggression, 2003; Otto Triffterer, Commentary on the Rome Statute of the International Criminal Court, 2nd ed., p. 17.

ឆ្លើយតបជាមួយនឹងការប្រព្រឹត្តបទឧក្រិដ្ឋ និងបញ្ហានិទ្ទណ្ឌភាព ឆ្នាំ១៩៩៨ រដ្ឋបានជួបប្រជុំគ្នាដើម្បីពិនិត្យ មើលសេចក្តីព្រាងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយទុកបញ្ហា និយមន័យការឈ្លានពាន មួយអន្លើសិន។ ឆ្នាំ ២០០០ លក្ខន្តិកៈ (Rome Statute) ត្រូវបានអនុម័ត ដោយមិនអនុញ្ញាត ឲ្យមានការធ្វើឧរក្សាសិទ្ធិមិនអនុវត្តន៍ឡើយ (Reservation)។ លក្ខន្តិកៈ បានចូលជាធរមានក្នុងឆ្នាំ ២០០២ ខែ កក្កដា ដែលមកដល់ពេលនេះ មានរដ្ឋជាភាគីចំនួន ១២២។[731] តុលាការនេះ ជាតុលាការអចិន្រ្តៃយ៍ ជាតុលាការពិភពលោក តែមិនមែនជាស្ថាប័នរបស់ អង្គការសហប្រជាជាតិឡើយ។[732]

### ១០.១.១.២.២. សមត្ថកិច្ច និងការអនុវត្តសមត្ថកិច្ច

តុលាការមានសមត្ថកិច្ច ចំពោះបទល្មើសបួនប្រភេទ គឺបទឧក្រិដ្ឋកម្មសង្គ្រាម បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបទឈ្លានពាន។ តុលាការមាន សមត្ថកិច្ចចំពោះបទល្មើសទាំងនេះ សម្រាប់អំពើកើតក្រោយពេល ដែល Rome Statute ចូលជាធរមានសម្រាប់រដ្ឋ ដែលពាក់ព័ន្ធ ត្រូវបានប្រព្រឹត្តដោយ មនុស្សអាយុលើសពី ១៨ឆ្នាំ នៅក្នុងពេលប្រព្រឹត្តបទឧក្រិដ្ឋ។[733] ភាគច្រើននៃបទល្មើស ក្នុងបទឧក្រិដ្ឋទាំងបីខាងមុខ ជាបទ

---

[731] Ruth Mackenzie, the Manual, *supra* note 724, p. 158. There 34 African States; 18 in Asia and the Pacific; 18 of Eastern Europe; 27 States of Latin America and Caribbean, and 25 from Western Europe and other States, see www.icc-cpi.int (visited on 31 May 2013).

[732] Ruth Mackenzie, the Manual, *supra* note 724, p. 157; the Rome Statute, *supra* note 634, Art. 4.

[733] The Rome Statute, Art. 26.

ល្មើសក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។[734] បទឧក្រិដ្ឋទាំងអស់នេះ ជាបទឧក្រិដ្ឋធ្ងន់ធ្ងរ និងជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ។

## ក. បទប្រល័យពូជសាសន៍

បទប្រល័យពូជសាសន៍សំដៅលើ អំពើមានចេតនាពិសេសបំផ្លាញក្រុមមនុស្សនៃ សាសនា ឬពូជសាសន៍ ទាំងស្រុង ឬដោយផ្នែក។[735] អំពើនេះអាចជាការសម្លាប់។ ការសម្លាប់ ក្នុងចេតនាបំបាត់ពូជ។ អ្នកប្រព្រឹត្តមានចេតនា សម្លាប់ និងចេតនា នៃការសម្លាប់គឺឲ្យផុតពូជ។ ការសម្លាប់ បុគ្គល X កាន់សាសនា y ដោយគ្រាន់តែ យកទ្រព្យសម្បត្តិ មិនបង្ហាញពីចេតនា ឬការធ្វើឲ្យបំបាត់ពូជក្រុមមនុស្សទេ។[736] ព្រោះវាជាចេតនាធម្មតា លើកលែងតែដើម្បីយកទ្រព្យ ដែលប្រសិនបើគ្មានទ្រព្យនោះ ក្រុមមនុស្សណាមួយនឹងស្លាប់ផុតពូជ ក្នុងអំឡុងពេលណាមួយ។ ពាក្យថា "ដោយផ្នែក" សំដៅលើសមាជិកមួយចំនួននៃក្រុមមនុស្ស។ នេះដោយពិចារណាទៅលើ អង្គហេតុដែលថា ជនត្រូវចោទមិនអាច សម្លាប់មនុស្សទាំងអស់ក្នុងក្រុមបានឡើយ។ ទោះបីជាយ៉ាងនេះ ក្តីចំនួនសមាជិក ដែលត្រូវបានសម្លាប់ ត្រូវតែមាន Substantial (Not Significant) Effect ទៅលើក្រុមមនុស្សទាំងមូល។[737] ករណី សម្លាប់ស្ត្រីទាំងអស់ក្នុងក្រុមមនុស្ស ស្ថិតក្នុងន័យនេះ

---

[734] Antonio Cassese, *Genocide*, see Antonio, the Oxford, *supra* note 55, pp. 332-333.

[735] The Genocide Convention, *supra* note 74, Art. II.

[736] Ethnic cleansing might not be act of genocide if withtout specific intention to destroy group; it might be just extermination.

[737] The Prosecutor v. Kayishema and Ruzindara, *supra* note 640, paras. 96-97; the *Prosecutor v. Bagilishema*, Case No. ICTR-95-1A-T, judgement of June 17, 2001, para. 64. They means "to destroy a considerable number of individuals who are

ពីព្រោះក្នុងរយៈពេល មួយនោះ ក្រុមមនុស្សនឹងបាត់បង់ឯងៗ ព្រោះគ្មានមនុស្សបង្កើតពូជនៃក្រុមមនុស្សនេះ។ ការសម្លាប់មនុស្សម្នាក់នៅក្នុងក្រុម ជាលទ្ធផលនៃ គោលនយោបាយជាក់លាក់ បង្ហាញពីចេតនាបំផ្លាញក្រុមមនុស្សឲ្យផុតពូជ ក៏អាចត្រូវបានចាត់ថា ជាអំពើព្រល័យពូជសាសន៍ផងដែរ។

បទប្រល័យពូជសាសន៍ សំដៅលើការបំផ្លាញមនុស្ស ឲ្យផុតពូជ មិនបានក្តោប ការបំផ្លាញសម្ភារដូចជា សៀវភៅសាសនា (Cultural Genocide)ទេ។ ដូចគ្នានេះដែរ ការសម្លាប់ក្រុមមនុស្ស ដែលប្រកាន់យកគំនិតនយោបាយ (Political Genocide) មិនមែនជាអំពើប្រល័យពូជសាសន៍ក្រោមមាត្រា នៃ Rome Statute ទេ។[738] ពាក្យ សម្រាប់ចាត់ប្រភេទក្រុមមនុស្ស ដូចជា ជាតិពូជសាសន៍ ជាតិពន្ធ គ្រាន់ជាពាក្យក្នុងច្បាប់ តែជាការអនុវត្ត មានការពិបាកក្នុងការចាត់ថ្នាក់ប្រភេទនៃ ក្រុមមនុស្សទាំងនេះ។

## ខ. បទឧក្រិដ្ឋកម្មសង្គ្រាម

បទឧក្រិដ្ឋកម្មសង្គ្រាម ជាអំពើប្រព្រឹត្តទៅលើមនុស្សក្នុងពេលមានសង្គ្រាមជាអន្តរជាតិ (International Armed Conflict)[739] ដែលជាជនស៊ីវិល និងទាហានដែលត្រូវបានការពារ របស់ប្រទេសក្នុងជម្លោះប្រដាប់អាវុធ។ វាអាចជាអំពើបំពារបំពានធ្ងន់ធ្ងរ លើសន្ធិសញ្ញាហ្សឺណែវឆ្នាំ ១៩៤៩ ដូចជាការសម្លាប់ ដែលត្រូវបានហាមឃាត់ដោយសន្ធិសញ្ញានេះ និង ដែលត្រូវបាន

part of the group", "must target at least a substantial part of the group"respectively.

[738] This article was adopted from the Genocide Convention. This might be due to the fact that States might be responsible for act of genocide as regards killing of the political opponents; Matthew Lippman, genocide, p. 604.

[739] Please see the previous page.

ចាត់ថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ វាជាអំពើដទៃទៀតផ្ទុយនឹងវិធានច្បាប់អន្តរជាតិ ដែលអនុវត្តន៍ក្នុងពេលមានសង្គ្រាម។[740] ការប្រព្រឹត្ត ត្រូវតែជាប់ពាក់ព័ន្ធជាមួយសង្គ្រាម។ ឧទាហរណ៍ អំពើចក់ប្លន់ ដើម្បីយកលុយទៅជួយធ្វើសង្គ្រាម អាចជាបទឧក្រិដ្ឋកម្មសង្គ្រាម តែបើប្លន់ក្នុងពេលសង្គ្រាមសម្រាប់ប្រយោជន៍អ្នកប្លន់ មិនមែនជាបទឧក្រិដ្ឋកម្មសង្គ្រាមឡើយ។

ក្នុងពេលថ្មីៗនេះ អំពើដែលត្រូវបានហាមឃាត់ ក្នុងសង្គ្រាមអន្តរជាតិ ត្រូវបានប្រព្រឹត្ត ក្នុងសង្គ្រាមក្នុងស្រុក (Internal Armed Conflict) រវាងរដ្ឋាភិបាល និងកងទ័ពប្រឆាំងនឹងរដ្ឋាភិបាល។ មានការតវ៉ា ដោយជនត្រូវចោទចំពោះការចោទប្រកាន់លើអំពើ ប្រព្រឹត្តនៅក្នុងអំឡុងពេលនៃសង្គ្រាមក្នុងស្រុក ក៏ប៉ុន្តែតុលាការ បានបដិសេធ ពីព្រោះវាគ្មានហេតុផលសមស្របសោះក្នុងការយកឱកាសពីចន្លោះប្រហោងក្នុងច្បាប់ ដោះសារមិនឲ្យមានការទទួលខុសត្រូវចំពោះអំពើដូចគ្នា ដែលត្រូវបានប្រព្រឹត្តក្នុងសង្គ្រាម។[741]

## គ. បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

បទឧក្រិដ្ឋនេះ រាប់បញ្ចូលនូវអំពើទារុណកម្ម ធ្វើនៅក្នុងក្របខ័ណ្ឌទូលំទូលាយ ឬជាប្រព័ន្ធ (Widespread or Systematic)។[742] "ទូលំទូលាយ" សំដៅលើ វិសាលភាពនៃអំពើក្នុងដែនដី។ ពាក្យ "ជាប្រព័ន្ធ" សំដៅលើការ

[740] Example, act of intentionally directing attackes against civilian objects, that is , objects which are not military objectives, see the Rome Statute, *supra* note 634, Art. 8(2).

[741] Rome Statute, *supra* note 634, Art. 8(2.c).

[742] There is a challenge as regards the existence of the crime against humanity; however, it was argued that the 1949 Geneva Convention leaves room for development of other crimes; see the Rome Statute, *supra* note 634, Art. 7.

ប្រព្រឹត្តជារចនាសម្ព័ន្ធ ពីលើមកក្រោម។ អំពើនេះ ត្រូវបានប្រព្រឹត្តលើប្រជាជនស៊ីវិល។ ដូចអំពើប្រល័យពូជសាសន៍ដែរ បទឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ អាចត្រូវបានប្រព្រឹត្តនៅក្នុងពេលសន្តិភាព ឬក្នុង ពេលសង្គ្រាម។[743] នៅមុនសង្គ្រាមលោកលើកទី ២ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឲ្យមានការជាប់ពាក់ព័ន្ធជាមួយសង្គ្រាម។[744] បទឧក្រិដ្ឋនេះ មានការវិវត្តក្រោយបទឧក្រិដ្ឋកម្មសង្គ្រាម ដោយសារថា ក្នុងសម័យបុរាណការសម្លាប់ប្រជាពលរដ្ឋរបស់ប្រទេសមួយ ដោយប្រទេសមួយទៀត ក្នុងពេលមានសង្គ្រាមបង្កជាបញ្ហាច្បាប់។ ការប្រព្រឹត្តលើប្រជាពលរដ្ឋ ដោយអាជ្ញាធររបស់រដ្ឋខ្លួនឯង គឺជារឿងផ្ទៃក្នុងរបស់ប្រទេសជាតិ។ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ជាទូទៅ គឺអំពើធ្វើលើ ប្រជាពលរដ្ឋរបស់ខ្លួនឯង។

### ឃ. បទឈ្លានពាន

អំពើឈ្លានពាន គឺជាការប្រើកម្លាំងខុសច្បាប់។ បទឧក្រិដ្ឋប្រភេទនេះ ទើបត្រូវបានដាក់បញ្ចូលទៅក្នុង Rome Statute តាមរយៈការធ្វើវិសោធនកម្មក្រោយលក្ខន្តិកៈចូលជាធរមាន។ បទល្មើសនេះ ធ្វើឡើងដោយបុគ្គល ដែលមានការគ្រប់គ្រងមានប្រសិទ្ធភាព លើយន្តការ នៃការប្រព្រឹត្តបទឈ្លានពាន [745] ក្នុងទំហំធំធេង (Gravity and Scale) និងរំលោភធម្មនុញ្ញអង្គការសហ

[743] Jonas Nilsson, *Crime against Humanity*, see Antonio, the Oxford, *supra* note 55, p. 287.

[744] International Tribunal for the Prosecution of Persons Responsible for Serious Violations of International Humanitarian Law Committed in the Territory of Former Yugoslavia since 1991, *the Prosecutor v. Dusko Tadic*, IT-94-1-AR72, decision on the defence motion for interlocutory appeal on jurisdiction, (1995, 2 October), at 73; Yoram Dinstein, Crimes against humanity, p. 900-901, 1996.

[745] The Rome Statute, *supra* note 634, Art. 8 *bis.*

ប្រជាជាតិ។[746] ទោះបីជាតុលាការ មានសមត្ថកិច្ចលើបទល្មើសនេះក្តី ក៏ការចោទប្រកាន់នឹងមិនអាចធ្វើទៅបានភ្លាមៗឡើយ ពីព្រោះតម្រូវឲ្យមាន វិសោធនកម្មចូលជាធរមាន ហើយឆ្នាំ ២០១៧ សន្និសីទរបស់រដ្ឋជាភាគី ត្រូវពិនិត្យ និងសម្រេច ដោយសំឡេងពីរភាគបី ថាត្រូវចាប់ផ្តើមអនុវត្តចោទប្រកាន់ ឬយ៉ាងណា។[747]

### ខ. សមត្ថកិច្ចលើបុគ្គល និងដែនដី

តុលាការមានសមត្ថកិច្ចចំពោះបទឧក្រិដ្ឋទាំងបួនប្រភេទនេះ ដែលប្រព្រឹត្តដោយប្រជាពលរដ្ឋនៃរដ្ឋជាភាគីទោះបីជា នៅទីកន្លែងណាក្តី ឬ លើដែនដីរបស់រដ្ឋជាភាគី។[748] ដែនដីរាប់បញ្ចូលលើនាវា ឬកប៉ាល់ ចុះបញ្ជីក្នុងរដ្ឋជាភាគី។ ការប្រព្រឹត្តលើដែនដី អាចធ្វើឡើងដោយប្រជាពលរដ្ឋ ឬដោយជនបរទេស។[749]

### ១០.១.១.២.៣. ការទទួលយកបណ្តឹង និងដំណើរការនីតិវិធី

រដ្ឋអាជ្ញាតាមពាក្យបណ្តឹងរបស់បុគ្គល ឬ តាមការដឹងដោយខ្លួនផ្ទាល់ (ឃើញក្នុងសារព័ត៌មានអំពីបទឧក្រិដ្ឋ) អាចផ្តើមការស៊ើបអង្កេត។ រដ្ឋអាជ្ញា ផ្អែកតាមអង្គហេតុ កើតមានក្នុងរដ្ឋជាភាគី ឬបង្ហាញជូនដោយរដ្ឋជាភាគីណាមួយ

---

746 *Id.*, Art. 8 *bis*; Antonio Cassese, International Criminal Law, 2003, p. 114.

747 Georghios M. Pikis, the Rome Statute, *supra* note 729, p. 44; ICC, Understanding the ICC, 2010, p. 12.

748 The Rome Statute, *supra* note 634, Art. 12.

749 *Id.*, Art. 12.

ឬ អង្គហេតុបញ្ជូនដោយក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ក៏អាចផ្ដើមធ្វើការងារស៊ើបអង្កេតផងដែរ។[750]

រដ្ឋអាជ្ញាត្រូវពិនិត្យមើលតើជាប្រភេទបទឧក្រិដ្ឋចែងក្នុង Rome Statute ប្រព្រឹត្តដោយមនុស្សអាយុលើស១៨ឆ្នាំឬទេ។ រដ្ឋអាជ្ញាត្រូវពិនិត្យមើល ថាមាន ដំណើរការចោទប្រកាន់ ធ្វើដោយរដ្ឋដែលពាក់ពន្ធ័លើអំពើឧក្រិដ្ឋទាំងនោះទេ។ ដំណើរការរបស់តុលាការព្រហ្មទណ្ឌ អាចត្រូវបានបញ្ឈប់ភ្លាម ប្រសិនបើមានដំណើរការចោទប្រកាន់ដោយតុលាការជាតិ តាមនីតិវិធី ទទួលយកបានដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ។ នេះជាឧទាហរណ៍ មួយបង្ហាញអំពីភាពបំពេញបន្ថែមរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការជាតិ (Principle of Complementary)។[751] តុលាការនឹងទទួលយកទី១. ករណីដែលរដ្ឋមិនបានចាត់ការរឿងក្ដី ទី២. រដ្ឋធ្វើការស៊ើបអង្កេត ហើយក៏ប៉ុន្តែ រដ្ឋមិនចាត់ការ ហើយតុលាការព្រហ្មណ្ឌអន្តរជាតិ សម្រេចថា ការសម្រេចមិនចាត់ការនោះ ធ្វើឡើងមិនត្រឹមត្រូវ ទី៣. រដ្ឋធ្វើការកាត់សេចក្ដីតែមិនគោរពគោលការណ៍កាត់ក្ដីយុត្តិធម៌ និងជាចុងក្រោយ តុលាការព្រហ្មទណ្ឌអន្តរជាតិ នឹងពិនិត្យក្ដី ទោះបីជាអំពើ ដែលចាត់ជាបទឧក្រិដ្ឋត្រូវបានកាត់រួចហើយដោយតុលាការជាតិក្ដី។[752] ឧទាហរណ៍ អំពើ x ត្រូវបានចាត់ ថាជា បទសម្លាប់ ក្រោមច្បាប់ជាតិ តែអំពើដដែល ត្រូវបានចាត់

[750] *Id.*, Art. 13.

[751] The Preamble , para. 10, and Article 1 of the Rome Statute, *supra* note 634. The investigation and prosecution by the International criminal court may be postponed by the resolution under the Chapter VII of the United Nations Security Council for the period of 12 months, *see* Rome Statute, Art. 16.

[752] The Rome Statute, *supra* note 634, Arts. 17 and 20.

ចូលជាបទសម្លាប់ តាមរយៈការកែនឲ្យចូលកងទ័ព ដែលជាបទឧក្រិដ្ឋក្រោមឧក្រិដ្ឋកម្មសង្គ្រាម។

ដើម្បីពិនិត្យមើលថាតើរឿងក្តីចូលក្នុងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ រដ្ឋអាជ្ញា ត្រូវការស៊ើបអង្កេតជាបឋម។ ក្រោយពេលរកឃើញថាតុលាការមានសមត្ថកិច្ច រដ្ឋអាជ្ញានឹងធ្វើការស្នើសុំដល់អង្គបុរេជំនុំជម្រះ ដើម្បីសុំធ្វើការស៊ើបអង្កេតពេញលេញ និងសុំឲ្យមានការឃុំខ្លួន។ កិច្ចការជាបន្ទាប់គឺការសុំការយល់ព្រមលើបទចោទ និង ការរៀបចំសវនាការ ក្រោយពីការយល់ព្រមលើបទចោទ។[753]

### ១០.១.១.២.៤. ទម្រង់នៃការទទួលខុសត្រូវ

បទល្មើសមួយកើតមាន ដោយសារអំពើរបស់បុគ្គលម្នាក់ ឬច្រើននាក់រួមគ្នាប្រព្រឹត្ត។ បុគ្គលខ្លះប្រព្រឹត្តផ្ទាល់ ខ្លះចូលរួមពីចម្ងាយ តាមរយៈការបញ្ជា ឬការជួយឲ្យមានការប្រព្រឹត្តិកើតមានឡើង។ នេះនាំឲ្យមានការបែងចែកការទទួលខុសត្រូវចម្បង (Principal Liability) និង ការទទួលខុសត្រូវបន្ទាប់បន្សំ (Accessory Liability) ។ ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ជាទូទៅ មិនពឹងផ្អែកលើការទទួលខុសត្រូវ របស់បុគ្គលណាមួយទៀតឡើយ។ តុលាការអាចឲ្យបុគ្គល ជួយប្រព្រឹត្តបទឧក្រិដ្ឋទទួលខុសត្រូវ ដោយមិនចាំបាច់រង់ចាំការដាក់ការទទួលខុសត្រូវរបស់ជនដៃដល់ជាមុនសិន។

លក្ខន្តិកៈទីក្រុងរ៉ូម បានកំណត់ប្រភេទទទួលខុសត្រូវជាច្រើនប្រភេទ មានការបញ្ជា ការជួយ និងតាមរយៈសហឧក្រិដ្ឋកម្មរួម (Joint Criminal

[753] The Rome Statute, *supra* note 634, Art. 15.

Enterprise: JCE) ការទទួលខុសត្រូវក្នុងការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ និងរួមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍។[754] លក្ខន្តិកៈហាក់ មិននិយាយច្បាស់អំពី ការធ្វើផែនការប្រព្រឹត្តបទល្មើសទេ។

ទម្រង់ទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួម ដែលបង្កើតឡើងក្នុងយុត្តិសាស្ត្រ នៃក្តីក្តាំ *Tadic* ដ៏ចម្រូងចម្រាស ត្រូវបានដាក់បញ្ចូលផងដែរ។ វាជាសមិទ្ធផលនៃប្រព័ន្ធ Common Law។ ទម្រង់នេះ បានបដិសេធនូវសមាសធាតុជាក់លាក់ នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល ដោយទទួលយក ធាតុអត្តនោម័តមិនប្រាកដប្រជា (*Mens Rea*)។[755] បញ្ហានេះមានពិតប្រាកដ បើពិនិត្យមើល JCE ទម្រង់ទី III[756]។ ការតម្រូវនូវធាតុអត្តនោម័តទាប (Low Threshold) នាំឲ្យ មានភាពងាយស្រួលក្នុងការបង្ហាញពីការទទួលខុសត្រូវ។ JCE មានបីប្រភេទ ដែលមានធាតុផ្សំរួមចំនួនបី ៖ ១. ផែនការឧក្រិដ្ឋកម្មរួម ២. មានមនុស្សចាប់ ពីពីរនាក់ទៅបានចូលរួម និងទី ៣. ការបរិច្ចាគ ឬចូលរួម នាំឲ្យមានភាព ចម្រើនទៅមុខនៃផែនការរួម ឬការប្រព្រឹត្តបទឧក្រិដ្ឋ។ ប្រភេទទី ១ គឺប្រភេទ ចម្បង (Basic Form)។ អ្នកចូលរួមទាំងអស់ មានផែនការឧក្រិដ្ឋកម្មរួម និងមានចេតនានាំឲ្យសម្រេចផលនៃផែនការដូចគ្នា។ ប្រសិនបើមានម្នាក់ក្នុងក្រុមបានប្រព្រឹត្ត អ្នកដទៃក្នុងក្រុមនឹងទទួលខុសត្រូវដែរ ដោយសារពួកគេ ត្រូវ

[754] *Id.,* Art. 25.

[755] The reason to adopt this form of responsibility is that massive crime and serious crime under international law were committed by many people, and difficult to identify their each contribution to the crimes. Adopting such a form is to catch all fishes, big and small.

[756] Katrina Gustafson, *Joint Criminal Enterprise*, see Antonio, the Oxford, *supra* note 55, p. 395.

បានចាត់ជាសហចារី (Co-Perpetrater)។[757] ទម្រង់ទី ២ (Sytematic Form) ត្រូវបានប្រើសម្រាប់ ករណីបទឧក្រិដ្ឋកើតនៅ ក្នុងមន្ទីរឃុំឃាំង។[758] បុគ្គលបានដឹងនូវ អំពើខុសច្បាប់ក្នុងពន្ធនាគារ តែនៅមានចេតនាចូលរួមក្នុង អំពើនោះ ឧទាហរណ៍ ការចូលរួមវាយសួរយកចម្លើយ គាត់នឹងទទួលខុសត្រូវ។ ទម្រង់ចុងក្រោយ សម្រាប់បទល្មើស មិនស្ថិតនៅក្នុងផែនការរួម។ ឧទាហរណ៍ មនុស្សមួយក្រុម បានព្រមព្រៀង រៀបចំផែនការប្លន់ធនាគារមួយ។ x បានដឹងថា y មានកាំភ្លើង ហើយជាទម្លាប់ ឬ ជាចរិតរបស់ y នៅពេលខឹង គាត់នឹងបាញ់សម្លាប់មនុស្ស ហើយ x នៅតែចូលរួមជាមួយ y។ X មិនគ្រាន់តែទទួលខុសត្រូវចំពោះបទប្លន់ ដែលគាត់មានចេតនាធ្វើនោះទេ ថែមទាំង ទទួលខុសត្រូវចំពោះ ការសម្លាប់ដោយ y ទោះបីជាគាត់គ្រាន់តែដឹងថា អាច នឹងកើតមានឡើង ហើយ x គ្មានចេតនា ឬចូលរួមប្រព្រឹត្តការសម្លាប់ទេ។ វាហាក់បីដូចជាការទទួលខុសត្រូវជំនួស ដោយគ្រាន់តែដឹងអ្វីដែលអាចនឹង កើតមានឡើង។ ការកំណត់ការចូលរួមនេះ ហាក់ទាមទារកម្រិតអប្បបរមា (Threshold) ទាបជាង សម្រាប់ការទទួលខុសត្រូវ ក្នុងការជួយប្រព្រឹត្តបទល្មើស ដែលតម្រូវឲ្យការជួយនាំ ឲ្យបទឧក្រិដ្ឋកើតមានឡើង ទាមទារនូវ Substantial Contribution។[759] វាកាន់តែស្មុគស្មាញជាបន្ថែមទៀត ប្រសិនបើទទួលស្គាល់ថា ការចូលរួមក្នុងទម្រង់ JCE គឺជា

---

[757] Trial Chamber Judgement in Case 001, 001-E188 (01 Case Judgement), 26 July 2010, para. 510; Gerhard Werle, *Individual Criminal Responsibility in Article 25 ICC Statute*, 54 Journal of International Criminal Justice, 2007, p. 958.

[758] 01 Case Judgement, *supra* note 757, para. 507.

[759] Example, for stealing a bike, there is a need of hammer to destroy key; Mr. X gives a small hammer, not in the sense that without such a hammer, crime would not have been occurred, Mr. X is responsible; *the Prosecutor v. Rutaganda*, *supra* note 640, para. 43.

ការប្រព្រឹត្ត។ ដោយសារមូលហេតុនេះហើយ ទើបបានជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) មិនបានប្រកាន់យក JCE ទម្រង់ទី៣។[760]

JCE ខុសពី ការរួមគំនិតទុច្ចរិតប្រព្រឹត្តបទឧក្រិដ្ឋ (Conspiracy) ដោយសារ Conspiracy គឺជាបទឧក្រិដ្ឋ ដែលមានការដាក់ទោស។ ឧទាហរណ៍ ប្រសិនបុគ្គលរួមគំនិត ធ្វើគោលនយោបាយប្រល័យពូជសាសន៍ គាត់នឹងមានទោស ទោះបីជាមិនទាន់មានការប្រព្រឹត្តក្តី។ ដូចគ្នានេះដែរ JCE ខុសពី Organized Crimes ដោយសារវាជាបទឧក្រិដ្ឋ ចំណែកឯ JCE គឺជាទម្រង់នៃការទទួលខុសត្រូវ។ ជាចុងក្រោយ ការចូលរួមក្នុង JCE អាចជាការជួយធ្វើផែនការ ដែល ខុសពីការរៀបចំផែនការប្រព្រឹត្តបទឧក្រិដ្ឋ ពីព្រោះវាជាផែនការនៃបទឧក្រិដ្ឋ វាមិនមានជាផែនការសម្រាប់ប្រព្រឹត្តបទឧក្រិដ្ឋ ដែលអាចត្រូវធ្វើដោយ បុគ្គលម្នាក់ទេ។ ទោះបីជាយ៉ាងនេះក្តី ក្នុង JCE ក៏មានការធ្វើផែនការសម្រាប់ប្រព្រឹត្តដែរ។ ការទៅប្លន់ធនាគារ គឺជាផែនការឧក្រិដ្ឋរួម ដែលអាចទាមទារឲ្យមានការរៀបផែនការ សម្រាប់ប្លន់ជាក់ស្តែង។ បុគ្គល x អាចទទួលខុសត្រូវចំពោះបទប្លន់ ក្នុងទម្រង់ JCE I សម្រាប់ការរៀបចំផែនការរបស់គាត់។

[760] ECCC, PTC, Decision on the Appeals against thr Co-Investigating Judges Order on JCE, 20 May 2010, D97/15/9, para. 77; for criticism, *see* David Scheffer and Anthony Dinh, the Pre-Trial Chamber's Significant Decision on JCE for Individual Responsibility, p. 3, www. Cambodiatribunal.org.

### ១០.១.១.២.៥. មូលដ្ឋានសម្រាប់ការរួចផុតពីការទទួលខុសត្រូវ

ការប្រព្រឹត្តបទឧក្រិដ្ឋ ជួនកាល បណ្តាលមកពីកាលៈទេសៈបង្ខំ ឬ បុគ្គលអ្នកប្រព្រឹត្តបានបាត់បង់សមត្ថភាព ដឹងខុសត្រូវ ក្នុងអំឡុងពេលនៃការប្រព្រឹត្ត។ ផ្អែកលើមូលដ្ឋាននេះហើយ លក្ខន្តិកៈទីក្រុងរ៉ូម បានចែងនូវមូលដ្ឋានមួយចំនួន ដែលផ្អែកតាមមូលដ្ឋានទាំងនេះ បុគ្គលអាច ត្រូវបានដាក់ឲ្យរួចផុតពីការទទួលខុសត្រូវ។

បុគ្គលដែលមានវិបត្តិផ្លូវចិត្ត ដែលមិនមានសមត្ថភាពក្នុងការដឹងខុសត្រូវ ឬមិនអាចគ្រប់គ្រងខ្លួននៅពេលប្រព្រឹត្តបទល្មើស។ អ្នកដែលញៀនជាតិស្រវឹង លើកលែងភាពស្រវឹង ឬពុល ជាចេតនាបង្កើតឡើង សម្រាប់ជំរុញការប្រព្រឹត្តិបទឧក្រិដ្ឋ។ ការការពារខ្លួន ឬទ្រព្យសម្បត្តិ ដែលសំខាន់សម្រាប់រស់រានមានជីវិត។ ការប្រព្រឹត្តបទឧក្រិដ្ឋ ដោយសារមានការគំរាមគំហែង។[761] ការច្រឡំអំពីច្បាប់ ឬអង្គហេតុ ក៏ចាត់ចូលក្នុងមូលដ្ឋាននេះដែរ ប្រសិនបើការច្រឡំធ្វើឲ្យមានផលអវិជ្ជមាន ដល់ធាតុអត្តនោម័ត។[762] បញ្ជារបស់ថ្នាក់លើអាចនាំឲ្យរួចផុតពីការទទួលខុសត្រូវ ប្រសិនបើអ្នកប្រព្រឹត្តមានកាតព្វកិច្ចតាមផ្លូវច្បាប់ មិនដឹងថាបទបញ្ជាខុសច្បាប់ច្បាស់ក្រឡែត។ ទោះបីជាយ៉ាងនេះក្តី បទបញ្ជា ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងបទប្រឆាំងនឹងមនុស្សជាតិ គឺ ត្រូវបានចាត់ថាខុសច្បាប់។[763]

[761] The Rome Statute, *supra* note 634, Art. 31.
[762] *Id.*, Art. 32.
[763] *Id.*, Art. 33.

វាអាចមានករណី ដែលបុគ្គលអាចតវ៉ាប្រឆាំងនឹងបទបញ្ជា ហើយគាត់ត្រូវបាន គេគំរាមថា នឹងសម្លាប់ចោល ប្រសិនបើគាត់មិនធ្វើតាម ហើយដែលចុងបញ្ចប់គាត់នឹងធ្វើតាមបញ្ជា។ ករណីនេះ បុគ្គលអាចលើកយកមូលដ្ឋាននៃការបង្ខិតបង្ខំ រួមជាមួយបទបញ្ជា មកសំអាងដើម្បីរួចផុតពីការចោទប្រកាន់ ឬដើម្បីទទួលបានទោសទណ្ឌស្រាល។[764]

### ១០.១.១.២.៦. បញ្ហាប្រឈម

### ក. អភ័យឯកសិទ្ធិ

ច្បាប់ពាក់ព័ន្ធអភ័យឯកសិទ្ធិ កើតមានជាយូរយារមកហើយ ហើយក្លាយជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ការផ្តល់អភ័យឯកសិទ្ធិ គឺដើម្បីជានាឲ្យដំណើរទំនាក់ទំនងការបរទេសរវាងរដ្ឋ និងរដ្ឋមានលក្ខណៈរលូន។ ការផ្តល់អភ័យឯកសិទ្ធិ ជាកិច្ចផ្តល់ទៅវិញទៅមក (Reciprocity)។ ក្នុងសម័យមុនសង្គ្រាមលោកលើកទី ២ បុគ្គលដូចជា ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ទទួលបានអភ័យឯកសិទ្ធិ ហើយប្រមុខអ្នកការទូតទទួល បានអភ័យឯកសិទ្ធិទូតពីការស៊ើបអង្កេត ឬចោទប្រកាន់នៅពីមុខ តុលាការប្រទេសក្រៅ ចំពោះសកម្មភាពរបស់រដ្ឋ (Official Act/Act of State) និងសកម្មភាពជាឯកជនរបស់គាត់ (Personal Act) ទាំងមុនពេល ក្នុងអំឡុងពេល និងក្រោយពេលឈប់កាន់តំណែង។ អ្នកស្រាវជ្រាវបានឲ្យឈ្មោះថា ជាអភ័យឯកសិទ្ធិ

[764] The accused can raise other grounds for relieving responsibility. In the case of rasing that, if he or she did not follows order, his or her life would be threatened, the court will consider case by case and actually examines the facts to test moral choice. It will not be accepted as a duress if to save his own life, a person killed 10 peoples.

ដាច់ខាត (Absolute Immunity)។[765] ក្រោយមក ដោយសារប្រហែលមានការបំពានលើអភ័យឯកសិទ្ធិ ដើម្បីផលប្រយោជន៍បុគ្គល និងការអភិវឌ្ឍវិធានច្បាប់អន្តរជាតិ មានការបែងចែងរវាង Functional Immunity និង Personal Immunity។ អភ័យឯកសិទ្ធិប្រភេទទី១ សម្រាប់កិច្ចការងាររដ្ឋ ហើយដែលត្រូវបានការពារពីការស៊ើបអង្កេត ឬចោទប្រកាន់ ដោយតុលាការប្រទេសផ្សេង ទោះបីបុគ្គលដែលជាអ្នកធ្វើអំពើក្នុងនាមរដ្ឋ អស់ពីអំណាចរួចហើយក្តី។ ប្រភេទទី ២ ជាអភ័យឯកសិទ្ធិផ្តល់ជូនបុគ្គល។ គាត់នឹងលែងមានអភ័យឯកសិទ្ធិ នៅពេលគាត់ឈប់ពីតំណែង។ នេះមានន័យថា អំពើជាឯកជនដូចជា ការសម្លាប់មនុស្ស ក្នុងពេលគាត់មាន Personal Immunity អាចត្រូវបានតុលាការប្រទេសដទៃលើកយកមកស៊ើបអង្កេត ឬចោទប្រកាន់បាន ក្រោយពេលបុគ្គលនោះលាលែង ឬឈប់ពីតំណែង។ អ្នកស្រាវជ្រាវបានអះអាងថា អភ័យឯកសិទ្ធិលែងមានចរិតលក្ខណៈដាច់ខាតហើយ (Relative Immunity)។

មានសំណួរមួយត្រូវបានចោទឡើង ថាតើការប្រព្រឹត្តបទឧក្រិដ្ឋ ជាអំពើរបស់រដ្ឋឬ ជារបស់បុគ្គលឯកជន។ តុលាការជាន់ខ្ពស់របស់អង់គ្លេស (House of Lords) បានឆ្លើយថា អំពើឧក្រិដ្ឋ ធ្វើឡើងដោយអ្នកដឹកនាំ មិនមែនជា អំពើរបស់រដ្ឋឡើយ ដូចនេះ មិនទទួលបានការការពារក្រោមច្បាប់អភ័យឯកសិទ្ធិទេ។[766] ចុះប្រសិនបើ រដ្ឋមន្ត្រីនៅក្នុងតំណែង អាចត្រូវបានតុលាការប្រទេសណាមួយធ្វើការស៊ើបអង្កេត ឬចោទប្រកាន់បានឬទេ? នៅក្នុងករណី បណ្តឹង

[765] Rhona K.M. Smith, the Textbook on IHRs, *supra* note 427, p. 11; Rosanne Van Alebeek, the Immunity of States and Their Officials in International Criminal Law and International Human Rights Law, 2007, p. 21.

[766] Robert Cryer, *Pinochet*, *see* Antonio, the Oxford, *supra* note 55, pp. 874-875.

ដោយ Congo ប្រឆាំងនឹង Belgium ទាក់ទិននឹង ប្រទេស នេះចេញដីកាឲ្យ Interpol ចាប់ខ្លួនរដ្ឋមន្ត្រីការបរទេស ចោទប្រកាន់ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តុលាការយុត្តិធម៌អន្តរជាតិ បានអះអាងថា តុលាការក្នុងស្រុក មិនត្រូវបានអនុញ្ញាតដោយច្បាប់អន្តរជាតិ ដើម្បីធ្វើដូចនេះទេ ក្នុងករណី រដ្ឋមន្ត្រីកំពុងកាន់តំណែង។[767] តុលាការជាតិ មិនអាចចាប់ខ្លួនសូម្បីរដ្ឋមន្ត្រីធ្វើដំណើរ ទៅក្រៅប្រទេស ទោះបីក្នុងគោលដៅជាឯកជន (លំហែកាយ) ដោយសារគាត់មាន Personal Immunity។[768] តុលាការយុត្តិធម៌អន្តរជាតិ មិនបានបដិសេធទេ អំពីលទ្ធភាពនៃការស៊ើបអង្កេត ឬចោទប្រកាន់ ក្រោយពីបុគ្គលនោះអស់អំណាច។[769] តុលាការ ជាប្រយោលគាំទ្រការពង្រីកប្រភេទបុគ្គលក្រៅពី ( ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល អ្នកការទូត និង រដ្ឋមន្ត្រីការបរទេស) ដែលត្រូវបានផ្តល់អភ័យឯកសិទ្ធិយ៉ាងហោចណាស់ សម្រាប់បេសកកម្មក្រៅប្រទេស។ អភ័យឯកសិទ្ធិ ជាបញ្ហាប្រឈមក្នុងការអនុវត្តការស៊ើបអង្កេត ឬការចោទប្រកាន់។[770]

បញ្ហាអភ័យឯកសិទ្ធិ នឹងមិនមែនជាឧបសគ្គឡើយ នៅមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយសារមាត្រានៃលក្ខន្តិកៈ បានចែងច្បាស់អំពីការមិន

[767] Case Concerning the Arrest Warrant, *Congo v. Belgium*, *supra* note 718, para. 61.
[768] *Id.*, para. 55.
[769] *Id.*, para. 61.
[770] Military of some States abroad enjoy immunity from investigation or prosecution by foreign court, see also the Rome Statute, *supra* note 634, Art. 16; Lee M. Caplan, *State Immunity, Human rights, and jus cogens: a critique of the normative hierarchy theory*, 97 American Journal of International law, 2003, p. 759; Yasmin Q. Naqvi, Impediments to Exercising Jurisdiction over International Crimes, 2010, p. 222.

អនុញ្ញាតឲ្យជំទាស់ការស៊ើបអង្កេត ឬចោទប្រកាន់ ផ្អែកលើអភ័យឯកសិទ្ធិ។[771] បញ្ហានឹងកើតមាន ប្រសិនបើតុលាការស្នើរដ្ឋភាគី បញ្ជូនអ្នកដឹកនាំ ឬបុគ្គល ដែលមានអភ័យឯកសិទ្ធិ របស់រដ្ឋដែលមិនមែនជាភាគី ពីព្រោះរដ្ឋមិនអាចបញ្ជូនមនុស្ស ដោយផ្ទុយនឹងច្បាប់ ទំនៀមទម្លាប់អន្តរជាតិពាក់ព័ន្ធអភ័យឯកសិទ្ធិ។[772] តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញា មិនត្រូវបានបង្កើតឡើងតាម សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ តាមជំពូកទី ៧ នៃធម្មនុញ្ញ របស់អង្គការសហប្រជាជាតិដូច ICTY ឡើយ។ ការទាមទារដោយតុលាការ ឲ្យរដ្ឋជាភាគីបញ្ជូនជនបរទេស ក្នុងទឹកដីខ្លួន ក្នុងអង្គហេតុនៃរឿងក្ដី បញ្ជូនដោយក្រុមប្រឹក្សាសន្តិសុខក្ដី ក៏មិនអាចយកឈ្នះរបាំងអភ័យឯកសិទ្ធិដែរ។ ប្រហែលជាមូលដ្ឋាន នេះហើយ ដែលសហរដ្ឋអាមេរិក បានធ្វើសន្ធិសញ្ញាជាមួយរដ្ឋ ជាភាគី Rome Statute មិនឲ្យបញ្ជូនប្រជាពលរដ្ឋអាមេរិក ទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ។[773] មូលដ្ឋានសមស្របមួយទៀត គឺការធានាអះអាងកាត់សេចក្ដី ជននោះនៅក្នុងតុលាការអាមេរិក ដែលគេគួរទទួលយក ប្រសិនបើពិនិត្យទៅលើគោលការណ៍បំពេញបន្ថែម និង អាទិភាពរបស់តុលាការជាតិ (the Principle of Complementary and of National Court Primacy)។

---

[771] Rome Statute, *supra* note 634, Art. 27; Provisions of the Genocide Convention does not say about immunity since it talked about responsibility of State officials. Thus, immunity is not a bar to prosecution.

[772] The Rome Statute, *supra* note 634, Art. 98.

[773] The Agreement between the United States of America and the Kingdom of Cambodia concerning Non-Surrender of Persons to the International Criminal Court, *see* Compilation of Enforceable Laws of Cambodia, UNHCHR (2009), pp. 933-939.

## ខ. ការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅ សម្រាប់បទឧក្រិដ្ឋ ដែលកើតមានឡើង ក្នុងពេលអតីតកាល ជួនកាល ក្នុងទម្រង់ជាច្បាប់ នាំមិនឲ្យមានការស៊ើបអង្កេត និងកាត់ទោសដោយតុលាការ។ វាមានបំណងលើកទឹកចិត្ត ឬជំរុញឲ្យបុគ្គលដែលអាចជាជនឧក្រិដ្ឋ ជួយលាតត្រដាងបទឧក្រិដ្ឋ និងជាពិសេសឲ្យជួយបញ្ចប់សង្គ្រាមដ៏រ៉ាំរ៉ៃ។ ការលើកលែងទោស ជួនកាលត្រូវបានសរសេរបញ្ចូល ក្នុងកិច្ចព្រមព្រៀងបញ្ចប់ជម្លោះប្រដាប់អាវុធ ដែលមានចូលរួមផងដែរ ដោយអង្គការសហប្រជាជាតិ។[774]

លក្ខន្តិកៈទីក្រុងរ៉ូម មិនបាននិយាយអំពើ បញ្ហាការលើកលែងទោសទេ ក៏ប៉ុន្តែវានឹងមិនមានបញ្ហាទេ ពីព្រោះច្បាប់លើកលែងទោសរបស់ប្រទេសមួយ មិនចងជាកាតព្វកិច្ចដល់ប្រទេសមួយទៀតឡើយ។ ជាពិសេស វាពិតជាមិនអាចទទួលយក បានឡើយនូវការលើកលែងទោសចំពោះ បទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ។ មានតុលាការជាតិ និងអន្តរជាតិ បដិសេធមិនទទួលស្គាល់ការលើកលែងទោស។[775]

សន្ធិសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និយាយអំពី ការលើកលែងទោស តែមិនសម្រាប់អ្នកប្រព្រឹត្តបទ ឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិទេ គឺសម្រាប់

[774] Peace Agreement between the Government of Sierra Leone and the Revolutionary United Front of Sierra Leone (1999 Lome Peace Accord), Art. IX, see , www.sierra-leone.org/lomeacccord.html; Stigen, the relationship, *supra* note 268, p. 417; Yasmin Q. Naqvi, Impediments, *supra* note 770, p. 82.
[775] The ECCC Law, *supra* note 91, Art. 11; Micaela Frulli, *Amnesty*, see Antonio, the Oxford, *supra* note 55, p. 244.

ការដែលគ្រាន់តែចូលរួមក្នុងសង្គ្រាម ឬ ជនប្រព្រឹត្តបទល្មើសស្រាល។[776] ការលើកលែងទោស ដោយរដ្ឋជាភាគី ដល់ពលរដ្ឋខ្លួនដែលបានប្រព្រឹត្តបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ អាចត្រូវបានចាត់ជាការសម្រេចមិនចោទប្រកាន់ ហើយប្រសិនបើជាការសម្រេចដើម្បីបិទបាំង ការចោទប្រកាន់ វាមិនមែនជាឧបសគ្គក្នុងការទទួលស៊ើបអង្កេតដោយតុលាការព្រហ្មទណ្ឌអន្តរជាតិឡើយ ។ តាមមូលដ្ឋាននេះ សូម្បីការលើកលែងទោស ដល់ជនជាប់ចោទ ដែលជាប្រជាពលរដ្ឋ នៃរដ្ឋមិនមែនជាភាគី របស់លក្ខន្តិកៈទីក្រុងរ៉ូម ក៏មិនបង្កជាបញ្ហាដែរ។ នេះបើពិចារណាទៅលើ ជំហរដ៏ច្រើន បដិសេធ អភ័យឯកសិទ្ធិ និង ការលើកលែងទោស។

## គ. កិច្ចសហការក្នុងការចាប់ខ្លួន

ស្រដៀងគ្នាជាមួយនឹងបញ្ហាអភ័យឯកសិទ្ធិ កិច្ចសហការក្នុងការចាប់ខ្លួន ជាការប្រឈម ដ៏ចម្បងមួយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ នេះដូចត្រូវបានបង្ហាញក្នុងក្តី Albashir ប្រធានាធិបតី របស់ ស៊ូដង់ ។ សំណុំរឿងនេះត្រូវបានបញ្ជូនមកតុលាការ ដោយក្រុមប្រឹក្សាសន្តិសុខ របស់អង្គការសហប្រជាជាតិ។[777] តុលាការព្រហ្មទណ្ឌអន្តរជាតិ បានចេញដីកាឲ្យចាប់ខ្លួន តែមិនទាន់ត្រូវបានចាប់ខ្លួនឡើយ។[778] តុលាការនេះ ត្រូវបានបង្កើតដោយសន្ធិសញ្ញា។ ទោះបីជា រដ្ឋមានកាតព្វកិច្ចក្តី ក៏រដ្ឋខ្លះមិនបំពេញតាមកាតព្វកិច្ចនេះ ហើយអន្តរាគមន៍ របស់អង្គការសហប្រជាជាតិ នៅមានកម្រិតនៅឡើយ។

---

[776] Protocol II to the 1949 Geneva convention, *supra* note 645, Art. 6(5).

[777] Pre-Trail Chamber of the ICC issued Decision on the Non-Compilance of the Republic of Chad with the Cooperation Requests Issued by the Court Regarding the Arrest and Surrender of Omar Hassan Ahmad Al-Bashir, *see* www.icc-cpi.int.

[778] id.,

អង្គការសហប្រជាជាតិ ក៏មានកាតព្វកិច្ចគោរពច្បាប់អន្តរជាតិ បើមិនដូច្នេះទេ អង្គការនេះ អាចនឹងត្រូវបានចោទប្រកាន់ ថាបំពានច្បាប់អន្តរជាតិ។ សូដង់ និង ប្រទេសក្នុងទ្វីបអាហ្វ្រិក ដែល Albashir ធ្វើដំណើរស្នាក់នៅ ឬឆ្លង កាត់ក៏ជាភាគីរបស់ Rome Statute។[779] អាស្រ័យហេតុនេះ បញ្ហាគឺការ សហការក្នុងការចាប់ខ្លួន ពីព្រោះពេលមកដល់តុលាការ Albashir លែងមាន អភ័យឯកសិទ្ធិ ដោយសារស៊ូដង់ ជាភាគីរបស់ Rome Statute។ វាអាច ជាបញ្ហានៃពេលវេលា យូរ ឬឆាប់ ដែល Albashir នឹងត្រូវបានចាប់ខ្លួន ដោយសារសំណុំរឿងនេះស្នើដោយក្រុមប្រឹក្សាសន្តិសុខ។ដោយយសារ បញ្ហា សុខភាព ដូចករណី លោក Pinochet លោក Albashir នឹងបង្ខំខ្លួនទៅ ព្យាបាលរោគ នៅក្នុងប្រទេសណាមួយ ដែលជាភាគីរបស់ Rome Statute ហើយដែលផ្តល់កិច្ចសហការក្នុងការចាប់ខ្លួនគាត់។ ចុងបញ្ចប់ គាត់អាចធ្លាក់ ពីអំណាច ហើយដោយសារតែ អំពើរបស់គាត់ ជាអំពើឧក្រិដ្ឋកម្ម មិនមែន ជាកិច្ចការរបស់រដ្ឋ Functional Immunity នឹងមិនបានជួយគាត់ទេ។[780] គាត់អាចនឹងត្រូវបានចាប់ខ្លួនដោយរដ្ឋាភិបាលថ្មី។

### ១០.១.១.៣. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

កាលពីជាង ៣០ ឆ្នាំមុន នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ មានការ សម្លាប់រង្គាល និងធ្វើទុក្ខទោសលើប្រជាជន ដែលភាគច្រើនជាប្រជាជន កម្ពុជា ដោយរបបកុម្មុយនីស្ត ដឹកនាំដោយប៉ុលពត។ មានប្រជាជនចំនួន

[779] Document from the ICC. Due to the fact that Albashir is still in the power, and pursuant to *dictum* of the ICJ in the case of *Congo v. Belguim*, African States are reluctant to arrest him to send to the ICC.

[780] Robert Cryer, *Pinochet, see* Antonio, the Oxford, *supra* note 55, p. 875.

ជាង ១លាននាក់បានស្លាប់។[781] ក្នុងឆ្នាំ ១៩៩៨ នៅពេលដែលកងកម្លាំងប្រដាប់អាវុធ និងមេដឹកនាំរបបនេះ ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ហើយប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថាបានសន្តិភាពពេញលេញ រាជរដ្ឋាភិបាល បានស្នើឲ្យមានការបង្កើតនូវតុលាការដើម្បីកាត់ទោសមេដឹកនាំ របបខ្មែរក្រហម ចំពោះអំពើដែលពួកគេបាន ប្រព្រឹត្តក្នុងអំឡុងពេលគ្រប់គ្រងប្រទេសកម្ពុជា។[782] អង្គការសហប្រជាជាតិ បានឯកភាព ហើយការចរចាក្នុងកិច្ចការបង្កើតតុលាការបានចាប់ផ្តើម រហូតដល់ អង្គការសហប្រជាជាតិបានឯកភាពលើកិច្ចព្រមព្រៀង ស្តីពី ការបង្កើតតុលាការ នៅក្នុងឆ្នាំ ២០០៣។ [783] កម្ពុជា បានផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀងនេះ ក្នុងឆ្នាំ ២០០៤។[784] សភាជាតិកម្ពុជា បានអនុម័តច្បាប់ ស្តីពី ការបង្កើត តុលាការនៅក្នុងឆ្នាំ ២០០១ ដែលមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា (អវតក)។[785]

អវតក ត្រូវបានចាត់ថាជាតុលាការកូនកាត់។[786] នេះដោយសារមាន បុគ្គលិកព្រះរាជអាជ្ញា និងចៅក្រមកម្ពុជា និងបរទេស ចូលរួមក្នុងដំណើរការនៃអង្គជំនុំជម្រះ។ អង្គជំនុំជម្រះនេះ ស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ប្រព័ន្ធតុលា

[781] Ben Kiernan, the Pol Pot Regime: Race, Power and Genocide in Cambodia under the Khmer Rouge (1975-1979), 1996, p. 456; Jamie Frederie Metzl, Western Responses to Human Rights Abuses in Cambodia, 1975-80, p. xiii.

[782] Establishment of the Extraordinary Chambers in the Courts of Cambodia (ECCC-Chronology), *see* www.eccc.gov.kh/en/about-eccc/chronologies.

[783] General Assembly Resolutions 57/228A, 57/228B and A/57/806; ECCC-Chronology, *see supra* note 782.

[784] ECCC-Chronology, *see supra* note 782.

[785] *Id.*

[786] FAQ- Office of Co-Investigating Judges, www.eccc.gov.kh/en/ocij/faq-office-of-co-investigating-judges

ការកម្ពុជា ហើយចំនួនចៅក្រមកម្ពុជា ជាចំនួនភាគច្រើននៅក្នុងអង្គវិនិច្ឆ័យនីមួយៗ។[787] អង្គជំនុំជម្រះនេះ ត្រូវបានបង្កើតឡើង ដើម្បីដាក់ឲ្យបុគ្គលទទួលខុសត្រូវ មិនមែនសម្រាប់ដាក់ការទទួលខុសត្រូវចំពោះរដ្ឋណាមួយដែលបានចូលរួមប្រព្រឹត្តជាមួយរបបប៉ុលពតនោះឡើយ។[788] អង្គជំនុំជម្រះត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ជាទីកន្លែងដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត។[789]

### ១០.១.១.៣.១. គោលបំណងនៃការបង្កើត

គោលបំណងនៃ អវតក គឺដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងរកការពិតពាក់ព័ន្ធជាមួយអ្វី ដែលបានកើតឡើង ក្នុងរបបប៉ុលពត។ និយាយឲ្យសាមញ្ញ តើមានអ្វីពិតប្រាកដបានកើតឡើង ហើយអ្នកណាជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋ។ មូលហេតុផ្សេងៗទៀត គឺមិនចង់ឲ្យមាននិទ្ទណ្ឌភាព ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ។

មានតុលាការជាតិ និងអន្តរជាតិជាច្រើន ត្រូវបានបង្កើត ដើម្បីកាត់ទោសបុគ្គល ដែលប្រព្រឹត្តបទឧក្រិដ្ឋ ក្រោមច្បាប់អន្តរជាតិ ដូចជាបទអំពើប្រល័យពូជសាសន៍ជាដើម។[790] បទឧក្រិដ្ឋនេះ គឺការបំពារបំពានដល់វិធានច្បាប់អន្តរជាតិ ដែលមានឋានៈខ្ពស់ជាងគេ ដែលបង្កើតឲ្យមានកាតព្វកិច្ច *Erga Omnes* ( *Erga Omnes* Obligation)។ ផ្អែកតាមប្រភេទកាតព្វកិច្ចនេះ រដ្ឋណាមួយ ឬអង្គការសហប្រជាជាតិ ទោះបីជា មិនបានទទួលរងនូវផល

---

[787] For In Trial Chamber, there are three Cambodian judges and three international judges, *see supra* note 91, Art. 9 New.
[788] *Id.*, Art. 1.
[789] The Genocide Convention, *supra* note 74, Art. VI.
[790] Please see above section.

ប៉ះពាល់ដោយអំពើឧក្រិដ្ឋទាំងនោះក្តី ដូចជាប្រជាពលរដ្ឋកម្ពុជា ឬប្រទេសកម្ពុជា ក៏មានសិទ្ធិអន្តរាគម តាមរយៈការចូលរួមបង្កើត និងឧបត្ថម្ភដល់តុលាការកាត់ទោសបុគ្គល ដែលបានប្រព្រឹត្តបទប្រល័យពូជសាសន៍។ ចំពោះបទឧក្រិដ្ឋ ដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើកម្ពុជា ឬអង្គការសហប្រជាជាតិ មិនបានបង្កើតអង្គជំនុំជម្រះនេះទេ រដ្ឋផ្សេងទៀត ផ្អែកតាមសន្ធិសញ្ញា ឬ ការអនុវត្តកាតព្វកិច្ច *Erga Omnes* អាចបង្កើតតុលាការកាត់ ទោសមេដឹកនាំខ្មែរក្រហម ហើយប្រទេសដែលមានមេដឹកនាំរបបប៉ុលពតរស់នៅ មានកាតព្វកិច្ចបញ្ជូនខ្លួនជនត្រូវចោទ ទៅឲ្យតុលាការនោះ ដើម្បីទទួលការកាត់ទោស។[791]

## ១០.១.១.៣.២. រចនាសម្ព័ន្ធ និងដំណើរការការងារ

អង្គជំនុំជម្រះសម្រាប់កាត់ទោសបុគ្គល ជាមេដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានអង្គភាពជាច្រើនក្នុងរចនាសម្ព័ន្ធរបស់ខ្លួន ដូចជាផ្នែករដ្ឋបាល ផ្នែកគាំពារជនរងគ្រោះ ផ្នែកគាំពារការពារក្តី ផ្នែកតុលាការ ដែលមានការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល។ គ្រប់ការិយាល័យទាំងអស់ មានបុគ្គលិកជាតិ និងអន្តរជាតិ ចូលរួមធ្វើការងារជាមួយគ្នា។[792]

---

[791] Genocide Convention, *supra* note 74, Art. 6.

[792] The ECCC Law, *supra* note 91, Chapter III.

អង្គភាពរដ្ឋបាលមានភារកិច្ចពាក់ព័ន្ធជាមួយនឹងបុគ្គលិក និង ហិរញ្ញវត្ថុ ក្នុងនោះ រាប់បញ្ចូលផងដែរ ផ្នែកកិច្ចការសាធារណៈ ដែលធ្វើការងារទំនាក់ទំនងជាមួយសាធារណជន ផ្សព្វផ្សាយព័ត៌មានស្តីពីដំណើរការតុលាការដល់សាធារណជន។[793] ផ្នែកគាំពារជនរងគ្រោះ មានតួនាទី ការពារ និងគាំទ្រជនរងគ្រោះ សម្របសម្រួលការងាររវាងជនរងគ្រោះ សាក្សី និងអង្គជំនុំជម្រះ។[794]

ដំណើរក្តីនៃ *អវតក* ចាប់ផ្តើមពីការដាក់ពាក្យបណ្តឹង របស់ជនរងគ្រោះ ឬកិច្ចផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញា ដែលនាំឲ្យមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ បញ្ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត។[795] ការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្វើការងារស៊ើបអង្កេត ប្រមូលឯកសារ ដែលអាចនឹងក្លាយជាភស្តុតាង ឬសំភាសន៍សាក្សីជាដើម។[796] ក្រោយពីស៊ើបអង្កេតរួចរាល់ សហចៅក្រមស៊ើបអង្កេតនឹង ជូនដំណឹងដល់ភាគី ដែលពាក់ព័ន្ធ ដូចជា ជនត្រូវចោទ អំពីការបញ្ចប់ការស៊ើបអង្កេត។ ចាប់ពីជូនដំណឹងក្នុងរយៈពេល ១៥ថ្ងៃ សហព្រះរាជអាជ្ញា ជនត្រូវចោទ អាចស្នើឲ្យការិយាល័យស៊ើបអង្កេតធ្វើការងារស៊ើបអង្កេត លើអង្គហេតុណាមួយបន្ថែមទៀត ដែលខ្លួនយល់ថាមិនទាន់បានគ្រប់ជ្រុងជ្រោយ ។[797] ភាគីស្នើសុំ អាចប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចមិន ធ្វើការស៊ើបអង្កេតរបស់សហចៅ

[793] The ECCC Law, *supra* note 91, Chapter IX.

[794] Victim Support, www.eccc.gov.kh/en/victims-support

[795] ECCC, Internal Rules (Rev.8), 3 August 2011, Rule 53, at www.eccc.gov.kh/en/document/legal/internal-rules-rev8.

[796] ECCC, Internal Rules, Rule 55 (5.a).

[797] *Id.*, Rule 66 (1).

ក្រមស៊ើបអង្កេត ទៅអង្គបុរេជំនុំជម្រះ។[798] ក្រោយពី អង្គបុរេជំនុំជម្រះ បានដោះស្រាយបណ្តឹងពាក់ព័ន្ធការបញ្ចប់ការស៊ើប អង្កេតរួចរាល់ ចៅក្រម ស៊ើបអង្កេតនឹងបញ្ជូនសំណុំរឿង[799]ទៅសហព្រះរាជអាជ្ញា ដើម្បីការិយាល័យ នេះ ចេញនូវដីកាសន្និដ្ឋានស្ថាពរ។[800] ក្រោយពីមានដីកានេះ សហចៅក្រម ស៊ើបអង្កេត នឹងចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់) ទៅអង្គជំនុំជម្រះ។[801] ភាគីដែលពាក់ព័ន្ធ អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ទៅអង្គបុរេជំនុំជម្រះ។[802] ក្រោយ ពីសម្រេចលើបណ្តឹងឧទ្ធរណ៍រួច សំណុំរឿងនឹងត្រូវបញ្ជូនទៅ កាន់ អង្គជំនុំជម្រះ។[803] ភាគីរួមមាន ជនត្រូវចោទ សហព្រះរាជអាជ្ញា អាចប្តឹង ឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះ ទៅអង្គជំនុំជម្រះតុលាការ កំពូល។សាលក្រមរបស់អង្គជំនុំជម្រះតុលាការកំពូល ចូលជាស្ថាពរ និងបិទ ផ្លូវតវ៉ា ។[804] នេះដូចគ្នា នឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលមាន ប្រភេទជាអាជ្ញាអស់ជំនុំ។[805]

សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេតជាតិ ឬអន្តរជាតិ អាចមាន គំនិតខ្វែងគ្នា ពាក់ព័ន្ធជាមួយការសម្រេចចោទប្រកាន់ជនសង្ស័យបន្ថែម ទៀត ។ សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា អាចប្តឹងទៅ អង្គបុរេ

[798] *Id.,* Rule 66 (2 and 3).
[799] *Id*., Rule 66 (4).
[800] *Id*., Rule 66 (5).
[801] *Id.,* Rule 67(1).
[802] *Id*., Rules 67 (5) and 74.
[803] *Id.,* Rule 69 (2.a).
[804] *Id.,* Rule 104 (3).
[805] *Id*., Rule 77 *bis* (2).

ជំនុំជម្រះ។[806] អង្គបុរេជំនុំជម្រះ នេះនឹងសម្រេចលើសំឡេងភាគច្រើន ៤ ក្នុងចំណោមប្រាំរូប (ចៅក្រមជាតិ ៣រូប និង ចៅក្រមអន្តរជាតិ២រូប)។[807] ក្នុងករណីរក ៤សម្លេងមិនបាន កិច្ចដែលស្នើឡើងនឹងត្រូវបន្ត។[808] ជាក់ស្តែង សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើចោទប្រកាន់បុគ្គលបន្ថែមទៀត ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាជាតិមិនយល់ស្រប នាំឲ្យព្រះរាជអាជ្ញាអន្តរជាតិប្តឹងទៅអង្គបុរេជំនុំជម្រះ។[809] អង្គបុរេនេះ មិនមានសំឡេង ៤ ឯកភាព។ ដូចនេះ កិច្ចស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ នឹងត្រូវបន្ត។ អង្គបុរេជំនុំជម្រះ បានបញ្ជូនឯកសារ (ដីកាបញ្ជូនរឿងឲ្យស៊ើបសួរ) ទៅឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីចាត់ការតាមនីតិវិធី។[810]

### ១០.១.១.៣.៣. សមត្ថកិច្ច

តាមខ្លឹមសារនៃមាត្រា ២ នៃច្បាប់បង្កើតអង្គជំនុំជម្រះ មន្ត្រីខ្មែរក្រហម ពីរប្រភេទតែប៉ុណ្ណោះ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់សាលាក្តីនេះ នោះគឺ មេដឹកនាំជាន់ខ្ពស់ (Senoir Leaders) និង អ្នកទទួលខុសត្រូវខ្ពស់បំផុត (Most Responsible Person)។[811] វាអាចនឹងមានគំនិតខ្វែងយោបល់ពាក់ព័ន្ធថាតើពាក្យទាំងនេះ បង្ហាញពីយុត្តាធិការបុគ្គល ឬគ្រាន់ជាពាក្យសម្រាប់ចង្អុលបង្ហាញផ្លូវសម្រាប់សហព្រះរាជអាជ្ញាក្នុងការ ជ្រើសរើសបុគ្គល

[806] The ECCC Law, *supra* note 91, Arts. 20 New and 23 New.
[807] *Id.*, Art. 20 new.
[808] *Id.*, Art. 23 new.
[809] Annex II: Excerpt of the Considerations of the Pre-Trial Chambers regarding the Disagreement between the Co-Prosecutors pursuant to Internal Rule 71, 18 August 2009.
[810] The ECCC, *supra* note 91, Art. 23 new.
[811] *Id.,* Art. 2 new.

ដើម្បីចោទប្រកាន់។ ជំហរណាមួយ នឹងនាំឲ្យមានផលវិបាកទៅតាមជំហរនោះ។ ប្រសិនបើ គេចាត់ថាពាក្យទាំងនោះបង្ហាញពី យុត្តាធិការបុគ្គល សហព្រះរាជអាជ្ញា ដែលជាស្ថាប័នធ្វើការចោទប្រកាន់នឹងមិនមានឆន្ទានុសិទ្ធិទូលាយ ក្នុងការសម្រេចបុគ្គលណាមួយគួរត្រូវបានចោទប្រកាន់។[812] សហព្រះរាជអាជ្ញា ត្រូវមានការប្រយ័ត្នប្រយែងនៅក្នុងកិច្ចនេះ ទាមទារឲ្យមានការប្រើកម្រិតខ្ពស់នៃភស្តុតាងក្នុងការជ្រើសរើសបុគ្គល ហើយតម្រូវឲ្យមានការស៊ើបអង្កេតថា ជនណាមួយជាអ្នកដឹកនាំជាន់ខ្ពស់ មុននឹងស៊ើបអង្កេតលើអង្គហេតុស៊ីជម្រៅ និងសរសេរដីកាបញ្ជូនរឿងឲ្យស៊ើបសួរ។ ប្រសិនបើសហព្រះរាជអាជ្ញា រកឃើញជនណាមួយស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ សហព្រះរាជអាជ្ញាត្រូវបញ្ជូនរឿងទៅសហចៅក្រមស៊ើបអង្កេត។ ការតម្រូវឲ្យមានការស៊ើបអង្កេត ដោយសហព្រះរាជអាជ្ញា ថាតើបុគ្គលចូលក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះ គឺដើម្បីបង្ការបាន នូវការដោះលែងជនត្រូវចោទ ក្នុងដំណាក់កាលជំនុំជម្រះ ដោយអង្គជំនុំជម្រះសាលាដំបូង ឆ្លើយតបទៅនឹងបណ្ដឹងដោយមេធាវី ដែលថាកូនក្ដីរបស់ខ្លួនមិនមែនជា បុគ្គលស្ថិតនៅក្នុងយុត្តាធិការរបស់សាលាក្ដី។

វាច្បាស់ណាស់ថាជនទាំងនោះ មិនចាំបាច់ជាជនជាតិខ្មែរឡើយ។ ជនបរទេស ក៏អាចស្ថិតនៅក្នុងយុត្តាធិការរបស់ *អវតក* ដែរ ឲ្យតែជននោះជា

[812] The Supreme Court Chamber asserted that the personal jurisdiction of the ECCC covers Khmer Rouge officials and the question of whether an accused was a Khmer Rouge official is justificable; terms “senior leaders” are not jurisdictional requirements, operating as prosecutorial policy to guide the independent discretion of the Con-Investigating Judges and Co-Prosecutors, *see* Supreme Court Chamber, Case File/Dossier No. 001/18-07-2007-ECCC/SC, 3 February 2012, para. 79.

មន្ត្រីខ្មែរក្រហម និងជាអ្នកដឹកនាំជាន់ខ្ពស់ ឬជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ។ ដើម្បីកំណត់ថា អ្នកណាមួយចូលក្នុងជំពូកមនុស្ស ក្នុងយុត្តាធិការ គេត្រូវពិនិត្យមើល កម្រិតនៃការទទួលខុសត្រូវរបស់បុគ្គល និង កម្រិតធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដែលពាក់ព័ន្ធ។[813]

សម្រាប់អ្នកដឹកនាំជាន់ខ្ពស់ ជាតុផ្សំចម្បង គឺឋានៈរបស់គាត់ និងការចូលរួមក្នុង ការរៀបចំគោលនយោបាយ ឬការតាមដានអនុវត្តគោលនយោបាយ ទោះបីជា ការចូលរួមធ្វើគោលនយោបាយ មិនមែនជាកត្តាចម្បងចាំបាច់។[814] សម្រាប់កំណត់នូវអ្នកទទួលខុសត្រូវខ្ពស់បំផុត ការចូលរួមក្នុងការអនុវត្ត គោលនយោបាយ និង អំណាច ឥទ្ធិពល ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ គឺជាកត្តាចម្បង។ លក្ខខណ្ឌទាំងនេះ សម្រាប់ញែកបុគ្គលដែលគ្រាន់តែជាទាហានធម្មតា ធ្វើតាមបញ្ជារបស់មេដឹកនាំ ទោះបីជាពួកគេបានសម្លាប់មនុស្សរាប់ពាន់នាក់ ដែលមិនចូលក្នុងប្រភេទមនុស្ស (អ្នកដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុត)។ ជននេះនឹងមិនសម្លាប់មនុស្សទេ ប្រសិនបើគ្មានបញ្ជា។ ដូចគ្នានេះដែរ មន្ត្រីមួយរូបជាមន្ត្រីជាន់ខ្ពស់ពិតមែន ប៉ុន្តែតែអាចមានតែឋានៈ និងមិនមានអំណាចអ្វីទាំងអស់ ក៏មិនស្ថិតចូលក្នុងសមត្ថកិច្ចរបស់តុលាការដែរ។ ជននេះ មិនមែនជាអ្នកដឹកនាំជាន់ខ្ពស់ ក្នុងន័យនៃមាត្រា ២ ឡើយ។

---

[813] 01 Case Judgment, *supra* note 757, para. 22; *Prosecutor v. Jankovic*, Decision on Referral of Case pursuat to Rule 11bis, ICTY Referral Bench (IT-96-23/2-PT), 22 July 2005, para. 19.

[814] Sean Morrison, *Extraordinary Chambers in the Courts of Cambodia: Interpreting the Limiting Language and Personal Jurisdiction of the Cambodian Tribunal*, 37 the Capital University Law Review 2009, p. 620

វាច្បាស់ណាស់ថា មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ខុសគ្នា។ វាគ្រប់គ្រាន់ណាស់ហើយប្រសិនបើ ព្រះរាជអាជ្ញារកឃើញ ជនណាមួយជាអ្នកដឹកនាំជាន់ខ្ពស់ ហើយមិនចាំបាច់បង្ហាញបន្ថែមថា ជននោះជាអ្នកទទួលខុសត្រូវខ្ពស់បំផុតទេ។ គេអាចនិយាយម្យ៉ាងទៀតថា អ្នកដឹកនាំជាន់ខ្ពស់ គឺអាចជាអ្នកទទួលខុសត្រូវខ្ពស់បំផុត។[815]

*អវតក* មានយុត្តាធិការទៅលើបទឧក្រិដ្ឋ៖ បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាម និង បទឧក្រិដ្ឋ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ប្រព្រឹត្តនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩។ វាមានភាពមិនច្បាស់លាស់ថា តើ *អវតក* មានសមត្ថកិច្ចលើបទឧក្រិដ្ឋកើតមុនរបបនេះ ប៉ុន្តែមានផលវិបាកមកដល់ក្រោយឆ្នាំ១៩៧៩ ដែរឬទេ?។

បទឧក្រិដ្ឋកម្មអន្តរជាតិខាងលើ មានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ហើយកិច្ចព្រមព្រៀងបង្កើតអង្គជំនុំជម្រះ បានយោងដល់លក្ខន្តិកៈនេះផងដែរ។[816] តាមការពិនិត្យប្រៀបធៀបមើល ទោះបីជាចំណងនៃបទល្មើសដូចគ្នា ក៏ប៉ុន្តែខ្លឹមសារខាងក្នុងនៃបទល្មើសតូចៗនីមួយៗមានភាពខុសគ្នាខ្លះរវាង បទប្បញ្ញត្តិ នៃច្បាប់បង្កើត អវតក និង លក្ខន្តិកៈទីក្រុងរ៉ូម ដែលចែងអំពីបទល្មើស។ ឧទាហរណ៍ មាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ចាត់ការប្រកាន់ពូជសាសន៍ (Apartheid) ជាបទឧក្រិដ្ឋក្រោមបទឧក្រិដ្ឋប្រឆាំង

---

[815] *Id.,* p. 627.

[816] Agreement between the United Nations and the Royal Government of Cambodia Concerning the Prosecution under Cambodian Law of Crimes Committed during the Period of Democratic Kampuchea, Article 9, *see* www.eccc.gov.kh.

នឹងមនុស្សជាតិ។[817] ជាតុផ្សំមួយនៃ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ បាន ទាមទារនូវជាតុរើសអើង និងការវាយប្រហារជាទូទៅ ដែលជាជាតុផ្សំរួមនៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។[818] នេះនាំឲ្យមានការបកស្រាយផ្សេងៗគ្នា។ អវតក បានបកស្រាយថា ជាតុផ្សំ នេះ នឹងពុំតម្រូវឲ្យប្រើសម្រាប់បទល្មើសតូចៗ ដូចជាបទល្មើសទារុណកម្ម ស្ថិតនៅក្នុងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ។[819]

មាត្រា២ នៃច្បាប់ស្តីពី *អវតក* មិនបានបញ្ជាក់ច្បាស់ ថាតើ បទល្មើសស្ថិតនៅក្នុងដែនយុត្តាធិការរបស់ខ្លួន កើតមានតែនៅក្នុងដែនដីកម្ពុជាឬយ៉ាងណាទេ។ ផ្អែកតាមកំណត់ត្រានៃការពិភាក្សានាពេលបង្កើតច្បាប់ អវតក បទឧក្រិដ្ឋ ដែលស្ថិតចូលក្នុងយុត្តាធិការ ត្រូវកើតមាននៅក្នុងដែនដីកម្ពុជា។[820] អាស្រ័យហេតុនេះ បទល្មើសកើតនៅក្នុងដែនដីវៀតណាមប្រព្រឹត្តដោយកម្មាភិបាលខ្មែរក្រហម នៅពេលពួកនេះទន្ទ្រានវាយលុកចូលដែនដីវៀតណាម មិនស្ថិតនៅក្នុងដែនយុត្តាធិការរបស់ អវតក ទេ។[821]

### ១០.១.១.៣.៤. ការទទួលខុសត្រូវ និងទម្រង់នៃការទទួលខុសត្រូវ

បទឧក្រិដ្ឋមួយដែលកើតមានឡើង តែងតែមានបុគ្គលណាមួយចូលរួមប្រព្រឹត្ត។ ដើម្បីដាក់បុគ្គលណាមួយឲ្យមានការទទួលខុសត្រូវ ចាំបាច់ត្រូវមាន

[817] The Rome Statute, *supra* note 634, Article 7 (1.j); the ECCC Law, *supra* note 91, Article 5.
[818] The ECCC Law, *supra* note 91, Article 5.
[819] Closing Order, Case File No.: 002/19-9-2007-ECCC-OCIJ, 15 September 2010, D427, para. 1365.
[820] Sean Morrison, *supra* note 813, p. 592.
[821] *Id.*, p. 592

ការបង្ហាញឲ្យឃើញនូវការចូលរួម ដោយប្រយោល ឬមិនប្រយោលក្តី។ ការដាក់ទោសទណ្ឌ គឺផ្អែកទៅតាមកម្រិតនៃការចូលរួម។ នេះជាការទទួលខុសត្រូវផ្អែកព្រហ្មទណ្ឌរបស់បុគ្គល។

ច្បាប់បង្កើត *អវតក* បានចែងនូវទម្រង់ផ្សេងៗ នៃការទទួលខុសត្រូវ ដូចជាការប្រព្រឹត្ត ការធ្វើផែនការ ជាដើម។[822] តាមបទប្បញ្ញត្តិដែលពាក់ព័ន្ធ ការចូលរួម អាចជាការចូលរួមដោយប្រយោល ឬដោយផ្ទាល់។ សម្រាប់បទប្រល័យពូជសាសន៍ ទម្រង់នៃការទទួលខុសត្រូវ មានការសមគំនិតប្រព្រឹត្តប្រល័យ ពូជសាសន៍។ បុគ្គលក៏នឹងមានទោសផងដែរ ចំពោះការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ។[823] អ្នកប្រព្រឹត្តផ្ទាល់ គឺជាចារី រីឯបុគ្គលចូលរួមប្រព្រឹត្តគឺជាសហចារី។ បុគ្គល តាមរយៈសម្ដី នាំឲ្យមានការប្រព្រឹត្តបទល្មើស។ នេះជាអំពើញុះញង់។[824] ក្នុងករណីខ្លះ វត្តមានរបស់បុគ្គលម្នាក់នៅទីកន្លែងប្រព្រឹត្ត ពិនិត្យមើលការប្រព្រឹត្តបទល្មើស ក៏អាចចាត់ជាការជួយផងដែរ។[825] អ្នកញុះញង់ និងអ្នកជួយ មិនមានទោសដូចគ្នាទេ តាមប្រព័ន្ធ Common Law។ ទម្រង់ខាងក្រោយ អាចនាំឲ្យទទួលទោសស្រាល ។[826] នេះខុសពីប្រព័ន្ធ Civil Law ដែលអ្នកជួយ និងអ្នកញុះញង់ ដែលគេចាត់ថាអ្នកសមគំនិតមានទោសដូចគ្នា។[827]

822 The ECCC Law, *supra* note 91, Art. 29.

823 *Id.,* Art. 4.

824 Human Rights Watch, Genocide, War Crimes, and Crimes againt Humanity: Topical Disgests of the Case Law of the International Criminal Tribunal for Rwanda and the International Criminal Tribunal for the Former Yugoslavia, 2004, p. 62 (HRW digests).

825 *The Prosecutor v. Kayishema and Ruzindana*, *supra* note 640, Judgement of 21 May 1999, paras. 200-201; HRW digest, p. 65.

826 Jens Ohlin, *Aiding and Abetting*, see Antonio, the Oxford, *supra* note 55, p. 240.

### ១០.១.១.៣.៥. ច្បាប់ដែលត្រូវអនុវត្ត

បទប្បញ្ញត្តិដែលពាក់ព័ន្ធ បានចែងថា ច្បាប់របស់កម្ពុជា នឹងត្រូវយកមកប្រើជាចម្បង។ ក្នុងករណីមានចន្លោះខ្វះខាតក្នុងច្បាប់កម្ពុជា អង្គជំនុំជម្រះនឹងយកវិធានច្បាប់អន្តរជាតិ ដូចជាសន្ធិសញ្ញា ស្តីពី សិទ្ធិបុគ្គល និងនយោបាយ មកអនុវត្ត។[828] កម្ពុជា បានចូលជាភាគីអនុសញ្ញា ស្តីពី ហាមឃាត់អំពើប្រល័យពូជសាសន៍ តាំងពីមុនឆ្នាំ ១៩៧៥។[829] អាស្រ័យហេតុនេះការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ មិនចោទជាបញ្ហាច្បាប់ឡើយនៅមុខ អវតក។ បញ្ហាកើតមានចំពោះការចោទប្រកាន់ លើបទឧក្រិដ្ឋកម្មសង្គ្រាម និងបទប្រឆាំងនឹងមនុស្សជាតិ ពីព្រោះឯកសារអន្តរជាតិ ចែងពីបទឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានអនុម័តក្រោយឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះ អាចចោទប្រកាន់បទល្មើសទាំងនេះបាន លុះត្រាបទល្មើស ត្រូវបានចែងក្រោមវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ ១៩៧៥។ សំណួរបានចោទឡើងថា តើបទល្មើសមានឋានៈទំនៀមទម្លាប់អន្តរជាតិមែនឬ? ហើយតើកម្ពុជាទទួលយកអនុវត្តវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយផ្ទាល់ដែរឬទេ? ក្រៅពីនេះ នៅមានសំណួរជាច្រើនទៀត ដូចជាពាក់ព័ន្ធនឹង អំពីនីត្យានុកូលភាពនៃការបង្កើតអង្គជំនុំជម្រះនេះ។ តើច្បាប់ជាតិឬអន្តរជាតិ ដែលខ្ពស់ជាង ក្នុង ករណីច្បាប់ទាំងពីរនេះមានទំនាស់នឹងគ្នា? តើច្បាប់បង្កើតសាលាក្តី ជាច្បាប់ពិសេស (*Lex Specialis*) ដែលត្រូវប្រើក្នុងពេលមាន

---

827 The Criminal Code of Cambodia, 2007, Article 29.

828 The ECCC Law, *supra* note 91, Art. 33 new; UN-RGC Agreement, *supra* note 816, Art. 12(1).

829 Cambodia acceded to the 1948 Convention on the Prevention and Punishment of Crime of Genocide on 14 October 1950, see en.wikipedia.org/wiki/List_of parties_to_the_Genocide_Convention.

សំណួរថា តើអង្គជំនុំជម្រះត្រូវប្រើ ក្រមនីតិវិធីព្រហ្មទណ្ឌ ឬវិធានផ្ទៃក្នុងរបស់ខ្លួន? តើវិធានផ្ទៃក្នុងមានតម្លៃខ្ពស់ជាង ក្រមនីតិវិធីព្រហ្មទណ្ឌដែរឬទេ? សំណួរទាំងនេះ តម្រូវឲ្យមានការសិក្សាស៊ីជម្រៅ។

### ១០.១.១.៣.៦. បញ្ហាគួរឲ្យចាប់អារម្មណ៍

### ក. ការលើកលែងទោស

អៀង សារី បានចូលមករួបរួមជាមួយរដ្ឋាភិបាលកម្ពុជា ក្នុងឆ្នាំ ១៩៩៦ ក្រោយពីបានលើកលែងទោសដោយព្រះមហាក្សត្រ ឲ្យរួចផុតពីការផ្តន្ទាទោស សម្រេចដោយតុលាការប្រជាជនបដិវត្តន៍កម្ពុជា បង្កើតឡើងតាមក្រឹត្យច្បាប់លេខ ០១ ខែកក្កដា ឆ្នាំ ១៩៧៩ ដើម្បីកាត់ទោស ប៉ុល ពត អៀងសារី កំបាំងមុខ ក្នុងឆ្នាំ ១៩៧៩ ពីបទប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋមួយចំនួនទៀត។[830]

មេធាវីរបស់លោក អៀង សារី បានយោងដល់ ការលើកលែងទោសនេះ និងផ្អែកលើ គោលការណ៍អន្តរជាតិ ស្តីពីការហាមឃាត់ការកាត់សេចក្តីពីរដងតទល់នឹងការចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ឃុំខ្លួន លោក អៀង សារី ដោយសហចៅក្រមស៊ើបអង្កេត។[831] មេធាវី បានប្តឹងប្រឆាំងនឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេត ទៅអង្គបុរេជំនុំជម្រះ ដោយអះ

[830] Judgement of the Revolutionary People's Revolutionary Court, U.N. A/34/491, 19 August 1979, p. 4; Howard J. De Nike, Genocide in Cambodia, Documents from the Trial of Pol Pot and Ieng Sary, 2000; Scott Worden, *An Anatomy of the Extraordinary Chambers*, in Jaya Ramji, Bringing the Khmer Rouge to Justice, 2005, p. 181.

[831] Ieng Sary's Submissions pursuant to the Decision on Expedited Request of Co-Lawyers for a Reasonable Extension of Time to File Challenges to Jurisdictional Issue, C22/I/26, 7 April 2008, p. 15.

អាងថា អង្គជំនុំជម្រះ មិនត្រូវកាត់ទោសលោក អៀង សារី ដែលជាអតីតឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៧៥ ដល់១៩៧៩ ជាថ្មីម្តងទៀតឡើយ។[832]

អង្គបុរេជំនុំជម្រះ បានចេញសេចក្តីសម្រេចអំពីបញ្ហានេះ ដោយសន្និដ្ឋានថា ការលើកលែងទោសមិនខ្វាស់ដំណើរការចោទប្រកាន់បានឡើយ។[833] វាមានការពាក់ព័ន្ធជាមួយបទប្រល័យពូជសាសន៍ ដោយសារមានការចោទពីបទប្រល័យពូជសាសន៍ ហើយបញ្ហា ដែលជាប់ពាក់ព័ន្ធ គឺការកាត់សេចក្តីពីរដងលើបទល្មើស និងអង្គហេតុតែមួយ។ តាមយុត្តិសាស្ត្រអន្តរជាតិ ការកាត់ទោសពីមុនមិនអាចរាំងស្ទះការកាត់សេចក្តី លើកទីពីរឡើយ ដោយសារការកាត់សេចក្តីលើកមុនមិនបានគោរពតាមស្តង់ដារអន្តរជាតិ។[834]ការលើកលែងទោស មិនមានសុពលភាពទេ ចំពោះបទឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ទោះបីជាមិនខុសច្បាប់របស់ជាតិក្តី។[835]

### ខ. អាជ្ញាយុកាលនៃការចោទប្រកាន់

បទឧក្រិដ្ឋដែល អង្គជំនុំជម្រះ លើកយកមកវិនិច្ឆ័យ កើតមានតាំងពី ជាង ៣០ ឆ្នាំមុន។ ច្បាប់ដែលអនុវត្តជាចម្បង សម្រាប់បទឧក្រិដ្ឋក្រោមច្បាប់ជាតិ

---

832 Trial Chamber, Decision on Ieng Sary's Rule 89 Preliminary Objections (*Ne Bis in idem* and Amnesty and Pardon), 3 November 2011, E51/15, p. 28; Pr-Trial Chamber, Decision on Ieng Sary's Appeal against the Closing Order, D247/1/30, 11 April 2011; Ronald C. Slye, *the Cambodian Amnesties: Beneficiaries and the Temporal Reach of Amnesties for Gross Violations of Human Rights*, Jaya Ramji (ed.,), Bringing the Khmer Rogue to Justice, 2005.

833 Pr-Trial Chamber, Ieng Sary against the Closing Order, *supra* note 832.

834 *Id.*

835 *Id.*; Micaela Frulli, *Amnesty*, *see* Antonio, the Oxford, *supra* note 55, p. 244.

គឺក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។[836] តាមច្បាប់នេះ អាជ្ញាយុកាលសម្រាប់ការចោទប្រកាន់ លើបទឧក្រិដ្ឋទារុណកម្ម ឬការសម្លាប់ មានថេរវេលា តែ ១០ឆ្នាំប៉ុណ្ណោះ។[837] នេះ មានន័យថា ក្រោយពីការប្រព្រឹត្ត ១០ឆ្នាំ គឺឆ្នាំ ១៩៨៩ (ប្រព្រឹត្តនៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩) ហើយក្នុងចន្លោះពេលនោះគ្មានការចោទប្រកាន់ទេ តុលាការ មិនអាចធ្វើការងារចោទប្រកាន់បានទៀតឡើយ ព្រោះហួសអាជ្ញាយុកាលកំណត់ សម្រាប់ការចោទប្រកាន់។ បញ្ហាច្បាប់ដ៏ចម្រូងចម្រាសបានត្រូវលើកឡើងដោយ មេធាវី ឌុច ក្នុងគោលបំណងថា សាលាក្តីនេះមិនអាចចោទប្រកាន់ ឌុច ក្នុងករណីបទទារុណកម្ម ឬការកាប់សម្លាប់អ្នកទោសនៅក្នុងគុកទួលស្លែងទេក្រោមច្បាប់ ឆ្នាំ ១៩៥៦។[838] រឿងនេះ ត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសេចក្តី សម្រេចដ៏ចម្រូងចម្រាស។[839] បញ្ហាបានចោទជាសំខាន់ថា តើច្បាប់បង្កើតអង្គជំនុំជម្រះ ដែលពន្យាររយៈពេលអាជ្ញាយុកាល ខុស ឬត្រូវច្បាប់។ ការពន្យារមិនខុសច្បាប់ លុះត្រារយៈពេលនៃអាជ្ញាយុកាល មិនទាន់ផុតរលត់។[840] ចំណុចចុងក្រោយនេះ នាំឲ្យមាន

[836] 1956 Penal Code of Cambodia is still in force, *supra* note 93.

[837] Preliminary Objection Concerning Termination of Prosecution of Domestic Crimes, E9/1, 4 February 2009, pp. 6-8; Trial Chamber, Decision on the Defence Preliminary Objection Concerning the Statute of Limitations of Domestic Crimes, 26 July 2010, E187, para. 4

[838] Preliminary Objection Concerning Termination of Prosecution of Domestic Crimes, E9/1, 4 February 2009, pp. 6-8.

[839] Trial Chamber, Decision on the Statute of Limitations, *supra* note 837.

[840] For concept of statutory limitation, *see* Christine Van den wyngaert, *War crimes, genocide and crimes against humanity-Are States taking national prosecutions seriously*? In Cherif Bassiouni ed., Internationl Criminal Law and Procedure, 1999, p. 232; Micaela Erulli, *are crimes against humanity more serious than war crimes*?, 12 EJIL (2012), pp. 341-342; Trial Chamber, Decision on the Statute of Limitations, *supra* note 837, para. 52.

យោបល់ខ្វែងគ្នាយ៉ាងស្រួចស្រាល់ រវាងចៅក្រមជាតិ និងអន្តរជាតិនៃអង្គជំនុំជម្រះ។ ទោះបីជាយ៉ាងនេះ ក្ដីចៅក្រមទាំងពីរក្រុម បានទទួលស្គាល់ថា ក្នុងអំឡុងពេល ១៩៧៥ ដល់ ១៩៧៩ ប្រព័ន្ធតុលាការមិនមានដំណើរការ ដែលខ្វាស់មិនឲ្យអាជ្ញាយុកាលដើរ។[841] ចៅក្រមជាតិ បានអះអាងថា រហូតដល់ឆ្នាំ ១៩៩៨ ទើបកម្ពុជាទទួលបានសន្តិភាពពេញលេញ។ ចាប់តាំងពី ១៩៧៥ ដល់ ១៩៩៣ អាជ្ញាយុកាលមិនដើរទេ ហើយទើបចាប់ផ្ដើមដើរក្រោយឆ្នាំ ១៩៩៣។ តាមន័យនេះ បើគិតរយៈពេល ១០ឆ្នាំ អាជ្ញាយុកាលនឹងផុតរលត់ ក្នុងឆ្នាំ ២០០៣។ ដោយសារសភាធ្វើច្បាប់បង្កើតអង្គជំនុំជម្រះ ក្នុងឆ្នាំ ២០០០ ដែលអាជ្ញាយុកាលមិនទាន់ផុតរលត់ ដូចនេះមិនខុសច្បាប់ទេ។[842] ជាលទ្ធផល តុលាការអាចធ្វើការចោទប្រកាន់ ឌុច ចំពោះបទទារុណកម្ម និងការសម្លាប់។[843] ចៅក្រមអន្តរជាតិបាន ប្រកាន់ជំហរផ្សេងពីនេះ ដោយអះអាងថា មុនឆ្នាំ ១៩៩៣ តុលាការកម្ពុជាមានដំណើរការរួចហើយ។ អាជ្ញាយុកាល ១០ឆ្នាំ ត្រូវបានចាប់ផ្ដើមគិត ហើយនឹងផុតរលត់មុនឆ្នាំ ២០០១។ ច្បាប់ធ្វើការពន្យារពេល ក្រោយពីផុតរលត់នៃអាជ្ញាយុកាល មិនត្រឹមត្រូវតាមច្បាប់ទេ។[844] អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិន ត្រូវកាត់ សេចក្ដី សំណុំរឿងរបស់ ឌុច លើបទចោទទារុណកម្ម និង ការសម្លាប់ក្រោមច្បាប់ជាតិទេ។ ការយល់ឃើញបៀបនេះ ស្រដៀងគ្នានឹងជំហររបស់មេធាវី ឌុច។[845]

---

[841] Trial Chamber, Decision on the Statute of Limitation, *supra* note 837, para. 32.
[842] *Id.*, para. 25.
[843] *Id.*, para. 25.
[844] *Id.,* para. 32.
[845] Preliminary Objection Concerning Termination of Prosecution of Domestic Crimes, *supra* note 838, para. 5-7.

### គ. ការឃុំខ្លួនមុនបង្កើតអង្គជំនុំជម្រះ

បញ្ហាច្បាប់ពាក់ព័ន្ធជាមួយនឹងការឃុំខ្លួន កើតមានចំពោះករណី ឌុច ដែលជាប្រធានគុកទួលស្លែង។[846] ឌុច ត្រូវបានចាប់ខ្លួនតាំងពីមុនពេលសាលាក្តី ត្រូវបានបង្កើតឡើង។[847] ក្រោយមក ឌុច ត្រូវបានបញ្ជូនមកដាក់ក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះ ផ្អែកតាមដីកា របស់សហចៅក្រមស៊ើបអង្កេត។[848] មេធាវីរបស់ ឌុច បានអះអាងថា ឌុច ត្រូវបានឃុំខ្លួនទុកដើម្បីបញ្ជូនទៅសាលាក្តីខ្មែរក្រហម។ ជាបន្ថែម មេធាវីរកឃើញថា ការឃុំខ្លួនរបស់ ឌុច ខុសនឹងច្បាប់ជាតិ និងអន្តរជាតិ។ ដូចនេះ វាហាមឃាត់មិនឲ្យសាលាក្តីកាត់ក្តី ឌុច ហើយតម្រូវឲ្យមានការដោះលែងរូបគាត់។[849]

សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបចំពោះបញ្ហានេះ ដោយយោងទៅតាមទ្រឹស្តី ការបំពារបំពាននីតិវិធី (Abuse of Procedures)។ សហចៅក្រមរកឃើញថា ការបំពារបំពាននីតិវិធីដោយអាជ្ញាធរអនុវត្តន៍ច្បាប់ នឹងនាំឲ្យមានការដោះលែងជនជាប់ចោទ ប្រសិនបើការបំពារបំពានធ្ងន់ធ្ងរ (ធ្វើទារុណកម្មលើជនជាប់ចោទ)។ ចៅក្រម មិនឃើញមានករណីនេះ កើតមានចំពោះ ឌុច ឡើយ។[850]

---

[846] Trial Chamber, Report of Examination, 19 November 2007, C21, p. 5.
[847] *Id.*
[848] The Office of the Co-Investigating Judge, Detention Order, 31 July 2007, C4/2; OCIJ, Order of Provisional Detention, C3/10, 31 July 2007, p. 10.
[849] Trial Chamber, Report of Examination, *supra* note 846, p. 5.
[850] OCIJ, Order of Provisional Detention, *supra* note 848, para. 21.

មេធាវីរបស់ ឌុច បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួន ឌុច ចេញដោយចៅក្រមស៊ើបអង្កេត ទៅអង្គបុរេជំនុំជម្រះ។[851] ទាំងសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ បានអះអាងថាខ្លួនមិនមានសមត្ថកិច្ច ពិនិត្យថា តើការឃុំខ្លួនឌុច នៅតុលាការយោធា មុនពេលគាត់ ត្រូវបានគេបញ្ជូនមកសាលាក្តី ជាការខុសច្បាប់ដែរឬទេ ?។[852]

អង្គជំនុំជម្រះសាលាដំបូង ជាការឆ្លើយតបចំពោះ ការលើកឡើងដោយមេធាវីរបស់ឌុច បានអះអាងថា ការឃុំខ្លួនរបស់ ឌុច ខុសច្បាប់ ហើយឌុច ត្រូវទទួលបាន ការបន្ថយរយៈពេលនៃទោស ប្រសិនបើអង្គជំនុំជម្រះ រកឃើញថាគាត់មានទោស។[853] ប្រសិនបើ អង្គជំនុំជម្រះ រកឃើញថា ឌុច គ្មានទោស ឌុច អាចប្តឹងទៅតុលាការជាតិ ដើម្បីសុំសំណង។[854] អង្គជំនុំជម្រះ បានដាក់ទោស ឌុច ចំនួន ៣៥ ឆ្នាំ។[855] ក៏ប៉ុន្តែ រយៈពេលនេះត្រូវបានដកចេញនូវរយៈពេលឃុំខ្លួនក្នុងអង្គជំនុំជម្រះ និង ការឃុំខ្លួននៅតុលាការយោធា ។[856] ជាសរុប ឌុច នឹងជាប់ទោសពន្ធនាគារ តែរយៈពេល ១៩ឆ្នាំ ដែល នាំឲ្យសហព្រះរាជអាជ្ញាប្តឹង ឧទ្ធរណ៍ ទាមទារដំឡើងទោសនៅអង្គជំនុំជម្រះតុលាការកំពូល។[857]

---

[851] Pre-Trial Chamber, Decision on Appeal against Provisional Detention Order of Kaing Guek Eav alias Duch, 3 December 2007, para. 4.

[852] *Id.*, para. 17; Trial Chamber, Report of Examination, *supra* note 846, p.3.

[853] Trial Chamber, Decision on Request for Release, 15 June 2009, E39/5, p. 15.

[854] *Id.*

[855] 01 Case Judgement, *supra* note 757, para. 631.

[856] *Id.,* para. 632.

[857] Co-Prosecutors'Appeal against the Judgement of the Trial Chamber in the Case of Kaing Guek Eav alias Duch, F10, 13 October 2010.

សាលក្រមនេះ ទទួលបានការស្វាគមន៍ដោយ អ្នកគាំទ្រសិទ្ធិមនុស្ស។ ចៅក្រមអន្តរជាតិ រួមជាមួយ ចៅក្រមជាតិ នៃអង្គជំនុំជម្រះ បានអះអាងថា សិទ្ធិរបស់ ឌុច ត្រូវបានគេរំលោភបំពាន។ ទោះបីជាយ៉ាងណាក្តី ចៅក្រម មិនបាននិយាយច្បាស់ថា ក្រៅពីការកាត់បន្ថយទោស ឌុច អាចប្តឹងទារ សំណងជំងឺចិត្ត និងសុំឲ្យមានការដាក់ទោសទណ្ឌ ជនដែលទទួលខុសត្រូវ ក្នុងការរំលោភសិទ្ធិរបស់ ឌុច។ វាអាចបណ្តាល មកពីអង្គជំនុំជម្រះនេះ ផ្សេង ពីតុលាការជាតិ ហើយការអនុវត្តជាក់ស្តែងនឹងជាការពិបាក។ យ៉ាងណាក្តី អង្គជំនុំជម្រះមិនបានហាមឃាត់ ឌុច មិនឲ្យសើរើរកជនដែលទទួលខុសត្រូវ ក្នុងការរំលោភសិទ្ធិរបស់គាត់ទេ។ បញ្ហា គឺថា តើ ឌុច អាចប្តឹងទៅតុលាការ ណា។ ការសម្រេច ផ្តល់ជាយុត្តិសាស្រ្តថា បើឃុំខ្លួនជនណាមួយខុសច្បាប់ ជននោះនឹងទទួលបានការកាត់បន្ថយទោស ហើយអ្នករំលោភសិទ្ធិ អាចនឹង ទទួលខុសត្រូវ ហើយជនរងគ្រោះ អាចទទួលបានសំណងជំងឺចិត្ត។

ក្រោយមក អង្គជំនុំជម្រះតុលាការកំពូល បានទទួលស្គាល់ថាមានការ រំលោភសិទ្ធិដោយប្រយោល ក៏ប៉ុន្តែ ដោយសារតែ មិនមានការចូលរួមខុស របស់សាលាក្តីខ្មែរក្រហម ពាក់ព័ន្ធជាមួយការឃុំខ្លួនរបស់ឌុច តុលាការកំពូល មិនផ្តល់ការបន្ថយទោសសម្រាប់ ការឃុំខ្លួនខុសច្បាប់ទេ។[858] តុលាការ កំពូល រកឃើញ ថា *ឌុច* បានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ តុលាការសម្រេច ឲ្យឌុចជាប់ទោស មួយជីវិត។[859]

---

[858] Supreme Court Chamber, *supra* note 812, paras. 398-399.
[859] *Id.*, para. 404.

### ឃ. ចម្លើយសារភាពដោយបង្ខិតបង្ខំ

ឯកសារ អាចជាភស្តុតាង ហើយឯកសារនោះទៀតសោត អាចជាឯកសារចម្លើយសារភាពដោយបង្ខិតបង្ខំ។ សំណួរផ្លូវច្បាប់ អាចត្រូវបានលើកឡើងថា តើឯកសារប្រភេទចុងក្រោយនេះ នឹងត្រូវទទួលយកបាន ដែរឬទេ?

ករណីនេះបានកើតមានឡើងក្នុងករណី ឌុច។ ឌុច ដែលជាប្រធានគុកទួលស្លែង បានធ្វើទារុណកម្ម និងចូលរួមក្នុងអំពើនេះ ដើម្បីទាញយកចម្លើយពីអ្នកទោសដែលជាប់គុកទួលស្លែង។[860] មេធាវីរបស់ ជនជាប់ចោទ បានស្នើឲ្យតុលាការបដិសេធ ឯកសារចម្លើយសារភាពទាំងស្រុង។ មេធាវី បានផ្អែកលើ កតិកាសញ្ញា ស្តីពី ការហាមឃាត់អំពើទារុណកម្ម[861] និងច្បាប់រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា។[862] ភាគីដែលពាក់ព័ន្ធ ដូចជា សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត បានថ្លែងយោង ដល់ការហាមប្រើចម្លើយសារភាពសម្រាប់ចោទប្រកាន់ជនរងគ្រោះនៃអំពើទារុណកម្ម លើបទឧក្រិដ្ឋ តែច្បាប់ និងសន្ធិសញ្ញា មិនបានហាមឃាត់ ការប្រើចម្លើយសារភាព ជាភស្តុតាងក្នុងការចោទប្រកាន់ អ្នកធ្វើអំពើទារុណកម្មឡើយ។[863]

សហចៅក្រមស៊ើបអង្កេត បានអះអាងថា ផ្នែកខ្លះនៃចម្លើយសារភាព មានលក្ខណៈពិតប្រាកដ និងអាចទុកចិត្តបាន ពីព្រោះមិនបានមកដោយសារការបង្ខិតបង្ខំ ឬអំពើទារុណកម្មទេ។ ផ្នែកនោះ ដូចជាពាក់ព័ន្ធនឹងប្រវត្តិ

[860] 01 Case Judgement, *supra* note 757, para. 240.

[861] The Torture Convention, *supra* note 189, p.85; Case of IENG Thirith, 02/19-09-2007-ECCC/OCIJ (PTC26), Defence Appeal against OCIJ's Order on Use of Statement which were of may have been obtained by torture of 28 July 2009, D130/9.

[862] Case of IENG Thirith, 02/19-09-2007-ECCC/OCIJ (PTC26), *id.*

[863] The Torture Convention, *supra* note 189, Art. 15.

របស់ជនរងគ្រោះនៃអំពើទារុណកម្ម ឬរចនាសម្ព័ន្ធរបស់មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ដែលអាចជាព័ត៌មានពិត។ ដូចគ្នានេះដែរ ចំណាររបស់ ឌុច លើចម្លើយសារភាព អាចត្រូវបានប្រើនៅក្នុងសវនាការ ពីព្រោះវាមិនត្រូវបានធ្វើឡើង ដោយការបង្ខិតបង្ខំលើ ឌុច ទេ។ ផ្ទុយទៅវិញ ជាការពិតអង្គហេតុខ្លះ ទទួលបានតាមរយៈការបង្ខិតបង្ខំ។[864] អាស្រ័យហេតុនេះ ការពិចារណាថា ចម្លើយសារភាពណាមួយ ឬផ្នែកមួយណានៃចម្លើយសារភាព អាចទទួលយកបាន ឬមិនបាន ផ្អែកទៅតាមករណីនីមួយៗជាក់ស្តែង។ ព័ត៌មានក្នុងចម្លើយសារភាព អាចជាព័ត៌មាននាំមុខ សម្រាប់ជួយអ្នកស៊ើបអង្កេត ក្នុងការស្វែងរកភស្តុតាងពិតប្រាកដ។[865] ទាញចេញពីអំណះអំណាងនេះ គេអាចនិយាយថា មិនមានហាមឃាត់ជាដាច់ខាតរាល់ឯកសារ ដែលជាចម្លើយសារភាពឡើយ។

មេធាវី ដែលបានជំទាស់នឹងការប្រើចម្លើយសារភាព មានយុទ្ធវិធីការពារដ៏វៀងវៃ ពីព្រោះព័ត៌មានក្នុងចម្លើយសារភាពអាចរួមផ្គុំ ជាមួយភស្តុតាងបង្កជាតឹកតាងដ៏មានទម្ងន់ បង្ហាញពីរចនាសម្ព័ន្ធច្បាស់លាស់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការមិនប្រើនូវចម្លើយសារភាពទាំងអស់ នាំឲ្យមិនមានព័ត៌មានគ្រប់គ្រាន់ក្នុងការ បង្កើតគោលបំណងរួម ដែលជាសមាសធាតុ មួយបង្កើតទម្រង់ទទួលខុសត្រូវ ដែលហៅថា សហឧក្រិដ្ឋកម្មរួម។

864 Relevance, IENG Sary's Motion against the Use of Torture Tainted Evidence at Trial, 4 February 2011, para. 17; the Office of Co-Investigating Judge, Order on Use of Statements which were or may have been obtained by torture, 28 July 2009, E3/1555, para. 28.

865 Relevance, IENG Sary's Motion against the Use of Torture, *supra* note 864, para. 17; the Office of Co-Investigating Judge, Order on Use of Statements, *supra* note 864, para. 26.

វាមិនសូវមានមូលដ្ឋានមាំទាំទេ ក្នុងការភ្ជាប់ការហាមឃាត់ទាំងស្រុងនូវការប្រើចម្លើយសារភាព ដល់ជនជាប់ចោទដទៃទៀត ក្រៅពី ឧច ដែលពួកគេមិនបានចូលរួមធ្វើអំពើទារុណកម្ម ទោះបីជាក្នុងទម្រង់ជាការជួយក្តី។ ជាពិសេស ដូចដែលបាននិយាយក្នុងទំព័រមុន ការហាមឃាត់មិនមានភាពដាច់ខាតឡើយ។ ចុងក្រោយ គេមិនគួរបកស្រាយមាត្រាក្នុងរដ្ឋធម្មនុញ្ញ នាំឲ្យមានការហាមឃាត់នូវរាល់ចម្លើយសារភាពនេះឡើយ។ ប្រសិនបើយោងទៅលើភាពមិនច្បាស់លាស់របស់មាត្រារដ្ឋធម្មនុញ្ញ គេក៏អាចបកស្រាយបានថា មាត្រានេះ ក៏ហាមមិនឲ្យប្រើចម្លើយសារភាព សម្រាប់ធ្វើជាភស្តុតាង ចោទប្រកាន់ជនប្រព្រឹត្តអំពើទារុណកម្ម ពីព្រោះការបកស្រាយផ្ទុយពីនេះ នឹងផ្ទុយនឹងកតិកាសញ្ញា ស្តីពី ការហាមឃាត់អំពើទារុណកម្ម ដែលកម្ពុជា ជារដ្ឋភាគី។

## ខ. សហឧក្រិដ្ឋកម្មរួម

សហឧក្រិដ្ឋកម្មរួម ជាទម្រង់នៃការទទួលខុសត្រូវ ដែលខុសពីបទល្មើស។ ជាគោលការណ៍ ចៅក្រមត្រូវរកឲ្យឃើញនូវ បទល្មើសជាមុនសិន រួចកំណត់នូវទម្រង់ដែលបុគ្គលណាមួយចូលរួម ក្នុងបទល្មើស ដែលនាំបុគ្គលណាមួយទទួលខុសត្រូវ។ ដូចគ្នានេះដែរ ការកំណត់ទម្រង់ទទួលខុសត្រូវ ជារឿងបន្ទាប់ពីការកំណត់ថា តើបុគ្គលណាមួយស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ។

សហឧក្រិដ្ឋកម្មរួម ត្រូវបានប្រើប្រាស់យ៉ាងហោចណាស់ ក្រោយសង្គ្រាមលោកលើកទី ២ ក៏ប៉ុន្តែ ពាក្យពេចន៍ ដែលបានប្រើបង្ហាញពីទម្រង់នេះ

នៅមិនទាន់មានភាពច្បាស់លាស់ និង ស៊ីសង្វាក់គ្នាទេ។[866] ទម្រង់នេះត្រូវបានប្រើជាក់លាក់ ដោយតុលាការព្រហ្មទណ្ឌសម្រាប់អតីតយូហ្គោស្លាវី ក្នុងរឿងក្តីរបស់លោក *Tadic*។[867] តាមសាលក្រមនេះ សហឧក្រិដ្ឋកម្មរួម មានបីទម្រង់៖ ទី១ ទម្រង់មូលដ្ឋាន (Basic) ទី២ ទម្រង់ខ្សែសង្វាក់ (Systematic Form) និង ទី៣ ពង្រីក (Extended Form/Liability)។[868] ជារួម សហ ឧក្រិដ្ឋរួម មានធាតុផ្សំបី៖ ទី១ គោលបំណងរួម (ឧទាហរណ៍ គម្រោងប្លន់ ធនាគារ) ទី២ មានមនុស្សចូលរួមចាប់ពីពីរនាក់ឡើងទៅ និង ទី៣ ការចូលរួម ក្នុងការសម្រេចគោលបំណងរួម។[869]

ការប្រើទម្រង់នៃការទទួលខុសត្រូវនេះ នាំឲ្យមានការរិះគន់ និង ការគាំទ្រ។ ការរិះគន់ ជាពិសេសចំពោះ ទម្រង់ទី ៣ របស់សហឧក្រិដ្ឋកម្មរួម ដោយសារបុគ្គលត្រូវបានចោទប្រកាន់ ដោយគ្រាន់តែបានដឹង និង បានចូលរួម។ បុគ្គល X រួមជាមួយមិត្តបីនាក់ផ្សេងទៀត មានបំណងប្លន់ (គោលបំណងរួម)។ X បានដឹងថា Y ក្នុងពេលប្លន់ មានកាន់កាំភ្លើង ហើយដែលជាទម្លាប់ Y នឹងសម្លាប់ជនរងគ្រោះ នៃអំពើប្លន់ ដែលជំទាស់មិនប្រគល់ទ្រព្យ។ X ដឹង ហើយនៅតែចូលរួមអំពើប្លន់ គាត់នឹងទទួលទោសចំពោះបទប្លន់ និង សម្លាប់ ប្រព្រឹត្តដោយ Y ដែលបទល្មើសចុងក្រោយនេះ X គ្រាន់តែដឹងថា ការសម្លាប់ អាចនឹងកើតមានឡើង។ ការដាក់ឲ្យ X ទទួលខុសត្រូវចំពោះអំពើសម្លាប់

---

[866] Indirect perpetration, co-perpetration or JCE, Gideon Boas, Forms of Responsibility in International Criminal Law, 2007, p. 124.

[867] *Prosecutor v.Tadic*, ICTY, Case No.: IT-94-1-A, Appeal Judgement of 15 July 1999; IENG Sary’s Motion against the Application at the ECCC of the Form of Liability Known as Joint Criminal Enterprise, 28 July 2008, D97,p. 3.

[868] Tadic, *id*., para. 227.

[869] *Prosecutor v. Brdanin*, ICTY, Case no.: IT-99-36-A, Judgement, 3 April 2007, para. 430.

ធ្វើឡើងដោយ Y ចាកឆ្ងាយពីទ្រឹស្តីទទួលខុសត្រូវព្រហ្មទណ្ឌ ដែលតម្រូវឲ្យមានការបកស្រាយតឹងរឹង ពិចារណាលើអំពើ និង ចេតនាប្រព្រឹត្តរបស់ជនល្មើស។[870]

អ្នកគាំទ្រ ទម្រង់ទទួលខុសត្រូវនេះ អះអាងថា ការប្រព្រឹត្តបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ មានផលវិបាកធ្ងន់ធ្ងរ មានមនុស្សស្លាប់ច្រើន ដែលធ្វើឲ្យមនុស្សជាតិមានក្តីសង្វេគជាខ្លាំង និងប៉ះពាល់ដល់សហគមន៍អន្តរជាតិទាំងមូល។[871] ការប្រព្រឹត្តចូលរួមដោយមនុស្សជាច្រើន ហើយមានការពិបាក ក្នុងការបង្ហាញការចូលរួមរបស់ជនល្មើសនីមួយៗ យ៉ាងជាក់លាក់។[872] ការប្រើទម្រង់នេះ មានភាពងាយស្រួលបង្ហាញអំពីការចូលរួមរបស់បុគ្គលនីមួយៗ។ នេះ នាំឲ្យមានការចោទប្រកាន់បុគ្គល ដែលពាក់ព័ន្ធក្នុងបទឧក្រិដ្ឋទាំងអស់ (ចាប់បានទាំងត្រីតូច និងត្រីធំ) ហើយអាច នឹងនាំឲ្យមនុស្សមានការរាងចាលក្នុងការប្រព្រឹត្តបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ។ ដូចនេះ គួរមានភាពធូររលុង ក្នុងការប្រើប្រាស់ ធាតុផ្សំទាំងពីរ សម្រាប់ដាក់ការទទួលខុសត្រូវ។ បញ្ហាដែលចម្រូងចម្រាស ពាក់ព័ន្ធជាមួយសហឧក្រិដ្ឋកម្មរួម គឺបញ្ហាឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៃទម្រង់នេះ ពីព្រោះសហឧក្រិដ្ឋកម្មនេះ មិនត្រូវបានចែងដោយច្បាប់អន្តរជាតិជាច្រើន ក្នុងទម្រង់ ជាសន្ធិសញ្ញា ដែលចងជាកាតព្វកិច្ច។

[870] Katrina Gustafson, *JCE, see* Antonio, the Oxford, *supra* note 55, p. 395.
[871] Shaw, IL, *supra* note 1, p. 668.
[872] Katrina Gustafson, Joint Criminal Enterprise, *see* Antonio, the Oxford, *supra* note 55, pp. 395-396.

ការចូលរួមក្នុងសហឧក្រិដ្ឋរួម មានការប្រព្រឹត្តផ្ទាល់ ការជួយ ការរៀបចំផែនការ។ គេមិនគួរច្រឡំ រវាងការរៀបចំប្រព្រឹត្តបទឧក្រិដ្ឋ និង ការធ្វើផែនការឧក្រិដ្ឋឡើយ។ សហឧក្រិដ្ឋកម្មរួម ខុសពី ទម្រង់ទទួលខុសត្រូវ ការសមគំនិតទុច្ចរិត (Conspiracy) ដែលប្រភេទឧក្រិដ្ឋ នៃអំពើប្រល័យពូជសាសន៍។[873] គ្រាន់តែជា Conspiracy គឺគ្រប់គ្រាន់រួចហើយក្នុងការទទួលខុសត្រូវផ្ទុយទៅវិញ សហឧក្រិដ្ឋកម្មរួម ដែលទាមទារនូវការប្រព្រឹត្ត ទោះបីមិនបានប្រព្រឹត្តដោយផ្ទាល់ខ្លួនក៏ដោយ។

នៅក្នុងសំណុំរឿងលេខ ០០១[874] និង ០០២របស់សាលាក្តីខ្មែរក្រហមសហព្រះរាជអាជ្ញា បានប្រើនូវទម្រង់ទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមទាំងបីប្រភេទ។ សហព្រះរាជអាជ្ញាផ្អែកលើមូលដ្ឋានថា ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និង ច្បាប់ស្តីពី អង្គជំនុំជម្រះ បានចែងឲ្យប្រើទម្រង់នេះ។[875] សហចៅក្រមស៊ើបអង្កេត បានប្រកាន់យកតែ ទម្រង់ទី ១ និងទី ២ តែប៉ុណ្ណោះ ក្នុងសំណុំរឿងលេខ ០០២។[876] មេធាវីទាំងអស់ បានបដិសេធនូវការប្រើទម្រង់នេះ។[877] ទោះបីជាយ៉ាងនេះក្តី អង្គបុរេជំនុំជម្រះ ឯកភាពឲ្យប្រើប្រាស់ទម្រង់នេះ (ទី ១ និងទី២)។[878]

---

[873] The Genocide Convention, *supra* note 74, Art. 3(b).

[874] The prosecutor applies the second form of joint criminal enterprise to Duch in the context of S21, *see* OCP, Rule 66 Final Submission regarding *Duch*, 18 July 2008, see final submission, D96, paras. 252-253.

[875] Closing Order, Case 002, *supra* note 819, para. 1541.

[876] *Id.*

[877] IENG Sary's Motion against the Application at the ECCC of the Form of Liability Known as Joint Criminal Enterprise, 28 July 2008, D97.

[878] ECCC, PTC, Decision on the Appeals against JCE, *supra* note 760, para. 77.

សេចក្តីអះអាងរួមជាសំខាន់ របស់មេធាវីជនជាប់ចោទ ប្រឆាំងនឹងការប្រើប្រាស់ទម្រង់នេះ គឺថា ទម្រង់នេះមិនទាន់មានឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ មុនឆ្នាំ ១៩៧៥ ពីព្រោះ មិនមានការអនុវត្តជាទូទៅនូវទម្រង់នេះ ដោយរដ្ឋ ដែលជាសមាសភាគមួយ នៃការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ។[879] បន្ថែមពីលើនេះ ទោះបីជាមានការទទួលស្គាល់ថា ទម្រង់នេះមានឋានៈដូចនេះក្តី ក៏កម្ពុជា មិនប្រើប្រាស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់ ដោយមិនចាំបាច់មានច្បាប់ចែងបញ្ចូលដោយសភាអនុញ្ញាតឲ្យតុលាការប្រើប្រាស់ទម្រង់នេះឡើយ។[880]

ការប្រកាន់ជំហរផ្សេង ដោយភាគីពាក់ព័ន្ធ ទាញចេញមកពីការបកស្រាយទូលាយ ឬតឹងរឹង នូវធាតុផ្សំរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ជាការពិតជាក់ស្តែង មានការលំបាកណាស់សូម្បីតែ ការយល់ដឹងអំពីជំហររបស់តុលាការជាតិ ទាក់ទងនឹងការអនុវត្តសន្ធិសញ្ញា ជាច្បាប់ជាក់លាក់ជាលាយលក្ខណ៍អក្សរ ដែលកម្ពុជាជាភាគី ចុះទម្រាំការប្រើច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយតុលាការកម្ពុជា ដែលច្បាប់ប្រភេទនេះ ជាច្បាប់អរូបី។ សូម្បីប្រទេស ដែល ប្រើប្រាស់ច្បាប់អន្តរជាតិញឹកញយ ក៏ស្ទាក់ស្ទើរក្នុងការប្រើប្រាស់ច្បាប់ ទំនៀមទម្លាប់អន្តរជាតិនេះដែរ។ ម្យ៉ាងទៀត វាជានិន្នាការទៅហើយ ដែលរដ្ឋមិន ឲ្យតម្លៃ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ខ្ពស់ជាងច្បាប់ធម្មតារបស់ជាតិ។[881] ជាចុងក្រោយ គេគួរមានការប្រយ័ត្នប្រយែង ក្នុងការបកស្រាយន័យនៃពាក្យ សហចារី ក្នុងច្បាប់កម្ពុជា។ សហចារី តាមច្បាប់កម្ពុជា

[879] IENG Sary's Motion against JCE, *supra* note 877, para. 18.
[880] *Id.*, para. 24.
[881] MEAS Bora, Customary International Law, Working Paper I, 2012 (in files of the author).

សំដៅលើអ្នកចូលរួមប្រព្រឹត្តផ្ទាល់[882] រីឯពាក្យសហចារី ក្នុងន័យប្រព្រឹត្តផ្ទាល់ ក្រោមសហឧក្រិដ្ឋកម្មរួម មិនទាមទារឲ្យមានការប្រព្រឹត្តផ្ទាល់ទេ។ ក្នុងន័យនេះ វាជាការគ្រប់គ្រាន់ហើយ ប្រសិនបើបុគ្គលណាមួយ មានចេតនាដូចគ្នា ចង់ឲ្យបទឧក្រិដ្ឋណាមួយកើតមានឡើង ហើយបទនោះត្រូវបានប្រព្រឹត្ត ដោយបុគ្គលណាមួយផ្សេងទៀត បុគ្គលមានចេតនា ដែលមិនចូលរួមប្រព្រឹត្តផ្ទាល់ នឹងត្រូវបានចាត់ថាជាសហចារី។

### ១០.១.១.៤. បត្យាប័ន និងការជួយគ្នាផ្នែកតុលាការ

បទល្មើសព្រហ្មទណ្ឌ ត្រូវបានប្រព្រឹត្តនៅក្នុងដែនដីមួយ ហើយដោយមធ្យោបាយណាមួយ ជនល្មើសបានរួចគេចខ្លួនទៅក្រៅប្រទេសរបស់ខ្លួន ដោយមិនទាន់បានទទួលការកាត់ទោសផង។ រដ្ឋនឹងធ្វើការស្នើសុំដល់រដ្ឋ ដែលជនល្មើសកំពុងជ្រកកោន ឲ្យបញ្ជូនខ្លួនទៅប្រឈមមុខនឹងការកាត់ទោស ឬអនុវត្តទោសដែលនៅសេសសល់។ ការបញ្ជូននេះ ត្រូវបានផ្តល់ន័យថាជាបត្យាប័ន។[883] តាមន័យនេះ បត្យាប័ន មានន័យខុសពី ការបណ្តេញចេញនូវជនណាមួយ ចេញពីដែនដីរបស់ខ្លួន ដោយសារជននោះចូលមកខុសច្បាប់។[884] បត្យាប័នខុសពី ការដោះដូរអ្នកទោសរវាងប្រទេសមួយ ដើម្បីឲ្យជនជាតិរបស់រដ្ឋ ដែលប្រព្រឹត្តល្មើសច្បាប់ប្រទេសមួយទៀត ទទួលបានការកាត់ទោសដោយរដ្ឋនោះ មកជាប់ទោសជាបន្តក្នុងពន្ធនាគារក្នុងរដ្ឋរបស់

---

[882] The Criminal Code of Cambodia, Article 26, *supra* note 827.

[883] Geoff Gilbert, Aspects of Extradition, 9 (1991); Christopher L. Blakesley, *the Law of International Extradition: A Comparative Study*, 62 International Review of Penal Law, 1(1991).

[884] 1994 Law on Immigration of Cambodia, Art. 37, a selection of Cambodian Law, *supra* note 886, pp.1039-1051. It is also different from "surrender", see Annalisa Ciampi, *Extradition*, see Antonio, the Oxford, *supra* note 55, p. 322.

ខ្លួន។[885] នេះនាំឲ្យមានភាពងាយស្រួល ដល់គ្រួសារក្នុងការសួរសុខទុក្ខអ្នកទោស និងជានាការគោរពសិទ្ធិអ្នកទោស។

បត្យាប័ន មានប្រវត្តិជាយូរមកហើយ ប៉ុន្តែទទួលបានការវិវត្ត គួរឲ្យកត់សម្គាល់ ដោយសាកលភាវូបនីយកម្ម នៃការធ្វើដំណើររបស់មនុស្សលោក និងកំណើនបទឧក្រិដ្ឋឆ្លងប្រទេស។ ស្របជាមួយគ្នានេះ កិច្ចព្រមព្រៀង ឬសន្ធិសញ្ញាទ្វេភាគី[886] ជាពហុភាគី របស់តំបន់[887] ឬរបស់សាកលលោកទាំងមូល បានចែងគ្រប់គ្រងដំណើរការបត្យាប័ន។[888] ទោះបីជាយ៉ាងនេះក្តី ប្រទេសខ្លះ ធ្វើបត្យាប័ន ដោយមិនមានសន្ធិសញ្ញាឡើយ។[889]

ជារួមឯកសារទាំងអស់ដែលចែងអំពីនីតិវិធី បត្យាប័ន បានចែងនូវគោលការណ៍រួមដូចជា៖ គោលការណ៍ពិសេស (Rule of Speciality) បទល្មើស

[885] For example, Treaty on Cooperation in the Execution of Penal Sentences between the Government of the United States of America and the Government of the Kingdom of Thailand, 1988; Michael Abbell, International Prisoner Transfer 2010, Annex D.

[886] Extradition Treaty between the Kingdom of Cambodia and the Kingdom of Thailand (1999); the Treaty on Extradition between the Kingdom of Cambodia and People Republic of China (2000); the Treaty on Extradition between the Kingdom of Cambodia and People Democratic Republic of Lao (2005) in A Selection of Laws Currently in Force in the Kingdom of Cambodia, COHCHR (2006)

[887] European Convention on Extradition (ETS No. 24), entered into force April 18, 1960; Additional Protocol to the European Convention on Extradition (ETS No. 86); Second Additional Protocol to the European Convention on Extradition (ETS No. 098)

[888] The UN Model Treaty on Extradition, G.A. res. 45/116, annex, 45 U.N. GAOR Supp. (No. 49A) at 212, U.N. Doc. A/45/49 (1990)

[889] Some States, such as France, this State extradites without treaty, but have statute providing for extradition, *see* Geoff Gilbert, *supra* note 883, p. 26, *see* also MEAS Bora, extradition, *supra* note 276.

ដែលអាចបត្យាប័ន មូលដ្ឋាននៃការបដិសេធបត្យាប័ន ព្រមទាំងចែងពីនីតិវិធីបត្យាប័ន។

បទល្មើសដែលអាចបត្យាប័នបាន គឺជាបទល្មើសមានទោសយ៉ាងតិចមួយឆ្នាំចែងដោយច្បាប់របស់ប្រទេសទាំងពីរ។[890] ពាក់ព័ន្ធក្នុងករណីនេះ រដ្ឋអាចបត្យាប័នបុគ្គលណាមួយ ប្រសិនបើទោសដែលនៅសល់យ៉ាងតិចរយៈពេល ៦ខែ។[891] បទល្មើសនយោបាយ មិនមែនជាបទល្មើសអាចធ្វើបត្យាប័នឡើយ។[892] អត្ថន័យ នៃ បទល្មើសនយោបាយ មិនទាន់ត្រូវបានកំណត់ក្រោមច្បាប់អន្តរជាតិទេ។ រដ្ឋនីមួយៗ ផ្តល់ន័យផ្សេងៗដល់បទល្មើសនយោបាយ។[893] ការសម្លាប់ស្តេច មិនត្រូវបានចាត់ថា ជាបទល្មើសនយោបាយឡើយ។[894]

រដ្ឋស្នើសុំបត្យាប័ន ចំពោះបទល្មើសណាមួយ នឹងមិនត្រូវចោទប្រកាន់ជននោះ ពីបទល្មើសផ្សេង ក្រោយពីបានទទួលជននោះឡើយ។ ដូចគ្នានេះដែរ រដ្ឋមិនត្រូវបញ្ជូនជននោះបន្តទៅរដ្ឋទី៣ណា ដោយគ្មានការយល់ព្រមពីរដ្ឋបញ្ជូនទី១ឡើយ។[895]

[890] Michael D. WIMS, *Dual or Double Criminality, Re-Examining the Traditional Exception to Extradition*, 62 International Review of Penal Law, 331(1991); the 2007 Code of the Criminal Procedure of Cambodia (CPC), Art. 571.
[891] CPC, Article 571.
[892] Treaty on Extradition between the Kingdom of Cambodia and People Republic of China, *supra* note 887, Art. 3.
[893] Michael, Extradition to USA, *supra* note 203, p. 123.
[894] Treaty on Extradition between the Kingdom of Cambodia and People Republic of China, *supra* note 887, Art. 3.
[895] *See* Geoff Gilbert, *supra* note 883, p. 106. The rule or prescription does exist in the context of extradition sought from foreign country by Cambodia whereby the

ទោះបីជាក្រោយពីចុះកិច្ចព្រមព្រៀង ដែលតាមរយៈនេះ រដ្ឋជាភាគី មានកាតព្វកិច្ច ធ្វើបត្យាប័នយ៉ាងណាក្តី កាតព្វកិច្ចមិនមានចរិតដាច់ខាតឡើយ។ ជាឧទាហរណ៍ រដ្ឋនឹងមិនបញ្ជូនជនណាមួយ ដែលរំលោភច្បាប់របស់ខ្លួនឡើយ។ នេះក្នុងករណី ដែលបទល្មើស ដែលនឹងត្រូវបានកាត់ទោស ហួសអាជ្ញាយុកាលរួចទៅហើយ[896] ឬច្បាប់ហាមបញ្ជូនជនជាតិរបស់ខ្លួន។[897] ការមិនបញ្ជូននេះ ផ្អែកលើមូលដ្ឋានដាច់ខាត។ ក្រៅពីនេះ ការបញ្ជូន ឬមិនបញ្ជូន ផ្អែកតាមឆន្ទានុសិទ្ធិរបស់រដ្ឋ។ ឧទាហរណ៍ រដ្ឋអាចមិនបញ្ជូន ប្រសិនបើច្បាប់ខ្លួនអនុញ្ញាតឲ្យកាត់ទោសជននោះ ទោះបីជាគាត់ប្រព្រឹត្តបទល្មើសនៅក្រៅដែនដីរបស់ខ្លួនក្តី។[898]

### ១០.១.១.៤.១. បញ្ហាប្រឈម និងដំណោះស្រាយ

ការធ្វើបត្យាប័ន នាពេលបច្ចុប្បន្ន មានភាពស្មុគស្មាញ ពីព្រោះហួសពីដែនសមត្ថកិច្ចរបស់រដ្ឋ និងពាក់ព័ន្ធជាមួយច្បាប់អន្តរជាតិ។ ក្នុងករណីខ្លះ រដ្ឋត្រូវបានរាំងដោយច្បាប់អន្តរជាតិ ទោះបីជាច្បាប់ជាតិអនុញ្ញាត ឲ្យមាន

country shall not prosecute person concerned the crime outside extradition request, *see* the CPC, *supra* note 890, Article 577.

[896] Extradition Treaty between the Kingdom of Cambodia and the Kingdom of Thailand, Art. 3 (4); the Treaty on Extradition between the Kingdom of Cambodia and People Republic of China , Art. 3(4); the Treaty on Extradition between the Kingdom of Cambodia and People Democratic Republic of Lao, Art. 3 (4).

[897] This is because most of civil law countries do not extradite their nationals, see Antonio, the Oxford, *supra* note 55, p. 229.

[898] It is in the case that national law of States does not allow extradition of its citizens to another State, Shaw, IL, *supra* note 1, p. 687; for definition of the territorial application of law, *see* Marko, Extraterritorial, *supra* note 249, p. 8.

បត្យាប័នយ៉ាងណាក្តី។ ច្បាប់អន្តរជាតិ នឹងមិនអនុញ្ញាតឲ្យបញ្ជូនបុគ្គលណាមួយ ទៅទទួលរងនូវគ្រោះថ្នាក់នៃអំពើទារុណកម្មឡើយ។[899]

ដើម្បីដឹងថា ទង្វើបញ្ជូនបុគ្គលណាមួយ នាំឲ្យទទួលរងនៅគ្រោះថ្នាក់ រដ្ឋដែលបញ្ជូន ត្រូវពិចារណានូវកត្តាជាច្រើន ដូចជាស្ថានភាពសិទ្ធិមនុស្សរបស់រដ្ឋដែលទទួលបុគ្គល។ នេះនឹងធ្វើឲ្យរដ្ឋបញ្ជូន ស្ទាក់ស្ទើរក្នុងការលើកយករឿងសិទ្ធិមនុស្សរបស់ប្រទេសមួយមកពិនិត្យ ដែលអាចធ្វើឲ្យរដ្ឋ នោះមានភាពថ្នាំងថ្នាក់ជាមួយខ្លួន។ ជំហររបស់រដ្ឋ ដែលថាការប្រព្រឹត្តដោយរដ្ឋលើប្រជាពលរដ្ឋរបស់ខ្លួន ជារឿងផ្ទៃក្នុងរបស់រដ្ឋ ស្ថិតនៅពីក្រោយនៃភាពស្ទាក់ស្ទើរនេះ។[900] ទន្ទឹមនឹងនេះ វាហាក់ដូចជាមិនទំនងទេ ដែលរដ្ឋនឹងទទួលខុសត្រូវ ចំពោះអំពើរំលោភសិទ្ធិមនុស្ស ដោយអាជ្ញាធររដ្ឋផ្សេង នៅក្រៅដែនដីរដ្ឋបញ្ជូន ដោយសារទង្វើរបស់រដ្ឋទទួល។[901] បញ្ហានឹងកាន់តែស្មុគស្មាញ ប្រសិនបើគេពិចារណា ដល់បត្យាប័នដោយប្រយោល (បញ្ជូនទៅរដ្ឋផ្សេងក្រោយពីទទួលបានជនណាមួយ)។[902]

រឿងដែលស្មុគស្មាញជាងគេ គឺពាក់ព័ន្ធជាមួយជនភៀសខ្លួន។ ដោយសារតែកង្វល់អំពើការធ្វើទុក្ខបុកម្នេញ ក្នុងប្រទេសដើមរបស់ខ្លួន រដ្ឋបានផ្តល់ឋានៈជាជនភៀសខ្លួន ក្រោយមកទើបដឹងថាបុគ្គលនោះ ជាអតីតភេរវករ

---

[899] The Torture Convention, *supra* note 251, Art. 3.

[900] John, the Rule of non-inquiry, *supra* note 400, pp. 1217-1220; Geoff Gilbert, *supra* note 279, p. 104; John Dugard and Christine Van den Wyngaert, *Reconciling Extradition with Human Rights*, 92 the AJIL 189 (1998); Susanne Zuhlke and Jens Chrisntian Pastille, *Extradition and the European Convention, Soering Revisited*, 59 ZaoRV (1999), p.752; Peter Malanczuk, IL, *supra* note 1, pp. 209, 220.

[901] *Soering v. the United Kingdom, supra* note 178, paras. 112-114.

[902] Mutombo v. Switzerland, *supra* note 407, para. 10.

ហើយរដ្ឋផ្តល់ឋានៈអាចដក ឋានៈជាជនភៀសខ្លួន នឹងធ្វើបត្យាប័នជននោះទៅទទួលទោសនៅក្រៅប្រទេស។ មាត្រាដែលពាក់ព័ន្ធ នៃសន្ធិសញ្ញា ស្តីពីជនភៀសខ្លួន មិនបានដោះស្រាយនូវបញ្ហាទំនាស់រវាង កាតព្វកិច្ចធ្វើបត្យាប័ន និងកាតព្វកិច្ចក្រោមសន្ធិសញ្ញាផ្សេងទៀតទេ។[903] ក្នុងដំណើរការបត្យាប័ន បុគ្គលអាចអះអាងថា គាត់នឹងទទួលរងគ្រោះថ្នាក់ នៃអំពើទារុណកម្ម។ ប្រសិនបើជាការពិត រដ្ឋមិនត្រូវបញ្ជូនជននោះជាដាច់ខាត ទោះបីជាគាត់ជាភេរវករក្តី។[904]

ករណីខាងលើនេះ បង្ហាញអំពីភាពរាំងស្ទះ។ រដ្ឋបានប្រើប្រាស់ការធានាជាលក្ខណៈនយោបាយ (Political Assurance) ផ្តល់ដោយរដ្ឋស្នើសុំ ដល់រដ្ឋបញ្ជូន ដើម្បីឲ្យរដ្ឋនេះបញ្ជូន។[905] ការធានា មិនបានចងជាកាតព្វកិច្ច មិនអាចលុបបំបាត់គ្រោះថ្នាក់នៃអំពើទារុណកម្មទេ។ គ្មានយន្តការតាមដាននូវស្ថានភាពរបស់បុគ្គល ក្រោយពេលគាត់ ត្រូវបានបញ្ជូនទៅដល់ដែនដីរបស់រដ្ឋស្នើសុំ។[906] ការធានា នឹងមិនមានប្រសិទ្ធភាពទេ ក្នុងករណីដែលរដ្ឋស្នើសុំជារដ្ឋសហព័ន្ធ។[907] ជាចុងក្រោយ ខុសអំពី ទោសប្រហារជីវិត ដែលនៅតែ

[903] The Refugee Convention, *supra* note 89, Art. 33.
[904] The Torture Convention, *supra* note 251, Art. 3.
[905] UN Model Treaty, *supra* note 888, Art. 4; Matthias WENTZEL, *Extradition Involving the Possibility of Death Penalty*, 62 International Review of Penal Law, 335 (1991).
[906] *Soering v. the United Kingdom*, *supra* note 178, paras. 69 and 83.
[907] *Id.,* para.128.

អនុញ្ញាតក្រោមច្បាប់អន្តរជាតិ[908] អំពើទារុណកម្មត្រូវបានហាមឃាត់ជាដាច់ខាត។[909]

ដំណោះស្រាយមួយ ដែលនាំឲ្យរដ្ឋមិនធ្វើខុសច្បាប់អន្តរជាតិ សន្តិសុខរបស់បុគ្គលត្រូវបានធានា ហើយគាត់នឹងមិនរួចចេញពីសំណាញ់ច្បាប់ គឺការបញ្ជូនជននោះទៅទទួលទោសក្នុងរដ្ឋ ដែលមិនធ្វើទារុណកម្មលើបុគ្គលនោះ។[910] ជំនួសឲ្យការបញ្ជូនបុគ្គលណាមួយទៅទទួលគ្រោះថ្នាក់ នៃអំពើទារុណកម្ម រដ្ឋដែលឧក្រិដ្ឋជនស្នាក់នៅ អាចកាត់ទោសជននោះ។ ដូចនេះ ការតាក់តែងច្បាប់ ផ្តល់យុត្តាធិការឲ្យតុលាការកាត់ទោស គួរត្រូវបានជំរុញ និងលើកទឹកចិត្ត។[911]

### ១០.១.១.៥. ការជួយគ្នាក្នុងវិស័យតុលាការ

ការជួយគ្នាក្នុងវិស័យតុលាការ ជាយន្តការមួយជួយកាត់បន្ថយភាពស្មុគស្មាញក្នុងការកាត់សេចក្តី។ ការជួយគ្នាក្នុងវិស័យតុលាការ សំដៅលើការជួយរបស់រដ្ឋមួយ ដល់រដ្ឋមួយទៀត ដូចជាការជួយចាប់ខ្លួន ការជួយប្រមូលភស្តុតាង និងការសាកសួរសាក្សី។[912] មានវិធាន និងគោលការណ៍មួយចំនួន

[908] The ICCPR, *supra* note 56, Art. 6.
[909] For Notion of the Peremptory Norm, *see* the Article 53 of the VCLT, *supra* note 36. It is according to Sir Elihu Lauterpacht and Daniel Bethlehem, *the Scope and Content of the Principle of Non-Refoulement*, in REFUGEE PROTECTION IN INTERNATIONAL LAW: UNHCR'S GLOBAL CONSULTATIONS ON INTERNATIONAL PROTECTION 74 (Erika Feller, Volker Turk and Frances Nicholson, ed. 2003).
[910] The Torture Convention, *supra* note 189, Art. 3.
[911] *Id.*, Arts. 4,5 and 7.
[912] 2004 ASEAN Treaty on Mutual Assistance in Criminal Matters, Art. 1. Cambodia is one of signatures (www.asean.org).

ស្រដៀងគ្នា សម្រាប់ប្រើក្នុងករណីបត្យាប័ន។[913] បន្ថែមពីលើនេះ រដ្ឋដែលជួយគ្នាក្នុងវិស័យតុលាការ ត្រូវតែគោរពទៅតាមកាតព្វកិច្ច ក្រោមច្បាប់ជាតិដែលរដ្ឋជាភាគី។[914]

## ១០.២. ការទទួលខុសត្រូវរបស់រដ្ឋ

ជំពូកមុនបានពិភាក្សារួចហើយអំពីការទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌរបស់បុគ្គល។ ជំពូកនេះ នឹងនិយាយអំពីការទទួលខុសត្រូវរបស់រដ្ឋ។ មុននឹងបរិយាយ វាជាការចាំបាច់ក្នុងការ បង្ហាញពីភាពខុសគ្នារវាង ការទទួលខុសត្រូវទាំងពីរ ប្រភេទនេះ។

ការទទួលខុសត្រូវរបស់រដ្ឋ គឺសម្រាប់អំពើធ្វើដោយរដ្ឋ ឬ ការចូលរួមរបស់រដ្ឋដែលខុសនឹងកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ។ ការទទួលខុសត្រូវរបស់រដ្ឋតម្រូវឲ្យរដ្ឋសងនូវសំណងខូចខាត ដោយប្រើថវិកាជាតិរបស់ខ្លួន ផ្ទុយពីការទទួលខុសត្រូវរបស់បុគ្គល ដែលបុគ្គលខ្លួនឯងជាអ្នកសងសំណង នៅពេលដែលតុលាការរកឃើញថា បុគ្គលមានទោស។ រដ្ឋាភិបាល ដោយមានការអនុញ្ញាត ពីសភាជាតិ បានធ្វើកិច្ចព្រមព្រៀងខ្ចីលុយពី បរទេស ដែលតាមរយៈកិច្ចព្រមព្រៀងនេះ ត្រូវសងលុយទៅតាមការឯកភាព។ ប្រសិនបើខកខានមិនបានសងលុយទេ រដ្ឋនឹងអាចត្រូវបានចោទថារំលោភកាតព្វកិច្ច នឹងទាមទារឲ្យមានការសងសំណង។ នេះគឺជាការទទួលខុសត្រូវចំពោះ អំពើ

---

[913] For example, like extradition, judicial assistance will be refused if an offence connected to a political offence, *see* the European Convention on Mutual Assistance in Criminal Matters, 20 April 1959, Treaty Series No, 24 (1992), Art. 2.

[914] 2009 Treaty between Cambodia and Malaysia on Mutual Assistance in Criminal Matters, Art.1.

រំលោភកាតព្វកិច្ចក្រោមកិច្ចសន្យាទ្វេភាគី។ មិនមានសន្ធិសញ្ញាជាក់លាក់ ឬលម្អិត នៅឡើយដែលនិយាយអំពីការទទួលខុសត្រូវ របស់រដ្ឋជាពិសេស ក្នុងទម្រង់ពហុភាគី ។[915] នេះខុសអំពី ការទទួលខុសត្រូវរបស់បុគ្គល ដែលត្រូវបានចែងឡើង ដោយសន្ធិសញ្ញា និងកិច្ចព្រមព្រៀងជាច្រើន ហើយស្ថាប័នជាច្រើនចាប់តាំងពីក្រោយសង្គ្រាមលោកលើកទី ២ ដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានបង្កើតឡើងដើម្បីអនុវត្ត។

### ១០.២.១. កំហុសជាអន្តរជាត

ដើម្បីឲ្យរដ្ឋមួយទទួលខុសត្រូវ វាទាមទារជាតុផ្សំចំនួនពីរ។ ទី១ អំពើរបស់រដ្ឋ និង អំពើត្រូវតែខុសច្បាប់អន្តរជាតិ។ អំពើ អាចជាអំពើជាក់ស្តែង[916] ឬជាការខកខានមិនបានបំពេញតាមកាតព្វកិច្ច ដូចជា ការទាមទារឲ្យស្វែងរកឧក្រិដ្ឋជន តែរដ្ឋមិនបានអនុវត្តតាម។[917] អំពើ អាចត្រូវបានធ្វើឡើងដោយភ្នាក់ងាររបស់រដ្ឋ ដូចជាមន្ត្រីក្នុងតុលាការ ក្នុងករណីតុលាការខកខានមិនបានស៊ើបអង្កេតបទឧក្រិដ្ឋ ក្រោមច្បាប់អន្តរជាតិណាមួយ។ នេះជាអំពើរបស់រដ្ឋ។ រដ្ឋក៏អាចទទួលខុសត្រូវចំពោះអំពើណាមួយ ប្រព្រឹត្តដោយបុគ្គល ឬក្រុមហ៊ុនឯកជន ដែលភ្នាក់ងាររបស់រដ្ឋ បានផ្តល់ការព្រមព្រៀងឲ្យធ្វើ[918] ឬបានចូលរួមប្រកាសទទួលយកអំពើទាំងនោះ ដូចជារបស់ខ្លួន។[919] នៅក្នុងរឿងក្តី USA ប្តឹងប្រឆាំងនឹង Iran តុលាការយុត្តិធម៌អន្តរជាតិ បានអះអាងថា ទោះបីជា

---

[915] It is a responsibility for violation of human rights treaties or humanitarian law, for example.
[916] Draft Articles, States, *supra* note 81, Art. 2.
[917] *Id.*, Art. 2.
[918] *Id.,* Art. 20.
[919] *Id.,* Art.11.

Iran មិនបានចូលរួមពីដំបូងជាមួយចលនានិស្សិត ដែលទន្ទ្រានស្ថានទូត និងចាប់មន្ត្រីទូតរបស់សហរដ្ឋអាមេរិកនៅក្នុង Iran តែក្រោយមក តាមរយៈសេចក្តីថ្លែងការណ៍របស់រដ្ឋនេះ រដ្ឋគាំទ្រនូវអំពើរបស់និស្សិត Iran ដែលនាំឲ្យ Iran ត្រូវទទួលខុសត្រូវចំពោះ អំពើនេះ។[920]

អំពើរបស់រដ្ឋ មិនចាំបាច់ប្រព្រឹត្តនៅក្នុងដែនដីរបស់ខ្លួន ទើបនាំឲ្យមានការទទួលខុសត្រូវទេ។ អំពើកើតនៅក្រៅដែនដី ប្រព្រឹត្តដោយភ្នាក់ងាររបស់ខ្លួនក៏ទាមទារឲ្យរដ្ឋទទួលខុសត្រូវផងដែរ។ តុលាការឧទ្ធរណ៍របស់ប្រទេស ហូឡង់ដ៍ ថ្មីៗនេះ បានអះអាងថា អំពើរបស់ ទាហានហូឡង់ដ៍ នៅក្រៅប្រទេសក្រោមការគ្រប់គ្រងមានប្រសិទ្ធភាពរបស់មេបញ្ជាការហូឡង់ដ៍ នាំឲ្យមានការរំលោភសិទ្ធិរបស់ជនបរទេស ហូឡង់ដ៍ ត្រូវទទួលខុសត្រូវ។[921] ក្នុងវិស័យសិទ្ធិមនុស្ស រដ្ឋបញ្ជូនទទួលខុសត្រូវចំពោះ អំពើទារុណកម្ម (រំលោភសិទ្ធិបុគ្គល) ដោយអាជ្ញាធរបរទេស នៅលើទឹកដីរបស់រដ្ឋនោះ ដែលជាលទ្ធផលនៃការបណ្តេញចេញ ឬបត្យាប័នដោយរដ្ឋបញ្ជូន។[922] ការទទួលខុសត្រូវរបស់រដ្ឋត្រូវបាន ពង្រីកដោយច្បាប់អន្តរជាតិ ដែលប្រែប្រួលទៅតាម វិសាលភាពកាន់តែធំឡើង ៗ នៃកាតព្វកិច្ចរបស់រដ្ឋ។

អំពើនោះ មិនចាំបាច់ប្រព្រឹត្តដោយ អង្គទាំងបីរួមគ្នា (ស្ថាប័ននីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ) របស់រដ្ឋនោះទេ។ ប្រសិនបើ ច្បាប់អន្តរជាតិទាម

920 ICJ, United States Diplomatic and Consular Staff in Tehran, I.C.J, Reports 1980, p.35, para. 74.

921 In file of the author.

922 The Torture Convention, *supra* note 189, Art. 3; HRC, General Comment No. 20 on Prohibition of torture, or other cruel, inhuman or degrading treatment or punishment (1992), para.9; CAT, General Comment No.1: Implementation of Article 3 of the Convention in the Context of Article 22 (*Refoulement* and communication).

ទារ ឲ្យសភាធ្វើច្បាប់ ដើម្បីបើកផ្លូវឲ្យតុលាការធ្វើការកាត់ទោសជនណាមួយ ហើយសភាមិនបានធ្វើច្បាប់ នាំឲ្យមានការខកខានក្នុងការកាត់ទោសជនណាមួយនោះ វាជាការគ្រប់គ្រាន់រួចហើយ ថារដ្ឋបានប្រព្រឹត្តខុស ហើយនាំឲ្យមានការទទួលខុសត្រូវ។ នេះជាពិសេសអនុវត្តន៍ ក្នុងវិស័យសិទ្ធិមនុស្ស។

អំពើទាំងនោះ ត្រូវតែខុសជាមួយកាតព្វកិច្ច ក្រោមច្បាប់អន្តរជាតិ។ វាជាកាតព្វកិច្ច ចែងក្រោមសន្ធិសញ្ញា ទ្វេភាគី ឬពហុភាគី ឬកាតព្វកិច្ច ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។[923]

### ១០.២.២. ការទទួលខុសត្រូវរួម

អំពើដែលប្រព្រឹត្ត ខុសច្បាប់អន្តរជាតិ អាចត្រូវបានប្រព្រឹត្តដោយរដ្ឋជាច្រើន ដូចនេះរដ្ឋ ដែលពាក់ព័ន្ធ នឹងចូលរួមទទួលខុសត្រូវ តាមចំណែកខុសរបស់ខ្លួន។[924] សមាជិករបស់ NATO ធ្វើសកម្មភាពណាមួយ ក្រោមប្រតិបត្តិការរបស់ NATO ដែលខុសនឹងច្បាប់អន្តរជាតិ អាចនឹងនាំឲ្យទាំង NATO និងរដ្ឋដែលពាក់ព័ន្ធទទួលខុសត្រូវរួមគ្នា។[925]

### ១០.២.៣. មូលដ្ឋាន នាំឲ្យរួចខ្លួនពីការទទួលខុសត្រូវ

ស្រដៀងគ្នានឹងការទទួលខុសត្រូវរបស់បុគ្គលផងដែរ ទោះបីជារដ្ឋ បានប្រព្រឹត្តខុសច្បាប់អន្តរជាតិក្តី រដ្ឋអាចនឹងទទួលបាននូវការរួចផុតពីការទទួលខុសត្រូវ។ រដ្ឋមួយបានព្រមព្រៀងមានសុពលភាព (Valid Consent)

[923] James, Drafted Articles, *supra* note 43, p. 83.
[924] *Id.*, p. 272.
[925] ECHR, *Behrami v. France and Saramati v. France*, Germany and Norway, (dec.) [GC], nos. 71412/10 and 78166/01) ECHR, 2 May 2007.pp. 41-42.

ឲ្យរដ្ឋមួយ ធ្វើសកម្មភាពដែលផ្ទុយនឹងច្បាប់អន្តរជាតិ រដ្ឋប្រព្រឹត្តនឹងមិនទទួលខុសត្រូវទេ។[926] ប្រធានសក្តិ[927] ស្ថានភាពចាំបាច់[928] និង ការប្រព្រឹត្តអំពើមួយក្រោមសម្ពាធ (Distress) ក៏ជាមូលដ្ឋានដែលនាំមិនឲ្យមានការទទួលខុសត្រូវ ផងដែរ។[929] វាខុសគ្នាជាចម្បង នៃមូលដ្ឋានទាំងនេះ ដូចជា ព្រឹត្តិការណ៍នៃប្រធានសក្តិកើតឡើងដោយមិនដឹងខ្លួនជាមុន។ ដោយសារខ្យល់ព្យុះ ធ្វើឲ្យនាវារបស់រដ្ឋមួយ មិនអាចបើកតាមសមុទ្រអន្តរជាតិ ដែលបង្ខំឲ្យអ្នកបើក បើកចូលក្នុងដែនសមុទ្ររបស់រដ្ឋមួយទៀត។ សម្រាប់ស្ថានភាពចាំបាច់ អាជ្ញាធររដ្ឋមួយ ដែលស្ថិតនៅក្នុងសភាពគ្រោះអាសន្ន មានចេតនាត្រូវបង្ខំចិត្តធ្វើអំពើល្មើសអ្វីមួយ ដើម្បីការពារប្រយោជន៍អ្វីមួយ ដែលមានទំហំធំធេងជាងអ្វី ដែលនឹងត្រូវបាត់បង់។[930] ក្នុងរឿងក្តី Gabcikovo-Nagymaros Project ប្រទេស ហុងគ្រី បានលើកឡើងថា ដោយសារមានភាពចាំបាច់ក្នុងការការពារបរិស្ថាន ខ្លួនត្រូវបញ្ឈប់គម្រោងសាងសង់ទំនប់ទឹក ឯកភាពឡើងដោយភាគីទាំងពីរ។ តុលាការ

យុត្តិធម៌អន្តរជាតិ បានឯកភាពនូវការអះអាងនេះ។[931] រដ្ឋនឹងមិនទទួលខុសត្រូវផង ដែរចំពោះអំពើតម្រូវដោយ កាតព្វកិច្ចដែលមានចរិតជា *Jus Cogens* ដែលនាំឲ្យមានការផ្អាកការអនុវត្តកាតព្វកិច្ចណាមួយចំពោះរដ្ឋដទៃ។[932] ដូចគ្នានេះ រដ្ឋត្រូវបំពេញកាតព្វកិច្ចទាមទារដោយមាត្រា ១០៣

[926] Draft Articles, States, *supra* note 21, Art. 20.
[927] *Id.*, Art. 23.
[928] *Id.*, Art. 25.
[929] *Id.*, Art. 24.
[930] James, Drafted Articles, *supra* note 43, p. 174
[931] ICJ, Gabcikovo-Nagymaros (Hungry/Slovakia), I.C.J Rports 1997, p.7.
[932] Draft Articles, States, *supra* note 81, Art. 26.

នៃច្បាប់ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ដែលតម្រូវឲ្យមានការ ផ្អាក ការអនុវត្តកាតព្វកិច្ចណាមួយ ដែលការខកខាននេះ ជាការរំលោភកាតព្វកិច្ចអន្តរជាតិ។[933] ទោះបីជាយ៉ាងនេះក្តី មូលដ្ឋានទាំងពីរខាងក្រោមនេះ មានភាពចម្រូងចម្រាស ពាក់ព័ន្ធនឹង អ្វីជាកាតព្វកិច្ច *Jus Cogens* និងវិសាលភាពនៃកាតព្វកិច្ច ក្រោមមាត្រា ១០៣។

### ១០.២.៤. វិធានការឆ្លើយតបចំពោះការរំលោភកាតព្វកិច្ចអន្តរជាតិ

នៅពេលមានការរំលោភកាតព្វកិច្ច រដ្ឋដែលរងគ្រោះ អាចចាត់វិធានការ ដើម្បីឆ្លើយតប (Countermeasure)។[934] វិធានការនេះ មានគោលបំណងដើម្បីឲ្យរដ្ឋបំពានកាតួពកិច្ចផ្អាកការបំពាននោះ។ ផលវិបាកនៃវិធានការ ត្រូវតែមានសមមាត្រ នឹងអ្វីដែលរដ្ឋរងគ្រោះ (រដ្ឋប្រកាន់យកវិធានការ) ទទួលរង។ រដ្ឋមិនអាចធ្វើសង្គ្រាម ដោយសារតែរដ្ឋមួយបានបង្ខាំងកប៉ាល់ដឹកទំនិញរបស់ខ្លួនឡើយ។ នៅក្នុងរឿងក្តី Gabcikovo-Nagymaros Project តុលាការយុត្តិធម៌អន្តរជាតិ បានអះអាងថា ប្រទេសឆេកូស្លូវ៉ាគី បានបង្កើតទំនប់ទឹកថ្មី ដែលនាំឲ្យមានការបង្វែរ មុខព្រួញទឹក ប៉ះពាល់ដល់ប្រជាពលរដ្ឋរស់នៅ ដើម្បីជាការឆ្លើយតបចំពោះ រដ្ឋម្ខាងបានផ្អាកធ្វើគម្រោង ដែលបង្កជាផលប៉ះពាល់ធ្ងន់ធ្ងរ ហើយមិនបានបំពេញតាមលក្ខខណ្ឌនៃសមមាត្រឡើយ។ ដូចនេះ វាជាវិធានការឆ្លើយតបមិនស្របច្បាប់។[935] គេគួរកត់សម្គាល់ផងដែរថា រដ្ឋមិនអាចឆ្លើយតបចំពោះ អំពើរបស់រដ្ឋមួយ ដែលធ្វើ

---

[933] The UN Charter, *supra* note 42, Art. 103.

[934] Draft Articles, States, *supra* note 81, Arts. 22, 49 and Chapter as a whole.

[935] ICJ, Gabcikovo-Nagymaros, *supra* note 931, paras. 85, 87.

តម្រូវតាម *Jus Cogens* ហើយបានរំលោភកាតព្វកិច្ចចំពោះខ្លួនឡើយ។ ជាចុងក្រោយ ការឆ្លើយតបត្រូវតែបានធ្វើឡើងភ្លាម ៗ។[936]

លក្ខខណ្ឌសមមាត្រ ទទួលបានភាពចម្រូងចម្រាស នៅក្នុងករណី ដែលរដ្ឋមួយឆ្លើយតប អំពើវាយប្រហារប្រើអាវុធ នុយក្លេអ៊ែរ ដែលរដ្ឋប្រើសិទ្ធិការពារខ្លួនឯងអាចប្រើនូវអាវុធនុយក្លេអ៊ែរផងដែរ។ សិទ្ធិការពារខ្លួន គឺជាវិធានការឆ្លើយតបមួយស្របច្បាប់ ដែលអនុញ្ញាតដោយច្បាប់ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ[937] ហើយការប្រើអាវុធនុយក្លេអ៊ែរក្នុង ករណីនេះ មិនទាន់ត្រូវបានហាមឃាត់ ឬអះអាងថាផ្ទុយនឹងច្បាប់អន្តរជាតិឡើយ។ ទោះបីជាយ៉ាងនេះក្តី រដ្ឋប្រើអាវុធប្រភេទនេះ ត្រូវទទួលខុសត្រូវចំពោះការរំលោភវិធានច្បាប់មនុស្សធម៌អន្តរជាតិ។[938]

ការស្នើឲ្យមានការទទួលខុសត្រូវ អាចធ្វើឡើងដោយរដ្ឋរងគ្រោះ ដែលមានតែម្នាក់ឯង។ ក្នុងករណីខ្លះអំពើដោយរដ្ឋមួយ រំលោភនូវកាតព្វកិច្ចចម្បងដែលមានរដ្ឋរងគ្រោះជាច្រើន។[939] នេះនាំឲ្យមានភាពស្មុគស្មាញ។ ក្នុងករណីនេះ តើអង្គការសហប្រជាជាតិអាចធ្វើការឆ្លើយតបបានឬទេ ?។

## ១០.២.៥. ការលើកឡើងឲ្យមានការទទួលខុសត្រូវ

ការនាំឲ្យមានការទទួលខុសត្រូវ ចាប់ផ្តើមពីការដាក់ពាក្យ (International Claim) អះអាងថាខ្លួនជារដ្ឋរងគ្រោះដោយអំពើណាមួយរបស់រដ្ឋ។[940] រដ្ឋ

---

[936] Draft Articles, States, *supra* note 81, Art. 50.
[937] *Id.,* Art. 21; the UN Charter, *supra* note 42, Art. 51.
[938] ICJ, the Legality of the Threat, *supra* note 290, para. 79.
[939] Draft Articles, States, *supra* note 81, Arts. 40, 41 and 46.
[940] *Id.*, Art. 43.

អាចចាប់ផ្តើមអ្វីការចរចា រកដំណោះស្រាយ។ ប្រសិនបើការដោះស្រាយ មិនទទួលបានអ្វីគាប់ចិត្ត ភាគីអាចប្តឹងជាផ្លូវការទៅកាន់តុលាការអន្តរជាតិ។

រដ្ឋរងគ្រោះអាចមិនស្នើសុំឲ្យមានការទទួលខុសត្រូវ ឬបោះបង់ចោលនូវការស្នើសុំឲ្យមានការទទួលខុសត្រូវ។ នេះជាសិទ្ធិ និងអធិបតេយ្យភាពរបស់រដ្ឋរងគ្រោះ។ រដ្ឋដែលបោះបង់ នឹងមិនអាចស្នើសុំឲ្យមានការទទួលខុសត្រូវវិញឡើយ។[941] ការបោះបង់ នឹងមិនបានបញ្ឈប់នូវការទទួលខុសត្រូវរបស់រដ្ឋប្រព្រឹត្តខុសច្បាប់អន្តរជាតិទេ ប្រសិនបើមានរដ្ឋរងគ្រោះជាច្រើន ដែលរដ្ឋនោះ មិនបានបោះបង់។ ដូចនេះ ការបោះបង់ ដែលនាំឲ្យបញ្ចប់ការទទួលខុសត្រូវ បានតែក្នុងករណីរំលោភកាតព្វកិច្ចទ្វេភាគីតែប៉ុណ្ណោះ ឬរដ្ឋរងគ្រោះទាំងអស់បោះបង់ចោលការសុំឲ្យមានការទទួលខុសត្រូវ។

### ១០.២.៦. ផលវិបាកនៃការរំលោភកាតព្វកិច្ច

រំលោភកាតព្វកិច្ច នឹងនាំឲ្យមានផលវិបាក ប្រសិនបើរកឃើញថាមានការរំលោភកាតព្វកិច្ច ពិតមែនដោយតុលាការ។ រដ្ឋប្រព្រឹត្តខុស មានកាតព្វកិច្ចផ្តល់ដល់រដ្ឋរងគ្រោះ នូវការជួសជុល ដែលមានជាសំណង (Compen sation) និង អ្វីផ្សេងទៀតទៅតាម សេចក្តីសម្រេចរបស់តុលាការ ដូចជាការធានាមិនឲ្យមាន អំពើខុសឆ្គងស្រដៀងគ្នានេះ កើតមាននាពេលអនាគត។[942] ច្បាប់អន្តរជាតិ ក៏បានចែងផ្តល់នូវការធ្វើឲ្យរដ្ឋរងគ្រោះពេញចិត្ត (Sastification) ដូចជាការតម្រូវឲ្យរដ្ឋប្រព្រឹត្តខុស សារភាពកំហុស ឬ សុំ

---

[941] Andrea Gattini, *A return ticket to 'communitarisme', please*, 13 EJIL (2002), p. 1197; *id.*, Art. 45.

[942] Draft Articles, States, *supra* note 81, Part Two, Chapter II on Reparation for Injury.

អភ័យទោស។[943] ការធ្វើឲ្យមានស្ថានភាពដូចដើមវិញ ឧទាហរណ៍ ការ ដោះលែងប្រជាពលរដ្ឋរបស់រដ្ឋរងគ្រោះ ចេញពីមន្ទីរឃុំឃាំងដោយរដ្ឋប្រព្រឹត្ត ខុស ( Restitution) ក៏ជាវិធានការមួយស្ថិតនៅក្នុង សំណង (Reparatio-n)។[944] ករណីខ្លះទៀត វាគ្រាន់តែជាសំណងនិមិត្តរូប តម្រូវរដ្ឋប្រព្រឹត្តខុស សងសំណងតែមួយ ដុល្លារសហរដ្ឋអាមេរិក ជាការគ្រប់គ្រាន់ហើយ។[945] ជាចុងក្រោយ ការប្រកាសសាលក្រមរកឃើញថា រដ្ឋណាមួយបានប្រព្រឹត្តខុស នឹងច្បាប់អន្តរជាតិ គឺជាការគ្រប់គ្រាន់ហើយផងដែរ។[946] តាមការបរិយាយនេះ យើងអាចនិយាយបានថា ប្រភេទសំណងណាមួយ វាអាស្រ័យទៅតាមករណីជាក់ស្តែង និងសេចក្តីសម្រេចរបស់តុលាការ។

អ្វីជាសំណងជាបញ្ហាមួយ ហើយការអនុវត្តសំណង ជាបញ្ហាមួយ ដែលមានភាពចម្រូងចម្រាសផងដែរ។ ដោយសារតែយន្តការអនុវត្តច្បាប់អន្តរជាតិ មិនសូវមានប្រសិទ្ធភាព រដ្ឋខ្លះ មិនបានអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការអន្តរជាតិទេ។ សម្រាប់សាលក្រមរបស់តុលាការអន្តរជាតិ ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ជាស្ថាប័នបង្ខំអនុវត្តសាលក្រម ក្នុងករណីដែលរដ្ឋមិនបានបំពេញតាមសេចក្តីទាមទារក្នុងសាលក្រម។ មិន មានករណីច្រើន នៃការខកខានមិនបានបំពេញតាមសាលក្រម របស់តុលាការអន្តរជាតិទេ ដោយសាររដ្ឋ បានឯកភាពគោរពនូវសាលក្រម ហើយរដ្ឋបានចរចា

[943] *Id.,* Art. 37.

[944] *Id.,* Art. 35.

[945] Use or threat of force, application of the convention on prevention and punishment of the crime of genocide (*Bosnia and Herzegovina/Yugoslavia*), judgement of 11 July 1996 and 26 February 2007, pp. 969 and 973.

[946] The M/V "Saiga"(No.2) (Saint Vincent and the Grenadines v. Guinea), International Ribunal for the Law of the Sea, Judgement of 1 July 1999, para. 176.

អស់លទ្ធភាពរួចហើយ មុនសម្រេចចិត្តប្តឹងមកតុលាការយុត្តិធម៌អន្តរជាតិ ដែលជាជម្រើសចុងក្រោយ។

### ១០.២.៧. ការទទួលខុសត្រូវ ក្រោមសន្ធិសញ្ញាផ្សេងទៀត

ការបរិយាយ អំពីការទទួលខុសត្រូវខាងលើ សំដៅលើការទទួលខុសត្រូវរបស់រដ្ឋមួយចំពោះរដ្ឋមួយទៀត។ នៅមានការទទួលខុសត្រូវរបស់រដ្ឋ ចំពោះបុគ្គល។ នេះកើតមានជាសំខាន់ ពាក់ព័ន្ធនឹងការការពារ និង លើកកម្ពស់សិទ្ធិមនុស្ស។ តាមសន្ធិសញ្ញាសិទ្ធិមនុស្ស រដ្ឋមានកាតព្វកិច្ចមួយចំនួនក្នុងការធានាឲ្យមានការគោរពសិទ្ធិមនុស្សពេញលេញ។ ក្នុងករណី រដ្ឋខកខានមិនបានបំពេញតាមកាតព្វកិច្ច ដែលតម្រូវនេះទេ រដ្ឋនឹងទទួលខុសត្រូវដូចជា ផ្តល់សំណងដល់ជនរងគ្រោះ នៃអំពើរំលោភសិទ្ធិ ដោយ អាជ្ញាធររបស់រដ្ឋ[947] ឬកែសម្រួលច្បាប់ ដែលនាំឲ្យមានការរំលោភនូវសិទ្ធិសេរី ភាព។ សេចក្តីបរិយាយលម្អិត សូមពិនិត្យមើលជំពូក ដែលនិយាយអំពីសិទ្ធិមនុស្ស។

### ១០.២.៨. ការទទួលខុសត្រូវរបស់សហគមន៍អន្តរជាត

ដោយសារតែមានជម្លោះជាច្រើន ហើយអង្គការសហប្រជាជាតិ មិនមានអំណាចគ្រប់គ្រាន់ក្នុងការដោះស្រាយ អ្នកសិក្សាស្រាវជ្រាវ បានបង្កើតនូវទ្រឹស្តី ការទទួលខុសត្រូវរបស់សហគមន៍អន្តរជាតិ (international comm unity)។ ការទទួលខុសត្រូវនេះ ជាសំខាន់គឺ ឆ្លើយតបទៅនឹង ការបំពារបំពានធ្ងន់ធ្ងរច្បាប់អន្តរជាតិ ដែលនាំឲ្យមានការគំរាមកំហែង ដល់សន្តិសុខ ឬ

[947] The ICCPR, *supra* note 56, Art. 2 ; the UDHR, *supra* note 371, Art. 8.

សន្តិភាពពិភពលោក។ នេះតម្រូវឲ្យ សហគមន៍អន្តរជាតិ មានការទទួលខុសត្រូវ ជានា និងធ្វើយ៉ាងណាបង្ការ និង បញ្ឈប់ការបំពារបំពានច្បាប់អន្តរជាតិ។

ទោះបីជាយ៉ាងនេះក្តី ការដាក់ការទទួលខុសត្រូវនេះ មានភាពចម្រូងចម្រាស ដោយសារតែ អ្វីទៅជាសហគមន៍អន្តរជាតិ? តើរដ្ឋចំនួនប៉ុន្មាន ទើបអាចចាត់ថាជា សហគមន៍អន្តរជាតិ? តើអង្គការសហប្រជាជាតិ អាចត្រូវបានចាត់ជាសហគមន៍អន្តរជាតិដែរឬទេ? បញ្ហាវានឹងកើតមានពាក់ព័ន្ធនឹងអំណាច និងវិសាលភាពការងារ ស្មើសម្រាប់សហគមន៍អន្តរជាតិ ពីព្រោះវាត្រូវបាន បង្កើតឡើងដោយរដ្ឋ។ អ្វីដែលសំខាន់គឺការមិនទុកចិត្តរបស់រដ្ឋដែលខ្លាច ប្រទេសមហាអំណាច យកលេសដើម្បីវាយប្រហារប្រទេសតូចតាចក្រោមស្លាកសហគមន៍អន្តរជាតិ។

វាមានការចាំបាច់ ក្នុងការធ្វើការបែងចែកខុសគ្នារវាងការទទួលខុសត្រូវ លើការងារ និងការទទួលខុសត្រូវ នាពេលដែលសហគមន៍អន្តរជាតិ អង្គការអន្តរជាតិ ប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់អន្តរជាតិ។ ជំពូក បរិយាយអំពី អង្គការអន្តរជាតិ នឹងបរិយាយអំពីប្រធានបទនេះ។

# ជំពូក ១១
# វិស័យផ្សេងទៀតនៃច្បាប់អន្តរជាតិសាធារណៈ

## ១១.១. ច្បាប់សមុទ្រ
### ១១.១.១. ប្រវត្តិ

ច្បាប់សមុទ្រ ជាច្បាប់មួយមានប្រវត្តិយូរអង្វែងមកហើយ ហើយមានការវិវត្ត ចេញ ពីសកម្មភាពរបស់រដ្ឋមួយ ក្នុងវិស័យ ឧទាហរណ៍ នាវាចរណ៍ ដែលជះឥទ្ធិពល ដល់រដ្ឋដែលស្ថិតនៅឯផ្នែកម្ខាងនៃសមុទ្រ។ បញ្ហាពាក់ព័ន្ធសមុទ្រ ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់រដ្ឋ ដោយសារតែសមុទ្រ មានតួនាទីសំខាន់ជាច្រើន ដូចជាផ្តល់ធនធានធម្មជាតិ សមុទ្រជាផ្លូវដឹក ជញ្ជូនទំនិញជាដើម។ ស្របពេលដែល រដ្ឋអភិវឌ្ឍន៍ បាននូវបច្ចេកវិទ្យាទំនើប និងកំណើនតម្រូវការធ្វើដំណើរតាមសមុទ្រ ការអះអាងទាមទារនូវអធិប តេយ្យភាពលើដែនសមុទ្រ មានកំណើនកាន់តែច្រើន។

អង្គការសង្គមប្រជាជាតិ បានព្យាយាមធ្វើសន្ធិសញ្ញា ស្តីពី ដែនសមុទ្រ របស់រដ្ឋ (Territorial Sea) ក្នុងឆ្នាំ ១៩៣០ ក៏ប៉ុន្តែកិច្ចការងារនេះ ទទួលបរាជ័យ ហើយមិនបានដាក់ចេញនូវសេចក្តីព្រាងណាមួយឡើយ។ ក្រោយឆ្នាំ ១៩៤៥ គណៈកម្មការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិ បង្កើតឡើងដោយ មហាសន្និបាតអង្គការសហប្រជាជាតិ បានចាត់ថាបញ្ហា សមុទ្រ ជាបញ្ហាមួយមានអាទិភាព សម្រាប់ការចងក្រង និងការអភិវឌ្ឍវិធាន ដែលពាក់ព័ន្ធ ហើយឆ្នាំ ១៩៥៦ សេចក្តីព្រាងដំបូងត្រូវបានបង្កើតឡើង។ ឆ្នាំ

១៩៥៨ សន្និសីទរបស់តំណាងរដ្ឋ (Diplomatic Conference) លើកទី១ បានត្រូវធ្វើឡើង ហើយបានអនុម័តចេញ សន្និសញ្ញាចំនួន បួន[948] ទោះបីជាបន្ទាប់ពីការពិភាក្សា យ៉ាងចម្រូងចម្រាស ជាពិសេសពាក់ព័ន្ធនឹងការឆ្លងកាត់របស់កប៉ាល់ចម្បាំងឆ្លងកាត់ដែនសមុទ្ររបស់រដ្ឋ និង បញ្ហា ខ្ពង់រាបបាតសមុទ្រ(Continental Self)។ គំនិតចង់ឲ្យមាន សន្និសញ្ញាចំនួន ៤ដោយឡែកៗ ពីព្រោះ បញ្ហាសមុទ្រវាជាបញ្ហាចម្រូងចម្រាស បើរដ្ឋជំទាស់ នឹងមាត្រាណាមួយនៃសន្និសញ្ញាមួយ រដ្ឋអាចចូលជាភាគីសន្និសញ្ញាមួយផ្សេងទៀត ដែលខ្លួនមិនជំទាស់។

សន្និសីទលើក ទី១ មិនបាននិយាយដាច់ស្រេចអំពី ចម្ងាយនៃដែនសមុទ្ររបស់រដ្ឋឡើយ។ រដ្ឋខ្លះ កំណត់យក ៣ miles ៦ miles ឬ ១២ miles ហើយបញ្ហានេះ ត្រូវបានលើកមកពិភាក្សា ក្នុងសន្និសីទលើកទី ២ក្នុងឆ្នាំ ១៩៦០។ មួយរយៈក្រោយមកទៀត បញ្ហាជាច្រើនទៀត ពាក់ព័ន្ធនឹងសមុទ្របានកើតមានឡើង ដូចជា ទស្សនៈ ស្តីពី មត៌ករួមរបស់មនុស្សលោក ដែលនាំឲ្យបង្កើតនូវ គណៈកម្មាធិការសម្រាប់បាតសមុទ្រ (Sea Bed Committee) បរិស្ថានក្នុងសមុទ្រ ដែលនាពេលនោះ អង្គការសហប្រជាជាតិបានរៀបចំសន្និសីទ លើកទី ១ ស្តីពី បរិស្ថានមនុស្ស (Human Environment) ក្នុងឆ្នាំ ១៩៧២ នៅក្នុងទីក្រុង Stockholm។ ក្រៅពីនេះ សន្និសញ្ញា ត្រូវបានកែសម្រួល ដោយបញ្ចូលនូវចម្ងាយ របស់ដែនសមុទ្ររបស់រដ្ឋរបបគ្រប់គ្រង សេរីភាពក្នុងការធ្វើនាវាចរណ៍ផងដែរ។ ក្នុងឆ្នាំ ១៩៨០

[948] The Territorial Sea and the Contiguous Zone; the High Sea; Fishing and Conservation of the Living Resources of the High Seas; and the Continental Shelf, *see* Brownlie's Documents, *supra* note 42.

សេចក្តីព្រាងត្រូវបានបង្កើតឡើង បន្ទាប់ពី គណៈកម្មការ បានធ្វើបញ្ជីនៃបញ្ហា ដែលគួរបញ្ចូលក្នុងសេចក្តីព្រាងសន្ធិសញ្ញា សម្រាប់ សន្និសីទលើកទី៣។ បន្ទាប់ពីកិច្ចពិភាក្សា ក្នុងសន្និសីទលើកទី៣ សន្ធិសញ្ញា ត្រូវបានអនុម័ត ក្នុងឆ្នាំ ១៩៨២ ដោយសំឡេងភាគច្រើន។[949]

សន្ធិសញ្ញា មានលក្ខណៈលម្អិត មាន ១៧ ផ្នែក និង ៩ ឧបសម្ព័ន្ធ។[950] ផ្នែកខ្លះ ឧទាហរណ៍ ជា Self-Contained Regime។[951] ឧបសម្ព័ន្ធត្រូវបានរាប់បញ្ចូល ជាផ្នែករបស់សន្ធិសញ្ញាផងដែរ។[952] សន្ធិសញ្ញា មិនអនុញ្ញាតឲ្យមាន ការចុះឧសន្យាមិនអនុវត្ត (Reservation)[953] ហើយលើកលែងមានបទប្បញ្ញត្តិផ្សេងអនុញ្ញាត។ វិធានក្នុងសន្ធិសញ្ញា ត្រូវបានអះអាងថាឆ្លុះបញ្ចាំងវិធានច្បាប់ ទំនៀមទម្លាប់អន្តរជាតិ ឧទាហរណ៍ វិធានពាក់ព័ន្ធសេរីភាពក្នុងការធ្វើនាវាចរណ៍។ រដ្ឋអាចធ្វើសេចក្តីថ្លែងការណ៍បាន។[954] ក្រោយមកក្នុងឆ្នាំ ១៩៩៤ មានកិច្ចព្រមព្រៀង បន្ថែមចំនួនពីរទៀត មួយក្នុងចំណោមនោះគឺ កិច្ចព្រមព្រៀងអនុវត្តន៍ផ្នែកទី ១១ នៃអនុសញ្ញា ឆ្នាំ

[949] The Convention was adopted *in* 10 December 1982, *entered into force* in 1994. As of July 2011, there are 167 States Parties. Thailand is the last one. Viet Nam ratified in 1994 with declaration, and party to the Implementing Agreement on Part XI in 2006. Cambodia only signed in 1983.

[950] The UNCLOS, *supra* note 30.

[951] It means that the treaty itself covers enough aspects, both norms and implementation mechanism, for the meaning of "self contained regime", *see* Brumo Simma and Dirk Pulkowski, *Leges Speciales and Self-Contained Regimes*, in James Crowford, the Law of State Reponsibility, p. 142 (2010).

[952] The UNCLOS, *supra* note 30, Art. 318.

[953] *Id.*, Art. 309.

[954] The UNCLOS, *supra* note 30, Art. 298.

១៩៨២។[955] បទប្បញ្ញត្តិខ្លះ នៃកិច្ចព្រមព្រៀងនេះ កែសម្រួលបទប្បញ្ញត្តិ អនុសញ្ញាឆ្នាំ ១៩៨២។ តាមខ្លឹមសារ រដ្ឋដែលចូលភាគីលើកិច្ចព្រមព្រៀង នេះ គឺត្រូវតែជាភាគីអនុសញ្ញាឆ្នាំ ១៩៨២ ផងដែរ។[956]

### ១១.១.១.១. បញ្ហាមួយចំនួនចែងក្នុងអនុសញ្ញា

#### ១១.១.១.១.១. ខ្សែមូលដ្ឋាន (Baseline)

ខ្សែមូលដ្ឋាន មានពីរប្រភេទ ទី១. ជាខ្សែធម្មតា ដែលគូសចេញពី កម្រិតទឹកនាចទាបបំផុត[957] និង ទី២. ខ្សែត្រង់ សម្រាប់ប្រើចំពោះប្រទេសមានបណ្តុំកោះច្រើន[958](ករណីប្រទេសហ្វីលីពីន)។ ខ្សែមូលដ្ឋានគឺខ្សែ ដែលខណ្ឌចែកដែនគោក នៅក្នុងនោះមាន ដែនទឹកខាងក្នុង និង ដែនសមុទ្ររបស់រដ្ឋ។[959] វាជាខ្សែមួយដ៏សំខាន់ ពីព្រោះការវាស់ចម្ងាយដែនសមុទ្រ តំបន់តភ្ជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ តំបន់ខ្ពង់រាបបាតសមុទ្រ ត្រូវគិតពីខ្សែមូលដ្ឋាននេះ។ ខ្សែមូលដ្ឋាន មិនអាចប្រែប្រួល តាមរដ្ឋចង់នោះឡើយ។

រដ្ឋអះអាងខ្សែមូលដ្ឋានថ្មី ដោយសារការប្រែប្រួល ដីមាត់សមុទ្រ ដែលធ្វើឲ្យកម្រិតទឹកនាចទាបបំផុត ផ្លាស់ទៅកាន់តែជ្រៅទៅក្នុងផ្នែកខាងសមុទ្រ តែទោះបីជាយ៉ាងនេះក្តី តាមផ្លូវច្បាប់ ការអះអាងនេះអាចនឹងពិបាកទទួលយក

---

[955] 1994 Agreement Relating to the Implementation of Part XI of the UNCLOS and 1995 Agreement for the Implementation of the Provisions of the United Nations Convention on the Law of the Sea relating the Conservation and Mamagement of Stradding Fish Stocks and Highly Migratory Fish Stocks.

[956] Thailand ratified both in 2011 with declaration attached to the UNCLOS, *see* http://www.un.org/Depts/los/reference_files/status2010.pdf; The 1994 Agreement, Art. 4(2).

[957] The UNCLOS, *supra* note 30, Art. 5.

[958] *Id.*, Art. 7.

[959] *Id.*, Art. 4.

ដោយរដ្ឋដទៃ។ ខ្សែមូលដ្ឋានក៏ នឹងមិនប្រែប្រួលដែរ តាមសំណាង់ ដែលរដ្ឋធ្វើក្នុងដែនសមុទ្រ ដែលតាមរយៈនេះ រដ្ឋអាចពង្រីកផ្ទៃសមុទ្រ។ សំណួរថាតើរដ្ឋមានសិទ្ធិធ្វើយ៉ាងដូចនេះដែរឬទេ? មានបណ្តឹង ដោយ ម៉ាឡេស៊ី ប្រឆាំងសឹង្ហបុរី ពាក់ព័ន្ធការកសាង Horsburgh Lighthouse on Pedra Branca/Pulau Batu Puteh ជាដែនកោះដែលភាគីទាំងពីរអះអាងថាជាដីរបស់ខ្លួន។[960]

### ១១.១.១.១.២. ដែនសមុទ្ររបស់រដ្ឋ

ក្នុងសម័យបុរាណ រដ្ឋមិនបានទាមទារចម្ងាយឆ្ងាយរបស់ដែនសមុទ្រ ពីដែនគោកឡើយ ដោយសារតែ បច្ចេកវិជ្ជាមិនទំនើប និងតម្រូវការសមុទ្រមិនមានច្រើន។[961] តែក្រោយមក ចម្ងាយវែងត្រូវបានទាមទារ ហើយមានការពិភាក្សាយ៉ាងខ្លាំង។ ចុងបញ្ចប់ ខ្នាត១២ miles ត្រូវបានដាក់បញ្ចូលក្នុង អនុសញ្ញាឆ្នាំ១៩៨២។[962] រដ្ឋមាន សិទ្ធិផ្តាច់មុខលើលំហអាកាសនៅពីលើដែនសមុទ្រ លើផ្ទៃសមុទ្រ (Ocean Surface) ក្នុងសមុទ្រ (Ocean Floor) បាតសមុទ្រ (Seabed) និង ក្រោមបាតសមុទ្រ (Subsoil)។[963] ការឆ្លងកាត់របស់ កប៉ាល់មុជទឹក ក្នុងដែនសមុទ្រ ត្រូវបង្ហាញខ្លួននៅលើផ្ទៃទឹក។[964] ទោះបីជា យ៉ាងនេះក្តី រដ្ឋត្រូវអនុញ្ញាតឲ្យមានការឆ្លងកាត់មិនបង្កគ្រោះថ្នាក់

[960] Sovereignty over Pedra Branca/Pulau Batu Puteh, Middle Rocks and South Ledge (Malaysia/Singapore), Judgement of 23 May 2008, p. 1461 and 1473.
[961] David Anderson, Modern Law of the Sea, 2007, p. 6.
[962] The UNCLOS, *supra* note 30, Art. 3.
[963] J. Ashley Roach and Robert W. Smith, Excessive Maritime Claims, 3rd ed., 2012, p. 672; the UNCLOS, *supra* note 30, Art. 2.
[964] The UNCLOS, *supra* note 30, Art. 20.

ដោយ កប៉ាល់របស់រដ្ឋផ្សេង (Innocent Passage)។[965] ការឆ្លងកាត់ ដូចនេះ មានន័យ ថាជាការឆ្លងកាត់ដែនសមុទ្រ ដែលមិនប៉ះពាល់ដល់ សន្តិភាព សន្តិសុខរបស់រដ្ឋដែនសមុទ្រ។[966] ទោះបីជាអនុសញ្ញាឆ្នាំ ១៩៨២ មិនបានតម្រូវ ក៏ប៉ុន្តែ រដ្ឋខ្លះទាមទារការជូនដំណឹងជាមុន នៃដំណើរនាវាចរណ៍របស់រដ្ឋប្រើកម្លាំងនុយក្លេអ៊ែរ[967] និងទទួលខុសត្រូវការបង្កការ ខូចខាត បរិស្ថានក្នុងដែនសមុទ្រ។ [968] ការទាមទារនេះ ត្រូវបានបដិសេធដោយរដ្ឋមួយចំនួន ក្នុងទ្វីបអឺរ៉ុប។[969]

### ១១.១.១.១.៣. តំបន់តភ្ជាប់

តំបន់តភ្ជាប់ ស្ថិតនៅក្បែរ និងបន្តពី ដែនសមុទ្ររបស់រដ្ឋ។ ផ្ទុយពីដែនសមុទ្រ រដ្ឋមិនមានអធិបតេយ្យពេញលេញទៅលើតំបន់ប្រភេទនេះ ដូចនេះ រដ្ឋដទៃ មានសេរីភាពនាវាចរណ៍ ដូចជាក្នុងតំបន់សមុទ្រអន្តរជាតិដែរ។ រដ្ឋដែនសមុទ្រ អាចអនុវត្តការត្រួតពិនិត្យដំណើរនាវាចរណ៍ របស់កប៉ាល់ប្រទេសដទៃ ក្នុងកម្រិតដែលអនុញ្ញាត ដើម្បីបង្ការ ឬដាក់ទណ្ឌកម្មចំពោះការរំលោភច្បាប់ពន្ធដារ ឬ អន្តោប្រវេសន៍ ដែលផ្តើមកើតមានក្នុងដែនសមុទ្ររបស់ខ្លួន។[970] តំបន់តភ្ជាប់ មានចម្ងាយ ២៤ miles ពីខ្សែមូលដ្ឋាន បើតាម

---

965 J. Ashley Roach, Excessive Maritime Claims, *supra* note 963, p. 672; the UNCLOS, *supra* note 30, Art. 17.

966 The UNCLOS, *supra* note 30, Art. 19.

967 Declartion of Bangadesh upon ratification of the 1982 UNCLOS in 2001, para. 4, www.un.org/depts/los/convention_agreements/convention_declarations.htm.

968 *Id.,* para. 5.

969 Declaration of the United Kingdom of Great Britain and Northern Ireland upon accession to the 1982 UNCLOS in 1997 (a), *see supra* note 967.

970 J. Ashley Roach, and Robert W. Smith, Excessive Maritime Claims, *supra* note 963, p. 673; the UNCLOS, *supra* note 30, Art. 33.

អនុសញ្ញាឆ្នាំ ១៩៨២។[971] ចម្ងាយនេះ ត្រូវបានពង្រីក បើប្រៀបធៀបជាមួយ ចម្ងាយសរុបរបស់ដែនសមុទ្រ និងតំបន់តភ្ជាប់ ដែលមានតែ ១២ miles ក្រោមអនុសញ្ញាឆ្នាំ ១៩៥៨។[972]

### ១១.១.១.១.៤. តំបន់សេដ្ឋកិច្ចផ្តាច់មុខ

តំបន់នេះមានចម្ងាយមិនលើសពី ២០០ miles ពីខ្សែមូលដ្ឋាន។[973] វាជាតំបន់មួយថ្មី បង្កើតក្រោមអនុសញ្ញាឆ្នាំ១៩៨២ ក្នុងគោលបំណងមួយ គឺជួយការពារបរិស្ថាននាវាចរណ៍។ រដ្ឋដែនសមុទ្រ មានសិទ្ធិអធិបតេយ្យ ក្នុងការប្រើប្រាស់ និងធ្វើអាជីវកម្ម ថែរក្សា និងគ្រប់គ្រងនូវធនធានធម្មជាតិនៅក្នុងតំបន់នេះ។[974]

រដ្ឋដទៃទៀតអាចប្រាស្រ័យ សេរីភាពនាវាចរណ៍ ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខដែរ ដូចជាការហោះហើរ ការដាក់ខ្សែកាប តែត្រូវស្របនឹងវិធានច្បាប់អន្តរជាតិ។[975] ទោះបីជាយ៉ាងនេះក្តី រដ្ឋដែនសមុទ្រខ្លះ កម្រិតសកម្មភាព មួយចំនួន ក្នុងតំបន់នេះ ដែលហួសពីអ្វីដែលអនុសញ្ញា ឆ្នាំ ១៩៨២ អនុញ្ញាត។[976] ជាក់ស្តែង រដ្ឋខ្លះ មិនអនុញ្ញាតនូវសមយុទ្ធយោធាក្នុង តំបន់នេះទេ[977] ហើយរដ្ឋខ្លះ ជំទាស់នឹងការកម្រិតនេះ។[978]

---

[971] The UNCLOS, *supra* note 30, Art. 33 (2).

[972] J. Ashley Roach, Excessive Maritime Claims, *supra* note 963, pp. 20-21.

[973] The UNCLOS, *supra* note 30, Art. 57.

[974] J. Ashley Roach, Excessive Maritime Claims, *supra* note 963, p. 673; the UNCLOS, *supra* note 30, Art. 56.

[975] The UNCLOS, *supra* note 30, Art. 48.

[976] J. Ashley Roach, Excessive Mari
time Claims, *supra* note 963, p. 674.

### ១១.១.១.១.៥. តំបន់ខ្ពង់រាបបាតសមុទ្រ

តំបន់នេះរួម មានបាតសមុទ្រ ដីក្រោមបាតសមុទ្រ ចម្ងាយពីខ្សែមូលដ្ឋាន គិតពីខ្សែមូលដ្ឋាន ២០០ miles។[979] ផ្អែកទៅតាមលក្ខណៈភូមិសាស្ត្រ ចាំបាច់រដ្ឋអាចទាមទារ សុំពង្រីកប្រវែង ខ្ពង់រាបបាតសមុទ្រហួស ពី ២០០ miles ទៅគណៈកម្មការកំណត់តំបន់ខ្ពង់រាបបាតសមុទ្រ ដែលជាអ្នកពិនិត្យ និងសម្រេច។ គណៈកម្មការ អាចសម្រេច ប្រគល់ឲ្យ ឬស្នើឲ្យរដ្ឋ ដែលដាក់ពាក្យសុំ ដាក់ព័ត៌មានបន្ថែម ដើម្បីគណៈកម្មការពិនិត្យ និងសម្រេចជាថ្មី។[980]

រដ្ឋដែនសមុទ្រ អាចអនុវត្តសិទ្ធិអធិបតេយ្យ ក្នុងការប្រើប្រាស់ និងធ្វើអាជីវកម្មធនធានធម្មជាតិ ដូចជា រ៉ែ ធនធានមានជីវិត និងគ្មានជីវិត។[981]

### ១១.១.១.១.៦. សមុទ្រអន្តរជាតិ

សមុទ្រអន្តរជាតិ ជាតំបន់ដែលមិនមែនជាកម្មសិទ្ធិរបស់រដ្ឋណាមួយឡើយ ហើយតភ្ជាប់ពីតំបន់សេដ្ឋកិច្ចផ្តាច់មុខ។[982] រដ្ឋដែនសមុទ្រ អាចត្រួតពិនិត្យមើលនាវាបើកបរលើតំបន់នេះ ដែលអាចបង្កប៉ះពាល់ដល់បរិស្ថាននាវាចរណ៍

[977] Declaration of India upon ratification of the UNCLOS in 1995, (b), *supra* note 967.
[978] Declaration of Germany upon the accession to the 1982 UNCLOS in 1994, *supra* note 967.
[979] The UNCLOS, *supra* note 30, Art. 76.
[980] *Id.,* Art. 76 (8).
[981] J. Ashley Roach, Excessive Maritime Claims*, supra* note 963, p. 674; the UNCLOS, *supra* note 30, Art. 77.
[982] The UNCLOS, *supra* note 30, Arts. 87 and 89.

តែមិនមានសិទ្ធិបញ្ឈប់នាវានោះឡើយ។ រដ្ឋទាំងអស់ អាចធ្វើការនេសាទ នៅក្នុងតំបន់នេះបាន។[983]

ដោយសារតែ រដ្ឋទាំងអស់មានសិទ្ធិ និង សេរីភាពនាវាចរណ៍ក្នុងសមុទ្រអន្តរជាតិ ភាពអនាធិបតេយ្យ ឬការធ្វើនាវាចរណ៍ដោយបំពាន អាចកើតមានឡើងដោយរដ្ឋ ឬក្រុមមនុស្សណាមួយ។ អនុសញ្ញាឆ្នាំ ១៩៨២ បានទាមទារឲ្យរដ្ឋទាំងអស់ សហការគ្នាក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរទាសករ[984] និងការជួញដូរគ្រឿងញៀន។[985] បន្ថែមពីលើនេះ រដ្ឋត្រូវសហការ ថែរក្សាគ្រប់គ្រងធនធានមានជីវិត នៅក្នុងសមុទ្រអន្តរជាតិ។[986]

### ១១.១.១.១.៧. តំបន់បាតសមុទ្រជ្រៅ

តំបន់នេះ មានបាតសមុទ្រ Ocean Floor និង ដីក្រោមសមុទ្រ ហួសពីដែនយុត្តាធិការជាតិ។[987] អនុសញ្ញា ឆ្នាំ ១៩៨២ ដាក់ឈ្មោះថា ជាតំបន់ (Area) ស្ថិតនៅបន្តពីខ្ពង់រាបបាតសមុទ្រ មានន័យថា មានទីតាំងចាប់ពី ២០០ miles។[988] វាជាតំបន់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរតំបន់បាតសមុទ្រជ្រៅ ដែលត្រូវបង្កើតឡើងដើម្បីត្រួតពិនិត្យ និងធានាឲ្យ រដ្ឋទាំងអស់អាចទទួលប្រយោជន៍ពីតំបន់នេះ។[989] ដូចគ្នានឹង សមុទ្រអន្តរជាតិ

[983] *Id.*, Arts. 88, 90 and 116.
[984] *Id.,* Arts. 99, 100 and 105.
[985] *Id*, Art. 108.
[986] *Id.*, Arts. 118-119.
[987] J. Ashley Roach, Excessive Maritime Claims, *supra* note 963, p. 675.
[988] The UNCLOS, *supra* note 30, Art. 133.
[989] *Id.*, Art. 157.

ដែរ តំបន់នេះ ត្រូវបានគេចាត់ថាជា មត៌ករួមរបស់មនុស្សជាតិ។[990] នេះតម្រូវឲ្យ ការស្រាវជ្រាវវិទ្យាសាស្ត្រនាវាចរណ៍ សម្រាប់ប្រយោជន៍ដល់មនុស្សលោកទាំងអស់[991] ការផ្ទេរនូវបច្ចេកវិទ្យាដល់ប្រទេសកំពុងអភិវឌ្ឍន៍[992] និងការចូលរួមក្នុងសកម្មភាពក្នុង Area ដើម្បីជានាថាប្រទេសទាំងអស់ ទទួលបានប្រយោជន៍ ពីការគ្រប់គ្រងតំបន់នេះ។[993]

## ១១.១.១.១.៨. កំណត់សម្គាល់

ចម្ងាយសមុទ្រជារបស់រដ្ឋ គិតពីខ្សែមូលដ្ឋាន អាចឆ្ងាយ ឬជិត ផ្អែកទៅតាមទីតាំងភូមិសាស្ត្ររបស់រដ្ឋនីមួយៗ។ ប្រទេសជប៉ុន និង វៀតណាម មានចម្ងាយសមុទ្រវែង ពីខ្សែមូលដ្ឋាន។ រដ្ឋនេះមានដែនសមុទ្រ តំបន់តភ្ជាប់ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ ក្នុងករណីខ្លះ រដ្ឋមានប្រវែងខ្ពង់រាបបាតខ្លី ដោយសារច្រាំងធ្លាក់គំហុក។ រដ្ឋខ្លះទៀត មានត្រឹមតែ ១២ miles នៃដែនសមុទ្រ ជួនកាលមាន តិចជាងនេះក៏មាន។ នេះ កើតមានចំពោះរដ្ឋ ដែលមានសមុទ្រ ទល់មុខរដ្ឋផ្សេង ហើយដែលស្ថិតនៅកៀកគ្នា។ ជាទូទៅ បើរដ្ឋមានតំបន់សេដ្ឋកិច្ចផ្តាច់មុខ គឺមានខ្ពង់រាបបាតសមុទ្រ។ ជាចុងក្រោយ អនុសញ្ញាផ្តល់នូវភាពបត់បែន។ នេះមានន័យថា រដ្ឋណាមួយទទួលបានចម្ងាយសមុទ្រប៉ុន្មាន វាអាស្រ័យផងដែរទៅលើ ទីតាំងភូមិសាស្ត្រជាក់ស្តែង និងការកាន់កាប់គ្រប់គ្រង លើកលែងតែផ្ទុយនឹងខ្លឹមសារ ឬបទប្បញ្ញត្តិ របស់អនុសញ្ញា។

[990] J. Ashley Roach, Excessive Maritime Claims, *supra* note 963, p. 675; the UNCLOS, *supra* note 30, Arts. 136, 140.
[991] *Id.*, Art. 143.
[992] *Id.,* Art. 144.
[993] *Id.*, Art. 148.

### ១១.១.១.២. យន្តការ

មានគណៈកម្មការកំណត់ខ្ពង់រាបបាតសមុទ្រ[994] (The Commission on the Limits of the Continental Shelf) និងអាជ្ញាធរបាតសមុទ្រជ្រៅ[995] (the International Seabed Authority: Authority)។ អាជ្ញាធរ មានការិយាល័យនៅក្នុងប្រទេស Jamaica[996] មានសន្និបាតរបស់រដ្ឋជាភាគីរបស់ អាជ្ញាធរ។[997] អាជ្ញាធរ មានក្រុមប្រឹក្សា ដែលមានសមាជិករបស់អាជ្ញាធរចំនួន ៣៦ និងមានគណៈកម្មការពីរ (គណៈកម្មការធ្វើផែនការសេដ្ឋកិច្ច និងគណៈកម្មការបច្ចេកទេស និងច្បាប់)។[998] ជាចុងក្រោយ អាជ្ញាធរ មានស្ថាប័នសហគ្រាស (Enterprise) ដែលអនុវត្តសកម្មភាព ដោយផ្ទាល់ក្នុងតំបន់។[999]

អាជ្ញាធរ មានលេខាធិការដ្ឋានជាសេនាធិការ និងមានតួនាទីជាសំខាន់គ្រប់គ្រង លើតំបន់ឲ្យមានប្រសិទ្ធភាព សម្រាប់ជាប្រយោជន៍ដល់រដ្ឋទាំងអស់។[1000] អាជ្ញាធរ មានថវិកាបានមកពីការចូលរួមបរិច្ចាគពីរដ្ឋជាសមាជិករបស់អាជ្ញាធរ។ អាជ្ញាធរ មានអភ័យឯកសិទ្ធិ[1001] មានឋានៈជានីតិបុគ្គលសាធារ

[994] The UNCLOS, *supra* note 30, Art. 76.
[995] *Id.*, Art. 156.
[996] *Id.*, Art. 156.
[997] *Id.*, Art. 161.
[998] *Id.*, Art. 163.
[999] The UNCLOS, *supra* note 30, Art. 170.
[1000] *Id.*, Art. 166.
[1001] *Id.*, Arts. 176-177.

ណៈអន្តរជាតិ។[1002] អាជ្ញាធរមានអំណាច តាមរយៈសន្និបាតរបស់រដ្ឋជាភាគី ផ្អាកសមាជិកភាពរបស់រដ្ឋ ដែលបង់ថវិកាសមាជិកភាពយឺតយ៉ាវ។[1003]

អនុសញ្ញា ឆ្នាំ ១៩៨២ បានតម្រូវឲ្យមានការបង្កើតតុលាការអន្តរជាតិសម្រាប់ច្បាប់សមុទ្រ (International Tribunal for the Law of Sea)។[1004] តុលាការ មាន អង្គជំនុំជម្រះចំនួនពីរ (Seabed Dispute Chamber and a Special Chamber)។[1005] មានការខ្វែងយោបល់អំពីភាពចាំបាច់នៃការបង្កើតតុលាការនេះ។ តំណាងរដ្ឋខ្លះយល់ថា តុលាការយុត្តិធម៌អន្តរជាតិ អាចដោះស្រាយជម្លោះសមុទ្របាន ហើយតុលាការនេះមិនសូវមានកិច្ចការរវល់ផង។ រដ្ឋដែលចង់ឲ្យមានតុលាការដោយឡែក បានអះអាងថា តុលាការអន្តរជាតិមិនមាន ជំនាញខាងច្បាប់សមុទ្រ និងមិនបើកចំហរឡើយ ជាពិសេសមិនអនុញ្ញាតឲ្យអង្គការអន្តរជាតិជាភាគីនៃរឿងក្តី។ ជាចុងបញ្ចប់ ក្នុងឆ្នាំ ១៩៩៧ មានការព្រមព្រៀងដោយរដ្ឋភាគច្រើន ឲ្យមានការបង្កើតតុលាការ ដោយឡែកសម្រាប់ដោះស្រាយជម្លោះសមុទ្រ ដែលមានទីតាំងនៅក្នុងប្រទេសអាឡឺម៉ង់។[1006]

---

[1002] *Id.*, Art. 170.
[1003] *Id.*, Arts. 184-185.
[1004] *Id.*, Annex VI.
[1005] *Id.*, Arts. 186-188.
[1006] There are 21 judges of the International tribunal for the law of sea; every 3 years, 11 were appointed for the Seabed Dispute Chamber. This Chamber can hear case filed by contractor against State (good, put in the text), provides advisory opinion requested by the seabed authority; the Statute of the International Tribunal for the Law of the Sea, Arts. 1, 2 14 and Section 4, www.itlos.org/index.php.

តុលាការនេះ មានអំណាច ជាងតុលាការដទៃទៀត។ រដ្ឋដែលចូលជាភាគី ត្រូវទទួលស្គាល់សមត្ថកិច្ចតុលាការ ឬអង្គភាពដោះស្រាយជម្លោះ ក្នុងការពិនិត្យមើលបណ្តឹង ពាក់ព័ន្ធនឹងការបកស្រាយអនុសញ្ញា។[1007] ទោះបីជាយ៉ាងនេះក្តី ជម្លោះក្រៅពីនេះ រដ្ឋអាចទទួលយកសមត្ថកិច្ចតុលាការ នាពេលចូលជាភាគី ឬនាពេលក្រោយ ពាក់ព័ន្ធនឹង វិស័យជាក់លាក់ ដូចជាបរិស្ថាននាវាចរណ៍ (Environment of Navigation)។[1008]

រដ្ឋអាចប្រកាសជ្រើសរើស ឧទាហរណ៍តុលាការយុត្តិធម៌អន្តរជាតិ ឬតុលាការអន្តរជាតិសម្រាប់ច្បាប់សមុទ្រ និងជ្រើសរើសសម្រាប់បញ្ហា ពាក់ព័ន្ធនឹងការបកស្រាយ បញ្ហាជាក់លាក់ ដូចជាបរិស្ថាននាវាចរណ៍។[1009]ការប្រកាសអាចផ្តល់សមត្ថកិច្ចដល់តុលាការ សម្រាប់តែបញ្ហាអាទិភាពដែលរដ្ឋចង់។ ជាទូទៅ រដ្ឋប្រកាសជ្រើសរើសយន្តការដោះស្រាយជម្លោះចំនួនពីពីរឡើងទៅ ហើយរដ្ឋភាគច្រើន ទទួលយក ការដោះស្រាយតាមមជ្ឈត្តករ។ ក្នុងករណីដែលរដ្ឋមិនប្រកាស ឬ រដ្ឋភាគីក្នុងជម្លោះ ប្រកាសយកយន្តការផ្សេងគ្នា រដ្ឋត្រូវបានសន្មតថា យកមជ្ឈត្តកម្ម ជាមធ្យោបាយក្នុងការដោះស្រាយវិវាទ។ រដ្ឋភាគីច្រើនប្រកាសយក តុលាការអន្តរជាតិសម្រាប់ច្បាប់សមុទ្រជា យន្តការ ក៏ប៉ុន្តែ មានរដ្ឋមួយចំនួនតូចតែប៉ុណ្ណោះមកដល់ពេលនេះ យកតុលាការនេះជាយន្តការផ្តាច់មុខក្នុងការដោះស្រាយជម្លោះសមុទ្រ។ ខុសពី តុលាការយុត្តិធម៌អន្តរជាតិ ដែលមិនចាំបាច់ទាមទារឲ្យរដ្ឋ ត្រូវចរចាដោះស្រាយជម្លោះជាមុនសិន តុលាការនេះ ក្នុងជម្លោះពាក់ព័ន្ធនឹងការបកស្រាយអនុសញ្ញា ឆ្នាំ

[1007] The UNCLOS, *supra* note 30, Art. 287.
[1008] *Id.*, Art. 298.
[1009] *Id.*, Art. 287; Declaration of Argentina upon ratification of the 1982 UNCLOS in 1995, (f), *supra* note 967.

១៩៨២ តម្រូវឲ្យរដ្ឋចរចាជាមុនសិន ប្រសិនបើទាមទារដោយកិច្ចព្រមព្រៀងផ្សេង ហើយបើកិច្ចព្រមព្រៀងនោះ មិនបើកផ្លូវឲ្យមកតុលាការនេះ តុលាការមិនអាចដោះស្រាយ បានឡើយ លើកលែងតែភាគីទាំងពីរព្រមព្រៀង។[1010] រឿងក្តីត្រូវឆ្លងកាត់ការដោះស្រាយដោយតុលាការក្នុងស្រុកសិន។[1011] រដ្ឋភាគីច្រើន មិនបានធ្វើការ ប្រកាសទេ ។ នេះមានន័យថា តុលាការនេះត្រូវបានអនុញ្ញាតឲ្យពិនិត្យ មើលជម្លោះ។ ការមិនប្រកាសរបស់រដ្ឋ អាចបណ្តាលមកពីបញ្ហា ការិយាធិបតេយ្យ ឬ មកពីរដ្ឋមិនចង់បាត់ឱកាសក្នុងការ នាំក្តីទៅឲ្យតុលាការសមុទ្រក្នុងការពិនិត្យ និងសម្រេច។ សេចក្តីសម្រេច របស់តុលាការមានលក្ខណៈស្ថាពរ និងចងកាតព្វកិច្ចដល់ភាគី។[1012]

តុលាការសមុទ្រ អាចចេញបញ្ជាឲ្យមានការដោះលែងកប៉ាល់ ដែលរដ្ឋបានបង្ខាំងទុក។[1013] ដូចតុលាការយុត្តិធម៌អន្តរជាតិដែរ តុលាការសមុទ្រមានសមត្ថកិច្ចផ្តល់យោបល់ និងចេញវិធានការបណ្តោះអាសន្ន[1014]។ ពាក់ព័ន្ធជាមួយចំណុចនេះ ជាដំបូងតុលាការ ត្រូវពិនិត្យមើលថាខ្លួនមាន *Prima Facie* យុត្តាធិការឬទេ បើមាន ទើបចេញនូវវិធានការបណ្តោះអាសន្ន។[1015] វិធានការបណ្តោះអាសន្ន សម្រាប់ឆ្លើយតបបញ្ហាបន្ទាន់។[1016]

[1010] During the time that the tribunal is seized of the case, if parties agreed and resolved issue through negotiation, the case can be dropped from the registrar; the UNCLOS, *supra* note 30, Art. 282.
[1011] *Id.*, Art. 295.
[1012] *Id.*, Art. 296.
[1013] The UNCLOS, *supra* note 30, Art. 292.
[1014] *Id.*, Art. 290.
[1015] *Id.*, Art. 290.
[1016] The Statute of the Tribunal, *supra* note 1006, Art. 25.

## ១១.២. បរិស្ថាន

បរិស្ថានគឺជា ក្តីបារម្ភរួមរបស់មនុស្សលោក។ បញ្ហាបរិស្ថាន មិនបានស្ថិតនៅក្នុងការពិភាក្សាលើឆាកអន្តរជាតិឡើយ ក្រោយសង្គ្រាមលោកលើកទី២។ មិនមានបទប្បញ្ញត្តិណាមួយ ក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ចែងពាក់ព័ន្ធនឹងបរិស្ថានទេ។ ផ្ទុយទៅវិញ បញ្ហានេះ ជាក្តីបារម្ភ ក្នុងកិច្ចពិភាក្សានៃវេទិកានយោបាយ របស់ប្រទេសលោកខាងលិចមួយចំនួន។[1017] មួយរយៈក្រោយមកទើប បញ្ហាបរិស្ថាន បានទាញចំណាប់អារម្មណ៍ក្នុងឆាកអន្តរជាតិ ដោយសារព្រឹត្តិការណ៍ខូចខាតធនធានធម្មជាតិ ការឡើងកំដៅផែនដី ដែលជាបច្ច័យនៃបរិស្ថានមិនល្អ។ ឧទាហរណ៍ គ្រោះទឹកជំនន់ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ (Climate Change)។

បរិស្ថាន មានន័យទូលំទូលាយ រាប់បញ្ចូលទាំងខ្យល់ ទឹក ដី ជីវចម្រុះ (Flora and Fauna) អេកូធម្មជាតិ សុខភាព និងសុវត្ថិភាពរបស់មនុស្ស និង អាកាសធាតុ។[1018] សមាសភាពក្នុងនិយមន័យនេះ មានភាពទាក់ទងគ្នាយ៉ាងជាក់លាក់។ នៅពេលមានកំណើនកំដៅ ទឹកកកអាចរលាយ ដែលធ្វើឲ្យជន់លិចតំបន់នៃប្រទេសខ្លះ ឬបាត់បង់រដ្ឋជាដែនកោះតូចៗ ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ដោយសារកំណើនកម្ពស់ទឹកសមុទ្រ។ រីឯប្រទេសខ្លះ កាន់តែខ្វះខាតទឹកប្រើប្រាស់[1019] មានភាពរាំងស្ងួត ប្រមូលភោគផលកសិកម្មមិនបាន

[1017] Michael Palmer, *towards a Greener China? Accessing Environmental Justice in the People's Republic of China*, in Andrew Harding, Access to Environmental Justice, A Comparative Study, 2007, p. 233.

[1018] PCA, Arbitration Regarding the Iron Rhine Railway (*Belguim v. the Netherlands*), Award of 24 May 2005, para. 58 (www.pca-cpa.org).

[1019] More than a billion people do not have access to safe water; more than 2,4 billions do not have access to adequate sanitation, *see* Hague Academy of

ល្អដូចធម្មតា។ កំណើនកំដៅ ក៏អាចធ្វើឲ្យមានការរលត់ផុតពូជ នៃជីវចម្រុះខ្លះផងដែរ។ កំណើនកំដៅ ដោយសារមានឧស្ម័ន ដែលមានជាតិពុល ដូចជាឧស្ម័នកាបូនិច (CO2) ធ្វើឲ្យមានការកកស្ទះក្នុងលំហអាកាស មិនអាចហើរទៅលើ ហើយជះកំដៅមកផែនដី ឬខូតស្រទាប់អូហ្សូន ដែលមានតួនាទីទប់ទល់កំដៅកុំឲ្យកើនកំដៅមកផែនដី។ ប្រភពនៃការបញ្ចេញ (Emission) ឧស្ម័នពុល ដូចជា ការប្រើប្រាស់ថាមពលក្នុងរោងចក្រឧស្សាហកម្ម ដំណើរការ ឧស្សាហកម្ម (ការផលិតដែក) ការប្រើប្រាស់សារធាតុរំលាយ (Solvent and Product Use) វិស័យកសិកម្ម និងសំរាមជាដើម។[1020]

កំណើនកំដៅ ដោយសារការបំពុលបរិស្ថាន អាចជាស្នាដៃរបស់មនុស្សលោក។ បរិស្ថាន មិនល្អ ឬការកើនកំដៅនៃផែនដី មិនមានកម្រិតត្រឹមដែនដីរបស់ប្រទេសណាមួយឡើយ។ និយាយជាសាមញ្ញ ការបំពុលបរិស្ថានក្នុងប្រទេសមួយ នាំឲ្យមានផលប៉ះពាល់ដល់ប្រជាជនរបស់ប្រទេសមួយទៀត។ ទោះបីជា មានសមិត្តិកម្មយ៉ាងនេះក្តី អ្នកវិទ្យាសាស្ត្រ មិនអាចកំណត់ជាក់លាក់នូវទំហំ ឬកម្រិតបំពុលបរិស្ថាន ដែលប្រទេសនីមួយៗបញ្ចេញ។ ការបំពុលបរិស្ថានរបស់ប្រទេសមួយ អាចប្រែប្រួលពីពេលមួយទៅពេលមួយទៀត ដោយសារទំហំនៃការអភិវឌ្ឍប្រទេសជាតិ ដែលអាចប៉ះពាល់ដល់បរិស្ថាន។ ខណៈដែលរដ្ឋខ្លះ កំពុងត្រូវការធនធានធម្មជាតិ និងថវិកាសម្រាប់អភិវឌ្ឍប្រទេសខ្លួន រដ្ឋត្រូវចូលរួមក្នុងការថែរក្សាបរិស្ថាន។ ម្យ៉ាងទៀត ប្រទេសកំពុងអភិវឌ្ឍ មិនមាន សមត្ថភាពគ្រប់គ្រាន់ ក្នុងការថែរក្សា

International Law, summer course (2011), International Environmental Law by Prof. Laurence Boisson de Chazournes (in file of the author).

[1020] Kyoto Protocol to the United Nations Framework Convention on Climate Change, *see* Annex A (www.unep.org).

បរិស្ថាន ដែលទាមទារឲ្យមានប្រទេសផ្សេង ឬ ស្ថាប័នអន្តរជាតិជួយ។ ពិចារណាលើប្រភពនៃការនាំឲ្យមានកំដៅលើផែនដី ការឆ្លើយតបទៅនឹងបញ្ហាបរិស្ថាន ទាមទារឲ្យមានការចូលរួម និង រួមបញ្ចូលនូវវិស័យជាច្រើន។ ដោយសារហេតុផលនេះហើយ បញ្ហាបរិស្ថានជាបញ្ហារួមរបស់មនុស្សលោកទាំងអស់។

### ១១.២.១. បញ្ហាបម្រែបម្រួលអាកាសធាតុ

ក្នុងឆ្នាំ ១៩៧២ មានសន្និសីទជាអន្តរជាតិមួយ ប្រព្រឹត្តធ្វើឡើងនៅក្នុងទីក្រុង Stockholm ដែលបាន ដាក់ចេញជា សេចក្តីថ្លែងការណ៍ទីក្រុង Stockholm ស្តីពី បរិស្ថានរបស់មនុស្ស ដោយដាក់សុវត្ថិភាព និង សុខមាលភាពរបស់មនុស្សជាបញ្ហាសំខាន់។ ដាក់ស្តែង គោលការណ៍ ៧ នៃ សេចក្តីថ្លែងការណ៍ទាមទារ ឲ្យរដ្ឋចាត់វិធានការបង្ការ ការបំពុលបរិស្ថាន ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស។[1021] ២០ ឆ្នាំក្រោយមក ទំនាក់ទំនងរវាងការអភិវឌ្ឍ និងបរិស្ថាន បានក្លាយជាប្រធានបទសំខាន់ ដែលត្រូវបានយកមកពិភាក្សានៅក្នុងកិច្ចប្រជុំនៅទីក្រុង Rio De Janeiro ហើយបានដាក់ចេញនូវសេចក្តីប្រកាស ស្តីពី បរិស្ថាន និងការអភិវឌ្ឍ។[1022] ការអភិវឌ្ឍ តាមរយៈការបង្កើតរោងចក្រឧស្សាហកម្ម និងផលិតកម្ម ដែលនាំឲ្យមានការបញ្ចេញឧស្ម័នពុល នាំឲ្យមានបម្រែបម្រួលអាកាសធាតុ បានទាញចំណាប់អារម្មណ៍សហគមន៍អន្តរជាតិ ឲ្យរៀបចំជាសន្ធិសញ្ញាជាក្របខ័ណ្ឌ (Framework

[1021] Declaration of the United Nations Conference on the Human Environment (Stockholm Declaration, 1972), www.unep.org.

[1022] Rio Declaration on Environment and Development, 1992, www.unep.org.

Convention) ស្តីពី បរិស្ថានក្នុងឆ្នាំ ១៩៩២។[1023] សន្ធិសញ្ញានេះ មានគោលបំណង ដើម្បីសម្រេចនូវការធ្វើឲ្យមានលំនឹង Greenhouse Gas ដែលនឹងជួយបង្ការផលវិបាកដ៏មាន គ្រោះថ្នាក់ក្នុង ប្រព័ន្ធអាកាសធាតុ។[1024] សន្ធិសញ្ញា ដើរតួនាទីជាឯកសារ គ្រួសត្រាយផ្លូវសម្រាប់សកម្មភាពរបស់រដ្ឋជាភាគីក្នុងការឆ្លើយតបចំពោះបញ្ហាបម្រែបម្រួលអាកាសធាតុ ទោះបីជាផ្នែកខ្លះនៃសន្ធិសញ្ញា បានប្រើប្រាស់ពាក្យពេចន៍ ដែលបង្ហាញពីភាពស្ទាក់ស្ទើរក្នុងការបង្កើតកាតព្វកិច្ចដល់រដ្ឋជាភាគី។ ឧទាហរណ៍ មាត្រា ៣បានចែងថា៖ រដ្ឋជាភាគីគួរការពារប្រព័ន្ធអាកាសធាតុ សម្រាប់ជាប្រយោជន៍នៃមនុស្សជំនាន់បច្ចុប្បន្ន និងអនាគត។ ឆ្នាំ ១៩៩៨ ពិធីសារ Kyoto (Kyoto Protocol) បន្ថែមពីលើ សន្ធិសញ្ញាជាក្របខ័ណ្ឌ ស្តីពី បម្រែបម្រួលអាកាសធាតុត្រូវបានអនុម័ត។ ក្រៅពីមានបញ្ចូលគោលការណ៍សំខាន់ៗ ដូចជាគោលការណ៍បង្ការ មូលហេតុនៃបម្រែបម្រួល ដែលមាននៅក្នុងសន្ធិសញ្ញាជាក្របខ័ណ្ឌ[1025] ពិធីសារ បានចែងរំឭកអំពីកាតព្វកិច្ចរបស់ប្រទេសអភិវឌ្ឍន៍ក្នុងការកាត់បន្ថយឧស្ម័នពុល ព្រមទាំងបានដាក់ចេញយន្តការថ្មី ផ្តោតលើទីផ្សារ (Market Oriented Mechanism)។[1026] ជាចុងក្រោយ បន្ថែមពីលើពិធីសារនេះ សន្និសីទរបស់រដ្ឋជាភាគី បានរៀបចំធ្វើនៅ Copen-

[1023] The United Nations Framework Convention on Climate Change (UNFCC) entered into force in December 1994, and there are 194 States Parties as of 2011, www.unep.org.
[1024] The UNFCC, Art. 2.
[1025] The Kyoto Protocol to UNFCC, *supra* note 1020. The Protocol entered into force in 2005; the United States of America is not party yet.
[1026] *Id.*, Arts. 3 and 12.

hagen ឆ្នាំ ២០០៩ ហើយបានដាក់ចេញនូវ Copenhagen Accord។[1027] ទោះបីវាត្រូវបានដាក់ឈ្មោះ ថាជាកិច្ចព្រមព្រៀងក្តី ក៏ប៉ុន្តែពាក្យពេចន៍ ខាងក្នុង ដែលត្រូវប្រើ វាពិបាកថាជាកិច្ចព្រមព្រៀង។ ក្រៅពីបានរំឭកឡើងវិញនូវកាតព្វកិច្ចរបស់រដ្ឋជាភាគី កិច្ចព្រមពៀងបាន ចែងរំឭកជាសំខាន់ អំពីកាតព្វកិច្ចរបស់ប្រទេសអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងជំនួយហិរញ្ញវត្ថុ ក្នុងចំនួន ៣០ billions (2010-2012) និង ការផ្តល់បច្ចេកវិជ្ជា ដល់ប្រទេសកំពុងអភិវឌ្ឍ ដើម្បីទប់ទល់ទៅនឹងបម្រែបម្រួលអាកាសធាតុ។[1028]

### ១១.២.២. បញ្ហាជីវចម្រុះ

ដូចដែលបានបរិយាយនៅក្នុងផ្នែកមុន ជីវចម្រុះ ជាសមាសភាពនៃបរិស្ថាន ហើយមានទំនាក់ទំនងជាមួយការប្រែប្រួលអាកាសធាតុ។ ការប្រែប្រួលអាកាសធាតុនាំឲ្យបាត់បង់ នូវប្រភេទជីវចម្រុះខ្លះជាយថាហេតុ។ ភាពរាំងស្ងួត បណ្តាលមកពីការប្រែប្រួលអាកាសធាតុ នាំឲ្យការប្រមូលកសិកម្ម ជាប្រភពនៃអាហារ បានតិចតួច បានធ្វើឲ្យមនុស្ស ងាកមករកជីវចម្រុះ រួមមានសត្វធ្វើជាចំណីអាហារ។ បន្ថែមពីលើនេះ មានការប្រមូលជីវចម្រុះសម្រាប់ អាជីវកម្មសេដ្ឋកិច្ច ក៏អាចនឹងនាំឲ្យមានការបាត់បង់ជីវចម្រុះ។ នេះគឺក្តីបារម្ភ ដែលនាំឲ្យមានការពិភាក្សា ឈានទៅដល់ការអនុម័ត សន្ធិសញ្ញា ស្តីពី ជីវចម្រុះ។ តាមសន្ធិសញ្ញានេះ ជីវចម្រុះសំដៅលើ សមាសភាពចម្រុះ ក្នុងចំណោម ៖

[1027] Copenhagen Accord (Decision 2/CP.15), 2009, FCCC/CP/2009/11/Add.1, www.unep.org.
[1028] *Id*., para. 8.

> "*living organisms from all sources including, inter alia, terrestrial, marine and other aquatic ecosystems and the ecological complexes of which they are part: this includes diversity within species, between species and of ecosystem.*"[1029]

គោលដៅសំខាន់នៃ សន្ធិសញ្ញា គឺដើម្បីថែរក្សានូវសមាសភាពជីវចម្រុះ ការប្រើប្រាស់ប្រកបដោយចីរភាព និង ការបែងចែងផលប្រយោជន៍ទទួលបានពីប្រភពធនធាន ដោយសមធម៌ និង យុត្តិធម៌។[1030] ពាក់ព័ន្ធនឹងបញ្ហាជីវចម្រុះនេះ ក្នុងឆ្នាំ ២០០០ ពិធីសារមួយទៀត ត្រូវបានអនុម័តឡើងនៅក្នុងទីក្រុង Cartegena ( Cartagena Protocol ) ដោយផ្តោតជាសំខាន់លើការដឹកជញ្ជូនឆ្លងប្រទេស Living Modified Organism (LMO) បង្កើតដោយប្រើបច្ចេកវិជ្ជាទំនើប ដែលនឹងនាំឲ្យមានផលប៉ះពាល់ ជាអវិជ្ជមានដល់ការថែរក្សា និង ប្រើប្រាស់ក្នុងលក្ខណៈនិរន្តរភាពនៃជីវចម្រុះ។[1031] បន្ថែមពីលើនេះ ពិធីសារបានចែងជាថ្មីនូវគោលការណ៍មួយចំនួន មានចែងរួចហើយក្នុងសន្ធិសញ្ញ ស្តីពី ជីវចម្រុះ ដូចជា គោលការណ៍ ស្តីពី ការបង្ការជាមុន (Precautionary Principle)។[1032]

---

[1029] The Convention on Biological Diversity entered into force in December 1993, Art. 2, www. unep.org.

[1030] *Id.*, Art. 1.

[1031] Cartagena Protocol on Biosafety to the Convention on Biological Diversity, 2000, Preamble; "living modified organism" means any living organism which possesses a navel combination of genetic material obtained through the use of modern biotechnology, Art. 2.

[1032] *Id.*, Art. 10 (6).

### ១១.២.៣. ផ្លូវទឹក

ទឹកមានតួនាទីយ៉ាងសំខាន់ សម្រាប់ប្រើប្រាស់ក្នុងវិស័យជាច្រើន ដូចជា កសិកម្ម ឧស្សាហកម្ម បរិស្ថាន និង នាវាចរណ៍។ ទឹក ឬផ្លូវទឹកមិនល្អ ដូចជា ការចាក់ចោលសំរាមក្នុងប្រភពទឹក អាចនាំឲ្យមានការបញ្ចេញឧស្ម័នពុល ដែលនាំឲ្យមានបម្រែបម្រួលអាកាសធាតុ។ ផ្លូវទឹកនៅក្នុងប្រទេសមួយ អាច មិនមានបញ្ហាច្រើន ពីព្រោះវាត្រូវបានប្រើប្រាស់ ដោយរដ្ឋតែមួយ និងងាយ ស្រួលយល់ដឹង និង ការដាក់ការទទួលខុសត្រូវចំពោះការធ្វើឲ្យផ្លូវទឹកមិនល្អ ដូចជាទឹកកខ្វក់។ ផ្លូវទឹកអន្តរជាតិ ជាពិសេសស្ថិតនៅលើ ខ្សែបន្ទាត់ព្រំដែន ខណ្ឌចែកប្រទេសពីរ អាចនឹងមានបញ្ហាពាក់ព័ន្ធការប្រើប្រាស់ផ្លូវទឹករួមគ្នា ដោយសារ ការបំពុលបរិស្ថានផ្លូវទឹកដោយប្រជាជននៃប្រទេសម្ខាង បង្កផល វិបាកដល់ប្រជាជននៃប្រទេសត្រើយម្ខាងទៀត។ វាអាចបណ្តាលមកពីមូល ហេតុនេះ ហើយទើបបណ្តាលឲ្យមាន ការរៀបចំ និងអនុម័ត សន្ធិសញ្ញា ស្តីពី ការប្រើប្រាស់ផ្លូវទឹកអន្តរជាតិ ក្រៅពីវិស័យនាវាចរណ៍។[1033] គោលបំណងនៃ សន្ធិសញ្ញា គឺ ដើម្បីចែងនូវទំនាក់ទំនងរវាងរដ្ឋ ពាក់ព័ន្ធនឹងការគ្រប់គ្រង ផ្លូវទឹក។ ក្នុងកម្រិតតំបន់ មានសន្ធិសញ្ញា ស្តីពី ការការពារ និងការប្រើ ប្រាស់ផ្លូវទឹក និង បឹងអន្តរជាតិ កិច្ចព្រមព្រៀងសហប្រត្តិបត្តិការ សម្រាប់ អភិវឌ្ឍន៍ប្រកបដោយចីរភាព នៃអាងទឹកទន្លេមេគង្គ ឆ្នាំ ១៩៩៥ ជាដើម ។[1034]

---

[1033] The United Nations Convention on the Non-Navigational Uses of International Watercourses, 1997, www.unep.org.

[1034] There are other conventions or instruments regarding waters, such as Senegal Water Charter (2002); Rhine Protection Convention (1999); Amazon Cooperation Agreement (1978); Boundary Water Treaty (1909); Protocol on Health and Water

### ១១.២.៤. បញ្ហាដទៃទៀតនៃវិស័យបរិស្ថាន

មានបញ្ហាជាច្រើនទៀត ដែលបានកើតឡើង ដែលបង្កឲ្យមានការប៉ះពាល់ដល់បរិស្ថាន។ បញ្ហាទាំងនោះ ត្រូវបានឆ្លើយតបជាដំបូង តាមរយៈការចងក្រងជាវិធានក្នុងទម្រង់ជាសន្ធិសញ្ញា។ បញ្ហាទាំងនោះ ដូចជា ការការពារស្រទាប់អូហ្សូន[1035] ការគ្រប់គ្រងការដឹកជញ្ជូនឆ្លងប្រទេស នូវកាកសំណល់មានគ្រោះថ្នាក់ និងការបំផ្លាញ ចោលជាដើម។[1036]

### ១១.២.៥. គោលការណ៍សំខាន់នៃច្បាប់បរិស្ថានអន្តរជាតិ

ការអភិវឌ្ឍមាននិរន្តរភាព ត្រូវបានបរិយាយនៅក្នុង សេចក្តីថ្លែងការណ៍ Rio ដែលកំណត់ថាជាការអភិវឌ្ឍ ឲ្យឆ្លើយតប ដោយសមធម៌ ដល់សេចក្តីត្រូវការផ្នែកអភិវឌ្ឍន៍ និងបរិស្ថាន សម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និង ជំនាន់ក្រោយ។[1037] គោលការណ៍នេះ បានតម្រូវផងដែរ ឲ្យមានការគិតគូរពិចារណា ការការពារបរិស្ថានក្នុងផែនការរួមនៃការអភិវឌ្ឍ។[1038] សមាសភាពមួយដែលគួរឲ្យចាប់អារម្មណ៍ គឺប្រយោជន៍ របស់មនុស្សជំនាន់ក្រោយ។ បញ្ហាពាក់ព័ន្ធបម្រែបម្រួលអាកាសធាតុ ក៏បានតម្រូវឲ្យរដ្ឋ ថែរក្សាបរិស្ថានសម្រាប់

(1999); Protocol on Civil Liability and Compensation for Transboundary Damage (2003), www.unep.org.

[1035] The Vienna Convention for the the Protection of the Ozone Layer (1987); Montreal Protocol on Substances that Deplete the Ozone Layer (1987), www.unep.org.

[1036] Basel Convention on the Control of Transboundary Movements of Hazardous Wastes and Their Disposal (1989); Rotterdam Convention on the Prior Informed Consent Procedure for Certain Hazardous Chemicals and Pesticides in International Trade (1998), www.unep.org.

[1037] Rio Declaration, *supra* note 1022, Principle 3.

[1038] *Id.,* Principle 4.

ផលប្រយោជន៍នៃជនជំនាន់ក្រោយ។[1039] តុលាការកំពូលរបស់ Philippines បានទទួលស្គាល់កាតព្វកិច្ចធានានូវការការពារសិទ្ធិមានបរិស្ថានល្អ របស់មនុស្សជំនាន់ថ្មី។[1040] គោលការណ៍នេះ កាន់តែទទួលបាននូវចំណាប់អារម្មណ៍ពីសំណាក់ស្ថាប័ន និង តុលាការអន្តរជាតិ។ នៅក្នុងរឿងក្តីរវាង *Hungary v. Slovakia* តុលាការយុត្តិធម៌អន្តរជាតិ បានបញ្ជាក់ និង គាំទ្រអំពីភាពចាំបាច់នៃការគិតគូរដល់បរិស្ថាន នៅក្នុងកិច្ចការងារអភិវឌ្ឍ ហើយបានយោងយ៉ាងជាក់លាក់ ដល់ទស្សនៃការអភិវឌ្ឍដោយចីរភាព ទាមទារឲ្យមានតុល្យភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ច និង ការការពារបរិស្ថាន។[1041] អង្គជំនុំជម្រះមជ្ឈត្តកម្មអចិន្ត្រៃយ៍ បានអះអាងថា គោលការណ៍នេះ ចងជាកាតព្វកិច្ច និងជាគោលការណ៍នៃច្បាប់អន្តរជាតិទូទៅ (the Principle of General International Law)។[1042]

### ១១.២.៥.១. គោលការណ៍បង្ការ និងប្រុងប្រយ័ត្នទុកជាមុន

គោលការណ៍នេះ ទាញមូលដ្ឋានចេញពីការបង្ការ កុំឲ្យមានការខូចខាតដល់បរិស្ថាន ដែលមិនអាចប៉ះប៉ូវវិញបាន ភាពមិនច្បាស់លាស់ទាំងស្រុងនៃវិទ្យាសាស្ត្រ (Lack of Full Scientific Certainty)។ គោលការណ៍នេះ ត្រូវបាន

[1039] UNFCC, *supra* note 1023, Art. 3.

[1040] The Supreme Court of the Republic of The Philippines, *Minors Oposa v. Secretary of the Department of Environment and Natural Resources*, Judgement of 30 July 1993, 33 ILM, 174 (1994), p. 185.

[1041] ICJ, Case Concerning the Gabcikovo-Nagymaros, *supra* note 931, para. 140; ICJ, Case concerning Rulp Mills on the River Uruguay ( *Argentina v. Uruguay*), Judgement of 20 April 2010, para. 177.

[1042] PCA, Artbitration concerning the Iron Rhine Railway, *supra* note 1018, para. 59.

បញ្ចូលក្នុងសន្ធិសញ្ញាជាច្រើនក្នុងវិស័យបរិស្ថាន។[1043] មាត្រា ៣ នៃសន្ធិសញ្ញា ស្តីពី ក្របខ័ណ្ឌបម្រែបម្រួលអាកាសធាតុ បានចែងថាៈ ភាគីត្រូវចាត់វិធានការបង្ការទុកជាមុន ដើម្បីបង្ការ ឬបន្ថយនូវមូលហេតុ នៃបម្រែបម្រួលអាកាសធាតុ ដែលបង្កឲ្យមានផលប៉ះពាល់ជាអវិជ្ជមាន។ គោលការណ៍នេះ វាជាប់ពាក់ព័ន្ធជាមួយកាតព្វកិច្ចបង្ការ និង មិនបង្កការខូតខាត ដល់បរិស្ថាន ក៏ដូចជាការបញ្ចៀសនូវសកម្មភាពណាមួយក្នុងដែនដី ឬ ទីកន្លែងណាមួយក្រោមយុត្តាធិការរបស់ខ្លួន នាំឲ្យមានការប៉ះពាល់បរិស្ថានរបស់រដ្ឋដទៃទៀត។[1044] ក្នុងរឿងក្តី Rulp Mills on the River Uruguay តុលាការយុត្តិធម៌អន្តរជាតិ រកឃើញថា Uruguay បានបំពាននូវកាតព្វកិច្ចសហការដែលរាប់បញ្ចូលការ ជូនដំណឹងអំពីផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍។[1045] ជាមួយគ្នានេះ វាទាមទារឲ្យរដ្ឋ ធ្វើការវាយតម្លៃអំពើប៉ះពាល់ដល់បរិស្ថានដោយសារការអភិវឌ្ឍ ហើយតុលាការ បានរកឃើញថា Uruguay ខកខានមិនបានបំពេញតាមកាតព្វកិច្ចនេះ។[1046] ជាចុងក្រោយ ការបង្ការ តម្រូវឲ្យរដ្ឋយកចិត្តទុកដាក់ ឃ្លាំមើលសកម្មភាពដែលនាំឲ្យមានការបំពុលបរិស្ថាន។ ក្នុងរឿងក្តីប្រឆាំងនឹង Nigeria គណៈកម្មការសិទ្ធិមនុស្សរបស់តំបន់អាហ្វ្រិក បានអះអាងថា រដ្ឋមានកាតព្វកិច្ច ការពារប្រជាពលរដ្ឋ ពីអំពើ

---

[1043] Rio Declaration, *supra* note 1022, Principle 5; preamble of the United Nations Convention on Biological Diversity; Cartagena Protocol, *supra* note 1031, Art. 11.8; the UNFCCC, *supra* note 1023, Art. 3.

[1044] ICJ, Case concerning Rulp Mills on the River Uruguay, *supra* note 1041, para. 101; ICJ, Legality of the Threat, *supra* note 290, para.29.

[1045] UNFCCC, *supra* note 1023, Arts. 3 and 4.

[1046] ICJ, Case concerning Rulp Mills on the River Uruguay, *supra* note 1041, para.111; African Commission on Human Rights, the Ogoni case, Communication 155/96, *the Social and Economic Rights Action Centre v. Nigeria*, finding of 27 May 2002, recommendation part.

ខូតខាតបង្កឡើងដោយអង្គភាពឯកជន និងបានរកឃើញថា តាមរយៈការផ្តល់ភ្លើងខៀវដល់អង្គភាពឯកជន ធ្វើសកម្មភាពប៉ះពាល់សិទ្ធិ និងបរិស្ថាន រដ្ឋមិនបានបំពេញតាមកាតព្វកិច្ចឃ្លាំមើលដោយយកចិត្តទុកដាក់ឡើយ។[1047]

### ១១.២.៥.២. ការទទួលខុសត្រូវដូចគ្នា តែតាមលទ្ធភាពផ្សេងគ្នា

(Common but Different Responsibility)

សន្ធិសញ្ញាជាច្រើនពាក់ព័ន្ធជាមួយបញ្ហាបរិស្ថាន បានចែងអំពីគោលការណ៍នេះ។ មាត្រា៣ នៃសន្ធិសញ្ញា ស្តីពី ក្របខ័ណ្ឌបម្រែបម្រួលអាកាសធាតុ ចែងថា៖ ១. រដ្ឋជាភាគី គួរ ការពារប្រព័ន្ធបរិស្ថានសម្រាប់ ប្រយោជន៍នៃមនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយ ផ្អែកតាមគោលការណ៍សមធម៌ និង ផ្អែកតាមក្តីបារម្ភរួម ក៏ប៉ុន្តែសមត្ថភាព និងការទទួលខុសត្រូវដោយឡែកៗ។ តាមខ្លឹមសារនេះ ប្រទេសអភិវឌ្ឍន៍ គួរធ្វើជាគំរូ ក្នុងការប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និង ផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន។ ២. ស្ថានភាពពិសេស និងសេចក្តីត្រូវការជាក់លាក់ របស់ប្រទេសកំពុងអភិវឌ្ឍ គួរត្រូវបានពិចារណាពេញលេញ។[1048] តុលាការ ហាក់មានភាពស្ទាក់ស្ទើរចំពោះគោលការណ៍នេះ។ ជាការពិត ការប្រយុទ្ធប្រឆាំង នឹងការបម្រែបម្រួលអាកាសធាតុក្នុងករណីខ្លះ តម្រូវឲ្យមានបច្ចេកវិជ្ជាទំនើបគ្រប់គ្រាន់ រួមផ្សំជាមួយថវិកា ដែលប្រទេសកំពុងអភិវឌ្ឍមិនមាន ហើយដែលប្រទេសអភិវឌ្ឍន៍មាន។ ដូចនេះ ប្រទេសអភិវឌ្ឍន៍ គួរជួយជាថវិកា និងបច្ចេកវិទ្យាដល់ប្រទេសកំពុងអភិវឌ្ឍ។ មានមូលដ្ឋានសមស្រប នៅពីក្រោយ

[1047] African Commission on Human Rights, the Ogoni case, *id*., para. 57.

[1048] The UNFCCC, *supra* note 1023, Art. 3; Rio Declaration, *supra* note 1022, Principle 7.

ការទាមទារនេះ។ ប្រទេសអភិវឌ្ឍន៍ ត្រូវបានប្រទេសកំពុងអភិវឌ្ឍ ចោទប្រកាន់ថា ជាអ្នកបង្កឲ្យមានបម្រែបម្រួលអាកាសធាតុ តាមរយៈការបញ្ចេញឧស្ម័នពុល ពីរោងចក្រឧស្សាហកម្ម។ ធនធានធម្មជាតិរបស់ប្រទេសកំពុងអភិវឌ្ឍខ្លះ ដែលទាមទារសម្រាប់ការអភិវឌ្ឍ ត្រូវបានធ្វើជាអាជីវកម្មដោយប្រទេសអភិវឌ្ឍន៍ ក្នុងអំឡុងពេលដែលប្រទេសអភិវឌ្ឍន៍ គ្រប់គ្រង។[1049] ប្រទេសកំពុងអភិវឌ្ឍត្រូវការ ការអភិវឌ្ឍសេដ្ឋកិច្ច តែតម្រូវឲ្យមានការការពារបរិស្ថាន។ ប្រទេសទាំងនេះ ត្រូវការមធ្យោបាយកាត់បន្ថយនូវផលប៉ះពាល់ដល់បរិស្ថាន[1050] ស្របពេលដែលខ្លួនត្រូវធ្វើការសម្របសម្រួល ដើម្បីរស់ស្របទៅតាមបម្រែបម្រួលនៃអាកាសធាតុ (Adaptation)។ ជាសរុបសំណើសុំជំនួយក្នុងកិច្ចការពារបរិស្ថាន គឺជារឿងមួយដ៏សមហេតុផល។ ប្រទេសអភិវឌ្ឍន៍ ខណៈទទួលស្គាល់ នូវការទាមទារនេះ បានឆ្លើយតបក្នុងទម្រង់ជាជំនួយមនុស្សធម៌ ដែលមិនមែនជាកាតព្វកិច្ចទាមទារដោយច្បាប់អន្តរជាតិ តម្រូវឲ្យខ្លួនជួយ ប្រទេសកំពុងអភិវឌ្ឍឡើយ។

### ១១.២.២. យន្តការ

#### ១១.២.២.១. សន្និសីទរបស់រដ្ឋជាភាគី (Conference of States Parties)

សន្ធិសញ្ញាពាក់ព័ន្ធជាមួយនឹងបរិស្ថាន មិនបានចែងបង្កើតនូវ យន្តការណាមួយមានប្រសិទ្ធភាពសម្រាប់ តាមដាន និងឃ្លាំមើល ការអនុវត្តតាមកាតព្វកិច្ច ទាមទារក្នុងសន្ធិសញ្ញា ដោយរដ្ឋជាភាគីឡើយ។ សន្ធិសញ្ញា មានចែង

[1049] African Commission on Human Rights, the *Ogoni* case, *supra* note 1046, para. 56.

[1050] UNFCCC, *supra* note 1023, Art. 4.

អំពីសន្និសីទ ដោយរដ្ឋជាភាគី។[1051] សម្រាប់សន្និសញ្ញា ស្តីពី ក្របខ័ណ្ឌបម្រែបម្រួលអាកាសធាតុ សន្និសីទរបស់រដ្ឋជាភាគី គឺជាអង្គភាពកំពូល។ សន្និសីទ ធ្វើឡើងនៅរៀងរាល់ឆ្នាំ ដើម្បីពិនិត្យមើល នូវរបាយការណ៍អនុវត្តសន្និសញ្ញា ដាក់ចេញជាអនុសាសន៍ សម្រាប់ការអនុវត្តកាតព្វកិច្ច ឲ្យបានកាន់តែប្រសើរ សម្របសម្រួលឲ្យមានការផ្លាស់ប្តូរបទពិសោធ ព័ត៌មានពាក់ព័ន្ធ ការងារបម្រែបម្រួលអាកាសធាតុ។[1052] Cartagena Accord គឺជាសមិទ្ធផលមួយចេញពី សន្និសីទរបស់រដ្ឋជាភាគី ក្នុងសន្និសីទលើកទី ១៥ (២០០៩) នៅក្នុងទីក្រុង Cartegena។ ការពិត ឯកសារនេះ គ្រាន់តែសរសេរបញ្ចូលនូវអនុសាសន៍ ដែលមិនចងជាកាតព្វកិច្ចដល់រដ្ឋជាភាគីឡើយ។ កុំថាឡើយជាអនុសាសន៍ សូម្បីរដ្ឋបំពាន កាតព្វកិច្ចក្តីក៏ សន្និសីទរបស់ប្រទេសជាភាគី គ្មានអំណាច ឬលទ្ធភាពដើម្បីដាក់ទណ្ឌកម្មដល់រដ្ឋដែលបំពាននូវវិធានឡើយ។

### ១១.២.២.២. យន្តការដទៃទៀត

ដើម្បីបង្ខំឲ្យរដ្ឋអនុវត្តតាមកាតព្វកិច្ចថែរក្សាបរិស្ថាន បុគ្គលអាចប្តឹងចូលទៅតុលាការក្នុងស្រុក ឬ យន្តការអន្តរជាតិដទៃទៀត។ ប្រជាពលរដ្ឋប្រទេសហ្វីលីពីន បានប្តឹងទៅ តុលាការកំពូល ដើម្បីទាមទារឲ្យមានការទទួលស្គាល់ជាក់ស្តែង នូវសិទ្ធិមានបរិស្ថានល្អ សម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយ។ ចលនាគាំទ្រសិទ្ធិមនុស្ស បាននាំបណ្តឹង ទៅគណៈកម្មការសិទ្ធិមនុស្សនៃទ្វីបអាហ្វ្រិក សុំដំណោះស្រាយចំពោះការ រំលោភសិទ្ធិមានបរិស្ថាន

[1051] UNFCCC, *supra* note 1023, Art. 7; the UN Convention on Biological Diversity, Article 23 (www.unep.org).
[1052] For more details, *see* the UNFCCC, *supra* note 1023, Art. 7.

ល្អ ដោយក្រុមហ៊ុន ឯកជននៅក្នុងប្រទេស Nigeria។ ក្នុងសំណុំរឿងទាំងពីរនេះ តុលាការ និងគណៈកម្មការ បានចេញសេចក្តីសម្រេច ឲ្យភាគីប្តឹងឈ្នះ។ មានចំណុចមួយចំនួន ដែលគួរកត់សម្គាល់ទី១. ភាគីប្តឹងទាមទារឲ្យមានការការពារបរិស្ថាន ផ្អែកតាមសិទ្ធិទទួលស្គាល់ក្នុងរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញា។ ទី ២. បណ្តឹងនេះ ធ្វើឡើងដើម្បីប្តឹងប្រឆាំងនឹងរដ្ឋរបស់ខ្លួនតែប៉ុណ្ណោះ។

រដ្ឋជាភាគីណាមួយ អាចប្តឹងប្រឆាំងនឹងរដ្ឋជាភាគីណាមួយទៀត ទៅតុលាការយុត្តិធម៌អន្តរជាតិ។ ទំនាស់ ដែលជាកម្មវត្ថុនៃបណ្តឹង ត្រូវតែពាក់ព័ន្ធជាមួយការបកស្រាយ ឬការអនុវត្តសន្ធិសញ្ញា។ ដើម្បីឲ្យតុលាការយុត្តិធម៌អន្តរជាតិ អាចទទួល ពិនិត្យបណ្តឹងបាន លុះត្រាភាគីប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់តុលាការយុត្តិធម៌អន្តរជាតិ តាមរយៈសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ទាមទារដោយមាត្រា ៣៦ នៅពេលណាមួយ។ ជាចុងក្រោយ តុលាការទទួលយកបណ្តឹង ក្នុងករណី ដែលរដ្ឋជាចុងចម្លើយ ប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់តុលាការផងដែរ។[1053]

### ១១.២.២.៣. បញ្ហាប្រឈម

បញ្ហាបរិស្ថានជាបញ្ហាមួយដ៏ចម្រូងចម្រាស់ ពាក់ព័ន្ធជាមួយនឹងវិស័យជាច្រើន ដូចជា ពាណិជ្ជកម្ម សិទ្ធិមនុស្ស ការប្រើប្រាស់អាវុធនុយក្លេអ៊ែរ និងទំនាក់ទំនងរវាងវិធានច្បាប់អន្តរជាតិផ្សេងទៀត និងវិធានច្បាប់បរិស្ថាន។ ក្រៅពីបញ្ហាធនធានមនុស្ស និងបច្ចេកវិជ្ជា រដ្ឋត្រូវកែសម្រួលគោលនយោបាយ ទម្លាប់ រស់នៅរបស់មនុស្ស ដែលប៉ះពាល់ដល់បរិស្ថាន និងច្បាប់

[1053] The Statute of ICJ, *supra* note 58, Art. 36.

ដើម្បីជានាធ្វើយ៉ាងណាឲ្យមាន ការអភិវឌ្ឍដោយចីរភាព។ កិច្ចការងារការពារបរិស្ថាន វាអាចប៉ះអធិបតេយ្យភាព ធនធានធម្មជាតិ ដែលរដ្ឋត្រូវការ ដើម្បីការអភិវឌ្ឍ និងផលប្រយោជន៍សេដ្ឋកិច្ចរបស់រដ្ឋ។ នេះត្រូវបានឆ្លុះបញ្ចាំងដោយភាពស្ទាក់ស្ទើររបស់ប្រទេសអភិវឌ្ឍន៍មួយចំនួន ក្នុងការចូលជាភាគី និងចងជាកាតព្វកិច្ចតាមសន្ធិសញ្ញា។ បន្ថែមពីលើនេះ តុលាការ ឬស្ថាប័នអន្តរជាតិមួយចំនួន ដែលធ្វើការងារក្នុងវិស័យពាណិជ្ជកម្ម ហាក់នៅមានភាពស្ទាក់ស្ទើរក្នុងការលើកកម្ពស់ការការពារបរិស្ថាន ឬ ដាក់បញ្ចូលបញ្ហាបរិស្ថានចូលទៅក្នុងឯកសារការងាររបស់ខ្លួន។

យន្តការអនុវត្តគឺជាបញ្ហាមួយដោយឡែកផ្សេងទៀត ដែលត្រូវយកចិត្តទុកដាក់។ ដូចដែលបានបរិយាយកន្លងមក មានតែការប្តឹងដោយប្រជាពលរដ្ឋក្នុងស្រុកទៅតុលាការរបស់ខ្លួនតែប៉ុណ្ណោះ។ ការប្តឹងដោយប្រជាពលរដ្ឋរបស់ប្រទេសមួយប្រឆាំងនឹងរដ្ឋផ្សេង ចំពោះអំពើដែលរដ្ឋនោះ បានធ្វើក្នុងដែនដីខ្លួន ប៉ះពាល់ដល់បរិស្ថាន ដល់ប្រទេសមួយទៀត គ្រាន់តែជាសុបិនប៉ុណ្ណោះ។ ពីព្រោះ ប្រជាពលរដ្ឋទាំងនោះ អាចមិនមាន Legal Standing[1054] ឬប្រសិនបើមានក្តី តុលាការ អាចមិនទទួលយកបណ្តឹង ឬរកមិនឃើញនូវទំនាក់ទំនងរវាងអំពើរបស់រដ្ឋ និងផលប៉ះពាល់ដោយផ្ទាល់ កើតមានមកលើភាគីដែលប្តឹងដោយសារភាពមិនច្បាស់លាស់នៃវិទ្យាសាស្ត្រ ឬ រដ្ឋដែលជាចុងចម្លើយមិនបានទទួលស្គាល់សមត្ថកិច្ចរបស់តុលាការក្នុងការពិនិត្យមើលបណ្តឹង។ ជាចុងក្រោយ សម្រាប់ស្ថាប័នខ្លះ សេចក្តីសម្រេចមិនចងជាកាតព្វកិច្ច ឬប្រសិនបើចងជាកាតព្វក្តី ក៏មិនមានយន្តការចាប់បង្ខំយ៉ាង

[1054] Alfred, *Popularis, supra* note 46.

មានប្រសិទ្ធភាព ដើម្បីឲ្យរដ្ឋដែលប្រព្រឹត្តល្មើសនឹងវិធានការពារបរិស្ថាន ធ្វើតាមសេចក្តីសម្រេច។

ទោះបីជាមានបញ្ហាប្រឈមដូចដែលបានបរិយាយក្តី ក្តីសង្ឃឹមនៅតែមាន។ តុលាការក្នុងស្រុក បានចេញសេចក្តីសម្រេចតម្រូវឲ្យមានការការពារបរិស្ថាន ស្ថាប័នអន្តរជាតិ ជាច្រើន ដូចជា World Bank IMF UNDP ដែលថ្មីៗនេះ បានដាក់បញ្ចូលកិច្ចការងារ ការពារបរិស្ថានទៅក្នុងរបៀបវារៈការងាររបស់ខ្លួន។ ប្រទេសមួយចំនួន បានកែសម្រួល ច្បាប់ គោលនយោបាយ និងធ្វើច្បាប់ថ្មី ដើម្បីធានាឲ្យការអភិវឌ្ឍមិនបង្កការខូចខាតធ្ងន់ធ្ងរដល់បរិស្ថាន។ បន្ថែមពីលើនេះ រដ្ឋមួយចំនួនបានប្តឹងទៅតុលាការ ឬស្ថាប័នអន្តរជាតិ ដោយយកការការពារបរិស្ថានជាមូលដ្ឋាន។[1055] វិធានច្បាប់អន្តរជាតិពាក់ព័ន្ធនឹងបរិស្ថាន ទើបតែមានអាយុជាង ៣០ឆ្នាំតែប៉ុណ្ណោះ ដូចនេះ ការរំពឹងទុកខ្ពស់ពេក ពិតជាមិនត្រឹមត្រូវឡើយ។

## ១១.៣. សេដ្ឋកិច្ច

### ១១.៣.១. ប្រវត្តិ

ទ្រឹស្តី Merchandism អះអាងថា ប្រទេសមួយមានសេដ្ឋកិច្ចល្អ គឺជាប្រទេសដែលនាំចេញបានច្រើន ដែលប្រមូលចំណូលជូនជាតិបានច្រើន។ ទ្រឹស្តីនេះត្រូវបានសេដ្ឋកិច្ចវិទូ អះអាងថា មិនទាន់ត្រឹមត្រូវទាំងស្រុងប៉ុន្មានទេ តាមស្ថានការពិភពលោក។ អ្នកសេដ្ឋកិច្ចទាំងនោះ បានអះអាងថា ការនាំចូលច្រើនគឺល្អជាង។ ការនាំចូលច្រើននាំឲ្យមាន ការប្រកួតប្រជែងរវាងមុខទំនិញ

[1055] Legality of the threat, *supra* note 290, para. 25; ICJ, Case Concerning the Gabcikovo-Nagymaros, *supra* note 931, para. 140; ICJ, Case concerning Rulp Mills on the River Uruguay, *supra* note 1041, para. 177.

ដែលអ្នកប្រើប្រាស់អាចជ្រើសរើស ទទួលបានផលិតផលល្អ ក្នុងតម្លៃ សមស្រប ដោយសារអ្នកផលិតត្រូវការសម្រិតសម្រាំងគុណភាពដើម្បី ទីផ្សារ។ ទាញចេញពីគុណភាព រដ្ឋនីមួយៗ នឹងផ្តោតលើការផលិតច្រើន នូវផលិតផលល្អជាងគេ ( Specialization) ដែលខ្លួនអាចផលិតបានសម្រាប់ការនាំចេញ។ រដ្ឋមិនមែនចេះតែផលិតឲ្យបានច្រើន ទោះគ្មានគុណភាពសម្រាប់នាំចេញឡើយ។ រដ្ឋគួរទិញទំនិញ *X* ពីបរទេស ក្នុងតម្លៃថោកជាងផលិតផល *X* ដែលខ្លួនអាចផលិត និងលក់ក្នុងតម្លៃថ្លៃជាង (Exchange of Product)។ ក្នុងន័យនេះ រដ្ឋអាចសំចៃថវិកា សម្រាប់ចំណាយ ក្នុងវិស័យផ្សេង និងចូលរួមនូវការពង្រឹងនូវផលិតភាព។ ទោះបីជាមានការខ្វែងយោបល់ អំពីការនាំចេញ ឬការនាំចូលនូវទំនិញ ទ្រឹស្តីទាំងនេះ សុទ្ធតែជួយជំរុញឲ្យមាន លំហូរនៃប្រភពទុន ទំនិញ និង សាកលភាវូបនីយកម្មនៃពាណិជ្ជ-កម្ម។ នេះទាមទារឲ្យបង្កើតយន្តការពាណិជ្ជកម្មមួយ ដែលជានាលំហូរនៃផលិតផល ដែលផ្អែកតាមជាចម្បងលើគោលគំនិតសេរីនិយម។[1056] ការបង្កើតប្រព័ន្ធសេដ្ឋកិច្ចនេះ ឆ្លុះបញ្ចាំង នូវបំណងរបស់ប្រទេសនាំចេញជាចម្បង ដែលនាពេលនោះ មានសហរដ្ឋអាមេរិក ប្រទេសក្នុងទ្វីបអឺរ៉ុប ហើយដែលប្រព័ន្ធនេះ មិនបាន គិតអំពីបញ្ហា ដែលប្រទេសកំពង់អភិវឌ្ឍបានជួបប្រទះឡើយ។ ប្រទេសកំពង់អភិវឌ្ឍខ្លះ កំពុងជួបបញ្ហា នៃការអត់ការងារធ្វើស្របពេលនេះ ត្រូវបើកចំហរទីផ្សារដើម្បីទទួលទំនិញពីខាងក្រៅ អាចនឹងនាំឲ្យមានការបិទទ្វាររោងចក្រ ធ្វើឲ្យបញ្ហាអត់ការងារធ្វើ កាន់តែធ្ងន់ធ្ងរប្រសិនបើប្រទេសនេះ មិនពូកែទាក់ទាញ បានការវិនិយោគផ្ទាល់ពីបរទេស។ នេះដោយមិនគិតដល់ការកាត់បន្ថយ ពន្ធនាំចូល តាមលក្ខខណ្ឌតម្រូវដោយ

[1056] Rudiger Wolfrum, WTO-World Economic Order, World Trade Law, 2006, p. 33.

អង្គការពាណិជ្ជកម្មពិភពលោក ដែលកាត់បន្ថយមួយចំណែកនៃចំណូលជាតិរបស់ប្រទេសកំពុងអភិវឌ្ឍ។

### ១១.៣.២. GATT និងគោលការណ៍ចម្បង

ឆ្នាំ ១៩៤៧ កិច្ចព្រមព្រៀងទូទៅ ស្តីពី តារាងពន្ធគយ និងពាណិជ្ជកម្ម (General Agreement on Tariff and Trade) ត្រូវអនុម័តឡើង។[1057] ក៏ប៉ុន្តែសហគមន៍អន្តរជាតិ មិនបានបង្កើតចេញរូបរាងជាផ្លូវការ នូវប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិទេ ដោយសារគោលបំណងរបស់ GATT គឺរឹតកម្រិតសកម្មភាពពាណិជ្ជកម្មរបស់រដ្ឋ តាមរយៈការកាត់ បន្ថយពន្ធនាំចូល។[1058] GATT គ្រាន់តែជាយន្តការបណ្តោះអាសន្ន។[1059] GATT មិនមានចែងអំពីការប្រព្រឹត្តដោយឡែកសម្រាប់ប្រទេសកំពុងអភិវឌ្ឍទេ។ វាគ្រាន់តែអំពាវនាវឲ្យមានការពិចារណា នូវសេចក្តីត្រូវការរបស់រដ្ឋទាំងនោះ ដោយសាររដ្ឋទាំងនោះភាគច្រើន ពុំទាន់បានឯករាជ្យ ហើយការប្រព្រឹត្តលម្អៀង អាចនាំឲ្យផ្ទុយនឹងគោលការណ៍ Most Favored Nations Clause (MFN)របស់ GATT។[1060] ឆ្នាំ១៩៧៩ គោលការណ៍ជួយជ្រោមជ្រែង (Enabling Clause) ដែលផ្តល់ការប្រព្រឹត្តឃោគយល់ពាក់ព័ន្ធពន្ធនាំចូល (Preferen tial Tariff) សម្រាប់ប្រទេសកំពុងអភិវឌ្ឍ តែជាជម្រើស និងមិនមែន

---

[1057] GATT, October 1947, UNTS 55, 94.

[1058] Rudiger Wolfrum, WTO, *supra* note 1056, pp. 12-13

[1059] *Id.,* p. 13; Peter Malanczuk, IL, *supra* note 1, p. 228.

[1060] WTO, the WTO Agreement Series, General Agreement on Tariffs and Trade, 1998, p. 2, www.wto.org/wto/publicat/publicat.htm.

ជាកាតព្វកិច្ច ត្រូវបានអនុម័ត។[1061] ទោះបីជាយ៉ាងនេះក្តី កិច្ចព្រមព្រៀង បានដាក់ចេញនូវវិធានចម្បងជាច្រើន ដែលក្រោយមក ត្រូវរក្សា និងបញ្ចូល ក្នុងកិច្ចព្រមព្រៀងក្នុងការបង្កើត អង្គការពាណិជ្ជកម្មពិភពលោក (The World Trade Organization) ក្នុងឆ្នាំ ១៩៩៤។[1062]

### ១១.៣.២.១. ការប្រព្រឹត្តដូចគ្នាចំពោះរដ្ឋ (Most Favor Nation :MFN)

មាត្រា ១ កិច្ចព្រមព្រៀមបានចែងពីវិធាននេះ[1063] ដោយទាមទារថា ប្រសិន បើរដ្ឋជាភាគីណាមួយ កំណត់ពន្ធនាំចូលសម្រាប់ទំនិញណាមួយដល់រដ្ឋណា មួយ ត្រូវកំណត់ដូចគ្នាសម្រាប់រដ្ឋជាភាគីទាំងអស់។[1064] វិធាននេះ មានវិសាលភាពទូលំទូលាយណាស់ គឺក្តោបក្រសោបទាំងអ្វី ដែលជាផល ប្រយោជន៍ផ្តល់ដល់រដ្ឋ និងអ្វីដែលរដ្ឋបដិសេធសម្រាប់រដ្ឋមួយទៀត លើក លែងសម្ភារ ដូចជាការដឹកជញ្ជូន។[1065] មូលហេតុនៅពីខាងក្រោយវិធាននេះ គឺជាការធានាឲ្យមាន លំហូរដោយសេរី តាមរយៈ ការប្រព្រឹត្តដោយស្មើរវាង រដ្ឋ និង រដ្ឋក្នុងវិស័យពាណិជ្ជកម្ម។ ការចរចា រវាងរដ្ឋនឹងរដ្ឋ ដើម្បីទទួលបាន មកវិញនូវការសន្យាកាត់បន្ថយពន្ធនាំចូល ជាថ្នូរទៅនឹងអ្វីដែលខ្លួនបានធ្វើ សម្បទាន ដែលជាផ្នែកមួយនៃការត្រៀមចូលជាសមាជិករបស់អង្គការពាណិ ជ្ជកម្មពិភពលោក ក៏តម្រូវឲ្យគោរពគោលការណ៍នេះដែរ។ លទ្ធផលនៃការ

---

[1061] Uruguay Round ended in 1994, modified old GATT to become consolidated and essentially enlarged system for the world trade order, *see* Rudiger Wolfrum, WTO, *supra* note 1056, p. 13.

[1062] WTO, the WTO Agreement, *supra* note 1060, p.1.

[1063] The 1947 GATT, *supra* note 1057.

[1064] The WTO Agreement, *supra* note 1060, pp. 2-3; Peter Malanczuk, IL, *supra* note 1, p. 229.

[1065] Peter Malanczuk, IL, *supra* note 1, p. 229.

កាត់បន្ថយពន្ធនេះ ក៏នឹងទទួលបានដោយរដ្ឋ ជាសមាជិកដទៃទៀតរបស់ WTO និងសមាជិក ដែលនឹងក្លាយ ជាភាគីរបស់ WTO។

ការប្រព្រឹត្តិទាមទារទាំងនៅទីផ្សារក្នុងស្រុក និងនៅឯព្រំដែន។ ទោះបីជាយ៉ាងនេះក្តី ការអនុវត្តវិធាននេះ ក៏មានការកម្រិតផងដែរ។ ការប្រព្រឹត្តិលើរដ្ឋជាភាគី ចំពោះទំនិញនាំចូល ពីប្រទេសកំពុងអភិវឌ្ឍន៍ ដោយយោគយល់ដល់ប្រទេសនេះ មិនខុសពីគោលការណ៍ MFN ឡើយ។[1066]

**១១.៣.២.២. ឧបត្ថម្ភធន** (Subsidies)

វាជាជំនួយមួយ ជាទូទៅ ជាថវិកា សម្រាប់ជួយក្រុមហ៊ុនក្នុងស្រុក។ តាមរយៈនេះ ក្រុមហ៊ុនក្នុងស្រុក ជាប្រយោល អាចលក់ទំនិញរបស់ខ្លួន ទោះបីជាក្នុង ឬក្រៅប្រទេសក្តីក្នុងតម្លៃថោក ដែលពិបាកឲ្យទំនិញដូចគ្នា នាំ ចូលពីប្រទេសក្រៅ អាចលក់ដោយប្រកួតប្រជែងបាន។[1067] ទង្វើនេះវាខុសពីបទប្បញ្ញត្តិពាក់ព័ន្ធ Anti-Dumping[1068] និងខុសអំពី វិធានដែលទាមទារឲ្យមានការប្រព្រឹត្តដូចគ្នារវាង ទំនិញដូចគ្នាផលិតនៅក្នុងស្រុក នាំចូលនៅក្នុងទីផ្សារក្នុងស្រុក។[1069]

---

[1066] The 1947 GATT, Art. XXIV, *supra* note 1057; the WTO, WTO Agreement Series, GATT, *supra* note 1060, pp. 2-3.

[1067] The 1947 GATT, *supra* note 1057, Art. XVI.

[1068] It prohibits State from selling goods in own territory higher price, but in other State low price for the same product. Such a trade will cause material injury to domestic industries. State takes action against dumping, shall prove that there is dumping; the 1947 GATT, *supra* note 1057, Art. VI.

[1069] The 1947 GATT, *supra* note 1057, Art. III.

អ្វីដែលជាផលិតផលស្រដៀងគ្នា (Like Product) គឺជារឿងមួយស្មុគស្មាញ។ ស្រា Volka អាចស្រដៀងគ្នានឹង ស្រាសរបស់កម្ពុជា។ ការផ្តល់ន័យអាចផ្អែកតាមរូបរាង បំណងនៃការប្រើប្រាស់។ គេក៏អាចប្រើ ទ្រឹស្តីតេស្តលើផលិតផលជំនួស (Substitute Test) ផងដែរ។ នេះមានន័យថា អ្នកប្រើប្រាស់អាចជំនួយស្រាស ដោយស្រា Volka។ គេត្រូវធ្វើការអង្កេតដើម្បីបានលទ្ធផលដូចនេះ។

ក្នុងដំណើរការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនមួយ ក្នុងប្រទេសមួយ ក្រុមហ៊ុនមួយអាចយកប្រយោជន៍ពីហេដ្ឋារចនាសម្ព័ន្ធ របស់រដ្ឋ ដូចជាស្ពាន ឬផ្លូវជាដើម។ នេះមិនមែនជា ការជួយរបស់រដ្ឋាភិបាល ក្នុងន័យដែលមានចែងហាមប្រាមក្នុងកិច្ចព្រមព្រៀងឡើយ។ នេះដោយសារ វាជាកិច្ចការទូទៅរបស់រដ្ឋ ហើយមិនគ្រាន់តែ ក្រុមហ៊ុនគ្រប់គ្រងដោយប្រជាពលរដ្ឋរបស់រដ្ឋទេ ក្រុមហ៊ុនរបស់បរទេស ក្នុងរដ្ឋ ក៏ទទួលបានផលប្រយោជន៍ពីហេដ្ឋារចនាសម្ព័ន្ធដែរ។ ដូចគ្នានេះដែរ ការណ៍ដែលធនាគាររដ្ឋ ឲ្យប្រាក់កម្ចីដល់ក្រុមហ៊ុនក្នុងស្រុកក្នុងអាត្រាការប្រាក់ធម្មតាទូទៅ មិនមែនជា Subsidies ទេ។ តាមន័យនេះគេអាចនិយាយបានថា ការហាមឃាត់ Subsidies មានទំនាក់ទំនងជាមួយគោលការណ៍មិនរើសអើង (Principle of Non-Discrimination)។

### ១១.៣.២.៣. ការការពារ (Safeguard)

ជាវិធានការមួយអនុញ្ញាតឲ្យរដ្ឋចាត់វិធានការការពារឧស្សាហកម្មក្នុងស្រុកនៅពេលដែល ចំនួននាំចូលច្រើនលើសកំណត់ ហើយវាជាព្រឹត្តិការណ៍ដែល មិនអាចឃើញជាមុន។[1070] រដ្ឋត្រូវបង្ហាញថា កំណើនចំនួននោះ ប៉ះពាល់ធ្ងន់ធ្ងរ

[1070] The 1994 GATT, Art. I (www.wto.org/english/docs_e/legal_e/06-gatt_e.htm).

(serious injury) ដល់ឧស្សាហកម្មក្នុងស្រុក។[1071] រដ្ឋ អាចហាមមិនឲ្យនាំទំនិញប្រភេទណាមួយ ពីប្រទេសណាមួយ។ ដូចនេះវិធានការនេះ ជាការលើកលែងចំពោះការហាមមិនកំណត់ចំនួន (quota)[1072] សម្រាប់នាំចូល។

### ១១.៣.៣. GATT ទៅជា WTO

ដូចដែលបាននិយាយរួចមកហើយ GATT ក្នុងឆ្នាំ ១៩៤៧ គ្រាន់តែយន្តការបណ្ដោះអាសន្ន។ ឆ្នាំ ១៩៩៤ មានការកែសម្រួល GATT ដោយដាក់បញ្ចូលនូវ គោលការណ៍យោគយល់ដល់ប្រទេសកំពុងអភិវឌ្ឍ ក៏ប៉ុន្តែវាមិនមែនជាកាតព្វកិច្ចនោះទេ។[1073] ក៏ប៉ុន្តែ GATTឆ្នាំ ១៩៩៤ មិនបានបង្កើតនូវយន្តការណាមួយឡើយ។ ដោយមានកិច្ចខិតខំប្រឹងប្រែង និងឆ្លងកាត់កិច្ចពិភាក្សាជាច្រើន[1074] កិច្ចព្រមព្រៀង បង្កើតអង្គការពាណិជ្ជកម្មពិភពលោក ត្រូវបានអនុម័ត។[1075] GATT ត្រូវបាន រាប់បញ្ចូលទៅក្នុងផ្នែកមួយរបស់ កិច្ចព្រមព្រៀង WTO ហើយភាគីរបស់ GATT តម្រូវឲ្យក្លាយជាភាគីរបស់ WTO ។[1076] រដ្ឋដែលចូលជាភាគីរបស់ WTO ត្រូវរាប់ថាជាភាគីរបស់ GATT

[1071] Anti-Dumping Agreement, Article 1; 1994 GATT, *supra* note 1070, Article VI; 1947 GATT, *supra* note 1057, Article XIX; Peter Malanczuk, *supra* note 1, p. 230.
[1072] The 1947 GATT, Article XI prohibits ban on import quota. One of measures is licencing scheme. State can manipulate by change from import quota to increese tariff which is a trade barrier. Other barrier is technecal one (labelling for example); Peter Malanczuk, IL, *supra* note 1, p. 229.
[1073] The 1994 GATT, *supra* note 1070, Art. I.
[1074] Example, Tokyo Round of 1937-1979.
[1075] Rudiger Wolfrum, WTO, *supra* note 1056, p. 14; Agreement Establishing the World Trade Organization, LT/UR/A/2, 15 April 1994, entered into force on 1 January 1995, *see* the WTO Agreement, Art. II(1).
[1076] Chiara Giorgetti, the Rules, Practice, and Jurisprudence of Interntional Courts and Tribunals, 2012, p. 133; WTO Agreement, *supra* note 1075, Art. XI.

ផងដែរ។[1077] កិច្ចព្រមព្រៀង WTO ជាកិច្ចព្រមព្រៀងរួមមួយ ចែងពីវិធាន ពាក់ព័ន្ធជាច្រើន និងមានវិសាលភាពទូលាយជាង GATT ដូចជាបញ្ហា កិច្ចព្រមព្រៀងសេដ្ឋកិច្ចតំបន់ជាដើម។[1078] កិច្ចព្រមព្រៀង បានបង្កើត អង្គការពាណិជ្ជកម្មពិភពលោក ដែលជាស្ថាប័នមួយ នៅក្រៅក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិ។

រចនាសម្ព័ន្ធរបស់ WTO មាន សន្និសីទថ្នាក់រដ្ឋមន្ត្រី (Ministerial Conference) [1079] អគ្គក្រុមប្រឹក្សា (General Council)[1080] មានតួនាទី ដោះស្រាយជម្លោះរវាងភាគី។ ក្រុមប្រឹក្សា មានស្ថាប័នពិសេស ដែលមានតួនាទី ត្រួតពិនិត្យកិច្ចព្រមព្រៀង ស្ដីពី ពាណិជ្ជកម្មនៃសេវាកម្ម (Council for Trade in Service) [1081] និង ក្រុមប្រឹក្សាពាណិជ្ជកម្មលើទំនិញ (Council for Trade in Goods)។ [1082] សន្និសីទថ្នាក់រដ្ឋមន្ត្រី នឹងបង្កើតគណៈកម្មាធិការពាណិជ្ជកម្ម និងការអភិវឌ្ឍ[1083] គណៈកម្មាធិការថវិកា។ [1084] កិច្ចព្រមព្រៀង បានបង្កើតយន្តការដោះស្រាយជម្លោះ ដែល មានលក្ខណៈដោយឡែក និងមានអំណាចជាច្រើន បើប្រៀបធៀបជាមួយ យន្តការដោះស្រាយជម្លោះក្នុងវិស័យផ្សេងទៀតនៃច្បាប់អន្តរជាតិ។[1085]

---

[1077] It is not only State that can be a party to the WTO Agreement, entity with custom administration is also entitled to become a party, such as European Union and Hong Kong.

[1078] Rudiger Wolfrum, WTO, *supra* note 1056, pp. 14-15.

[1079] The WTO Agreement, *supra* note 1075, Art. IV(1).

[1080] *Id.,* Art. IV (2).

[1081] *Id.,* Art. IV (5).

[1082] *Id.*, Art. IV(5).

[1083] *Id.*, Art. IV (7).

[1084] *Id.,* Art. IV(7).

[1085] Rudiger Wolfrum, WTO, *supra* note 1056, p. 70.

រដ្ឋដែលចង់ចូលជាភាគីរបស់ TWO ត្រូវបំពេញលក្ខខណ្ឌមួយចំនួន ដូចជា រៀបចំច្បាប់ដែលពាក់ព័ន្ធ ធ្វើឲ្យមានតម្លាភាពអំពីច្បាប់ និងផ្សព្វផ្សាយខ្លឹមសារឲ្យរដ្ឋដទៃទៀតបានដឹង។ រដ្ឋត្រៀមចូលជាសមាជិក ត្រូវបានតម្រូវឲ្យមានការចរចាបញ្ចុះ នូវពន្ធនាំចូល ព្រមទាំងផ្តល់សម្បទាន ពាក់ព័ន្ធពាណិជ្ជកម្ម ដើម្បីឲ្យមានការគាំទ្រពីប្រទេសដទៃទៀតសម្រាប់ចូលជាសមាជិករបស់ WTO។

## ១១.៣.៤. យន្តការដោះស្រាយជម្លោះ

តាម GATT រដ្ឋត្រូវធ្វើការពិគ្រោះយោបល់រវាងរដ្ឋ និងរដ្ឋ ហើយប្រសិនបើរដ្ឋពិចារណាឃើញថា រដ្ឋណាមួយធ្វើសកម្មភាពប៉ះពាល់ខ្លួន ត្រូវដាក់ពាក្យជាលាយលក្ខណ៍អក្សរ និងស្នើឲ្យមានអន្តរាគមន៍ពីរដ្ឋដទៃទៀត។[1086] ជាបន្ថែម រដ្ឋត្រូវបង្ហាញថាមាន ការរំលោភកាតព្វកិច្ច និងមានការខូចខាតដល់ខ្លួន។ នីតិវិធីចំណាយពេលវេលាច្រើន រដ្ឋមិនសហការ ហើយរដ្ឋអាចជំទាស់នូវអន្តរាគមន៍ណាមួយ។ ដោយសារយន្តការនេះ មិនមានប្រសិទ្ធភាព ទើបនាំឲ្យមានការបង្កើតយន្តការតាមកិច្ចព្រមព្រៀង WTO។

យន្តការដោះស្រាយជម្លោះ ត្រូវបានបង្កើតឡើង តាមកិច្ចព្រមព្រៀងដោះស្រាយជម្លោះ (Dispute Settlement Understanding: DSU) ដែលមានចរិតជាការផ្សះផ្សា និងតាមផ្លូវតុលាការ។ ឯកសារនេះ ជាផ្នែកមួយនៃកិច្ចព្រមព្រៀង WTO។ ភាគីនៃកិច្ចព្រមព្រៀង WTO ត្រូវបានសន្មតថាទទួលយកយុត្តាធិការរបស់ DSB ដូចនេះរដ្ឋចុងចម្លើយ ត្រូវទទួលយកសមត្ថកិច្ច

[1086] 1947 GATT, *supra* note 1057, Arts. XXII and XXIII(1), *see* Chiara Giorgetti, the Rules, Practice, *supra* note 1076, p. 138.

នៃ Panel ប្រសិនបើសមាជិកណាមួយ បានស្នើឲ្យបង្កើត។[1087] យន្តការនេះ មាន Dispute Settlement Body (DSB) លេខាធិការដ្ឋានផ្នែកច្បាប់ Panel និង Appellate Body។[1088] លេខាធិការដ្ឋានក្រៅពីតួនាទី ស្រាវជ្រាវច្បាប់ មានតួនាទីជួយធ្វើសេចក្តីព្រាងរបាយការណ៍សម្រាប់[1089] Panel ដែលមានតួនាទីពិនិត្យពិចារណាបណ្តឹងរបស់រដ្ឋ និងជួយដល់ DSB ដាក់ចេញជាអនុសាសន៍។[1090] Appellate Body ជាស្ថាប័នអចិន្ត្រៃយ៍របស់ DSB មានតួនាទីពិនិត្យ ពិចារណាមើលបញ្ហាច្បាប់ ក្នុងរបាយការណ៍អនុសាសន៍របស់ Panel ។[1091]

ជាបឋម ភាគីទាំងពីរត្រូវធ្វើការចរចា ក្នុងកន្លែងរបស់ DSB ដោយគ្មានវត្តមានរបស់បុគ្គល ឬរដ្ឋទី៣។ ប្រសិនបើមិនបានសម្រេច ក្នុងរយៈពេល ៦០ថ្ងៃ រដ្ឋដើមបណ្តឹង អាចស្នើឲ្យ DSB បង្កើត Panel ។[1092]ភាគីដើមបណ្តឹងធ្វើលិខិតជូនដំណឹងទៅ DSB តាមរយៈលេខាធិការដ្ឋាន ដើម្បីបង្កើត Panel លើកលែង DSB មិនឯកភាពបង្កើត។ DSB នឹងជូនដំណឹង ទៅរដ្ឋមួយទៀត ដោយបង្ហាញថាមានការ បំពានកាតព្វកិច្ចដោយរដ្ឋមួយទៀត។ រដ្ឋទាំងពីរអាចស្នើសមាសភាព ក៏ប៉ុន្តែក្នុងករណីមិនអាចព្រមព្រៀងបាន DSB នឹងសម្រេចអំពីសមាសភាព ដែលមានចំនួន ៣រូប។[1093] ក្នុងដំណើរ

[1087] Chiara Giorgetti, the Rules, Practice, *supra* note 1076, p. 142.
[1088] Chiara Giorgetti, the Rules, Practice, *supra* note 1076, p. 139.
[1089] DSU, *supra* note 1086, Art. 27.
[1090] *Id.*, Art. 11.
[1091] *Id.*, Art. 17.
[1092] Chiara Giorgetti, the Rules, practices, *supra* note 1076, p. 138; DSU, *supra* note 1086, Article 5.
[1093] Helmut, the Concise of the UN, *supra* note 8, pp. 905-906; the DSU, *supra* note 1086, Art. 8(5).

ការនៃការដោះស្រាយជម្លោះ រដ្ឋដែលមានជម្លោះមិនត្រូវធ្វើអ្វីនាំឲ្យជម្លោះកាន់តែមានភាពធ្ងន់ធ្ងរ រហូតដល់មានចេញសេចក្តីសម្រេចឡើយ។[1094]

Panel ដំណើរការស្តាប់ការអះអាងរបស់ភាគីទាំងពីរ និងសម្រេចចេញជារបាយការណ៍ ដែលនៅក្នុងនោះមានសរសេរបញ្ចូលនូវអនុសាសន៍។ រដ្ឋដែលអាចមានផលប្រយោជន៍ ក៏អាចចូលរួម និងធ្វើការសង្កេតជាលាយលក្ខណ៍អក្សរ។[1095] Panel ក៏ទទួលនូវយោបល់ ពីអ្នកជំនាញដែរ ក៏ប៉ុន្តែមានការខ្វែង យោបល់រវាងភាគី ពីព្រោះ ចរិតលក្ខណៈលម្អៀងនៃយោបល់ខ្លះ។[1096] Panel ត្រូវដំណើរការក្តីទាំងស្រុងឲ្យចប់ក្នុងរយៈពេល ៦ខែ ក្នុងករណីបន្ទាន់ ក្នុងរយៈពេល ៣ខែ។[1097] Panel ត្រូវអនុញ្ញាតឲ្យរដ្ឋជាភាគីដាក់អំណះអំណាងមកខ្លួនក្នុងពេលកំណត់ណាមួយ បន្ទាប់មក Panel នឹងចេញរបាយការណ៍ បណ្តោះអាសន្ន ទុកឲ្យភាគីនៃក្តីពិនិត្យ មុនបញ្ជូនរបាយការណ៍របស់ខ្លួន ទៅ DSB។[1098] របាយការណ៍ នឹងត្រូវបញ្ជូនទៅភាគីក្នុងអំឡុងពេល ៦០ថ្ងៃ ក្រោយពីទទួលរបាយការណ៍ ភាគីមិនប្តឹងឧទ្ធរណ៍ ឬ DSB មិនជំទាស់នឹងរបាយការណ៍ របាយការណ៍ នឹងត្រូវបានចាត់ថាទទួល

[1094] DSU, *supra* note 1086, Art. 23; USA's Trade Act, Section 30 (1) allows USA to take unilateral measure to response to party breach obligation toward it. This is reason to have such a statement in Article 23.

[1095] The DSU, *supra* note 1086, Arts. 10 and 12.

[1096] In "Shrim case", brief from the Western environmental organiztion suppoted the USA measure to ban import of shrim caught from means which catches turtle; in the "Retreaded tyres case", brief supported the ban by Brazil on import of retreaded tyres due to environmental concern (retreaded tyres are worse, will be out of use and become place of mosquito if not well disposed; the DSU, *supra* note 1086, Art. 13.

[1097] The DSU, *supra* note 1086, Art. 12(8).

[1098] *Id.*, Art. 15.

យក ហើយអនុសាសន៍ក្នុង របាយការណ៍នឹងចងជាកាតព្វកិច្ច (Reversal Consensus)។[1099] ភាគីមិនពេញចិត្តនឹងរបាយការណ៍ អាចដាក់ ពាក្យបណ្តឹងទៅ Appellate Body ក្នុងអំឡុង ៦០ថ្ងៃ ក្រោយពីមានរបាយការណ៍ ប្រសិនបើមិនពេញចិត្តខ្លឹមសារនៃអនុសាសន៍ ពាក់ព័ន្ធនឹងបញ្ហាច្បាប់។ Appellate Body មានសមាជិកចំនួន ៧រូប ជ្រើសរើសដោយ DSB និងត្រូវធ្វើកិច្ចការងារ ឲ្យចប់ក្នុងរយៈពេល ៣ខែ ។[1100] ជាទូទៅ Appellate Body មិនមើលសំណុំរឿងជាថ្មីឡើយ។ Appellate Body ពិនិត្យ ពាក្យបណ្តឹងជាសម្ងាត់ ផ្អែកតាមព័ត៌មានផ្តល់ដោយ ភាគីពាក់ព័ន្ធនឹងក្តីក្តាំ និងរដ្ឋទី៣ នឹងសរសេររបាយការណ៍មានអនុសាសន៍ ដោយគ្មានវត្តមាន របស់ភាគី។ អនុសាសន៍ត្រូវបញ្ជូន ទៅ DSB ហើយនឹងភ្ជាប់កាតព្វកិច្ច ប្រសិនបើ DSB មិនជំទាស់ និងក្លាយជាអនុសាសន៍ចុងក្រោយបិទផ្លូវតវ៉ា។[1101]

ភាគីដែលចាញ់ក្តីត្រូវអនុវត្តន៍តាមអនុសាសន៍ឲ្យបានទាំងស្រុងក្នុងរយៈពេលសមស្រប (Reasonable Period of Time)។ មានការបកស្រាយថា រយៈពេលនេះ គឺ ១៥ ខែ។[1102] ជាទូទៅមានការអនុវត្តតាម ក៏ប៉ុន្តែមិនបានក្នុងអំឡុងនៃពេលវេលា ដែលត្រូវបានកំណត់ឡើយ ពីព្រោះរដ្ឋត្រូវការពេលវេលាច្រើន ឧទាហរណ៍បើអនុសាសន៍ទាមទារឲ្យមានការកែប្រែច្បាប់ណាមួយ។ DSB ជាស្ថាប័នពិនិត្យមើលការអនុវត្តអនុសាសន៍។[1103] បើភាគីមិនអនុវត្តតាមអនុសាសន៍ នឹងមានវិធានការបង្ខំឲ្យអនុវត្ត តាមរយៈការចាត់

[1099] Chiara Giorgetti, the Rules, practice, *supra* note 1076, p. 139.
[1100] The DSU, *supra* note 1086, Art. 17.
[1101] *Id.*, Art. 17.
[1102] *Id.,* Art. 21 (4).
[1103] *Id.*, Art. 21(6).

វិធានតបត (Countermeasure) ដូចជា ការដកនូវសម្បទានពន្ធលើទំនិញនាំចូលពីរដ្ឋនោះ។ មុននឹងដាក់ចេញនូវវិធានការ ត្រូវមានការចរចារជាមុនជាមួយរដ្ឋនោះសិន ហើយ DSB មិនជំទាស់នឹងវិធានការនោះផងដែរ។[1104]

Panel និង Appellate Body ខុសពីស្ថាប័នដទៃដូចជា តុលាការសិទ្ធិមនុស្ស បានបកស្រាយច្បាប់ ដោយផ្តោតទៅលើន័យនៃពាក្យជា សំខាន់មិនផ្តោតទៅលើគោលបំណងនៃសន្ធិសញ្ញា ដែលពាក់ព័ន្ធទេ ពីព្រោះគោលបំណងអាចមានពីរយ៉ាងតិច គឺ សេរីភាវូបនីយកម្ម និង ការពារទីផ្សារក្នុងស្រុក ដែលទាំងពីរនេះ ពិបាកថ្លឹងថ្លែងជាមួយគ្នា។ អ្នកសិក្សាស្រាវជ្រាវ បានស្នើថា ការបកស្រាយ គួរជួយធានានូវភាពចាំបាច់នៃស្ថេរភាពប្រព័ន្ធពាណិជ្ជកម្មពហុភាគី។[1105]

### ១១.៣.៥. បញ្ហាពាណិជ្ជកម្ម សុខភាព និង បរិស្ថាន

ទាញចេញពីយុត្តិសាស្ត្រ DSB ហាក់មានភាពស្ទាក់ស្ទើរក្នុងការពិភាក្សាបញ្ហាបរិស្ថានក្នុងវិស័យពាណិជ្ជកម្ម។ ការខកខានមិនបានបង្កើត គណៈកម្មាធិការពាណិជ្ជកម្ម និងបរិស្ថាន ជាឧទាហរណ៍មួយគាំទ្រ សេចក្តីសន្និដ្ឋាននេះ។ ស្ថាប័នដោះស្រាយជម្លោះ បានពិនិត្យដោយប្រយោល បញ្ហាបរិស្ថានក្នុងបណ្តឹងពាក់ព័ន្ធមាត្រា ២០ (General Exception)។ មានបណ្តឹងមួយចំនួនមកហើយ ពាក់ព័ន្ធ នឹងវិធានការហាមឃាត់ការនាំចូលទំនិញ ដោយផ្អែកលើមូលដ្ឋានក្នុងមាត្រា២០។ សហរដ្ឋអាមេរិក បានហាមមិនឲ្យ នាំចូលនូវបង្កង (Shrim) ដែលត្រូវបានចាប់ប៉ះពាល់ដល់សត្វកន្ធាយ ដោយផ្អែក

[1104] Chiara Giorgetti, the Rules, practice, *supra* note 1076, p. 138.
[1105] Lorand Bartels, *Applicable Law in WTO Dsipute Settlement Proceedings*, 35(3) Journal of World Trade, 2001, p. 519

លើមូលដ្ឋានចាំបាច់ការពារបរិស្ថាន។ Appellate Body រកឃើញថា ទង្វើនេះ មានយុត្តិកម្មក្រោមមាត្រា ២០ (ក) តែមាន ចរិតបំពារបំពាន ពីព្រោះមិនបានគិតដល់ស្ថានភាពរបស់ប្រទេសនីមួយៗ និងខកខានមិនបាន ចរចាជាមុន មុននឹងចាត់វិធានការជាឯកតោភាគី។[1106]

### ១១.៣.៦. ទំនាក់ទំនងរវាង កិច្ចព្រមព្រៀង WTO និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (Free Trade Agreement: FTA)

កិច្ចព្រមព្រៀង WTO មិនហាមឃាត់ FTA ទេទោះបីជា រដ្ឋនៅក្នុងកិច្ចព្រមព្រៀងអាចទទួលផលប្រយោជន៍ពិសេស ខុសពី WTOក្តី។ FTA ត្រូវតែមានតួនាទី ជួយពង្រឹង ពាណិជ្ជកម្មសេរី។ រដ្ឋក្នុង FTA មិនត្រូវទទួលបាន ការបញ្ចុះពន្ធនាំចូលប្រទេសរបស់ខ្លួន ទាបជាង មុននឹងចូលជាភាគី FTA ដែលផ្តល់ដល់រដ្ឋមិនមែនជាភាគី FTA ឡើយ។ ក្នុងករណី មានការខុសគ្នា រវាងកិច្ចព្រមព្រៀងទាំងពីរនេះ កិច្ចព្រមព្រៀង WTO នឹងមានឋានានុក្រម ខ្ពស់ជាង។[1107]

## ១១.៤. លំហអាកាស

លំហអាកាស (Outer Space) ស្ថិតនៅហួសពីអាកាស (Air Space) ដែលស្ថិតនៅក្នុងដែនអធិបតេយ្យភាពរបស់រដ្ឋ ហើយជាលំហដែលយន្តហោះហោះហើរ។ ចម្ងាយលំហអាកាសពីផែនដី មិនមានភាពច្បាស់លាស់ទេ។ ផ្កាយរណប នៅក្នុង លំហអាកាស អាចមានចម្ងាយពីរដងឆ្ងាយជាង

[1106] United States-Import Prohibition of Certain Shrimp and Shrimp Products, Report of the Appellate Body of the World Trade Organization, 12 October 1998, para. 186, WT/DS58/AB/R.

[1107] The TWO Agreement, *supra* note 1075, Art. XVI (3).

កម្រិតកម្ពស់អតិបរមា ដែលយន្តហោះអាចហោះហើរបាន។ [1108] ដូចនេះ លំហអាកាសរបស់រដ្ឋមិនអាច ឆ្ងាយដូចចម្ងាយផ្កាយរណប ពីផែនដីទេ។

ក្នុងឆ្នាំ ១៩៥៧ រដ្ឋបានចាប់ផ្តើមជជែកពិភាក្សា ពីប្រព័ន្ធ និងយន្តការ ដើម្បីធានាការប្រើប្រាស់ដោយសន្តិវិធី នៃលំហអាកាស។ មួយឆ្នាំក្រោយមក សហរដ្ឋអាមេរិក និងសហភាពសូវៀត បានពិភាក្សា បញ្ហានេះ និងដាក់ស្នើឲ្យអង្គការសហប្រជាជាតិពិចារណា។ ជាលទ្ធផល ក្នុងឆ្នាំ ១៩៥៩ អង្គការសហប្រជាជាតិ បានបង្កើត គណៈកម្មាធិការ ស្តីពី ការប្រើប្រាស់ដោយសន្តិវិធី នូវលំហអាកាស (Committee on the Peaceful Uses of Outer Space: COPUOS) ដែលមានអនុគណៈកម្មាធិការចំនួនពីរៈ អនុគណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកទេស និងអនុគណៈកម្មាធិការនីតិកម្ម។ អនុគណៈកម្មាធិការខាងក្រោយនេះ បានចរចា និងធ្វើសេចក្តីព្រាងសន្ធិសញ្ញា ចំនួន៥។[1109]

ជារួមសន្ធិសញ្ញាដែលពាក់ព័ន្ធ បានចែងអំពី ១). ការមិនយកជាសម្បត្តិផ្ទាល់របស់រដ្ឋណាមួយ នូវលំហអាកាស ២). ការគ្រប់គ្រងសព្វាវុធ ៣). សេរីភាព

---

[1108] Peter Malanczuk, IL, *supra* note 1, pp. 207, 202-203, 206.

[1109] The 1967 Treaty on Principles Governing the Activities of States in the Exploration and Use of Outer Space, including the Moon and Other Celestial Bodies; the 1968 Agreement on the Rescue of Astronauts, the Return of Astronauts and the Return of Objects Launched into Outer Space; the 1972 Convention on International Liability for Damage Caused by Space Objects; the 1975 Convention on Registration of Objects Launched into Outer Space; and the 1979 Agreement Governing the Activities of States on the Moon and Other Celestial Bodies; the 1963 Treaty Banning Nuclear Weapon Tests in the Atmosphere, in Outer Space, and Under Water, see http://en.wikipedia.org/wiki/Space_law.

នៃការធ្វើអាជីវកម្ម ៤). ការទទួលខុសត្រូវចំពោះការខូចខាតបង្ក ដោយវត្ថុធ្លាក់ពីលំហអាកាស ៥). សុវត្ថិភាព និងការសង្គ្រោះយានអវកាស និង អ្នកអវកាស ៦). ការបង្ការការជ្រៀតជ្រែកដោយគ្រោះថ្នាក់ ដោយសកម្មភាពអវកាស និង បរិស្ថាន ៧). ការជូនដំណឹង និងចុះបញ្ជីសកម្មភាពក្នុងលំហអាកាស ៨). ការស៊ើបអង្កេតវិទ្យាសាស្ត្រ និងការធ្វើអាជីវកម្ម លើធនធានធម្មជាតិក្នុងលំហអាកាស និង ៩). ការដោះស្រាយជម្លោះ។

## ១១.៤.១. ការប្រើប្រាស់ធនធានថាមពលនុយក្លេអ៊ែរ និងសម្ភារដទៃទៀតក្នុងលំហអាកាស

ផ្កាយរណប បង្ហោះនៅក្នុងលំហអាកាស ហួសពីអធិបតេយ្យភាពដែនដីរបស់រដ្ឋ ដែលអាចបង្កជាបញ្ហាចោទមួយចំនួន។ ក្រៅពី សិទ្ធិសេរីភាពទទួលបានព័ត៌មាន តាមរយៈផ្កាយរណប និង អធិបតេយ្យភាពរបស់រដ្ឋ បញ្ហាចោទគឺបំណែក ឬតួផ្កាយរណប ដែលអាចធ្លាក់មកលើផែនដី បង្កការខូចខាតដល់បរិស្ថាន ឬជីវិតមនុស្ស។ សកម្មភាពអាជីវកម្មផ្កាយរណប មិនត្រូវប៉ះពាល់ដល់បរិស្ថានទេ។[1110] មានករណីរួចទៅហើយ គឺ Cosmos 954 ដើរដោយថាមពលនុយក្លេអ៊ែររបស់ សូវៀត ដែលបានបែកជាចំណែក ក្នុងឆ្នាំ ១៩៧៨ នៅលើដែនដីកាណាដា បង្កការខូចខាតដល់ ប្រទេស Austria។[1111]

រដ្ឋត្រូវបង្ហាញព័ត៌មាន អំពីសកម្មភាពក្នុងលំហអាកាស (មាត្រា ១០ដល់ ១២) ទទួលខុសត្រូវចំពោះ ការខូចខាត បង្កដោយវត្ថុ របស់ខ្លួនក្នុងលំហអាកាស (មាត្រា ៧)។ ការទទួលខុសត្រូវនេះ រាប់បញ្ចូលផងដែរនូវ សកម្ម

[1110] The Outer Space Treaty, *supra* note 1109, Art. 9.

[1111] Peter Malanczuk, IL, *supra* note 1, p. 206.

ភាពធ្វើឡើងដោយ អង្គភាពមិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធជាមួយរដ្ឋ។[1112] មាត្រា ២នៃអនុសញ្ញា ឆ្នាំ១៩៧២ ស្តីពី ការទទួលខុសត្រូវចំពោះការខូចខាត បណ្តាលមកពីសម្ភារតាំងក្នុងលំហអាកាស បានដាក់ការទទួលខុសត្រូវផងដែរចំពោះទង្វើរបស់ អង្គការអន្តរជាតិក្នុងលំហកាស។

ពាក់ព័ន្ធជាមួយ អាវុធនុយក្លេអ៊ែរ មាត្រា ៤ បានហាមឃាត់នូវ ការតាំងអាវុធនុយក្លេអ៊ែរនៅក្នុងលំហអាកាស។[1113] ជាមួយគ្នានេះ មានការហាមឃាត់ការសាកល្បង អាវុធនុយក្លេអ៊ែរក្នុងលំហអាកាស។[1114]

### ១១.៤.២. ការធ្វើអាជីវកម្មក្នុងលំហអាកាស និង សេចក្តីត្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍

មានសេចក្តីថ្លែងការណ៍ឆ្នាំ ១៩៩៦ ស្តីពីកិច្ចសហប្រតិបត្តិការ ក្នុងការធ្វើអាជីវកម្ម និងការប្រើប្រាស់លំហអាកាស សម្រាប់ការទាញយកប្រយោជន៍ និង ប្រយោជន៍រដ្ឋទាំងអស់ ដោយពិចារណា ជាពិសេសនូវសេចក្តីត្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍ។ សេចក្តីថ្លែងការណ៍ បានចែងថា រដ្ឋមានសេរីភាពក្នុងការធ្វើកិច្ចសហប្រតិបត្តិការ ក្នុងការធ្វើអាជីវកម្ម និងប្រើប្រាស់លំហអាកាស។ ក្នុងបរិបទនេះ ការយកចិត្តទុកដាក់ជាសំខាន់ គួរផ្តល់ដល់ផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍ តាមរយៈ កម្មវិធីលំហអាកាស ដែលធ្វើជាមួយប្រទេសដែលឈានមុខក្នុងសមត្ថភាពខាងអវកាស។

---

[1112] H.Bittlinger, *Private Space Activities: Questions of International Responsibility,* 30 Proceeding of IISL, 191 (1987).

[1113] 1967 Outer Space Treaty, *supra* note 1109.

[1114] 1963 Treaty Banning Nuclear Weapon Tests, *supra* note 1109; Peter Malanczuk, IL, *supra* note 1, p. 202; Manfred Lachs, the Law of Outer Space, 2010, p. 99.

### ១១.៤.៣. ស្ថានីយអវកាសអន្តរជាតិ និងច្បាប់របស់រដ្ឋ

រដ្ឋជាច្រើន បានធ្វើច្បាប់ជាតិ ស្តីពី លំហអាកាស ក្នុងពេលថ្មីនេះ។ រដ្ឋមួយចំនួន មានកាណាដា រដ្ឋនៃទីភ្នាក់ងារអវកាសអឺរ៉ុប ជប៉ុន សភាពសូវៀត និងសហរដ្ឋអាមេរិក បានចូលជាភាគីនៃកិច្ចព្រមព្រៀង ស្តីពី ស្ថានីយអវកាសអន្តរជាតិឆ្នាំ ១៩៩៨។ កិច្ចព្រមព្រៀងនេះ បានបង្កើត NASA ដែលជាស្ថាប័ន ធ្វើការងារសម្របសម្រួល ការចូលរួមរបស់រដ្ឋ ក្នុងសកម្មភាព ក្នុងស្ថានីយអវកាស។

# សន្និដ្ឋាន

ច្បាប់អន្តរជាតិ មកដល់ពេលនេះ មានការរីកចម្រើន និងវិវត្តយ៉ាងខ្លាំង គ្របដណ្តប់លើវិស័យជាច្រើន និងមានប្រធាននៃច្បាប់អន្តរជាតិ ជាច្រើន រាប់បញ្ចូលបុគ្គល។ បន្ថែមពីលើនេះ មានយន្តការជាច្រើន ត្រូវបានបង្កើតឡើង ដើម្បីអនុវត្តច្បាប់អន្តរជាតិ។ នេះគឺជាការឆ្លើយតប ទៅនឹងកំណើននៃទំនាក់ទំនងរដ្ឋ និងរដ្ឋ។

ទន្ទឹមនឹងនេះ មានការរិះគន់ជាច្រើន ដូចជាភាពមិនទាន់ស៊ីសង្វាក់ក្នុងវិធាន និងយន្តការផ្សេងៗ ដែលគេមើលឃើញថា ច្បាប់អន្តរជាតិមិនមានភាពច្បាស់លាស់ និងយន្តការមិនទាន់មានប្រសិទ្ធភាពពេញលេញ។ ទោះបីជាយ៉ាងនេះក្តី អ្នកសិក្សាស្រាវជ្រាវ បានកត់សម្គាល់ឃើញថា រដ្ឋជាច្រើនទាំងរដ្ឋនៃប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍ បានចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និងអភិវឌ្ឍវិធាននៃច្បាប់អន្តរជាតិ និងបានជ្រើសរើសយកយន្តការរបស់អង្គការសហប្រជាជាតិមកដោះស្រាយជម្លោះ។ នេះឆ្លុះបង្ហាញតាមរយៈកំណើននៃរឿងក្តី ដែលរដ្ឋបានប្តឹងមកតុលាការយុត្តិធម៌អន្តរជាតិ។

និន្នាការទាំងនេះ នឹងបន្តកើតមានឡើង។ តែទោះបីជាយ៉ាងនេះក្តី ការសិក្សា និងស្រាវជ្រាវច្បាប់អន្តរជាតិ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍនៅតែមានកម្រិត។ អាស្រ័យហេតុនេះ ប្រទេសកំពុងអភិវឌ្ឍគួរជំរុញការសិក្សា និងស្រាវជ្រាវច្បាប់អន្តរជាតិ ក្នុងស្រទាប់និស្សិត សាស្ត្រាចារ្យ និងមន្ត្រីធ្វើការងារនៅក្នុងក្រសួងការបរទេស ឲ្យកាន់តែស៊ីជម្រៅ តាមរយៈការបញ្ចូលមុខវិជ្ជាច្បាប់អន្តរជាតិឲ្យបានទូលំទូលាយទៅក្នុងកម្មវិធីសិក្សាកម្រិតឧត្តមសិក្សា

ការស្រាវជ្រាវ និងបោះពុម្ពផ្សព្វផ្សាយច្បាប់អន្តរជាតិ និងការបង្កើតមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវច្បាប់អន្តរជាតិ ដើម្បីទាញយកប្រយោជន៍ពីច្បាប់អន្តរជាតិ និងយន្តការ ដែលមានស្រាប់។

**<u>SUBJECT INDEX</u>**


Acquiescence p. 38

Affirmation Action p. 169

Countermeasure p. 307

Diplomatic Protection p. 152

Direct Application p. 40

Double Standard p. 189

Dual Criminality p. 104

Dualism p. 81

Exhaustion of Local Remedy p. 197

*Egar Omnes* p. 271

Equity p. 79

Estoppel p. 39

General Principle of International Law p. 40

Genocide p. 252

Implied Power p. 65

Incorporation p. 84

Inherent Rights p. 108

Inherent Limitation p. 171

*Jus Cogens* p. 16

Last-in-Time Rule p. 86

Monism p. 81

| | |
|---|---|
| Non-Derogable Rights | p. 174 |
| Non-Discrimination | p. 347 |
| Non-Justiciability | p. 161 |
| *Indirect Refoulement* | p. 147 |
| Non-Self Executing Treaty | p. 85 |
| *Opinio Juris* | p. 29 |
| Persistent Objection | p. 45 |
| Political Assurance | p. 147 |
| Positive Obligation | p. 186 |
| Principle of Complementary | p. 256 |
| Principle of Consent | p. 40 |
| Principle of Distinction | p. 222 |
| Principle of Legality | p. 41 |
| Principle of Proportionality | p. 226 |
| Principle of Reciprocity | p. 142 |
| Reparation | p. 113 |
| Reservation | p. 61 |
| Right to Self-determination | p. 178 |
| Right to internal self-determination | p. 183 |
| Rule of Non-Inquiry | p. 146 |
| Rule of Speciality | p.296 |
| Slavery | p. 25 |

Subject of International Law p. 244

Torture p. 22

Transformation p. 82

Universal Juridiction p. 100

*Uti Possedi* p. 16

# លិខិតជូនចំពោះប្រិយមិត្តអ្នកសិក្សា និងស្រាវជ្រាវ

ក្នុងសៀវភៅនេះ ខ្ញុំបាទបានជម្រាបជូនរួចហើយ អំពីការចូលរួមចំណែកយ៉ាងសកម្ម របស់អ្នកសិក្សា និងស្រាវជ្រាវ ក្នុងការអភិវឌ្ឍប្រទេសជាតិ។ អាស្រ័យហេតុនេះ វាទាមទារឲ្យមានការលើកទឹកចិត្តក្នុងការសិក្សាស្រាវជ្រាវ សរសេរនិងបោះពុម្ពជាស្នាដៃ ដោយប្រយោល ដូចជាការមិនលួចថតចម្លង ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ជាដើម។

ការសរសេរសៀវភៅ ជាការលំបាកស្មុគស្មាញ ចំណាយពេលវេលា។ ជាក់ស្តែង ខ្ញុំបានចំណាយពេល ជាច្រើនឆ្នាំ អានសៀវភៅ និងសរសេរសៀវភៅនេះឡើង និងមិនមានសង្ឃឹមថាបានចំណូលច្រើនពីការលក់សៀវភៅនេះទេ ដូចអ្នកនិពន្ធបរទេស ដែលអាចទទួលបានចំណូលជាច្រើនពីការលក់សៀវភៅ។ ផ្អែកលើហេតុផលនេះ ខ្ញុំបាទជាអ្នករៀបរៀង និងនិពន្ធ ក្នុងនាមផ្ទាល់ និងអ្នកនិពន្ធទាំងអស់ សូមទទូច និងអង្វរ កុំឲ្យមានការលួចថតចម្លងស្នាដៃ។ ទង្វើមិនលួចចម្លង គឺជាការគោរពដល់អ្នកនិពន្ធ ដែលខ្ញុំបាទសូមសម្តែងនូវសេចក្តីអរគុណយ៉ាងជ្រាលជ្រៅទុកជាមុន។

តម្លៃរបស់សៀវភៅនេះ មិនថ្លៃទេ។ ប្រិយមិត្តអ្នកសិក្សាស្រាវជ្រាវ អាចរកបានដោយធ្វើទំនាក់ទំនងតាមលេខទូរស័ព្ទ៖ ០៧៧៧៧៥៤៣, ០៩៨៣៨១៨១៩។ ចំណូលមួយផ្នែក នៃការលក់សៀវភៅនេះ នឹងប្រើប្រាស់សម្រាប់កិច្ចការងារជួយសង្គម។

ខ្ញុំបាទសូមសម្តែងសេចក្តីអរគុណទុកជាមុន និងជូនពរប្រិយមិត្ត ជនរួមជាតិ អ្នកសិក្សាស្រាវជ្រាវ ទទួលបាននូវសុខភាពល្អ និងជោគជ័យគ្រប់ពេលវេលា។

**បណ្ឌិត មាស បូរ៉ា**

ភ្នំពេញថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៣

# ជីវប្រវត្តិរបស់អ្នកនិពន្ធ

## ១. សាវតារកំណើត

- លោកបណ្ឌិត មាស បូរ៉ា កើតនៅ ថ្ងៃទី ៥ ខែមីនា ឆ្នាំ ១៩៧៣ ក្នុងស្រុកពាមរក៍ ខេត្តព្រៃវែង។
- រៀបអាពាហ៍ពិពាហ៍ មានកូនពីរនាក់ (ស្រីម្នាក់ និងប្រុសម្នាក់)។

## ២. ការអប់រំ

- បណ្ឌិតច្បាប់ សាកលវិទ្យាល័យណាហ្គូយ៉ា (២០០៧) ប្រទេសជប៉ុន។
- អនុបណ្ឌិតច្បាប់ សាកលវិទ្យាល័យណាហ្គូយ៉ា (២០០៣)។
- បរិញ្ញាបត្រច្បាប់ មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (១៩៩៨) កម្ពុជា។

## ៣. ការងារ និងសង្គមវិជ្ជាជីវៈ

- សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(២០១២)
- មន្ត្រីច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (២០០៧)។
- សមាជិកវាយតម្លៃគុណភាពអប់រំនៅកម្ពុជា(២០១០)។
- អគ្គលេខាធិការរងគណៈកម្មាធិការជាតិអេស្កាប់ (២០០៩)។
- សាស្ត្រាចារ្យច្បាប់អន្តរជាតិ (២០០៧)។

- សាកលវិទ្យាធិការរង សាកលវិទ្យាល័យឯកទេស នៃកម្ពុជា (២០០៦)។
- អ្នកផ្តល់យោបល់ច្បាប់ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (២០០៧)។
- មន្ត្រីនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច (១៩៩៨)។
- សមាជិក Asian Society of International Law, Singapore (2011-2013)
- សមាជិក Law Asia, Australia (2012-2014)

៤. រង្វាន់

- អាហារូបករណ៍ អង្គការសហប្រជាជាតិ សម្រាប់ការបណ្តុះបណ្តាលច្បាប់អន្តរជាតិ(២០១១)។
- អាហារូបករណ៍ ស៊ើបអង្កេត Justice Rapid Response។
- អាហារូបករណ៍របស់រដ្ឋាភិបាលជប៉ុន (២០០៣ ដល់ ២០០៦)។

៥. ស្នាដៃស្រាវជ្រាវ

- ការសម្លាប់ដោយក្រុមមនុស្ស ឆ្នាំ ២០០៧ (សាកលវិទ្យាល័យតូក្យូ ប្រទេសជប៉ុន)។

- បត្យាប័នៈ ច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ក្នុង Jorg Menzel ed., Introduction to Cambodian Law, 2012។
- ក្រមនីតិវិធីព្រហ្មទណ្ឌៈ កំណត់សម្គាល់ ក្នុង Jorg Menzel ed., Introduction to Cambodian Law, 2012។
- ច្បាប់សិទ្ធិមនុស្ស ក្នុងប្រទេសកម្ពុជា ក្នុង Cambodian Yearbook of Comparative Legal Studies, 2010។
- សិទ្ធិរបស់ជនជាប់ចោទៈ បទពិសោធពីសំណុំរឿងរបស់លោក ឌុច ក្នុង Nagoya Uinversity Journal of Law and Political Sience, 2012, Vol. 245។
- ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុង Cambodian University for Specialties Journal of Law and Political Science, 2013, Vol. 1។

# REFERENCE


I. INSTRUMENT

*1.1.* Universal

*Human Rights*

1. Hague Convention for the Pacific Settelemnt of International Disputes Treaty (1899)
2. Hague Convention respecting the Laws and Customs of War on Land (1907).
3. Geneva Slavery Convention (1926).
4. The Charter of the United Nations (1945).
5. The International Covenant on Civil and Political Rights (1966).
6. The Optional Protocol to the International Covenant on Civil and Political Rights (1966).
7. The Convention against Torture and Other Cruel, Inhuman or Degrading Treatment or Punishment (1984).
8. The United Nations Declaration on the Rights of Indigenous Peoples (2007).
9. The Optional Protocol to the Convention against Torture and Other Cruel, Inhuman or Degrading Treatment or Punishment (2002).
10. The International Covenant on Economic, Social and Cultural Rights (1966).
11. Third Optional Protocol to Convention on the Rights of the Child (2001).
12. The Universal Declaration of Human Rights (1948).
13. The International Convention on the Elimination of All Forms of Racial Discrimination (1966).
14. The International Convention on the Elimination of All Forms of Discrimination against Woman (1979).
15. General Comment of the Human Rights Committee No. 31 (2004).
16. The General Comment No. 33 of the United Nations Human Rights Committee on the Obligations of States Parties under the Optional Protocol to the International Covenant on Civil and Political Rights (2008).

17. General Comment No. 24 of the Human Rights Committee on Issues relating to Reservations Made upon Ratification or Accession to the Covenant or the Optional Protocols (1994).
18. General Comment of the Committee on Economic, Social and Cultural Rights No. 9: the Domestic Application of the Covenant (1998).
19. Human Rights Committee, General Comment No. 18 : Non-Discrimination (1989).
20. General Comment of the Human Rights Committee No. 25 on Article 25 (1996).
21. Human Rights Committee, General Comment No. 32, Article 14: Right to Equality before Courts and Tribunals and to a Fair Trial, (2007).
22. Human Rights Committee, General Comment No. 29 on Article 4, States of Emergency (2001).
23. Measures to Improve Further the Effectiveness, Harmonization and Reform of the Treaty Body System (2011).
24. Treaty-Specific Guidelines regarding the Form and Content of Periodic Reports to Be Submitted by States Parties under Article 44, paragraph 1(b), of the Convention on the Rights of the Child (2010).
25. Overview of the Working Methods of the Committee on the Rights of the Child (2010).
26. How to Complian about Human Rights Treaty Violations: the Covenant on Civil and Political Rights-Descrption.
27. The Human Rights Committee, Rules of Procedure (1994).
28. Concluding Observations of the Committee against Troture, CAT/C/KHM/CO/2 (2011).
29. Rules of Procedure, CAT/C/3/Rev.5 (2011).
30. The Report on the Visit of the Subcommittee on Prevention of Torture, CAT/C/42/2 (2009).
31. Provisional Conclusions and Recommendations, CAT A/58/44 (2003).
32. Report of the Special Rapporteur on the Promotion and Protection of Human Rights and Fundamental Freedoms While Countering Terrorism (2012).

33. Vienna Declaration and Programme of Action (1993).

*Refugees*

34. The Convention relating to the Status of Refugees (1951).
35. The UN Declaration on Refugees (1967).
36. The Protocol to the 1951 Refugee Convention (1967).
37. Handbook on Procedures and Criteria for Determining Refugee Status under the 1951 Convention and the 1967 Protocol relating to the Status of Refugees (1992).
38. UNHCR, Exclusion from Refugee Status (2001).
39. UNHCR Note on the Principle of *Non-Refoulement* (1997).
40. Guidelines on International Protection: “Internal Flight or Relocation Alternative”within the Context of Article 1A(2) of the 1951 Convention and/or 1967 Protocol relating to the Status of Refugees (2003).

*Immunities and State Responsibility*

41. The General Convention on the Privillages and Immunities of the United Nations (1946).
42. The Convention on the Privileges and Immunities of the Specialized Agencies (1947).
43. Draft Articles on the Responsibility of International Organizations, with Commentaries (2011).

*Trade, Space and Environment*

44. Agreement Establishing the World Trade Organization (1995).
45. The Agreement on Implementation of Article VI of the GATT 1994 (Anti-Dumping Agreement).
46. The Treaty on Principles Governing the Activities of States in the Exploration and Use of Outer Space, including the Moon and Other Celestial Bodies (1967).
47. The Agreement on the Rescue of Astronauts, the Return of Astronauts and the Return of Objects Launched into Outer Space (1968).
48. The Convention on International Liability for Damage Caused by Space Objects (1972).

49. The Convention on Registration of Objects Launched into Outer Space (1975).
50. Treaty Banning Nuclear Weapon Tests in the Atmosphere, in Outer Space and Under Water (1963).
51. The Agreement Governing the Activities of States on the Moon and Other Celestial Bodies (1979).
52. The Outer Space Treaty (1967).
53. Rio Declaration on Environment and Development (1992).
54. Kyoto Protocol to the United Nations Framework Convention on Climate Change (1998).
55. Declaration of the United Nations Conference on the Human Environment (1972).
56. UN Framework Convention on Climate Change (1994).
57. Copenhagen Accord (2009).
58. The Convention on Biological Diversity (1993).
59. Cartagena Protocol on Biosafety to the Convention on Biological Diversity (2000).
60. The United Nations Convention on the Non-Navigational Uses of International Watercourses (1997).
61. Senegal Water Charter (2002).
62. Rhine Protection Convention (1999).
63. Amazon Cooperation Agreement (1978).
64. Boundary Water Treaty (1909).
65. Protocol on Health and Water (1999).
66. Protocol on Civil Liability and Compensation for Transboundary Damage (2003).
67. The Vienna Convention for the the Protection of the Ozone Layer (1987).
68. Montreal Protocol on Substances that Deplete the Ozone Layer (1987).
69. Basel Convention on the Control of Transboundary Movements of Hazardous Wastes and Their Disposal (1989).
70. Rotterdam Convention on the Prior Informed Consent Procedure for Certain Hazardous Chemicals and Pesticides in International Trade (1998).

*Other Areas*

71. The Draft Articles on Diplomatic Protection (2006).
72. The Declaration on the Granting of Independence to Colonial Countries and Peoples (1960).
73. The Vienna Convention on the Law of Treaties (1969).
74. International Tribunal for the Prosecution of Persons Responsible for Serious Violations of International Humanitarian Law Committed in the Territory of Former Yugoslavia (1993).
75. The Convention for the Suppression of the Financing of Terrorism (1999).
76. The UN Model Treaty on Extradition (1990).
77. The United Nations Convention on the Law of the Sea (1982).
78. The Vienna Convention on the Law of Treaties (1969).
79. The Rules of Procedure of the International Court of Justice (1978).
80. The Charter of the United Nations (1945).

*1.2. Regional*

1. The European Convention on Extradition (1960).
2. The European Convention for the Protection of Human Rights and Fundamental Freedoms (1950).
3. The Additional Protocol to the European Convention on Extradition (1975).
4. Second Additional Protocol to the European Convention on Extradition (1978).
5. Protocol No. 13 to the Convention for the Protection of Human Rights and Functional Freedoms, concerning the Abolition of the Death Penalty in All Circumstances (2002).
6. The European Convention for the Prevention of Torture and Inhuman or Degrading Treatment or Punishment (1987).
7. American Convention on Human Rights (1978).
8. African Charter on Human and Peoples'Rights (1986).
9. Protocol to the African Charter on Human and Peoples's Rights on the Establishment of the African Court on Human and Peoples'Rights (2008).

10. Arab Charter on Human Rights (2008).
11. Term of References of ASEAN Intergovernmental Commission on Human Rights(2004).
12. The Charter of the Association of Southeast Asian Nations (2007).
13. CHA-AM HUA HIN Declaration on the Intergovernmental Commission on Human Rights (2009).
14. Press Release of the Fourth Meeting of the AICHR on the ASEAN Human Rights Declaration (2012).
15. The Organization of Africa Union Convention Governing the Specific Aspects of Refugee Problems in Africa (1974).

*1.3 Extraordinary Chambers in the Courts of Cambodia (ECCC)*

1 The Internal Rules (Rev.8), (2011).
2 Excerpt of the Considerations of the Pre-Trial Chambers regarding the Disagreement between the Co-Prosecutors pursuant to Internal Rule 71 (2009).
3 Agreement between the United Nations and the Royal Government of Cambodia concerning the Prosecution under Cambodian Law of Crimes Committed during the Period of Democratic Kampuchea (2003).
4 The Law on the Establishment of Exraordinary Chambers in the Courts of Cambodia for the Prosecution of Crimes Committed During the Period of Democratic Kampuchea (2004).

1.4.National

1. Extradition Treaty between the Kingdom of Cambodia and the Kingdom of Thailand (1999).
2. The Treaty on Extradition between the Kingdom of Cambodia and People Republic of China (2000).
3. Code of the Criminal Procedure of Cambodia (2007).
4. Immigration Law of Cambodia (1994)
5. Agreement between the Kingdom of Cambodia and India on Transfer of Prisoners.

6. Agreement between the Governement of Australia and the Government of Cambodia concerning Transfer of Sentenced Persons (2006)
7. The Agreement between the United States of America and the Kingdom of Cambodia concerning Non-Surrender of Persons to the International Criminal Court(2005).
8. The Treaty on Extradition between the Kingdom of Cambodia and People Democratic Republic of Lao (2005).
9. The Constitution of the Kingdom of Cambodia (1993).
10. Treaty of Peace, Friendship and Cooperation between the Socialist Republic of Vietnam and the People's Republic of Kampuchea (1979).
11. Declartion of Bangadesh upon Ratification of the 1982 UNCLOS in 2001
12. Declaration of Germany upon the Accession to the 1982 UNCLOS in 1994.
13. Reservation of Chile to the Convention against Torture (1987).
14. Australia Reply to the View of the Human Rights Committee in the Case of A v. Australia (No. 560/1993) (the Annual Report of the Human Rights Committee in 1994 (A/49/40).
15. The Extradition Treaty between the USA and Canada (1976), 27 UST. 983; TIAS. N. 8237.

## II. JURISPRUDENCE

2.1. International Court of Justice

1. Case concerning the Frontier Dispute (*Burkina Faso/Republic of Mali*), Judgement of 1986.
2. Mavrommatis Palestine Concessions case, PCIJ, Series A, No.2, 1994, p.12.
3. The Diallo (*Guinea v. Democratic Republic of the Congo*) case, ICJ Reports, 2007.
4. ICJ, Case Concerning the Gabcikovo-Nagymaros (*Hungary v. Slovakia*), Judgement of 25 September 1997.
5. PCA, Arbitration concerning the Iron Rhine Railway (*Belgium v. the Netherlands)*, Award of 24 May 2005.

6. ICJ, Case concerning Rulp Mills on the River Uruguay ( *Argentina v. Uruguay*), Judgement of 20 April 2010.
7. LAGRANT Case (*Germany v. United States of America*), Summary of 27 June 2001 Judgment.
8. The ICJ, Case Concerning Application of the International Convention on the Elimination of All Forms of Racial Discrimination (*Georgia v. Russian Federation*), Request for the Indication of Provisional Measures, Order of 15 October 2008, para. 149.
9. The Press Release No. 2012/36 on Request for Interpretation of the Judgement of 15 June 1962 in the Case concerning the Temple of PreahVihear (*Cambodia v. Thailand*), 29 November 2012.

10. Case Concerning Military and Paramilitary Activities (*Nicaragua v United* States)'( ICJ, Military Case), 1986 ICJ Reports 14, at 138 ( 275-276).
11. East Timor (*Portugal v. Australia*), Judgement, I.C.J. Reports 1995.
12. Case Concerning the Arrest Warrant of 11 April 2000 (*Congo v. Belgium),* 2002 ICJ 121 (Feb 14, 2002), 41 ILM 536 (2002).

*Advisory Opinion*

13. International Court of Justice, 2010 July 22, Accordance with international law of the unilateral declaration of independence in respect of Kosovo.
14. ICJ, Difference relating to Immunity from Legal Process of a Special Rapporteur of the Commission on Human Rights, Advisory of 29 April 1999.
15. ICJ, Reparation case, ICJ Report 1949, p. 174, 179.
16. ICJ, Legality of the Threat or Use of Nuclear Weapon, Advisory Opinion of 8 July 1996.

*2.2. Human Rights Committee and Other Treaty Bodies*

1. *A v. Australia*, Communication No. 560/1993, CCPR/C/59/D/560/1993 (Apr. 3, 1997).

2. View of the Human Rights Committee, 6 November 1997, Communication No. 577/1994, CCPR/C/61/D/577/1994.
3. *Mutombo v. Switzerland*, Communication No. 13/1993, U.N. Doc.A/49/44 at 45 (1994).
4. *Judges v. Canada*, Communication No. 829/1998, U.N. Doc. CCPR/C/78/D/829/1998 (2003)
5. *Piandong v. Philippines*, Communication No.869/1999, Oct 2000

*2.3. Inter-American Court of Human Rights*

1. *Report No.51/96, Decision of the Inter-American Commision on Human Rights as to the Merit of Case 10.675, United State (1997).*
2. Habeas Corpus in Emergency Sistuation (Arts. 27(2) and 7(6) of the American Convention on Human Rights), Advisory Opinion OC-8/87 (1978)

*2.4. African Courts/Commission for Human Rights*

1. African Commission on Human Rights, the Ogoni case, Communication 155/96*, the Social and Economic Rights Action Centre v. Nigeria* (2002).
2. *Kaunda v. President of South Africa,* CCT 23/04 (2004).
3. *373/09 INTERIGHTS*, Institute for Human Rights and Development in Africa/Mauritania, Decision on 3 March 2010.

*2.5. European Court of Human Rights*

1. *Soering v. the United Kingdom*, No. 14038/88 [1989] ECHR 14 (July 7, 1989).
2. *Tyrer v. the United Kingdom*, EHRR 2, (1978).
3. *Frette v. France* (App. 36515/97), Judgement of 26 February 2002, 38 EHRR 438 (2004).
4. *X and Y v. the Netherlands*, 91 Eur. Ct. H.R. (ser. A) (1985).

*2.6. International Criminal Tribunals*

1. *Prosecutor v.Tadic*, Appeal Judgement of 15 July 1999 (ICTY).
2. *Prosecutor v. Brdanin*, IT-99-36-A, Judgement, 3 April 2007 (ICTR).

3. Trial Chamber, *Prosecutor v. Kayishema and Ruzindana*, Judgement of 21 May 1999 (ICTR).
4. *Prosecutor v. Jankovic*, Decision on Referral of Case pursuat to Rule 11bis, ICTY Referral Bench (IT-96-23/2-PT), 22 July 2005.

2.7. National

1. The Supreme Court of the Republic of The Philippines, *Minors Oposa v. Secretary of the Department of Environment and Natural Resources*, Judgement of 30 July 1993, 33 ILM, 174 (1994).
2. *R. v. Bow Street Metropolitan Stipendiary Magistrate and Others*, ex parte Pinochet Ugarte (No 3), 24 March, 1999, [2000] 1 AC 147, at 276.
3. *Van Zyl v. Government of RSA*, 2007, SCA.
4. Petitioners v. Haitian Centers Council, Inc, et al., No. 92-344 (June 21, 1993), 113 S. Ct. 2549.

*2.8. ECCC*

1. IENG Sary's Motion against the Application at the ECCC of the Form of Liability Known as Joint Criminal Enterprise, 28 July 2008, D97 (redacted version).
2. Closing Order, No.: 002/19-09-2007-ECCC-OCIJ, D427, 15 September 2010.
3. Case of IENG Thirith, 02/19-09-2007-ECCC/OCIJ (PTC26), Defence Appeal against OCIJ's Order on Use of Statement which were of may have been obtained by torture'of 28 July 2009, D130/9/6.
4. IENG Sary's Motion against the Use of Torture Tainted Evidence at Trial, 4 February 2011.
5. The OCIJ, Order on Use of Statements which were or may have been obtained by torture, 28 July 2009, E3/155.
6. Preliminary Objection Concerning Termination of Prosecution of Domestic Crimes, E9/1, 4 February 2009.
7. Case 01, Pre-Trial Chamber, Report of Examination, 19 November 2007, C21/82.

8. The Office of the Co-Investigating Judge, Detention Order, 31 July 2007, C4/2.
9. OCIJ, Order of Provisional Detention, C3/10, 31 July 2007.
10. Pre-Trial Chamber, Decision on Appeal against Provisional Detention Order of KaingGuekEav alias Duch, 3 December 2007.
11. Trial Chamber, Decision on Request for Release, 15 June 2009, E39/5.
12. Co-Prosecutors'Appeal against the Judgement of the Trial Chamber in the Case of KaingGuekEav alias Duch, F10, 13 October 2010.
13. Judgement of the Revolutionary People's Revolutionary Court, U.N. A/34/491, 19 August 1979.
14. Ieng Sary's Submissions pursuant to the Decision on Expedited Request of Co-Lawyers for a Reasonable Extension of Time to File Challenges to Jurisdictional Issue, C22/I/26, 7 April 2008.
15. Trial Chamber, Decision on Ieng Sary's Rule 89 Preliminary Objections (Ne Bis in idem and Amnesty and Pardon), 3 November 2011, E51/15.
16. Pr-Trial Chamber, Decision on IengSary's Appeal against the Closing Order, D247/1/30, 11 April 2011.
17. Trial Chamber, Decision on the Defence Preliminary Objection Concerning the Statute of Limitations of Domestic Crimes, 26 July 2010, E187.
18. Supreme Court Chamber, Case File/Dossier No. 001/18-07-2007-ECCC/SC, 3 February 2012.
19. Trial Chamber, KAING GuekEav *alia* Duch, Judgememt, 26 July 2010.


## III. <u>TEXT</u>

### 3.1. **<u>Books</u>**


1. A.A. Cancado Trindade, Co-Existnce and Co-ordination of Mechanisms of International Protection of Human Rights, *Recueil des Cours*, 202 (1987-II).
2. Anette Faye Jacobsen, Human Rights Monitoring (2008).
3. Anthony A. D'Amato, the Concept of Custom in International Law (1971).

4. Anthony Aust, Handbook of International Law (2005).
5. Anthony Aust, Modern Treaty Law and Practice, 2nd ed. (2007).
6. Antonio Augusto Cancado Trindad, International Law for Humankind (2010).
7. Antonio Cassese, the Oxford Companion to International Criminal Justice (2009).
8. Asian Human Rights Commission, Rule of Law and Human Rights in Asia (2006).
9. Bardo Fassbender, the United Nations Charter as the Constitution of the International Law (2009).
10. Ben Kiernan, the Pol Pot Regime: Race, Power and Genocide in Cambodia under the Khmer Rouge (1975-1979) (1996).
11. Benedetto Conforti, an Introduction to International law (2012).
12. Birgit Schlutter, Developments in Customary International Law (2010).
13. Black’s Law Dictionary, 8th ed., (1998).
14. Bowett, Self-defence in International Law (1958).
15. Bruno Simma, UN Charter Commentary (1995).
16. BudislavVukas and Trpimir M. Sosic, International Law: New Actors, New Concepts Continuing Dilemmas (2010).
17. Christopher P.M. Waters, British and Canadian Perspectives on International Law(2006).
18. Chiara Giorgetti, the Rules, Practice, and Jurisprudence of International Courts and Tribunals (2012).
19. Christian Tomuschat, Obligations arising for States without or against their will, *Recueil des Cours* 241 (1993-IV).
20. M. Cherif Bassiouni, Crimes against humanity in International Criminal Law (1999)
21. D.J. Harris, Cases and Materials on International Law, 5th ed., (1998).
22. D.J. Harris, Law of the European Convention on Human Rights, 2nd ed., (2009).
23. Dan Kuwali, the Responsibility to Protect: Implementation of Article 4(h) intervention (2011).
24. Dinah Shelton, International law and Domestic Legal Systems; Incorporation, Transformation, and Persuasion (2011).

25. Dr. Bertrand G. Ramcharan, the Protection Roles of the UN Human Rights Special Procedures (2009).
26. Edward McWhinney and Mariko Kawano, Judge Shigeru Oda and the Path to Judicial Wisdom, Opinions (Declarations, Separate Opinions, Dissenting Opinions) on the International Court of Justice, 1993-2003), Vol. IV (2006).
27. Gary Knight and Hungdah Chiu, the International Law of Sea (1991).
28. Geoff Gilbert, Aspects of Extradition (1991).
29. Geoff Gilbert, transnational fugitive offenders in international law, extradition and other mechanisms (1998).
30. Georghios M. Pikis, the Rome Statute for the International Criminal Court (2010).
31. Guy S. Goodwin Gill, the Refugee in International Law, 2nd ed., (1996).
32. Hague Academy of International Law, summer course (2011), International Environmental Law by Prof. Laurence Boisson de Chazournes.
33. Helmut Tuerk, Reflections on the Contemporary Law of Sea (2012).
34. Helmut Volger, a Concise Encyclopedia of the United Nations, 2nd ed., (2010).
35. Human Rights Watch, Genocide, War Crimes, and Crimes againt Humanity: Topical Disgests of the Case Law of the International Criminal Tribunal for Rwanda and the International Criminal Tribunal for the Former Yugoslavia (2004).
36. Ian Brownlie, Principles of Public International Law, 7th ed., (2008).
37. Ian Brownlie, Basic Documents in International Law, 5th ed., (2002).
38. J. Ashley Roach and Robert W. Smith, Excessive Maritime Claims, 3rd ed., (2012).
39. Jacobs & White, The European Convention on Human Rights, 4th ed., (2006).
40. James Crawford, the International Law Commission’s Articles on State Responsibility of International Organization (2002).

41. Jan-JaapKuipers, The European Union and Private International Law (2012).
42. Javier Garcia Roca and Pablo Santolaya, Europe of Rights: A Compendium on the European Convention of Human Rights (2012).
43. Jo Stigen, the Relationship between the international criminal court and national jurisdiction (2008).
44. Joan Fitzpatrick, human rights in crisis (1994).
45. Johann Bair, the International Covenant on Civil and Political Rights and Its (First) Optional Protocol (2005).
46. Judgment of the International Military Tribunal for the Trial of the German Major War Criminals, Nuremberg (1946).
47. Kelsen, the Principles of International Law, 2nd ed.,(1966).
48. Leonardo Morlino and GianluigiPalombella, Rule of Law and Democracy (2010).
49. Liber Amicorum and RudigerWolfrum, Coexistence, cooperation and solidarity (2012).
50. Louis Henkin, the international bill of rights, the covenant on civil and political rights (1981).
51. Manfred Lachs, the Law of Outer Space (2010).
52. Martin Dixon & Robert McCorquodale, Cases and Materials on International Law (1991).
53. M. Cherif Bassiouni, Jose Doria and Hans-Petter Gasser, the Legal Regime of the International Criminal Court (2009).
54. M.Shaw, International Law, 6th ed., (2008).
55. Malgosia Fitzmaurice and Phoebe Okowa, Treaty Interpretation and the Vienna Convention on the Law of Treaties: 30 years on (2010).
56. Marko Milanovic, Extraterritorial Application of Human Rights Treaties (2011).
57. Mathhew Craven, the Decolonization of International Law (2007).
58. Menno T. Kamminga, Inter-State Accountability for violations of human rights (1992).
59. Michael Koebele, Corporate responsibility under the Alien Tort Statute (2009).

60. Horst Fischer, International and National Prosecution of Crimes under International Law: Current Developments (2001).
61. Nigel S. Rodley, the Treatment of Prisoners under International Law, 2nd ed., (1999).
62. Jared L. Watkins and Randle C. DeFalco, *Nullum Crimen Sine Lege*, the Jurisdiction of the Extraordinary Chambers in the Courts of Cambodia and Joint Criminal Enterprise.
63. Peter Malanczuk, Akhehurst's Modern Introduction to International Law, 7th ed., (1997).
64. Rebecca M.M. Wallace, International Law , 4th ed., (2002).
65. Rhona K.M. Smith, Textbook on International Human Rights, 5th ed., (2012).
66. Roberta Arnold and Noelle Quenivet, International Humanitorian Law and Human Rights Law (2008).
67. RozaPati, Due Process and International Terrorism, An International Legal Analysis (2009).
68. Rudiger Wolfrum and Peter-Tobias Stoll, WTO-World Economic Order, World Trade Law (2006).
69. Sarah Joseph, Ratie Mitchell *et al*..., Seeking Remedies for Torture Victims (2006).
70. ShahriarKhateri and Ruth Wangerin, the Open Wound (2009).
71. Silvia D'ASCOLi, Sentencing in International Criminal Law (2011).
72. Steve Peers and Nicola Rogers, EU Immigration and Asylum Law: Text and Commentary (2006).
73. J. Herman Burgers and Hans Danelius, the United Nations Convention aginst Torture (1988).
74. Helmut Volger, A Concise Encyclopedia of the United Nations, 2nd ed.,(2010).
75. The United Nations, Historical Review of Developments relating to Aggression (2003).
76. Thomas Buergenthal and Sean D. Murphy, Public International Law (2007).
77. TunkuSofiahJewa, the Third World and International Law (2007).
78. Gary Klintworth, Vietnam's Intervention in Cambodia in International Law, (1989).

79. Knut Dormann, Elements of War Crimes under the Rome Statute of the ICC: Sources and Commentary (2002).
80. William A. Schabas, the Death Penalty as Cruel Treatment and Torture (1996).
81. William Edward Hall, Treatise on International Law, 8th ed., (1924).
82. William R. Slomanson, Fundamental Perspectives on International Law (1990).
83. Yoram Dinstein, Crimes against humanity (1996).
84. Giorgio Gaja, obligations *Erga Omnes*, international crimes and *Jus cogens*: a tentative analysis of three related concepts (1989).
85. Andrzej Wasilkowski, monist and dualist at present (1996).
86. Michael Abbell, Extradition to and from the Uinted States (Michael, Extradition to USA) (2010).
87. Michael Abbell, International Prisoner Transfer (2010).

**3.2. Articles**

1. L.C. Green, *General Principles of Law and Human Rights*, 8 Current Legal Problems, 1955.
2. A. J.J. de Hoogh, *The relationship between Jus Cogens, Obligations ergaomnes and International Crimes: Peremptaory norms in perspective*, 42 Austrian Journal of Public and International Law, 1991.
3. Alexander Kiss, *Commentary by the Rapporteur on Limitation Provisions*, 17(1) Human Rights Quarterly, 1985.
4. Alexander Orakhelashvili, *Restrictive Interpretation of Human Rights Treaties in the Recent Jurisprudence of the European Court of Human Rights*, 14 European Journal of International Law, 2003.
5. Alfred P. Rubin, *Actio Popularis, Jus Cogens and Offenses Erga Omnes*, 35 New England Law Review, 2001.
6. Andrea Gattini, *A return ticket to 'communitarisme'*, please, 13 EJIL, 2002.
7. Anthea Roberts, *Traditional and Modern Approaches to Customary International Law: a Reconciliation*, in Henry J. Steiner, International Human Rights in Context, 3rd ed, 2007.

8. Bert B. Lockwood, *Working Paper for the Committee of Experts on Limitation Provisions,* 25(4) Human Rights Quarterly, 2003.
9. Bruno Simma, *does the UN charter provide an adequate legal basis for individual or collective responses to violations of obbilgationsergaomnes?* in Jost Delbruck, the future of international law enforcement, New scenarios-new law? 1993.
10. Carlos Manuel Vazquez, *the four doctrines of self-executing treaties*, 89 the American Journal of International Law (1995).
11. Christine Van den wyngaert, *war crimes, genocide and crimes against humanity-Are States taking national prosecutions seriously?* in Cherif Bassiouni ed., Internationl Criminal Law and Procedure, 1999.
12. Christopher L. Blakesley, *the Law of International Extradition: A Comparative Study*, 62 International Review of Penal Law, 1991.
13. Michael Akehurst, *the Hierarchy of the Sources of International Law*, BYIL, 1976.
14. Claire M. Germain, *Approaches to Statutory Interpretation and Legislative History in France*, 13 Duke Journal of Comparative and International Law, 2003.
15. D.W. Bowett, *Estoppel before International Tribunals and Its Relation to Acquiescence*, 33 the British Yearbook of International Law, 1957.
16. Dapo Akande*, international organization*, in Malcolm D. Evans, International Law, 2ed., 2006.
17. Gerhard Werle, *Individual Criminal Responsibility in Article 25 ICC Statute*, 54 Journal of International Criminal Justice, 2007.
18. H.Bittlinger, *Private Space Activities: Questions of International Responsibility*, 30 Proceeding of American Society of IL, 1987.
19. Halim Morris, *Self-Determination: An Affirmative Right or Mere Rhetoric*? 4 ILSA j. Int'l & Comp. L., 1997.
20. HannesVallikivi, *Domestic Applicability of Customary International Law in Estonia*, 7 Juridica International, 2002.
21. Hans Wehberg, *Pacta Sunt Servanda*, 53 American Journal of International Law, 1959.
22. Harold HongjuKoh, *why do nations obey international law?* 106 Yale Law Journal, 1997.

23. David A. Colson, *How persistent must the persistent objector be?* 61 Wash. L. Rev. 1980.
24. Ted L. Stein, *the Approach of the Different Drummer: the Principle of Persistent Objector in International Law*, 26(2) Harv. Int'l. L. J. 1985
25. Jonathan I. Charney, *the Persistent Objector Rule and the Development of Customary International Law*, BYIL, 1986.
26. Daniel O'Donnell, *Commentary by the Rapporteur on Derogation*, 7(1) Human Rights Quarterly, 1985.
27. I.C. MaccGibbon, *the Scope of Acquiescence in International Law*, 31 British Yearbook of International Law, 1954.
28. Ibrahim F.I. Shihata, *the Treaty as a Law-Declarating and Custom-Making Instrument*, 22 Revue Egyptian de droit international, 1966.
29. J.S. Watson, *the limited utility of International Law in the Protection of Human Rights*, 74 Proceedings of the American Society of International Law,1980.
30. Jean Allain, *the Jus Cogens Nature of non-refoulement*, 13 (4) IJRL, 2002.
31. Jerzy Rajski, *the New Polish Private International Law*, 15 International and Comparative Law Quarterly, 1965.
32. Joan F. Hartman, *Working Paper for the Committee of Experts on the Article 4 Derogation Provision*, 7 Human Rights Quarterly, 1985.
33. Johannes Morsink, *world war two and the Universal Declaration*, 15 Human Rights Quarterly, 1993.
34. John C. Yoo, *treaties and public lawmaking: a textual and structural defense of non-self-execution*, 99 the Columbia Law Review (1999).
35. John Dugard and Christine Van den Wyngaert, *Reconciling Extradition with Human Rights*, 92 the American Journal of International Law, 1998.
36. John H. Jackson, *Status of treaties in domestic legal systems: a policy analysis,* 86 the American Journal of International Law, 1992.

37. John Quigley, *the Rule of non-inquiry and human rights treaties*, 45 Catholic University Law Review, 1996.
38. Jordan J. Paust, *self-executing treaties*, 82 the American Journal of International Law, 1988.
39. Jorg Menzel, *Cambodia from Civil War to a Constituiton to Constitutionalism?* in Constitutionalism in Southeast Asia, Clauspeter Hill and Jorg Menzel (ed.), 2008.
40. Josef L. Kunz, *the Meaning and the Range of the Norm Pacta Sunt Servanda*, 39 (2) Amreican Journal of International Law, 1945.
41. Kristen B. Rosati, *the United Nations Convention against Torture: A self-executing treaty that prevents the removal of persons ineligible for asylum and withholding of removal*, 26 Denva Journal of International Law and Policy, 2003.
42. Kristin NadasdyWuerffel, *Note: Discriminating Among Rights? A Nation's Legislating a Hierarchy of Human Rights in the Context of International Human Rights Customary Law*, 33 Valparaiso University Law Review, 1998.
43. Lee M. Caplan, *State Immunity, Human rights, abd jus cogens: a critique of the normative hierarchy theory*, 97 American Journal of International law, 2003.
44. Lori Fisler Damrosch, *the Role of US Senate concerning self-executing and non-self-executing treaties*, 67 Chicago-Kent Law Review, 1991.
45. Luke Marsh and Michael Ramsden, *Joint Criminal Enterprise: Cambodia's Reply to Tadic*, 11 international criminal law review, 2011.
46. Mark Gibney, *Transnational State Responsibility for violations of human rights*, 12 Harvard Human Rights Journal, 1999.
47. Marko Divac Oberg, *the Legal Effects of Resolutions of the UN Security and General Assembly in Jurisprudence of the ICJ*, 16(5) EJIL, 2005.
48. Matthias WENTZEL, *Extradition Involving the Possibility of Death Penalty*, 62 International Review of Penal Law, 1991.
49. MEAS Bora, Customary International Law, Working Paper I ( in Khmer), 2012.

50. Meas Bora, *Extradition: International and Cambodian Law*, in Hor Peng, Kong Phallack and Jorg Menzel, Eds., Introduction to Cambodian Law, 2012.
51. MicaelaErulli, *are crimes against humanity more serious than war crimes?* 12 EJIL, 2012.
52. Michael D. WIMS, *Dual or Double Criminality, Re-Examining the Traditional Exception to Extradition*, 62 International Review of Penal Law, 1991.
53. Naomi Roht-Arriaza, *the Multiple Prosecution of Augusto Pinochet*, in Ellen L. Lutz & Caitlin Reiger, Prosecuting Heads of State, 2009.
54. Peter R. Baehr, *Concern for Development Aid and Fundamental Human Rights: the Dilemma as Faced by the Netherlands*, 4(1) Human Rights Quarterly, 1982.
55. Philip Alston, *the Universal Declaration at 35: Western and Passe or Alive and Universal*, 31 the Review of International Commission of Jurists, 1983.
56. Pierre-Marie Dupuy, *reviewing the difficulties of codification: On ago's classification of obligations of means and Obligations of Result in relation to State Responsibility*, 10 EJIL,1999.
57. R.R. Baxter, multilateral *Treaties as Evidence of Customary International Law*, 41 British Yearbook of International Law, 1965-66.
58. Rebecca J. Cook, *State responsibility for violations of Women's Rights*, 17 Harvard Human Rights Journal, 1994.
59. Sean Morrison, *Extraordinary Chambers in the Courts of Cambodia: Interpreting the Limiting Language and Personal Jurisdiction of the Cambodian Tribunal*, 37 the Capital University Law Review, 2009.
60. Sir ElihuLauterpacht and Daniel Bethlehem, *the Scope and Content of the Principle of Non-Refoulement*, in Refugee Protection in International Law: UNHCR's Global Consultations on International Protection (Erika Feller, Volker Turk and Frances Nicholson, ed. 2003).
61. Susanne Zuhlke and Jens Chrisntian Pastille, *Extradition and the European Convention, Soering Revisited*, 59 ZaoRV, 1999.

62. Terayakoji, *emerging hierarchy in international human rights and beyond: from the perspective of non-derogable rights*, 12 (5) European Journal of International Law, 2001.
63. Nada Al-Duaij, *the Volunteer Human Shields in International Humanitarian Law*, 12 Oregon Review of International Law, 138, 2010.

**IV. OTHERS**

1. Commission Communication to the Council and Parliament, Democratization, the rule of law, respect for human rights and good governance: the challenges of the partnership between the European Union and the ACP States, COM (98) 146, 1998.
2. Conclusions of the work of the Study Group on the Fragmentation of International Law: Difficulties arising from the Diversiifcation and Expansion of International Law , Yearbook of the International Law Commission, 2006, vol. II, Part II.
3. Human Rights Watch, Fighting Terrorism Fairly and Effectively, Recommendations for President-Elect Barack Obama, November 2008.
4. International Commission of Jurists, Courts and the Legal Enforcement of Economic, Social and Cultural Rights, Comparative Experiences of Justiciability, Human Rights and Rule of Law Series: No.2, 2008.
5. International Commission of Jurists, Legal Commentary to the ICJ Berlin Declaration, counter-terrorism, human rights and the rule of law, Human Rights and Rule of Law Series: No. 1, 2008.
6. International Commission of Jurists, Legal Commentary to the ICJ Geneva Declaration, upholding the rule of law and the role of judges and lawyers in times of crisis, Human Rights and Rule of Law Series: No. 3, 2009.
7. Reservations to Treaties, Text and Title of the draft guidelines provisionally adopted by the Drafting Committee on 5,6,18,19, 27, 28 and 29 May 2009, A/CN.4/L.744.